### សៀវភៅណែនាំសិក្សា

# ក្រមរដ្ឋប្បវេណី

(បោះពុម្ពលើកទី ៦)

Introduction to the Civil Code of Japan, 6th edition

និពន្ធដោយ អ៊ីកិដា ម៉ាសាអូ

ប្រែសម្រួលដោយ ឈឿន គុយអេង

សមាគមអ្នកច្បាប់ជប៉ុនជាមួយកម្ពុជា

សាកលវិទ្យាល័យជាតិគ្រប់គ្រង

# 第６版クメール語版の出版によせて

時代は変わる。けれどもその中で、我々は、人々がより幸福な社会生活を送れる仕組みを工夫する、絶え間ない努力を続けて行かなければならないのである。

1997 年に日本で初版を出版した原著『民法への招待』は、幸い日本民法の入門書として多数の読者の支持を得て版を重ね、23 年目の 2020 年 11 月に、第 6 版を発行することになった。

このクメール語翻訳版の制作は、原著第 6 版の「はしがき」にもあるように、『日本カンボジア法律家の会』（JJL,共同代表=桜木和代弁護士・木村晋介弁護士）のご尽力によって実現したものである。2000 年 12 月から、順次翻訳されて王立法律経済大学や司法省、弁護士会、裁判官養成所に寄贈され、ついに 2008 年には本書 3 訂版補訂の完全訳が完成して寄贈されたのである。

幸いその翻訳書は、yellow book と呼ばれて多方面で活用されたと聞く。今日のカンボジア王国は、既に立派な民法典を持つ国となっているが、当時の貴国の復興にこの翻訳書が少しでも役に立ったのであれば、大変幸いである。

そして、その後の原著の改訂に対応させるべく、本書第 5 版（2018 年出版）についての翻訳作業が、当時カンボジアに派遣されていた JICA の法律専門家であった篠田陽一郎弁護士のご支援もあって開始され、この度、チュン・クイエンさん（王立法経大学（RULE）かつ名古屋大学日本法センター（CJL）の卒業者で名古屋大学大学院法学研究科修士課程修了）という素晴らしい翻訳者の手で、最新版の第 6 版（2020 年）の翻訳が完成した次第である。

日本では、2020 年 4 月に、民法の債権や契約の分野の約 120 年ぶりの大改正が施行され、さらに相続の分野でも同時期にいくつかの重要な改正があった。この第 6 版では、それらの改正がすべて盛り込まれている。したがって、大変幸いなことに、この第 6 版クメール版は、文字通り、最新の日本民法典の紹介書となっているのである。

私は、2000 年 12 月末に最初の部分的な翻訳書の贈呈式と記念講演のためにカンボジアを訪れた時のことを、そしてその後翻訳が進むたびに何度も繰り返して訪問し、講義をした日々のことを、今でも鮮明に覚えている。訪れるたびに急速な復興を目にすることは、私の大きな喜びだった。

そしてあれからちょうど 20 年が経過した。新しいカンボジア民法典の完成には、多くの日本人学者も協力した。カンボジア民法典は、も

ちろん日本民法典と異なるところも、日本民法典よりも先進的と思えるところもあるが、本書は、カンボジア民法典の理解にも役立つ書であると信じる。

最も大事なことは、民法は、それぞれの国で、それぞれの国民のために、より平和で幸福な生活を享受するためのルールを作るものだということである。本書が、アジアの「友人」としての日本とカンボジアの相互理解につながることも期待しつつ、何よりも「民法」という、市民の基本法典の共通の「考え方」を学べる書となることを願っている。

最後に、訳者チュン・クイエンさんに心からの御礼を申し上げます。また、第6版クメール語版の完成に尽力してくださった、JJLの桜木和代弁護士、木村晋介弁護士、元JICAの篠田陽一郎弁護士にも、またクイエンさんを支援してくださったご家族や友人の方々にも、感謝の意を表します。

東京にて 2021年2月

池田真朗
Masao IKEDA
慶應義塾大学名誉教授　Professor emeritus at Keio University
武蔵野大学大学院法学研究科長（前副学長）Dean,Graduate School of Law(Ex-Vice President) at Musashino University

## អារម្ភកថា

## នៅក្នុងការបោះពុម្ពលើកទី6 ជាភាសាខ្មែរ

សម័យកាលគឺផ្លាស់ប្តូរជានិច្ច។ ប៉ុន្តែនៅក្នុងនោះ យើងគ្រប់គ្នានៅតែត្រូវបន្តប្រឹងប្រែងកែលំអរបៀបនៃការរស់នៅរបស់មនុស្សគ្រប់រូបឲ្យកាន់តែមានសុភមង្គលជាងមុន។

«សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» ត្រូវបានបោះពុម្ពជាលើកដំបូងនៅប្រទេសជប៉ុនក្នុងឆ្នាំ1997 និងទទួលបានការគាំទ្រច្រើនពីអ្នកអានជាបន្តបន្ទាប់ក្នុងនាមជាសៀវភៅសេចក្តីផ្តើមនៃក្រមរដ្ឋប្បវេណី ហើយឈានដល់ការបោះពុម្ពលើកទី6 គម្រប់ខួប 23ឆ្នាំ នាខែវិច្ឆិកា ឆ្នាំ2020។

ដូចបានជម្រាបជូននៅក្នុង «ការបោះពុម្ពលើកទី6 បុព្វកថា» រួចហើយថា ការរៀបចំបកប្រែជាភាសាខ្មែរនេះអាចលេចជារូបរាងបានដោយសារការជ្រោមជ្រែងពី «សមាគមអ្នកច្បាប់ជប៉ុនកម្ពុជា» (JJL, សហតំណាងដោយ៖ លោកស្រីមេធាវី SAKURAGI KAZUYO និង លោកមេធាវី KIMURA SHINSUKE)។ ចាប់តាំងពីខែធ្នូ ឆ្នាំ2000 មកសៀវភៅនេះត្រូវបានបកប្រែជាបន្តបន្ទាប់ ហើយត្រូវបានយកទៅប្រគល់ជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រសួងយុត្តិធម៌ គណៈមេធាវី និង សាលាភូមិន្ទចៅក្រម។ នៅឆ្នាំ2008 ការបោះពុម្ពលើកទី3 នៃសៀវភៅនេះ ត្រូវបានបកប្រែចប់ជាស្ថាពរ ហើយត្រូវបានប្រគល់ជូនស្ថាប័នពាក់ព័ន្ធខាងលើនេះផងដែរ។

ខ្ញុំលឺថា សៀវភៅបកប្រែនេះត្រូវបានគេហៅថាជា សៀវភៅលឿង ហើយត្រូវបានប្រើប្រាស់ក្នុងបរិបទជាច្រើន។ ក្នុងពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសមួយដែលមានក្រមរដ្ឋប្បវេណីយ៉ាងទំនើបរួចហើយ ប៉ុន្តែ នាសម័យនោះ ខ្ញុំសង្ឃឹមថា សៀវភៅនេះ បានចូលរួមចំណែកទោះបីជាតិចតួចក៏ដោយ ដល់ការ ស្តារប្រទេសកម្ពុជាឡើងវិញ។

ក្រោយមកទៀត ដោយសារមានភាពចាំបាច់ក្នុងការធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លើយតបជាមួយនឹងការកែសម្រួលច្បាប់ដើម ការបោះពុម្ពលើកទី 5 (ឆ្នាំ2018) របស់សៀវភៅនេះ ត្រូវបានចាប់ផ្តើមបកប្រែឡើងវិញ ដោយមានការជួយជ្រោមជ្រែងពីលោកមេធាវី SHINODA YOICHIRO ជំនាញការនៃអង្គការចៃកា (JICA) ដែលបានបំពេញបេសកម្មនៅកម្ពុជាក្នុងពេលនោះ ។ ការបកប្រែថ្មីបំផុត នៃការបោះពុម្ពលើកទី6 (ឆ្នាំ2020) បានបកប្រែបញ្ចប់ស្ថាពរ ដោយអ្នកបកប្រែដ៏ជំនាញ គឺលោកឈឿន គុយអេង (បញ្ចប់ថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច និងមជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំច្បាប់ជប៉ុន (CJL), ហើយបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់នៅសាលកលវិទ្យាល័យណាហ្គោយ៉ាប្រទេសជប៉ុន)។

នៅខែមេសា ឆ្នាំ2020 ប្រទេសជប៉ុនបានធ្វើវិសោធនកម្មទ្រង់ទ្រាយធំជាលើកដំបូងក្នុងរយៈពេល 120ឆ្នាំនេះ ទៅលើផ្នែកស្តីពីសិទ្ធិលើបំណុល និង កិច្ចសន្យានៅក្នុងក្រមរដ្ឋប្បវេណី ហើយក្នុងពេលទន្ទឹមគ្នានេះ ផ្នែកស្តីពី

សន្តតិកម្មក៏មានការធ្វើវិសោធនកម្មនូវចំណុចសំខាន់ៗមួយចំនួនផងដែរ។ ការបោះពុម្ពលើកទី6 នេះ បានបញ្ចូលនូវវិសោធនកម្មទាំងអស់នេះ។ ដូចនេះ ការបោះពុម្ពលើកទី6 ជាភាសាខ្មែរនេះ គឺជាសៀវភៅដែលបង្ហាញអំពីក្រមរដ្ឋប្បវេណីថ្មីបំផុតរបស់ជប៉ុន ដូចមានក្នុងចំណងជើងស្រាប់។

ខ្ញុំនៅចងចាំយ៉ាងច្បាស់ នៅពេលដែលខ្ញុំបានមកប្រទេសកម្ពុជានៅចុងខែធ្នូ ឆ្នាំ2000 ដើម្បីចូលរួមពិធីដាក់បង្ហាញសៀវភៅបកប្រែនៃផ្នែកខ្លះៗជាលើកដំបូង និង បានធ្វើបទបង្ហាញជាអនុស្សាវរីយ៍ ហើយក្រោយមកទៀត ខ្ញុំនៅតែបន្តទៅធ្វើបទបង្ហាញនៅកម្ពុជាជាច្រើនលើកច្រើនសារ ស្របជាមួយនឹងដំណើរការនៃការបកប្រែ។ ខ្ញុំរីករាយយ៉ាងខ្លាំង ដោយមើលឃើញនូវការរីកចម្រើនរបស់កម្ពុជា នៅរាល់ពេលដែលខ្ញុំបានទៅ។

គិតចាប់តាំងពីពេលនោះមក រយៈពេល 20ឆ្នាំគត់ បានកន្លងផុតហើយ។ ការតាក់តែងក្រមរដ្ឋប្បវេណីថ្មីរបស់កម្ពុជានេះ ក៏មានការចូលរួមសហការពីអ្នកស្រាវជ្រាវច្បាប់ជប៉ុនជាច្រើនផងដែរ។ ពិតហើយថា ក្រមរដ្ឋប្បវេណីរបស់កម្ពុជាគឺខុសពីក្រមរដ្ឋប្បវេណីជប៉ុន ហើយមានផ្នែកខ្លះគឺក្រមរដ្ឋប្បវេណីកម្ពុជាមានលក្ខណៈទំនើបជាងក្រមរដ្ឋប្បវេណីជប៉ុនទៅទៀត ប៉ុន្តែ ខ្ញុំជឿជាក់ថា សៀវភៅនេះនឹងមានអត្ថប្រយោជន៍ដើម្បីស្វែងយល់ក្រមរដ្ឋប្បវេណីកម្ពុជាផងដែរ។

រឿងដែលសំខាន់បំផុតគឺ ក្រមរដ្ឋប្បវេណីគឺបង្កើតនូវវិធានដើម្បីឲ្យប្រទេសនីមួយៗ និងប្រជាជនគ្រប់រូបនៃបណ្តាប្រទេសទាំងនោះ កាន់តែរស់នៅដោយមានសុភមង្គល និងដោយមានសន្តិភាព។ ខ្ញុំរំពឹងថាសៀវភៅនេះ នឹងក្លាយជាស្ពាននាំឲ្យប្រទេសជប៉ុន និង ប្រទេសកម្ពុជាយល់ដឹងអំពីគ្នាទៅវិញទៅមកក្នុងនាមជា «មិត្ត» ក្នុងតំបន់អាស៊ី ហើយខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងក្លាយជាអត្ថបទដែលអាចសិក្សាអំពី «គោលគំនិត» រួមនៃច្បាប់មូលដ្ឋានរបស់ប្រជាជនបាន ពោលគឺ «ក្រមរដ្ឋប្បវេណី»។

ជាចុងក្រោយ ខ្ញុំសូមអរគុណចេញពីចិត្តដល់អ្នកបកប្រែ គឺលោក ឈឿន គុយអេង។ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះលោកស្រីមេធាវី SAKURAGI KAZUYO និង លោកមេធាវី KIMURA SHINSUKE នៃសមាគម JJL, លោកមេធាវី SHINODA YOICHIRO អតីតជំនាញការនៃអង្គការចៃកា ព្រមទាំងក្រុមគ្រួសារ និង មិត្តភក្តិរបស់លោកឈឿន គុយអេង ដែលបានខិតខំប្រឹងប្រែងរៀបចំតាក់តែងការបោះពុម្ពលើកទី6 ជាភាសាខ្មែរនេះ។

ទីក្រុងតូក្យូ ខែ កុម្ភៈ ឆ្នាំ 2021

Masao IKEDA

Professor emeritus at Keio University

Dean, Graduate School of Law ( Ex-Vice President ) at Musashino University.

# 第６版クメール語版の出版にあたって

日本カンボジア法律家の会（Japan Jurist league with Cambodia ）
共同代表
弁護士　桜木和代
弁護士　木村晋介

日本カンボジア法律家の会は、カンボジアの復興に法律面から協力しようと、1993 年 10 月に設立された NGO です。1993 年から活動をはじめ、今年で 28 年が経過しました。活動には幾つかのプロジェクトがありますが、その 1 つが、“クメール語の法律教材の提供”です。古くは刑事事件の模擬裁判のクメール語によるビデオの提供、日本人刑法学者の『刑法入門』のクメール語版の提供等がありました。2000 年から日本の民法学者池田真朗教授の『民法への招待』のクメール語化事業が始まりました。池田先生の『民法への招待』は、日本民法を素材とし、法律学を専攻していない人にもわかりやすく著されていますが、民法という大部な法律を理解し、民法の本質をつかむには最適な体系書であり、私たちは是非これをクメール語にしてカンボジアの皆さんに提供したいと考えたのです。

この『民法への招待』第 3 版のクメール語への翻訳は、クオン･テイリー先生にお願いしました。当時カンボジアには民法典はなく、法律に関する資料もない中で、テイリー先生から、フランス植民地時代の 1920 年に制定されたカンボジア民法を参考資料とするしかなかった、とお聞きしました。大変なご苦労をおかけしたと思います。

最初のクメール語化から 20 年が経過し、この間カンボジアでは日本の起草支援を受けながら、新しい民法が制定されました。そこで新しいカンボジア民法の用語に沿った『民法への招待』の翻訳が望まれるところとなり、私たちは、『民法への招待』第 5 版のクメール語化事業に取りかかりました。

翻訳はチュン・クイエンさんにお願いしました。クイエンさんは、王立法経大学及び名古屋大学日本法センター（CJL）卒業後、名古屋大学大学院法学研究科修士課程で債権法を学ばれ、その後カンボジアに戻り、Japan International Cooperation Agency（JICA）のシニアリーガルオフィサーとして、日本語・クメール語の法律文書の翻訳や、セミナーでの通訳等に携わってこられました。カンボジア民法と日本民法そして両国の法律用語に精通しクイエンさんこそまさに『民法への招待』の翻訳の適任者と考え、クイエンさんに依頼したところ、快く引き受けて下さったのです。

折しも日本では、2020 年に、日本民法の債権や契約の分野等の大改正があり、池田先生は、これら重要な改正に合わせ、『民法への招待』第 6 版を出版されました。そこで私たちはクイエンさんに第 6 版を原本として翻訳することを更にお願いし、クイエンさんもこれに応えてくれました。このような経緯を経て、『民法への招待』第 6 版のクメール語版が誕生しました。

この度の『民法への招待』クメール語化事業は、法律に関連するカンボジアの各界の皆さまからの要望があったことが、事業開始の動機となっています。カンボジア民法典が、日本民法典と異なるところがあっても、旧版クメール語版『民法への招待』が、カンボジ

アの地で、皆さまのお役に立っていることを実感しました。新しいカンボジア民法に沿った、『民法への招待』第 6 版クメール語版は、さらに皆さまのお役に立てるものと確信しています。

翻訳者のチュン・クイエンさんには、本当にお世話になりました。心からの御礼を申し上げます。またクイエンさんを支援してくださったご家族にも、感謝の意を表します。

また、本事業に当たり、国立経営大学にはハオペン学長をはじめとする「『民法への招待』クメール語化編集委員会」が設置され、同委員会のご協力を頂きました。日本側とカンボジア側双方の協力によって、『民法への招待』第 6 版が誕生したことは、とても嬉しいことであり、今後双方の協力関係の発展に、新たな期待を寄せるところです。

2021 年 4 月 1 日

# អារម្ភកថា
# នៅក្នុងការបោះពុម្ពលើកទី6 ជាភាសាខ្មែរ

**សមាគមអ្នកច្បាប់កម្ពុជាជប៉ុន**

( Japan Jurist league with Cambodia )

**សហតំណាងដោយ៖**

លោកស្រីមេធាវី SAKURAGI KAZUYO

លោកមេធាវី KIMURA SHINSUKE

សមាគមអ្នកច្បាប់កម្ពុជាជប៉ុន គឺជា NGO ដែលត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ1993 ដើម្បីផ្តល់ការសហការផ្នែកច្បាប់ដើម្បីស្តារប្រទេសកម្ពុជាឡើងវិញ។ សមគមនេះចាប់ផ្តើមសកម្មភាពនៅឆ្នាំ1993 ហើយគិតមកដល់ឆ្នាំនេះគឺមានរយៈពេលជាង 28ឆ្នាំហើយ។ នៅក្នុងសកម្មភាពរបស់សមាគម មានគម្រោងជាច្រើនហើយមួយក្នុងចំណោមសកម្មភាពនោះ គឺ «ការផ្តល់ឯកសារសិក្សាច្បាប់ជាភាសាខ្មែរ»។ តាំងពីមុនមកសមាគមបានផ្តល់នូវវីដេអូជាភាសាខ្មែរអំពីតុលាការប្រឌិតនៃរឿងក្តីព្រហ្មទណ្ឌ និងបានផ្តល់ «សៀវភៅសេចក្តីផ្តើមនៃក្រមព្រហ្មទណ្ឌ» របស់អ្នកច្បាប់ជប៉ុនជំនាញក្រមព្រហ្មទណ្ឌជាភាសាខ្មែរ ជាអាទិ៍។ តាំងពីឆ្នាំ2000 ការងារបកប្រែជាភាសាខ្មែរនូវ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» របស់លោកសាស្ត្រាចារ្យ Masao IKEDA អ្នកស្រាវជ្រាវក្រមរដ្ឋប្បវេណីជប៉ុន បានចាប់ផ្តើម។ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» របស់លោកសាស្ត្រាចារ្យ IKEDA បានតាក់តែងដោយផ្អែកលើក្រមរដ្ឋប្បវេណីជប៉ុន ហើយមានភាពងាយស្រួលយល់សម្រាប់អ្នកដែលមិនសិក្សាជំនាញនីតិសាស្ត្រផងដែរ។ សៀវភៅនេះគឺសាកសមបំផុតសម្រាប់ស្វែងយល់នូវក្រមរដ្ឋប្បវេណីដែលជាច្បាប់យ៉ាងធំ និង ងាយចាប់បាននូវគោលការណ៍សំខាន់ៗនៃក្រមរដ្ឋប្បវេណី ហើយយើងខ្ញុំពិតជាចង់បកប្រែជាភាសាខ្មែរ ហើយជូនជនជាតិកម្ពុជាទាំងអស់គ្នា។

ការបកប្រែជាភាសាខ្មែរនូវការបោះពុម្ពលើកទី3 នៃ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» នេះសមាគមបានពឹងពាក់ទៅកាន់លោកសាស្ត្រាចារ្យ គង់ ទេលី។ យើងបានលឺមកថា នៅពេលនោះប្រទេសកម្ពុជាពុំទាន់មានក្រមរដ្ឋប្បវេណីនៅឡើយទេ ហើយក៏ពុំសូវមានឯកសារពាក់ព័ន្ធនឹងច្បាប់ផងដែរ ហេតុនេះ លោកសាស្ត្រាចារ្យ ទេលី មានតែក្រមរដ្ឋប្បវេណីដែលបានអនុម័តនៅក្នុងឆ្នាំ1920 ក្នុងសម័យអាណានិគមបារាំងប៉ុណ្ណោះជាឯកសារយោង។ លោកសាស្ត្រាចារ្យពិតជួបការលំបាកច្រើនហើយក្នុងការបកប្រែនេះ។

រយៈពេល 20ឆ្នាំ បានកន្លងផុតហើយ គិតចាប់តាំងពីការបកប្រែជាភាសាខ្មែរលើកដំបូង ហើយក្នុងអំឡុងពេល 20ឆ្នាំនោះ ប្រទេសកម្ពុជាបានទទួលជំនួយក្នុងការតាក់តែងច្បាប់ពីប្រទេសជប៉ុន ហើយក្រមរដ្ឋប្បវេណីថ្មីត្រូវបានអនុម័តឡើង។ ដូចនេះ យើងខ្ញុំមានបំណងបកប្រែ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី»

ឲ្យស្របទៅតាមពាក្យបច្ចេកទេសនៅក្នុងក្រមរដ្ឋប្បវេណីថ្មីរបស់កម្ពុជា ហើយក៏បានចាប់ផ្តើមការងារបកប្រែការបោះពុម្ពលើកទី5 នៃ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» នេះ។

អ្នកបកប្រែគឺ លោក ឈឿន គុយអេង។ ក្រោយពីបញ្ចប់ថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច និងមជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំច្បាប់ជប៉ុន លោក គុយអេង បន្តការសិក្សាថ្នាក់អនុបណ្ឌិតលើនីតិសិទ្ធិលើបំណុល នៅសាកលវិទ្យាល័យណាហ្គោយ៉ាប្រទេសជប៉ុន។ ក្រោយពីត្រឡប់មកកម្ពុជាវិញ លោក គុយអេង បានធ្វើការងារពាក់ព័ន្ធនឹងការបកប្រែឯកសារច្បាប់ជាភាសាជប៉ុន・ខ្មែរ និងបកប្រែដោយផ្ទាល់នៅក្នុងសិក្ខាសាលាជាអាទិ៍ នៅក្នុងគម្រោងអភិវឌ្ឍន៍ច្បាប់ និងតុលាការនៃអង្គការ JICA ក្នុងឋានៈជា មន្ត្រីច្បាប់ជាន់ខ្ពស់។ លោក គុយអេង មានចំណេះដឹងលើក្រមរដ្ឋប្បវេណីកម្ពុជា និងក្រមរដ្ឋប្បវេណីជប៉ុន និងមានជំនាញក្នុងការបកប្រែពាក្យបច្ចេកទេសច្បាប់នៃប្រទេសទាំងពីរ ហេតុនេះ យើងខ្ញុំគិតថា លោក គុយអេង ជាបុគ្គលសាកសមបំផុតក្នុងការបកប្រែ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» នេះ ហើយលោក គុយអេង ពេញចិត្តនឹងទទួលយកការងារនេះ តាមសំណូមពររបស់យើងខ្ញុំ។

នៅក្នុងឆ្នាំ2020 ប្រទេសជប៉ុនមានវិសោធនកម្មទ្រង់ទ្រាយធំលើផ្នែកស្តីពីសិទ្ធិលើបំណុល និង កិច្ចសន្យាក្នុងក្រមរដ្ឋប្បវេណីជប៉ុន ហើយលោកសាស្ត្រាចារ្យ IKEDA បានចេញផ្សាយការបោះពុម្ពលើកទី6 នៃ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» ដោយបញ្ចូលនូវខ្លឹមសារវិសោធនកម្មដ៏សំខាន់ខាងលើនេះ។ ហេតុនេះ យើងខ្ញុំបានស្នើសុំបន្ថែមឲ្យលោក គុយអេង បកប្រែចេញពីច្បាប់ដើមនៃការបោះពុម្ពលើកទី6 នេះ ហើយលោក គុយអេង បានយល់ព្រមចំពោះការស្នើសុំបន្ថែមនេះ។ ការបកប្រែជាភាសាខ្មែរ នៃការបោះពុម្ពលើកទី6 នៃ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» បានប្រសូត្រឡើង ដោយមានសារតាបែបនេះ។

ការងារបកប្រែ «សៀវភៅណែនាំឲ្យសិក្សាក្រមរដ្ឋប្បវេណី» នេះ បានចាប់ផ្តើមឡើងតាមសំណូមពរពីមជ្ឈដ្ឋាននានារបស់អ្នកច្បាប់កម្ពុជា។ ទោះបីជាក្រមរដ្ឋប្បវេណីខ្មែរ មានខ្លឹមសារខុសពីក្រមរដ្ឋប្បវេណីជប៉ុនក៏ដោយ ក៏យើងខ្ញុំបានដឹងថា អត្ថបទចាស់នៃការបកប្រែជាភាសាខ្មែរនៃ «សៀវភៅណែនាំឲ្យសិក្សាក្រមរដ្ឋប្បវេណី» បានផ្តល់ប្រយោជន៍ដល់អ្នកទាំងអស់គ្នានៅកម្ពុជា។ យើងខ្ញុំជឿជាក់យ៉ាងមុតមាំថា ការបកប្រែជាភាសាខ្មែរនៃការបោះពុម្ពលើកទី6 នៃ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» ស្របតាមក្រមរដ្ឋប្បវេណីថ្មីរបស់កម្ពុជានេះ នឹងកាន់តែផ្តល់ប្រយោជន៍ដល់អ្នកទាំងអស់គ្នា។

យើងខ្ញុំសូមអរគុណចេញពីចិត្តដល់អ្នកបកប្រែ លោក ឈឿន គុយអេង ដែលបានជួយជាអ្នកបកប្រែ។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះក្រុមគ្រួសាររបស់លោក គុយអេង ដែលជួយគាំទ្រនូវការងារនេះ។

មួយវិញទៀត សាកលវិទ្យាល័យជាតិគ្រប់គ្រងដោយមានឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ ហោ ប៉េង ជាប្រធាន បានរៀបចំបង្កើតនូវ «គណកម្មការកែសម្រួលការបកប្រែជាភាសាខ្មែរនៃ "សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី" » ដើម្បីសហការដល់ការងារបកប្រែនេះ។ យើងខ្ញុំមានទឹកចិត្តសោមនស្សរីករាយដែល

ការបោះពុម្ពលើកទី6 នៃ «សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី» នេះ បានប្រសូត្រឡើងដោយមានកិច្ចសហការរវាងភាគីកម្ពុជា និង ភាគីជប៉ុនហើយយើងខ្ញុំមានការរំពឹងទុកខ្ពស់ ចំពោះវឌ្ឍនភាពនៃកិច្ចសហការរួមគ្នារបស់ភាគីទាំងសងខាងនាពេលអនាគត។

ថ្ងៃទី1 ខែមេសា ឆ្នាំ2021

# អារម្ភកថា

សៀវភៅនេះ ត្រូវបានបកប្រែជាភាសាខ្មែរពីសៀវភៅដើមជាភាសាជប៉ុន ដែលត្រូវបានសរសេរឡើងសម្រាប់ជាការណែនាំអំពីការសិក្សានូវចំណុចសំខាន់ៗនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន។ កាលពីឆ្នាំ២០០៨ សៀវភៅនេះ ត្រូវបានបកប្រែនិងកែសម្រួលជាភាសាខ្មែរម្តងរួចទៅហើយ និងត្រូវបានប្រើប្រាស់ក្នុងបរិបទជាច្រើន។ និស្សិតខ្មែរដែលសិក្សាជំនាញច្បាប់ភាគច្រើនបានអានសៀវភៅនេះ ដើម្បីសិក្សាបន្ថែមពីក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ហើយពួកគេនិយមហៅសៀវភៅនេះថា សៀវភៅលឿង។

ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រាជរដ្ឋាភិបាលបាន និងកំពុងធ្វើកំណែទម្រង់ច្បាប់ជាច្រើនដើម្បីសម្របខ្លួនទៅក្នុងឆាកអន្តរជាតិ។ ជាសមិទ្ធផល ក្នុងពេលបច្ចុប្បន្នប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយដែលមានក្រមរដ្ឋប្បវេណីទំនើប។ ទោះបីជាយ៉ាងនេះក៏ដោយ ការស្វែងយល់ពីចំណុចសំខាន់ៗនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន នៅតែមានសារៈសំខាន់សម្រាប់អ្នកច្បាប់ខ្មែរ ពីព្រោះក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន អាចត្រូវបានចាត់ទុកជាគំរូច្បាប់នៃក្រមរដ្ឋប្បវេណីរបស់កម្ពុជា។

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយណាស់ នៅពេលដែលដឹងថា «សមាគមអ្នកច្បាប់ជប៉ុនជាមួយកម្ពុជា» ( សហតំណាងដោយៈ លោកស្រីមេធាវី SAKURAGI KAZUYO និង លោកមេធាវី KIMURA SHINSUKE ) បាននិងកំពុងរៀបចំដំណើរការបោះពុម្ពសៀវភៅនេះ ជាលើកទី៦ ជាភាសាខ្មែរ ដោយបានបញ្ចូលនូវចំណុចសំខាន់ៗនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ដែលត្រូវបានធ្វើវិសោធនកម្ម នៅខែមេសា ឆ្នាំ២០២០។

ខ្ញុំសង្ឃឹមថា ប្រជាពលរដ្ឋខ្មែរ ជាពិសេសក្មួយៗនិស្សិតច្បាប់នឹងទទួលបានការយល់ដឹងកាន់តែច្រើនពីវិស័យរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន តាមរយៈការអានសៀវភៅនេះ។

ជាចុងក្រោយ ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណដល់សមាគមអ្នកច្បាប់ជប៉ុនជាមួយកម្ពុជា និងក្រុមការងារបកប្រែដែលបានរៀបចំការបោះពុម្ពលើកទី៦ ជាភាសាខ្មែរ។ ខ្ញុំសូមអរគុណ លោកបណ្ឌិត សេង ប៊ុនធឿន និងលោកស្រី ប៉ុក ភារុន ដែលជាសមាជិកនៃគណៈកម្មការត្រួតពិនិត្យការបកប្រែនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងដំណើរការបោះពុម្ពសៀវភៅនេះ៕

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

បណ្ឌិត ហោ ប៉េង

សាកលវិទ្យាធិការ

សាកលវិទ្យាល័យជាតិគ្រប់គ្រង

**PREFACE**

This book is the Khmer translation of an introductory book on Japanese Civil Code which has given the explanation on the important issues provided in the Civil Code of Japan. In 2008, the introductory book on Japanese Civil Code was once translated into Khmer; the Khmer translation has been used in various contexts. Most of the Cambodian students majoring in law have read the book in order to gain additional knowledge regarding the Civil Code of Japan. The book has been simply called “the yellow book”.

Under the leadership of **Samdech Akka Moha Sena Padei Techo Hun Sen,** the government have been conducting a great deal of legal reform in order to adjust Cambodia on the international stage. In consequence, Cambodia has become the country that owns the modern civil code. However, the knowledge of Civil Code of Japan is still indispensable for Cambodian students majoring in law and officials working in the judicial sectors because the Civil Code of Japan is considered as the model law of the Civil Code of Cambodia.

I am pleased to know that the Japan Jurists League with Cambodia (co-represented by Ms. SAKURAGI KAZUYO and Mr. KIMURA SHINSUKE) has been working on the 6th publication of the Khmer translation. Interestingly, the significant issues in the Civil Code of Japan which was amended in last April 2020 have been incorporated in the 6th publication.

I hope Cambodian people, especially the students majoring in law, will be able to expand their knowledge regarding the Civil Code of Japan after reading this book.

Last but not least, I would like to give my profound thanks to the Japan Jurists League with Cambodia (JJL) and translation team for devotion to the 6th publication. I am also thankful to NUM Technical Commission, namely Dr. SENG Bunthoeun and Ms. POK Phearoun, who have spent their valuable time reviewing the Khmer translation.

Phnom Penh, July 07, 2021

HOR Peng

Rector

National University of Management

សៀវភៅណែនាំសិក្សា

# ក្រមរដ្ឋប្បវេណី

(បោះពុម្ពលើកទី ៦)

Introduction to the Civil Code of Japan, 6th edition

និពន្ធដោយ អ៊ីកិដា ម៉ាសាអូ

ប្រែសម្រួលដោយ ឈឿន គុយអេង

សមាគមអ្នកច្បាប់ជប៉ុនជាមួយកម្ពុជា

សាកលវិទ្យាល័យជាតិគ្រប់គ្រង

## ការបោះពុម្ពលើកទី 6 បុព្វកថា

សៀវភៅនេះត្រូវបានបោះពុម្ពជាលើកដំបូងក្នុងឆ្នាំ1997 និងទទួលបានការគាំទ្រពីអ្នកអានជាច្រើន ហើយត្រូវបានបោះពុម្ពជាបន្តបន្ទាប់ ឈានដល់ការបោះពុម្ពលើកទី6 គម្រប់ខួប 23ឆ្នាំ នៃសៀវភៅនេះ។ នៅក្នុងការបោះពុម្ពលើកទី5 (ខែមេសា ឆ្នាំ2018) ខ្ញុំបានធ្វើការកែសម្រួលទាំងស្រុង ដោយបញ្ចូលនូវការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីដែលផ្តោតទៅលើវិស័យនីតិសិទ្ធិលើបំណុល ហើយដែលបានអនុម័តនៅថ្ងៃទី2 ខែមិថុនា ឆ្នាំ2017 និងដាក់ឱ្យអនុវត្តនៅថ្ងៃទី1 ខែមេសា ឆ្នាំ2020។ ដោយឡែក ក្រោយពេលបោះពុម្ព ចាប់ពីខែមិថុនា ឆ្នាំ2018 ដល់ខែមិថុនា ឆ្នាំ2019 មានការធ្វើវិសោធនកម្មជាបន្តបន្ទាប់លើចំណុចសំខាន់ៗនៃវិស័យនីតិគ្រួសារ (គន្លីស្តីពីញាតិ និង គន្លីស្តីពីសន្តតិកម្ម)។ នៅក្នុងការបោះពុម្ពលើកទី6នេះ ធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការធ្វើវិសោធនកម្មនេះឱ្យបានឆាប់រហ័ស និង រៀបចំជាសៀវភៅសេចក្តីផ្តើមក្រមរដ្ឋប្បវេណីថ្មីបំផុតសម្រាប់ឆ្នាំ2020។

ព័ត៌មានតាមកាសែតជាអាទិ៍ បានផ្សព្វផ្សាយថា ការធ្វើវិសោធនកម្មទំនាក់ទំនងសិទ្ធិលើបំណុលក្នុងឆ្នាំ2017 គឺជា វិសោធនកម្មលើខ្លឹមសារយ៉ាងជិតស្និទ្ធនឹងការរស់នៅ ដោយបានពិចារណាអំពីកិច្ចការពារអ្នកប្រើប្រាស់ផងដែរ ប៉ុន្តែ តាមពិត គេបានធ្វើវិសោធនកម្មជាច្រើនទៅលើបទប្បញ្ញត្តិផ្នែកជំនួញដែលពាក់ព័ន្ធនឹងសហគ្រាសជាអាទិ៍។

ហើយវិសោធនកម្មលើវិស័យនីតិគ្រួសារលើកនេះ ធ្វើឡើងលើចំណុចជាច្រើនដូចជា ការបន្ថយអាយុដល់នីតិភាព, ការកំណត់អាយុអាចរៀបការរបស់បុរសស្ត្រីឱ្យដូចគ្នា, ការពន្យារវិសាលភាពនៃការសុំកូនពិសេស, ការសម្រួលទម្រង់នៃលិខិតមតកសាសន៍ដែលសរសេរដោយខ្លួនឯង, ការផ្លាស់ប្តូរគោលគំនិតនៃភាគបម្រុង (ប្តូរទៅជាសិទ្ធិទាមទារឱ្យសងប្រាក់នៃផ្នែកដែលបំពាន), ការបង្កើតសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ និង ការបង្កើតប្រព័ន្ធជនដែលផ្តល់វិភាគទានពិសេស ជាអាទិ៍។ យើងអាចនិយាយថា នេះជាការឆ្លើយតបនឹងសង្គមដែលមានអាត្រាកំណើតទាប និង អាត្រាជរាខ្ពស់, និងភាពសម្បូរបែបនៃរបបរស់នៅថ្មី ព្រមទាំងការបង្ហាញអំពីការគោរពឆន្ទៈសេរីរបស់បុគ្គលឯកជន (ការសម្រេចដោយឆន្ទៈ)។

តាមរយៈទស្សនៈនេះ យើងអាចយល់បានថា នេះគឺជាសម័យកាលដែលក្រមរដ្ឋប្បវេណីដែលជាច្បាប់មូលដ្ឋាននៃនីតិឯកជន ត្រូវសម្របជាមួយការផ្លាស់ប្តូរ និង ភាពសម្បូរបែបនៃសង្គមបច្ចុប្បន្ន។ ចំណុចនេះហើយដែលបង្ហាញថា ការងារបកស្រាយក្រមរដ្ឋប្បវេណីទាំងមូលនេះ កាន់តែលំបាកជាមុន។

នៅក្នុងស្ថានភាពបែបនេះហើយ ការបោះពុម្ពលើកទី6 នេះ នៅតែបន្តរក្សា និង ពង្រឹង លក្ខណៈពិសេសនៃសៀវភៅនេះដែលមានបំណងបង្ហាញ អំពីរូបភាពនៃក្រមរដ្ឋប្បវេណីទាំងមូលឱ្យងាយស្រួលយល់សម្រាប់ និស្សិតដែលមិនសិក្សាជំនាញនីតិសាស្ត្រ និង សាធារណៈជនទូទៅដែលបានសិក្សាជំនាញផ្សេងទៀត ហើយនេះជាគោលគំនិតចាប់តាំងពីការបោះពុម្ពលើកទី1 (សូមអានសារទៅកាន់អ្នកអានដែលមានជំនាញផ្សេង នៅក្នុងជំពូកទី10 ជំបូន្មានសិក្សា ក្នុងសៀវភៅនេះ)។

ជារឿងគួរឱ្យរីករាយដែលសៀវភៅនេះត្រូវបានយកទៅប្រើប្រាស់ក្នុងទម្រង់យ៉ាងច្រើន លើសពីការរំពឹងទុករបស់អ្នកនិពន្ធទៅទៀត។ សៀវភៅនេះត្រូវបានយកទៅប្រើប្រាស់ជាឯកសារបង្រៀនជាសេចក្តីផ្តើមក្រមរដ្ឋប្បវេណីនៅក្នុងសាកលវិទ្យាល័យ និង វគ្គបណ្តុះបណ្តាលខ្លីៗជាច្រើន ហើយថែមទាំងត្រូវបានប្រើប្រាស់ជាមេរៀននៅតាមសាលាតូចធំ និង ស្ថាប័នបណ្តុះបណ្តាលរបស់សហគ្រាសឯកជនជាច្រើន។ ខ្ញុំយល់ថា បុគ្គលដែលត្រូវសិក្សាមុខវិជ្ជាពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណីដើម្បីត្រៀមប្រឡងវិជ្ជាជីវៈនានា ឬ បុគ្គលដែលមិនបានបញ្ចប់ការសិក្សាច្បាប់ ហើយមានបំណងបន្តការសិក្សាទៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ គឺគួរតែប្រើប្រាស់សៀវភៅនេះ ដើម្បីចាប់យកចំណុចសំខាន់ៗនៃក្រមរដ្ឋប្បវេណី។ លើសពីនេះ អ្នកអាចប្រើប្រាស់សៀវភៅនេះ ជាការប្រឡងសាកល្បងមួយដើម្បីសម្រេចថា ខ្លួនមានទេពកោសល្យនឹងសិក្សាមុខវិជ្ជាច្បាប់ឬទេ (តើខ្លួនយល់ថា ការសិក្សាច្បាប់គួរឱ្យចាប់អារម្មណ៍ដែរឬទេ?)។

លើសពីនេះ ក្នុងពេលបច្ចុប្បន្ននេះ ការបណ្តុះបណ្តាលបន្ត និង ការបណ្តុះបណ្តាលជំនាញបន្ថែមសម្រាប់អ្នកធ្វើការ ទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំង។ ក្នុងនាមជាអ្នកនិពន្ធ ខ្ញុំដឹងថាគេនឹងទទួលស្គាល់លក្ខណៈសម្បត្តិរបស់សៀវភៅនេះ ក្នុងនាមជាសៀវភៅមេរៀនសម្រាប់ការបណ្តុះបណ្តាលនូវចំណេះដឹងទាំងនេះផងដែរ។

គួរជម្រាបថាលើកនេះ សៀវភៅនេះមិនត្រឹមតែត្រូវបានបកប្រែជាភាសាខ្មែរ ដើម្បីចូលរួមចំណែកក្នុងការសិក្សាច្បាប់នៅកម្ពុជានោះទេ ប៉ុន្តែថែមទាំងត្រូវបានបោះពុម្ពជាភាសាចិនផងដែរ។

ការបោះពុម្ពជាភាសាខ្មែរ អាចលេចចេញជារូបរាងបាន ដោយសារការខិតខំប្រឹងប្រែងរបស់ «សមាគមអ្នកច្បាប់ជប៉ុនជាមួយកម្ពុជា» (សហតំណាងដោយ៖ លោកស្រីមេធាវី SAKURAGI KAZUYO និង លោកមេធាវី KIMURA SHINSUKE)។ សៀវភៅនេះបានផ្តល់ឱ្យប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍ និង ស្តារប្រទេសពីស្ថានភាពដែលសឹងតែមិនមានសៀវភៅច្បាប់ណាសរសេរជាភាសាជាតិទាល់តែសោះ ដើម្បីប្រើប្រាស់ជាអត្ថបទសិក្សាច្បាប់។ ចាប់តាំងពីខែធ្នូ ឆ្នាំ2000 ផ្នែកដែលត្រូវបានបកប្រែហើយ ត្រូវបានយកទៅប្រគល់ជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រសួងយុត្តិធម៌ គណៈមេធាវី និង សាលាភូមិន្ទចៅក្រម ជាច្រើនលើក (អ្នកបកប្រែដំបូងគឺលោក ឡៅ គឹមលាង ហើយបន្ទាប់មកទៀតគឺលោក គង់ ទេលី សាស្ត្រាចារ្យវងនៃសាកលវិទ្យាល័យ Nagoya)។ នៅឆ្នាំ2004 ផ្នែកស្តីពីនីតិទ្រព្យសម្បត្តិត្រូវបានបកប្រែចប់ ហើយនៅឆ្នាំ2008 សៀវភៅនេះដដែលបានបោះពុម្ពលើកទី3 ត្រូវបានបកប្រែទាំងស្រុង និង ត្រូវបានប្រគល់ជូន (សូមពិនិត្យមើលរូបភាពគម្របសៀវភៅដែលបានភ្ជាប់ក្នុងសៀវភៅនេះ)។ ប្រទេសកម្ពុជាបានប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីថ្មីដែលបានតាក់តែងឡើងក្នុងទម្រង់ថ្មីនៅចុងឆ្នាំ2007។ ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងអាចចូលរួមចំណែកទោះបីជាតិចតួចក៏ដោយដល់ការបណ្តុះបណ្តាលច្បាប់នៅប្រទេសកម្ពុជា ដែលត្រូវបានស្តារឡើងវិញយ៉ាងឆាប់រហ័ស (បច្ចុប្បន្ននេះ សៀវភៅបកប្រែនេះកំពុងដាក់ឱ្យនិស្សិតកម្ពុជាអាចមើលបានដោយមិនគិតថ្លៃ នៅក្នុង http://masaoikeda.com

តាមរយៈការសហការរបស់លោកសាស្ត្រាចារ្យ Shiozawa Kazuhiro នៃសាកលវិទ្យាល័យ SEIKEI ហើយការបោះពុម្ពកែសម្រួលលើកចុងក្រោយ កំពុងតែដាក់ឱ្យបកប្រែ)។

លើសពីនេះ ការបោះពុម្ពជាភាសាចិន «ការបកស្រាយតាមលក្ខណៈក្រមរដ្ឋប្បវេណី» ដែលជាការបោះពុម្ពលើកទី 5 នៃសៀវភៅនេះ បានឈានទៅដល់ការបោះពុម្ពផ្សាយដោយក្រុមហ៊ុនបោះពុម្ពរបស់សាកលវិទ្យាល័យ TSING HUA តាមរយៈកិច្ចសហការពីក្រុមការងាររបស់លោក Daming Zhu សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ MUSASHINO (សាស្ត្រាចារ្យរងនៅសាកលវិទ្យាល័យ PEKING)។ អ្នកបកប្រែរួមមានលោកសាស្ត្រាចារ្យ Zhu, លោកសាស្ត្រាចារ្យ Yu Chen នៃសាកលវិទ្យាល័យ MUSASHINO, លោកស្រីសាស្ត្រាចារ្យរង Anni Jin និង លោកស្រី Zi Wang ។ ខ្ញុំសូមបង្ហាញនូវទឹកចិត្តអរគុណ ចំពោះការខិតខំប្រឹងប្រែងរបស់លោកសាស្ត្រាចារ្យ Zhu និងសហការី។

ក្នុងនាមជាអ្នកនិពន្ធ ខ្ញុំមានទឹកចិត្តរីករាយក្រៃលែង ដែលសៀវភៅនេះអាចបំពេញតួនាទីក្នុងការបង្ហាញរូបភាពទាំងមូលនៃក្រមរដ្ឋប្បវេណីជប៉ុនទៅកាន់បណ្ដាប្រទេសខាងក្រៅ។

មុនពេលឈានមកដល់ការបោះពុម្ពលើកទី៦នេះ នៅពេលបោះពុម្ពលើកដំបូងលោក Katsuhiko Kato នៃសមាគមគណនេយ្យករ ជាអ្នកទទួលបន្ទុកបោះពុម្ពសៀវភៅនេះ ហើយក្រោយមកទៀត ទទួលបានការកែសម្រួលពីលោក Eiji Minemura ជាអាទិ៍។ ការបោះពុម្ពលើកទី6 នេះ លោក Kato នឹងទទួលបន្ទុកសារជាថ្មី។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការគាំទ្រជិត 25ឆ្នាំកន្លងមកនេះ។

ខែ កញ្ញា ឆ្នាំ 2020

IKEDA MASAO

# មាតិកា


ជំពូកទី 1 : លំនាំសិក្សា ........ 1

I. នៅមុនពេលដល់ម៉ោងចូលថ្នាក់ ........ 2

II. សារទៅកាន់អ្នកអាន ........ 2

III. ការត្រៀមដើម្បីសិក្សា ........ 3

IV. វិសាលភាពនៃក្រមរដ្ឋប្បវេណី ........ 4

V. ទិដ្ឋភាពទូទៅនៃក្រមរដ្ឋប្បវេណី ........ 5

1. រចនាសម្ព័ន្ធនៃក្រមរដ្ឋប្បវេណី ........ 5

2. សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល ........ 5

3. ការបង្កើត និង ការវិវត្តន៍នៃក្រមរដ្ឋប្បវេណីជប៉ុន ........ 6

VI. ឋានៈរបស់ក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ទាំងមូល ........ 7

1. ក្រមរដ្ឋប្បវេណីក្នុងនាមជាច្បាប់មូលដ្ឋាននៃនីតិឯកជន ........ 7

2. ច្បាប់ទូទៅ និង ច្បាប់ពិសេស ........ 8

VII. លក្ខណៈពិសេសនៃក្រមរដ្ឋប្បវេណី ........ 9

1. គោលការណ៍ស្វ័យភាពនៃឆន្ទៈ និង គោលការណ៍សេរីភាពនៃកិច្ចសន្យា ........ 9

2. បទប្បញ្ញត្តិស្ម័គ្រចិត្ត និង បទប្បញ្ញត្តិចាប់បង្ខំ ........ 10

VIII. សេចក្តីសង្ខេប–គោលគំនិតក្នុងការសិក្សាក្រមរដ្ឋប្បវេណី ........ 11

ជំពូកទី២ : បទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ........ 12

I. ចរិតលក្ខណៈនៃបទប្បញ្ញត្តិទូទៅ និង លំដាប់នៃការសិក្សា ........ 13

II. ចំពោះការសិក្សាបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ........ 14

1. ចំណុចសំខាន់ៗនៃបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី និង វិធីសាស្រ្តសិក្សា ........ 14

2. បញ្ញត្តិដំបូងនៃបទប្បញ្ញត្តិទូទៅ ........ 15

III. ការសិក្សាចំណុចសំខាន់ៗក្នុងបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ........ 17

1. ការបង្ហាញឆន្ទៈ និង សកម្មភាពគតិយុត្ត ........ 17
2. ការការពារជនដែលត្រូវបានកម្រិតសមត្ថភាព ........ 19
3. ការបង្ហាញឆន្ទៈដែលមានបញ្ហា ........ 24
4. ការតំណាង ការតំណាងគ្មានសិទ្ធិ និងការតំណាងដែលមានលក្ខណៈជារូបភាព ........ 29
5. មោឃភាព និង ការលុបចោល ........ 31
6. លក្ខខណ្ឌ និង ការកំណត់ពេល ........ 32
7. អាជ្ញាយុកាល ........ 34
8. នីតិបុគ្គល ........ 38
9. លំនៅឋាន និង ការបាត់ខ្លួន ........ 43
ជំពូកទី 3 : នីតិសិទ្ធិប្រត្យក្ស (1) — នីតិសិទ្ធិប្រត្យក្សទូទៅ ........ 45
I. ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិប្រត្យក្ស ........ 46
1. «វត្ថុ» ក្នុងនាមទ្រព្យធនសកម្ម និង សិទ្ធិប្រត្យក្ស ........ 46
2. និយមន័យនៃសិទ្ធិប្រត្យក្ស និង គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់ ........ 47
3. ប្រភេទនៃសិទ្ធិប្រត្យក្ស ........ 48
4. ការប្រៀបធៀបនីតិសិទ្ធិប្រត្យក្សទូទៅ និង នីតិសិទ្ធិប្រាតិភោគប្រត្យក្ស ........ 50
II. ចំណុចសំខាន់នៃនីតិសិទ្ធិប្រត្យក្សទូទៅដែលត្រូវសិក្សា ........ 50
1. សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ........ 50
2. ការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស ........ 51
3. កម្មសិទ្ធិ ........ 60
4. សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផលក្រៅពីកម្មសិទ្ធិ ........ 65
5. សិទ្ធិកាន់កាប់ ........ 67
ជំពូកទី៤ : នីតិសិទ្ធិលើបំណុល (1) — នីតិកិច្ចសន្យា ........ 70
I. ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិលើបំណុល ........ 72

1. សិទ្ធិលើបំណុលដែលជាសិទ្ធិមានចំពោះបុគ្គល ..... 72
2. សិទ្ធិលើបំណុលក្នុងនាមទ្រព្យធនសកម្ម ..... 72
3. រចនាសម្ព័ន្ធនៃនីតិសិទ្ធិលើបំណុល និង លំដាប់សិក្សា ..... 73
II. ការសិក្សាចំណុចសំខាន់ៗនៃកិច្ចសន្យាទូទៅ ..... 74
1. ការបង្កើតកិច្ចសន្យា ..... 74
2. ប្រភេទនៃកិច្ចសន្យា ..... 75
3. អានុភាពនៃកិច្ចសន្យា ..... 77
4. ការមិនអនុវត្តកាតព្វកិច្ច និង ការរំលាយកិច្ចសន្យា ..... 82
5. ខសន្យាតាមទម្រង់ជាក់លាក់ ..... 85
III. ការសិក្សាចំណុចសំខាន់ៗនៃកិច្ចសន្យាពិសេស ..... 86
1. កិច្ចសន្យាលក់ទិញ ..... 86
2. កិច្ចសន្យាប្រទានកម្ម ..... 90
3. កិច្ចសន្យាជួល ..... 91
4. កិច្ចសន្យាខ្ចីប្រើ ..... 94
5. កិច្ចសន្យាខ្ចីបរិភោគ ..... 94
6. កិច្ចសន្យាម៉ៅការ ..... 95
7. កិច្ចសន្យាអាណត្តិ ..... 96
8. កិច្ចសន្យាបញ្ញើ ..... 97
9. កិច្ចសន្យាក្រុមហ៊ុន ..... 98
10. កិច្ចសន្យាដែលមានច្បាប់កំណត់ផ្សេងទៀត ..... 98
11. កិច្ចការពារអ្នកប្រើប្រាស់ និង Cooling-Off ..... 99
ជំពូកទី៥ : នីតិសិទ្ធិលើបំណុល (2) — នីតិអំពើអនីត្យានុកូល ..... 101
I. មូលហេតុនៃការកកើតសិទ្ធិលើបំណុលក្រៅពីកិច្ចសន្យា ..... 102

II. ការសិក្សាអំពីចំណុចសំខាន់នៃអំពើអនីត្យានុកូល ...... 102
1. អំពើអនីត្យានុកូលគឺជា ...... 102
2. គំនិតដើមស្តីពីសំណងការខូចខាតនៃអំពើអនីត្យានុកូល ...... 103
3. លក្ខខណ្ឌបង្កើតអំពើអនីត្យានុកូល ...... 103
4. អានុភាពនៃអំពើអនីត្យានុកូល ...... 106
5. អំពើអនីត្យានុកូលពិសេស ...... 108
6. បញ្ញត្តិផ្សេងទៀតស្តីពីអំពើអនីត្យានុកូល ...... 110
7. ច្បាប់ស្តីពីការធានាសំណងការខូចខាតដោយរថយន្ត ...... 110
8. ច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល ...... 111
III. ការសិក្សាអំពីចំណុចសំខាន់នៃការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនឥតហេតុ ...... 112
1. ការគ្រប់គ្រងដោយឈឺឆ្អាល ...... 112
2. សេចក្តីចម្រើនឥតហេតុ ...... 114
ជំពូកទី 6 : នីតិសិទ្ធិលើបំណុល (3) — នីតិសិទ្ធិលើបំណុលទូទៅ ...... 116
I. ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិលើបំណុល ...... 117
1. ខ្លឹមសារនៃសិទ្ធិលើបំណុលទូទៅ ...... 117
2. លក្ខណៈជាមូលដ្ឋាននៃសិទ្ធិលើបំណុល ...... 117
3. អត្ថន័យនៃបញ្ញត្តិស្តីពីសិទ្ធិលើបំណុលទូទៅ ...... 118
II. ការសិក្សាអំពីចំណុចសំខាន់នៃសិទ្ធិលើបំណុលទូទៅ ...... 119
1. ប្រភេទនៃសិទ្ធិលើបំណុល ...... 119
2. ការមិនអនុវត្តកាតព្វកិច្ច ...... 122
3. សមត្ថភាពរបស់ម្ចាស់បំណុល ...... 126
4. ទំនាក់ទំនងសិទ្ធិលើបំណុលនៃភាគីច្រើននាក់ ...... 130
5. អនុប្បទានសិទ្ធិលើបំណុល ...... 139

6. ការរលត់សិទ្ធិលើបំណុល ........ 145
III. ក្រមរដ្ឋប្បវេណី និងកិច្ចការច្បាប់នៃសហគ្រាស ........ 149
ជំពូកទី 7 : នីតិសិទ្ធិប្រត្យក្ស (2) — នីតិសិទ្ធិប្រាតិភោគប្រត្យក្ស ........ 151
I. ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិប្រាតិភោគប្រាត្យក្ស ........ 152
1. អត្ថន័យ និង លក្ខណៈនៃសិទ្ធិប្រាតិភោគប្រត្យក្ស ........ 152
2. មុខងាររបស់សិទ្ធិប្រាតិភោគប្រត្យក្ស និង ឋានៈនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស ........ 153
II. ចំណុចសំខាន់ៗនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស ........ 154
1. សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យា ........ 154
2. សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់ ........ 159
3. ប្រាតិភោគដែលគ្មានច្បាប់កំណត់ ........ 160
ជំពូកទី 8 : នីតិញាតិ ........ 164
I. អត្ថន័យ និង ឋានៈនៃនីតិគ្រួសារ ........ 165
II. ទិដ្ឋភាពទូទៅនៃនីតិញាតិ ........ 165
1. ខ្លឹមសារនៃនីតិញាតិ ........ 165
2. ទស្សនៈស្តីពីញាតិ ........ 165
III. ចំណុចសំខាន់ៗនៃនីតិញាតិ ........ 166
1. អាពាហ៍ពិពាហ៍ ........ 166
2. ការលែងលះ ........ 171
3. ឪពុកម្តាយនិងកូនបង្កើត・កូនចិញ្ចឹម ........ 172
4. អំណាចមេបា អាណាព្យាបាល ហិតូបត្ថម្ភ និង ការទំនុកបំរុង ........ 174
ជំពូកទី 9 : នីតិសន្តតិកម្ម ........ 179
I. ទិដ្ឋភាពទូទៅនៃនីតិសន្តតិកម្ម ........ 180
1. រចនាសម្ព័ន្ធនៃសន្តតិកម្ម ........ 180

II. ចំណុចសំខាន់ៗនៃនីតិសន្តតិកម្ម ....................................................................................181
1. សន្តតិកម្មតាមច្បាប់ .......................................................................................................181
2. ការយល់ព្រម និង ការបោះបង់សន្តតិកម្ម .................................................................... 185
3. ការបែងចែកមត៌ក ....................................................................................................... 186
4. សន្តតិកម្មដោយមតកសាសន៍......................................................................................... 187
5. សិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ .................................................................................... 189
6. ភាគបម្រុង.....................................................................................................................191
7. ការបំបែកទ្រព្យសម្បត្តិ ................................................................................................ 192
8. នត្ថិភាពនៃសន្តតិជន .................................................................................................. 192
ជំពូកទី 10 : ដំបូន្មានក្នុងការសិក្សា.................................................................................... 194
I. មុនពេលទម្លាក់វាំងននចុះ................................................................................................ 195
II. ដំបូន្មាននៃការសិក្សាក្រមរដ្ឋប្បវេណីសម្រាប់អ្នកអានកម្រិតដំបូង ................................... 195
1. វិធីសិក្សា..................................................................................................................... 195
2. យុត្តិសាស្ត្រ និង ទ្រឹស្តីបកស្រាយ ................................................................................ 197
III. ដំបូន្មាននៃការសិក្សាក្រមរដ្ឋប្បវេណីសម្រាប់អ្នកអានកម្រិតមធ្យម.................................. 198
1. វិធីសិក្សា..................................................................................................................... 198
2. ប្រព័ន្ធតុលាការ និង យុត្តិសាស្ត្រ ....................................................................................200
3. សម្រាប់បុគ្គលដែលចង់ក្លាយជាអ្នកអានកម្រិតខ្ពស់...........................................................202
IV. សេចក្តីសន្និដ្ឋាន ..........................................................................................................204

# ជំពូកទី 1 : លំនាំសិក្សា

I. **នៅមុនពេលដល់ម៉ោងចូលថ្នាក់**

II. **សារទៅកាន់អ្នកអាន**

III. **ការត្រៀមដើម្បីសិក្សា**

IV. **វិសាលភាពនៃក្រមរដ្ឋប្បវេណី**

V. **ទិដ្ឋភាពទូទៅនៃក្រមរដ្ឋប្បវេណី**

1. រចនាសម្ព័ន្ធនៃក្រមរដ្ឋប្បវេណី
2. សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល
3. ការបង្កើត និង ការវិវត្តន៍នៃក្រមរដ្ឋប្បវេណីជប៉ុន

VI. **ឋានៈរបស់ក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ទាំងមូល**

1. ក្រមរដ្ឋប្បវេណីក្នុងនាមជាច្បាប់មូលដ្ឋាននៃនីតិឯកជន
2. ច្បាប់ទូទៅ និង ច្បាប់ពិសេស

VII. **លក្ខណៈពិសេសនៃក្រមរដ្ឋប្បវេណី**

–គោលការណ៍ស្វ័យភាពនៃឆន្ទៈ (ស្វ័យភាពនៃបុគ្គលឯកជន)

1. គោលការណ៍ស្វ័យភាពនៃឆន្ទៈ និង គោលការណ៍សេរីភាពនៃកិច្ចសន្យា
2. បទប្បញ្ញត្តិស្ម័គ្រចិត្ត និង បទប្បញ្ញត្តិចាប់បង្ខំ

VIII. **សេចក្តីសង្ខេប–គោលគំនិតក្នុងការសិក្សាក្រមរដ្ឋប្បវេណី**

## I. នៅមុនពេលដល់ម៉ោងចូលថ្នាក់

សៀវភៅនេះ មិនដូចនឹងសៀវភៅពន្យល់អំពីក្រមរដ្ឋប្បវេណីទូទៅនោះទេ។ សៀវភៅនេះបានតាក់តែងឡើងតាមរចនាសម្ព័ន្ធក្នុងថ្នាក់សិក្សានៅតាមមហាវិទ្យាល័យទូទៅ ដោយចាប់ផ្តើមពីការផ្តល់លំនាំសិក្សាអំពីលំដាប់លំដោយ និង របៀបសិក្សាក្រមរដ្ឋប្បវេណី ហើយបញ្ចប់ដោយការផ្តល់ដំបូន្មានអំពីការរៀនសូត្រ។ ប៉ុន្តែ ខ្ញុំយល់ថា អ្នកអានមួយចំនួនដែលមានចំណេះដឹងអំពីក្រមរដ្ឋប្បវេណីរួចហើយ មិនត្រូវការរចនាសម្ព័ន្ធបែបនេះទេ ហើយចង់ចាប់ផ្តើមពីខ្លឹមសារច្បាប់ជាក់ស្តែងតែម្តង។ ក្នុងករណីនេះ សូមរំលងជំពូកទី1 ហើយចាប់ផ្តើមអានជំពូកទី2 បទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ក៏បានដែរ។ ប៉ុន្តែ ខ្លឹមសារនៅក្នុងជំពូកទី1 នេះ គឺជាចំណេះដឹងមូលដ្ឋានដែលចាំបាច់ ហេតុនេះ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាឆ្លៀតពេលមើលជំពូកនេះផងដែរ នៅពេលដែលកំពុងតែអានសៀវភៅនេះ។

## II. សារទៅកាន់អ្នកអាន

សៀវភៅនេះ បានច្បិចយកចំណុចសំខាន់ៗនៃមុខវិជ្ជារដ្ឋប្បវេណី ដើម្បីឱ្យអ្នកអានងាយស្រួលសិក្សាបានកាន់តែស៊ីជម្រៅ។ នៅក្នុងពិភពលោកនេះ មានសៀវភៅសេចក្តីផ្តើមក្រមរដ្ឋប្បវេណីជាច្រើន ហេតុនេះហើយ ខ្ញុំសូមបញ្ជាក់អំពីគោលបំណងឱ្យបានច្បាស់លាស់នៅទីនេះ។ គោលបំណងចម្បង គឺសម្រាប់បុគ្គលដែលមានជំនាញផ្សេងៗ ដែលមានបំណងសិក្សាក្រមរដ្ឋប្បវេណី ឬ ចង់ដឹងអំពីទិដ្ឋភាពទូទៅនៃក្រមរដ្ឋប្បវេណីដោយសារមានការចាំបាច់ណាមួយ ហើយមិនសំដៅតែទៅលើអ្នកដែលមានបំណងចាប់យកជំនាញច្បាប់តែម្តងនោះទេ។ ពិតប្រាកដហើយថា ខ្ញុំសប្បាយចិត្តដែលអ្នកទើបក្លាយជានិស្សិតច្បាប់នៅសាកលវិទ្យាល័យអានសៀវភៅនេះ ប៉ុន្តែ ខ្ញុំក៏ចង់ឱ្យសៀវភៅនេះមានប្រយោជន៍ដល់និស្សិតដែលកំពុងសិក្សាជំនាញសេដ្ឋកិច្ច និង ពាណិជ្ជកម្ម ឬ បុគ្គលដែលមានចំណេះដឹងជាក់ស្តែងអំពីរូបិយាណត្តិ និង មូលប្បទានប័ត្រជាដើម នៅក្នុងសហគ្រាស ហើយមិនធ្លាប់បានសិក្សាអំពីច្បាប់ ឬក៏ បុគ្គលដែលកំពុងសិក្សាជំនាញផ្សេងនៅក្នុងមហាវិទ្យាល័យ ឬ វគ្គខ្លីផ្សេងទៀត។ ជាពិសេស ខ្ញុំចង់ឱ្យសៀវភៅនេះក្លាយជាសៀវភៅដែលសាកសមបំផុតសម្រាប់អ្នកដែលចាប់ផ្តើមសិក្សាក្រមរដ្ឋប្បវេណី ដើម្បីត្រៀមប្រឡងយកវិជ្ជាជីវៈដូចជា គណនេយ្យករជំនាញ ឬ ភ្នាក់ងារពន្ធដារជាអាទិ៍។

មូលហេតុនៃការរៀបចំសៀវភៅបែបនេះ ក៏មានពាក់ព័ន្ធនឹងខ្លួនខ្ញុំផ្ទាល់ផងដែរ។ ខ្ញុំមានប្រវត្តិបញ្ចប់ការសិក្សាដំបូងចេញពីជំនាញសេដ្ឋកិច្ច មិនមែនច្បាប់នោះទេ។ ជាក់ស្តែង នៅក្នុងសម័យកាលចុងក្រោយនៃវិវាទក្នុងមហាវិទ្យាល័យ ខ្ញុំបានចាប់ផ្តើមសិក្សាច្បាប់ទាំងខ្ញុំជានិស្សិតផ្នែកសេដ្ឋកិច្ច នៅក្រោយពេលមានបញ្ហាកើតឡើងនៅក្នុងការប្រឡងចូលមហាវិទ្យាល័យ។ ហេតុនេះហើយ ទាល់តែជិតដំណាក់កាលបញ្ចប់ការសិក្សា ទើបខ្ញុំចាប់ផ្តើមយល់អំពីខ្លឹមសារនៃមេរៀនដូចគ្នានឹងនិស្សិតច្បាប់ដែរ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចដឹងច្បាស់ជាងអ្នកណា

ទាំងអស់អំពី ផលវិបាកនៃការស្វែងយល់ទ្រឹស្តីច្បាប់ និង ការព្យាករណ៍ដែលខុសស្រឡះនៅពេលចាប់ផ្តើមដំបូងទៅលើមេរៀនដែលត្រូវរៀនរបស់អ្នកដែលសិក្សាជំនាញសេដ្ឋកិច្ច ជាដើម។

ខ្ញុំបានប្រើប្រាស់បទពិសោធន៍ទាំងនេះ ដើម្បីបង្ហាញអំពីចំណុចគួរឱ្យចាប់អារម្មណ៍នៃការសិក្សាក្រមរដ្ឋប្បវេណី ដោយដកចេញនូវអារម្មណ៍ពិបាក និង ការភាន់ច្រឡំចំពោះការសិក្សាច្បាប់ពីអ្នកអានទាំងអស់គ្នា។ តាមពិតការសិក្សាក្រមរដ្ឋប្បវេណី គឺជាការសិក្សាដែលគួរឱ្យចាប់អារម្មណ៍ខ្លាំងមែនទែន។ ជំនាញច្បាប់ គឺជាជំនាញមូលដ្ឋានមួយដូចនឹងពាក្យពេជន៍របស់វា។ ហេតុនេះ វាមានសារៈសំខាន់ខ្លាំងណាស់ (ចំពោះជំនាញនីតិសាស្ត្រនៅក្នុងសកលវិទ្យាល័យណាក៏ដោយ ក៏ក្រមរដ្ឋប្បវេណី គឺជាមុខវិជ្ជាដែលមានក្រេឌីតច្រើនបំផុតក្នុងចំណោមមុខវិជ្ជាផ្សេងទៀតដែរ)។

លើសពីនេះ ការសិក្សាក្រមរដ្ឋប្បវេណី មិនធ្វើឱ្យអ្នកខាតបង់អ្វីនោះទេ។ អ្នកអាចចាប់ផ្តើមសិក្សាក្រមរដ្ឋប្បវេណីដូចខាងក្រោមនេះ សម្រាប់ជាប្រយោជន៍ជាក់ស្តែងក៏បានដែរ។ ប៉ុន្តែ ដូចមានរៀបរាប់បន្តទៅនេះ ក្រមរដ្ឋប្បវេណីដែលជាច្បាប់មូលដ្ឋានតែមួយគត់នៃបណ្តានីតិឯកជនទាំងអស់ គឺជាជំនាញដែលពាក់ព័ន្ធនឹងទំនាក់ទំនងបុគ្គលយ៉ាងខ្លាំង ដោយសារតែវាមានវិសាលភាពយ៉ាងទូលំទូលាយទៅលើជីវភាពរស់នៅក្នុងសង្គមរបស់យើងគ្រប់គ្នា។ ជាចុងក្រោយ ខ្ញុំសង្ឃឹមថានៅពេលដែលអ្នកទាំងអស់គ្នាបានយល់ច្បាស់អំពីក្រមរដ្ឋប្បវេណី ក្រៅពីទទួលបានប្រយោជន៍ជាក់ស្តែង អ្នកទាំងអស់គ្នានឹងបានស្វែងយល់អំពីមនុស្ស ហើយខំប្រឹងប្រែងបំពេញចំណុចខ្វះខាតនានា និង ធ្វើឱ្យសង្គមកាន់តែល្អជាងមុន។

## III. **ការត្រៀមដើម្បីសិក្សា**

ដំបូង នៅពេលចាប់ផ្តើមសិក្សាក្រមរដ្ឋប្បវេណី សូមអ្នកទាំងអស់គ្នាបោះចោលនូវអារម្មណ៍តានតឹង ហើយសិក្សាតាមសម្រួល។

តើចំណុចនេះមានន័យយ៉ាងណា? ខ្ញុំយល់ថា អ្នកដែលមិនទាន់ធ្លាប់បានសិក្សាច្បាប់ភាគច្រើន តែងយល់ថាច្បាប់គឺជាឯកសារគតិយុត្តដាច់ខាតដែលរដ្ឋអំណាចបានសម្រេច ហើយប្រជាជនត្រូវតែគោរព។ ប៉ុន្តែ ខ្ញុំសូមនិយាយជាមុនថា ការគិតបែបនេះមិនសូវត្រឹមត្រូវនោះទេ ចំពោះក្រមរដ្ឋប្បវេណីនេះ។

នៅក្នុងចំណោមច្បាប់ទាំងអស់ មានច្បាប់ជាច្រើនគឺជាច្បាប់ដែលមានលក្ខណៈចាប់បង្ខំឱ្យប្រជាជន ត្រូវតែគោរពតាមបញ្ញត្តិនោះ ដើម្បីស្ថេរភាពសង្គម និង ការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាជន។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីបានគិតថារបស់ដែលសំខាន់បំផុត គឺជា «**ឆន្ទៈ**» របស់ពួកយើង។ គោលបំណងជាមូលដ្ឋានរបស់ក្រមរដ្ឋប្បវេណី គឺបង្កើតនូវទំនាក់ទំនងជីវភាពសង្គមដោយការបង្ហាញឆន្ទៈតាមការពិចារណាខ្លួនឯងទៅវិញទៅមក រវាងប្រជាពលរដ្ឋម្នាក់ៗដែលមានសមត្ថភាពក្នុងការវិនិច្ឆ័យ (⇒ : សូមយោងគោលការណ៍ស្វ័យភាពនៃឆន្ទៈនៅក្នុងចំណុច VII)។

លើសពីនេះ ក្រមរដ្ឋប្បវេណីមានបញ្ញត្តិជាច្រើនដែលមិន «ដាច់ខាត» នោះទេ ហើយភាគីអាចបង្កើតនូវវិធានដែលខុសពីមាត្រាក្នុងក្រមរដ្ឋប្បវេណីដោយឆន្ទៈសេរីរបស់ខ្លួនបាន ហើយមានវិស័យជាច្រើនដែលវិធានដែលភាគីបានបង្កើតនោះ មានអាទិភាពជាងវិធាននៅក្នុងមាត្រាច្បាប់ (សូមយោងខ្លឹមសារអំពី បញ្ញត្តិចាប់បង្ខំ និង បញ្ញត្តិស្ម័គ្រចិត្តនៅក្នុងចំណុច VII.2)។

ដូចនេះ នៅពេលដែលអ្នកទាំងអស់គ្នាសិក្សាអំពីក្រមរដ្ឋប្បវេណី សូមបោះបង់ចោលនូវការគិតអំពី «សម្ពាធ» «តឹងតែង» និង «ពិបាកយល់» ជាដើម។

## IV. **វិសាលភាពនៃក្រមរដ្ឋប្បវេណី**

ក្រមរដ្ឋប្បវេណីមិនមែនជាច្បាប់ដែលពិបាកយល់នោះទេ ហើយច្បាប់នេះនៅជិតនឹងជីវភាពប្រចាំថ្ងៃរបស់យើងគ្រប់គ្នា។ ហេតុនេះហើយ យើងអាចនិយាយបានថាក្រមរដ្ឋប្បវេណីនេះគឺជាច្បាប់ដែលមានសារៈសំខាន់ខ្លាំង។

សូមមើលជាក់ស្តែងអំពី ភាពពាក់ព័ន្ធរវាងក្រមរដ្ឋប្បវេណី និង ខ្សែជីវិតរបស់មនុស្សម្នាក់។ មនុស្សម្នាក់ៗត្រូវបានទទួលស្គាល់អំណាចជាមូលដ្ឋាន (សមត្ថភាពទទួលសិទ្ធិ) ដើម្បីរស់នៅក្នុងសង្គមក្នុងនាមជាមនុស្សទូទៅ ចាប់ពីថ្ងៃដែលរស់រានមានជីវិត។ ហើយបុគ្គលម្នាក់ៗ អាចប្រាស្រ័យទាក់ទងជាមួយអ្នកដទៃដោយឆន្ទៈសេរីរបស់ខ្លួនឯង ហើយបង្កើតនូវទំនាក់ទំនងសង្គមជាមួយអ្នកដទៃបាន (ការបង្ហាញឆន្ទៈ)។ ប៉ុន្តែ នៅពេលដែលបុគ្គលម្នាក់នៅជាកូនក្មេងនៅឡើយ គឺពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើតទំនាក់ទំនងគតិយុត្តនៅឡើយទេ (សមត្ថភាពក្នុងការធ្វើសកម្មភាព) ហេតុនេះហើយ ការបង្កើតទំនាក់ទំនងសង្គមដោយការបង្ហាញឆន្ទៈរបស់បុគ្គលនោះ ត្រូវមានការគាំពារក្នុងទម្រង់ជាក់លាក់ណាមួយ ដូចជា ការឯកភាពពីឪពុកម្តាយជាដើម (ការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព)។ ក្រោយមកទៀត មនុស្សម្នាក់ៗចាប់ផ្តើមមានវត្ថុដែលអាចប្រើប្រាស់ និងចាត់ចែងដោយសេរី តាមចិត្តខ្លួនឯងបាន (សិទ្ធិប្រត្យក្ស) ហើយក៏អាចទទួលបានសិទ្ធិ (សិទ្ធិលើបំណុល) ដែលអាចទាមទារឱ្យអ្នកដទៃធ្វើសកម្មភាពជាក់លាក់មួយ តាមរយៈការសន្យា (កិច្ចសន្យា) ដោយការបង្ហាញឆន្ទៈសេរីជាមួយអ្នកដទៃ ហើយបង្កើតឱ្យមានអានុភាពគតិយុត្តជាក់លាក់មួយ។ នៅក្នុងនោះក៏អាចមាន បុគ្គលខ្លះអាចទាមទារសំណងការខូចខាត ដោយសារការជួបគ្រោះថ្នាក់ចរាចរណ៍ជាអាទិ៍ (អំពើអនីត្យានុកូល)។ លើសពីនេះ មនុស្សម្នាក់ៗមិនល្អឥតខ្ចោះនោះទេ ហើយជីវិតរស់នៅក៏មានកម្រិតដែរ ហេតុនេះហើយ ការទាមទារសំណង ឬការទាមទារធ្វើសកម្មភាពណាមួយពីអ្នកដទៃក៏ដោយ ក៏ត្រូវមានការកម្រិតជាពេលវេលាផងដែរ (អាជ្ញាយុកាល)។ ហើយមនុស្សភាគច្រើននៅពាក់កណ្តាលជីវិតរបស់ខ្លួន តែងរកឃើញដៃគូជីវិត (អាពាហ៍ពិពាហ៍)។ ក្រោយរៀបអាពាហ៍ពិពាហ៍ មានប្តីប្រពន្ធខ្លះអាចបង្កើតកូនដោយខ្លួនឯង (កូនបង្កើត) ហើយប្តីប្រពន្ធខ្លះក៏យកកូនរបស់អ្នកដទៃមកធ្វើជាកូនរបស់ខ្លួន (កូនចិញ្ចឹម)។ ក្រោយមកទៀត មនុស្សខ្លះបានប្រឹងប្រែងពេញមួយជីវិត និងឈានដល់ខ្សែជីវិតចុងក្រោយ ហើយនៅពេលដែលស្លាប់ មានករណីខ្លះទ្រព្យសម្បត្តិត្រូវបន្តទៅឱ្យសហព័ទ្ធ និង កូន (សន្តតិកម្ម)

ឬ មានករណីខ្លះ អ្នកស្លាប់បានសរសេរទុកនូវវិធីបែងចែកទ្រព្យសម្បត្តិរបស់ខ្លួនកាលនៅរស់ ដើម្បីបំពេញឆន្ទៈចុងក្រោយរបស់អ្នកស្លាប់ (មតកសាសន៍)។

ខ្លឹមសារដែលបានរៀបរាប់ខាងលើនេះ គឺស្ថិតនៅក្នុងវិសាលភាពរបស់ក្រមរដ្ឋប្បវេណីទាំងអស់ (ហើយនៅក្នុងរង្វង់ក្រចក គឺជាពាក្យពេចន៍ច្បាប់នៃក្រមរដ្ឋប្បវេណី)។ ខ្ញុំយល់ថា អ្នកទាំងអស់គ្នាកំពុងតែចាប់អារម្មណ៍ថា ក្រមរដ្ឋប្បវេណីពិតជាស្ថិតនៅជិតខ្លួនរបស់យើងគ្រប់ៗគ្នានៅក្នុងជីវភាពសង្គម។

## V. **ទិដ្ឋភាពទូទៅនៃក្រមរដ្ឋប្បវេណី**

### 1. **រចនាសម្ព័ន្ធនៃក្រមរដ្ឋប្បវេណី**

សូមបើកមើលសៀវភៅច្បាប់ធំបំផុតរបស់ជប៉ុន។ សៀវភៅច្បាប់ភាគច្រើនបំផុត គឺចងក្រងតាមលំដាប់លំដោយពីរដ្ឋធម្មនុញ្ញ ច្បាប់រដ្ឋបាល ហើយក្រោយមកច្បាប់ពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណី។ ក្រមរដ្ឋប្បវេណីគឺជាបណ្តុំច្បាប់ដ៏ធំដែលមានលើសពី 1000មាត្រា ហើយចំនួនមាត្រានេះ ពិតជាច្រើនខ្លាំង ប៉ុន្តែ យើងអាចនិយាយបានថា វាគ្មានវិធីផ្សេងដែលអាចជៀសមិនឱ្យមានមាត្រាច្រើននោះទេ ពីព្រោះ ក្រមនេះមានវិសាលភាពទៅលើជីវភាពនៅក្នុងសង្គមរបស់យើងគ្រប់គ្នា។ ហើយតាមពិតទៅ មានបញ្ញត្តិជាច្រើនគឺជាការយល់ឃើញទូទៅក្នុងសង្គម។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកទាំងអស់គ្នាកុំព្រួយបារម្ភអំពីចំនួននៃមាត្រា។

ក្រមរដ្ឋប្បវេណីជប៉ុនបែងចែកជា 5គន្ថី រួមមាន បទប្បញ្ញត្តិទូទៅ សិទ្ធិប្រត្យក្ស សិទ្ធិលើបំណុល ញាតិ និង សន្តតិកម្ម (ច្បាប់ធំៗ ត្រូវបានគេហៅថា «ក្រម»)។ នៅក្នុងការសិក្សាច្បាប់ ចំពោះគន្ថី 3 ដំបូង គេហៅថា នីតិទ្រព្យសម្បត្តិហើយ ចំពោះគន្ថី 2 ចុងក្រោយ គេហៅថា នីតិគ្រួសារ ឬ នីតិឋានៈបុគ្គល។ គន្ថីស្តីពីបទប្បញ្ញត្តិទូទៅមើលទៅហាក់បីដូចជា បទបញ្ញត្តិរួមគ្នានៅក្នុងក្រមរដ្ឋប្បវេណីទាំងមូល ប៉ុន្តែ ខ្លឹមសារជាក់ស្តែងនៃគន្ថីនេះ គឺពាក់ព័ន្ធតែជាមួយសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុលប៉ុណ្ណោះ ហេតុនេះ យើងគួរហៅថា បទបញ្ញត្តិរួមនៃនីតិទ្រព្យសម្បត្តិទើបត្រឹមត្រូវជាង។ នៅក្នុងសៀវភៅនេះ គឺផ្តោតសំខាន់លើការពន្យល់អំពីនីតិទ្រព្យសម្បត្តិ ប៉ុន្តែ ក៏មានបង្ហាញខ្លះៗអំពីនីតិគ្រួសារផងដែរ (ក្នុងនោះរួមមាន អាពាហ៍ពិពាហ៍ កូនបង្កើត កូនចិញ្ចឹម សន្តតិកម្ម និង មតកសាសន៍)។ ជាពិសេស ចំណុចដែលជាទំនាក់ទំនងរវាងនីតិសន្តតិកម្មជាអាទិ៍ និងនីតិទ្រព្យសម្បត្តិ សម្រាប់ជាចំណេះដឹងជាមូលដ្ឋានដល់អ្នកអានដែលសិក្សាច្បាប់ពន្ធនានា ដើម្បីត្រៀមប្រឡងភ្នាក់ងារពន្ធដារជាអាទិ៍។

### 2. **សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល**

ដូចបានរៀបរាប់ខាងលើនេះ «បទប្បញ្ញត្តិទូទៅ» កំណត់អំពីបញ្ញត្តិរួមគ្នារវាង «សិទ្ធិប្រត្យក្ស» និង «សិទ្ធិលើបំណុល» (ឧទាហរណ៍ដែលបានលើកឡើងក្នុងចំណុច IV រួមមាន សមត្ថភាពទទួលសិទ្ធិ ការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ការបង្ហាញឆន្ទៈ និង អាជ្ញាយុកាល ជាអាទិ៍)។ ហើយនៅក្នុងគន្ថីស្តីពី «សិទ្ធិប្រត្យក្ស» កំណត់អំពី «សិទ្ធិគ្រប់គ្រងដោយផ្ទាល់ចំពោះវត្ថុរបស់បុគ្គល»។ សិទ្ធិប្រត្យក្សជាតំណាង(ដែលមាន

លក្ខណៈពេញលេញ) គឺកម្មសិទ្ធិ។ កម្មសិទ្ធិករអាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងដោយសេរី លើវត្ថុកម្មសិទ្ធិបាន។ សិទ្ធិប្រត្យក្ស គឺជាសិទ្ធិដាច់ខាតដែលអាចអះអាងចំពោះបុគ្គលទាំងអស់ក្នុងលោកនេះ (អាចលុបបំបាត់ការជ្រៀតជ្រែក និង ការរារាំងពីអ្នកដទៃ) ហេតុនេះ ប្រភេទនៃសិទ្ធិប្រត្យក្សត្រូវបានកំណត់ក្នុងក្រមរដ្ឋប្បវេណី (គោលការណ៍សិទ្ធិប្រត្យក្សកំណត់ដោយច្បាប់) ហើយយើងទាំងអស់គ្នាមិនអាចបង្កើតនូវប្រភេទនៃសិទ្ធិប្រត្យក្សថ្មីតាមចិត្តបានឡើយ។ ផ្នែកចុងក្រោយនៃគន្ថីស្ដីពី «សិទ្ធិប្រត្យក្ស» មានកំណត់អំពី «សិទ្ធិគ្រប់គ្រងចំពោះវត្ថុនោះទេ» ហើយផ្នែកនេះមានកំណត់អំពីការគ្រប់គ្រងតម្លៃដោះដូរនៃវត្ថុ ពោលគឺ សិទ្ធិប្រត្យក្សក្នុងនាមជា «ប្រាតិភោគ» ដើម្បីជាមធ្យោបាយធានាសិទ្ធិលើបំណុលចំពោះបុគ្គល (ឧបមាថា បើសិនជាមិនអាចសងសិទ្ធិលើបំណុលជាប្រាក់បាននោះទេ សូមយកវត្ថុនេះទៅលក់ដោយបង្ខំ ហើយប្រមូលបំណុលពីប្រាក់ថ្លៃលក់ចុះ)។ បន្តមកទៀតគន្ថីស្ដីពី «សិទ្ធិលើបំណុល» មានកំណត់អំពីលក្ខណៈផ្សេងៗនៃសិទ្ធិលើបំណុល និង ដំណើរការនៃការកកើតរហូតដល់ការរលត់នៃសិទ្ធិលើបំណុល នៅផ្នែកខាងដើមគន្ថី (ផ្នែកនេះ គឺជា គន្ថីស្ដីពីសិទ្ធិលើបំណុល «ទូទៅ» ហើយការសិក្សាចំណុចនេះ ហៅថានីតិសិទ្ធិលើបំណុលទូទៅ។) ហើយនៅផ្នែកខាងក្រោយនៃគន្ថី កំណត់អំពីមូលហេតុនៃការកកើតសិទ្ធិលើបំណុលនេះ (ការសិក្សាលើផ្នែកនេះ ហៅថានីតិសិទ្ធិលើបំណុលពិសេស)។ សិទ្ធិលើបំណុលសំដៅទៅលើ «សិទ្ធិដែលបុគ្គលជាក់លាក់មួយ អាចទាមទារឱ្យបុគ្គលជាក់លាក់មួយទៀត ធ្វើសកម្មភាពកំណត់ណាមួយជាអាទិ៍» ហើយមូលហេតុនៃការកកើតសិទ្ធិលើបំណុលនេះមានចំនួន 4 ប៉ុន្តែ មូលហេតុធំជាងគេបំផុត គឺ កិច្ចសន្យា (ក្រៅពីនេះរួមមាន អំពើអនីត្យានុកូល ជាអាទិ៍)។ សិទ្ធិលើបំណុល គឺជាសិទ្ធិដែលមានអានុភាពមិនដាច់ខាតចំពោះភាគីទាំងសងខាង ហើយយើងគ្រប់គ្នាអាចបង្កើតខ្លឹមសារនៃសិទ្ធិលើបំណុលដោយសេរី (លើកលែងតែ កិច្ចសន្យាដែលមានខ្លឹមសារផ្ទុយនឹងសង្គមប៉ុណ្ណោះ) តាមរយៈកិច្ចសន្យាបាន (គោលការណ៍សេរីភាពនៃកិច្ចសន្យា សេរីភាពនៃការបង្កើតសិទ្ធិលើបំណុល)។

### 3. **ការបង្កើត និង ការវិវត្តន៍នៃក្រមរដ្ឋប្បវេណីជប៉ុន**

ក្រមរដ្ឋប្បវេណីជប៉ុន ត្រូវបានប្រកាសឱ្យប្រើនៅក្នុងឆ្នាំ1896 ហើយដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ 1898។ ហើយផ្នែកស្ដីពីនីតិគ្រួសារ (ចាប់ពីមាត្រា725) ត្រូវបានធ្វើវិសោធនកម្មស្ទើរតែទាំងស្រុងនៅក្នុងឆ្នាំ1947 ក្រោយសង្គ្រាមលោកលើកទី2។ ប៉ុន្តែ ផ្នែកស្ដីពីនីតិទ្រព្យសម្បត្តិក្នុងគន្ថីដើមទាំង3 (ត្រឹមមាត្រា724) ស្ទើរតែត្រូវបានរក្សាតាមទម្រង់ដើមតាំងពីពេលប្រកាសឱ្យប្រើ រហូតដល់ពេលបច្ចុប្បន្ននេះ (ដូច្នេះ មាត្រាទាំងអស់នោះត្រូវបានសរសេរក្នុងទម្រង់តួអក្សរបុរាណ ដោយមិនមានប្រើប្រាស់សញ្ញាវណ្ណយុត្តិអ្វីឡើយ)។ ក្រោយមកនៅក្នុងឆ្នាំ2004 គន្ថីដើមទាំង 3 ត្រូវប្ដូរមកប្រើប្រាស់ពាក្យពេចន៍ និង របៀបសរសេរបែបសម័យទំនើបវិញ។ ហេតុនេះ ការធ្វើវិសោធនកម្មក្នុងឆ្នាំ2017 គឺជាការធ្វើវិសោធនកម្មទ្រង់ទ្រាយធំ ក្នុងរយៈពេល 120ឆ្នាំកន្លងមកនេះ ហើយខ្លឹមសារនៃការធ្វើវិសោធនកម្មក្នុងឆ្នាំ2017 ត្រូវដាក់ឱ្យអនុវត្តនៅក្នុងខែមេសា ឆ្នាំ2020។

ការរៀបចំបែងចែកជាគន្ថីស្ដីពីបទប្បញ្ញត្តិទូទៅនៅខាងដើមនេះ គឺជាទម្រង់របស់**ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់** (បើនិយាយឱ្យត្រឹមត្រូវគឺ សេចក្ដីព្រាងក្រម) ដែលហៅថា **ប្រព័ន្ធ**Pandekten។ ប៉ុន្តែ ខ្លឹមសារនៃក្រមរដ្ឋប្បវេណី

ជប៉ុន ពុំសូវខិតទៅជិតក្រមរដ្ឋប្បវេណីអាឡឺម៉ង់នោះទេ។ បើនិយាយជារួមទៅ ក្រមរដ្ឋប្បវេណីជប៉ុនទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីអាឡឺម៉ង់ និង ក្រមរដ្ឋប្បវេណីបារាំងពាក់កណ្ដាលម្នាក់ ហើយមានចំណុចមួយចំនួន គឺយើងអាចមើលឃើញច្បាស់តែម្ដងថា ចំណុចនេះទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីបារាំងខ្លាំង។

ក្រមរដ្ឋប្បវេណីទំនើបរបស់ប្រទេសជប៉ុនត្រូវបានបង្កើតឡើងដំបូងបង្អស់ ដោយនីតិវិទូបរទេសសញ្ជាតិបារាំងឈ្មោះ Gustave Émile Boissonade de Fontarabie ក្រោមការអញ្ជើញរបស់រដ្ឋាភិបាលសម័យម៉ីជិ។ ក្រមរដ្ឋប្បវេណីនេះត្រូវបានចងក្រងតាមលំនាំ**ក្រមរដ្ឋប្បវេណីបារាំង** (ក្រមណាប៉ូឡេអុង ឆ្នាំ1804) ហើយត្រូវបានគេហៅថា **ក្រមរដ្ឋប្បវេណីចាស់** (នៅពេលនោះ ក្រមរដ្ឋប្បវេណីប្រទេសអ៊ីតាលី ជាអាទិ៍ ដែលជាក្រមរដ្ឋប្បវេណីរបស់បណ្ដាប្រទេសនានាដែលយកតាមលំនាំបារាំង និង យុត្តិសាស្ត្រ និង ទ្រឹស្ដីនានានៅក្នុងអំឡុងពេលកន្លះសតវត្សក្រោយការអនុវត្តក្រមរដ្ឋប្បវេណីបារាំងក៏ត្រូវលើកយកមកពិចារណាផងដែរ។ ដោយឡែក ផ្នែកស្ដីពីនីតិគ្រួសារត្រូវបានព្រាងដោយគណៈកម្មការជនជាតិជប៉ុន)។ ក្រមរដ្ឋប្បវេណីចាស់នេះ (ប្រកាសនៅឆ្នាំ1890) ត្រូវបានពន្យារពេលអនុវត្ត ហើយកប់ចោល ដោយសារតែមានវិវាទចម្រូងចម្រាស់អំពីការអនុវត្តក្រមនេះ។ ប៉ុន្តែ គន្ថីទី1 ដល់គន្ថីទី3 នៃក្រមរដ្ឋប្បវេណីជប៉ុនបច្ចុប្បន្ន គឺជាសមទ្ធិផលដែលទទួលបានពីការកែតម្រូវក្រមរដ្ឋប្បវេណីចាស់។ នៅក្នុងពេលកែតម្រូវនោះ គេបានយោងតាមគម្រូនៃសេចក្ដីព្រាងក្រមរដ្ឋប្បវេណីអាឡឺម៉ង់ដែលជាក្រមថ្មីជាងគេបំផុតនៅក្នុងសម័យនោះ ដូចនេះ ទម្រង់នៃការបែងចែងជាគន្ថី គឺយកលំនាំតាមបែបក្រមរដ្ឋប្បវេណីអាឡឺម៉ង់ ហើយខ្លឹមសារវិញ គឺមានមាត្រាជាច្រើនដែលបន្សល់ដដែលតាមក្រមរដ្ឋប្បវេណីចាស់របស់លោក Boissonade។ នៅពេលកែតម្រូវនោះ មានលោក Hozumi Nobushige (ជនជាតិជប៉ុនដំបូងបង្អស់ដែលទទួលបានសញ្ញាប័ត្រប្រកបវិជ្ជាជីវៈមេធាវីនៅសវនាការប្រទេសអង់គ្លេស) លោក Ume Kenjiro និង លោក Tomii Masaaki ដែលធ្លាប់មានបទពិសោធន៍សិក្សានៅប្រទេសបារាំង ទាំង 3នាក់នេះ ជាសមាជិកគណកម្មការរៀបចំសេចក្ដីព្រាង។

## VI. ឋានៈរបស់ក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ទាំងមូល

### 1. ក្រមរដ្ឋប្បវេណីក្នុងនាមជាច្បាប់មូលដ្ឋាននៃនីតិឯកជន

បន្ដទៅនេះ សូមពិនិត្យមើលអំពីឋានៈរបស់ក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ទាំងមូល។ នៅក្នុងពិភពលោកយើងនេះមានច្បាប់ជាច្រើន ប៉ុន្តែ ច្បាប់ដូចជារដ្ឋធម្មនុញ្ញ និង ច្បាប់រដ្ឋបាលជាដើម គឺជាច្បាប់ដែលកំណត់អំពីរបបគ្រប់គ្រងរបស់រដ្ឋ និងទំនាក់ទំនងរបស់រដ្ឋជាមួយបុគ្គល ដែលគេហៅថា នីតិសាធារណៈ។ ផ្ទុយមកវិញ ច្បាប់ដែលបញ្ញត្តឡើងដោយផ្ដោតទៅលើទំនាក់ទំនងជីវភាពរបស់បុគ្គល និង បុគ្គល គឺជា នីតិឯកជន។ លើសពីនេះ នៅក្នុងពិភពច្បាប់ ក្រុមមនុស្សដូចជាក្រុមហ៊ុនជាដើម ត្រូវបានគេហៅថាជានីតិបុគ្គល ក្នុងអត្ថន័យដែលច្បាប់បានប្រដូចសកម្មភាពនោះក្នុងនាមជាបុគ្គល។ ហេតុនេះ ច្បាប់ពាណិជ្ជកម្មជាអាទិ៍ដែលកំណត់អំពីក្រុមហ៊ុន ក៏រាប់បញ្ចូលជា

នីតិឯកជនផងដែរ។ នៅក្នុងវិស័យនីតិឯកជននេះគឺមានច្បាប់ជាច្រើន ប៉ុន្តែ ច្បាប់ដែលជាមូលដ្ឋានចម្បងបំផុត គឺក្រមរដ្ឋប្បវេណី ហើយគេហៅក្រមរដ្ឋប្បវេណីថា ច្បាប់មូលដ្ឋាននៃនីតិឯកជន។

### 2. **ច្បាប់ទូទៅ និង ច្បាប់ពិសេស**

តើច្បាប់ទូទៅ និង ច្បាប់ពិសេស មានអត្ថន័យបែបណា? សូមពិចារណាទាំងអស់គ្នាថា យើងបានសន្យាទិញលក់វត្ថុមួយដោយប្រាក់។ នេះគឺជាកិច្ចសន្យាលក់ទិញដែលមានក្នុងក្រមរដ្ឋប្បវេណី។ ជាបឋម បញ្ញត្តិស្តីពីកិច្ចសន្យាលក់ទិញ គឺមាននៅក្នុងក្រមរដ្ឋប្បវេណី។ ប៉ុន្តែ នៅពេលដែលបុគ្គលនោះគឺជាពាណិជ្ជករ ឬ ក្រុមហ៊ុន និងបានទិញលក់ដើម្បីសកម្មភាពជំនួញវិញ ក្នុងករណីនេះ វាជាកិច្ចសន្យាលក់ទិញដូចគ្នា ប៉ុន្តែ វាក្លាយជាបញ្ហានៃច្បាប់ពាណិជ្ជកម្មវិញម្តង។ មួយវិញទៀត ទោះបីជាអ្នកទិញគឺជាបុគ្គលធម្មតាដូចពួកយើងក៏ដោយ នៅពេលដែលអ្នកលក់បានមកលក់ទំនិញដល់ផ្ទះ ហើយចុះកិច្ចសន្យាលក់ទិញជាមួយយើង ក្នុងករណីនេះ ការទិញលក់ដូចគ្នាក៏ដោយ ក៏ត្រូវក្លាយជាកម្មវត្ថុដែលកំណត់ក្នុងច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្មពិសេស (ហៅថា ច្បាប់ស្តីពីការដើរលក់ទំនិញដល់ទីកន្លែងមុនការធ្វើវិសោធនកម្មឆ្នាំ2000)។ ថ្វីត្បិតតែជាការលក់ទិញដូចគ្នាក៏ដោយ បើសិនជាភាគីគឺជាពាណិជ្ជករ នោះវានឹងក្លាយជាបញ្ហានៃច្បាប់ពាណិជ្ជកម្ម ហើយបើសិនជាការទិញលក់ដោយទម្រង់ដើរលក់ដល់ផ្ទះ នោះវានឹងជាបញ្ហានៃច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្មពិសេស។ ហេតុនេះ ទាក់ទងនឹងការលក់ទិញ ក្រមរដ្ឋប្បវេណីគឺជាច្បាប់ទូទៅចំពោះច្បាប់ពាណិជ្ជកម្ម និង ច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្មពិសេស ហើយច្បាប់ពាណិជ្ជកម្ម និង ច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្មពិសេសគឺជាច្បាប់ពិសេសចំពោះក្រមរដ្ឋប្បវេណី។ ហើយការអនុវត្តច្បាប់ពិសេសដោយមានអាទិភាពជាងច្បាប់ទូទៅ គឺជាវិធានមួយដែលមានអត្ថិភាពនៅក្នុងប្រព័ន្ធច្បាប់ទាំងមូល។ ជាបឋម យើងត្រូវយកច្បាប់ពិសេសមកប្រើ ហើយបើសិនជាច្បាប់ពិសេសមិនមានកំណត់ទេ យើងត្រូវយកបញ្ញត្តិដែលជាគោលការណ៍នៅក្នុងច្បាប់ទូទៅមកប្រើ។ ដូចនេះ នៅក្នុងឧទាហរណ៍ខាងលើនេះក៏ដោយ បើសិនជានៅក្នុងច្បាប់ពាណិជ្ជកម្មពុំមានបញ្ញត្តទេ យើងត្រូវត្រឡប់មកមើលគោលការណ៍ក្នុងក្រមរដ្ឋប្បវេណី។ ហើយជាបឋមត្រូវយកច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្មពិសេសមកអនុវត្ត ហើយផ្នែកដែលច្បាប់នេះពុំមានបញ្ញត្តទេ ត្រូវយកបញ្ញត្តិស្តីពីការលក់ទិញដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីមកអនុវត្ត។ តាមរយៈឧទាហរណ៍នេះ យើងអាចមើលឃើញថា ក្រមរដ្ឋប្បវេណី គឺជាចំណុចចាប់ផ្តើមនៃមូលដ្ឋាន និង គោលគំនិតចម្បងរបស់បទប្បញ្ញត្តិជាច្រើននៅក្នុងវិស័យនីតិឯកជន ក្នុងនាមជាច្បាប់មូលដ្ឋាននៃនីតិឯកជន។ ដូចនេះ យើងអាចនិយាយថា ការសិក្សានីតិឯកជន គឺត្រូវចាប់ផ្តើមសិក្សាពីក្រមរដ្ឋប្បវេណីជាមុន។

សូមបញ្ជាក់ថា ការបកស្រាយខាងលើនេះ មិនមែនមានន័យថា ការសិក្សាមុខវិជ្ជាក្រមរដ្ឋប្បវេណីមានប្រៀបជាងការសិក្សាមុខវិជ្ជាច្បាប់ពាណិជ្ជកម្មជាដើមនោះទេ។ ក្រមរដ្ឋប្បវេណី និង ច្បាប់ពាណិជ្ជកម្មជាអាទិ៍ សុទ្ធតែមានលក្ខណៈពិសេសរៀងៗខ្លួន។ ច្បាប់ពាណិជ្ជកម្មមានលក្ខណៈបច្ចេកទេសខ្លាំងជាងក្រមរដ្ឋប្បវេណី ហើយច្បាប់នេះមានការវិវត្តន៍យ៉ាងច្រើនទៅតាមការអភិវឌ្ឍន៍នៃបែបបទប្រតិបត្តិការពាណិជ្ជកម្ម ប៉ុន្តែ ក្រមរដ្ឋប្បវេណីពុំមានសក្តានុពលបែបនេះទេ។ លើសពីនេះ ក្រមរដ្ឋប្បវេណីដែលមានតួនាទីជាច្បាប់មូលដ្ឋាន គឺជាគោលគំនិតដើមដែលនាំឱ្យ

បង្កើតនូវច្បាប់ពិសេសជាច្រើន ហេតុនេះ ក្រមរដ្ឋប្បវេណីមានចរិកលក្ខណៈដែលមិនងាយប្រែប្រួលញឹកញាប់នោះទេ (ការកែប្រែក្រមរដ្ឋប្បវេណី លុះត្រាតែសង្គមមានការផ្លាស់ប្តូរយ៉ាងខ្លាំងប៉ុណ្ណោះ)។ ដូចនេះ ច្បាប់នីមួយៗតែងមានចរិកលក្ខណៈ និងគោលគំនិតខុសៗគ្នា ដែលចាំបាច់នៅពេលសិក្សា។

## VII. **លក្ខណៈពិសេសនៃក្រមរដ្ឋប្បវេណី**

–គោលការណ៍ស្វ័យភាពនៃឆន្ទៈ (ស្វ័យភាពនៃបុគ្គលឯកជន)

### 1. **គោលការណ៍ស្វ័យភាពនៃឆន្ទៈ និង គោលការណ៍សេរីភាពនៃកិច្ចសន្យា**

បន្តទៅនេះ យើងនឹងបង្ហាញអំពីលក្ខណៈពិសេសដ៏សំខាន់របស់ក្រមរដ្ឋប្បវេណី។ មុននេះ ខ្ញុំបានលើកឡើងថា ក្រមរដ្ឋប្បវេណីផ្តោតសំខាន់បំផុតទៅលើ «ឆន្ទៈ» របស់ភាគីម្នាក់ៗ។ ពោលគឺ ក្រមរដ្ឋប្បវេណីមានគោលគំនិតថា ប្រជាពលរដ្ឋគ្រប់គ្នាមិនត្រូវរស់នៅក្រោមវិធានដែលកំណត់ដោយអ្នកដទៃនោះទេ តែយ៉ាងហោចណាស់ ខ្លួនយើងម្នាក់ៗអាចបង្កើតនូវវិធានតាមឆន្ទៈរបស់ខ្លួនឯង ទៅលើ «ទំនាក់ទំនងនៃជីវភាពរស់នៅរវាងបុគ្គលម្នាក់និងបុគ្គលម្នាក់ទៀត» ហើយមានជីវភាពដោយគោរពតាមវិធានដែលបង្កើតដោយខ្លួនឯង។ នេះហៅថា គោលការណ៍ស្វ័យភាពនៃឆន្ទៈ ឬ គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ ហើយជាក់ស្តែង ការបង្កើតវិធានបានដោយសេរីរបស់បុគ្គលនីមួយៗ (ទំនាក់ទំនងសិទ្ធិលើបំណុល) ដរាបណាមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនៅក្នុងសង្គម ហៅថា «គោលការណ៍សេរីភាពនៃកិច្ចសន្យា»។

លើសពីនេះ វិធាននោះអាចត្រូវបានបង្កើតឡើងដោយសេរី ហើយវិធានទាំងនោះនឹងក្លាយទៅជាច្បាប់ រវាងបុគ្គលដែលបានបង្កើតវិធានទាំងនោះ ពោលគឺ វាក្លាយជាច្បាប់របស់ភាគី ហើយ វិធានទាំងនោះនឹងមានអាទិភាពក្នុងការអនុវត្តជាងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ ឧបមាថា នៅក្នុងកិច្ចសន្យាលក់ទិញមួយ គុណភាពនៃទំនិញដែលបានប្រគល់មកមិនស្របតាមខ្លឹមសារនៃកិច្ចសន្យាជាអាទិ៍ ក្នុងករណីនេះ ក្រមរដ្ឋប្បវេណីបញ្ញត្តថា អ្នកទិញអាចទាមទារឱ្យអ្នកលក់ជួសជុល ឬ ទាមទារវត្ថុជំនួសជាអាទិ៍បាន (ចាប់ពីមាត្រា562។ យ៉ាងណាមិញ នៅក្នុងសៀវភៅនេះនឹងសរសេរតែលេខមាត្រាប៉ុណ្ណោះ ចំពោះការយោងមាត្រាពីក្រមរដ្ឋប្បវេណី។) នេះហៅថា «ការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា» ដែលត្រូវបានកំណត់ដោយវិសោធនកម្មច្បាប់ឆ្នាំ2017 (បញ្ញត្តិពីមុនគឺ «ការទទួលខុសត្រូវជានាវិការៈ)។ ទោះបីជាក្រមបញ្ញត្តបែបនេះក៏ដោយ បើសិនជាភាគីបានសន្យាផ្សេងពីខ្លឹមសារនៃមាត្រាច្បាប់នៅក្នុងកិច្ចសន្យា ក្នុងករណីនេះ ការសន្យានោះនឹងមានអាទិភាពជាង ហើយបញ្ញត្តិនៃក្រមរដ្ឋប្បវេណីយកមកអនុវត្តតែក្នុងករណីដែលគ្មានការសន្យាខាងលើនេះតែប៉ុណ្ណោះ។ បើនិយាយឱ្យងាយស្រួលយល់ទៅ ឧទាហរណ៍ថា ការលក់ទំនិញបញ្ចុះតម្លៃមួយដែលមានផ្លាកបិតថា អាវនេះ «មានកន្លែងសឹក និងរហែកខ្លះ ហើយទិញរួចហើយមិនអាចប្តូរវិញនោះទេ» ហើយបើសិនជាអ្នកទិញបានយល់ព្រមទិញទាំងបានដឹងបែប

នេះ វាមានន័យថា ភាគីបានព្រមព្រៀងគ្នាទិញលក់ដោយ លើកលែងការទទួលខុសត្រូវចំពោះការអនុវត្តមិនស្រប តាមខ្លឹមសារនៃកិច្ចសន្យាខាងលើនេះ។ ការធ្វើកិច្ចសន្យាបែបនេះពុំបង្ករជាបញ្ហាអ្វីទាំងអស់ ហើយមានសុពលភាព ធម្មតា។

## 2. បទប្បញ្ញត្តិស្ម័គ្រចិត្ត និង បទប្បញ្ញត្តិចាប់បង្ខំ

អ្នកអានខ្លះប្រហែលយល់ឃើញថា ប្រសិនបើច្បាប់អាចត្រូវបានបដិសេធដោយឆន្ទៈរបស់ភាគីដូចករណីខាងលើនេះ មានច្បាប់ក៏មិនអាចជួយអ្វីបានដែរ ប៉ុន្តែ ដាច់ខាតវាមិនអាចក្លាយជាបែបនេះទេ។ នៅពេលដែលភាគីបានកំណត់វិធានដោយខ្លួនឯង វិធាននោះនឹងត្រូវយកមកប្រើប្រាស់ ប៉ុន្តែ ចំណុចដែលភាគីមិនបានកំណត់អំពីវិធានជាមុន បញ្ញត្តិរបស់ច្បាប់នឹងត្រូវយកមកប្រើប្រាស់។ ឧទាហរណ៍ថា ភាគីបានកំណត់អំពីតម្លៃ ប៉ុន្តែ ពុំបានកំណត់ថា ភាគីណាត្រូវចេញថ្លៃសេវាដឹកជញ្ជូន ឬក៏ វិធីដោះស្រាយក្នុងករណីដែលទំនិញនោះមានវិការៈបន្តិចបន្តួចដែលមិនបានចាប់អារម្មណ៍ជាដើម។ នៅក្នុងករណីបែបនេះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកប្រើប្រាស់ក្នុងទម្រង់ជាការបំពេញបន្ថែមលើឆន្ទៈរបស់ភាគី។

ដូចនេះ បញ្ញត្តិដែលផ្តល់អាទិភាពនៃការអនុវត្តដល់ឆន្ទៈរបស់ភាគីជាងខ្លឹមសារនៃមាត្រាច្បាប់ ហៅថា បញ្ញត្តិស្ម័គ្រចិត្ត។ ផ្ទុយមកវិញ បញ្ញត្តិដែលមានខ្លឹមសារដែលភាគីមិនអាចផ្លាស់ប្តូរបាន បើទោះបីជាមានការព្រមព្រៀងយ៉ាងណាក៏ដោយ ហៅថា បញ្ញត្តិដែលចាប់បង្ខំ។ នីតិសិទ្ធិលើបំណុលនៅក្នុងក្រមរដ្ឋប្បវេណី គឺសម្បូរទៅដោយបញ្ញត្តិស្ម័គ្រចិត្ត។ ជាការពិតណាស់នៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ចំពោះបញ្ញត្តិស្តីពីប្រភេទនៃសិទ្ធិប្រត្យក្សជាដើម ដោយសារតែសិទ្ធិប្រត្យក្សមានលក្ខណៈផ្តាច់មុខចំពោះវត្ថុ ពោលគឺ សិទ្ធិគ្រប់គ្រងដាច់ខាតទៅលើវត្ថុដែលអាចអះអាងចំពោះបុគ្គលទាំងអស់នៅក្នុងពិភពលោកនេះបាន ហើយសិទ្ធិដែលមានអានុភាពខ្លាំងបែបនេះ បើសិនជាយើងអាចបង្កើតបានតាមទំនើងចិត្ត វានឹងបង្កបញ្ហាដល់អ្នកជុំវិញខ្លួន ហេតុនេះហើយ សិទ្ធិបែបនេះមិនអាចត្រូវបានបង្កើតខុសពីខ្លឹមសារនៃមាត្រាច្បាប់ដោយឆន្ទៈយើងគ្រប់ៗគ្នាឡើយ (នេះហៅថា «គោលការណ៍សិទ្ធិប្រត្យក្សតាមការកំណត់របស់ច្បាប់»។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកជាច្រើននៅក្នុងនីតិសិទ្ធិលើបំណុល ដែលមានសរសេរនៅក្នុងច្បាប់ពុំមែនជាបញ្ញត្តិដែលត្រូវគោរពដាច់ខាតនោះទេ។

ចំណុចខាងលើនេះ គឺជាចំណុចដែលខុសគ្នាដាច់ស្រឡះជាមួយច្បាប់ដូចជា ក្រមព្រហ្មទណ្ឌ និង ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកជាដើមដែលស្ថិតនៅក្នុងវិស័យច្បាប់សាធារណៈ។ ឧទាហរណ៍ ច្បាប់ចរាចរណ៍កំណត់ថា ពណ៌ក្រហមត្រូវឈប់ ហើយ ពណ៌បៃតងត្រូវបន្តដំណើរ ក្នុងករណីនេះ បើសិនជាប្រជាពលរដ្ឋទាំងអស់ពុំគោរពតាមដាច់ខាតនោះទេ សណ្តាប់ធ្នាប់ចរាចរណ៍នឹងពុំអាចគ្រប់គ្រងបាន ហើយគ្រោះថ្នាក់ចរាចរណ៍ប្រាកដជាកើតមានឡើងជាច្រើន។ ពោលគឺ យើងពុំអាចកំណត់តាមទំនើងចិត្តខ្លួនឯងថា ពណ៌ក្រហមត្រូវបន្តដំណើរ ហើយពណ៌បៃតងត្រូវឈប់នោះទេ។ ប៉ុន្តែ ចំពោះករណីនីតិសិទ្ធិលើបំណុលនៅក្នុងក្រមរដ្ឋប្បវេណី ពុំមែនជាការ «មិនគោរពច្បាប់នោះទេ» ប៉ុន្តែ វាជាបរិបទដែល «វិធានដែលភាគីបានបង្កើតមានអានុភាពខ្លាំងជាងច្បាប់» ទៅលើករណីមួយចំនួន។

ចំពោះភាពពាក់ព័ន្ធគ្នារវាងបុគ្គល និង ច្បាប់ មិនមែនច្បាប់មានឋានៈខ្ពស់ហើយត្រូវតែគោរពដាច់ខាតនោះទេ ប៉ុន្តែ វាមានន័យថា ជាការគាំពារយ៉ាងទូលាយដល់សេរីភាពនៃការបង្កើតវិធានដោយឆន្ទៈរបស់បុគ្គលខ្លួនឯងម្នាក់ ហើយនៅពេលដែលបុគ្គលមិនបានកំណត់អំពីវិធាននោះទេ ក្រមរដ្ឋប្បវេណីដើរតួជាការបំពេញបន្ថែម។

នេះជា លក្ខណៈពិសេសបំផុតរបស់ក្រមរដ្ឋប្បវេណី (នីតិសិទ្ធិលើបំណុល)។ ពិតហើយថា សេរីភាពនៃការបង្កើតវិធានដោយសេរីនេះ គឺជាសេរីភាពនៅក្នុងពិភពដ៏តូចមួយ ដូចជា រវាងភាគីនៃកិច្ចសន្យាជាដើម។ ទោះបីជានៅក្នុងពិភពដ៏តូចនេះក៏ដោយ ក៏ក្នុងពេលថ្មីៗនេះ គេបានបញ្ចូលនូវការកែតម្រូវចំពោះគោលការណ៍មួយចំនួនដើម្បីជានាសមភាពរបស់បុគ្គលនីមួយៗ (ការកម្រិតគោលការណ៍សេរីភាពនៃកិច្ចសន្យា)។ យ៉ាងណាមិញ ចំពោះចំណុចដែលច្បាប់ត្រូវដើរតួជាការបំពេញបន្ថែមចំពោះវិធានដែលបង្កើតដោយបុគ្គល នៅក្នុងគោលគំនិតដើមនេះ សូមអ្នកទាំងអស់គ្នាចងចាំទុកឱ្យបាន នៅពេលដែលសិក្សាអំពីក្រមរដ្ឋប្បវេណី។

## VIII. សេចក្តីសង្ខេប – គោលគំនិតក្នុងការសិក្សាក្រមរដ្ឋប្បវេណី

ក្រមរដ្ឋប្បវេណី ក៏មានភាពជាវិធានគតិយុត្តក្នុងនាមជាច្បាប់មួយផងដែរ។ ពោលគឺ មានផ្នែកដែលជា «ខ្លឹមសារស្នូល»។ ប៉ុន្តែ ភាពជាវិធាននេះពុំមានច្រើននោះទេ បើប្រៀបធៀបជាមួយច្បាប់ផ្សេងៗជាច្រើនទៀត។ ផ្នែកស្តីពីបទប្បញ្ញត្តិទូទៅ និង នីតិសិទ្ធិប្រត្យក្ស គឺមានអត្ថន័យយ៉ាងធំធេងក្នុងនាមជាវិធានគតិយុត្ត ប៉ុន្តែ ផ្នែកស្តីពីកិច្ចសន្យានៃនីតិសិទ្ធិលើបំណុលវិញ អាចនិយាយបានថាគឺជាបញ្ញត្តិមួយដែលបានចងក្រងតាមទម្លាប់នៅក្នុងកិច្ចសន្យាជំនួញដែលគេអនុវត្តតាំងពីដើមមក សម្រាប់ឱ្យភាគីយកជាមូលដ្ឋានសម្រាប់សម្រេចចិត្តក្នុងការបង្ហាញឆន្ទៈរបស់ខ្លួនប៉ុណ្ណោះ។ មានន័យថា បើសិនជាឆន្ទៈរបស់ភាគីមានភាពច្បាស់លាស់ គេនឹងគោរពតាមឆន្ទៈនោះ ប៉ុន្តែ បើសិនជាឆន្ទៈមិនច្បាស់លាស់នោះទេ គេនឹងយកបញ្ញត្តិដែលត្រូវបានចងក្រងឡើងក្នុងនាមជាឆន្ទៈរបស់ភាគីជាទូទៅមកអនុវត្ត។ ត្រង់នេះហើយទើបគេមិនធ្វើជាវិធានចាប់បង្ខំនោះ។

លើសពីនេះ នៅក្នុងវិសោធនកម្មច្បាប់ឆ្នាំ2017 បានបង្ហាញអំពីគោលគំនិតដើមស្តីពី អានុភាពចងចំពោះឆន្ទៈ ពោលគឺ គេផ្តល់សារៈសំខាន់ដល់ខ្លឹមសារនៃការសន្យារបស់ភាគី ហើយរៀបចំកែសម្រួលច្បាប់ឱ្យមានភាពសមស្របតាមឆន្ទៈរបស់ភាគី។

ដូចនេះ ខ្ញុំសូមនិយាយថា ចំណុចសំខាន់ក្នុងការសិក្សាក្រមរដ្ឋប្បវេណី មិនមែនជា «ការចងចាំអំពីវិធានដែលត្រូវគោរពនោះទេ» ប៉ុន្តែ ជា «ការពិចារណាអំពីអត្ថន័យនៃវិធានដែលក្រមរដ្ឋប្បវេណីបានបង្ហាញ ក្នុងនាមជាស្តង់ដាសម្រាប់វាស់នូវសមភាពរបស់ភាគី»។

ការពន្យល់អំពីលំនាំសិក្សាត្រូវបញ្ចប់ត្រឹមនេះ។ បន្តទៅនេះ យើងនឹងចាប់ផ្តើមសិក្សាអំពីខ្លឹមសារនៃក្រមរដ្ឋប្បវេណី។

យ៉ាងណាមិញ នៅក្នុងការបោះពុម្ពលើកទី6នៃសៀវភៅនេះ នឹងយកមាត្រានៃក្រមរដ្ឋប្បវេណីដែលជាខ្លឹមសារនៃវិសោធនកម្មច្បាប់ដែលត្រូវអនុវត្តនៅថ្ងៃទី1 ខែមេសា ឆ្នាំ2020 ធ្វើជាគោលការណ៍។

# ជំពូកទី២

# បទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី

I. **ចរិតលក្ខណៈនៃបទប្បញ្ញត្តិទូទៅ និង លំដាប់នៃការសិក្សា**

II. **ចំពោះការសិក្សាបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី**

1. ចំណុចសំខាន់ៗនៃបទប្បញ្ញត្តិទូទៅ និង វិធីសាស្ត្រសិក្សា
2. បញ្ញត្តិដំបូងនៃបទប្បញ្ញត្តិទូទៅ

III. **ការសិក្សាចំណុចសំខាន់ៗក្នុងបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី**

1. ការបង្ហាញឆន្ទៈ និងសកម្មភាពគតិយុត្ត
2. ការការពារជនដែលត្រូវបានកម្រិតសមត្ថភាព
3. ការបង្ហាញឆន្ទៈប្រកបដោយបញ្ហា
4. ការតំណាង ការតំណាងដោយគ្មានសិទ្ធិ ការតំណាងដែលមានលក្ខណៈជារូបភាព
5. មោឃភាព និង ការលុបចោល
6. លក្ខខណ្ឌ និង ការកំណត់ពេល
7. អាជ្ញាយុកាល
8. នីតិបុគ្គល
9. លំនៅឋាន និង ការបាត់ខ្លួន

## I. ចរិតលក្ខណៈនៃបទប្បញ្ញត្តិទូទៅ និង លំដាប់នៃការសិក្សា

នៅក្នុងជំពូកមុន ខ្ញុំបានរៀបរាប់អំពីរចនាសម្ព័ន្ធរបស់ក្រមរដ្ឋប្បវេណី និងបានពន្យល់ថា ក្រមរដ្ឋប្បវេណីជប៉ុន បានបែងចែកជា 5 គន្ថី ដែលមាន បទប្បញ្ញត្តិទូទៅ សិទ្ធិប្រត្យក្ស សិទ្ធិលើបំណុល ញាតិ និង សន្តតិកម្មរួចហើយ។ នៅក្នុងចំណោមគន្ថីទាំង 5 នេះ តាមវិធីហៅនៅក្នុងបរិបទសិក្សា គន្ថីទី1~3 គេហៅថា នីតិទ្រព្យសម្បត្តិ ហើយគន្ថីទី4~5 គេហៅថា នីតិគ្រួសារ ឬ នីតិឋានៈបុគ្គល។ ដោយឡែក បើមើលទៅលើចំណងជើង យើងប្រហែលជាអាចយល់ថា បទប្បញ្ញត្តិទូទៅគឺជាវិធានរួមនៃក្រមរដ្ឋប្បវេណីទាំងមូល ប៉ុន្តែ ខ្លឹមសារជាក់ស្តែង គឺជាចំណុចដែលទាក់ទងនឹងសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុលនៅក្នុងគន្ថីបន្ទាប់ទាំងពីរប៉ុណ្ណោះ ហេតុនេះ ខ្ញុំក៏បានបកស្រាយរួចហើយថា បទប្បញ្ញត្តិទូទៅនេះគួរតែមើលថាជាវិធានរួមនៃនីតិទ្រព្យសម្បត្តិទើបសមស្រប។ ដូច្នេះ ខ្ញុំយល់ថាក្នុងលំដាប់នៃការសិក្សាក៏ដោយ ក៏គួរតែសិក្សាចាប់ពីបទប្បញ្ញត្តិទូទៅ (នៅក្នុងសៀវភៅសិក្សាផ្សេងៗ គេហៅថា «បទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី»)នេះទៅមុន ទើបសមហេតុផល។ ម្យ៉ាងទៀត ជាក់ស្តែងនៅតាមមហាវិទ្យាល័យជាច្រើន ក៏បានរៀបចំកម្មវិធីសិក្សាស្របតាមលំដាប់នេះដែរ ប៉ុន្តែ បញ្ហាដែលលំបាកមួយគឺ ក្រមរដ្ឋប្បវេណីមិនគួរឱ្យចាប់អារម្មណ៍ទេ បើសិនជាចាប់ផ្តើមសិក្សាពីបទប្បញ្ញត្តិទូទៅមុន។ ខ្ញុំផ្ទាល់ក៏ធ្លាប់មានអារម្មណ៍បែបនេះនៅពេលដែលខ្ញុំជានិស្សិតនៅឡើយ ហើយបច្ចុប្បន្ននេះក៏ដោយ ក៏មាននិស្សិតមិនតិចទេដែលបានលើកឡើងអំពីអារម្មណ៍បែបនេះ។ រឿងនេះមិនមែនជារឿងដែលគ្មានហេតុផលនោះទេ។

នៅក្នុងជំពូកមុន ខ្ញុំបានរៀបរាប់រួចហើយថា ការបែងចែកគន្ថី ដោយយកបទប្បញ្ញត្តិទូទៅដាក់នៅខាងដើម គឺជាប្រព័ន្ធPandekten ហើយ វាគឺជាទម្រង់ដែលយកតាមក្រមរដ្ឋប្បវេណីអាឡឺម៉ង់(បើមើលឱ្យត្រឹមត្រូវ គឺសេចក្តីព្រាងនៃក្រមរដ្ឋប្បវេណីអាឡឺម៉ង់)។ នៅចុងឆ្នាំ ១៨៨៧ ក្នុងពេលដែលក្រមរដ្ឋប្បវេណីបច្ចុប្បន្នជប៉ុន (ជាការកែសម្រួលលើក្រមរដ្ឋប្បវេណីចាស់ Gustave Émile Boissonade de Fontarabie) ត្រូវបានតាក់តែងឡើង ជប៉ុនបានយកលំនាំតាមប្រព័ន្ធនៃការបែងចែកជាគន្ថីនៃសេចក្តីព្រាងក្រមរដ្ឋប្បវេណីអាឡឺម៉ង់ ដែលជាក្រមរដ្ឋប្បវេណីទំនើបបំផុតក្នុងសម័យនោះ (ប៉ុន្តែដូចខ្ញុំបានរៀបរាប់ក្នុងជំពូកមុនរួចហើយថា ខ្លឹមសារនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនមិនដូចគ្នាទាំងស្រុងជាមួយនឹងក្រមរដ្ឋប្បវេណីនៃប្រទេសអាឡឺម៉ង់នោះទេ ហើយជារួម យើងអាចនិយាយថា ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនទទួលឥទ្ធិពលស្មើរតែពាក់កណ្តាលម្នាក់ ពីក្រមរដ្ឋប្បវេណីអាឡឺម៉ង់ និង ក្រមរដ្ឋប្បវេណីបារាំង ហើយមានផ្នែកខ្លះគឺអាចមើលឃើញច្បាស់តែម្តងថា ផ្នែកនោះទទួលឥទ្ធិពលខ្លាំងពីក្រមរដ្ឋប្បវេណីបារាំង)។ ប្រព័ន្ធដែលដាក់វិធានរួមនៅខាងដើមនេះ គឺពិតជាមានលក្ខណៈសមហេតុសមផល ប៉ុន្តែ បើសិនជាយើងចាប់ផ្តើមសិក្សាអំពីបទប្បញ្ញត្តិទូទៅនេះមុនគេ វាបានសេចក្តីថា យើងចាប់ផ្តើមសិក្សាវិធានរួមទាំងមិនទាន់ចេះវិភាគរឿងក្តីជាក់ស្តែងនីមួយៗនៅឡើយ ហេតុនេះ យើងនឹងមានអារម្មណ៍ហាក់បីដូចជាត្រូវបានបង្ខំឱ្យសិក្សាពីការបកស្រាយមានលក្ខណៈអរូបី ហើយមិនផ្សារភ្ជាប់ជាមួយរឿងជាក់ស្តែង។

មានមតិមួយលើកឡើងថា ដើម្បីជៀសវាងនូវបញ្ហាខាងលើ នៅក្នុងជំពូកដំបូង គួរចាប់ផ្តើមសិក្សាពីផ្នែកកិច្ចសន្យា (ពោលគឺ នីតិសិទ្ធិលើបំណុល) ដែលជាដើមហេតុនៃការកកើតទំនាក់ទំនងសិទ្ធិជាក់ស្តែង ហើយជាផ្នែកដែលមានលក្ខណៈពិសេសនៃក្រមរដ្ឋប្បវេណីជាងគេ ទើបការសិក្សាអាចទទួលអារម្មណ៍ពិតជាក់ស្តែង និង ងាយស្រួលយល់។ មានន័យថា ចាប់ផ្តើមសិក្សាអំពីកិច្ចសន្យាលក់ទិញដែលជាការទិញ ឬ ការលក់វត្ថុ បណ្តើរ ហើយឈានទៅសិក្សាបន្តិចម្តងៗ អំពីខ្លឹមសារនៃបញ្ញត្តិដែលជាបទប្បញ្ញត្តិទូទៅរួមនៃសិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្ស។ ទោះបីជាបែបនេះក៏ដោយ ជាឧទាហរណ៍ មុខវិជ្ជាទាក់ទងនឹងក្រមរដ្ឋប្បវេណី ទាំងក្នុងមហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យសេដ្ឋកិច្ច ឬ មហាវិទ្យាល័យពាណិជ្ជកម្មនៅតាមសាកលវិទ្យាល័យ ភាគច្រើនយកបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីជាផ្នែកទី1 នៃមុខវិជ្ជាក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះហើយ បើសិនជានិស្សិតទាំងឡាយពីមហាវិទ្យាល័យទាំងនេះ ចង់សិក្សាក្រមរដ្ឋប្បវេណីស្របតាមកម្មវិធីសិក្សា គឺគួរតែសិក្សាចាប់ពីបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ទើបមានការខាតបង់តិចបំផុត។ ដូចនេះ ក្នុងជំពូកនេះ ខ្ញុំនឹងព្យាយាមពន្យល់ដោយផ្តោតសំខាន់ថា តើយើងគួរសិក្សាដោយយកចិត្តទុកដាក់នៅកន្លែងណា ហើយត្រូវប្រើវិធីសាស្ត្របែបណា ទើបងាយស្រួលយល់ជាងមុន និង កាន់តែគួរឱ្យចាប់អារម្មណ៍ជាងមុន ក្នុងករណីដែលយើងសិក្សាក្រមរដ្ឋប្បវេណីដោយចាប់ផ្តើមចេញពីបទប្បញ្ញត្តិទូទៅមុន។

ចំណុចសំខាន់មាន 2។ ទី1 គឺយើងគិតបញ្ច្រាសពីអ្វីដែលបានសរសេរខាងលើ មានន័យថា យើងជានិច្ចកាលនឹកគិតអំពីឧទាហរណ៍ជាក់ស្តែងបណ្តើរ ហើយសិក្សាបណ្តើរ។ ទី2 គឺយើងត្រូវសិក្សា ដោយស្វែងយល់ថា តើវិធានរួមទាំងអស់នេះ មានអត្ថន័យបែបណា និង មានឋានៈយ៉ាងណា? នៅក្នុងក្រមរដ្ឋប្បវេណីទាំងមូល។ ប៉ុន្តែ តាមពិតទៅ សៀវភៅសិក្សាអំពីបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីដែលសរសេរឡើង ដោយមានការចាប់អារម្មណ៍អំពីចំណុចទាំង 2 ខាងលើនេះ មានមិនច្រើននោះទេ។ ហេតុដូច្នេះជាបន្តទៅទៀត ខ្ញុំនឹងបង្ហាញឱ្យច្បាស់អំពី លំដាប់នៃការសិក្សា និង កម្រិតនៃភាពចាំបាច់ជាដើម នៅក្នុងការសិក្សាបទប្បញ្ញត្តិទូទៅ ដោយសាកល្បងបកស្រាយដោយចាប់អារម្មណ៍អំពីចំណុចទាំង 2 ខាងលើនេះ។ ជាក់ស្តែង ខ្ញុំនឹងពន្យល់ដោយព្យាយាមលើកយកឧទាហរណ៍អំពីកិច្ចសន្យាលក់ទិញ នៅក្នុងបរិបទភាគច្រើន។

## II. ចំពោះការសិក្សាបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី

### 1. ចំណុចសំខាន់ៗនៃបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី និង វិធីសាស្ត្រសិក្សា

ខ្ញុំសូមរំលឹកឡើងវិញអំពី ការរៀបរាប់ក្នុងជំពូកទី1 ស្តីពីលំនាំសិក្សា។ ក្រមរដ្ឋប្បវេណី ផ្តោតសំខាន់បំផុតលើស្វ័យភាពនៃឆន្ទៈរបស់យើងម្នាក់ៗ។ ហេតុនេះ នៅក្នុងចំណោមបញ្ញត្តិទាំងឡាយនៃបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ទី1 យើងនឹងសិក្សា «សមត្ថភាពក្នុងការបង្ហាញឆន្ទៈ» ដែលបុគ្គលទូទៅមាន និង «សមត្ថភាពដែលអាចធ្វើសកម្មភាពដែលកើតឡើងនៅក្នុងទំនាក់ទំនងគតិយុត្តរវាងបុគ្គលម្នាក់ៗ»។ ហេតុដូច្នេះហើយ ចំពោះជនដែលគ្មាន

សមត្ថភាពវិនិច្ឆ័យដោយខ្លួនឯងបាន ក្រមរដ្ឋប្បវេណីមានវិធានការដើម្បីការពារជនដែលគ្មានសមត្ថភាពវិនិច្ឆ័យដោយខ្លួនឯងនោះ ដោយឱ្យអ្នកណាម្នាក់ជួយបំពេញការបង្ហាញឆន្ទៈនោះ។

ទី2 យើងនឹងសិក្សាអំពី បញ្ហានានាដែលកើតមានឡើងនៅពេលដែលបុគ្គលមានសមត្ថភាពវិនិច្ឆ័យដោយខ្លួនឯង បានបង្ហាញឆន្ទៈភ្ជាប់ទំនាក់ទំនងគតិយុត្ត។ នេះគឺជាផ្នែកដែលសំខាន់បំផុត នៅក្នុងបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី។ មានន័យថា ផ្នែកនេះមានបញ្ញត្តិអំពី សកម្មភាពគតិយុត្ត ដែលជាសកម្មភាពបង្កើតអានុភាពគតិយុត្តស្របតាមគោលបំណងនៃឆន្ទៈ ដោយអំណាចនៃការបង្ហាញឆន្ទៈ និងបញ្ញត្តិអំពី ការដោះស្រាយបញ្ហាដែលកើតមានឡើង ក្នុងករណីដែលបុគ្គលមានសមត្ថភាពវិនិច្ឆ័យដោយខ្លួនឯង បានបង្ហាញឆន្ទៈខុស (ការភាន់ច្រឡំ) ឬបានបង្ហាញឆន្ទៈខុសពីឆន្ទៈដើម ដោយសារតែត្រូវបានគេបោកប្រាស់ (ការឆបោក) (ឧទាហរណ៍ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពី អានុភាពដែលរួមមាន មោឃភាព និង ការលុបចោលជាអាទិ៍ ក្នុងនាមជាវិធីដោះស្រាយបញ្ហា។ ដោយឡែក ពាក្យថា «អានុភាព» ដែលប្រើក្នុងក្រមរដ្ឋប្បវេណីជាដើម គឺសំដៅទៅលើលទ្ធផលអ្វីមួយ ដែលកើតឡើងតាមរយៈការប្រើប្រាស់បញ្ញត្តិ ឬ ប្រព័ន្ធច្បាប់ណាមួយ ហើយវាមិនមានន័យថាប្រសិទ្ធភាពទេ)។ លើសពីនេះផ្នែកនេះក៏មានបញ្ញត្តអំពី ការបង្ហាញឆន្ទៈជំនួសដោយបុគ្គលក្រៅពីខ្លួនឯង ដែលជាប្រព័ន្ធនៃការតំណាងដែរ។

ទី3 យើងនឹងសិក្សាអំពីបញ្ហានៃអាជ្ញាយុកាល។ អាជ្ញាយុកាលកើតមានទាំងនៅលើសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានកំណត់អំពីអាជ្ញាយុកាលរួមគ្នានៅក្នុងបទប្បញ្ញត្តិទូទៅ។ ហើយ ទី4 យើងនឹងសិក្សាអំពីបញ្ហានៃនីតិបុគ្គល។ តាមពិតទៅ ចំណុចនៃនីតិបុគ្គលនេះ គឺជាចំណុចមានបញ្ហាស្មុគស្មាញខ្លាំងនៅក្នុងបទប្បញ្ញត្តិទូទៅ ហេតុនេះ ខ្ញុំយល់ថា និស្សិតនៃមហាវិទ្យាល័យច្បាប់ទូទៅក៏ដោយ ក៏គួរតែសិក្សាអំពីបទប្បញ្ញត្តិទូទៅនេះក្រោយគេ។ ប៉ុន្តែ នៅក្នុងមហាវិទ្យាល័យសេដ្ឋកិច្ច ឬ មហាវិទ្យាល័យពាណិជ្ជកម្ម មានសិក្សាអំពីសហគ្រាស ហើយជនដទៃទៀតដែលមានចំណាប់អារម្មណ៍ខ្លាំងទៅលើច្បាប់ស្ដីពីទំនាក់ទំនងពាណិជ្ជកម្មវិញប្រហែលជាឆាប់យល់អំពីផ្នែកនេះជាងនិស្សិតនៃមហាវិទ្យាល័យច្បាប់ទៅទៀត។ ខ្ញុំយល់ថា ចំណុចនេះមានទំនាក់ទំនងជាមួយការសិក្សានាពេលអនាគតផងដែរ ហេតុនេះ ទោះបីជាសិក្សាចំនុចនេះនៅពេលក្រោយក៏ដោយ គឺត្រូវសិក្សាឱ្យបានហ្មត់ចត់។

## 2. បញ្ញត្តិដំបូងនៃបទប្បញ្ញត្តិទូទៅ

ក្រោយពីចងចាំអំពីចំណុចសំខាន់ៗសម្រាប់សិក្សាដែលបានរៀបរាប់ខាងលើរួចហើយ ខ្ញុំនឹងពន្យល់ដោយសង្ខេបអំពី បញ្ញត្តិដែលមានចែងដំបូងបំផុតនៅក្នុងបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ពោលគឺមាត្រា1 និង មាត្រា2 នៃក្រមរដ្ឋប្បវេណី។ នៅក្នុងចំណុចនេះមានកំណត់អំពី បញ្ញត្តិមានលក្ខណៈទ្រឹស្ដី និងបញ្ញត្តិមានលក្ខណៈមូលដ្ឋាន និង បញ្ញត្តិមានលក្ខណៈទូទៅដែលត្រូវយកមកអនុវត្ត នៅក្នុងករណីដែលបញ្ញត្តិដទៃទៀតមិនអាចដោះស្រាយដាច់ស្រឡះដោយឯកឯងបាន។ បញ្ញត្តិមានលក្ខណៈទ្រឹស្ដីដែលបានលើកឡើងមុននេះ (មាត្រា1 កថាខណ្ឌទី1 បញ្ញត្តថា «សិទ្ធិឯកជនត្រូវតែសមស្របទៅតាមសុខុមាភាពសាធារណៈ» និង មាត្រា2 បញ្ញត្តថា «ក្រមនេះ ត្រូវបកស្រាយ

ដោយគោរពគោលការណ៍នៃសេចក្ដីថ្លៃថ្នូររបស់បុគ្គល និង ភាពស្មើគ្នារបស់បុគ្គលទាំងពីរភេទ») មានសារៈសំខាន់ ប៉ុន្តែ ពុំសូវទាក់ទងនឹងការបកស្រាយជាក់ស្ដែងនោះទេ។ ដោយឡែក «សិទ្ធិឯកជន ត្រូវតែសមស្របទៅតាមសុខមាលភាពសាធារណៈ» គឺសំដៅទៅលើការទទួល និង ការអនុវត្តសិទ្ធិដោយសេរីរបស់បុគ្គលឯកជន ត្រូវតែសម្របទៅនឹងការរីកចម្រើនដ៏ត្រឹមត្រូវរបស់សង្គម ប៉ុន្តែ វាមិនមានន័យថា អំណាចសាធារណៈអាចកម្រិតសិទ្ធិរបស់បុគ្គលឯកជនជាអាទិ៍នោះទេ។ ហើយមាត្រា2 គឺជាបញ្ញត្តិជាក់ស្ដែង។

រីឯបញ្ញត្តិមានលក្ខណៈទូទៅរួមមាន មាត្រា1 កថាខណ្ឌទី2 **គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់** និងមាត្រា1 កថាខណ្ឌទី3 **គោលការណ៍ប្រើប្រាស់សិទ្ធិដោយបំពាន** (បញ្ញត្តិទាំងនេះហៅថា «**មាត្រាទូទៅ**»)។ នៅក្នុងការបកស្រាយជាក់ស្ដែង បញ្ញត្តិនេះត្រូវយកមកអនុវត្តជាមធ្យោបាយសម្របសម្រួលចុងក្រោយដើម្បីដោះស្រាយបញ្ហា ក្នុងករណីដែលបញ្ញត្តិជាក់ស្ដែងនីមួយៗមិនអាចដោះស្រាយបានដាច់ស្រឡះ (យើងអាចលើកជាឧទាហរណ៍បានដូចជា «ការប្រើប្រាស់មធ្យោបាយគតិយុត្តនៅក្នុងស្ថានភាពបែបនេះមិនត្រូវបានអនុញ្ញាតទេ ដោយសារផ្ទុយនឹងគោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់» ឬ «ការប្រើប្រាស់សិទ្ធិមួយនេះនៅក្នុងស្ថានភាពបែបនេះមិនត្រូវបានអនុញ្ញាតទេ ដោយសារវាជាការប្រើសិទ្ធិដោយបំពាន» ជាដើម)។ ជាពិសេសនៅក្នុងការអនុវត្តជាក់ស្ដែង គោលការណ៍នៃសុចរិភាព (គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់) ត្រូវយកមកប្រើជាញឹកញាប់ ហើយវាមានបង្កប់បញ្ហាសំខាន់ថា តើយើងគួរពឹងផ្អែកទៅលើ «មាត្រាទូទៅ» បែបនេះដល់កម្រិតណានៅក្នុងបច្ចេកទេសគតិយុត្ត ជាដើម ប៉ុន្តែ នៅទីនេះ សូមស្វែងយល់ដោយត្រួសៗជាមុនសិន។

ដោយឡែក មាត្រា1 និង មាត្រា2 ខាងលើ ត្រូវបានដាក់បន្ថែមជាលើកដំបូងនៅក្នុងគន្ថីស្ដីពីបទប្បញ្ញត្តិទូទៅ នៅពេលវិសោធនកម្មគន្ថីទី4 និងគន្ថីទី5 ទាំងស្រុងនៃក្រមរដ្ឋប្បវេណីនៅឆ្នាំ1947។ ពេលនោះ គេបានបែងចែកជាមាត្រា1 និងមាត្រា1 ភាគ2 ប៉ុន្តែ ត្រូវបានកែប្រែមកមាត្រា1 និង មាត្រា2 វិញ នៅពេលវិសោធនកម្ម តាមរយៈការធ្វើទំនើបកម្មពាក្យពេចន៍នៅក្នុងឆ្នាំ2004 (ការបន្ថែមទៅជាមាត្រា1 ភាគ2 នេះ ធ្វើឡើងដើម្បីជៀសវាងការផ្លាស់ប្ដូរលេខមាត្រាទាំងមូល ដោយសារតែការបន្ថែមមាត្រាថ្មី ហេតុនេះហើយ គេតែងដាក់លេខមាត្រាបែបនេះ (ហៅថា «សាខាលេខ») នៅក្នុងករណីបន្ថែមមាត្រា។ ហើយ មាត្រា1 នៃក្រមរដ្ឋប្បវេណីដែលត្រូវបានអនុម័តដំបូងនៅក្នុងឆ្នាំ1896 ដែលបានចែងថា «សិទ្ធិឯកជនត្រូវចាប់ផ្ដើមមាន នៅពេលចាប់កំណើត» បានក្លាយជាមាត្រា3 កថាខណ្ឌទី1 នៃក្រមរដ្ឋប្បវេណីបច្ចុប្បន្ន)។

## III. ការសិក្សាចំណុចសំខាន់ៗក្នុងបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី

### 1. ការបង្ហាញឆន្ទៈ និង សកម្មភាពគតិយុត្ត

បន្តទៅនេះ ខ្ញុំនឹងបង្ហាញតាមលំដាប់លំដោយនៃចំណុចសំខាន់ៗដែលត្រូវសិក្សានៅក្នុងបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ដោយគោរពតាមលំនាំសិក្សាដែលបានរៀបរាប់ខាងលើនេះ (ប៉ុន្តែ វាអាចខុសបន្តិចបន្តួចទៅនឹងលំដាប់លេខរៀងនៃមាត្រា)។

#### (1) ការបង្ហាញឆន្ទៈ

ជាដំបូង យើងនឹងសិក្សាអំពី «ការបង្ហាញឆន្ទៈ» ដែលជាពាក្យពេចន៍ដែលត្រូវបានប្រើប្រាស់ យ៉ាងញឹកញាប់បំផុតនៅក្នុងក្រមរដ្ឋប្បវេណី។ ការបង្ហាញឆន្ទៈគឺជាការប្រាប់ ពោលគឺបង្ហាញអំពីឆន្ទៈរបស់ខ្លួនទៅភាគីម្ខាងទៀត ក្នុងគោលបំណងបង្កើតទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ។ នៅក្នុងចំណុចនេះ សូមអ្នកទាំងអស់គ្នាចងចាំថា ការបង្ហាញឆន្ទៈដែលមានន័យក្នុងក្រមរដ្ឋប្បវេណី គឺជាការបង្ហាញឆន្ទៈដែលនាំឱ្យមានអានុភាពគតិយុត្ត ក្នុងការបង្កើតនូវទំនាក់ទំនងគតិយុត្ត ស្របតាមឆន្ទៈដែលបានបង្ហាញចេញមកប៉ុណ្ណោះ ហេតុនេះ រាល់ការប្រាប់អំពីអ្វីដែលខ្លួនគិតទាំងអស់ទៅកាន់ភាគីម្ខាងទៀត មិនអាចក្លាយទៅជាការបង្ហាញឆន្ទៈក្នុងន័យតាមក្រមរដ្ឋប្បវេណីទាំងអស់នោះទេ។ ឧទាហរណ៍ យើងចង់ប្រាប់ពាក្យពេចន៍ដែលបង្ហាញពីអារម្មណ៍ស្រលាញ់របស់ខ្លួនទៅកាន់សង្សារ។ ទោះបីជាយើងបានសម្រេចចិត្តយ៉ាងច្បាស់លាស់ ហើយបាននិយាយចេញពីមាត់ក៏ដោយ ក៏ការប្រាប់ពាក្យពេចន៍ទាំងនោះ មិនមែនជាការបង្ហាញឆន្ទៈក្នុងន័យក្រមរដ្ឋប្បវេណីនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើយើងបានហុចប្រាក់ 4000៛ ចេញមក ហើយនិយាយថា «សូមឱ្យស្ករកៅស៊ូនេះមកខ្ញុំ» នៅតូបលក់ចាប់ហួយក្នុងស្ថានីយរថភ្លើង ក្នុងករណីនេះ សកម្មភាពនោះគឺជាការបង្ហាញឆន្ទៈយ៉ាងច្បាស់លាស់។ ពីព្រោះ វាជាសំណើដើម្បីបង្កើតកិច្ចសន្យាទិញស្ករកៅស៊ូក្នុងតម្លៃ 4000៛ ហើយកិច្ចសន្យាលក់ទិញនឹងកើតមានឡើង ប្រសិនបើអ្នកលក់ធ្វើស្វីការ ហើយវានាំឱ្យមានទំនាក់ទំនងគតិយុត្តរវាងអ្នកលក់ និងអ្នកទិញស្ករកៅស៊ូ ហើយសិទ្ធិលើបំណុល និង កាតព្វកិច្ចនឹងកើតមានចំពោះភាគីទាំងសងខាង។ មានន័យថា សំណើទិញស្ករកៅស៊ូក្នុងតម្លៃ 4000៛ ក៏ជាការបង្ហាញឆន្ទៈ ហើយស្វីការចំពោះសំណើនេះ ក៏ជាការបង្ហាញឆន្ទៈផងដែរ។ ម្យ៉ាងទៀត ការបង្ហាញឆន្ទៈនឹងកើតមានអានុភាព ចាប់ពីពេលដែលការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត (គោលការណ៍ទៅដល់ មាត្រា97 កថាខណ្ឌទី1)។

#### (2) សកម្មភាពគតិយុត្ត

បន្តទៅនេះ យើងនឹងសិក្សាអំពីពាក្យថា «សកម្មភាពគតិយុត្ត» ម្តង។ យើងតែងឃើញពាក្យនេះយ៉ាងញឹកញាប់នៅក្នុងការសិក្សាក្រមរដ្ឋប្បវេណី ប៉ុន្តែ វាមិនមែនជាពាក្យដែលពិបាកយល់នោះទេ។ សកម្មភាពគតិយុត្ត គឺជាសកម្មភាពដែលបង្កើតឱ្យមានអានុភាពគតិយុត្តស្របតាមឆន្ទៈ ផ្អែកតាមរយៈការបង្ហាញឆន្ទៈ ហើយវាជាធាតុផ្សំនៃការបង្ហាញឆន្ទៈដែលបានរៀបរាប់ខាងលើ។ ដូចនេះ កម្មវត្ថុដែលតំណាងឱ្យសកម្មភាពគតិយុត្ត គឺជាកិច្ចសន្យាដែល

បានរៀបរាប់ខាងលើនេះ។ កិច្ចសន្យា គឺជាសកម្មភាពគតិយុត្តដែលត្រូវបានបង្កើតឡើង តាមរយៈការបង្ហាញឆន្ទៈ 2 មកពីទិសផ្ទុយគ្នា ហើយបានត្រូវគ្នា ដូចជាការនិយាយថា របស់នេះខ្ញុំនឹងលក់ក្នុងតម្លៃនេះ និង របស់នេះខ្ញុំនឹងទិញតម្លៃនេះ ជាដើម។ សកម្មភាពគតិយុត្តផ្សេងពីនេះ គឺមានសកម្មភាពឯកតោភាគី ដូចជា មតកសាសន៍ ជាដើម។ មានន័យថា នៅក្នុងមតកសាសន៍ គឺមតកជនបានបង្ហាញឆន្ទៈដោយខ្លួនឯងតែម្នាក់នៅក្នុងលិខិតមតកសាសន៍ថា ឱ្យរបស់នេះទៅអ្នកនេះ ឬទៅអ្នកនោះ ជាដើម ហើយអានុភាពគតិយុត្តនឹងកើតមានឡើងស្របតាមការបង្ហាញឆន្ទៈនោះ ហេតុនេះហើយ ទើបគេហៅថាជា សកម្មភាពឯកតោភាគី ។ លើសពីនេះ ក្នុងសកម្មភាពគតិយុត្តគឺនៅមានប្រភេទមួយទៀត ហៅថា សកម្មភាពរួមគ្នា។ នេះគឺជាការព្រមព្រៀងគ្នា ក្នុងគោលបំណងតែមួយដូចគ្នាដែលបុគ្គលជាច្រើននាក់បានបង្ហាញឆន្ទៈមកពីទិសស្របគ្នា ដូចជា ការបង្កើតក្រុមហ៊ុន ជាដើម។ ដូចនេះ ស្នូលសំខាន់នៅក្នុងពាក្យសកម្មភាពគតិយុត្តនេះ គឺសំដៅទៅលើកិច្ចសន្យា សកម្មភាពឯកតោភាគី និងសកម្មភាពរួមគ្នា ប៉ុន្តែភាគច្រើនបំផុត គឺសំដៅទៅលើកិច្ចសន្យា។ ហេតុនេះហើយ យើងអាចយល់បានថា នៅក្នុងដំណាក់កាលនៃការសិក្សាបញ្ញត្តិជាមូលដ្ឋានៃបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏យើងជៀសមិនផុតពីការសិក្សា ដោយគិតអំពីបញ្ហាជាក់ស្តែងនៃកិច្ចសន្យានៅក្នុងនីតិសិទ្ធិលើបំណុលនោះទេ។

### (3) សកម្មភាពគតិយុត្តដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ

ចំណុចនេះក៏បានរៀបរាប់រួចហើយថា យើងគ្រប់គ្នាអាចបង្កើតខ្លឹមសារនៃកិច្ចសន្យាដោយសេរី ហើយបង្កើតសិទ្ធិលើបំណុលផ្សេងៗ ផ្អែកតាមគោលការណ៍សេរីភាពនៃកិច្ចសន្យាបាន ប៉ុន្តែយើងមិនអាចបង្កើតខ្លឹមសារនៃកិច្ចសន្យាដែលផ្ទុយនឹងសង្គមនោះទេ។ ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិក្នុងមាត្រា៩០ នៃបទប្បញ្ញត្តិទូទៅថា សកម្មភាពគតិយុត្តណាដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ត្រូវចាត់ទុកជាមោឃៈ។ ដោយឡែក នៅក្នុងករណីដែលពិចារណាអំពីឧទាហរណ៍ជាក់ស្តែងដែលផ្ទុយនឹងមាត្រា៩០ នៃក្រមរដ្ឋប្បវេណី ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាប្រុងប្រយ័ត្នចំពោះការលើកយកការប្រើប្រាស់គ្រឿងញៀនជាឧទាហរណ៍ជាដើម ដែលសកម្មភាពនេះពិតជាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អប្រាកដមែន ប៉ុន្តែ វាមិនមែនជាសកម្មភាពគតិយុត្តដែលជាធាតុផ្សំនៃការបង្ហាញឆន្ទៈនោះទេ ហើយវាគ្រាន់តែជាទង្វើ ឬ សកម្មភាពជាក់ស្តែងប៉ុណ្ណោះ។ ដោយហេតុថា កិច្ចសន្យាគឺជារបស់តំណាងឱ្យសកម្មភាពគតិយុត្ត ហេតុនេះបើសិនជាពិចារណាអំពីឧទាហរណ៍ជាក់ស្តែងនៃកិច្ចសន្យាដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ យើងអាចលើកឧទាហរណ៍អំពី កិច្ចសន្យាដែលប្រគល់លុយដើម្បីឱ្យប្រព្រឹត្តបទល្មើស ឬ កិច្ចសន្យាទិញលក់គ្រឿងញៀនដែលត្រូវបានហាមឃាត់ ជាដើម (មានន័យថា ការលើកយក «ការប្រើប្រាស់គ្រឿងញៀន» មកធ្វើជាឧទាហរណ៍ដែលផ្ទុយនឹងមាត្រា៩០ គឺមិនត្រឹមត្រូវនោះទេ ហើយឧទាហរណ៍ដែលត្រឹមត្រូវគឺ «ការបង្កើតកិច្ចសន្យាលក់ទិញគ្រឿងញៀនដែលត្រូវបានហាមឃាត់)។ កិច្ចសន្យាលេងល្បែង ម៉ាជាំង ជាដើម ក៏ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អផងដែរ។ កិច្ចសន្យាបែបនេះ គឺត្រូវបានមោឃភាព ហើយកិច្ចសន្យាដែលមោឃភាពមិនអាចបង្កើតឱ្យមានសិទ្ធិលើបំណុលនោះទេ។

ដូចនេះ បើសិនជាបានសន្យាគ្នាក្នុងវង់ល្បែងរួចហើយថា អ្នកចាញ់ត្រូវបង់ប្រាក់ក៏ដោយ ក៏កាតព្វកិច្ចបង់ប្រាក់តាមផ្លូវច្បាប់មិនកើតមាននោះទេ។

## 2. **ការការពារជនដែលត្រូវបានកម្រិតសមត្ថភាព**

### (1) សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព

លើកនេះ យើងនឹងសិក្សាអំពីពាក្យថា សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព។ ដូចបានរៀបរាប់រួចហើយថា បុគ្គលត្រូវបានទទួលស្គាល់សមត្ថភាពទទួលសិទ្ធិជាបុគ្គលម្នាក់មួយរូប ពោលគឺ មានលក្ខណៈសម្បត្តិក្លាយជាប្រធាននៃសិទ្ធិនិងករណីយកិច្ចតាមផ្លូវច្បាប់ ចាប់ពីពេលចាប់កំណើត (⇒ពាក្យគន្លឹះ៖ សមត្ថភាពទទួលសិទ្ធិ)។ ប៉ុន្តែ ដើម្បីឱ្យបុគ្គលម្នាក់អាចប្រាប់អំពីឆន្ទៈដែលខ្លួនបានបង្កើតដោយសេរី ទៅកាន់បុគ្គលផ្សេងទៀត ហើយអាចបង្កើតទំនាក់ទំនងគតិយុត្តបាន បុគ្គលនោះត្រូវតែមានសមត្ថភាពដែលអាចធ្វើការសម្រេចចិត្តបានដោយខ្លួនឯងថែមទៀត ហើយក្រមរដ្ឋប្បវេណីបានហៅសមត្ថភាពនោះថា សមត្ថភាពខាងឆន្ទៈ។ នៅក្នុងក្រមរដ្ឋប្បវេណី បុគ្គលដែលគ្មានសមត្ថភាពខាងឆន្ទៈ ដូចជា បុគ្គលដែលមានស្មារតីមិនប្រក្រតី ហើយមិនអាចវិនិច្ឆ័យបានដូចធម្មតាជាដើម ពោលគឺបុគ្គលដែលមិនមានសមត្ថភាពខាងឆន្ទៈ ត្រូវបានហៅថា «បុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ» ហើយទោះបីជាបុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈបានបង្កើតកិច្ចសន្យាជាមួយបុគ្គលផ្សេងក៏ដោយ ក៏កិច្ចសន្យានោះគ្មានអានុភាពដែរ។ មានន័យថា ទំនាក់ទំនងគតិយុត្តផ្អែកតាមកិច្ចសន្យានោះមិនកើតមានឡើងទេ (មាត្រា៣កថាខណ្ឌទី២។ មាត្រាដែលបង្ហាញខាងក្រោមដោយមិនបញ្ជាក់ឈ្មោះរបស់ច្បាប់ គឺសំដៅទៅលើមាត្រារបស់ក្រមរដ្ឋប្បវេណីទាំងអស់)។

ប៉ុន្តែ ប្រសិនបើយើងត្រូវបញ្ជាក់ម្តងមួយៗថា តើបុគ្គលជាក់លាក់នេះមានសមត្ថភាពខាងឆន្ទៈដែរឬទេ ទៅតាមរឿងក្តីនីមួយៗនោះ យើងនឹងត្រូវចំណាយពេលច្រើន ហើយនឹងមានករណីខ្លះពិបាកសម្រេចផងដែរ។ ហេតុនេះ ក្រមរដ្ឋប្បវេណីបានកំណត់អំពី ស្តង់ដារនៃសមត្ថភាពដែលអាចវិនិច្ឆ័យដោយខ្លួនឯងអំពីសកម្មភាពគតិយុត្ត ពោលគឺបែងចែកបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាព និង បុគ្គលដែលគ្មានសមត្ថភាពធ្វើសកម្មភាព ហើយចាត់ទុកបុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ និង បុគ្គលដែលមិនអាចវិនិច្ឆ័យបាន ថាជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។ ដើម្បីការពារដល់បុគ្គលទាំងនោះ ក្រមរដ្ឋប្បវេណីបានរៀបចំទុកនូវបញ្ញត្តិដែលទទួលស្គាល់ សកម្មភាពគតិយុត្តតែមួយផ្នែករបស់បុគ្គលដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព និង តម្រូវឱ្យមានការយល់ព្រម ឬ ជំនួយពីអ្នកណាម្នាក់ (មាត្រា5 ~ មាត្រា19)។ ប៉ុន្តែ បើមើលពីជ្រុងម្ខាងទៀត ការការពារបុគ្គលដែលបានចុះកិច្ចសន្យាជាមួយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ទាំងខ្លួនមិនបានដឹង ក៏មានភាពចាំបាច់ផងដែរ ហេតុនេះ ក្រមរដ្ឋប្បវេណីក៏មានរៀបចំទុកនូវបញ្ញត្តិអំពីចំណុចនោះផងដែរ (យោងមាត្រា20 និង មាត្រា21)។

ពាក្យគន្លឹះ: **សមត្ថភាពទទួលសិទ្ធិ**

បុគ្គលម្នាក់ៗត្រូវបានទទួលស្គាល់សមត្ថភាពទទួលសិទ្ធិ ដែលជាលក្ខណៈសម្បត្តិសម្រាប់ក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ចាប់ពីពេលចាប់កំណើតមក។ ប៉ុន្តែបើកំណត់បែបនេះ មានន័យថា ប្រសិនបើឪពុកស្លាប់នៅមុនពេលទារកសម្រាលបន្តិច ទារកនោះពុំទាន់មានសិទ្ធិទទួលសន្តតិកម្មពីមត៌ករបស់ឪពុកបានឡើយ (សូមអានជំពូកទី9 ស្តីពីសន្តតិកម្ម) ហើយនៅក្នុងករណីដែលឪពុកស្លាប់ដោយសារអំពើអនីត្យានុកូល (សូមអានជំពូកទី5) ដូចជា គ្រោះថ្នាក់ចរាចរណ៍ជាដើមក៏ដោយ ក៏ទារកនោះនៅមានទាន់ក្លាយជាប្រធាននៃសិទ្ធិដើម្បីទាមទារសំណងការខូចខាតនោះទេ។ ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានចាត់ទុកទារកដែលនៅក្នុងផ្ទៃថាបានសម្រាលហើយ ចំពោះការទាមទារសំណងការខូចខាតដោយអំពើអនីត្យានុកូល (មាត្រា721) សន្តតិកម្ម (មាត្រា886) និង អច្ច័យទាន (មាត្រា965)។ សូមបញ្ជាក់ថា ជាគោលការណ៍សមត្ថភាពទទួលសិទ្ធិនេះក៏ត្រូវបានផ្តល់ដល់ជនបរទេសផងដែរ (មាត្រា3 កថាខណ្ឌទី2)។

ដោយឡែក ជនដែលត្រូវបានកម្រិតសមត្ថភាពដែលនឹងរៀបរាប់ខាងក្រោមនេះ គ្រាន់តែសំដៅទៅលើការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពប៉ុណ្ណោះ មិនមែនជាការដាក់កម្រិតលើសមត្ថភាពទទួលសិទ្ធិនោះទេ។

### (2) ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ក្រមរដ្ឋប្បវេណីបានកំណត់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពជា 4ប្រភេទ៖ **អនីតិជន** (យោងតាមមាត្រា4 អនីតិជនគឺជាជនមានអាយុតិចជាង 20ឆ្នាំ។ ដោយឡែក នៅពេលធ្វើវិសោធនកម្មច្បាប់ អាយុក្លាយជានីតិជនត្រូវបានបន្ថយមក 18ឆ្នាំវិញ ចាប់ពីថ្ងៃទី1 ខែមេសា ឆ្នាំ2022។ ហេតុនេះ នៅក្រោយពេលអនុវត្តនេះ អនីតិជននឹងត្រូវប្តូរជាជនដែលមានអាយុតិចជាង 18ឆ្នាំវិញ) **នីតិជននៅក្រោមអាណាព្យាបាល ជននៅក្រោមហិតូបត្ថម្ភ** និង**ជននៅក្រោមការទំនុកបំរុង**។ ក្រមរដ្ឋប្បវេណីដែលបានតាក់តែងឡើងតាំងពីសម័យមុនរហូតដល់ត្រឹមខែមេសា ឆ្នាំ2000 បានបញ្ញត្តពី ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាព ហើយបែងចែកជា 3 ប្រភេទគឺ អនីតិជន ជនដែលហាមមិនឱ្យគ្រប់គ្រងទ្រព្យ និងឧបជនដែលហាមមិនឱ្យគ្រប់គ្រងទ្រព្យ។ ជនដែលហាមមិនឱ្យគ្រប់គ្រងទ្រព្យ សំដៅទៅលើជនដែលត្រូវបានហាមឃាត់មិនឱ្យចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន។ ចំពោះឧបជនដែលហាមមិនឱ្យគ្រប់គ្រងទ្រព្យ សំដៅទៅលើជនដែលមានកម្រិតប្រហាក់ប្រហែលនឹងជនដែលហាមមិនឱ្យគ្រប់គ្រងទ្រព្យ។ ប៉ុន្តែ ការប្រើប្រាស់ពាក្យពេចន៍ច្បាប់ទាំងនេះខ្វះភាពត្រឹមត្រូវ ដោយមានលក្ខណៈជ្រុលខ្លាំងពេក ហើយជាប្រព័ន្ធដែលនៅមានចំណុចខ្លះដែលខ្វះការការពារដល់ជនដែលជាកម្មវត្ថុនៃបញ្ញត្តិនេះ។ លើសពីនេះស្របពេលសង្គមជប៉ុនមានជនជរាកាន់តែចាឡើង ភាពចាំបាច់ក្នុងការផ្តល់ការការពារដល់ជនជរាដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យ ដោយសារតែអាយុច្រើនក៏កាន់តែខ្លាំងឡើង។ ដោយមើលឃើញស្ថានភាពបែបនេះហើយ បានជាក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្ម ដោយបង្កើតឱ្យមានប្រព័ន្ធនីតិជននៅក្រោមអាណាព្យាបាល ក្នុងគោលបំណងបង្កើនសុខុមាលភាពដល់ជនជរា និង ជនពិការ (សម្រេចនៅខែធ្នូ ឆ្នាំ1999 និង ចាប់អនុវត្តនៅខែមេសា ឆ្នាំ

2000)។ តាមរយៈការធ្វើវិសោធនកម្មនេះ ពាក្យ «អសមត្ថជនក្នុងការធ្វើសកម្មភាព» ត្រូវប្តូរមកជា «ជនដែលត្រូវបានកម្រិតសមត្ថភាព» ហើយនៅពេលធ្វើទំនើបកម្មពាក្យពេចន៍ក្នុងឆ្នាំ2004 ពាក្យនោះត្រូវប្តូរមកជា «ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព» វិញ។

នៅក្រោយពេលវិសោធនកម្ម ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក្រៅពីអនីតិជន រួមមាន ជនដែលហាមមិនឱ្យគ្រប់គ្រងទ្រព្យ ត្រូវប្តូរមកជា ជននៅក្រោមអាណាព្យាបាលទូទៅ និង ឧបជនដែលហាមមិនឱ្យគ្រប់គ្រងទ្រព្យ ត្រូវប្តូរមកជា ជននៅក្រោមហិតូបត្ថម្ភ ហើយប្រព័ន្ធនៃជននៅក្រោមការទំនុកបម្រុងត្រូវបានបង្កើតថ្មី។ ឧទាហរណ៍ថា មានបុគ្គលម្នាក់ដែលស្ថិតក្នុងស្ថានភាពដែលគ្មានសមត្ថភាពវិនិច្ឆ័យរឿងរ៉ាវផ្សេងៗបានដោយសារវិបត្តិស្មារតី (នៅក្នុងពាក្យពេជន៍ច្បាប់ សំដៅលើសមត្ថភាពយល់ដឹងពីហេតុផល) ហើយតុលាការគ្រួសារបានចេញដីកាសម្រេចចាប់ផ្តើមអាណាព្យាបាលតាមការស្នើសុំរបស់សាមីខ្លួន សហព័ទ្ធ ឬ សាច់ញាតិជិតស្និទ្ធ។ ក្នុងករណីនេះ បុគ្គលដែលទទួលបានដីកាសម្រេចនោះ ត្រូវហៅថា នីតិជនដែលនៅក្រោមអាណាព្យាបាល ហើយត្រូវបានអមជាមួយដោយអ្នកអាណាព្យាបាល ហើយអ្នកអាណាព្យាបាលនោះអាចលុបចោលសកម្មភាពគតិយុត្តដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើ (មាត្រា8~10)។ មួយវិញទៀត ចំពោះបុគ្គលដែលគ្មានសមត្ថភាពគ្រប់គ្រាន់ល្មមៗក្នុងការវិនិច្ឆ័យរឿងរ៉ាវ តែមិនធ្ងន់ធ្ងរដល់ថ្នាក់ជននៅក្រោមអាណាព្យាបាលទូទៅ អាចក្លាយជាជននៅក្រោមហិតូបត្ថម្ភ ដោយដីកាសម្រេចចាប់ផ្តើមហិតូបត្ថម្ភ ហើយជននោះត្រូវបានអមជាមួយដោយហិតូបត្ថម្ភកៈ ហើយសកម្មភាពគតិយុត្តជាក់លាក់មួយចំនួនដែលច្បាប់បានកំណត់ គឺតម្រូវឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយសកម្មភាពដែលគ្មានការយល់ព្រមទេអាចលុបចោលបាន (មាត្រា11 មាត្រា12 និង មាត្រា13)។ លើសពីនេះ ចំពោះជនដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យតិចតួច អាចក្លាយជាជននៅក្រោមការទំនុកបម្រុងដោយដីកាសម្រេច ហើយជននោះត្រូវមានអ្នកជួយទំនុកបម្រុងអមជាមួយ ហើយភាគីអាចជ្រើសរើសសកម្មភាពគតិយុត្តជាក់លាក់ណាមួយ ដែលតម្រូវឱ្យមានការយល់ព្រមពីអ្នកជួយទំនុកបម្រុងបាន (មាត្រា15~17)។

### (3) ការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

#### ① ការលុបចោលសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

មធ្យោបាយជាក់ស្តែងដើម្បីការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺការរៀបចំទុកបញ្ញត្តិដែលអនុញ្ញាតឱ្យលុបចោលសកម្មភាពគតិយុត្ត ដែលត្រូវបានធ្វើឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។ ការលុបចោល ដែលនឹងរៀបរាប់លម្អិតខាងក្រោម គឺជាមធ្យោបាយដែលធ្វើឱ្យគ្មានអ្វីកើតឡើងតាំងពីដំបូង (សូមអានជំពូកទី5៖ មោឃភាព និង ការលុបចោល) ។ ជាបឋម សូមពិចារណាអំពីករណីអនីតិជន ឧទាហរណ៍ថា សិស្សវិទ្យាល័យម្នាក់ត្រូវបានអ្នកលក់ណែនាំឱ្យចុះកិច្ចសន្យាទិញរបស់ដែលមានតម្លៃរាប់លានរៀល ក្នុងករណីនេះតើយើងគួរធ្វើយ៉ាងណា? យោងតាមមាត្រា5 នៃក្រមរដ្ឋប្បវេណី អនីតិជនត្រូវទទួលការយល់ព្រមពីឪពុកម្តាយដែលជាអ្នកតំណាងដែលច្បាប់បានកំណត់ (អាចជាអ្នកមានអំណាចមេបា ឬ អ្នកអាណា

ព្យាបាលប្រសិនបើគ្មានអ្នកមានអំណាចមេបា) នៅពេលធ្វើសកម្មភាពគតិយុត្ត ដូចជាចុះកិច្ចសន្យាជាដើម ហើយប្រសិនបើគ្មានការយល់ព្រមនោះទេ សាមីខ្លួន និង ឪពុកម្តាយអាចលុបចោលសកម្មភាពគតិយុត្តនោះ ឱ្យគ្មានតាំងពីដំបូងបាន (យោងតាមមាត្រា120 ដែលនឹងរៀបរាប់ខាងក្រោម អ្នកដែលអាចលុបចោល ពោលគឺ អ្នកមានសិទ្ធិលុបចោល រួមមាន ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពខ្លួនឯងផ្ទាល់ ឬ អ្នកតំណាងរបស់ជននោះ អ្នកទទួលបន្ត ឬ អ្នកមានសិទ្ធិផ្តល់ការយល់ព្រម)។ អ្នកមានអំណាចមេបាគឺជាអ្នកតំណាងដែលច្បាប់បានកំណត់ ហេតុនេះ អ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួន ព្រមទាំងតំណាងឱ្យសាមីខ្លួន ចំពោះសកម្មភាពគតិយុត្ត (កិច្ចសន្យា ជាអាទិ៍) ទាក់ទងនឹងទ្រព្យសម្បត្តិរបស់សាមីខ្លួនផងដែរ (នឹងមានការរៀបរាប់អំពី ការតំណាង នៅពេលក្រោយ។ ⇒ការតំណាង ការតំណាងដោយគ្មានសិទ្ធិ និង ការតំណាងដែលមានលក្ខណៈជារូបភាព)។ លើសពីនេះ ទ្រព្យសម្បត្តិដែលឪពុកម្តាយបានអនុញ្ញាតឱ្យចាត់ចែងដោយកំណត់គោលបំណងឱ្យប្រើប្រាស់លើអ្វីមួយជាក់លាក់ និង ទ្រព្យសម្បត្តិដែលបានអនុញ្ញាតឱ្យចាត់ចែងតិចតួចដោយមិនកំណត់គោលបំណងជាក់លាក់ គឺអនីតិជនអាចចាត់ចែងតាមចិត្តឯង ពោលគឺដោយសេរីបាន (មាត្រា៥ កថាខណ្ឌទី៣)។ ដោយឡែក អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ ពោលគឺបើបានរៀបការហើយ ត្រូវចាត់ទុកជានីតិជន (មាត្រា 753)។

ដូចបានរៀបរាប់ខាងលើ នីតិជននៅក្រោមអាណាព្យាបាលត្រូវអមជាមួយដោយអ្នកអាណាព្យាបាលរបស់នីតិជន ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា៨)។ សកម្មភាពគតិយុត្តរបស់នីតិជននៅក្រោមអាណាព្យាបាល ក៏អាចលុបចោលបានដែរ (ប៉ុន្តែ ការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃ ឬ សកម្មភាពពាក់ព័ន្ធជីវភាពប្រចាំថ្ងៃផ្សេងទៀត មិនមែនជាកម្មវត្ថុនៃការលុបចោលឡើយ។ មាត្រា៩)។ ជននៅក្រមហិតូបបត្ថម្ភ ត្រូវមានហិតូបត្ថម្ភកៈអមជាមួយ (មាត្រា12)។ ចំពោះករណីជននៅក្រោមហិតូបត្ថម្ភ សកម្មភាពមួយផ្នែកគឺអាចធ្វើបានដោយខ្លួនឯង ប៉ុន្តែករណីសកម្មភាពសំខាន់ៗទាក់ទងនឹងទ្រព្យសម្បត្តិ គឺត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ (មាត្រា13 កថាខណ្ឌទី1)។ ប្រសិនបើបានធ្វើសកម្មភាពខាងលើដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ឬ ការអនុញ្ញាតិពីតុលាការដែលអាចជំនួសការយល់ព្រមទេ សកម្មភាពនោះអាចលុបចោលបាន (មាត្រា13 កថាខណ្ឌទី4)។ តាមរយៈវិសោធនកម្មនៅឆ្នាំ1999 ហិតូបត្ថម្ភកៈត្រូវបានផ្តល់សិទ្ធិឱ្យលុបចោល ចំពោះសកម្មភាពណាដែលជាកម្មវត្ថុដែលត្រូវមានការយល់ព្រម ប៉ុន្តែ ជននៅក្រោមហិតូបត្ថម្ភបែរជាបានធ្វើតាមចិត្តឯងទៅវិញ (មាត្រា120 កថាខណ្ឌទី1)។ លើសពីនេះ សិទ្ធិតំណាងក៏ត្រូវបានផ្តល់ទៅឱ្យហិតូបត្ថម្ភកៈដែរ តាមរយៈសេចក្តីសម្រេចរបស់តុលាការចំពោះសកម្មភាពគតិយុត្តជាក់លាក់ដែលភាគីបានជ្រើសរើសតាមការស្នើសុំ (សកម្មភាពនេះត្រូវមានការយល់ព្រមពីសាមីខ្លួនផងដែរ ប្រសិនបើការស្នើសុំនោះបានធ្វើឡើងដោយបុគ្គលក្រៅពីសាមីខ្លួន។ សូមយោង មាត្រា576 ភាគ 4 កថាខណ្ឌទី1 និងទី2)។ នៅក្នុងករណីប្រព័ន្ធទំនុកបម្រុងក៏ដោយ ក៏អ្នកជួយទំនុកបម្រុងត្រូវបានផ្តល់សិទ្ធិតំណាង ឬ សិទ្ធិផ្តល់ការយល់ព្រម (សិទ្ធិលុបចោល) តាមរយៈសេចក្តីសម្រេចរបស់តុលាការ ចំពោះសកម្មភាពគតិយុត្តជាក់លាក់ដែលភាគីបានជ្រើសរើសតាមការស្នើសុំ (មាត្រា17 កថាខណ្ឌទី1 មាត្រា876 ភាគ9 កថាខណ្ឌទី1)។

ចំណុចនេះ គឺឈរលើការគោរពការសម្រេចចិត្តរបស់អ្នកនៅក្រោមការទំនុកបម្រុង ហេតុនេះហើយបានជាមានលក្ខខណ្ឌតម្រូវឱ្យមានការស្នើសុំ ឬ ការយល់ព្រមពីសាមីខ្លួន។ មាត្រា17 កថាខណ្ឌទី2 និង មាត្រា876 ភាគ9 កថាខណ្ឌទី2)។

② ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

យ៉ាងណាមិញ តើភាគីម្ខាងទៀតដែលបានជ្រុលចុះកិច្ចសន្យាជាមួយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ត្រូវរង់ចាំរហូតទាំងមិនដឹងថា ជនដែលត្រូវកម្រិតសមត្ថភាពនោះលុប ឬ មិនលុបចោលកិច្ចសន្យាដែរឬទេ? នេះមានន័យថា ភាគីម្ខាងទៀតដែលបានធ្វើជំនួញជាមួយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ត្រូវស្ថិតនៅក្នុងស្ថានភាពដែលគ្មានស្ថិរភាពរយៈពេលយ៉ាងយូរ។ ដើម្បីជៀសវាងនូវស្ថានភាពដែលគ្មានផលប្រយោជន៍បែបនេះ ក្រមរដ្ឋប្បវេណីបានរៀបចំទុកនូវបញ្ញត្តិដែលអនុញ្ញាតឱ្យ ភាគីម្ខាងទៀតអាចដាស់តឿនឱ្យភាគីនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្តល់សច្ចានុម័ត ឬ មិនផ្តល់សច្ចានុម័តចំពោះកិច្ចសន្យានោះ (សច្ចានុម័ត មានន័យថា ការទទួលស្គាល់អានុភាពនៅពេលក្រោយ)។

ក្នុងករណី ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពនោះ បានក្លាយជាសមត្ថជនវិញនៅពេលក្រោយ (ឧទាហរណ៍ថា បុគ្គលដែលជាអនីតិជននៅពេលចុះកិច្ចសន្យា បានក្លាយទៅជានីតិជន) ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននោះឆ្លើយថាផ្តល់សច្ចានុម័ត ឬ មិនផ្តល់សច្ចានុម័ត ក្នុងអំឡុងពេលលើសពី 1ខែ គិតចាប់ពីពេលនោះបាន ហើយប្រសិនបើគ្មានការឆ្លើយតបក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានផ្តល់សច្ចានុម័តលើសកម្មភាពនោះ (មាត្រា20 កថាខណ្ឌទី1)។ ហើយក្នុងករណី ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពនៅតែជាជនដែលត្រូវកម្រិតសមត្ថភាពដដែល ភាគីម្ខាងទៀតអាចដាស់តឿនឱ្យឆ្លើយតបដូចគ្នាចំពោះសកម្មភាពដែលស្ថិតក្នុងទំហំនៃសិទ្ធិនោះ ទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់ ហិតូបត្ថម្ភកៈ ឬ អ្នកជួយទំនុកបម្រុងបាន ហើយបើគ្មានការឆ្លើយតបក្នុងអំឡុងពេលដូចគ្នានោះទេ ត្រូវចាត់ទុកថា បានផ្តល់សច្ចានុម័ត (មាត្រា20 កថាខណ្ឌទី2)។ លើសពីនេះ ភាគីម្ខាងទៀតអាចដាស់តឿនទៅកាន់ជននៅក្រោមហិតូបត្ថម្ភ ឬ ជននៅក្រោមការទំនុកបម្រុងដែលបានទទួលដីកាសម្រេចតាមមាត្រា16 ឱ្យទៅទទួលសច្ចានុម័តពីហិតូបត្ថម្ភកៈ ឬ អ្នកជួយទំនុកបម្រុង ក្នុងអំឡុងលើសពី 1ខែ បាន ហើយបើសិនជា ជននៅក្រោមហិតូបត្ថម្ភ ឬ ជននៅក្រោមការទំនុកបម្រុងមិនបានផ្តល់ដំណឹងអំពីការទទួលបានសច្ចានុម័តក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលុបចោលសកម្មភាពនោះ (មាត្រា20 កថាខណ្ឌទី4)។

ម្យ៉ាងទៀត ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព បានប្រើប្រាស់មធ្យោបាយឆបោកដើម្បីឱ្យភាគីម្ខាងទៀតជឿថាខ្លួនជាសមត្ថជន ក្នុងករណីនេះ ជននោះមិនអាចលុបចោលសកម្មភាពនោះបានទេ (មាត្រា21)។

③ ប្រព័ន្ធអាណាព្យាបាលតាមការស្ម័គ្រចិត្ត

«ច្បាប់ស្តីពី កិច្ចសន្យាអាណាព្យាបាលតាមការស្ម័គ្រចិត្ត» បានបង្កើតឡើង ស្របពេលជាមួយការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីនៅក្នុងឆ្នាំ1999 ហើយត្រូវបានដាក់ឱ្យអនុវត្តនៅខែមេសា ឆ្នាំ2000 ដូចគ្នា។ ប្រព័ន្ធនេះគឺឈរលើការគោរពសិទ្ធិសម្រេចចិត្តដោយខ្លួនឯង ដោយបុគ្គលម្នាក់ៗ ក្នុងពេលដែលនៅមានសមត្ថភាពគ្រប់គ្រាន់ដើម្បីវិនិច្ឆ័យនៅឡើយ អាចសម្រេចជ្រើសរើសជនដែលកាន់កិច្ចការអាណាព្យាបាលមកឱ្យខ្លួននៅពេលខ្លួនក្លាយជាគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យនាពេលអនាគត និង ចុះកិច្ចសន្យាជាមួយបុគ្គលនោះជាមុនបាន។ ភាគីអាចសម្រេចថាផ្តល់សិទ្ធិណាខ្លះ ដោយស្ម័គ្រចិត្តក្នុងកិច្ចសន្យាជាមុនបាន។ នេះហៅថា ប្រព័ន្ធអាណាព្យាបាលតាមការស្ម័គ្រចិត្ត។

## 3. **ការបង្ហាញឆន្ទៈដែលមានបញ្ហា**

### (1) **សេចក្តីផ្តើម**

នីតិជនទូទៅដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាព និង គ្មានបញ្ហាអំពីសមត្ថភាពវិនិច្ឆ័យក៏ដោយ ក៏មានករណីខ្លះបានបង្ហាញឆន្ទៈមិនត្រឹមត្រូវ ដូចជា ការបង្ហាញឆន្ទៈមានវិការៈ ពោលគឺ ឆន្ទៈដែលមានស្នាម និងមានករណីខ្លះបានបង្ហាញឆន្ទៈមិនស្របគ្នាទាល់តែសោះទៅនឹងឆន្ទៈពិតផងដែរ។ ក្នុងករណីបែបនេះ យើងមិនអាចទទួលស្គាល់អានុភាពនៃការបង្ហាញឆន្ទៈនោះទេ។ ក្រមរដ្ឋប្បវេណីបានរៀបចំទុកនូវវិធានដើម្បីលុបចោល ឬ ធ្វើមិនឱ្យអានុភាពនៃការបង្ហាញឆន្ទៈកើតឡើង ចំពោះករណីបែបនេះ។

### (2) **ការបង្ហាញឆន្ទៈដោយការឆបោក ឬ ការគម្រាមកំហែង**

ការបង្ហាញឆន្ទៈតាមរយៈការឆបោក ឬ ការគម្រាមកំហែង ពោលគឺអ្នកលក់ត្រូវបានគេកុហក ឬ បង្ខំ ហើយបាននិយាយថាលក់ផ្ទះនេះ ទាំងខ្លួនគ្មានបំណងលក់ទាល់តែសោះជាដើម ហើយចំពោះករណីបែបនេះ ការបង្ហាញឆន្ទៈនោះអាចលុបចោលបាន (មាត្រា96 កថាខណ្ឌទី1)។ ប្រសិនបើការបង្ហាញឆន្ទៈត្រូវបានលុបចោល ឧមាថា កិច្ចសន្យាលក់ទិញផ្ទះត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈ2 ត្រូវគ្នា ដូចជា «ទិញតម្លៃប៉ុណ្ណេះ» និង «លក់តម្លៃប៉ុណ្ណេះ» ហើយតាមរយៈការលុបការបង្ហាញឆន្ទៈ1 ក្នុងចំណោមការបង្ហាញឆន្ទៈទាំង2 ខាងលើនេះ នាំឱ្យការបង្ហាញឆន្ទៈនោះមិនមានតាំងពីដំបូង មានន័យថា កិច្ចសន្យាលក់ទិញក៏មិនកើតមានឡើងផងដែរ។ ដោយសារតែកិច្ចសន្យាមិនកើតមានឡើង ហេតុនេះ បើសិនជាបានប្រគល់ផ្ទះហើយ គឺត្រូវប្រគល់មកវិញ ហើយបើបានបង់ប្រាក់ហើយ គឺត្រូវសងមកវិញ (នេះហៅថា ការធ្វើបដិទានស្ថានភាពដើម)។ «ស្ថានភាពដើម» មានន័យថា ស្ថានភាពតាំងពីដំបូង មិនមែនស្ថានភាពបច្ចុប្បន្ននោះទេ។

ហើយក្រមរដ្ឋប្បវេណីកំណត់អំពី ការបង្ហាញឆន្ទៈដែលកើតចេញពីការឆបោក និង ការគម្រាបកំហែង «ត្រឹមតែប៉ុណ្ណឹង»។ «ត្រឹមតែប៉ុណ្ណឹង» មានន័យថា មនុស្សភាគច្រើនប្រហែលជាយល់ឃើញថា បុគ្គលដែលបានឆបោក ឬ

គម្រាមកំហែង គឺជាមនុស្សអាក្រក់ ហើយត្រូវដាក់ទោសទណ្ឌ ប៉ុន្តែ ករណីនេះមិនមែនជាបញ្ហានៅក្នុងក្រមរដ្ឋប្បវេណីនោះទេ (បើសិនជាការឆបោក គឺជាបញ្ហាថា តើការឆបោកនោះត្រូវនឹងលក្ខខណ្ឌនៃការឆបោកក្នុងក្រមព្រហ្មទណ្ឌដែរឬទេ? ហើយបើសិនជាត្រូវនឹងលក្ខខណ្ឌ ជននោះត្រូវទទួលរងទោសទៅតាមការកំណត់របស់ក្រមព្រហ្មទណ្ឌ)។ សូមអ្នកទាំងអស់គ្នាយល់ថា គោលបំណងនៃក្រមរដ្ឋប្បវេណី គឺស្វ័យភាពខាងឆន្ទៈរបស់ភាគី ហេតុនេះ ក្រមរដ្ឋប្បវេណីទទួលស្គាល់អានុភាព ចំពោះតែឆន្ទៈដែលបានសម្រេចដោយសេរីរបស់ភាគីក្នុងការបង្ហាញឆន្ទៈប៉ុណ្ណោះ និងរឹតត្បិតចំពោះការបង្ហាញឆន្ទៈដែលមិនបានធ្វើដោយសេរី។

ដោយឡែក យើងឃើញថាមានករណីជាច្រើន ការឆបោកធ្វើឡើងដោយភាគីម្ខាងទៀតនៃជំនួញ (ឧបមាថា X ឆបោក Y ឱ្យលក់ផ្ទះមកខ្លួនក្នុងតម្លៃថោកជាដើម)។ ប៉ុន្តែ ក៏មានករណីខ្លះ ការឆបោកធ្វើឡើងដោយតតិយជន ពោលគឺបុគ្គលផ្សេងផងដែរ (Z បោកបញ្ឆោត Y ឱ្យលក់ផ្ទះទៅ X ក្នុងតម្លៃថោក)។ ក្នុងករណីនេះ ការលុបចោលអាចធ្វើបាន លុះត្រាតែភាគីម្ខាងទៀត (ពោលគឺ ប្រសិនបើការបង្ហាញឆន្ទៈរបស់ Y មានបញ្ហា ភាគីម្ខាងទៀតសំដៅលើអ្នកទិញ X) នៃការបង្ហាញឆន្ទៈបានដឹង ឬ អាចដឹងអំពីអង្គហេតុនៃការឆបោកនោះ (មាត្រា96 កថាខណ្ឌទី2)។

លើសពីនេះ ក្រមរដ្ឋប្បវេណីបានកំណត់ថា ការលុបចោលការបង្ហាញឆន្ទៈដោយផ្អែកលើការឆបោកមិនអាចតតាំងចំពោះតតិយជនដែលសុចរិត និង គ្មានកំហុសបានឡើយ (មាត្រា96 កថាខណ្ឌទី3)។ ពាក្យថា «តតិយជនសុចរិត» នៅទីនេះ សំដៅទៅលើបុគ្គលផ្សេងដែលមិនដឹងអំពីអង្គហេតុ (⇒ពាក្យគន្លឹះ: សុចរិត និង ទុច្ចរិត)។ ឧទាហរណ៍ថា A បានចាញ់បោក B និង បានលក់អចលនវត្ថុ ហើយផ្ទេរការចុះបញ្ជីទៅឱ្យ B ប៉ុន្តែ B និយាយតែមាត់ថានឹងបង់ប្រាក់ឱ្យ តែមិនដែលបានបង់ប្រាក់នោះទេ ហេតុនេះ A បានលុបចោលកិច្ចសន្យានោះដោយសារមូលហេតុឆបោក។ ទោះបីជាបានលុបចោលហើយក៏ដោយ ក៏ B នៅតែយកអចលនវត្ថុនោះធ្វើជារបស់ខ្លួន ទៅបង្កើតហ៊ីប៉ូតែក(ជំពូកទី ៧ II) ដើម្បីជានាការខ្ចីប្រាក់ពី C ដែរ។ ក្នុងករណីនេះ ប្រសិនបើ C មិនដឹង និង មិនមានកំហុសក្នុងការមិនដឹងអំពីការឆបោករបស់ B ទេ A មិនអាចតតាំងចំពោះ C អំពីអានុភាពនៃការលុបចោលទេ (មិនអាចអះអាងអំពីការលុបចោលចំពោះ C ហេតុនេះ ក៏មិនអាចបដិសេធហ៊ីប៉ូតែករបស់ C ដែរ)។ ត្រង់ចំណុចនេះប្រហែលជាមានអ្នកគិតថា វាគួរឱ្យអាណិតចំពោះបុគ្គលដែលត្រូវបានគេឆបោក ប៉ុន្តែ បើពិចារណាផ្ទុយមកវិញយើងក៏ចាំបាច់ត្រូវការពារភាគី C ដែលបានធ្វើជំនួញដោយជឿជាក់ថាអចលនវត្ថុនោះជារបស់ B (សូម្បីតែការចុះបញ្ជីក៏ផ្ទេររួចហើយដែរ) ទាំងមិនបានដឹងអំពីស្ថានភាព និង គ្មានកំហុសអំពីការមិនបានដឹងស្ថានភាពនោះទាល់តែសោះ។ យើងអាចគិតថា បុគ្គលដែលត្រូវបានគេបោកក៏មានការធ្វេសប្រហែសផងដែរ។ នៅក្នុងករណីបែបនេះហើយ ទើបក្រមរដ្ឋប្បវេណីបានរៀបចំទុកនូវបញ្ញត្តិដែលបានវិនិច្ឆ័យ ដោយឈរលើសមភាពរបស់ភាគីដែលពាក់ព័ន្ធ (ក្នុងករណីនេះ ភាគីម្ខាងទៀតដែលរងការឆបោកត្រូវទទួលបានការការពារ ប៉ុន្តែ មិនត្រូវទទួលការការពាររហូតដល់ធ្វើឱ្យរងគ្រោះដល់តតិយជនដែលបានចូលទៅក្នុងជំនួញទាំងមិនបានដឹងអំពីការឆបោក និង មិនមានកំហុសក្នុងការមិនបានដឹងនោះទេ។ ដោយឡែក ចំពោះករណីគម្រាមកំហែងវិញ យើងពិបាកនឹងគិតថា បុគ្គលដែលរងការគម្រាមកំហែងមានកំហុសណាស់ ហេតុនេះ យើងត្រូវការពារអ្នកបង្ហាញឆន្ទៈដែលទទួលរងការគម្រាមកំហែង

ទោះបីជាមានតតិយជនសុចរិត និង គ្មានកំហុសក៏ដោយ។ ដោយសារមូលហេតុនេះហើយ ទើបកថាខណ្ឌទី3 នៃមាត្រា96 បានកំណត់តែនៅក្នុងករណីការឆបោកប៉ុណ្ណោះ)។

| |
|---|
| ពាក្យគន្លឹះ: **សុចរិត និង ទុច្ចរិត** |
| នៅក្នុងពិភពច្បាប់ សុចរិតសំដៅទៅលើការមិនបានដឹងអំពីស្ថានភាព ចំណែកឯ ទុច្ចរិតសំដៅទៅលើការដឹងអំពីស្ថានភាព (នៅក្នុងករណីខ្លះ សុចរិតសំដៅទៅលើការមិនបានដឹងស្ថានភាពរួមជាមួយនឹងការជឿជាក់ (ឧទាហរណ៍ថា ភាគីម្ខាងទៀតនៃជំនួញគឺជាបុគ្គលដែលមានសិទ្ធិត្រឹមត្រូវ))។ ហេតុនេះហើយ បុគ្គលសុចរិតដែលលើកមកនិយាយនៅទីនេះ មិនមែនមានន័យថា បុគ្គលដែលមានសណ្ដានចិត្តល្អនោះទេ។ ផ្ទុយមកវិញ គោលបំណងដែលធ្វើបាបដល់អ្នកដទៃ ហៅថា «ឆន្ទៈព្យាបាទ» មិនមែន ទុច្ចរិតនោះទេ។ ហើយករណីដែលបុគ្គលម្នាក់បានដឹងថា អ្នកលក់បានចុះកិច្ចសន្យាលក់ទិញជាមួយបុគ្គលដទៃរួចហើយ ប៉ុន្តែ នៅតែទៅទិញវត្ថុដូចគ្នានោះ ទោះបីជាខ្លួនដឹងថា ការទៅទិញពីក្រោយខ្នងគេបែបនេះ អ្នកទិញប្រាកដជាជួបបញ្ហាក៏ដោយ ដែលជាករណីដែលគ្មានបំណងយ៉ាងសកម្មភាពដើម្បីបំពានដល់អ្នកដទៃបែបនេះ ហៅថា «ទុច្ចរិតធ្ងន់ធ្ងរ»។ |

### (3) ការបង្ហាញឆន្ទៈដោយភាន់ច្រឡំ

លើសពីនេះ ប្រសិនបើអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដែលខុសពីការគិតនៅក្នុងចិត្តទាំងស្រុង តើចំណុចនេះគួរដោះស្រាយយ៉ាងម៉េចដែរ? ក្រមរដ្ឋប្បវេណីហៅចំណុចនេះថា ការភាន់ច្រឡំ ហើយការបង្ហាញឆន្ទៈដោយការភាន់ច្រឡំនោះអាចលុបចោលបាន (មាត្រា95។ នៅមុនពេលវិសោធនកម្មនៅឆ្នាំ2017 គេចាត់ទុកថា មោឃភាព ប៉ុន្តែ ត្រូវប្ដូរមកជាការលុបចោលវិញ តាមរយៈវិសោធនកម្ម)។ នៅក្នុងផ្នែកអំពី ការភាន់ច្រឡំនេះ គឺជាផ្នែកដែលត្រូវបានវិសោធនកម្មធំជាងគេ នៅក្នុងការធ្វើវិសោធនកម្មនៅឆ្នាំ2017។

ការភាន់ច្រឡំរួមមាន ① ការភាន់ច្រឡំដែលខ្វះឆន្ទៈស្របគ្នាទៅនឹងឆន្ទៈដែលបានបង្ហាញ (ឧទាហរណ៍ អ្នកលក់បានសរសេរផ្លាកតម្លៃ ហើយបិតលើទំនិញដោយសរសេរខ្វះលេខសូន្យមួយ។ មាត្រា95 កថាខណ្ឌទី1 ចំណុចទី1) និង ② ការភាន់ច្រឡំដែលការយល់ដឹងអំពីស្ថានភាពដែលអ្នកបង្ហាញឆន្ទៈយកជាមូលដ្ឋាននៃសកម្មភាពគតិយុត្តខុសពីការពិត (ឧទាហរណ៍ អ្នកបង្ហាញឆន្ទៈបាននិយាយថាទិញសេះ ដោយសារតែខ្លួនគិតថាសេះនោះកំពុងផើមដែលការពិតសេះនោះមិនផើមនោះទេ។ មាត្រា95 កថាខណ្ឌទី1 ចំណុចទី2)។ ការភាន់ច្រឡំចំណុចទី② ហៅថា ការភាន់ច្រឡំអំពីមូលហេតុ។ វិសោធនកម្មច្បាប់បានកំណត់ថាអាចលុបចោលបាន ចំពោះការបង្ហាញឆន្ទៈទាំងនេះ ក្នុងករណីដែលការភាន់ច្រឡំនោះមានសារៈសំខាន់ ដោយពិចារណាលើគោលបំណងនៃសកម្មភាពគតិយុត្ត និង ការយល់ឃើញទូទៅក្នុងការធ្វើជំនួញ (មាត្រា95 កថាខណ្ឌទី1 វាក្យខណ្ឌទី1។ នៅមុនពេលវិសោធនកម្ម គេហៅថា ការភាន់ច្រឡំអំពី «សារធាតុ»។)។ ប៉ុន្តែ នៅក្នុងករណីនៃការភាន់ច្រឡំអំពីមូលហេតុ ពោលគឺផ្អែកលើបញ្ញត្តិនៃចំណុចទី2 អ្នកបង្ហាញឆន្ទៈអាចលុបចោលបាន លុះត្រាតែបានបង្ហាញអំពីស្ថានភាពដែលជាមូលដ្ឋាននៃសកម្មភាពគតិយុត្តចំពោះអង្គហេតុនោះ (មានន័យថា បានបង្ហាញចេញអំពីមូលហេតុ)។

លើសពីនេះ នៅក្នុងករណីដែលការភាន់ច្រឡំកើតឡើងដោយសារតែកំហុសធ្ងន់ធ្ងររបស់អ្នកបង្ហាញឆន្ទៈ (ដោយសារតែគ្មានភាពចាំបាច់ត្រូវការពារដល់អ្នកបង្ហាញឆន្ទៈ) ការលុបចោលការបង្ហាញឆន្ទៈនោះមិនអាចធ្វើបាននោះទេ។ ប៉ុន្តែ ចំណុចខាងលើនេះ ត្រូវលើកលែងចំពោះករណីដែលភាគីម្ខាងទៀតបានដឹងអំពីការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ ឬ មិនបានដឹងដោយមានកំហុសធ្ងន់ធ្ងរ និង ករណីដែលភាគីម្ខាងទៀតបានភាន់ច្រឡំដូចគ្នាជាមួយអ្នកបង្ហាញឆន្ទៈ (ដោយសារតែគ្មានភាពចាំបាច់ត្រូវការពារដល់ភាគីម្ខាងទៀត) ដូចនេះ អ្នកបង្ហាញឆន្ទៈអាចអនុញ្ញាតឱ្យអះអាងពីការភាន់ច្រឡំបាន ទោះបីជាមានកំហុសធ្ងន់ធ្ងរក៏ដោយ(មាត្រាដូចគ្នា កថាខណ្ឌទី៣ ចំណុចទី១ និងទី២។

ហើយការលុបចោលទាំងនេះមិនអាចតតាំងចំពោះតតិយជនសុចរិត និង គ្មានកំហុសបានទេ ដូចគ្នានឹងករណីឆបោកដែលបានរៀបរាប់ខាងលើផងដែរ (មាត្រា94 កថាខណ្ឌទី4)។ ចំណុចនេះផងដែរ ការធ្វើវិសោធនកម្មច្បាប់បានកែតម្រូវអានុភាពនៃការឆបោក និង ការភាន់ច្រឡំឱ្យដូចគ្នា (⇒ពាក្យគន្លឹះ៖ លក្ខខណ្ឌ និង អានុភាព) ហេតុនេះ យើងអាចនិយាយថា បញ្ហាពីមុនមកត្រូវបានដោះស្រាយរួចរាល់។

<table>
<tr><td>

ពាក្យគន្លឹះ: **លក្ខខណ្ឌ និង អានុភាព**

នៅក្នុងពិភពច្បាប់ ស្ថានភាពមួយដែលត្រូវមានជាចាំបាច់ ដើម្បីយកបទបញ្ញត្តិណាមួយមកអនុវត្តបាន (ដើម្បីឱ្យបទបញ្ញត្តិនោះអាចប្រើការបាន) គេហៅថាជា លក្ខខណ្ឌ (ភាសាជប៉ុនហៅថា «យ៉ាកេន»)។ (រីឯពាក្យថា «លក្ខខណ្ឌ» ក្នុងន័យមួយផ្សេងទៀត ដែលភាសាជប៉ុនអាចថា «ត្សូកេន» នោះវិញ គឺសំដៅលើការកំណត់លក្ខខណ្ឌតាមច្បាប់ក្នុងទម្រង់ឃ្លាថា «ប្រសិនបើ» ដូចជាពោលពាក្យថា «ប្រសិនបើប្រឡងជាប់មហាវិទ្យាល័យ យើងនឹង ជូនរថយន្តនេះជារង្វាន់» ជាដើម)។ លើសពីនេះ ពាក្យថា «អានុភាព» គឺជាអ្វីដែលនឹងត្រូវកើតមានឡើងបន្ទាប់ពីពេលដែលបានបំពេញចប់រួចរាល់ទៅតាមលក្ខខណ្ឌចាំបាច់ទាំងឡាយ និងបានអនុវត្តតាមច្បាប់បញ្ញត្តិហើយនោះ។ ដូចនេះ «អានុភាព» (ភាសាជប៉ុនហៅថា «ឃោកា» ប្រើក្នុងច្បាប់មិនមានន័យ ដូចពាក្យថា «គីគីម៉េ» ក្នុងភាសាជប៉ុន ដែលមានន័យថា «ប្រសិទ្ធភាព» ដូចក្នុងករណីពោលពាក្យថា «មានប្រសិទ្ធភាពក្នុងការកាត់បន្ថយទម្ងន់» នោះទេ។

</td></tr>
</table>

### (4) ឋបនីយផ្លូវចិត្ត

មួយវិញទៀត មនុស្សខ្លះក៏មានបំណងនិយាយកុហកផងដែរ។ តើការបង្ហាញឆន្ទៈនៅក្នុងករណីនេះគួរតែមិនទទួលស្គាល់អានុភាពដែរឬទេ? នៅក្នុងករណីបែបនេះ ចំពោះភាគីម្ខាងទៀតដែលមិនដឹង ប្រាកដជាជឿជាក់លើការនិយាយកុហកនោះ ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានកំណត់ថាមានអានុភាព បើទោះបីជាអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយការលេងសើច ឬ កុហកក៏ដោយ ហើយនេះហៅថា «ឋបនីយផ្លូវចិត្ត» (មានន័យថាមានការបំរុងទុកជាស្រេចនៅក្នុងចិត្ត)។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹង ឬ អាចដឹងថានេះមិនមែនជាឆន្ទៈពិតទេ ការបង្ហាញឆន្ទៈនោះត្រូវចាត់ទុកថាមោឃភាព (មាត្រា93 វាក្យខណ្ឌទី1 និង វាក្យខណ្ឌទី2)។

ដោយឡែក វិសោធនកម្មច្បាប់ឆ្នាំ2017 បានកំណត់ថ្មីនៅក្នុងមាត្រា93 កថាខណ្ឌទី2 ថា មោឃភាពនៃការបង្ហាញឆន្ទៈដោយផ្អែកតាមបញ្ញត្តិ កថាខណ្ឌទី2 វាក្យខណ្ឌទី2 មិនអាចតតាំងចំពោះតតិយជនសុចរិតបានទេ។ នេះគឺជាការការពារដល់តតិយជនសុចរិតចំពោះករណីឋបនីយផ្លូវចិត្ត ដែលដូចគ្នាទៅនឹងការបង្ហាញឆន្ទៈមិនពិតក្នុងមាត្រា94 កថាខណ្ឌទី2 ខាងក្រោមផងដែរ (សូមយោងការពន្យល់អំពីការបង្ហាញឆន្ទៈមិនពិតខាងក្រោម)។

### (5) ការបង្ហាញឆន្ទៈមិនពិតដោយឃុបឃិត

ករណីកាន់តែស៊ីជម្រៅជាងខាងលើនេះ គឺសាមីខ្លួន និង ភាគីម្ខាងទៀតបានឃុបឃិតគ្នា មានន័យថា បានពិភាក្សាជាមួយភាគីម្ខាងទៀត ហើយបង្ហាញឆន្ទៈមិនពិត។ ឧទាហរណ៍ A និង B បានសហការគ្នា ដោយផ្ទេរដីដែលជាកម្មសិទ្ធិរបស់ A មកឱ្យ B ដើម្បីបង្កើតឱ្យគេមើលឃើញថា A មានទ្រព្យសម្បត្តិតិចតួច ក្នុងគោលបំណងរត់គេចពីការទាមទារឱ្យទទួលខុសត្រូវពីម្ចាស់បំណុលរបស់ A។ ការបង្ហាញឆន្ទៈខាងលើនេះត្រូវមោឃភាព ដោយសារការបង្ហាញឆន្ទៈមិនពិត (ការបង្ហាញឆន្ទមិនពិតដោយឃុបឃិត) (មាត្រា94 កថាខណ្ឌទី1)។ ប៉ុន្តែ ប្រសិនបើបុគ្គលសុចរិត C ដែលជឿជាក់លើការទិញលក់ខាងលើនេះ ហើយបានទិញដីនោះបន្តពី B ក្នុងករណីនេះ ប្រសិនបើយើងចាត់ទុកកិច្ចសន្យាលក់ទិញរវាង A និង B មោឃភាព នោះ C នឹងទទួលរងការខាតផលប្រយោជន៍ ហេតុនេះហើយនៅក្នុងស្ថានភាពបែបនេះ A និង B មិនអាចតតាំងអំពីមោឃភាពនៃការបង្ហាញឆន្ទៈមិនពិត ចំពោះតតិយជនសុចរិត C នោះទេ (មាត្រា94 កថាខណ្ឌទី2)។ អត្ថន័យដើមនៃបញ្ញត្តិនេះគឺ ការព្រមព្រៀងដែលខុសពីរូបភាពខាងក្រៅ អាចយកមកអនុវត្តតែចំពោះទំនាក់ទំនងរវាងគូភាគីប៉ុណ្ណោះ ប៉ុន្តែ ក្នុងពេលបច្ចុប្បន្ន បញ្ញត្តិនេះត្រូវយកមកអនុវត្តជាទម្រង់ «អនុវត្តប្រដូច» ចំពោះវិវាទទាក់ទងនឹងជំនួញអចលនវត្ថុជាក់ស្តែង ក្នុងនាមជាបញ្ញត្តិដែលការពារដល់បុគ្គលដែលជឿជាក់លើការមើលឃើញខាងក្រៅ (សូមយោងជំពូកទី3 II 2 (4) អំពីការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស)។

## 4. ការតំណាង ការតំណាងគ្មានសិទ្ធិ និងការតំណាងដែលមានលក្ខណៈជារូបភាព

### (1) ស្វ័យភាពខាងឆន្ទៈ និងប្រព័ន្ធនៃការតំណាង

បើពិចារណាពីគោលការណ៍ស្វ័យភាពខាងឆន្ទៈ បុគ្គលម្នាក់ៗអាចបង្កើតទំនាក់ទំនងគតិយុត្តដោយឆន្ទៈសេរីបាន ប៉ុន្តែ ទំហំនៃសកម្មភាពដែលបុគ្គលម្នាក់ៗអាចធ្វើបាន គឺមានដែនកំណត់។ ចំពោះហើយករណីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពដែលបានរៀបរាប់ពីមុន ជនទាំងនោះពុំមានឆន្ទៈពេញលេញនោះទេ ហេតុនេះហើយ ត្រូវមាននរណាម្នាក់ជួយបំពេញការបង្ហាញឆន្ទៈរបស់ជននោះ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានរៀបចំទុកនូវប្រព័ន្ធដែលបុគ្គលដទៃអាចបង្ហាញឆន្ទៈជំនួសឱ្យសាមីខ្លួន ហើយការបង្ហាញឆន្ទៈនោះបង្កើតឱ្យមាននូវអានុភាពគតិយុត្ត ក្នុងនាមជាការបង្ហាញឆន្ទៈរបស់សាមីខ្លួន។ នេះហៅថា ការតំណាង។ ដូចនេះ យើងអាចសរុបជារួមថា ការតំណាង គឺជាប្រព័ន្ធដើម្បីបំពេញស្វ័យភាពនៃឆន្ទៈចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព និង ដើម្បីពង្រីកស្វ័យភាពខាងឆន្ទៈចំពោះនីតិជនដែលមានសមត្ថភាពវិនិច្ឆ័យទូទៅ។

### (2) តំណាងដែលច្បាប់បានកំណត់ និងតំណាងដោយឆន្ទៈ




ការតំណាងចែកចេញជា2 គឺការតំណាងដែលច្បាប់បានកំណត់ និង ការតំណាងដោយឆន្ទៈ។ ឪពុកម្តាយរបស់អនីតិជនជាអាទិ៍ គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ ហើយច្បាប់បានប្រគល់ឋានៈជាអ្នកតំណាង ប៉ុន្តែការតំណាងដែលធ្វើឡើងជាទូទៅ គឺជាការតំណាងដោយឆន្ទៈ ដែលផ្តល់សិទ្ធិតំណាងដល់បុគ្គលជាក់លាក់តាមរយៈកិច្ចសន្យា។ បុគ្គលដែលក្លាយជាអ្នកតំណាងត្រូវបង្ហាញយ៉ាងដាច់ខាតថាសកម្មភាពនេះធ្វើឡើងដើម្បីម្ចាស់សិទ្ធិ (នេះហៅថា របបបញ្ជាក់នាម) សកម្មភាពគតិយុត្តនោះនឹងមានសុពលភាពចំពោះម្ចាស់សិទ្ធិផ្ទាល់ ពោលគឺ មានអានុភាពដូចគ្នានឹងសកម្មភាពដែលម្ចាស់សិទ្ធិធ្វើដោយខ្លួនឯង (មាត្រា99)។ ផ្ទុយមកវិញ ការបង្ហាញឆន្ទៈដែលអ្នកតំណាងបានធ្វើដោយមិនបញ្ជាក់នាម (ហើយជាស្ថានភាពដែលមិនដឹងថាអ្នកណាជាម្ចាស់សិទ្ធិទោះជាតាមរយៈកាលៈទេសៈជុំវិញក៏ដោយ) ត្រូវចាត់ទុកថា អ្នកតំណាងបានធ្វើឡើងដើម្បីខ្លួនឯង ហើយអានុភាពនោះត្រូវមានចំពោះ

អ្នកតំណាង ការកំណត់បែបនេះគឺដើម្បីការពារដល់ភាគីម្ខាងទៀត (មាត្រា100)។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីការបង្ហាញឆន្ទៈតំណាងរបស់អ្នកតំណាង (ការបង្ហាញឆន្ទៈដើម្បីម្ចាស់សិទ្ធិ) អានុភាពត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ (មាត្រា100 វាក្យខណ្ឌទី2)។

មួយវិញទៀត អានុភាពទាំងអស់នៃការតំណាងមានទៅលើម្ចាស់សិទ្ធិ ហើយអ្នកតំណាងមិនមានទទួលរងការខាតប្រយោជន៍អ្វីទាំងអស់ ហេតុនេះហើយ សូម្បីតែជនដែលត្រូវបានកម្រិតសម្តភាពក្នុងការធ្វើសកម្មភាពដែលបានរៀបរាប់ពីមុន ក៏អាចក្លាយជាអ្នកតំណាងរបស់បុគ្គលដទៃដែរ (មាត្រា102)។ ប៉ុន្តែ ក្នុងករណីដែលបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពបានទទួលដីកាសម្រេចចាប់ផ្តើមអាណាព្យាបាលដូចបានរៀបរាប់ពីមុន ក្នុងពេលខ្លួនកំពុងធ្វើជាអ្នកតំណាង ការតំណាងនោះត្រូវរលត់។ ត្រូវអនុវត្តដូចគ្នាចំពោះករណីធនក្ស័យរបស់អ្នកតំណាង ឬ មរណភាពរបស់ម្ចាស់សិទ្ធិ ឬ អ្នកតំណាង (មាត្រា111 កថាខណ្ឌទី1)។ ក្រៅពីនេះ ទោះបីជាអានុភាពទាំងអស់កើតមានចំពោះម្ចាស់សិទ្ធិផ្ទាល់ក៏ដោយ ក៏អ្នកដែលបង្ហាញឆន្ទៈជាក់ស្តែងគឺអ្នកតំណាង ហេតុនេះ បើសិនជាមានបញ្ហាទាក់ទងនឹងវិការៈនៃការបង្ហាញឆន្ទៈ និង សុចរិត ឬ ទុច្ចរិតដូចមានរៀបរាប់ខាងលើ ជាគោលការណ៍គឺត្រូវវិនិច្ឆ័យអំពីបញ្ហានេះចំពោះអ្នកតំណាង (មាត្រា101 កថាខណ្ឌទី1)។

ដោយឡែក ការធ្វើជាអ្នកតំណាងឱ្យភាគីម្ខាងទៀត (កិច្ចសន្យារបស់ខ្លួនឯង) ឬ ធ្វើជាអ្នកតំណាងឱ្យភាគីទាំងសងខាង (តំណាងឱ្យសងខាង) ចំពោះសកម្មភាពគតិយុត្តតែមួយ ត្រូវចាត់ទុកជាសកម្មភាពដែលបានធ្វើដោយបុគ្គលដែលគ្មានសិទ្ធិតំណាង (មានន័យថា ការតំណាងដែលគ្មានសិទ្ធិដែលនឹងរៀបរាប់ខាងក្រោម) ប៉ុន្តែសកម្មភាពខាងលើនេះអាចធ្វើទៅបានបើម្ចាស់សិទ្ធិបានអនុញ្ញាតជាមុន (មាត្រា108)។

### (3) ការតំណាងដែលគ្មានសិទ្ធិ និងការតំណាងដែលមានលក្ខណៈជារូបភាព

ប្រសិនបើអ្នកដទៃណាម្នាក់ដែលមិនត្រូវបានផ្តល់សិទ្ធិតំណាងផង ប៉ុន្តែ បានបន្លំខ្លួនធ្វើជាអ្នកតំណាង ហើយចុះកិច្ចសន្យាដើម្បីម្ចាស់សិទ្ធិ តើរឿងនេះនឹងទៅជាយ៉ាងណា? នេះហៅថា ការតំណាងដែលគ្មានសិទ្ធិ ហើយអានុភាពនៃការតំណាងមិនកើតមាននោះទេ បើសិនជាម្ចាស់សិទ្ធិមិនផ្តល់សច្ចានុម័ត (មាត្រា113 កថាខណ្ឌទី1)។ ការកំណត់បែបនេះ គឺដើម្បីការពារម្ចាស់សិទ្ធិ។ ក្នុងករណីនេះ ភាគីម្ខាងទៀតអាចទាមទារឱ្យអ្នកតំណាងដោយគ្មានសិទ្ធិនោះអនុវត្តជំនួស ឬ សងសំណងការខូចខាត (មាត្រា117 កថាខណ្ឌទី1)។

ប៉ុន្តែ នៅក្នុងករណីដែលម្ចាស់សិទ្ធិបានបង្ហាញថាផ្តល់សិទ្ធិតំណាងឱ្យទៅបុគ្គលណាម្នាក់ ទាំងរឿងនោះមិនមែនជាការពិត ឬ ករណីដែលបានផ្តល់សិទ្ធិតំណាងទៅឱ្យដែរ ប៉ុន្តែ អ្នកតំណាងនោះអនុវត្តសកម្មភាពតំណាងលើសពីកម្រិតនៃសិទ្ធិតំណាងដែលបានផ្តល់ឱ្យ ឬ ករណីដែលបានផ្តល់សិទ្ធិតំណាងឱ្យបុគ្គលនោះពីមុនដែរ ប៉ុន្តែមិនបានជូនដំណឹងអំពីការរលត់សិទ្ធិតំណាងនោះទៅភាគីម្ខាងទៀត ដូចនេះ យើងមានភាពចាំបាច់ដើម្បីការពារដល់ភាគីម្ខាងទៀតដែលបានជឿជាក់លើរូបភាពខាងក្រៅបែបនេះ។ ហេតុនេះ ក្រមរដ្ឋប្បវេណីបានរៀបចំទុកនូវ

ប្រព័ន្ធនៃការតំណាងដែលមានលក្ខណៈជារូបភាព ហើយកំណត់ឱ្យម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវ ប្រសិនបើភាគីម្ខាងទៀតបានជឿជាក់លើរូបភាពខាងក្រៅបែបនេះ ដោយសុចរិតនិងគ្មានកំហុស។ មាត្រា109 កំណត់អំពី**ការតំណាងដែលមានលក្ខណៈជារូបភាពដោយសារការបង្ហាញការផ្តល់សិទ្ធិតំណាង**, មាត្រា110 កំណត់អំពី**ការតំណាងដែលមានលក្ខណៈជារូបភាពនៃការអនុវត្តហួសទំហំនៃសិទ្ធិ** និង មាត្រា112 កំណត់អំពី**ការតំណាងដែលមានលក្ខណៈជារូបភាពនៅក្រោយការរលត់សិទ្ធិតំណាង** (មាត្រា109 មិនបានបង្ហាញច្បាស់អំពីលក្ខខណ្ឌសុចរិត និងគ្មានកំហុសទេ ប៉ុន្តែ ចំណុចនេះត្រូវបានបន្ថែមជាបញ្ញត្តិច្បាស់លាស់នៅក្នុងវិសោធនកម្មឆ្នាំ2004។ ដោយឡែក សូម្បីតែ ពាក្យថា «មូលហេតុត្រឹមត្រូវ» ក្នុងមាត្រា110 ក៏ត្រូវរួមបញ្ចូលទាំងអត្ថន័យអំពី ភាពសុចរិត និងគ្មានកំហុសរបស់តតិយជនផងដែរ)។

ការតំណាងជាលក្ខណៈរូបភាពនេះ មានតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចការជំនួញបច្ចុប្បន្ន។ ហើយវិធីការពារតតិយជនក្នុងកិច្ចការជំនួញដែលយើងមើលឃើញនៅទីនេះ គឺដើមឡើយម្ចាស់សិទ្ធិពិតប្រាកដ (ករណីនេះគឺ សំដៅលើម្ចាស់សិទ្ធិ) មានកំហុសណាមួយ ហើយតតិយជនដែលចូលទៅក្នុងកិច្ចការជំនួញបានជឿជាក់ដោយសុចរិត និង គ្មានកំហុស ហើយបង្កើតឱ្យមានការតំណាងជាលក្ខណៈរូបភាព ដើម្បីការពារទៅដល់តតិយជន ហើយទ្រឹស្តីច្បាប់នេះហៅថា **ទ្រឹស្តីច្បាប់ដែលការពារការជឿជាក់លើរូបភាពខាងក្រៅ** (**ទ្រឹស្តីច្បាប់មើលឃើញរូបភាពខាងក្រៅនៃសិទ្ធិ** និង **ទ្រឹស្តីច្បាប់លក្ខណៈរូបភាព**)។

## 5. មោឃភាព និង ការលុបចោល

ពាក្យថា មោឃភាព នៅក្នុងក្រមរដ្ឋប្បវេណី មានន័យថា ការមិនកើតមានអានុភាពអ្វីទាំងអស់តាំងពីដំបូង។ មោឃភាពអាចបែងចែកជា 2 គឺ ករណីដែលច្បាប់កំណត់ថាមោឃភាពដាច់ខាត ចំពោះសកម្មភាពគតិយុត្តប្រឆាំងនឹងសង្គម ដូចជាសកម្មភាពគតិយុត្តដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនៅក្នុងមាត្រា90 និងករណីមោឃភាពដែលត្រូវបានកំណត់ជាវិធានមួយដើម្បីការពារភាគី ដូចជា ឋបនីយផ្លូវចិត្ត ជាអាទិ៍។ ចំណែកឯការលុបចោលវិញ គឺមានអានុភាពរហូតដល់ពេលលុបចោល ហើយនៅពេលមានការលុបចោលត្រូវចាត់ទុកថាមោឃភាពតាំងពីដំបូង (មាត្រា121) (⇒ពាក្យគន្លឹះ៖ សន្មត និង ចាត់ទុក) មានន័យថា មិនមានអានុភាពអ្វីទាំងអស់កើតឡើងគិតត្រឡប់ទៅតាំងពីពេលចាប់ផ្តើមដំបូង (នេះហៅថា «**មានអានុភាពប្រតិសកម្ម**»)។ លើសពីនេះ សកម្មភាពដែលអាចត្រូវបានលុបចោល អាចទទួលស្គាល់នៅពេលក្រោយបាន ដូចជា ឪពុកម្តាយអាចទទួលស្គាល់នៅពេលក្រោយចំពោះកិច្ចសន្យាទិញលក់ដែលគ្មានការយល់ព្រមពីខ្លួនដែលជាឪពុកម្តាយ (នេះហៅថា «**សច្ចានុម័ត**») ហើយអានុភាពនៃការផ្តល់សច្ចានុម័តនោះ ក៏មានលក្ខណៈប្រតិសកម្មដែរ (មាត្រា122)។ ប៉ុន្តែ សកម្មភាពដែលមោឃភាព គឺគ្មានអានុភាពតាំងពីដំបូង ហេតុនេះមិនអាចផ្តល់សច្ចានុម័តនៅពេលក្រោយ ហើយក្លាយជាមានអានុភាពនោះទេ (មាត្រា119 វាក្យខណ្ឌទី1)។ ដោយឡែក បុគ្គលដែលអាចលុបចោលបាន(**អ្នកមានសិទ្ធិលុបចោល**) មានកំណត់ក្នុងមាត្រា120 នៃក្រមរដ្ឋប្បវេណី (រួមមាន សាមីខ្លួនដែលជាជនដែលត្រូវបានកម្រិតសមត្ថ

ភាពដូចជាអនីតិជនជាអាទិ៍ ឬ បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារការឆបោកជាអាទិ៍ និងអ្នកតំណាង ឬ ប្រតិសិទ្ធិរបស់ជនទាំងនោះប៉ុណ្ណោះ)។ មួយវិញទៀត សកម្មភាពដែលមោឃភាពមិនអាចក្លាយជាមានអានុភាពដោយសារការកន្លងផុតនៃពេលវេលានោះទេ ប៉ុន្តែ សកម្មភាពដែលអាចលុបចោល អាចក្លាយទៅជាមិនអាចលុបចោលបានដោយសារការកន្លងផុតនៃពេលវេលា ហើយជាលទ្ធផលសកម្មភាពនោះមានអានុភាពជាស្ថាពរ (សិទ្ធិលុបចោលត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើមិនបានអនុវត្តក្នុងរយៈពេល 5ឆ្នាំ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុម័តបាន ឬ ក្នុងរយៈពេល 20ឆ្នាំ គិតចាប់ពីពេលធ្វើសកម្មភាព។ មាត្រា126។ ⇒យោងជំពូកនេះ III 7. អាជ្ញាយុកាល)។

ពាក្យគន្លឹះ: **ការសន្មត និង ការចាត់ទុក**

ក្នុងបរិបទច្បាប់ «ការសន្មត» សំដៅទៅលើ ការសន្មតថាបែបនឹងជាបណ្តោះអាសន្នសិន ប៉ុន្តែ គេអនុញ្ញាតឱ្យភាគីដាក់ភស្តុតាងផ្ទុយ ពោលគឺ ភាគីអាចបញ្ជាក់ថាអង្គហេតុនេះមិនពិតទេ ហើយលុបចោលការសន្មតនោះបាន។ ផ្ទុយមកវិញ «ការចាត់ទុក» សំដៅទៅលើ ការដែលច្បាប់បានសម្រេចថាបែបនឹង ហើយមិនអនុញ្ញាតឱ្យមានការបញ្ជាក់ផ្ទុយពីនេះ ហើយលុបចោលការចាត់ទុកនោះទេ។

## 6. **លក្ខខណ្ឌ និង ការកំណត់ពេល**

### (1) សេចក្តីផ្តើម

នៅក្នុងការអនុវត្តសកម្មភាពគតិយុត្ត ភាគីអាចកំណត់មិនឱ្យអានុភាពនោះកើតឡើងភ្លាមៗ រហូតដល់ចំណុចពេលវេលាមួយក្នុងពេលអនាគត ឬ រហូតដល់កើតមានព្រឹត្តការណ៍ណាមួយក្នុងពេលអនាគត ទើបកើតមានអានុភាពបាន (ឬផ្ទុយមកវិញ គឺឱ្យអស់អានុភាពបាន)។ នេះជាបញ្ហាទាក់ទងនឹង លក្ខខណ្ឌ និងការកំណត់ពេល។ ភាពខុសគ្នារវាងលក្ខខណ្ឌ និង ការកំណត់ពេលគឺ លក្ខខណ្ឌគឺជាការកំណត់ទាក់ទងនឹងព្រឹត្តការណ៍ដែលមិនទៀងទាត់ថានឹងអាចកើតមានឡើងនោះទេ ដូចជា ប្រសិនបើប្រឡងជាប់ជាគណនេយ្យករជាដើម ចំណែកឯ ការកំណត់ពេលគឺជាការកំណត់ទាក់ទងនឹងពេលវេលាដែលទៀងទាត់ថានឹងមកដល់ ដូចជា ដើមឆ្នាំក្រោយ ឬ ពេលដល់នីតិភាពជាដើម។

### (2) លក្ខខណ្ឌ

លក្ខខណ្ឌចែកចេញជា 2។ បើសិនជាអានុភាពចាប់ផ្តើមកើតឡើងដោយសារលក្ខខណ្ឌត្រូវបានបំពេញ (អានុភាពត្រូវបានបង្អង់រហូតមកដល់ពេលនេះ) ហៅថា **លក្ខខណ្ឌបង្អង់** ហើយចំណែកឯ អានុភាពត្រូវរលត់ដោយសារលក្ខខណ្ឌត្រូវបានបំពេញ ចំពោះសកម្មភាពគតិយុត្តដែលកើតមានអានុភាពរួចហើយ ហៅថា **លក្ខខណ្ឌរំលាយ** (មាត្រា127)។ ការកំណត់ថា «ខ្ញុំនឹងផ្តល់អាហាររូបករណ៍ ប្រសិនបើប្រឡងជាប់មហាវិទ្យាល័យ» គឺជាការដាក់លក្ខខណ្ឌបង្អង់ចំពោះកិច្ចសន្យាប្រទានកម្ម ហើយការកំណត់ថា «ខ្ញុំឱ្យនាឡិកានេះទៅអ្នក ប៉ុន្តែបើរៀនមិន

បានឡើងថ្លៃហើយក៏ត្រូវសងមកខ្ញុំវិញ» គឺជាការដាក់លក្ខខណ្ឌរំលាយកិច្ចសន្យាប្រទានកម្ម។ ករណីលក្ខខណ្ឌដែលគ្មានលទ្ធភាពនឹងបំពេញ (ហៅថា **លក្ខខណ្ឌអលទ្ធភាព**) ចំពោះលក្ខខណ្ឌបង្អង់ គឺមានន័យថាមោឃភាព ដោយសារតែអានុភាពមិនអាចកើតមានឡើងនោះទេ ហើយចំពោះលក្ខខណ្ឌរំលាយ គឺមានន័យថាគ្មានលក្ខខណ្ឌ ដោយសារតែមិនអាចបាត់បង់អានុភាព (មាត្រា133)។ ដោយឡែក ប្រសិនបើបុគ្គលដែលខាតបង់ផលប្រយោជន៍ ដោយសារលក្ខខណ្ឌត្រូវបានបំពេញ បានរារាំងមិនឱ្យលក្ខខណ្ឌនោះត្រូវបានបំពេញដោយចេតនា ភាគីម្ខាងទៀត អាចចាត់ទុកថាលក្ខខណ្ឌនោះត្រូវបានបំពេញ។ ផ្ទុយមកវិញ ប្រសិនបើភាគីដែលទទួលផលប្រយោជន៍ពីការបំពេញលក្ខខណ្ឌ បានបំពេញលក្ខខណ្ឌនោះដោយមិនត្រឹមត្រូវ ភាគីម្ខាងទៀតអាចចាត់ទុកថា លក្ខខណ្ឌមិនត្រូវបានបំពេញនោះទេ (មាត្រា130)។

### (3) ការកំណត់ពេល

ការកំណត់ពេលគឺជាការកំណត់ព្រឹត្តិការណ៍ដែលទៀងទាត់ថានឹងមកដល់ ហើយការកំណត់ពេលអាចបែងចែកជា 2។ **ការកំណត់ពេលពិតប្រាកដ** សំដៅទៅលើការកំណត់យ៉ាងជាក់លាក់អំពីពេលវេលាដែលត្រូវមកដល់ ដូចជា ឆ្នាំក្រោយ ខែមេសាជាដើម ចំណែកឯ **ការកំណត់ពេលមិនពិតប្រាកដ** សំដៅទៅលើការកំណត់ព្រឹត្តិការណ៍ដែលទៀងទាត់ថានឹងមកដល់ ប៉ុន្តែមិនអាចដឹងថានឹងមកដល់ពេលណា ដូចជា នៅពេលមានខ្យល់ព្យុះលើកក្រោយ ជាដើម។ នៅមុនការកំណត់ពេលមកដល់ ប្រយោជន៍ដែលភាគីទទួលបានហៅថា **ប្រយោជន៍នៃកំណត់ពេល**។ ប្រសិនបើយកចុងខែមីនា ជាការកំណត់ពេលសង មានន័យថា កូនបំណុលទទួលបានប្រយោជន៍នៃការកំណត់ពេល ដោយមិនចាំបាច់ត្រូវសងប្រាក់រហូតដល់ចុងខែមីនាបាន។ ប្រយោជន៍នៃការកំណត់ពេលអាចបោះបង់ចោលបាន លុះត្រាតែមិនធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត (ទោះបីជាកំណត់ពេលសង នៅចុងខែមីនាក៏ដោយ ក៏កូនបំណុលអាចសងនៅចុងខែកុម្ភៈបានដែរ។ មាត្រា136 កថាខណ្ឌទី2)។ ប្រយោជន៍នៃការកំណត់ពេលត្រូវសន្មតថាជាប្រយោជន៍របស់កូនបំណុល (មាត្រា136 កថាខណ្ឌទី1) ហើយប្រយោជន៍នៃការកំណត់ពេលនេះនឹងបាត់បង់ទៅវិញ ប្រសិនបើមានសកម្មភាព ឬ អង្គហេតុដែលធ្វើឱ្យបាត់បង់ជំនឿចិត្តលើកូនបំណុល (មាត្រា137)។ សកម្មភាពដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីមានដូចជា ដីកាសម្រេចប្រកាសចាប់ផ្តើមនីតិវិធីក្ស័យធនចំពោះកូនបំណុល ជាដើម ប៉ុន្តែ ភាគីក៏អាចព្រមព្រៀងនៅក្នុងកិច្ចសន្យាថា បើសិនជាមានករណីនេះកើតឡើង កូនបំណុលត្រូវបាត់បង់ប្រយោជន៍នៃការកំណត់ពេល ទុកជាមុនបាន (ហៅថា **ការបាត់បង់ផលប្រយោជន៍នៃកំណត់ពេលតាមកិច្ចសន្យា**)។ ដោយឡែក នៅក្នុងការអនុវត្តជាក់ស្តែង ការបាត់បង់ផលប្រយោជន៍នៃកំណត់ពេលតាមកិច្ចសន្យា តែងតែត្រូវបានកំណត់ក្នុងកិច្ចសន្យាកម្ចីប្រាក់ស្ទើរគ្រប់កិច្ចសន្យា (សូមយោង សៀវភៅនេះ ជំពូកទី4 ចំណុច5. អំពីកិច្ចសន្យាខ្ចីប្រាក់)។ ឧទាហរណ៍ អ្នកខ្ចីនឹងត្រូវបាត់បង់ប្រយោជន៍នៃការកំណត់ពេល បើសិនជាយឺតយ៉ាវក្នុងការសង កម្ចីចំនួនប៉ុន្មានលើកជាដើម (សូមអ្នកទាំងអស់គ្នាប្រុងប្រយ័ត្នថា ប្រសិនបើបាត់បង់ប្រយោជន៍នៃការកំណត់ពេល កូនបំណុលត្រូវតែសងប្រាក់កម្ចីដែលនៅសល់ទាំងអស់ឱ្យទៅម្ចាស់បំណុលភ្លាមៗ)។

## 7. អាជ្ញាយុកាល

### (1) អាជ្ញាយុកាលនៃការរំលត់ និង អាជ្ញាយុកាលនៃលទ្ធកម្ម

នៅចំណុចនេះ ខ្ញុំនឹងរៀបរាប់អំពីអាជ្ញាយុកាល។ អ្នកទាំងអស់គ្នាប្រហែលជាធ្លាប់បានមើលភាពយន្តដែលនិយាយអំពីអាជ្ញាយុកាលនៃក្រមព្រហ្មទណ្ឌរួចហើយ ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីក៏មានបញ្ញត្តអំពីអាជ្ញាយុកាលទាំងនៅលើសិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្សផងដែរ ហើយត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិទូទៅនេះ។ អាជ្ញាយុកាលនៅទីនេះមាន 2ប្រភេទ គឺ អាជ្ញាយុកាលនៃការរំលត់ និង អាជ្ញាយុកាលនៃលទ្ធកម្ម។ ហើយអាជ្ញាយុកាលដែលងាយស្រួលយល់ជាងគេ ប្រហែលជាអាជ្ញាយុកាលនៃការរំលត់។ មាត្រា166 កថាខណ្ឌទី1 នៃក្រមរដ្ឋប្បវេណីបានកំណត់ថា សិទ្ធិលើបំណុលទូទៅ (ដូចជា សិទ្ធិលើបំណុលចំពោះប្រាក់កម្ចីរបស់បុគ្គលទូទៅ ជាដើម) នឹងត្រូវរលត់ប្រសិនបើមិនអនុវត្តក្នុងអំឡុងពេល 5ឆ្នាំ គិតចាប់ពីពេលម្ចាស់បំណុលបានដឹងថាអាចអនុវត្តសិទ្ធិបាន(ចំណុចចាប់ផ្តើមជាអត្តនោម័ត) ឬ ក្នុងអំឡុងពេល 10ឆ្នាំ គិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិបាន (ចំណុចចាប់ផ្តើមជាសត្យានុម័ត)។ ដោយឡែក ចំពោះសិទ្ធិទាមទារសំណងការខូចខាតដោយសារការបំពានលើអាយុជីវិត ឬ រូបរាងកាយ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់គឺ 20ឆ្នាំ (ដើម្បីផ្តល់ការការពារយ៉ាងគ្រប់គ្រាន់ដល់ជនរងគ្រោះ) ក្នុងករណីដែលម្ចាស់បំណុលមិនបានដឹងថាអាចអនុវត្តសិទ្ធិបាន (មាត្រា167)។ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីសិទ្ធិលើបំណុលផ្សេងទៀត (មិនរួមបញ្ចូលនូវកម្មសិទ្ធិ) នឹងត្រូវផុតអាជ្ញាយុកាលក្នុងរយៈពេល 20ឆ្នាំនៃការមិនអនុវត្តសិទ្ធិដោយគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិបាន (មាត្រា166 កថាខណ្ឌទី2)។

ផ្ទុយមកវិញ អាជ្ញាយុកាលនៃលទ្ធកម្ម សំដៅទៅលើការបន្តប្រើប្រាស់វត្ថុរបស់អ្នកដទៃដោយគិតថាជារបស់ខ្លួនរាប់សិបឆ្នាំ និងជាហេតុនាំឱ្យវត្ថុនោះក្លាយជារបស់ជនដែលកំពុងបន្តប្រើប្រាស់នោះ ហើយម្ចាស់សិទ្ធិដើមមិនអាចទាមទារឱ្យជននោះសងវិញនោះទេ។ ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ មាត្រា162 នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តថា ជនដែលកាន់កាប់ ពោលគឺកំពុងក្តោបក្តាប់ និងប្រើប្រាស់វត្ថុរបស់អ្នកដទៃនៅក្រោមការគ្រប់គ្រងរបស់ខ្លួនជាបន្តបន្ទាប់រយៈពេល 20ឆ្នាំ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ (មានន័យថា ស្ថានភាពមួយដែលអ្នកជុំវិញនោះបានដឹង និង គ្មានរឿងរ៉ាវកើតឡើង) និងដោយមានឆន្ទៈយកជាកម្មសិទ្ធិរបស់ខ្លួន អាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះបាន។ លើសពីនេះ ក្នុងករណីអចលនវត្ថុ មាត្រាដដែលនេះបានបញ្ញត្តថា បើសិនជាជននោះសុចរិត និង គ្មានកំហុសនៅពេលចាប់ផ្តើមកាន់កាប់ទេ (ពាក្យថា «សុចរិត» ធ្លាប់បានរៀបរាប់រួចហើយ គឺមានអត្ថន័យថាមិនបានដឹងអំពីស្ថានភាព មិនមែនមានន័យថា សណ្តានចិត្តល្អនោះទេ ⇒ពាក្យគន្លឹះ: សុចរិត និងទុច្ចរិត) ពោលគឺមិនបានដឹងថាខ្លួនមិនមែនជាម្ចាស់សិទ្ធិពិតប្រាកដនៅពេលដែលខ្លួនចាប់ផ្តើមកាន់កាប់ ហើយមិនមានកំហុសក្នុងការមិនបានដឹង មានន័យថា ជាស្ថានភាពមួយដែលជាទូទៅគ្មានលទ្ធភាពនឹងអាចដឹងបាន ដូចនេះ អាជ្ញាយុកាលនៃលទ្ធកម្ម មានរយៈពេល 10ឆ្នាំ (មាត្រា162 កថាខណ្ឌទី2)។

សូមអ្នកទាំងអស់គ្នាប្រុងប្រយ័ត្នត្រង់ចំណុចនេះថា កម្មសិទ្ធិមិនរលត់ដោយអាជ្ញាយុកាលនោះទេ (ចំណែកឯសិទ្ធិប្រត្យក្សផ្សេងទៀតនឹងត្រូវផុតអាជ្ញាយុកាលក្នុងរយៈពេល 20ឆ្នាំ)។ ឧទាហរណ៍ថា ទោះបីជា A ទុកដីរបស់ខ្លួនចោលប៉ុន្មានឆ្នាំក៏ដោយ ក៏កម្មសិទ្ធិនោះមិនរលត់ដោយឯកឯងដែរ។ ទោះបីជាម្ចាស់សិទ្ធិទុកដីឱ្យទំនេរចោលរហូតដល់ពេលទទួលមរណភាពក៏ដោយ បើសិនជាមានសហព័ទ្ធ ឬ កូន បុគ្គលទាំងនោះនឹងទទួលបន្តដោយសន្តតិកម្ម។ ប៉ុន្តែ ប្រសិនបើ B បានចូលទៅរស់នៅដីរបស់ A ហើយបើសិនជា A និងក្រុមគ្រួសារជាដើមមិនបានអះអាងអ្វីទាល់តែសោះ ហើយទុកឱ្យ B រស់នៅហាក់បីដូចជាកម្មសិទ្ធិករលើដីនោះចាប់ពី 20ឆ្នាំ ឡើងទៅ ដូចនេះ B នឹងធ្វើលទ្ធកម្មដោយអាជ្ញាយុកាលលើដីនោះ ហើយជាលទ្ធផល A មិនអាចទាមទារឱ្យគេសងមកខ្លួនវិញទេ ឬ អាចនិយាយថាបាត់បង់កម្មសិទ្ធិតែម្តង។

### (2) ការគណនាអំឡុងពេលអាជ្ញាយុកាល

ជាគោលការណ៍ ការគណនាអំឡុងពេលត្រូវអនុលោមតាមបញ្ញត្តិនៃជំពូកទី6 គន្ថីទី1 នៃក្រមរដ្ឋប្បវេណីលើកលែងតែករណីមួយផ្នែក (មាត្រា138)។ ករណីមួយផ្នែកសំដៅលើ ករណីមានកំណត់ផ្សេងនៅក្នុងច្បាប់ ឬ បញ្ញត្តិផ្សេង ឬ ករណីមានការសម្រេចបង្គាប់ពីតុលាការ ឬករណីមានកំណត់ផ្សេងជាមុននៅក្នុងសកម្មភាពគតិយុត្តរបស់ភាគីដូចជា កិច្ចសន្យាជាដើម។

ឧទាហរណ៍ នៅពេលថ្ងៃត្រង់ក្នុងថ្ងៃនេះ យើងបាននិយាយថា «ខ្ចីប្រាក់រយៈពេល 1ខែ» ក្នុងករណីនេះ វិធីគណនាអំឡុងពេលជាគោលការណ៍ គឺពេលវេលាដែលនៅសល់ក្នុងថ្ងៃនេះត្រូវផាត់ចោលទាំងអស់ ហើយចាប់ផ្តើមរាប់ពីថ្ងៃស្អែក (មាត្រា140 វាក្យខណ្ឌទី1)។ វិធីគិតបែបនេះ ហៅថា «គោលការណ៍មិនរាប់បញ្ចូលថ្ងៃដែលចាប់ផ្តើម»។ ប៉ុន្តែ ឧទាហរណ៍ យើងបាននិយាយ «រយៈពេល 3ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី3 ខែក្រោយ» ក្នុងករណីនេះជាអញ្ញត្តិកម្ម ដោយត្រូវយកថ្ងៃទី3 ដែលជាថ្ងៃចាប់ផ្តើមទៅរាប់បញ្ចូល ហើយត្រូវដល់កំណត់ត្រឹមថ្ងៃទី3 ដល់ថ្ងៃទី5 (មាត្រា140 វាក្យខណ្ឌទី2)។

ក្នុងករណីដែលបានកំណត់អំឡុងពេលជាសប្តាហ៍ ខែ និង ឆ្នាំ យើងត្រូវគណនាដោយអនុលោមតាមប្រតិទិនសុរិយគតិ (មិនពិចារណាអំពីខែដែលមានចំនួនថ្ងៃច្រើន និង ថ្ងៃដែលមានចំនួនតិចនោះទេ។ មាត្រា143 កថាខណ្ឌទី1)។ ប្រសិនបើមិនរាប់បញ្ចូលអំឡុងពេលនៃដើមសប្តាហ៍ ដើមខែ ឬ ដើមឆ្នាំនោះទេ អំឡុងពេលនោះត្រូវបញ្ចប់នៅមួយថ្ងៃមុនថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើមរាប់នៃសប្តាហ៍ចុងក្រោយ ឬ ខែចុងក្រោយ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេល (មាត្រា143 កថាខណ្ឌទី2)។

បើមើលទៅតាមការប្រើប្រាស់ពាក្យពេចន៍ខាងលើ ហាក់បីដូចជារឿងមួយដែលពិបាក ប៉ុន្តែ ការពិតរឿងនេះមិនពិបាកនោះទេ។ មានន័យថា ប្រាក់កម្ចីធម្មតាដែលត្រូវសងនៅថ្ងៃទី31 ខែមីនា ឆ្នាំ2010 ហើយបើសិនជាម្ចាស់បំណុលទុកចោលរហូតដោយមិនទាមទារឱ្យសងនោះទេ អាជ្ញាយុកាលនៃអំឡុងពេល 10ឆ្នាំ នឹងចាប់ផ្តើមរាប់នៅថ្ងៃ

បន្ទាប់ដែលត្រូវនឹងថ្ងៃទី1 ខែមេសា រហូតដល់មុនមួយថ្ងៃនៃថ្ងៃទី1 (ថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើម) ខែមេសា 10ឆ្នាំក្រោយ ពោលគឺអាជ្ញាយុកាលនឹងស្ថាពរនៅម៉ោង 12យប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2020។

### (3) ការបន្តសារជាថ្មី និង ការបង្អង់ការចូលជាស្ថាពរ

ជាគោលការណ៍ អាជ្ញាយុកាលគឺគោរពនូវស្ថានភាពជាក់ស្តែងដែលបន្តជានិរន្តន៍ ដោយផ្តល់ឱ្យនូវសិទ្ធិណាមួយ ឬ រំលត់សិទ្ធិណាមួយ។ ហេតុនេះហើយ បើសិនជាមានការទទួលស្គាល់អំពីការអះអាងសិទ្ធិពីម្ចាស់សិទ្ធិពិតប្រាកដ ឬ បុគ្គលដែលគ្មានសិទ្ធិ និង កូនបំណុលដែលមិនបានសងបានទទួលស្គាល់សិទ្ធិរបស់ម្ចាស់សិទ្ធិពិតប្រាកដជាដើម ក្នុងករណីនេះ ភាពចាំបាច់នៃការផ្តល់តម្លៃចំពោះការបន្តស្ថានភាពជាក់ស្តែងនឹងបាត់បង់ ហើយអាជ្ញាយុកាលត្រូវចាប់ផ្តើមសារជាថ្មី ហើយត្រូវចាប់ផ្តើមរាប់សារឡើងវិញ (ចាប់ពីសូន្យ) ចាប់ពីពេលនោះមក (បើសិនជាគ្មានការអនុវត្តសិទ្ធិក្នុងពេលនោះ)។ នេះហៅថា ការបន្តសារជាថ្មី (មាត្រា147 កថាខណ្ឌទី2, មាត្រា148 កថាខណ្ឌទី2 និង មាត្រា152)។

សូមចំណាំថា បើសិនជាមានការបន្តសារជាថ្មី ទ្រនិចនាឡិកានៃការគណនាអាជ្ញាយុកាលត្រូវត្រឡប់មកចំណុចសូន្យវិញ ហើយត្រូវចាប់ផ្តើមដំណើរការពីចំណុចសូន្យសារឡើងវិញ ប្រសិនបើមិនមានការអនុវត្តសិទ្ធិ។ មានន័យថា អាជ្ញាយុកាលនៃការរំលត់រយៈពេល 5ឆ្នាំ បានបន្តសារជាថ្មីនៅឆ្នាំទី3 ហើយទោះបីជា 2ឆ្នាំក្រោយមកទៀតបានកន្លងផុតចាប់ពីពេលបន្តសារជាថ្មីនោះក៏ដោយ ក៏អាជ្ញាយុកាលមិនបំពេញដែរ លុះត្រាតែ 3ឆ្នាំក្រោយមកទៀតបានកន្លងផុត។

លើសពីនេះ មានប្រព័ន្ធមួយទៀត គឺ **ការបង្អង់ការចូលជាស្ថាពរ**។ នេះគឺជាទស្សនៈថ្មីដែលបានបង្កើតឡើងនៅក្នុងវិសោធនកម្មឆ្នាំ2017។ ឧទាហរណ៍ បើសិនជាមានការទាមទារពីបុគ្គលដែលអះអាងថាខ្លួនជាម្ចាស់សិទ្ធិ ក្នុងករណីនេះ ដំណើរការនៃអាជ្ញាយុកាលត្រូវឈប់ជាបណ្តោះអាសន្ន រហូតដល់ពេលដែលមានការទទួលស្គាល់ថានរណាជាម្ចាស់សិទ្ធិពិតប្រាកដជាមុនសិន (នៅមុនពេលវិសោធនកម្មឆ្នាំ2017 ប្រព័ន្ធដែលស្រដៀងគ្នានេះ ហៅថា «ការបង្អង់អាជ្ញាយុកាល» ដែលជាប្រព័ន្ធបញ្ឈប់អាជ្ញាយុកាលជាបណ្តោះអាសន្ន ក្នុងករណីដែលម្ចាស់សិទ្ធិមានស្ថានភាពណាមួយដែលមិនអាចអះអាងអំពីការបន្តសារជាថ្មីបាន ហើយប្រព័ន្ធនេះក៏ត្រូវបានបញ្ចូលនៅក្នុងការបង្អង់ជាស្ថាពរដែរ)។ ការបង្អង់ការចូលជាស្ថាពរនេះគ្រាន់តែបញ្ឈប់ទ្រនិចនាឡិកានៃអាជ្ញាយុកាលជាបណ្តោះអាសន្នប៉ុណ្ណោះ មិនមែនត្រឡប់មកសូន្យវិញនោះទេ។ បើសិនជាម្ចាស់សិទ្ធិអាចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិបាន ការបង្អង់ការចូលជាស្ថាពរនឹងត្រូវបញ្ចប់ ហើយអាជ្ញាយុកាលនឹងបន្តសារជាថ្មី បើសិនជាមិនបានអនុវត្តសិទ្ធិចាប់ពីពេលនោះមក (ប្រសិនបើមិនអាចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិនោះទេ ការបញ្ឈប់បណ្តោះអាសន្នដែលជាការបង្អង់ការចូលជាស្ថាពរនឹងបញ្ចប់ ហើយអាជ្ញាយុកាលនឹងចាប់ផ្តើមបន្តវិញ)។

ឧទាហរណ៍ ការទាមទារតាមផ្លូវតុលាការ (មិនរួមបញ្ចូលករណីដាស់តឿន តាមរយៈការផ្ញើរលិខិតយបត្រទាមទារឡើយ) ការស្នើសុំដាស់តឿនឱ្យបង់ប្រាក់ ការដាក់ពាក្យសុំសះជាតាមផ្លូវតុលាការ ការដាក់ពាក្យសុំសន្ធានកម្មរដ្ឋប្បវេណី ការដាក់ពាក្យសុំសន្ធានកម្មរឿងគ្រួសារ ការចូលរួមនីតិវិធីក្ស័យធនជាដើម នឹងក្លាយជាមូលហេតុនៃ «ការបង្អង់ការចូលជាស្ថាពរ» (ច្បាប់វិសោធនកម្ម មាត្រា147 កថាខណ្ឌទី1)។ មានន័យថា អាជ្ញាយុកាលមិនស្ថាពរនោះទេ រហូតដល់ពេលមូលហេតុខាងលើនេះបញ្ចប់ (រហូតដល់រយៈពេល 6ខែ គិតចាប់ពីពេលដោះស្រាយបណ្តឹងរួចរាល់ ឬ បណ្តឹងបានបញ្ចប់ដោយមិនបញ្ជាក់សិទ្ធិស្ថាពរ)។ បើសិនជាសិទ្ធិបានកំណត់ដាក់លាក់ដោយសាលក្រមស្ថាពរជាដើម ការកំណត់សិទ្ធិដាក់លាក់នោះនឹងក្លាយជាមូលហេតុនៃការបន្តសារជាថ្មី ហើយបើសិនជាម្ចាស់សិទ្ធិនៅតែមិនអនុវត្តសិទ្ធិរបស់ខ្លួនដែលបានកំណត់ដាក់លាក់ អាជ្ញាយុកាលនឹងចាប់ផ្តើមដំណើរការសារជាថ្មីចាប់ពីពេលស្ថាពរនោះ (មាត្រា147 កថាខណ្ឌទី2)។

ពាក្យគន្លឹះ: **ការបន្តសារជាថ្មី និង ការបង្អង់ការចូលជាស្ថាពរ**

ការបន្តសារជាថ្មី គឺអាជ្ញាយុកាលចាប់ផ្តើមឡើងវិញ ហើយការបង្អង់ការចូលជាស្ថាពរ គឺការបញ្ឈប់បណ្តោះអាសន្ន។ បើសិនជាចាប់ផ្តើមឡើងវិញ គឺមានន័យថាត្រូវរាប់ពីសូន្យសារជាថ្មី។ ការបញ្ឈប់ជាបណ្តោះអាសន្ន គឺត្រូវរាប់បន្ត ក្រោយពេលហេតុនោះត្រូវបញ្ចប់ (ដោយឡែក ពាក្យថា «ការបន្តសារជាថ្មី» ត្រូវបានហៅថា «ការផ្អាក» នៅមុនវិសោធនកម្មឆ្នាំ2017 ហើយនៅក្រោយវិសោធនកម្មនេះ ពាក្យនេះត្រូវប្រើតែនៅក្នុងមាត្រា164 ប៉ុណ្ណោះ)។

### (4) ការលើកឡើង និងការបោះបង់ចោលនូវអាជ្ញាយុកាល

ចំណុចមួយទៀតដែលត្រូវចំណាំទុក គឺអាជ្ញាយុកាលនៃក្រមរដ្ឋប្បវេណីមិនធ្វើឱ្យរំលត់សិទ្ធិ ឬ លទ្ធកម្មសិទ្ធិដោយឯកឯងនោះទេ ទោះបីជាអំឡុងពេលដែលត្រូវបានកំណត់កន្លងផុតក៏ដោយ។ បុគ្គលដែលចង់បានផលប្រយោជន៍ពីអាជ្ញាយុកាលនោះត្រូវតែអះអាងអំពីអាជ្ញាយុកាលសម្រាប់ខ្លួនឯងដូចជា ខ្ញុំមិនបង់ប្រាក់នោះទេដោយសារអាជ្ញាយុកាលរលត់ហើយ ឬ វត្ថុនេះក្លាយជារបស់ខ្ញុំដោយសារអាជ្ញាយុកាលនៃលទ្ធកម្មបានសម្រេចហើយ ជាដើមដែលនេះហៅថា ការលើកឡើងអំពីអាជ្ញាយុកាល។ នៅក្នុងអាជ្ញាយុកាលអាចមានផ្នែកមួយដែលផ្ទុយនឹងសីលធម៌ ហេតុនេះហើយ ការទទួលយកផលប្រយោជន៍នៃអាជ្ញាយុកាលត្រូវផ្អែកទៅលើឆន្ទៈចុងក្រោយរបស់សាមីខ្លួន។ តុលាការមិនអាចសម្រេចអំពីអាជ្ញាយុកាលទាំងសាមីខ្លួនមិនបានលើកឡើងនោះទេ (មាត្រា145)។ លើសពីនេះ ផលប្រយោជន៍នៃអាជ្ញាយុកាលអាចបោះបង់ចោលបាន នៅក្រោយពេលអាជ្ញាយុកាលបានសម្រេច (ការបកស្រាយផ្ទុយនៃមាត្រា146)។ នេះន័យថា បើសិនជាបុគ្គលម្នាក់បានខ្ចីប្រាក់ពីបុគ្គលណាម្នាក់ទៀត ហើយរយៈពេលលើសពី 10ឆ្នាំ បានកន្លងផុត ប៉ុន្តែ ដោយសារតែបុគ្គលនោះជាអ្នកមានគុណរបស់អ្នកខ្ចី ហើយអ្នកខ្ចីនៅតែចង់សងទៅបុគ្គលនោះជាដាច់ខាត ក្នុងករណីនេះ អ្នកខ្ចីអាចបោះបង់អាជ្ញាយុកាល ហើយសងប្រាក់ទៅក៏បានដែរ។

### (5) អត្ថន័យនៃអត្ថិភាពប្រព័ន្ធអាជ្ញាយុកាល

មូលដ្ឋាននៃការរៀបចំឱ្យមានប្រព័ន្ធអាជ្ញាយុកាលបែបនេះ យើងអាចនិយាយថា ដើម្បីរក្សាស្ថិរភាពនៃទំនាក់ទំនងគតិយុត្តក្នុងសង្គមដោយទទួលស្គាល់អង្គហេតុដែលបន្តរហូតមក ឬ ក្នុងគោលបំណងមិនការពារដល់បុគ្គលដែលកំពុងលង់លក់ជាមួយនឹងសិទ្ធិរបស់ខ្លួន ប៉ុន្តែ ទោះបីជាផ្អែកលើមូលដ្ឋានណាមួយក៏ដោយ ក៏មូលហេតុសំខាន់បំផុតគឺ ការបញ្ជាក់អំពីសិទ្ធិកាន់តែលំបាក នៅពេលដែលពេលវេលាកាន់តែកន្លងទៅយូរ។ ការឱ្យតម្លៃទៅលើមូលដ្ឋានណាមួយខ្លាំងជាងគេ គឺអាស្រ័យទៅលើទស្សនៈលើអាជ្ញាយុកាលរបស់អ្នកសិក្សាច្បាប់ម្នាក់ៗ ហើយមានទ្រឹស្តីជាច្រើនដែលកំពុងយល់ឃើញខុសគ្នាអំពីអត្ថន័យ និង សារជាតុគតិយុត្តនៃអាជ្ញាយុកាល។

## 8. នីតិបុគ្គល

### (1) សេចក្តីផ្តើម

ក្រមរដ្ឋប្បវេណីបានប្រដូចសហគ្រាសជាដើមទៅនឹងបុគ្គល ដោយផ្តល់ឋានៈជា «នីតិបុគ្គល» និងទទួលស្គាល់ជាប្រធាននៃសកម្មភាពគតិយុត្ត (ដោយឡែក បើប្រៀបធៀបជាមួយនីតិបុគ្គល យើងទាំងអស់គ្នាម្នាក់ៗហៅថា «រូបវន្តបុគ្គល»។ ប៉ុន្តែដាច់ខាត មិនមែនមានន័យថា«មនុស្សព្រៃ»ទេ)។ ការទទួលស្គាល់ថាជានីតិបុគ្គលមានន័យថាជាការផ្តល់លក្ខណៈសម្បត្តិជានីតិបុគ្គល ហើយការទទួលស្គាល់លក្ខណៈសម្បត្តិជានីតិបុគ្គលមានន័យថាជាការផ្តល់ឋានៈជាប្រធាននៃសិទ្ធិ និង ករណីយកិច្ចដូចរូបវន្តបុគ្គល។ ដើមឡើយ នៅក្នុងក្រមរដ្ឋប្បវេណីមានកំណត់មាត្រាទាក់ទងនឹងនីតិបុគ្គលយ៉ាងច្រើននៅក្នុងបទប្បញ្ញត្តិទូទៅ។ ប៉ុន្តែ នៅខែមិថុនា ឆ្នាំ2006 ច្បាប់ចំនួន 3 ត្រូវបានប្រកាសឱ្យប្រើ ហើយច្បាប់ទាំងនេះបានកែទម្រង់ប្រព័ន្ធនៃនីតិបុគ្គលបម្រើប្រយោជន៍សាធារណៈដែលនឹងរៀបរាប់ខាងក្រោម។ តាមរយៈនេះ បញ្ញត្តិស្តីពីនីតិបុគ្គលនៅក្នុងក្រមរដ្ឋប្បវេណីមានការផ្លាស់ប្តូរយ៉ាងខ្លាំង និងមានកំណត់តែ 5មាត្រា ប៉ុណ្ណោះក្នុងក្រមរដ្ឋប្បវេណី ហើយបញ្ញត្តិដែលនៅសល់ មានចែងនៅក្នុងច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិដែលជាច្បាប់មួយក្នុងចំណោមច្បាប់ទាំង3 (ច្បាប់ទាំង 3នេះ ត្រូវបានអនុវត្តនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2008)។

### (2) នីតិបុគ្គលសាជីវកម្ម និង នីតិបុគ្គលមូលនិធិ

នីតិបុគ្គលនៅក្នុងវិស័យឯកជនចែកចេញជា នីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិ។ បើនិយាយជារួម នីតិបុគ្គលសាជីវកម្មគឺជាការប្រមូលផ្តុំមនុស្ស ហើយ នីតិបុគ្គលមូលនិធិគឺជាការប្រមូលផ្តុំទ្រព្យសម្បត្តិ (ពិតណាស់ នៅក្នុងនីតិបុគ្គលមូលនិធិក៏ដោយ ក៏មានការប្រមូលផ្តុំមនុស្សជាអង្គការលេខដើម្បីប្រើប្រាស់ទ្រព្យសម្បត្តិនោះផងដែរ)។ នៅក្នុងចំណោមនីតិបុគ្គលដូចជានីតិបុគ្គលសាជីវកម្ម រួមមានក្រុមហ៊ុនជាដើម គឺជាការប្រមូលផ្តុំនៃមនុស្ស ហេតុនេះ យើងចាំបាច់ត្រូវទទួលស្គាល់អ្នកតំណាងម្នាក់ក្នុងចំណោមការប្រមូលផ្តុំនោះ ហើយផ្តល់ឋានៈជាប្រធាននៃសិទ្ធិផ្សេងទើបងាយស្រួលយល់ (សូម្បីតែការចុះកិច្ចសន្យាលក់ទិញមួយ ក៏មិនមែនអ្នកតំណាងម្នាក់ឯងជាអ្នក

ទិញនោះទេ គឺចាំបាច់ត្រូវទទួលស្គាល់ឱ្យក្រុមហ៊ុនទាំងមូលត្រូវក្លាយជាអ្នកទិញ)។ ប៉ុន្តែ មិនមែនគ្រប់ការប្រមូលផ្តុំមនុស្សទាំងអស់ត្រូវក្លាយជានីតិបុគ្គលសាជីវកម្មនោះទេ (សមាគម គឺជាការប្រមូលផ្តុំមនុស្សដែលមានការចូលរួមពីបុគ្គលម្នាក់ៗខ្លាំងជាង នីតិបុគ្គលសាជីវកម្មទៅទៀត ⇒សូមយោង ចំណុចទី៩ ជំពូកទី4)។ បន្ទាប់មកទៀត តើមូលហេតុអ្វីបានត្រូវផ្តល់ឋានៈជានីតិបុគ្គលដល់ការប្រមូលផ្តុំទ្រព្យសម្បត្តិ? នេះដោយសារតែ យើងមិនមែនពិចារណាអំពីការប្រមូលផ្តុំប្រាក់កាស ចាប់ដំណើរការ ហើយបានផលចំណេញទេ ប៉ុន្តែ យើងផ្តោតទៅលើការផ្តល់លក្ខណៈសម្បត្តិជាប្រធាននៃសិទ្ធិឯករាជ្យ និង ឱ្យធ្វើសកម្មភាពដោយមានអង្គការលេខ និង ប្រើប្រាស់ទ្រព្យសម្បត្តិក្នុងគោលបំណងជាក់លាក់សម្រាប់ការងារមនុស្សធម៌ ដូចជា ការសាងសង់សាលារៀន និង មន្ទីរពេទ្យជាដើមដែលជា**ប្រយោជន៍សាធារណៈ** (ផលប្រយោជន៍សម្រាប់បុគ្គលច្រើនមិនកំណត់ជាក់លាក់)។

នីតិបុគ្គលសាជីវកម្មចែកចេញជា **នីតិបុគ្គលសាជីវកម្មយកចំណេញ** និង **នីតិបុគ្គលសាជីវកម្មបម្រើប្រយោជន៍សាធារណៈ**។ នីតិបុគ្គលសាជីវកម្មយកចំណេញ សំដៅទៅលើក្រុមហ៊ុន ហើយត្រូវអនុលោមតាមបញ្ញត្តិនៃច្បាប់ក្រុមហ៊ុន។ នេះមានន័យថា នៅមុនពេលវិសោធនកម្មឆ្នាំ2006 ក្រមរដ្ឋប្បវេណីបានកំណត់អំពី នីតិបុគ្គលសាជីវកម្មបម្រើប្រយោជន៍សាធារណៈ និងនីតិបុគ្គលមូលនិធិ។ លើសពីនេះ ក្រៅពីក្រមរដ្ឋប្បវេណី និង ច្បាប់ក្រុមហ៊ុន គឺមានច្បាប់ពិសេសផ្សេងទៀតយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលទទួលស្គាល់នីតិបុគ្គល។ យ៉ាងណាមិញ នីតិបុគ្គលបម្រើប្រយោជន៍សាធារណៈត្រូវបានឱ្យនិយមន័យថាជា នីតិបុគ្គលដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងប្រពៃណី សាសនា សប្បុរសធម៌ ការសិក្សាស្រាវជ្រាវ និង បច្ចេកវិទ្យាជាដើម ក្នុងគោលបំណងបម្រើប្រយោជន៍មនុស្សជាតិមិនកំណត់។

វិធានជាមូលដ្ឋាននៃនីតិបុគ្គលសាជីវកម្មគឺ លក្ខន្តិកៈ។ ក្នុងលក្ខន្តិកៈនេះត្រូវសរសេរអំពី គោលបំណង នាមករណ៍ ទីស្នាក់ការ ឈ្មោះសមាជិកនៅពេលបង្កើត បញ្ញត្តិស្តីពីការទទួលបាន និង បាត់បង់លក្ខណៈសម្បត្តិជាសមាជិក និង ចំណុចផ្សេងទៀត (ច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិ មាត្រា11 កថាខណ្ឌទី1)។ នៅក្នុងនីតិបុគ្គលមូលនិធិនៃបញ្ញត្តិក្នុងច្បាប់ចាស់ បានហៅវិធានជាលាយលក្ខណ៍អក្សរដែលកំណត់វិធានជាមូលដ្ឋានថា «សកម្មភាពបរិច្ចាគ» ប៉ុន្តែ នៅក្នុងច្បាប់ថ្មីក៏ត្រូវបានហៅថា «លក្ខន្តិកៈ» ដែរ។ នៅក្នុងនោះក៏ត្រូវសរសេរអំពី គោលបំណង នាមករណ៍ ទីស្នាក់ការ បញ្ញត្តិនៃទ្រព្យធន វិធីជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល អភិបាល និង អ្នកត្រួតពិនិត្យជាអាទិ៍ (មាត្រា153 កថាខណ្ឌទី1 នៃច្បាប់ដដែល)។

### (3) នីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិទូទៅ

នីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈដែលបញ្ញត្តក្នុងក្រមរដ្ឋប្បវេណី ត្រូវទទួលបាននូវប្រព័ន្ធអនុគ្រោះពន្ធជាអាទិ៍។ ហេតុនេះហើយ ការរីកចម្រើនយ៉ាងខ្លាំងនៃសកម្មភាពសេដ្ឋកិច្ចបាននាំឱ្យ កើតមានស្ថានភាពនៃការប្រើប្រាស់ដោយបំពានចំពោះនីតិបុគ្គលមូលនិធិដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ហើយបង្កជាបញ្ហាសង្គម។ ហេតុនេះហើយ គេបានផ្លាស់ប្តូរគោលគំនិតជាមូលដ្ឋាននៃនីតិបុគ្គលក្នុងក្រមរដ្ឋប្បវេណី ហើយបានបង្កើតច្បាប់

ដែលគេហៅថាច្បាប់ទាំង 3 សម្រាប់កំណែទម្រង់ប្រព័ន្ធនីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈ ដោយតាក់តែងនូវបញ្ញត្តិដែលកំណត់យ៉ាងលំអិតនៅក្នុងច្បាប់ស្តីពីការរៀបចំសមាគម (ប្រកាសឱ្យប្រើនៅឆ្នាំ2006) និង ផ្ទេរបញ្ញត្តិជាច្រើនពីក្រមរដ្ឋប្បវេណីទៅច្បាប់នោះ។ ច្បាប់ទី1 គឺ«ច្បាប់ស្តីពី នីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិទូទៅ (ហៅកាត់ថា «**ច្បាប់នីតិបុគ្គលសាជីវកម្មទូទៅ និង មូលនិធិទូទៅ**»)» ច្បាប់ទី2 គឺ «ច្បាប់ស្តីពីការទទួលស្គាល់នីតិបុគ្គលសាជីវកម្មបម្រើប្រយោជន៍សាធារណៈ និង នីតិបុគ្គលមូលនិធិបម្រើប្រយោជន៍សាធារណៈជាអាទិ៍ (ហៅកាត់ថា «**ច្បាប់ទទួលស្គាល់នីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ**» និងច្បាប់ទី3 គឺជាច្បាប់ដែលសម្របសម្រួលច្បាប់ដែលពាក់ព័ន្ធ (ហៅកាត់ថា «**ច្បាប់សម្របសម្រួល**»)។

ដើម្បីជំរុញសកម្មភាពមិនស្វែងរកប្រាក់ចំណេញរបស់ប្រជាពលរដ្ឋឱ្យកាន់តែខ្លាំងក្លា គេបានកំណែទម្រង់ពីការអនុវត្តកន្លងមកដោយការអនុញ្ញាតឱ្យបង្កើតនីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ ត្រូវធ្វើតាមរយៈឆន្ទានុសិទ្ធិទាំងស្រុងរបស់ស្ថាប័នមានសមត្ថកិច្ច (មាត្រា24 ចាស់នៃក្រមរដ្ឋប្បវេណី) ទៅជា ①រៀបចំប្រព័ន្ធដែលអាចបង្កើតនីតិបុគ្គលដែលជានីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិ ដោយគ្រាន់តែចុះបញ្ជីស្របតាមបញ្ញត្តិច្បាប់ប៉ុណ្ណោះ និង ②រៀបចំប្រព័ន្ធដោយឡែកដើម្បីទទួលស្គាល់ភាពនៃការបម្រើប្រយោជន៍សាធារណៈ ដើម្បីក្លាយជានីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ (មានន័យថា ការបង្កើតនីតិបុគ្គលគឺអាចធ្វើបានដោយងាយស្រួល ប៉ុន្តែដើម្បីឱ្យមានការទទួលស្គាល់ថាជា នីតិបុគ្គលបម្រើប្រយោជន៍សាធារណៈបាន លុះត្រាតែទទួលនូវការអនុញ្ញាតយ៉ាងតឹងរ៉ឹងដោយឡែក។)

### (4) ស្ថាប័ននីតិបុគ្គល

ទោះបីជាច្បាប់បានប្រដូចនីតិបុគ្គលឱ្យដូចគ្នានឹងបុគ្គលក៏ដោយ ក៏នីតិបុគ្គលទាំងសាជីវកម្ម និង មូលនិធិពុំអាចដំណើរការដោយខ្លួនឯងនោះទេ ហេតុនេះត្រូវមានអង្គភាពសម្រាប់ប្រតិបត្តិការ។ អង្គភាពទាំងអស់នេះគឺជាស្ថាប័ននីតិបុគ្គល។

①សម្រាប់នីតិបុគ្គលសាជីវកម្ម ស្ថាប័នធ្វើសេចក្តីសម្រេចគឺជា «**មហាសន្និបាតសមាជិក**» ធ្វើឡើងដោយ «**សមាជិក**» (⇒ពាក្យគន្លឹះ: សមាជិក)។ ក្នុងករណីនីតិបុគ្គលមូលនិធិវិញ (ដោយសារជាការប្រមូលផ្តុំនូវទ្រព្យសម្បត្តិ) ពុំមានគោលគំនិតអំពីសមាជិក ឬ មហាសន្និបាតសមាជិកនោះទេ ហេតុនេះហើយ ឆន្ទៈរបស់អ្នកបង្កើតគឺជាសេចក្តីសម្រេចស្ថាពរ ប៉ុន្តែ នៅក្នុងច្បាប់ថ្មីបានភ្ជាប់កាតព្វកិច្ចឱ្យនីតិបុគ្គលមូលនិធិត្រូវតែងតាំងក្រុមប្រឹក្សាគ្រប់គ្រង (កថាខណ្ឌទី1 មាត្រា170 នៃច្បាប់នីតិបុគ្គលសាជីវកម្មទូទៅ និង មូលនិធិទូទៅ)។ ②ស្ថាប័នអនុវត្តកិច្ចការ ទាំងនីតិបុគ្គលសាជីវកម្ម និង នីតិបុគ្គលមូលនិធិគឺ អភិបាល ហើយត្រូវរៀបចំឱ្យមាន អភិបាល ជាដាច់ខាត (បញ្ញត្តិចាស់គឺ កថាខណ្ឌទី1 មាត្រា52, នៅក្នុងច្បាប់នីតិបុគ្គលសាជីវកម្មទូទៅ និង មូលនិធិទូទៅគឺ កថាខណ្ឌទី1 មាត្រា60 និង កថាខណ្ឌទី1 មាត្រា170)។ ③ស្ថាប័នត្រួតពិនិត្យ គឺអ្នកត្រួតពិនិត្យ ហើយស្ថាប័ននេះមិនតម្រូវឱ្យមានជាដាច់ខាតនោះទេ (បញ្ញត្តិចាស់ មាត្រា58) ប៉ុន្តែ នៅក្នុងច្បាប់ថ្មីបានផ្តោតសំខាន់ទៅលើមុខងារនៃការត្រួត

ពិនិត្យ ហេតុនេះហើយ មានការតម្រូវឱ្យតែងតាំងអ្នកត្រួតពិនិត្យនៅក្នុងនីតិបុគ្គលសាជីវកម្មខ្នាតធំដែលមានតែងតាំងសវនករគណនេយ្យ និង នីតិបុគ្គលសាជីវកម្មទូទៅដែលមានក្រុមប្រឹក្សាភិបាល ហើយនីតិបុគ្គលមូលនិធិទូទៅត្រូវតែមានស្ថាប័នត្រួតពិនិត្យដាច់ខាត (មាត្រា61 និង កថាខណ្ឌទី1 មាត្រា170 នៃច្បាប់នីតិបុគ្គលសាជីវកម្មទូទៅ និង មូលនិធិទូទៅ)។

> ពាក្យគន្លឹះ: **សមាជិក**
>
> ពាក្យថា សមាជិក នៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្មមានន័យថា «អ្នកចូលរួមបង្កើតសាជីវកម្ម» ហើយមិនមែនសំដៅទៅលើនិយោជិក ដែលក្រុមហ៊ុនជាអាទិ៍ ជួលឱ្យធ្វើការនោះទេ។ ឧទាហរណ៍ បើយើងនិយាយអំពី «សមាជិក» នៃក្រុមហ៊ុនមូលធនដែលជានីតិបុគ្គលរកប្រាក់ចំណេញ គឺសំដៅទៅលើ «ម្ចាស់ហ៊ុន»។

### (5) **របបស្ដីពីការបង្កើតនីតិបុគ្គល**

ចំពោះការបង្កើតនីតិបុគ្គលខាងលើនេះត្រូវបានបែកចែកជារបបផ្សេងៗ អាស្រ័យទៅលើកម្រិតនៃការជ្រៀតជ្រែករបស់រដ្ឋ។ នេះជាការបង្ហាញតាមលំដាប់ចាប់ពីកម្រិតតឹងតែងទៅ ①**របបអនុញ្ញាតពិសេស** ដែលការទទួលស្គាល់នីតិបុគ្គលមួយត្រូវបង្កើតច្បាប់ពិសេសមួយ។ ធនាគារជប៉ុន ជាអាទិ៍ត្រូវបានបង្កើតតាមរយៈរបបនេះ។ ②**របបផ្ដល់ការអនុញ្ញាត** ដែលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យអាចទទួលស្គាល់ឱ្យបង្កើតតាមរយៈឆន្ទានុសិទ្ធិដោយសេរី។ នេះគឺជារបបនៅក្នុងគោលជំហរនៃនីតិបុគ្គលនៅក្នុងក្រមរដ្ឋប្បវេណីពីមុន (បញ្ញត្តិចាស់ មាត្រា34)។ ③**របបទទួលស្គាល់** ដែលស្ថាប័នមានសមត្ថកិច្ចត្រូវតែទទួលស្គាល់ឱ្យបង្កើត បើសិនជាបានបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ជាមុន។ ការបង្កើតសាលារៀនឯកជន គឺស្ថិតនៅក្នុងរបបនេះ (យោងច្បាប់ស្ដីពី ការបង្កើតសាលារៀនឯកជន)។ និង ④**របបតាមវិធាន** ដែលស្ថាប័នមានសមត្ថកិច្ចត្រូវទទួលស្គាល់ដោយគ្មានការត្រួតពិនិត្យជាមុន បើសិនជាមានការចុះបញ្ជីដោយគោរពតាមរចនាសម្ព័ន្ធជាក់លាក់ដែលកំណត់ក្នុងច្បាប់។ ក្រុមហ៊ុនដែលមានកំណត់ក្នុងច្បាប់ស្ដីពីក្រុមហ៊ុន និង សហជីពកម្មករ គឺស្ថិតនៅក្នុងរបបនេះ។ ច្បាប់ថ្មីស្ដីពី នីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិទូទៅ ក៏អនុលោមតាមរបបនេះដែរ។

### (6) **អំពើអនីត្យានុកូលរបស់នីតិបុគ្គល**

ក្រមរដ្ឋប្បវេណីបានទទួលស្គាល់សមត្ថភាពក្នុងការធ្វើសកម្មភាពរបស់នីតិបុគ្គល ដូចគ្នាទៅនឹងបុគ្គល ហេតុនេះហើយ ការបញ្ញត្តអំពីសមត្ថភាពក្នុងការប្រព្រឹត្តអំពើអនីត្យានុកូលរបស់នីតិបុគ្គល (អំពើដែលធ្វើឱ្យខូចខាតដោយខុសច្បាប់ទៅលើបុគ្គលដទៃ ដោយចេតនា ឬ កំហុស) ក៏ត្រូវតែមានផងដែរ (នៅក្នុងបញ្ញត្តិចាស់នៃក្រមរដ្ឋប្បវេណីបានកំណត់ថា នីតិបុគ្គលត្រូវទទួលខុសត្រូវ ក្នុងករណីដែលអភិបាល ឬ អ្នកតំណាងផ្សេងទៀត (ស្ថាប័នតំណាង) របស់នីតិបុគ្គលនោះបានប្រព្រឹត្តអំពើអនីត្យានុកូល ប៉ុន្តែមាត្រាទាំងនេះត្រូវបានលុបចេញពីក្រមរដ្ឋប្បវេណីតាមរយៈច្បាប់ថ្មីខាងលើនេះ ហើយបញ្ញត្តិដូចគ្នាត្រូវបានកំណត់នៅក្នុងច្បាប់ស្ដីពីនីតិបុគ្គលសាជីវកម្មទូទៅ និង

នីតិបុគ្គមូលនិធិទូទៅ)។ ប៉ុន្តែ យើងមិនអាចយល់ច្បាស់ពីចំណុចនេះទេ បើមិនទាន់បានរៀនលម្អិតនៅក្នុងផ្នែកដែលនិយាយអំពីអំពើអនីត្យានុកូលនៃនីតិសិទ្ធិលើបំណុល (ចាប់ពីមាត្រា709 ⇒សូមយោងជំពូកទី5)។

### (7) **ទស្សនៈអំពីនីតិបុគ្គល**

ដោយឡែក គោលគំនិតនៃទស្សនៈអំពីនីតិបុគ្គលមានជាច្រើន ហើយក្នុងនោះទស្សនៈ 2 មានគោលគំនិតផ្ទុយគ្នា គឺ ទ្រឹស្តីចាត់ទុកជានីតិបុគ្គល ដែលបានលើកឡើងថា អត្ថិភាពនៃនីតិបុគ្គល គឺគ្រាន់តែជាការចាត់ទុកថាជារូបវន្តបុគ្គលប៉ុណ្ណោះ ចំណែកឯ ទ្រឹស្តីអត្ថិភាពពិតនៃនីតិបុគ្គល បានលើកឡើងថា នីតិបុគ្គលមានអត្ថិភាពពិតប្រាកដ។ ភាពខុសគ្នានៃគោលគំនិតទាំងនេះ មានផ្នែកខ្លះ បានជះឥទ្ធិពលដល់ការបកស្រាយ និង ពន្យល់អំពីបញ្ញត្តិសំខាន់ៗនៃនីតិបុគ្គល ប៉ុន្តែ អ្នកដែលទើបតែចាប់ផ្តើមសិក្សាមិនគួរផ្តោតអារម្មណ៍លើចំណុចនេះខ្លាំងពេកនោះទេ ហើយគួរយកចិត្តទុកដាក់ទៅលើអត្ថន័យជារួមនៃបញ្ញត្តិអំពីនីតិបុគ្គល (ការបង្កើត, សមត្ថភាព, ស្ថាប័ន និង ការរលត់ជាដើម) ក្នុងក្រមរដ្ឋប្បវេណីវិញ។

### (8) **ក្រុមដែលគ្មានសមត្ថភាពទទួលសិទ្ធិ និង ឧបនីតិបុគ្គល**

លើសពីនេះ ការប្រមូលផ្តុំដើម្បីប្រយោជន៍របស់បុគ្គលជាក់លាក់ដែលជាសមាជិក ដោយគ្មានគោលបំណងស្វែងប្រាក់ចំណេញ និង គ្មានគោលបំណងបម្រើប្រយោជន៍សាធារណៈ (សមាគមនិស្សិត សមាគមមិត្តរួមជំនាន់ និង សហគមន៍អ្នកជិតខាង ជាដើម) ត្រូវបានគេហៅថា «**ក្រុមដែលគ្មានសមត្ថភាពទទួលសិទ្ធិ**» ហើយរហូតមកដល់ពេលនេះ គេនៅមិនអាចកំណត់ថាជា នីតិបុគ្គលនោះទេ ដរាបណាមិនមានការកំណត់ក្នុងច្បាប់ពិសេស (ចំពោះក្រុមដែលគ្មានសមត្ថភាពទទួលសិទ្ធិ ពុំមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែ យុត្តិសាស្ត្រ និង ទ្រឹស្តីអ្នកច្បាប់បានទទួលស្គាល់ថា ក្រុមដែលគ្មានសមត្ថភាពទទួលសិទ្ធិ អាចក្លាយជាប្រធាននៃប្រតិបត្តិការជំនួញឯកពាជ្យ និង ប្រធាននៃបណ្តឹង។ ឧទាហរណ៍ក្នុងករណីធ្វើលទ្ធកម្មអចលនវត្ថុ ហើយចុះបញ្ជីជាដើម គឺត្រូវដាក់ឈ្មោះរបស់អ្នកតំណាង ហើយបើសិនជាក្រុមដែលគ្មានសមត្ថភាពទទួលសិទ្ធិធ្វើជំនួញ ហើយមានជំពាក់បំណុលក៏ដោយ មិនអាចប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជនរបស់សមាជិកម្នាក់ៗនោះទេ។ លើសពីនេះ សូម្បីតែសមាជិកដែលបានលាលែង ក៏មិនអាចទាមទារឱ្យសងដើមទុនដែលបានបណ្តាក់ទុនវិញបានដែរ)។ ច្បាប់ស្តីពីឧបនីតិបុគ្គលដែលបានតាក់តែងឡើងនៅក្នុងឆ្នាំ2001 បានផ្តល់លក្ខណៈសម្បត្តិជានីតិបុគ្គលដល់ក្រុមខាងលើនេះ ជា «**ឧបនីតិបុគ្គល**» ហើយអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមដូចជាអចលនវត្ថុជាដើម។ ប៉ុន្តែ «ឧបនីតិបុគ្គល» នេះត្រូវបានលុបចោលដោយច្បាប់ថ្មីក្នុងឆ្នាំ2006 ហើយឧបនីតិបុគ្គលត្រូវបន្តអត្ថិភាពរបស់ខ្លួនក្នុងនាមជានីតិបុគ្គលសាជីវកម្មទូទៅ។

## 9. លំនៅឋាន និង ការបាត់ខ្លួន

### (1) លំនៅឋាន

នៅក្នុងបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីក៏មានចែងអំពីលំនៅឋានដែរ។ លំនៅឋាន គឺជាមូលដ្ឋានដើម្បីសម្រេចថា កាតព្វកិច្ចត្រូវអនុវត្តនៅកន្លែងណា (មាត្រា484) និង សន្តតិកម្មត្រូវចាប់ផ្តើមនៅកន្លែងណា (មាត្រា883) ជាដើម ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានកំណត់ចំណុចនេះនៅក្នុងបទប្បញ្ញត្តិទូទៅ។ កន្លែងដែលជាទីតាំងនៃជីវភាពរបស់បុគ្គលម្នាក់ៗ ត្រូវកំណត់ថាជា លំនៅឋាន (មាត្រា22) ហើយករណីដែលមិនដឹងអំពីលំនៅឋានច្បាស់លាស់ទេ ទីសំណាក់ (**ទីសំណាក់** សំដៅទៅលើកន្លែងដែលបុគ្គលនោះរស់នៅជាបន្តបន្ទាប់ក្នុងរយៈពេលមួយ ប៉ុន្តែ ការជិតដិតទៅនឹងទីកន្លែងនោះមិនដល់កម្រិតនៃលំនៅឋាន) ត្រូវចាត់ទុកថាជាលំនៅឋាន (មាត្រា23)។ ពាក្យថា «**ទីតាំងនៃជីវភាព**»នេះ ត្រូវលើកមកពិភាក្សាថា អាចមានតែមួយ ឬ អាចមានច្រើន។ ឧទាហរណ៍ថា បុរសម្នាក់រស់នៅជាមួយប្រពន្ធកូននៅទីក្រុងTOKYO ហើយធ្វើការងារនៅទីស្នាក់ការនៅទីក្រុងOSAKA ក្នុងករណីនេះ ទ្រឹស្តីដែលបកស្រាយថាអាចមានច្រើនគឺជាទ្រឹស្តីទូទៅ ដែលបានទទួលស្គាល់ថា កន្លែងទាំងពីរនេះគឺជាលំនៅឋានទៅតាមទំនាក់ទំនងគតិយុត្តនីមួយៗ ហើយ ចំពោះទំនាក់ទំនងគតិយុត្តទាក់ទងនឹងការងារ គឺទីក្រុងOSAKA ក្លាយជាលំនៅឋាន។ លំនៅឋានក៏ក្លាយជាបញ្ហាផងដែរ ទាក់ទងនឹងសិទ្ធិបោះឆ្នោត។ យុត្តិសាស្ត្ររបស់តុលាការកំពូលបានបកស្រាយថា លំនៅឋានរបស់និស្សិតមហាវិទ្យាល័យដែលកំពុងរស់នៅផ្ទះជួល គឺកន្លែងដែលនិស្សិតកំពុងតែសិក្សា (មានន័យថា រាល់ពេលបោះឆ្នោត គាត់មិនចាំបាច់ត្រូវត្រឡប់ទៅស្រុកកំណើតវិញទេ។ ប៉ុន្តែ គាត់ត្រូវធ្វើសៀវភៅស្នាក់នៅដោយផ្លាស់ប្តូរមកផ្ទះជួលវិញ)។

### (2) ការបាត់ខ្លួន (ការគ្រប់គ្រងទ្រព្យធនរបស់បុគ្គលដែលអវត្តមាន)

បុគ្គលដែលចាកចេញពីលំនៅឋាន ឬ ទីសំណាក់របស់ខ្លួន ហើយមិនមានសង្ឃឹមថានឹងអាចត្រឡប់មកវិញដោយងាយ ហៅថា «**បុគ្គលអវត្តមាន**»។ ចំពោះបុគ្គលដែលបាត់ខ្លួន ប្រសិនបើទុកចោលទ្រព្យសម្បត្តិរបស់គាត់ក្នុងករណីនេះ មិនត្រឹមតែសាមីខ្លួននោះទេ ម្ចាស់បំណុល និង អ្នកដែលត្រូវបានសន្មតជាសន្តតិជន ក៏មិនពេញចិត្តផងដែរ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា ក្នុងករណីដែលបុគ្គលអវត្តមានមិនបានចាត់តាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិទេ តុលាការគ្រួសារអាចធ្វើចំណាត់ការចាំបាច់នានា ដូចជា ជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ តាមការស្នើសុំរបស់អ្នកដែលត្រូវបានសន្មតជាសន្តតិជនរបស់បុគ្គលអវត្តមាន ម្ចាស់បំណុល និង អ្នកមានទំនាក់ទំនងផលប្រយោជន៍ ព្រមទាំងព្រះរាជអាជ្ញា (មាត្រា25 កថាខណ្ឌទី1 វាក្យខណ្ឌទី1)។

ប្រសិនបើមិនដឹងថាបុគ្គលអវត្តមានស្លាប់ ឬ រស់ក្នុងរយៈពេល 7ឆ្នាំ តុលាការគ្រួសារអាចប្រកាសអំពីការបាត់ខ្លួនតាមការទាមទាររបស់អ្នកមានទំនាក់ទំនងផលប្រយោជន៍បាន (មាត្រា30 កថាខណ្ឌទី1)។ បញ្ញត្តិខាងលើនេះត្រូវអនុវត្តដូចគ្នាផងដែរ ប្រសិនបើបុគ្គលនោះមានវត្តមាននៅក្នុងនាវាដែលលិច ឬ ជួបប្រទះនឹងគ្រោះថ្នាក់ផ្សេង

ទៀត ហើយមិនដឹងច្បាស់ថាស្លាប់ ឬ រស់ ក្នុងរយៈពេល 1ឆ្នាំ គិតចាប់ពីហេតុនោះបានកន្លងផុត (មាត្រា30 កថាខណ្ឌទី2)។ ប្រសិនបើមានការប្រកាសអំពីការបាត់ខ្លួន ជននោះត្រូវបានចាត់ទុកថាបានទទួលមរណភាព នៅចំណុចពេលដែល 7ឆ្នាំ បានកន្លងផុតគិតចាប់ពីពេលមិនបានដឹងច្បាស់ថាស្លាប់ ឬ រស់ ឬ នៅចំណុចពេលឧបទ្ទវហេតុបានបញ្ចប់ (មាត្រា31)។

ដោយឡែក ពាក្យថា «ចាត់ទុក» ខុសពីពាក្យថា «សន្មត» ហើយទោះបីជាសាមីខ្លួននៅរស់ក៏ដោយ ក៏អានុភាពនៃការប្រកាសនោះមិនបាត់បងដែរ លុះត្រាតែការប្រកាសអំពីការបាត់ខ្លួននោះត្រូវបានលុបចោល។ ក្នុងករណីនេះ ប្រសិនបើតុលាការគ្រួសារបានលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមរយៈការទាមទាររបស់សាមីខ្លួន ឬ អ្នកមានទំនាក់ទំនងផលប្រយោជន៍ ការប្រកាសនេះនឹងក្លាយជាគ្មានតាំងពីដំបូង។ ហេតុនេះ ជាគោលការណ៍សកម្មភាពគតិយុត្តដែលធ្វើឡើងដោយចាត់ទុកថាបុគ្គលនោះបានស្លាប់ត្រូវក្លាយជាមោឃភាព ប៉ុន្តែ យើងមិនអាចបង្កការខូចខាតដែលមិនអាចស្មានទុកបានដល់បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ឬ ចុះកិច្ចសន្យា ដោយជឿជាក់លើការប្រកាសបាត់ខ្លួននោះទេ។ ហេតុនេះហើយ សកម្មភាពដែលបានធ្វើដោយសុចរិតមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួន ត្រូវបន្តមានអានុភាព (មាត្រា32 កថាខណ្ឌទី1 វាក្យខណ្ឌទី2) ហើយបុគ្គលដែលទទួលបានទ្រព្យសម្បត្តិតាមរយៈការប្រកាសអំពីការបាត់ខ្លួន ត្រូវសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលបានប៉ុណ្ណោះ (មាត្រា32 កថាខណ្ឌទី2)។

# ជំពូកទី 3

## នីតិសិទ្ធិប្រត្យក្ស (1) — នីតិសិទ្ធិប្រត្យក្សទូទៅ

I. **ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិប្រត្យក្ស**

1. «វត្ថុ» ក្នុងនាមទ្រព្យធនសកម្ម និង សិទ្ធិប្រត្យក្ស
2. និយមន័យនៃសិទ្ធិប្រត្យក្ស និង គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់
3. ប្រភេទនៃសិទ្ធិប្រត្យក្ស
4. ការប្រៀបធៀបនីតិសិទ្ធិប្រត្យក្សទូទៅ និង នីតិសិទ្ធិប្រាតិភោគប្រត្យក្ស

II. **ចំណុចសំខាន់នៃនីតិសិទ្ធិប្រត្យក្សទូទៅដែលត្រូវសិក្សា**

1. សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស
2. ការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស
3. កម្មសិទ្ធិ
4. សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផលក្រៅពីកម្មសិទ្ធិ
5. សិទ្ធិកាន់កាប់

## I. និន្នាការទូទៅនៃនីតិសិទ្ធិប្រត្យក្ស

### 1. «វត្ថុ» ក្នុងនាមទ្រព្យធនសកម្ម និង សិទ្ធិប្រត្យក្ស

ក្រមរដ្ឋប្បវេណីបានបញ្ញត្តដោយបែងចែកសិទ្ធិដែលយើងមានជា សិទ្ធិចំពោះវត្ថុ និង សិទ្ធិចំពោះបុគ្គល។ សិទ្ធិចំពោះវត្ថុមានកំណត់ក្នុងគន្ថីទី2 សិទ្ធិប្រត្យក្ស នៃក្រមរដ្ឋប្បវេណី ហើយហៅថា នីតិសិទ្ធិប្រត្យក្ស។

ដើម្បីធ្វើឱ្យងាយស្រួលយល់ដល់អ្នកដែលសិក្សាផ្នែកសេដ្ឋកិច្ច និង ផ្នែកគណនេយ្យ ខ្ញុំសូមរៀបរាប់អំពីទ្រព្យធនសកម្មជាមុន។ ឧទាហរណ៍ ពាក្យថា ទ្រព្យធនសកម្មនៅក្នុងផ្នែកគណនេយ្យ គឺសំដៅទៅលើសមត្ថភាពក្នុងការរកចំណូលនាពេលអនាគតរបស់ក្រុមហ៊ុន ប៉ុន្តែ នៅទីនេះយើងមិនពិចារណាពិបាកបែបនេះទេ ហើយសូមអ្នកទាំងអស់គ្នាគិតថា ជាគោលការណ៍ គឺសំដៅទៅលើទ្រព្យសម្បត្តិដែលបុគ្គលម្នាក់មាន។ ទ្រព្យសម្បត្តិរបស់បុគ្គលអាចមាន អចលនវត្ថុដូចជា អគារ និង ដី, និងចលនវត្ថុដូចជា គ្រឿងសង្ហារឹម គ្រឿងអលង្ការ ផ្ទាំងគំនូរ, ព្រមទាំងសិទ្ធិលើបំណុលក្នុងទម្រង់ដូចជា ប័ណ្ណភាគហ៊ុន គណនីត្រូវទទួល ប្រាក់កម្ចី និង ប្រាក់សន្សំក្នុងកុងធនាគារ ជាដើម។ ក្រៅពីនេះ ក៏មានសាច់ប្រាក់សុទ្ធផងដែរ។ ក្នុងចំណោមវត្ថុខាងលើនេះ ចំពោះចលនវត្ថុ និង អចលនវត្ថុដែលមានរូបរាង ហៅថា «វត្ថុ» ក្នុងន័យក្រមរដ្ឋប្បវេណី (និយមន័យនៃវត្ថុ មាននៅក្នុងមាត្រា85 នៃបទប្បញ្ញត្តិទូទៅ ក្រមរដ្ឋប្បវេណី) (⇒ ពាក្យគន្លឹះ: វត្ថុចម្បង និង វត្ថុចំណុះ, វត្ថុដើម និង ផល)។ ហើយសិទ្ធិគ្រប់គ្រងដោយផ្ទាល់ចំពោះវត្ថុប្រភេទនេះរបស់បុគ្គលហៅថា «សិទ្ធិប្រត្យក្ស»។ មានន័យថា នៅក្នុងនីតិសិទ្ធិប្រត្យក្សមិនបានកំណត់អំពីវត្ថុណាដែលនឹងក្លាយទ្រព្យធនសកម្មនោះទេ ប៉ុន្តែ កំណត់អំពីទម្រង់នៃសិទ្ធិគ្រប់គ្រងដែលបុគ្គលមានចំពោះវត្ថុ។

ដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនបានចាត់ទុកថា ដី និង អគារនៅលើដីនោះ គឺជាអចលនវត្ថុឯករាជ្យពីគ្នា (ក៏មានប្រទេសផ្សេងដែលចាត់ទុកថាជាវត្ថុតែមួយផងដែរ)។ ហើយផ្ទុយពីនេះ ជាគោលការណ៍ ដើមឈើនៅលើដីនោះគឺជាផ្នែកមួយនៃដី (វត្ថុភ្ជាប់នៅក្នុងមាត្រា86។ ត្រូវចាត់ទុកថាអចលនវត្ថុ) ហើយវាអាចក្លាយជាកម្មវត្ថុនៃការធ្វើជំនួញឯករាជ្យ ដោយតម្រូវឱ្យមានតែឆន្ទៈរបស់ភាគី និង ការកំណត់របស់ច្បាប់ប៉ុណ្ណោះ។

**ពាក្យគន្លឹះ: វត្ថុចម្បង និង វត្ថុចំណុះ, វត្ថុដើម និង ផល**

ក្នុងករណីដែលវត្ថុ 2 មានទំនាក់ទំនងជាចម្បង និង ចំណុះជាលក្ខណៈសត្យានុម័ត និង សេដ្ឋកិច្ច (ឧទាហរណ៍ ផ្ទះ និង គ្រឿងសង្ហារឹមនៅខាងក្នុងជាដើម) ហៅថា វត្ថុចម្បង និង វត្ថុចំណុះ ហើយនៅក្នុងទំហំដែលមិនធ្វើឱ្យប៉ះពាល់សិទ្ធិរបស់អ្នកដទៃ វាសនាគតិយុត្តរបស់វត្ថុចំណុះត្រូវអនុលោមតាមវត្ថុចម្បង (ឧទាហរណ៍ បើសិនជាវត្ថុចម្បងត្រូវបានលក់ វត្ថុចំណុះត្រូវបានលក់ដូចគ្នា)។ វត្ថុចម្បង និង វត្ថុចំណុះត្រូវស្ថិតនៅក្រោមកម្មសិទ្ធិករតែមួយ ហើយវត្ថុចំណុះត្រូវតែជាវត្ថុដែលឯករាជ្យពីវត្ថុចម្បង (ទ្វារ និង ទ្វារសំណាញ់ខាងក្រៅអគារ គឺនៅជាប់នឹងអគារ ហើយមិនអាចក្លាយជាវត្ថុឯករាជ្យពីអគារដែលជាវត្ថុចម្បងនោះទេ)។

វត្ថុដែលមានប្រយោជន៍សេដ្ឋកិច្ចកើតចេញពីវត្ថុអ្វីមួយ ហៅថា ផល។ ហើយវត្ថុដែលបង្កើតផល ហៅថា វត្ថុដើម។ សូមចំណាំថា ពាក្យថា ផល មិនមែនសំដៅតែទៅលើផលជាផ្លែផ្កានោះទេ។ ផលដែលកើតចេញពីធម្មជាតិ ឬ សកម្មភាពមនុស្ស តាមរយៈវិធីប្រើវត្ថុដើមបែបសេដ្ឋកិច្ច ហៅថា ផលធម្មជាតិ (ដូចជា ស៊ុត ផ្លែឈើ ពោមចៀម គ្រួស រ៉ែ និង ខ្សាច់ ជាអាទិ៍។ មាត្រា88 កថាខណ្ឌទី1) ចំណែកឯ ប្រាក់ ឬ វត្ថុផ្សេងទៀត ដែលទទួលបានក្នុងនាមជាតម្លៃតបទៅនឹងការប្រើប្រាស់វត្ថុដើម ហៅថា ផលស៊ីវិល (ដូចជា ថ្លៃឈ្នួល ការប្រាក់ ជាអាទិ៍។ មាត្រា88 កថាខណ្ឌទី2)។

## 2. និយមន័យនៃសិទ្ធិប្រត្យក្ស និង គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់

ចំពោះនិយមន័យនៃសិទ្ធិប្រត្យក្ស យើងបានរៀបរាប់ដោយសង្ខេបរួចហើយ (ជំពូកទី1)។ ឧទាហរណ៍ យើងមានកម្មសិទ្ធិលើនាឡិកាដៃមួយ ក្នុងករណីនេះ យើងអាចប្រើប្រាស់នាឡិកានោះដោយសេរី និង ទទួលផល ព្រមទាំងចាត់ចែងផងដែរ។ ហើយ «សិទ្ធិដែលបុគ្គលអាចគ្រប់គ្រងដោយចំពោះលើវត្ថុអ្វីមួយ» ហៅថា «សិទ្ធិប្រត្យក្ស»។ អាស្រ័យហេតុនេះ នៅក្នុងសិទ្ធិប្រត្យក្សជាសិទ្ធិដែលអាចគ្រប់គ្រងដោយផ្ទាល់លើវត្ថុអ្វីមួយ ប្រាកដជាមានលក្ខណៈដែលហាមមិនឱ្យអ្នកដទៃមករំខានដល់ការគ្រប់គ្រងវត្ថុនោះ និង លក្ខណៈដែលអាចអះអាងចំពោះបុគ្គលគ្រប់រូបទូទាំងពិភពលោក។ នេះហៅថា លក្ខណៈផ្តាច់មុខ ឬ លក្ខណៈដាច់ខាតនៃសិទ្ធិប្រត្យក្ស។ ហើយសិទ្ធិដែលអាចអះអាងចំពោះបុគ្គលគ្រប់រូបទូទាំងពិភពលោកបែបនេះ មានឥទ្ធិពលដល់បុគ្គលជុំវិញខ្លួន ហេតុនេះហើយ បុគ្គលម្នាក់ៗមិនអាចបង្កើតខ្លឹមសារនៃសិទ្ធិប្រត្យក្សនេះតាមចិត្តឯងនោះទេ។ ដូចនេះ ក្រមរដ្ឋប្បវេណី មាត្រា175 បានកំណត់ថា «សិទ្ធិប្រត្យក្សអាចបង្កើតបាន តែតាមខ្លឹមសារដែលមានកំណត់នៅក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតប៉ុណ្ណោះ»។ នេះមានន័យថា ភាគីមិនអាចបង្កើតប្រភេទនៃសិទ្ធិប្រត្យក្សតាមរយៈកិច្ចសន្យាជាដើម ដែលខុសទៅនឹងប្រភេទនៃសិទ្ធិប្រត្យក្សដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀតនោះទេ ហើយខ្លឹមសារនៃសិទ្ធិប្រត្យក្សមិនអាចខុសទៅនឹងអ្វីដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀតនោះទេ។ នេះហៅថា គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់។ ដូចនេះ បញ្ញត្តិអំពីប្រភេទ និង ខ្លឹមសារនៃសិទ្ធិប្រត្យក្ស គឺជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ដែលមិនអាចធ្វើការផ្លាស់ប្តូរតាមឆន្ទៈរបស់ភាគីបានឡើយ។ នេះគឺជាចំណុចដែលខុសគ្នាទាំងស្រុងពីសិទ្ធិលើបំណុល ដែលភាគីអាចបង្កើតបានដោយសេរីតាមរយៈកិច្ចសន្យាបាន (ចំពោះសិទ្ធិលើបំណុល ភាគីអាចបង្កើតខ្លឹមសារនៃសិទ្ធិលើបំណុលរាប់ពាន់រាប់ម៉ឺនរូបភាពខុសគ្នាតាមរយៈកិច្ចសន្យាបាន ដរាបណាមិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។ ដោយសារតែ សិទ្ធិលើបំណុលមានអានុភាពមិនដាច់ខាតដោយមានចំណងរវាងភាគីតែប៉ុណ្ណោះ ហេតុនេះហើយ ភាគីអាចបង្កើតបានដោយសេរី)។

## 3. ប្រភេទនៃសិទ្ធិប្រត្យក្ស

### (1) កម្មសិទ្ធិ

ឥលូវនេះ យើងនឹងមើលអំពីប្រភេទនៃសិទ្ធិប្រត្យក្សដែលត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី (ប្រភេទនៃសិទ្ធិគ្រប់គ្រងចំពោះវត្ថុរបស់បុគ្គល)។ កម្មវត្ថុដែលតំណាងឱ្យសិទ្ធិប្រត្យក្សគឺ កម្មសិទ្ធិ (មាត្រា206)។ កម្មសិទ្ធិករនៃនាឡិកាអាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងនាឡិកានោះ ដោយចិត្តឯង និង ដោយសេរីបាន។ នេះមានន័យថា កម្មសិទ្ធិ គឺជាទម្រង់មួយនៃសិទ្ធិប្រត្យក្សជាសកលយ៉ាងពេញលេញ។ ហេតុនេះ យើងនឹងមើលបន្តថា តើសិទ្ធិប្រត្យក្សណាខ្លះដែលគ្មានទម្រង់ជាសកលយ៉ាងពេញលេញ?

### (2) សិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតក្រៅពីកម្មសិទ្ធិ

ឧទាហរណ៍ ចំពោះវត្ថុដែល A មានកម្មសិទ្ធិលើក៏ដោយ ក៏ B ដែលជាអ្នកដទៃអាចមានសិទ្ធិមួយផ្នែកទៅលើវត្ថុនោះដែរ។ ចំណុចដែលត្រូវចំណាំនៅទីនេះគឺ ដើមឡើយសិទ្ធិប្រត្យក្សប្រភេទដូចគ្នាមិនអាចមាននៅលើវត្ថុតែមួយនោះទេ (គោលការណ៍សិទ្ធិមួយលើវត្ថុមួយ)។ ឧទាហរណ៍ បងប្អូន 2នាក់ មានកម្មសិទ្ធិលើវត្ថុតែមួយ ក្នុងករណីនេះ បងប្អូននោះមានកម្មសិទ្ធិអវិភាគរួមគ្នាលើវត្ថុតែមួយ មិនមែនមានកម្មសិទ្ធិម្នាក់មួយនោះទេ។ ហើយកម្មសិទ្ធិដែលមានតែមួយលើវត្ថុមួយ អាចកាត់ផ្តាច់នូវមុខងារណាមួយ ក្នុងចំណោមមុខងារនៃកម្មសិទ្ធិដែលមានការប្រើប្រាស់ ការអាស្រ័យផល និង ការចាត់ចែង ទៅឱ្យបុគ្គលដទៃកាន់បាន (កម្មសិទ្ធិករលើដីគឺជា A ប៉ុន្តែ សិទ្ធិប្រើប្រាស់ដើម្បីដាំដុះនៅលើដីនោះគឺជា B ជាដើម)។ នេះហៅថា សិទ្ធិប្រត្យក្សផ្សេងទៀតក្រៅពីកម្មសិទ្ធិ ឬ សិទ្ធិប្រត្យក្សដែលត្រូវបានកម្រិត។

### (3) សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផល

ប្រភេទនៃសិទ្ធិប្រត្យក្សផ្សេងទៀតដែលក្រមរដ្ឋប្បវេណីបានកំណត់រួមមាន **សិទ្ធិលើដី** ជាសិទ្ធិប្រើប្រាស់ដីអ្នកដទៃដោយសេរី ដូចជាសាងសង់សំណង់អគារនៅលើដីនោះជាដើម (ចាប់ពីមាត្រា265), **សិទ្ធិបង្កើនផលអចិន្ត្រៃយ៍** ជាសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃសម្រាប់ដាំដំណាំ ឬ ចិញ្ចឹមសត្វ (ចាប់ពីមាត្រា270), **សេវភាព** ជាសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃដើម្បីចេញចូល ឬ ទាញយកទឹកជាដើម សម្រាប់ជាប្រយោជន៍ដីរបស់ខ្លួន (ចាប់ពីមាត្រា280), និង **សិទ្ធិចំពោះទ្រព្យរួមរបស់សមាជិកនៃសហគមន៍** ជាសិទ្ធិដែលក្រុមមនុស្សជាក់លាក់មួយ អាចប្រើប្រាស់ដីរួមគ្នា (មាត្រា263 និង មាត្រា294)។ សិទ្ធិទាំងនេះគឺជាសិទ្ធិដែលពាក់ព័ន្ធនឹងអចលនវត្ថុ ហើយជាសិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតទាំង 4ប្រភេទ សម្រាប់ប្រើប្រាស់វត្ថុរបស់អ្នកដទៃ។ ជាទូទៅ សិទ្ធិទាំងនេះហៅថា សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផល។ នេះមានន័យថា សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផល ត្រូវបានកម្រិតត្រឹមតែខ្លឹមសារនៃការប្រើប្រាស់ និង អាស្រ័យផលលើវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃប៉ុណ្ណោះ និងជាសិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតដែលរឹតត្បិតទៅលើកម្មសិទ្ធិត្រឹមកម្រិតនោះ។

### (4) **សិទ្ធិប្រាតិភោគប្រត្យក្ស**

ផ្ទុយពីនេះ ក្រមរដ្ឋប្បវេណីក៏មានកំណត់អំពីខ្លឹមសារនៃសិទ្ធិប្រត្យក្សដែលត្រូវបានកម្រិត ដែលជាសិទ្ធិធានាតែតម្លៃនៃវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ និង គ្មានការប្រើប្រាស់ជាក់ស្ដែងលើវត្ថុនោះ។ ជាក់ស្ដែង ម្ចាស់បំណុលក្ដោបក្ដាប់តម្លៃនៃវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល នៅពេលដែលម្ចាស់បំណុលនោះបានឱ្យប្រាក់ទៅកូនបំណុលខ្ចីជាដើម ដើម្បីធានាការប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនមកវិញ។ នេះហៅថា សិទ្ធិប្រាតិភោគប្រត្យក្ស (មានន័យថា នៅពេលដែលខ្ចីប្រាក់ កូនបំណុលបានដាក់ទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីធានា ហើយបើសិនជាមិនអាចសងប្រាក់តាមកំណត់ពេលទេ ម្ចាស់បំណុលអាចលក់វត្ថុដែលបានផ្ដល់ជាការធានានោះ ហើយប្រមូលប្រាក់ដែលបានឱ្យខ្ចីនោះពីថ្លៃលក់វត្ថុនោះវិញ។ ទម្រង់នៃការអនុវត្តបែបនេះ គឺជាសិទ្ធិប្រាតិភោគប្រត្យក្ស)។ សិទ្ធិប្រាតិភោគប្រត្យក្សដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីអាចបែងចែកជា 2 គឺ **សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យា** (សិទ្ធិនេះកើតឡើងតាមរយៈកិច្ចសន្យារបស់ភាគី) និង **សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់** (សិទ្ធិនេះត្រូវបានផ្ដល់ដោយច្បាប់ ក្នុងករណីដែលស្ថានភាពជាក់លាក់ណាមួយបានកើតឡើង)។ សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យារួមមាន **សិទ្ធិលើការបញ្ចាំ** (ចាប់ពីមាត្រា342។ ដោយឡែក សិទ្ធិលើការបញ្ចាំ ក៏អាចបង្កើតនៅលើអចលនវត្ថុ និង សិទ្ធិលើបំណុលផងដែរ) ដែលត្រូវបានបង្កើតញឹកញាប់ទៅលើចលនវត្ថុ ពោលគឺទំនិញទូទៅ និង **ហ៊ីប៉ូតែក** (ចាប់ពីមាត្រា369) ដែលត្រូវបានប្រើប្រាស់ទៅលើអចលនវត្ថុ ពោលគឺដី និង អគារ។ សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់ រួមមាន**សិទ្ធិឃាត់ទុក** (ចាប់ពីមាត្រា295) និង **ឯកសិទ្ធិ** (ចាប់ពីមាត្រា303)។

### (5) **សិទ្ធិកាន់កាប់**

ហើយសិទ្ធិមួយទៀតដែលជាមិត្តរបស់សិទ្ធិប្រត្យក្ស គឺ សិទ្ធិកាន់កាប់។ សិទ្ធិដែលត្រូវបានយកមកបញ្ញត្តិដំបូងគេនៅក្នុងគន្ថីស្ដីពីសិទ្ធិប្រត្យក្ស ពុំមែនជាបញ្ញត្តិនៃកម្មសិទ្ធិនោះទេ ប៉ុន្តែជាបញ្ញត្តិអំពីសិទ្ធិកាន់កាប់ (សិទ្ធិកាន់កាប់ ត្រូវបានបញ្ញត្តចាប់ពីមាត្រា180) ពីព្រោះ សិទ្ធិនេះមានសារជាតុខ្លះខុសពីសិទ្ធិប្រត្យក្សផ្សេងទៀត។ មានន័យថា សិទ្ធិប្រត្យក្សចាប់ពីកម្មសិទ្ធិទៅ ទោះបីមានលក្ខណៈពេញលេញ ឬមួយផ្នែកក៏ដោយ សុទ្ធតែជាសិទ្ធិដែលមានរូបភាពបង្ហាញអំពីសិទ្ធិអំណាចតាមច្បាប់សារជាតុដែលបុគ្គលមានចំពោះវត្ថុ (សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត) ប៉ុន្តែ សិទ្ធិកាន់កាប់មិនមែនពិចារណាបែបនេះនោះទេ ហើយវាជាប្រព័ន្ធមួយដែលការពារស្ថានភាពជាក់ស្ដែងនៃការគ្រប់គ្រងលើវត្ថុនោះនៅពេលបច្ចុប្បន្ន ដោយមិនគិតអំពីម្ចាស់សិទ្ធិតាមច្បាប់សារជាតុនោះទេ (មានពន្យល់នៅពេលក្រោយក្នុងចំណុចទី II 5)។

ដូចនេះ គន្ថីស្ដីពីសិទ្ធិប្រត្យក្សក្នុងក្រមរដ្ឋប្បវេណី ត្រូវបានបញ្ញត្តតាមលំដាប់ដែលចាប់ផ្ដើមចេញពីសិទ្ធិកាន់កាប់ កម្មសិទ្ធិ សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផល និង សិទ្ធិប្រាតិភោគប្រត្យក្ស។ នៅក្នុងចំណោមសិទ្ធិខាងលើនេះ សិទ្ធិកាន់កាប់ កម្មសិទ្ធិ និងរហូតដល់សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផល នៅក្នុងការសិក្សាផ្នែកច្បាប់ គេហៅថា

នីតិសិទ្ធិប្រត្យក្សក្នុងន័យចង្អៀត ឬ នីតិសិទ្ធិប្រត្យក្សទូទៅ។ ចំណែកឯ ការសិក្សាសិទ្ធិប្រាតិភោគប្រត្យក្សវិញ គេបានចាត់ទុកជាផ្នែកឯករាជ្យ ហើយហៅថា នីតិសិទ្ធិប្រាតិភោគប្រត្យក្ស។

### 4. **ការប្រៀបធៀបនីតិសិទ្ធិប្រត្យក្សទូទៅ និង នីតិសិទ្ធិប្រាតិភោគប្រត្យក្ស**

នីតិសិទ្ធិប្រត្យក្សទូទៅមានចំណុចពិសេសត្រង់ មានខ្លឹមសារជាលក្ខណៈទ្រឹស្តីច្រើន និងមានមាត្រាដែលជាបញ្ញត្តិដែលអនុវត្តដោយបង្ខំច្រើន។ ចំណែកឯ នីតិសិទ្ធិប្រាតិភោគប្រត្យក្សវិញមានចំណុចពិសេសត្រង់លក្ខណៈមុខងារ និង លក្ខណៈបច្ចេកទេស ដែលអាចនិយាយបានថា ជាផ្នែកមួយដែលមានសារៈសំខាន់បំផុតសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុជាក់ស្តែង (នៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុជាក់ស្តែង នីតិសិទ្ធិប្រាតិភោគប្រត្យក្ស និង នីតិសិទ្ធិលើបំណុលទូទៅ បានក្លាយជាបញ្ហាញឹកញាប់ជាងគេ)។ បើនិយាយឱ្យស្រួលយល់ នៅក្នុងនីតិសិទ្ធិប្រត្យក្សទូទៅ យើងនឹងសិក្សាដោយផ្តោតសំខាន់ថា តើសិទ្ធិប្រត្យក្សគឺជាអ្វី? ចំណែកឯ នៅក្នុងនីតិសិទ្ធិប្រាតិភោគប្រត្យក្សវិញ យើងនឹងសិក្សាថា តើសិទ្ធិប្រត្យក្សនេះត្រូវប្រើប្រាស់បែបណា ដើម្បីធានា និងប្រមូល សិទ្ធិលើបំណុលដែលជាប្រាក់កម្ចី ឬ គណនីត្រូវទទួល ជាអាទិ៍។ លើសពីនេះ ប្រសិនបើយើងមិនយល់ដល់ប្រតិបត្តិការជំនួញជាក់ស្តែងទេ យើងនឹងមានភាពលំបាកយ៉ាងខ្លាំងដើម្បីយល់អំពីអត្ថន័យពិតនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស។ ដូចនេះ នៅក្នុងលំដាប់លំដោយនៃការសិក្សាក្រមរដ្ឋប្បវេណី យើងអាចសិក្សាអំពីនីតិសិទ្ធិប្រត្យក្សទូទៅជាមុនបាន ប៉ុន្តែ នីតិសិទ្ធិប្រាតិភោគប្រត្យក្សវិញ គួរតែទុកក្រោយបន្តិចសិន។ វិធីសាស្ត្រសិក្សាមួយដែលខ្ញុំអាចណែនាំបានគឺ ដំបូងយើងត្រូវយល់អំពីចំណុចជាមូលដ្ឋាននៃនីតិសិទ្ធិប្រត្យក្សទូទៅ ហើយបន្ទាប់មកទៀត ទើបសិក្សាអំពីនីតិសិទ្ធិប្រាតិភោគប្រត្យក្សដែលពាក់ព័ន្ធនឹងសិទ្ធិលើបំណុលទូទៅ។ ហេតុនេះ នៅក្នុងសៀវភៅនេះ ខ្ញុំនឹងបង្ហាញត្រួសៗអំពីនីតិសិទ្ធិប្រាតិភោគប្រត្យក្សនៅក្នុងផ្នែកនេះ ហើយការបកស្រាយលម្អិតនឹងធ្វើឡើងនៅក្នុងជំពូកទី7 បន្ទាប់ពីបានសិក្សាអំពីនីតិសិទ្ធិលើបំណុលរួច។

## II. **ចំណុចសំខាន់នៃនីតិសិទ្ធិប្រត្យក្សទូទៅដែលត្រូវសិក្សា**

### 1. **សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស**

ដូចបានរៀបរាប់រួចហើយថា សិទ្ធិប្រត្យក្ស គឺជាសិទ្ធិគ្រប់គ្រងដាច់ខាត និងផ្ទាល់មុខលើវត្ថុ ហើយអាចអះអាងចំពោះបុគ្គលគ្រប់រូប។ លើសពីនេះ ក្នុងករណីដែលសិទ្ធិនេះត្រូវបានបំពានដោយបុគ្គលដទៃ យើងអាចទាមទារឱ្យបញ្ឈប់ការបំពាននោះ ទាមទារឱ្យប្រគល់វិញចំពោះវត្ថុដែលបុគ្គលដទៃបានដកហូត និងទាមទារមិនឱ្យកើតមានការបំពាន ដោយផ្អែកលើសារជាតុជាមូលដ្ឋានដែលសិទ្ធិប្រត្យក្សមាន។ នេះហៅថា សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សនេះ គឺជាសិទ្ធិដែលកើតចេញពីការមានសិទ្ធិប្រត្យក្សផ្ទាល់ (ក្នុងករណីនេះ បើសិនជាមានស្ថានភាពនៃការបំពានដែលខុសនឹងច្បាប់ជាសច្ចានុម័ត ម្ចាស់សិទ្ធិអាចអនុវត្តសិទ្ធិទាមទារ

នេះបាន ដោយមិនតម្រូវឱ្យមានអត្ថិភាពនៃចេតនា ឬ កំហុសរបស់អ្នកបំពាននោះទេ) ហើយខុសគ្នាពីសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិលើបំណុល ដែលបុគ្គលណាម្នាក់អាចទាមទារចំពោះបុគ្គលជាក់លាក់ផ្សេងដោយផ្អែកលើកិច្ចសន្យាជាដើម (ឧទាហរណ៍ ការទាមទារថ្លៃលក់ទិញដោយផ្អែកលើកិច្ចសន្យាលក់ទិញ ជាអាទិ៍)។ មានន័យថា បើនិយាយអំពីកម្មសិទ្ធិ កម្មសិទ្ធិករអាចទាមទារឱ្យប្រគល់វិញ បើសិនជាបុគ្គលដទៃបានយកវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនតាមទំនើងចិត្ត (ឬដោយចៃដន្យ) និង អាចទាមទារឱ្យចាកចេញពីដីរបស់ខ្លួន បើសិនជាបុគ្គលដទៃបានចូលមកដោយគ្មានការអនុញ្ញាតជាដើម (សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងដោយផ្អែកលើកម្មសិទ្ធិ)។ ហើយសូម្បីតែសិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតផ្សេងទៀត ដូចជា សិទ្ធិលើដីជាដើម ក៏អាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ទៅតាមទំហំនៃសិទ្ធិប្រត្យក្សនីមួយៗផងដែរ (ចំពោះសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សនៅក្នុងសិទ្ធិប្រាតិភោគប្រត្យក្សដូចជា ហ៊ីប៉ូតែក ជាអាទិ៍ នឹងមានរៀបរាប់នៅក្នុងជំពូកទី7)។

## 2. ការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស

សិទ្ធិប្រត្យក្ស ទាំងចលនវត្ថុ និង អចលនវត្ថុ អាចត្រូវបានផ្ទេរតាមរយៈកិច្ចសន្យាដូចជា លក់ទិញ និង ប្រទានកម្ម និង អាចត្រូវបានផ្ទេរដោយមូលហេតុសន្តតិកម្មជាដើមផងដែរ។ ចំណុចដែលត្រូវពិភាក្សាធំបំផុតនៅក្នុងនីតិសិទ្ធិប្រត្យក្សទូទៅ គឺការផ្លាស់ប្តូរសិទ្ធិប្រត្យក្សនេះ ពោលគឺ បញ្ហានៅពេលដែលសិទ្ធិប្រត្យក្សផ្ទេរពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។ នៅក្នុងចំណុចនេះមានការពិភាក្សាច្រើន និងមានទ្រឹស្តីជាច្រើនត្រូវបានបង្កើតឡើង។ ប៉ុន្តែ អ្នកទើបចាប់ផ្តើមសិក្សាមិនគួរផ្តោតសំខាន់លើការពិភាក្សាទាំងនោះពេកទេ ហើយបែរជាមើលរំលងរចនាសម្ព័ន្ធស្នូលឡើយ។ នៅចំណុចនេះ យើងនឹងសង្កត់ធ្ងន់អំពីរចនាសម្ព័ន្ធជាមូលដ្ឋាននៃបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីជប៉ុន។

### (1) គោលការណ៍បង្ហាញជាសាធារណៈ

សិទ្ធិប្រត្យក្សគឺជាសិទ្ធិដែលអាចអះអាងចំពោះបុគ្គលគ្រប់រូប ហេតុនេះហើយ ប្រសិនបើបុគ្គលដែលនៅជុំវិញមិនអាចដឹងថានរណាជាម្ចាស់សិទ្ធិតាមវិធីសាស្ត្រណាមួយនោះទេ បុគ្គលដែលនៅជុំវិញនោះនឹងជួបបញ្ហាលំបាក។ មានន័យថា ចំពោះសិទ្ធិប្រត្យក្សគឺត្រូវតែមានវិធីណាមួយដែលអាចជូនដំណឹងជាសាធារណៈអំពីអត្ថិភាពនៃសិទ្ធិនោះ និយាយជារួមគឺ សិទ្ធិនេះត្រូវតែមានវិធីបង្ហាញជាសាធារណៈ។ គោលគំនិតដែលលើកឡើងថាការផ្លាស់ប្តូរសិទ្ធិប្រត្យក្សត្រូវស្របជាមួយការបង្ហាញជាសាធារណៈ គេហៅថា គោលការណ៍បង្ហាញជាសាធារណៈ។ បច្ចុប្បន្ននេះ ចំណុចដែលតម្រូវឱ្យមានការបង្ហាញជាសាធារណៈនេះ គឺដូចគ្នានៅតាមបណ្តាប្រទេសដទៃផងដែរ ប៉ុន្តែ បញ្ហាគឺអត្ថន័យគតិយុត្តដែលមាននៅក្នុងការបង្ហាញជាសាធារណៈ ។

### (2) គោលការណ៍នៃលក្ខខណ្ឌតតាំង

① សញ្ញាណទូទៅ

គោលការណ៍ជាមូលដ្ឋាននៃក្រមរដ្ឋប្បវេណីជប៉ុនចំពោះការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស ពោលគឺរចនាសម្ព័ន្ធជាមូលដ្ឋាន គឺដូចគ្នានឹងការផ្ទេរសិទ្ធិលើបំណុលទូទៅ ដែលនឹងមានរៀបរាប់នៅពេលក្រោយផងដែរ ពោលគឺ គោលការណ៍នៃលក្ខខណ្ឌតតាំង។ និយាយជារួម នៅក្នុងទំនាក់ទំនងរវាងភាគីនិងភាគី សិទ្ធិប្រត្យក្សត្រូវផ្ទេរដោយការបង្ហាញឆន្ទៈរបស់ភាគីប៉ុណ្ណោះ (មាត្រា176។ ហៅថា **គោលការណ៍បង្ហាញឆន្ទៈ**នៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស។ នេះមានន័យថា « លក្ខខណ្ឌអានុភាព» ដែលចាំបាច់ដើម្បីផ្ទេរសិទ្ធិប្រត្យក្សមានតែការបង្ហាញឆន្ទៈរបស់ភាគីប៉ុណ្ណោះ)។ ប៉ុន្តែ ដើម្បីអះអាងការតតាំងអំពីចំណុចខាងលើនេះ ចំពោះបុគ្គលផ្សេងក្រៅពីភាគីក្នុងកិច្ចសន្យា ភាគីត្រូវបំពេញនីតិវិធីដើម្បីតតាំងដែលច្បាប់បានកំណត់ ពោលគឺ បំពេញលក្ខខណ្ឌតតាំង។ (⇒ពាក្យគន្លឹះ: **លក្ខខណ្ឌតតាំង**) នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន លក្ខខណ្ឌតតាំងនៃអចលនវត្ថុគឺការចុះបញ្ជី (មាត្រា177) និង លក្ខខណ្ឌតតាំងនៃចលនវត្ថុគឺការប្រគល់វត្ថុនោះ (មាត្រា178)។ (ដោយឡែក សូមនិយាយទុកជាមុនថា ទោះបីជាសិទ្ធិកាន់កាប់គឺជាសិទ្ធិប្រត្យក្សក៏ដោយ ក៏សិទ្ធិនេះគ្រាន់តែការពារត្រឹមស្ថានភាពជាក់ស្តែងនៃការគ្រប់គ្រងវត្ថុ ហើយសិទ្ធិនេះខុសគ្នាទៅនឹងសិទ្ធិប្រត្យក្សជាក់លាក់ផ្សេងទៀតដូចជា កម្មសិទ្ធិជាដើម ហេតុនេះហើយ ទោះបីជាកំពុងតែកាន់កាប់អចលនវត្ថុក៏ដោយ ក៏មិនអាចចុះបញ្ជីសិទ្ធិកាន់កាប់បានដែរ។

នេះមានន័យថា បើសិនជា A លក់ដីដែលជាកម្មសិទ្ធិរបស់ខ្លួនឱ្យទៅ B ហើយគ្រាន់តែបង្កើតកិច្ចសន្យាដោយបង្ហាញឆន្ទៈត្រូវគ្នាដែលថាចង់លក់និងចង់ទិញនោះ ក្នុងករណីនេះ ដីរបស់ A ក្លាយជាវត្ថុរបស់ B តែនៅក្នុងទំនាក់ទំនងរវាង A និង B ប៉ុណ្ណោះ។ B មិនអាចអះអាងថាវត្ថុនោះក្លាយជារបស់ខ្លួន ចំពោះអ្នកនៅជុំវិញនោះដែលជា C D និង E នោះទេ ហើយដើម្បីអះអាងការតតាំងបាន លុះត្រាតែ B បានទទួលការចុះបញ្ជីផ្ទេរពី A។ តាមរយៈការផ្លាស់ប្តូរឈ្មោះក្នុងសៀវភៅចុះបញ្ជីមកឱ្យ B ហើយវាធ្វើឱ្យ B អាចបង្ហាញជាសាធារណៈថា ខ្លួនជាម្ចាស់សិទ្ធិ។ ដូចនេះ វិធីបង្ហាញជាសាធារណៈនៅប្រទេសជប៉ុនគឺ ការចុះបញ្ជីចំពោះអចលនវត្ថុ និង ការទទួលការប្រគល់ចំពោះចលនវត្ថុ ប៉ុន្តែ ការផ្លាស់ប្តូរសិទ្ធិប្រត្យក្សកើតឡើងតាមរយៈការបង្ហាញឆន្ទៈរបស់ភាគីប៉ុណ្ណោះ ហើយការផ្ទេរការចុះបញ្ជី និង ការប្រគល់វត្ថុគ្រាន់តែតម្រូវឱ្យមានក្នុងនាមជាលក្ខខណ្ឌតតាំងនោះទេ។

> ពាក្យគន្លឹះ: **លក្ខខណ្ឌតតាំង**
>
> នៅក្នុងប្រទេសជប៉ុន គេប្រើប្រាស់គោលការណ៍នៃលក្ខខណ្ឌតតាំង ទាំងទៅលើការអនុប្បទានសិទ្ធិលើបំណុល និង ការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើអចលនវត្ថុ និង ចលនវត្ថុ។ យើងនឹងបែងចែកឱ្យបានត្រឹមត្រូវអំពី « លក្ខខណ្ឌអានុភាព» និង «លក្ខខណ្ឌតតាំង» នៃការផ្ទេរសិទ្ធិ។ លក្ខខណ្ឌតតាំងចំពោះតតិយជននៃករណីអនុប្បទានសិទ្ធិលើបំណុល គឺការជូនដំណឹងតាមរយៈលិខិតដែលមានកាលបរិច្ឆេទស្លាពទៅកាន់កូនបំណុល ឬ ការយល់ព្រមពីកូនបំណុល (មាត្រា467 កថាខណ្ឌទី2⇒ជំពូកទី6 II 5 (2))។

② នីតិប្រៀបធៀប

គោលគំនិតដែលយកការព្រមព្រៀងធ្វើជាការផ្ទេរសិទ្ធិប្រត្យក្ស ហើយយកការប្រគល់ ឬ ការចុះបញ្ជីធ្វើជាលក្ខខណ្ឌតតាំងនេះ គឺជាគោលគំនិតបែបប្រទេសបារាំង។ ផ្ទុយមកវិញ នៅក្នុងគោលគំនិតបែបប្រទេសអាឡឺម៉ង់ សិទ្ធិប្រត្យក្សមិនផ្ទេរដោយគ្រាន់តែមានការព្រមព្រៀងនោះទេ។ ករណីអចលនវត្ថុ ការផ្លាស់ប្តូរសិទ្ធិប្រត្យក្សកើតឡើងដំបូងនៅពេលដែលផ្ទេរការចុះបញ្ជី ចំណែកឯករណីចលនវត្ថុវិញ ការផ្លាស់ប្តូរសិទ្ធិប្រត្យក្សកើតឡើងដំបូងនៅពេលប្រគល់។ មានន័យថា នៅប្រទេសអាឡឺម៉ង់ ការចុះបញ្ជីមិនមែនជាលក្ខខណ្ឌតតាំងនោះទេ ប៉ុន្តែ វាជាលក្ខខណ្ឌបង្កើត និង លក្ខខណ្ឌអានុភាពនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស។ តាមពិត វិធីចុះបញ្ជីរបស់ប្រទេសបារាំង និង ប្រទេសអាឡឺម៉ង់គឺខុសគ្នា ហើយច្បាប់ចុះបញ្ជីនៅក្នុងប្រទេសជប៉ុនកំពុងប្រើប្រាស់វិធីចុះបញ្ជីជាក់ស្តែងតាមគោលគំនិតបែបអាឡឺម៉ង់។ ដោយសារមានស្ថានភាពខាងលើនេះផង និងវិធីរបស់ប្រទេសអាឡឺម៉ង់ដែលសិទ្ធិមាននៅនឹងកន្លែងចុះបញ្ជីតែម្តងបែបនេះ វាងាយស្រួលយល់ផង ហេតុនេះហើយ នៅក្នុងចំណោមអ្នកសិក្សាច្បាប់ជប៉ុនក៏មានទស្សនៈដែលអះអាងគាំទ្រការបកស្រាយតាមបែបប្រទេសអាឡឺម៉ង់ ចំពោះការផ្លាស់ប្តូរសិទ្ធិប្រត្យក្សផងដែរ។ ការពិភាក្សាលើចំណុចនេះនឹងកាន់តែពិបាកខ្លាំងចាប់ពីចំណុចនេះទៅមុខ ប៉ុន្តែ សូមអ្នកទាំងអស់គ្នាចំណាំទុកថា បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីជប៉ុនកំពុងតែប្រកាន់យកនូវគោលការណ៍នៃលក្ខខណ្ឌតតាំងតាមបែបប្រទេសបារាំង។

**(3) បញ្ហានៃការតតាំង**

សូមពិចារណាអំពីឧទាហរណ៍មុននេះឡើងវិញ បើសិនជា A បានចុះកិច្ចសន្យាលក់ដីដែលជាកម្មសិទ្ធិរបស់ខ្លួនឱ្យទៅ B, នៅក្នុងដំណាក់កាលនេះ កម្មសិទ្ធិលើដីនោះបានផ្ទេរទៅឱ្យ B រួចហើយ នៅក្នុងទំនាក់ទំនងរវាង A និង B។ ប៉ុន្តែ បើសិនជាការចុះបញ្ជីនៅតែមានឈ្មោះ A ដដែល ហើយបើស្ថិតនៅក្នុងស្ថានភាពដែលមិនបានចុះបញ្ជីផ្ទេរមកឱ្យ B នៅឡើយទេ, B មិនអាចតតាំងថាខ្លួនជាម្ចាស់សិទ្ធិចំពោះបុគ្គលគ្រប់រូបនោះទេ។ នៅក្នុងស្ថានភាពនេះ ឧបមាថា A បានលក់ដីដូចគ្នានោះទៅឱ្យ C ផងដែរ។ ការទិញលក់ជាន់គ្នាបែបនេះមិនចង់ឱ្យកើតមាននោះទេ ប៉ុន្តែ ដោយសារស្ថានភាពផ្សេងៗ ជាក់ស្តែងរឿងនេះកើតមានច្រើន។ នៅក្នុងករណីបែបនេះ បើសិនជា C បានទទួលការចុះបញ្ជីផ្ទេរពី A មកមុន, C នឹងអាចអះអាងថាខ្លួនជាម្ចាស់សិទ្ធិចំពោះបុគ្គលគ្រប់រូប ហើយដីនោះនឹងក្លាយទៅជារបស់ C។ នៅក្នុងឧទាហរណ៍នៃការធ្វើអនុប្បទានជាន់គ្នាបែបនេះ ប្រសិនបើបុគ្គលដែលអះអាងអំពីសិទ្ធិដែលមានវិសមតិភាពជាមួយគ្នា មានច្រើននាក់បែបនេះ អាទិភាពនៃសិទ្ធិនោះត្រូវសម្រេចដោយលក្ខខណ្ឌតតាំង។ នេះហៅថា បញ្ហានៃការតតាំង។

ប៉ុន្តែ ប្រសិនបើបុគ្គល C ដែលនៅក្នុងឧទាហរណ៍នេះ បានដឹងយ៉ាងច្បាស់ថា A និង B បានចុះកិច្ចសន្យាលក់ទិញជាមួយគ្នារួចហើយ ហើយខ្លួននៅតែចុះកិច្ចសន្យាដោយមានបំណងដណ្តើមពី B ទៀត ហើយបានចុះបញ្ជីផ្ទេរមកខ្លួន។ ក្នុងករណីនេះ បញ្ហានឹងកើតមានឡើង បើសិនជាយើងនៅតែផ្តល់អាទិភាពឱ្យ C ទៀត ហេតុនេះហើយ យុត្តិសាស្ត្រតុលាការបានចាត់ទុក C ដែលនៅក្នុងករណីខាងលើនេះ ជាបុគ្គលទុច្ចរិតធ្ងន់ធ្ងរ ហើយជាករណី

លើកលែង B គឺជាអនុប្បទានិកទី1 ដែលអាចតតាំងថាខ្លួនជាម្ចាស់សិទ្ធិ ចំពោះបុគ្គលដែលទុច្ចរិតធ្ងន់ធ្ងរនោះ ទោះបីជាមិនទាន់បានបំពេញការចុះបញ្ជីក៏ដោយ។

ដោយឡែក អ្នកសិក្សាច្បាប់មួយចំនួនបានលើកឡើងថា តើហេតុអ្វីការធ្វើអនុប្បទានជាន់គ្នា ជាលក្ខណៈទ្រឹស្តីអាចកើតមានឡើង? នៅពេលដែល A បានលក់ឱ្យ B លើកដំបូងនេះ A បានក្លាយជាបុគ្គលដែលគ្មានសិទ្ធិរួចទៅហើយ ហេតុនេះ នៅនឹងខ្លួនរបស់ A ពុំមានសិទ្ធិដែលត្រូវលក់ទៅឱ្យ C នោះទេ។ ទ្រឹស្តីមួយចំនួនបានពន្យល់បន្ថែមលើចំណុចខាងលើនេះផងដែរ។ នៅក្នុងការសិក្សាបែបទ្រឹស្តី នេះជាចម្ងល់ដែលពិបាកខ្លាំង។ យ៉ាងហោចណាស់ សូមអ្នកទាំងអស់គ្នាចំណាំថា អនុលោមតាមបញ្ញត្តិនៃគោលការណ៍នៃលក្ខខណ្ឌតតាំងគឺមានរចនាសម្ព័ន្ធដូចតទៅនេះ ៖ នៅក្នុងទំនាក់ទំនាងរវាង A និង B គឺ B បានធ្វើលទ្ធកម្មនូវសិទ្ធិស្ថាពរតាំងពីដំណាក់កាលដែលខ្លួនបានទិញពី A ប៉ុន្តែ សិទ្ធិនោះនៅមិនទាន់អាចការពារចំពោះតតិយជនផ្សេងនោះទេ (ក្នុងន័យនេះគឺសិទ្ធិមិនទាន់ពេញលេញ) ហេតុនេះហើយ បើសិនជាមានលេចឡើងនូវបុគ្គល C ដែលបានបំពេញលក្ខខណ្ឌតតាំងនៃសិទ្ធិជាមុន ក្នុងករណីនេះ C អាចអះអាងអំពីការធ្វើលទ្ធកម្មនូវសិទ្ធិចំពោះ B ហើយជាលទ្ធផល B មិនអាចតតាំងចំពោះ C បាន មានន័យថា ការធ្វើលទ្ធកម្មរបស់ B ត្រូវបានបដិសេធ (ជាលទ្ធផល B មិនអាចធ្វើលទ្ធកម្មនូវសិទ្ធិពិតប្រាកដមែន ប៉ុន្តែ បើមើលពីទស្សនៈនៃកិច្ចសន្យា B អាចទាមទារសំណងការខូចខាតនៃការមិនអនុវត្តកាតព្វកិច្ចចំពោះ A បាន។ ⇒ជំពូកទី6 II 2 (2))។

### (4) លក្ខខណ្ឌតតាំងនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើអចលនវត្ថុ

① <u>សញ្ញាណទូទៅ</u>

ចំណុចនេះ ខ្ញុំនឹងពន្យល់លម្អិតបន្តិចអំពីការចុះបញ្ជីដែលជាលក្ខខណ្ឌតតាំងនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើអចលនវត្ថុ។ ក្រមរដ្ឋប្បវេណី មាត្រា177 បញ្ញត្តថា «ការបង្កើត ការផ្ទេរ និង ការកែប្រែសិទ្ធិប្រត្យក្សលើអចលនវត្ថុ មិនអាចតតាំងនឹងតតិយជនបានឡើយ បើសិនជាមិនបានចុះបញ្ជីនៃសិទ្ធិប្រត្យក្សនោះ ដោយអនុលោមតាមបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ ឬ ច្បាប់ទាក់ទងនឹងការចុះបញ្ជីផ្សេងទៀត»។ នេះមានន័យថា ការបង្កើត ការផ្ទេរ និង ការកែប្រែសិទ្ធិប្រត្យក្ស នឹងកើតមានអានុភាពគតិយុត្តតាមរយៈការបង្ហាញឆន្ទៈប៉ុណ្ណោះ ប៉ុន្តែ មិនអាចតតាំងនឹងតតិយជនបាននោះទេ បើសិនជាមិនបានចុះបញ្ជី។ ហេតុនេះ ការចុះបញ្ជីគ្រាន់តែជាមធ្យោបាយដើម្បីតតាំងនឹងតតិយជនប៉ុណ្ណោះ ប៉ុន្តែ សិទ្ធិបានផ្ទេររួចហើយ ទោះបីជាគ្មានការចុះបញ្ជីក៏ដោយ។ ដូច្នេះហើយ ចម្ងល់នឹងអាចកើតឡើងដូចតទៅនេះ ៖ ចំណុចទី① ករណីដែលភាគីមិនចុះបញ្ជីក៏អាចមាន ហើយផ្ទុយមកវិញ ទោះបីជាមានការចុះបញ្ជីក្លែងបន្លំដែលគ្មានការព្រមព្រៀងទាល់តែសោះក៏ដោយ ក៏ការចុះបញ្ជីនោះក្លាយជាមោឃភាព ហើយសិទ្ធិពិតប្រាកដបានផ្ទេរទៅឱ្យបុគ្គលផ្សេង ក៏អាចកើតឡើងផងដែរ។ ចំណុចទី② ហើយបុគ្គលដែលមិនបានចុះបញ្ជី ពុំអាចតតាំងចំពោះ «តតិយជន» បាន តើសំដៅទៅលើតតិយជន (បុគ្គលផ្សេង) គ្រប់ប្រភេទឬយ៉ាងណា?

តែចំណុចនេះប្រហែលជាមិនមានន័យថា មិនអាចតតាំងចំពោះបុគ្គលផ្សេងគ្រប់រូប បើមិនបានចុះបញ្ជីនោះទេ។ ខ្ញុំនឹងរៀបរាប់អំពីចំណុចទាំងនេះនៅខាងក្រោម។

② <u>អានុភាពសន្មត និងអានុភាពនៃជំនឿទុកចិត្តនៃការបង្ហាញជាសាធារណៈនៃការចុះបញ្ជី</u>

ការចុះបញ្ជីគឺជាលក្ខខណ្ឌតតាំងនៃសិទ្ធិប្រត្យក្ស ហើយមិនមែនជាលក្ខខណ្ឌអានុភាពនោះទេ ហេតុនេះហើយ បើទោះបីជាមានការផ្លាស់ប្តូរសិទ្ធិប្រត្យក្សក៏ដោយ ក៏មិនប្រាកដថាមានការចុះបញ្ជីដែរ (ករណីដែលម្ចាស់សិទ្ធិទុកចោលមិនទៅចុះបញ្ជីតែម្តង ក៏អាចមានដែរ។ ប៉ុន្តែ ការធ្វើបែបនេះ ម្ចាស់សិទ្ធិប្រាកដជាចាញ់អនុប្បទានិកថ្មី ឬ ម្ចាស់បំណុលដែលរឹបអូស បើសិនជាមានការធ្វើអនុប្បទានជាន់គ្នា ឬ ការរឹបអូស ជាអាទិ៍)។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ជាទូទៅបើមានការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស ការចុះបញ្ជីក៏ត្រូវធ្វើឡើងដែរ។ ដូចនេះ ការចុះបញ្ជីត្រូវបានទទួលស្គាល់នូវអានុភាពសន្មត ហើយយុត្តិសាស្ត្រតុលាការក៏បានបកស្រាយថា ទំនាក់ទំនងនៃសិទ្ធិដូចមានកត់ត្រានៅក្នុងការចុះបញ្ជីត្រូវសន្មតថាមាន លុះត្រាតែមានភស្តុតាងផ្ទុយពីនេះ (នេះហៅថា **ការសន្មតតាមអង្គហេតុ** ហេតុនេះ ប្រសិនបើអ្នកដែលមានវិវាទអំពីភាពត្រឹមត្រូវចំពោះខ្លឹមសារនៃការចុះបញ្ជី អាចបញ្ជាក់អំពីស្ថានភាពដែលមិនច្បាស់លាស់នៃភាពត្រឹមត្រូវបាន, នោះការសន្មតនឹងត្រូវបាត់បង់)។

ផ្ទុយមកវិញ គេមិនទទួលស្គាល់ អានុភាពនៃជំនឿទុកចិត្តនៃការបង្ហាញជាសាធារណៈ ដោយជឿជាក់ទាំងស្រុងថា បើមានការចុះបញ្ជី គឺមានសិទ្ធិនោះទេ (នៅប្រទេសអាឡឺម៉ង់ដែលបានរៀបរាប់ពីមុន បានទទួលស្គាល់អានុភាពនៃជំនឿទុកចិត្តនៃការបង្ហាញជាសាធារណៈ ដោយសារតែ ប្រទេសនេះប្រកាន់យកគោលការណ៍ថា សិទ្ធិមិនត្រូវបានផ្ទេរបើសិនជាគ្មានការចុះបញ្ជី ហើយជាលទ្ធផល បើមានការចុះបញ្ជី គឺមានសិទ្ធិ។ ខ្ញុំក៏បានរៀបរាប់រួចហើយថា នៅប្រទេសជប៉ុនក៏មានអ្នកដែលគាំទ្រទ្រឹស្តីបែបនេះដែរ)។ ដូចនេះ ទោះបីជាភាគីបានធ្វើប្រតិបត្តិការជំនួញ ដោយជឿជាក់លើការចុះបញ្ជីមិនពិតដែលមិនសមស្របនឹងទំនាក់ទំនងច្បាប់សារជាតុក៏ដោយ ក៏មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិដែលកត់ត្រាក្នុងការចុះបញ្ជីនោះទេ។ ប៉ុន្តែ នៅក្នុងយុត្តិសាស្ត្រតុលាការ ចំពោះករណីមានការចុះបញ្ជីមិនសមស្របនឹងទំនាក់ទំនងច្បាប់សារជាតុ គេបានកែតម្រូវភាពមិនត្រឹមត្រូវនៃចំណុចនេះ ដោយអនុវត្តប្រដូចនូវមាត្រា94 កថាខណ្ឌទី2 **ការបង្ហាញឆន្ទៈមិនពិតដោយឃុបឃិត** (ដើមឡើយ មាត្រានេះមិនត្រូវយកមកអនុវត្តចំពោះករណីនេះទេ ប៉ុន្តែដោយសារមានគោលបំណងដូចគ្នាទើប គេយកមកអនុវត្តប្រដូច) ហើយការពារបុគ្គលដែលបានធ្វើជំនួញនោះ ប្រសិនបើលក្ខខណ្ឌដូចតទៅនេះត្រូវបានបំពេញ៖ ទី1 ម្ចាស់សិទ្ធិមានទំនួលខុសត្រូវក្នុងការទុកចោលការចុះបញ្ជីមិនពិតនោះ និងទី2 បុគ្គលដែលបានធ្វើប្រតិបត្តិការជំនួញដោយជឿជាក់លើការចុះបញ្ជីនោះ ជាបុគ្គលដែលសុចរិត។ នេះមានន័យថា បើសិនជាម្ចាស់សិទ្ធិពិត A បានចុះបញ្ជីផ្ទេរឱ្យ B និងទុកចោលស្ថានភាពនៃការចុះបញ្ជីនោះ ហើយ B បានលក់ទៅឱ្យ C ដែលមិនបានដឹងអំពីស្ថានភាពពិត ក្នុងករណីនេះ ការទុកចោលនូវការចុះបញ្ជីរបស់ម្ចាស់សិទ្ធិ A ត្រូវប្រដូចជា ការបង្ហាញឆន្ទៈមិនពិតដោយឃុបឃិតគ្នារបស់ A និង B ហើយ

តាមរយៈមាត្រា94 កថាខណ្ឌទី2 A មិនអាចតតាំង អំពីមោឃភាពនៃរូបភាពខាងក្រៅដែលជាការចុះបញ្ជីចំពោះ C ដែលសុចរិតបានទេ (C អាចធ្វើលទ្ធកម្មដោយមានអានុភាព)។

③ ការចុះបញ្ជី និង តតិយជន

ប្រសិនបើយើងបកស្រាយថា តតិយជននៅក្នុងមាត្រា177 សំដៅទៅលើតតិយជនគ្រប់រូប លើកលែងតែភាគី និង ប្រតិសិទ្ធិសាកល (សន្តតិជនជាដើម) ក្នុងករណីនេះ បញ្ហាអាចកើតមានឡើងត្រង់ថា ទោះបីជាកម្មសិទ្ធិករពិតប្រាកដ X ក៏មិនអាចទាមទារចំពោះ Y ដែលបានផ្ទេរការចុះបញ្ជីដោយក្លែងបន្លំឯកសារ ឱ្យធ្វើបដិទានការចុះបញ្ជីបានដែរ ដោយសារមូលហេតុថា X គ្មានការចុះបញ្ជី។ ហេតុនេះហើយ អ្នកច្បាប់បានចាប់ផ្ដើមពិចារណាអំពី ការកម្រិតជាក់លាក់ណាមួយចំពោះពាក្យថា «តតិយជន» (ទ្រឹស្ដីកម្រិត)។

នៅក្នុងយុត្តិសាស្ត្រតុលាការបានផ្ដល់សញ្ញាណថា តតិយជនដែលម្ចាស់សិទ្ធិមិនអាចតវ៉ាដោយគ្មានការចុះបញ្ជីបាន គឺជា «បុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវនៃការអះអាងអំពីការមិនចុះបញ្ជី» ដូចជា បុគ្គលដែលបានធ្វើលទ្ធកម្មសិទ្ធិប្រត្យក្សលើអចលនវត្ថុតែមួយ ភតិកៈ និង ម្ចាស់បំណុលនៃការរឹបអូសជាដើម។ ផ្ទុយមកវិញ តតិយជនដែលម្ចាស់សិទ្ធិអាចតវ៉ាបានដោយគ្មានការចុះបញ្ជី (បុគ្គលដែលគ្មានផលប្រយោជន៍ត្រឹមត្រូវនៃការអះអាងអំពីការមិនចុះបញ្ជី) ជាចម្បង គឺជាបុគ្គលដូចខាងក្រោមនេះ។ ①បុគ្គលដែលច្បាប់ស្ដីពីការចុះបញ្ជីអចលនវត្ថុបានកំណត់យ៉ាងច្បាស់ឱ្យដកចេញ : ទី1 បុគ្គលដែលរារាំងការស្នើសុំចុះបញ្ជីដោយឆបោក ឬ ដោយគម្រាមកំហែង (កថាខណ្ឌទី1 មាត្រា5 នៃច្បាប់ស្ដីពីការចុះបញ្ជីអចលនវត្ថុ) និង ទី2 បុគ្គលដែលមានករណីយកិច្ចស្នើសុំចុះបញ្ជីដើម្បីអ្នកដទៃ (អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកជម្រះបញ្ជីក្ស័យធន និង អាណត្តិគាហក ជាអាទិ៍)។ ឧទាហរណ៍ ចំពោះបុគ្គលនៅក្នុងចំណុចទី2 ខាងលើនេះ អាចជាករណីដែល B បានទិញអចលនវត្ថុពី A ប៉ុន្តែ C ដែលជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ B បានចុះបញ្ជីដាក់ឈ្មោះរបស់ខ្លួនឯង ក្នុងករណីនេះ ទោះបីជាគ្មានការចុះបញ្ជីក៏ដោយ ក៏ B អាចតតាំងចំពោះ C បានដែរ។ ②បុគ្គលដែលទុច្ចរិតធ្ងន់ធ្ងរដែលស្របនឹងបញ្ញត្តនៃកថាខណ្ឌទី1 និង កថាខណ្ឌទី2 មាត្រា5 នៃច្បាប់ស្ដីពីការចុះបញ្ជីអចលនវត្ថុ (បុគ្គលដែលដឹងពីស្ថានភាពពិតហើយបានធ្វើជំនួញក្នុងគោលបំណងបំពានដល់ម្ចាស់សិទ្ធិពិតប្រាកដ ដែលមិនត្រូវបានអនុញ្ញាតតាមគោលការណ៍សុចរិត និងស្មោះត្រង់) ពីព្រោះ បុគ្គលដែលគ្រាន់តែទុច្ចរិត (ដឹងអំពីស្ថានភាព) ត្រូវបានអនុញ្ញាតនៅក្នុងទំហំនៃការប្រកួតប្រជែងដោយសេរី។ ការដកចេញបុគ្គលដែលទុច្ចរិតធ្ងន់ធ្ងរនេះ ត្រូវបានកំណត់ស្ថាពររួចហើយនៅក្នុងយុត្តិសាស្ត្រតុលាការ ហើយទ្រឹស្ដីជាច្រើនក៏យល់ស្របផងដែរ។ ③បុគ្គលដែលចូលកាន់កាប់ដោយខុសច្បាប់ និង បុគ្គលដែលប្រព្រឹត្តអំពើអនីត្យានុកូល (យោងជំពូកទី5 អំពើអនីត្យានុកូល) ជាអាទិ៍។

### (5) លក្ខខណ្ឌតតាំងនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើចលនវត្ថុ

① សញ្ញាណទូទៅ

ក្រមរដ្ឋប្បវេណី មាត្រា178 បញ្ញត្តថា «ការធ្វើអនុប្បទានសិទ្ធិប្រត្យក្សលើចលនវត្ថុ មិនអាចតតាំងនឹងតតិយជនបានឡើយ ប្រសិនបើគ្មានការប្រគល់ចលនវត្ថុនោះ» ហេតុនេះ លក្ខខណ្ឌតតាំងនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើចលនវត្ថុ គឺការប្រគល់។ តាមរយៈនេះ ប្រសិនបើ A បានធ្វើកិច្ចសន្យាលក់ Laptop ឱ្យទៅ B ហើយ B បានបង់ប្រាក់ថ្លៃលក់ទិញជាមុនគ្រប់ចំនួនហើយ ប៉ុន្តែ មិនទាន់បានទទួលការប្រគល់ Laptop នោះនៅឡើយទេ។ ក្នុងពេលនោះ A បានធ្វើកិច្ចសន្យាលក់ Laptop ដដែលនោះ ឱ្យទៅ C ហើយបានប្រគល់ Laptop រួចរាល់។ ក្នុងករណីនេះ អ្នកដែលបានបំពេញលក្ខខណ្ឌតតាំងគឺជា C ហើយ B ពុំមានលក្ខខណ្ឌតតាំងនោះទេ ហេតុនេះហើយ គាត់មិនអាចអះអាងចំពោះ C ឱ្យប្រគល់ Laptop មកវិញនោះទេ។ នេះគឺជាបញ្ហានៃការតតាំងចំពោះចលនវត្ថុ (ប្រាកដហើយថា B អាចទាមទារឱ្យ A ដែលជាភាគីម្ខាងទៀតប្រគល់ Laptop ដូចគ្នានោះ បើសិនជា Laptop នោះមានច្រើន និងអាចទាមទារសំណងការខូចខាតជាសាច់ប្រាក់ក៏បាន។ ចំណុចនេះយើងនឹងសិក្សានៅក្នុងនីតិសិទ្ធិលើបំណុល)។

② ចលនវត្ថុដែលជាកម្មវត្ថុនៃមាត្រា178

ចលនវត្ថុតាមក្រមរដ្ឋប្បវេណី សំដៅទៅលើវត្ថុដែលក្រៅពីដី និង វត្ថុ (ពោលគឺ វត្ថុទាំងនោះគឺជាអចលនវត្ថុ) ដែលភ្ជាប់នឹងដី (មាត្រា86 កថាខណ្ឌទី2)។ ប៉ុន្តែ ទោះបីជាចលនវត្ថុក៏ដោយ បើសិនជាវត្ថុនោះមានរបបនៃលក្ខខណ្ឌតតាំងពិសេស និង វត្ថុដែលមានលក្ខណៈមិនអាចយកការប្រគល់ធ្វើជាលក្ខខណ្ឌតតាំងបាននោះទេ, មាត្រា 178 គឺមិនអាចយកមកអនុវត្តបានទេ។ ឧទាហរណ៍ ចំពោះនាវា និង គ្រឿងចក្រសាងសង់ គឺមានប្រព័ន្ធចុះបញ្ជី ហើយចំពោះរថយន្ត និង យន្តហោះ គឺមានប្រព័ន្ធចុះបញ្ជីប័ណ្ណ ហេតុនេះ វត្ថុទាំងអស់នេះបានប្រើប្រាស់លក្ខខណ្ឌតតាំងជាការទទួលបានការចុះបញ្ជី ឬ ការចុះបញ្ជីប័ណ្ណ។ ចលនវត្ថុដែលចំណុះឱ្យអចលនវត្ថុ (ឧបមាថា កន្ទេលជប៉ុន TATAMI និង ទ្វារដែលបានភ្ជាប់ទៅអគារ) ត្រូវមានវាសនារួមជាមួយអចលនវត្ថុនោះ ហេតុនេះ បើសិនជាមានការចុះបញ្ជីផ្ទេរអចលនវត្ថុ ចលនវត្ថុនោះនឹងត្រូវបានបង្ហាញជាសាធារណៈតាមរយៈការចុះបញ្ជីនោះ។

ដោយឡែក ចំពោះប្រាក់ (លុយ) វិញ គឺមានការកំណត់ពិសេសនៅក្នុងច្បាប់ ហើយមិនអាចមើលក្នុងនាមជាចលនវត្ថុនោះទេ (កម្មសិទ្ធិ និង សិទ្ធិកាន់កាប់ត្រូវបញ្ចូលគ្នាតែមួយ ហើយត្រូវបានបកស្រាយថា វាមិនមែនជាកម្មវត្ថុនៃមាត្រា178 នោះទេ)។

③ បែបយ៉ាងនៃការប្រគល់

បើសិនជានិយាយតាមបែបផ្សេង ការប្រគល់សំដៅទៅលើ ស្ថានភាពដែលច្បាប់មើលឃើញថាការកាន់កាប់បានផ្ទេរ។ អ្វីដែលជាបញ្ហាគឺ បែបយ៉ាងនៃការប្រគល់។ ប្រាកដហើយថា ការប្រគល់កម្មវត្ថុជាក់ស្តែងទៅឱ្យភាគីម្ខាងទៀត គឺជាការប្រគល់ (នេះហៅថា **ការប្រគល់ដោយជាក់ស្តែង**។ មាត្រា182 កថាខណ្ឌទី1) ប៉ុន្តែ តាមក្រមរដ្ឋប្បវេ

ណី គឺមានវិធីនៃការផ្ទេរការកាន់កាប់ 3ប្រភេទ ផ្សេងទៀត។ ទី1 គឺជា**ការប្រគល់ដោយសង្ខេប** (មាត្រា182 កថាខណ្ឌទី2)។ ឧទាហរណ៍ B ទិញវត្ថុមួយពី A ដែលខ្លួនបានខ្ចី និងកំពុងតែក្តោបក្តាប់វត្ថុនោះ ក្នុងករណីនេះ ដើមឡើយ B កំពុងតែកាន់កាប់រួចទៅហើយ ហេតុនេះ B ក៏ទទួលបានការប្រគល់តែម្តងទៅ (មិនចាំបាច់សងទៅវិញហើយ ទើបប្រគល់សារជាថ្មីនោះទេ)។ ទី2 គឺហៅថា **ការប្តូរលក្ខណៈនៃការកាន់កាប់** (មាត្រា183) A បានលក់វត្ថុដែលខ្លួនកំពុងក្តោបក្តាប់ទៅឱ្យ B ប៉ុន្តែ A នៅតែបន្តក្តោបក្តាប់វត្ថុនោះដើម្បី B តាមការព្រមព្រៀង។ នៅក្នុងករណីនេះក៏ដោយ ក៏ B បានទទួលការប្រគល់ការកាន់កាប់ដែរ (មានន័យថា នៅក្នុងករណីនេះ B បានធ្វើលទ្ធកម្មការកាន់កាប់ ហើយAកាន់កាប់ដោយតំណាងឱ្យ B។ នៅក្នុងករណីបែបនេះ យើងហៅការកាន់កាប់របស់ B ថា ការកាន់កាប់ដោយប្រយោល)។ ទី3 គឺហៅថា **ការផ្ទេរការកាន់កាប់ដោយបញ្ជា** (មាត្រា184)។ A បានលក់របស់ដែល C កំពុងតែកាន់កាប់ទៅ B ហើយបានបង្គាប់ទៅ C ថា ការកាន់កាប់នៅពេលអនាគត គឺធ្វើឡើងដើម្បី B ហើយ B បានផ្តល់សច្ចានុម័តលើខ្លឹមសារនេះ, ក្នុងករណីនេះ B បានទទួលការកាន់កាប់រួចហើយ (ធ្វើលទ្ធកម្មការកាន់កាប់។ នៅក្នុងករណីនេះផងដែរ B គឺកាន់កាប់ដោយប្រយោល ហើយ C បានកាន់កាប់ដោយផ្ទាល់តំណាងឱ្យ B)។ វិធីប្រគល់ទាំងអស់នេះ មានលក្ខខណ្ឌសមហេតុផល ក្នុងន័យដែលមិនតម្រូវឱ្យប្រគល់ត្រឡប់វិញសិន ហើយទើបប្រគល់ទៅវិញនោះទេ។ ប៉ុន្តែ នៅក្នុងចំណោមការប្រគល់ការកាន់កាប់ទាំងអស់នេះ ការប្តូរលក្ខណៈនៃការកាន់កាប់មានបញ្ហាខ្លាំងជាងគេបំផុត ពីព្រោះ វត្ថុដែលជារបស់ A បានក្លាយជាវត្ថុរបស់ B ហើយ B បានបំពេញលក្ខខណ្ឌតតាំងដែលជាការប្រគល់រួចហើយ ប៉ុន្តែ វត្ថុគឺស្ថិតនៅក្នុងដៃរបស់ A ដែលជាកម្មសិទ្ធិករពីមុនដដែល។ ប៉ុន្តែ យុត្តិសាស្ត្រតុលាការ និង ទ្រឹស្តីទូទៅទទួលស្គាល់ថា ការប្រគល់ដោយប្តូរលក្ខណៈនៃការកាន់កាប់នេះ ជាលក្ខខណ្ឌតតាំងនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សដូចការប្រគល់ដែរ។ ដូច្នេះហើយ ប្រសិនបើ C បានជឿជាក់លើរូបភាពខាងក្រៅនេះ (ជឿជាក់ថា A គឺជាកម្មសិទ្ធិករ) ហើយបានទិញវត្ថុនោះពី A។ ក្នុងករណីនេះ តើ C នឹងទៅជាយ៉ាងណា? ការការពារ C ត្រូវពិចារណានៅក្នុងបញ្ញត្តិអំពីការធ្វើលទ្ធកម្មភ្លាមៗ (លទ្ធកម្មដោយសុចរិត)។ ដោយឡែក ច្បាប់ពិសេសស្តីពីការធ្វើអនុប្បទានសិទ្ធិលើបំណុលនៃចលនវត្ថុក្នុងឆ្នាំ2004 បានបង្កើតប្រព័ន្ធចុះបញ្ជីអនុប្បទានចលនវត្ថុ ហើយបានបញ្ញត្តថា ប្រសិនបើបានចុះបញ្ជីនៅក្នុងកុំព្យូទ័ររបស់មន្ទីរកិច្ចការច្បាប់ អំពីការបានទទួលអនុប្បទាននៃចលនវត្ថុក្នុងករណីនេះ ការចុះបញ្ជីអនុប្បទាននេះ ត្រូវចាត់ទុកថា ជាការប្រគល់ (ពោលគឺ ជាលក្ខខណ្ឌតតាំងដូចការប្រគល់ដែរ។⇒ជំពូកទី7 II 3 ②)។

### (6) ការកាន់កាប់ និង ការធ្វើលទ្ធកម្មដោយសុចរិតលើចលនវត្ថុ

មុននេះ ខ្ញុំបានរៀបរាប់អំពី សិទ្ធិកាន់កាប់រួចហើយ។ ពោលគឺ សិទ្ធិកាន់កាប់សំដៅទៅលើសិទ្ធិដែលត្រូវបានផ្តល់ការការពារជាក់លាក់មួយ ចំពោះស្ថានភាពជាក់ស្តែងដែលបុគ្គលណាមួយកំពុងតែគ្រប់គ្រងលើវត្ថុអ្វីមួយ បើទោះបីជាមិនដឹងថាបុគ្គលនោះពិតជាមានសិទ្ធិប្រត្យក្ស ឬ មិនមានក៏ដោយ។ ក្រមរដ្ឋប្បវេណី មាត្រា188 បញ្ញត្តថា សិទ្ធិដែលអ្នកកាន់កាប់បានអនុវត្តចំពោះវត្ថុកាន់កាប់ ត្រូវសន្មតថាជាសិទ្ធិស្របច្បាប់។ នេះមានន័យថា ប្រសិនបើបុគ្គលណាមួយបានអនុវត្តសិទ្ធិក្នុងនាមជាកម្មសិទ្ធិករនៃវត្ថុណាមួយទៅលើវត្ថុនោះ, ក្នុងករណីនេះ យើងសន្មតជាបណ្តោះ

អាសន្នសិនថា បុគ្គលនោះគឺជាកម្មសិទ្ធិករ។ ប៉ុន្តែ ចំណុចដែលត្រូវប្រុងប្រយ័ត្នត្រង់កន្លែងនេះគឺ ពាក្យថា សន្មតនៃវាក្យសព្ទច្បាប់ សំដៅទៅលើរបស់ដែលអាចតវ៉ា ដោយបញ្ជាក់ភស្តុតាងផ្ទុយបាន (ផ្ទុយមកវិញ «ចាត់ទុក» គឺជាការកំណត់របស់ច្បាប់ថាត្រូវមានន័យបែបនេះ ហេតុនេះ ច្បាប់មិនអនុញ្ញាតឱ្យបញ្ជាក់ភស្តុតាងផ្ទុយនោះទេ។ ⇒ពាក្យគន្លឹះ: សន្មត និង ចាត់ទុក)។ ដូចនេះ បើសិនជាមានបុគ្គលមកអះអាងថាខ្លួនទើបជាកម្មសិទ្ធិករ ហើយបុគ្គលនោះអាចបញ្ជាក់ថាខ្លួនពិតជាកម្មសិទ្ធិករមែន ក្នុងករណីនេះ សិទ្ធិរបស់អ្នកកាន់កាប់នឹងត្រូវបានបដិសេធ។ ទោះជាយ៉ាងណាក៏ដោយ ការកាន់កាប់ត្រូវបានទទួលការការពារកាន់តែខ្លាំង ចំពោះការផ្លាស់ប្តូរសិទ្ធិប្រត្យក្សនៃចលនវត្ថុ។ នេះគឺជា បញ្ញត្តិអំពីការធ្វើលទ្ធកម្មដោយសុចរិត។

ក្រមរដ្ឋប្បវេណីមាត្រា192 បានកំណត់អំពី លទ្ធកម្មដោយសុចរិតថា «តាមរយៈសកម្មភាពជួញដូរ បុគ្គលដែលបានចាប់ផ្តើមកាន់កាប់ចលនវត្ថុដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ត្រូវធ្វើលទ្ធកម្មសិទ្ធិអនុវត្តចំពោះចលនវត្ថុនោះភ្លាមៗ បើសិនជាសុចរិត និង គ្មានកំហុស»។ តើបញ្ញត្តិនេះមានន័យដូចម្តេច? ការជួញដូរចលនវត្ថុគឺត្រូវបានធ្វើឡើងជាប្រចាំថ្ងៃ ហេតុនេះ មានករណីខ្លះ អ្នកទិញមិនបានដឹងថា ខ្លួនបានទិញវត្ថុពីបុគ្គលដែលគ្មានសិទ្ធិចាត់ចែងនោះទេ។ ឧទាហរណ៍ថា អ្នកលក់មិនមែនជាកម្មសិទ្ធិករនៃទំនិញនេះទេ ហើយគ្រាន់តែរក្សាទុកឱ្យកម្មសិទ្ធិករប៉ុណ្ណោះ, ហើយអ្នកលក់នោះបានបន្លំខ្លួនជាកម្មសិទ្ធិករ ហើយលក់ទំនិញនោះទៅបាត់។ ប៉ុន្តែ បើសិនជា អ្នកទិញត្រូវស្រាវជ្រាវថាអ្នកលក់មានសិទ្ធិអំណាចត្រឹមត្រូវក្នុងការលក់គ្រប់តែពេលនោះ, កិច្ចសន្យាលក់ទិញក៏ដោយក៏មិនងាយនឹងកើតមានឡើងនោះទេ។ ហេតុដូច្នេះហើយ នៅក្នុងករណីបែបនេះ យើងមានភាពចាំបាច់ដើម្បីការពារអ្នកទិញដែលបានជឿជាក់រូបភាពខាងក្រៅនៃអ្នកលក់។ ដូចនេះ ក្រមរដ្ឋប្បវេណីបានពិចារណាអំពីសុវត្ថិភាពនៃការជួញដូរ ហើយបញ្ញត្តថា នៅក្នុងករណីចលនវត្ថុ ប្រសិនបើអ្នកទិញបានទិញ និង បានចាប់ផ្តើមកាន់កាប់ដោយសុចរិត («សុចរិត» នៅទីនេះ មិនមែនមានន័យថាដឹងពីស្ថានភាពទេ គឺសំដៅលើការជឿជាក់ភាគីម្ខាងទៀតថាជាអ្នកមានសិទ្ធិត្រឹមត្រូវ), អ្នកទិញត្រូវធ្វើលទ្ធកម្មសិទ្ធិនៅពេលបានទទួលការប្រគល់នោះ (បើការលក់ទិញ គឺកម្មសិទ្ធិ) ទោះបីជា អ្នកលក់មិនមែនជាអ្នកមានសិទ្ធិត្រឹមត្រូវក៏ដោយ។ គោលគំនិតនេះត្រូវបានគេស្គាល់ថា គោលការណ៍នៃការជឿជាក់ជាសាធារណៈ។ គោលការណ៍នេះ ផ្តល់ការការពារដល់បុគ្គលដែលជឿជាក់ ហើយបានទទួលការកាន់កាប់។ ប៉ុន្តែ តាមពិតទៅ គោលការណ៍នៃការជឿជាក់ជាសាធារណៈ សំដៅទៅលើការលះបង់តែម្ខាងនូវសិទ្ធិរបស់ភាគីអ្នកមានសិទ្ធិ (ទោះបីជាមាន ឬ គ្មានកំហុសរបស់បុគ្គលនោះក៏ដោយ) ហើយវាមានលក្ខណៈជាវិធានលំអៀងក្នុងបរិបទខ្លះ។ ហេតុនេះ នៅក្នុងក្រមរដ្ឋប្បវេណីបានទទួលស្គាល់យ៉ាងច្បាស់តែក្នុងបញ្ញត្តិនេះប៉ុណ្ណោះ។

ដោយឡែក នៅក្នុងមាត្រា192 មានករណីលើកលែង ពីព្រោះ ការកំណត់ថាកម្មសិទ្ធិករដើមត្រូវបាត់បង់នូវសិទ្ធិតែម្តងចំពោះករណីវត្ថុលួច ឬ វត្ថុបាត់ គឺមានលក្ខណៈជ្រុលពេក ហេតុនេះ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់អាចទាមទារឱ្យសងវិញចំពោះអ្នកកាន់កាប់បាន ក្នុងអំឡុងពេល 2ឆ្នាំ គិតចាប់ពីពេលលួច ឬ ពេលបាត់វត្ថុនោះ (មាត្រា193)។

## 3. **កម្មសិទ្ធិ**

### (1) អត្ថន័យ និង ខ្លឹមសារនៃកម្មសិទ្ធិ

កម្មសិទ្ធិ គឺជាសិទ្ធិដែលម្ចាស់សិទ្ធិអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជារបស់ខ្លួនដោយសេរី នៅក្នុងទំហំដែលច្បាប់បានកម្រិត (មាត្រា206)។ ការប្រើប្រាស់ គឺជាការប្រើវត្ថុនោះដោយខ្លួនឯង។ ការអាស្រ័យផល គឺជាការយកជាកម្មសិទ្ធិរបស់ខ្លួននូវផលដែលកើតចេញពីវត្ថុ។ ការជួលវត្ថុជាកម្មសិទ្ធិឱ្យអ្នកដទៃ ហើយយកថ្លៃឈ្នួល (ផលស៊ីវិល) ក៏ជាការអាស្រ័យផលផងដែរ។ នៅក្នុងការចាត់ចែង រួមមានការចាត់ចែងលក្ខណៈរូបធាតុនៃវត្ថុ (ការប្រើអស់ ការកែច្នៃ ការបំផ្លាញ និង ការបោះបង់ចោលជាអាទិ៍) និង ការចាត់ចែងលក្ខណៈគតិយុត្តនៃវត្ថុ (អនុប្បទាន និង ការបង្កើតសិទ្ធិប្រើប្រាស់អាស្រ័យផល ឬ សិទ្ធិប្រាតិភោគប្រត្យក្ស ជាអាទិ៍)។

កម្មសិទ្ធិគឺជាសិទ្ធិប្រត្យក្សដែលមានលក្ខណៈពេញលេញ ហើយអាចបែងចែកផ្នែកខ្លះនៃលក្ខណៈនោះទៅបង្កើតជាសិទ្ធិលើដីដែលជាសិទ្ធិប្រត្យក្សប្រើប្រាស់ អាស្រ័យផល និង ហ៊ីប៉ូតែកដែលជាសិទ្ធិប្រាតិភោគប្រត្យក្ស ទៅឱ្យបុគ្គលផ្សេងបាន។ ប្រាកដហើយ បើសិនជាអំឡុងពេលនៃសិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផលដែលបានផ្ដល់ឱ្យបុគ្គលផ្សេងបានបញ្ចប់ ឬ សិទ្ធិប្រាតិភោគប្រត្យក្សបានរលត់ ដោយសារការសងកាតព្វកិច្ចដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស នោះកម្មសិទ្ធិ នឹងត្រូវត្រឡប់មកមានលក្ខណៈពេញលេញដូចស្ថានភាពដើមវិញ។

កម្មសិទ្ធិនៃដី ត្រូវមានអានុភាពទាំងផ្នែកលើដី និង ផ្នែកក្រោមដី នៅក្នុងទំហំនៃការកម្រិតរបស់ច្បាប់ (មាត្រា207)។ ដូចនេះ ការអូសខ្សែអគ្គិសនីនៅផ្នែកខាងលើដី និង ការជីកផ្លូវក្រោមដីជាដើម ត្រូវមានការយល់ព្រមពីកម្មសិទ្ធិករនៃដី ហើយបើគ្មានការយល់ព្រមទេ សកម្មភាពទាំងអស់នេះនឹងក្លាយជាកម្មវត្ថុនៃការទាមទារឱ្យបញ្ឈប់ការរារាំង។ ប៉ុន្តែ «ផ្នែកលើ និង ផ្នែកក្រោម»នេះ ត្រូវមានកម្រិតតាមការសមហេតុផល។ ឧទាហរណ៍ យន្តហោះដែលហោះខ្ពស់នៅលើមេឃមិនមានការបំពានដល់កម្មសិទ្ធិនៃដីនោះទេ។

### (2) ទំនាក់ទំនងដីជាប់គ្នា

លើសពីនេះ ដីតែងតែនៅជាប់ជាមួយនឹងដីរបស់អ្នកដទៃ ហេតុនេះ វាត្រូវមានលក្ខណៈពិសេសនៃកម្មសិទ្ធិលើដីវាងគ្នា ដើម្បីកំណត់អំពីវិធានជាក់លាក់។ នេះហៅថា ទំនាក់ទំនងនៃដីជាប់គ្នា ហើយក្រមរដ្ឋប្បវេណីកំណត់លម្អិតចាប់ពីមាត្រា209។ ឧទាហរណ៍នៃបញ្ញត្តិនេះមានដូចជា បញ្ញត្តិអំពី ដីដែលត្រូវបានហ៊ុំព័ទ្ធដោយដីរបស់អ្នកដទៃ ហើយមិនជាប់ទៅនឹងផ្លូវសាធារណៈនោះទេ (នៅមុនពេលវិសោធនកម្មក្រមរដ្ឋប្បវេណីឆ្នាំ2004 ដីប្រភេទនេះហៅថា «ដីបិទជិត») ក្នុងករណីនេះ កម្មសិទ្ធិករនៃដីនោះមានសិទ្ធិឆ្លងកាត់ដីដែលហ៊ុំព័ទ្ធ ដើម្បីទៅដល់ផ្លូវសាធារណៈបាន (មាត្រា210 កថាខណ្ឌទី1) និង បញ្ញត្តិអំពី ការហាមឃាត់មិនឱ្យកម្មសិទ្ធិករនៃដីទប់ទឹកដែលហូរឆ្លងកាត់តាមធម្មជាតិ (មិនមែនការបង្ហូរទឹកសិប្បនិម្មិតទេ) ពីដីជាប់គ្នា (មាត្រា214) ជាអាទិ៍។ សូមរំលងអំពីការពន្យល់លម្អិតនៅកន្លែងនេះ។

### (3) លទ្ធកម្មកម្មសិទ្ធិ

① ទ្រឹស្តីជាមូលដ្ឋាន

វិធីនៃការធ្វើលទ្ធកម្មកម្មសិទ្ធិជាទូទៅ គឺការធ្វើលទ្ធកម្មតាមរយៈកិច្ចសន្យា (លក់ទិញ និង ប្រទានកម្ម ជាអាទិ៍) និង លទ្ធកម្មតាមសន្តតិកម្ម (ស្នងបន្តសិទ្ធិពីកម្មសិទ្ធិករដើម) ហើយក្រៅពីនេះ ក្រមរដ្ឋប្បវេណីមានកំណត់អំពីវិធីធ្វើលទ្ធកម្មតាំងពីដំបូង ដែលមានបញ្ញត្តិចាប់ពីមាត្រា239។ ការកាន់កាប់មុន ការរើសបាន ការរកឃើញ និង ឧបាគមន៍។ នៅក្នុងចំណោមនេះ ការកាន់កាប់មុន ការរើសបាន និង ការរកឃើញ គឺជាករណីលើកលែង ប៉ុន្តែបញ្ហានៃការភ្ជាប់លើអចលនវត្ថុដែលជាផ្នែកមួយនៃឧបាគមន៍នេះ គឺមានសារៈសំខាន់ខ្លាំង។ ក្រៅពីនេះ កម្មសិទ្ធិក៏អាចត្រូវបានធ្វើលទ្ធកម្មតាំងពីដំបូង ដោយអាជ្ញាយុកាលដែរ (ប៉ុន្តែ កម្មសិទ្ធិមិនមានអាជ្ញាយុកាលនៃការរលត់នោះទេ។ ទោះបីជាទុកចោលដីរបស់ខ្លួនរយៈពេលច្រើនឆ្នាំក៏ដោយ ក៏កម្មសិទ្ធិមិនមានអាជ្ញាយុកាលនៃការរលត់ឡើយ។ ដោយឡែក បើសិនជាបុគ្គលផ្សេងបានកាន់កាប់ដីនោះជាច្រើនឆ្នាំក្នុងនាមជាដីរបស់ខ្លួន ហើយនៅតែបន្តកាន់កាប់ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដូចនេះ អាជ្ញាយុកាលនៃលទ្ធកម្មត្រូវស្ថាពរ ហើយក្នុងករណីនេះ កម្មសិទ្ធិករដើមនឹងបាត់បង់សិទ្ធិរបស់ខ្លួន (⇒ជំពូកទី2 III 7 (1))។

② ការកាន់កាប់មុននូវវត្ថុគ្មានម្ចាស់

ឧទាហរណ៍ បុគ្គលដែលបានកាន់កាប់ ដោយមានឆន្ទៈយកជាកម្មសិទ្ធិលើចលវត្ថុដែលគ្មានកម្មសិទ្ធិករ (គ្មានម្ចាស់) ដូចជាករណីចាប់បានសត្វព្រៃជាដើម អាចធ្វើលទ្ធកម្មកម្មសិទ្ធិលើសត្វនោះបាន (មាត្រា239 កថាខណ្ឌទី1)។ ចលនវត្ថុដែលកម្មសិទ្ធិករបានបោះបង់ចោល (ពោលគឺ បោះចោលដោយមានឆន្ទៈបោះបង់កម្មសិទ្ធិ) ក៏ជាកម្មវត្ថុនៃការកាន់កាប់មុននូវវត្ថុគ្មានម្ចាស់ដែរ។ ផ្ទុយមកវិញ អចលនវត្ថុដែលគ្មានម្ចាស់នឹងក្លាយជារបស់រដ្ឋ (ក្លាយជាកម្មសិទ្ធិរបស់រដ្ឋ។ មាត្រា239 កថាខណ្ឌទី2)។ ឧទាហរណ៍ បុគ្គលដែលគ្មានសាច់ញាតិបានស្លាប់ ហើយគ្មានទាំងសន្តតិជន និង អ្នកមើលថែទាំពេលនៅរស់នោះទេ ក្នុងករណីនេះ អចលនវត្ថុដែលជាកម្មសិទ្ធិរបស់បុគ្គលនោះត្រូវក្លាយជារបស់រដ្ឋ។

③ ការរើសបានវត្ថុបាត់

ចំពោះវត្ថុបាត់ នៅក្រោយពេលអ្នករើសបាន (វត្ថុជ្រុះ, វត្ថុភ្លេច) បានយកទៅប្រគល់នៅប៉ុស្តិ៍នគរបាល ហើយប៉ុស្តិ៍នគរបាលបានប្រកាសជាសាធារណៈដើម្បីស្វែងរកម្ចាស់រួចហើយ (ច្បាប់ស្តីពីវត្ថុបាត់មាត្រា1, មាត្រា10) ប៉ុន្តែមិនអាចស្វែងរកឃើញម្ចាស់ពិតប្រាកដក្នុងរយៈពេល 3ខែ គិតចាប់ពីពេលប្រកាស ក្នុងករណីនេះ អ្នករើសបាននឹងធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ (មាត្រា240)។ ចំណុចដែលត្រូវប្រុងប្រយ័ត្នគឺ វត្ថុដែលបុគ្គលដទៃភ្លេច និង របស់ដែលបានរត់ចេញពីផ្ទះ (សត្វដែលបុគ្គលដទៃចិញ្ចឹម) ត្រូវកំណត់ជា វត្ថុបាត់ (ច្បាប់ស្តីពីវត្ថុបាត់ មាត្រា12)។

ហើយវត្ថុនេះ កម្មសិទ្ធិករមិនបានបោះបង់កម្មសិទ្ធិនោះទេ ហេតុនេះ វាមិនអាចក្លាយជាករណីការកាន់កាប់មុននូវវត្ថុគ្មានម្ចាស់នោះទេ (ដូចនេះ ទូរទស្សន៍ដែលគេបោះចោលនៅកន្លែងចាក់សម្រាមគឺជាការបោះបង់កម្មសិទ្ធិយ៉ាងច្បាស់ក្រឡែត ហេតុនេះយើងអាចយកបានដោយឯកឯង ប៉ុន្តែ កង់ដែលទុកចោលនៅតាមផ្លូវវិញ យើងមិនអាចយកជិះដោយឯកឯងនោះទេ។ នេះគឺជាបទល្មើសចាប់យកវត្ថុចេញពីការកាន់កាប់របស់អ្នកដទៃ។ ក្រមព្រហ្មទណ្ឌ មាត្រា254)។

④ <u>ការរកឃើញកំណប់</u>

ឧទាហរណ៍ ចំពោះការរកឃើញកាក់មាសជំនាន់មុនពីក្នុងដីរបស់ខ្លួនក៏ដោយ ក៏ករណីនេះត្រូវយកមកអនុវត្តដូចគ្នានឹងករណីរើសបានវត្ថុបាត់ (ហេតុនេះហើយ ត្រូវប្រកាសជាសាធារណៈ ហើយបើសិនជាគ្មានកម្មសិទ្ធិករបង្ហាញខ្លួនទេ ត្រូវក្លាយជាកម្មសិទ្ធិរបស់ខ្លួន)។ ប៉ុន្តែ បើសិនជារកឃើញកំណប់ចេញពីដីរបស់អ្នកដទៃវិញ កម្មសិទ្ធិករនៃដីនោះ និង អ្នករកឃើញត្រូវចែកពាក់កណ្ដាលម្នាក់ ហើយធ្វើលទ្ធកម្មកម្មសិទ្ធិលើកំណប់នោះ (មាត្រា241។ ច្បាប់ស្ដីពីវត្ថុបាត់ មាត្រា13)។

⑤ <u>ឧបាគមន៍</u>

វត្ថុចាប់ពី 2 ឡើងទៅ (ដែលមានកម្មសិទ្ធិករខុសគ្នា) បានរួមគ្នា ឬ ជាប់គ្នា ហើយជាលទ្ធផល ការធ្វើឱ្យមកស្ថានភាពដើមវិញ មានភាពលំបាកយ៉ាងខ្លាំង ឬ ចាំបាច់ត្រូវកំទេចដើម្បីបំបែកជាដើម ក្នុងករណីនេះ ក្រមរដ្ឋប្បវេណីកំណត់ថា វត្ថុដែលបានរួមគ្នា ឬ ជាប់គ្នានោះ គឺជាវត្ថុតែមួយ (ចាប់ពីមាត្រា243)។ ពីព្រោះ ការបំបែក ឬ ស្ដារស្ថានភាពដើមដោយបង្ខំ នឹងធ្វើឱ្យបាត់បង់ផលប្រយោជន៍សេដ្ឋកិច្ចសង្គម។ នេះហៅថា ឧបាគមន៍។ ករណីរួមគ្នានៃវត្ថុ គឺជា ការភ្ជាប់គ្នា (វត្ថុភ្ជាប់គ្នា), ករណីចម្រុះចូលគ្នា គឺជា ការលាយ (វត្ថុលាយចូលគ្នា), ហើយករណីយកវត្ថុជាតុដើមអ្នកដទៃមកធ្វើចេញជាវត្ថុប្រភេទផ្សេងដោយកម្លាំងរបស់ខ្លួន គឺជាការកែច្នៃ (វត្ថុកែច្នៃ)។ ហេតុនេះ យើងអាចនិយាយបានថា នៅក្នុងឧបាគមន៍បែងចែកជា 3 គឺ ការភ្ជាប់គ្នា ការលាយចូលគ្នា និង ការកែច្នៃ។ នៅក្នុងនោះ ការភ្ជាប់ទៅនឹងអចលនវត្ថុមានបញ្ហាច្រើនជាងគេ។

នៅក្នុងគោលគំនិតដើមនៃការភ្ជាប់គ្នានៃចលនវត្ថុគឺ វត្ថុចាប់ពី 2 ឡើងទៅបានភ្ជាប់គ្នាហើយមិនអាចបំបែកបានដោយមិនធ្វើឱ្យខូចខាតនោះទេ ក្នុងករណីនេះ កម្មសិទ្ធិនឹងធ្លាក់ទៅលើកម្មសិទ្ធិករនៃវត្ថុដែលជាចំណែកចម្បង (មាត្រា243។ ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលត្រូវចំណាយសោហ៊ុយហួសហេតុដើម្បីបំបែក)។ នេះមានន័យថា កម្មសិទ្ធិករលើចលនវត្ថុដែលជាចំណែកបន្ទាប់បន្សំមិនអាចទាមទារឱ្យប្រគល់វិញនោះទេ (ប៉ុន្តែ វាមិនសមរម្យនោះទេ បើសិនជាឱ្យកម្មសិទ្ធិករលើវត្ថុដែលជាចំណែកចម្បងធ្វើលទ្ធកម្មតែម្ខាងនោះ ហេតុនេះ កម្មសិទ្ធិករលើវត្ថុនៃចំណែកបន្ទាប់បន្សំដែលបានបាត់បង់កម្មសិទ្ធិនោះ អាចទាមទារប្រាក់សំណងដោយផ្អែកលើបញ្ញត្តិស្ដីពីសេចក្ដីចម្រើនឥតហេតុ ចំពោះកម្មសិទ្ធិករលើវត្ថុដែលជាចំណែកចម្បងបាន បើសិនជាមានការខូចខាត។ មាត្រា248។

យើងនឹងសិក្សាអំពី សេចក្តីចម្រើនឥតហេតុ នៅក្នុងជំពូកទី5)។ ប្រសិនបើមិនអាចបែងចែកចំណែកចម្បង ឬ ចំណែកបន្ទាប់បន្សំនោះទេ កម្មសិទ្ធិករនៃចលនវត្ថុនីមួយៗ មានកម្មសិទ្ធិអវិភាគទៅលើវត្ថុភ្ជាប់នោះ ទៅតាមសមាមាត្រនៃតម្លៃវត្ថុនោះនៅពេលភ្ជាប់គ្នា (មាត្រា244។ ចំពោះកម្មសិទ្ធិអវិភាគនឹងមានពន្យល់នៅផ្នែកខាងក្រោយ)។ ចំពោះការលាយចូលគ្នា (ឧទាហរណ៍ ប្រេងសាំងដែលជាកម្មសិទ្ធិរបស់បុគ្គល 2នាក់ បានចាក់បញ្ចូលគ្នា) ត្រូវអនុវត្តដូចគ្នានូវបញ្ញត្តិស្តីពីការភ្ជាប់គ្នា (មាត្រា245)។

ចំពោះការកែច្នៃវិញ ទោះបីជាបុគ្គលមួយបានកែច្នៃលើចលនវត្ថុរបស់អ្នកដទៃក៏ដោយ ជាគោលការណ៍ កម្មសិទ្ធិលើវត្ថុកែច្នៃនោះធ្លាក់ទៅលើកម្មសិទ្ធិករនៃវត្ថុធាតុដើម។ ប៉ុន្តែ ប្រសិនបើតម្លៃកើនឡើងដោយសារការកែច្នៃនេះលើសពីតម្លៃវត្ថុធាតុដើមយ៉ាងខ្លាំង អ្នកកែច្នៃអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ (មាត្រា246 កថាខណ្ឌទី1។ នៅក្នុងករណីនេះក៏ដោយ ក៏កម្មសិទ្ធិករនៃវត្ថុធាតុដើមដែលបានបាត់បង់កម្មសិទ្ធិនោះ អាចទាមទារប្រាក់សំណងដោយផ្អែកលើមាត្រា248 បាន)។

### ⑥ ការភ្ជាប់អចលនវត្ថុ

មាត្រា242 បញ្ញត្តថា កម្មសិទ្ធិករនៃអចលនវត្ថុធ្វើលទ្ធកម្មកម្មសិទ្ធិលើ «វត្ថុដែលបានភ្ជាប់ជាចំណុះឱ្យអចលនវត្ថុនោះ» ហើយបញ្ញត្តិដដែល វាក្យខណ្ឌទី2 បញ្ញត្តថា «ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងដល់សិទ្ធិរបស់បុគ្គលដទៃដែលបានភ្ជាប់វត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តឡើយ»។ ឧទាហរណ៍ថា បុគ្គលដទៃបានយកដើមឈើទៅដាំ និង ដុះឬសនៅលើដីរបស់អ្នក ក្នុងករណីនេះ កម្មសិទ្ធិនៅលើដើមឈើនោះ គឺជាកម្មសិទ្ធិករនៅលើដី។ ប៉ុន្តែ បើសិនជាបុគ្គលដទៃនោះ គឺជាភតិកៈត្រឹមត្រូវនៅលើដីនោះវិញ (ពីព្រោះ ភតិកៈមានសិទ្ធិប្រើប្រាស់ដីដោយសេរី) ភតិកៈមានកម្មសិទ្ធិនៅលើដើមឈើនោះ។

ប៉ុន្តែ ចំណុចដែលត្រូវប្រុងប្រយ័ត្ន គឺប្រទេសជប៉ុនបានចាត់ទុកថា ដី និង អគារនៅលើដីនោះគឺជាអចលនវត្ថុផ្សេងគ្នាជាដរាប ហេតុនេះហើយ ចំពោះទំនាក់ទំនងរវាងដី និង អគារវិញ គឺមាត្រា242 មិនយកមកអនុវត្តនោះទេ។ ដូចនេះ ឧទាហរណ៍នៃមាត្រា242 មានដូចជា វត្ថុដែលគេយកមកបិតភ្ជាប់ទៅនឹងអគារ ហើយមិនអាចដកចេញពីអគារបាន ឬ ការចាក់ខ្សាច់ទៅលើដីនៅមាត់សមុទ្រជាដើម។ ប៉ុន្តែ បញ្ហាលំបាក គឺករណីដែលគេជួលជុលកែលំអអគារដោយឯកឯង។ បើសិនជាគេយកស៊ុមរបស់បង្អួចទៅភ្ជាប់នឹងអគារដើម យើងអាចមើលឃើញយ៉ាងច្បាស់ថា វាជាការភ្ជាប់ចលនវត្ថុដែលជាវត្ថុធាតុដើមនៃស៊ុមបង្អួចទៅនឹងអគារ។ ប៉ុន្តែ ទោះបីជាផ្នែកដែលបានកែលំអនោះបានប្រើប្រាស់ជញ្ជាំងនៃអគារដើមក៏ដោយ ក៏ផ្នែកដែលកែលំអនោះ អាចមើលឃើញថាជាអគារឯករាជ្យផងដែរ។ ក្នុងករណីនេះ យើងនៅមានបញ្ហាថា តើវាជាការភ្ជាប់អគារ (អចលនវត្ថុ) ទៅនឹងអគារ (អចលនវត្ថុ) ដែរឬទេ? ហើយបញ្ហានេះ មានការខ្វែងគំនិតគ្នា។

### (4) កម្មសិទ្ធិអវិភាគ

កន្លងមក ខ្ញុំបានបកស្រាយថា នៅលើចលនវត្ថុតែមួយអាចបង្កើតសិទ្ធិប្រត្យក្សដូចគ្នាតែមួយប៉ុណ្ណោះ (គោលការណ៍វត្ថុមួយសិទ្ធិមួយ)។ ឧទាហរណ៍ បើសិនជា A មានកម្មសិទ្ធិលើដី «ក» A អាចបង្កើតសិទ្ធិប្រើប្រាស់ដី និងហ៊ីប៉ូតែកនៃដីនោះឱ្យទៅ B បាន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មិនអាចមានករណី C មានកម្មសិទ្ធិផ្សេងលើដី «ក» ដូចគ្នាក្រៅពី A នោះទេ។ ប៉ុន្តែ A អាចមានកម្មសិទ្ធិ (មួយ) រួមគ្នាជាមួយបុគ្គលដទៃនៅលើដី «ក» បាន។ នេះហៅថា កម្មសិទ្ធិអវិភាគ។ ក្រមរដ្ឋប្បវេណីបញ្ញត្តថា កម្មសិទ្ធិករអវិភាគម្នាក់ៗ អាចប្រើប្រាស់វត្ថុអវិភាគទាំងមូលតាមសមាមាត្រនៃចំណែករបស់ខ្លួនបាន (មាត្រា249)។ ចំណែកអវិភាគអាចសម្រេចបានតាមការព្រមព្រៀងរបស់កម្មសិទ្ធិករអវិភាគ ប៉ុន្តែ បើសិនជាគ្មានការសម្រេចទេ ត្រូវសន្មតថា កម្មសិទ្ធិករអវិភាគម្នាក់ៗមានចំណែកស្មើៗគ្នា (មាត្រា250)។ បើសិនជាចុះបញ្ជីកម្មសិទ្ធិអវិភាគលើអចលនវត្ថុ ចំណែកអវិភាគម្នាក់ៗត្រូវតែកត់ត្រាចូល (ច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ មាត្រា59 ចំណុចទី4)។ ទោះបីជាបែបនេះក៏ដោយ តាមច្បាប់ កម្មសិទ្ធិករអវិភាគម្នាក់ៗអាចប្រើប្រាស់វត្ថុអវិភាគទាំងមូល ហេតុនេះមិនមែនមានន័យថា បើយើងមានចំណែក 1 ភាគ 10 ហើយយើងអាចប្រើប្រាស់បានតែទំហំ 1 ភាគ 10 នៃផ្ទៃក្រឡាដីនោះទេ។ ប៉ុន្តែ បើសិនជាកម្មសិទ្ធិករអវិភាគម្នាក់ៗបានព្រមព្រៀងគ្នាអំពីការបែងចែកការប្រើប្រាស់វត្ថុអវិភាគ ដូចនេះ ការប្រើប្រាស់ត្រូវអនុលោមតាមការព្រមព្រៀងនោះ។

កម្មសិទ្ធិករអវិភាគម្នាក់ៗ អាចទាមទារឱ្យបែងចែកវត្ថុអវិភាគ ចំពោះកម្មសិទ្ធិករអវិភាគផ្សេងទៀតនៅពេលណាក៏បាន ប៉ុន្តែកម្មសិទ្ធិអវិភាគម្នាក់ៗអាចធ្វើកិច្ចសន្យាហាមមិនឱ្យទាមទារបែងចែកវត្ថុអវិភាគដែលមានរយៈពេលមិនលើសពី 5ឆ្នាំបាន (មាត្រា256 កថាខណ្ឌទី1)។

ដោយឡែក អ្នកសិក្សាច្បាប់លើកឡើងថា នៅក្នុងទ្រឹស្តីទូលាយនៃគោលគំនិតសហកម្មសិទ្ធិ ក្រៅពីកម្មសិទ្ធិអវិភាគក្នុងន័យចង្អៀតនេះក៏មាន វត្ថុសមូហភាព និង វត្ថុសាធារណៈដែរ។ វត្ថុសមូហភាព សំដៅទៅលើទំនាក់ទំនងទ្រព្យសម្បត្តិក្រុមហ៊ុនដែលយើងនឹងសិក្សានៅខាងមុខ (⇒ជំពូកទី4 III.9)។ វត្ថុនេះមានការកំណត់ដោយក្រុមហ៊ុននូវគោលបំណងជាក់លាក់នៃការប្រើប្រាស់ ហេតុនេះហើយ យើងអាចនិយាយបានថា វាមានចំណុចខុសគ្នានឹងកម្មសិទ្ធិអវិភាគដូចជា ការចាត់ចែងវត្ថុនោះត្រូវបានកម្រិត ហើយការទាមទារឱ្យបែងចែកកម្មវត្ថុនោះក៏ត្រូវបានហាមឃាត់ ជាអាទិ៍ (មាត្រា676)។ វត្ថុសាធារណៈ សំដៅទៅលើទំនាក់ទំនងទ្រព្យសម្បត្តិសាធារណៈដែលមានសមាជិកជាអ្នកភូមិមួយក្រុម ឬ មួយតំបន់ អាចប្រើប្រាស់រួមគ្នានូវធនធានព្រៃឈើ ភ្នំ និង ទីវាល។ ក្នុងករណីនេះ វាគឺជាការប្រើប្រាស់នូវទ្រព្យសម្បត្តិសាធារណៈរួមគ្នាក្រោមការគ្រប់គ្រងរបស់គណកម្មការភូមិ ឬ តំបន់ ហេតុនេះ សមាជិកម្នាក់ៗ មិនអាចមានចំណែកដោយឡែក ឬ ការទាមទារឱ្យបែងចែកនោះទេ។

ខ្ញុំសូមបញ្ជាក់អំពី ការហៅពាក្យបច្ចេកទេស ចំពោះស្ថានភាពអវិភាគលើសិទ្ធិនៃទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ (សិទ្ធិលើដី និង សិទ្ធិជួលជាដើម) ហៅថា **ឧបកម្មសិទ្ធិអវិភាគ**។

**(5) អគារសហកម្មសិទ្ធិ**

នៅក្នុងអគារលំនៅឋានរួម ដូចជា អគារខុនដូ ជាដើម គឺមានកម្មសិទ្ធិឯករាជ្យជាច្រើនតាមបន្ទប់នីមួយៗ នៅក្នុងអគារតែមួយ។ នេះហៅថា សហកម្មសិទ្ធិ ហើយចំណុចនេះ មានបញ្ញត្តិនៅក្នុង «ច្បាប់ស្តីពីអគារសហកម្មសិទ្ធិ» (ហៅកាត់ថា«ច្បាប់សហកម្មសិទ្ធិ»។ ចូលជាធរមានឆ្នាំ1962 និង វិសោធនកម្មទ្រង់ទ្រាយធំឆ្នាំ1983)។

នៅក្នុងច្បាប់សហកម្មសិទ្ធិនេះបានបែងចែកអគារសហកម្មសិទ្ធិនេះទៅជា **ចំណែកឯកជន** (បន្ទប់នីមួយៗដែលក្លាយជាកម្មវត្ថុនៃកម្មសិទ្ធិឯករាជ្យ ជាអាទិ៍), និង **ចំណែករួម** ដែលត្រូវប្រើប្រាស់រួមដោយសហកម្មសិទ្ធិករ, ហើយសិទ្ធិប្រើប្រាស់ដី (ករណីភាគច្រើនគឺកម្មសិទ្ធិ ប៉ុន្តែក៏អាចមានករណីសិទ្ធិលើដី និង សិទ្ធិជួលផងដែរ។ សហកម្មសិទ្ធិករម្នាក់ៗមានសិទ្ធិអវិភាគ ឬឧបកម្មសិទ្ធិអវិភាគទៅតាមភាគរយនៃចំណែកឯកជន) ដែលបានសាងសង់អគារសហកម្មសិទ្ធិនោះចាត់ទុកជាផ្នែកតែមួយនឹងចំណែកឯកជន (សហកម្មសិទ្ធិករ មិនអាចកាត់ផ្តាច់សិទ្ធិនៃចំណែកឯកជន និង សិទ្ធិប្រើប្រាស់ដី ហើយធ្វើការចាត់ចែងទេ)។ ដើម្បីធានានូវស្វ័យភាពរបស់សហកម្មសិទ្ធិករគ្រប់រូប គេបានរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រង ហើយគណៈកម្មការនេះត្រូវដំណើរការតាមឆន្ទៈរួមរបស់សហកម្មសិទ្ធិករដែលជាសមាជិក ហើយក៏មានកំណត់អំពីបទបញ្ញានិងវិធីសម្រេចរួមដែរ។

## 4. សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផលក្រៅពីកម្មសិទ្ធិ

**(1) សិទ្ធិលើដី**

សិទ្ធិលើដី គឺជាសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ ដើម្បីយកជាកម្មសិទ្ធិនូវសំណង់នានា និង រុក្ខជាតិផ្សេងៗ នៅលើដីរបស់អ្នកដទៃនោះ (មាត្រា265)។ សំណង់សំដៅទៅលើអគារជាអាទិ៍ ហើយសិទ្ធិលើដីនេះផ្តោតសំខាន់ទៅលើសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ ហេតុនេះ ច្បាប់មិនកម្រិតត្រឹមតែជាកម្មសិទ្ធិលើសំណង់ ឬ រុក្ខជាតិនោះទេ ហើយក៏មិនចាំបាច់ទាល់តែនៅលើដីដោយផ្ទាល់នោះទេ។ ជាទូទៅ សិទ្ធិនេះកើតឡើងតាមរយៈការចុះកិច្ចសន្យាបង្កើតសិទ្ធិលើដីរវាងកម្មសិទ្ធិករ និង អ្នកប្រើប្រាស់ ប៉ុន្តែ ក៏អាចមានការធ្វើលទ្ធកម្មតាមរយៈមតកសាសន៍ និង អាជ្ញាយុកាលនៃលទ្ធកម្មផងដែរ។

សិទ្ធិលើដីមានភាពស្រដៀងគ្នាទៅនឹងសិទ្ធិជួល (នៅក្នុងច្បាប់ស្តីពីការជួលដីជួលផ្ទះ បានហៅសិទ្ធិលើដីដែលមានគោលបំណងយកកម្មសិទ្ធិលើអគារ និង សិទ្ធិជួលអចលនវត្ថុ រួមគ្នាថាជា សិទ្ធិជួលដី)។ ប៉ុន្តែ បើសិនជាយើងនិយាយអំពីចំណុចខុសគ្នាគឺ សិទ្ធិលើដីគឺជាសិទ្ធិប្រត្យក្ស ហេតុនេះ វាជាសិទ្ធិដែលប្រើប្រាស់ដោយផ្ទាល់ចំពោះដីដែលជាកម្មវត្ថុ ប៉ុន្តែ សិទ្ធិជួលដីគឺជាសិទ្ធិលើបំណុល ហេតុនេះ វាជាសិទ្ធិទាមទារប្រើប្រាស់ដីប៉ុណ្ណោះ។ ជាលទ្ធផល សិទ្ធិលើដីត្រូវបានទទួលស្គាល់អំពីការធ្វើអនុប្បទាន និង ការធ្វើសន្តតិកម្ម (ម្ចាស់សិទ្ធិលើដីអាចធ្វើអនុប្បទានសិទ្ធិលើដីនោះទៅឱ្យបុគ្គលផ្សេងដោយសេរី) ប៉ុន្តែ សិទ្ធិជួល ត្រូវបានកម្រិតអំពីការធ្វើអនុប្បទាន (មាត្រា612)។ ម្ចាស់សិទ្ធិលើដីមានសិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិ (អាចទាមទារឱ្យកម្មសិទ្ធិករចុះបញ្ជីអំពីសិទ្ធិលើដី) ប៉ុន្តែ អ្នក

ជួល មិនអាចទាមទារឱ្យចុះបញ្ជីនោះទេ ប្រសិនបើកម្មសិទ្ធិករមិនបានព្រមព្រៀងអំពីចំណុចនេះ។ បើសិនជាយើងពិនិត្យមើលអំពីបញ្ញត្តិអំពីអំឡុងពេលអត្ថិភាពផ្សេងទៀតក៏ដោយ ក៏សិទ្ធិលើដីនេះ គឺជាសិទ្ធិដែលមានលក្ខណៈខ្លាំងបើប្រៀបធៀបជាមួយនឹងសិទ្ធិជួល។

(2) **សិទ្ធិបង្កើនផលអចិន្ត្រៃយ៍**

សិទ្ធិបង្កើនផលអចិន្ត្រៃយ៍ គឺជាសិទ្ធិប្រត្យក្សដែលប្រើប្រាស់ដីរបស់អ្នកដទៃ សម្រាប់ធ្វើស្រែចម្ការ និង ចិញ្ចឹមសត្វ។ សិទ្ធិនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងសិទ្ធិលើដី ប៉ុន្តែ ការបង់ថ្លៃឈ្នួលប្រើប្រាស់ដីមានជាតុផ្សំខុសគ្នា (មាត្រា270)។ នៅអំឡុងឆ្នាំ1800 នៃសម័យម៉ីជិ សិទ្ធិនេះត្រូវបានប្រើប្រាស់ច្រើន ប៉ុន្តែ បច្ចុប្បន្ននេះ សិទ្ធិនេះកម្រនឹងយកមកប្រើប្រាស់ណាស់ (ភាគច្រើនបំផុតគឺ គេប្រើប្រាស់សិទ្ធិជួល)។

(3) **សេវភាព**

សេវភាព គឺជាសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ ដើម្បីផលប្រយោជន៍នៃដីផ្សេងទៀត តាមគោលបំណងជាក់លាក់ (វាក្យខណ្ឌទី1 មាត្រា280)។ ឧទាហរណ៍ កម្មសិទ្ធិករនៃដី «ក» បានបង្កើតសេវភាពឆ្លងកាត់ សម្រាប់ធ្វើដំណើរឆ្លងទៅប្រើប្រាស់ដី «ក» ឬ សេវភាពទាញយកទឹកដែលអូសកាត់ដីរបស់ «ខ» ជាដើម, ក្នុងករណីនេះ យើងហៅ ដី «ក» ជា **ដីប្រើ** ហើយ ដី «ខ» ជា **ដីបម្រើ**។ តើសេវភាពមានអ្វីខុសគ្នាទៅនឹងចំណុចស្តីពីទំនាក់ទំនងដីជាប់គ្នាដែលបានសិក្សាមុននេះ? ទំនាក់ទំនងដីជាប់គ្នា គឺជាការកំណត់ត្រឹមកម្រិតអប្បបរិមាទៅលើកម្មសិទ្ធិនៃដីជាប់គ្នាប៉ុណ្ណោះ ហេតុនេះ បើសិនជាការកំណត់នេះមិនគ្រប់គ្រាន់នោះទេ ភាគីអាចចុះកិច្ចសន្យាបង្កើតសេវភាពនេះបាន។ ដោយឡែក សេវភាព អាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាល តាមរយៈការប្រើប្រាស់ជាក់ស្តែងជាបន្តបន្ទាប់ (មាត្រា283) ហើយសេវភាព ក៏អាចរលត់ដោយអាជ្ញាយុកាលផងដែរ ប្រសិនបើគ្មានការប្រើប្រាស់សោះក្រោយការបង្កើត (មាត្រា291)។

(4) **សិទ្ធិចំពោះទ្រព្យរួមរបស់សមាជិកនៃសហគមន៍**

សិទ្ធិចំពោះទ្រព្យរួមរបស់សមាជិកនៃសហគមន៍ សំដៅទៅលើសិទ្ធិប្រត្យក្សតាមច្បាប់ប្រពៃណី ដែលសមាជិកនៅក្នុងសហគមន៍ ឬ ភូមិ អាចប្រើប្រាស់រួមគ្នានូវធនធានព្រៃឈើ ភ្នំ និង ទីវាល ជាអាទិ៍។ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់ សិទ្ធិចំពោះទ្រព្យរួមរបស់សមាជិកនៃសហគមន៍ដែលមានលក្ខណៈអវិភាគ (មាត្រា263) និងសិទ្ធិចំពោះទ្រព្យរួមរបស់សមាជិកនៃសហគមន៍ដែលគ្មានលក្ខណៈអវិភាគ (មាត្រា294) ហើយខ្លឹមសារជាក់លាក់គឺពឹងផ្អែកទៅលើប្រពៃណី។

## 5. **សិទ្ធិកាន់កាប់**

### (1) **សេចក្តីផ្តើម**

ខ្ញុំនឹងសរុបខ្លឹមសារទាំងមូលអំពីសិទ្ធិកាន់កាប់ដែលបានលើកឡើងកន្លងមកនៅទីនេះ។ សូមរំលឹកឡើងវិញបន្តិចថា ទោះបីជាសិទ្ធិកាន់កាប់ គឺជាសិទ្ធិប្រត្យក្សក៏ដោយ ក៏សិទ្ធិនេះខុសគ្នាទាំងស្រុងទៅនឹងសិទ្ធិប្រត្យក្សផ្សេងទៀតផងដែរ (កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតផ្នែកខ្លះ)។ ក្រមរដ្ឋប្បវេណីបានរៀបចំឡើងហាក់បីដូចជាមានអត្ថិភាព «សិទ្ធិកាន់កាប់» ប៉ុន្តែ កម្មវត្ថុពិតប្រាកដដែលត្រូវបានការពារដោយច្បាប់ គឺស្ថានភាពជាក់ស្តែងនៃ «ការកាន់កាប់»។ ការគ្រប់គ្រងទៅលើវត្ថុជាក់លាក់ណាមួយ គឺត្រូវទទួលការការពារដោយច្បាប់ ក្នុងនាមជាការកាន់កាប់។ ក្នុងករណីនេះ យើងមិនពិចារណាថា បុគ្គលដែលកំពុងតែកាន់កាប់នោះ មានសិទ្ធិប្រត្យក្សដែលអាចគ្រប់គ្រងវត្ថុ (ហៅថា សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តិ) ដោយជាក់ស្តែងនោះទេ (ដូចនេះ អាចមានករណីខ្លះអ្នកកាន់កាប់បានទទួលការការពារ ដោយប្រើប្រាស់បណ្តឹងដែលផ្អែកលើសិទ្ធិកាន់កាប់ (រៀបរាប់នៅពេលក្រោយ) ប៉ុន្តែ ចាញ់ក្តី នៅក្នុងបណ្តឹងអំពីសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តវិញ)។

### (2) **ការកកើតនៃការកាន់កាប់**

ការកាន់កាប់ សំដៅទៅលើ «ការក្តាប់ទុកវត្ថុ ដោយមានឆន្ទៈសម្រាប់ខ្លួនឯង» (មាត្រា180)។ យោងតាមនិយមន័យនេះ នៅក្នុងការកាន់កាប់មានធាតុផ្សំ 2 គឺ ការក្តាប់ទុក ឬ គ្រប់គ្រងវត្ថុជាក់ស្តែង (នេះហៅថា ធាតុសត្យានុម័តនៃការកាន់កាប់) និង មានឆន្ទៈសម្រាប់ខ្លួនឯង (នេះហៅថា ធាតុអត្តនោម័តនៃការកាន់កាប់)។ ប៉ុន្តែក្នុងពេលបច្ចុប្បន្ននេះ មានឆន្ទៈសម្រាប់ខ្លួនឯងនេះ ត្រូវបានបកស្រាយយ៉ាងទូលាយ ហើយគេគិតថា បើបុគ្គលណាម្នាក់ស្ថិតក្នុងគោលជំហរក្នុងការទទួលផលប្រយោជន៍សម្រាប់ខ្លួនឯងដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី គឺត្រូវបានទទួលស្គាល់ថាបុគ្គលនោះ មានឆន្ទៈសម្រាប់ខ្លួនឯងជាដរាប។ ការក្តាប់ទុកវត្ថុ មិនសំដៅតែទៅលើការចាប់កាន់វត្ថុនោះទេ ប៉ុន្តែ គ្រាន់តែស្ថិតក្នុងស្ថានភាពមួយដែលសង្គមជាទូទៅមើលឃើញថា បុគ្គលនោះកំពុងតែគ្រប់គ្រងវត្ថុនោះគឺគ្រប់គ្រាន់ហើយ (ឧទាហរណ៍ វត្ថុដែលបានទុកនៅផ្ទះរបស់ម្ចាស់ដែលកំពុងធ្វើដំណើរកំសាន្ត ក៏ការកាន់កាប់កើតឡើងដែរ)។ ការក្តាប់ទុកវត្ថុនេះ អាចធ្វើឡើងតាមរយៈអ្នកតំណាង ឬ អ្នកជំនួយបាន ដូចមានរៀបរាប់ពេលក្រោយ។ ប៉ុន្តែ ប្រសិនបើការក្តាប់ទុកវត្ថុកាន់កាប់ក្នុងន័យខាងលើនេះបាត់បង់ នោះសិទ្ធិកាន់កាប់ក៏រលត់ដែរ (វាក្យខណ្ឌទី1 មាត្រា203)។

### (3) **បែបយ៉ាងនៃការកាន់កាប់**

<u>① ការកាន់កាប់ដោយខ្លួនឯង និង ការកាន់កាប់ដោយតំណាង</u>

ការកាន់កាប់ដែលអ្នកកាន់កាប់ក្តាប់ទុកវត្ថុដោយខ្លួនឯង គឺជា **ការកាន់កាប់ដោយខ្លួនឯង** ចំណែកឯ ការឱ្យអ្នកតំណាងកាន់កាប់ក្តាប់ទុកវត្ថុជំនួស គឺជា **ការកាន់កាប់ដោយតំណាង** (មាត្រា181)។ ឧទាហរណ៍នៃការជួលផ្ទះ

យើងអាចនិយាយថា អ្នកកាន់កាប់ដោយផ្ទាល់ គឺជាអ្នកជួល ហើយអ្នកឱ្យជួល**កាន់កាប់ដោយប្រយោល**។ នៅក្នុងករណីនេះ ទោះបីក្រមរដ្ឋប្បវេណីហៅអ្នកតំណាងកាន់កាប់ថា «អ្នកតំណាង» ក៏ដោយ ប៉ុន្តែវាមានលក្ខណៈខុសគ្នាទៅនឹងពាក្យអ្នកតំណាងតាមរយៈការបង្ហាញឆន្ទៈ (បុគ្គលដែលទទួលបានសិទ្ធិតំណាងពីម្ចាស់សិទ្ធិ) ដែលមានកំណត់ចាប់ពីមាត្រា99 នៃក្រមរដ្ឋប្បវេណី។ គ្រាន់តែនៅក្នុងទំនាក់ទំនងជាក់ស្តែងនៃការកាន់កាប់វត្ថុនេះ អ្នកតំណាងកាន់កាប់ជំនួសមានទំនាក់ទំនងជាក់លាក់ជាមួយម្ចាស់សិទ្ធិ ហើយកំពុងកាន់កាប់ដោយមានឆន្ទៈដើម្បីម្ចាស់សិទ្ធិប៉ុណ្ណោះ គឺគ្រាប់គ្រាន់ហើយ។ ដោយឡែក ករណីអ្នកបម្រើការងារក្នុងផ្ទះ និង បុគ្គលិកហាងទំនិញ ជាដើម គឺជាអ្នកជំនួយកាន់កាប់ (បុគ្គលដែលជួយជាដៃជាជើងក្នុងការកាន់កាប់ដល់ម្ចាស់សិទ្ធិ) ហើយការកាន់កាប់ដោយតំណាងមិនកើតឡើងនោះទេ។

<u>② ការកាន់កាប់យកជារបស់ខ្លួន និង ការកាន់កាប់មិនយកជារបស់ខ្លួន</u>

ការកាន់កាប់ដែលអ្នកកាន់កាប់មាន «**ឆន្ទៈយកជាកម្មសិទ្ធិ**» ហៅថា ការកាន់កាប់យកជារបស់ខ្លួន ហើយការកាន់កាប់ក្រៅពីនេះ ហៅថា ការកាន់កាប់មិនយកជារបស់ខ្លួន (មាត្រា185)។ ការបែងចែកនេះ មានអត្ថប្រយោជន៍ចំពោះអាជ្ញាយុកាលនៃលទ្ធកម្ម (មាត្រា162) និង ការកាន់កាប់មុននៃវត្ថុដែលគ្មានម្ចាស់ (មាត្រា239) ដែលធ្លាប់បានសិក្សាកន្លងមក។

ចំពោះបុគ្គលដែលបានទិញវត្ថុ មានការកាន់កាប់យកជារបស់ខ្លួន ហើយចំពោះអ្នកជួលវិញ ពុំមានការកាន់កាប់យកជារបស់ខ្លួននោះទេ។ ប៉ុន្តែ ប្រសិនបើអ្នកជួលបានទិញយកវត្ថុដែលជួលនោះ ក្នុងករណីនេះ ការកាន់កាប់មិនយកជារបស់ខ្លួន ត្រូវក្លាយជាការកាន់កាប់យកជារបស់ខ្លួន ដោយសារការកាន់កាប់ផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តថ្មី (មាត្រា185)។ នៅក្នុងយុត្តិសាស្ត្រថ្មីៗនេះបានបកស្រាយថា សន្តតិកម្មក៏ក្លាយជាមូលហេតុនៃសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តថ្មីដែរ។

### (4) លទ្ធកម្មនៃសិទ្ធិកាន់កាប់

ការកាន់កាប់រួមមាន ការកាន់កាប់ដោយលទ្ធកម្មតាំងពីដំបូង និងការកាន់កាប់ដោយលទ្ធកម្មបន្តពីម្ចាស់មុន។ ការរើសបានវត្ថុបាត់ ជាអាទិ៍ គឺជាការកាន់កាប់ដោយលទ្ធកម្មតាំងពីដំបូង ប៉ុន្តែ ការកាន់កាប់ដោយលទ្ធកម្មបន្តពីម្ចាស់មុនមានសារសំខាន់ជាង មានន័យថា អ្នកកាន់កាប់ថ្មីធ្វើលទ្ធកម្មបន្តនូវការកាន់កាប់ដែលមានសភាពដូចគ្នានឹងការកាន់កាប់របស់ម្ចាស់មុន ដូចជាតាមរយៈកិច្ចសន្យាលក់ទិញជាដើម។ លទ្ធកម្មបន្តនេះ បូករួមទាំងការធ្វើលទ្ធកម្មតាមសន្តតិកម្មផងដែរ។

ចំពោះការធ្វើលទ្ធកម្មបន្ត អ្នកកាន់កាប់អាចអះអាងអំពីការកាន់កាប់របស់ម្ចាស់មុនក៏បាន ឬ អះអាងអំពីការកាន់កាប់របស់ខ្លួនដែលកើតឡើងថ្មីក៏បាន (មាត្រា187 កថាខណ្ឌទី1)។ ប៉ុន្តែ បើសិនជាអះអាងអំពីការកាន់កាប់

របស់ម្ចាស់មុន ក្នុងករណីនេះ អ្នកកាន់កាប់ថ្មីត្រូវទទួលបន្តនូវវិការៈ (ទុច្ចរិត និង កំហុស ជាអាទិ៍) នៃការកាន់កាប់របស់ម្ចាស់មុនផងដែរ (មាត្រា187 កថាខណ្ឌទី2)។

(5) **អានុភាពនៃការកាន់កាប់**

① សិទ្ធិទាមទារឱ្យការពារការកាន់កាប់

នៅពេលទទួលរងការរារាំងការកាន់កាប់ពីបុគ្គលដទៃ អ្នកកាន់កាប់អាចទាមទារឱ្យបញ្ឈប់ការរារាំងនោះ តាមបណ្តឹងដោយផ្អែកលើការកាន់កាប់បាន ទោះបីជាការកាន់កាប់នោះធ្វើឡើង ឬមិនបានធ្វើឡើងដោយផ្អែកលើសិទ្ធិត្រឹមត្រូវក៏ដោយ (ចាប់ពីមាត្រា197)។ បណ្តឹងដោយផ្អែកលើការកាន់កាប់មាន 3ប្រភេទ គឺ **បណ្តឹងទាមទារឱ្យបញ្ឈប់ការរារាំង បណ្តឹងទាមទារឱ្យបង្ការជាមុននូវការរារាំង** និង **បណ្តឹងទាមទារឱ្យប្រគល់វិញ**។

បណ្តឹងដោយផ្អែកលើការកាន់កាប់ គឺជាសិទ្ធិបញ្ឈប់ការរារាំងចំពោះការកាន់កាប់វត្ថុជាក់ស្តែង ហេតុនេះហើយ វាគ្មានទំនាក់ទំនងនឹងបណ្តឹងដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តនោះទេ (ការបញ្ឈប់ការរារាំងដោយផ្អែកកម្មសិទ្ធិ ជាអាទិ៍, មាត្រា202 កថាខណ្ឌទី1)។ ដូចនេះ បុគ្គលតែម្នាក់អាចដាក់បណ្តឹងដោយផ្អែកលើការកាន់កាប់ផង និង បណ្តឹងដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តផង ព្រមគ្នាបាន។

② ការសន្មតនៃសិទ្ធិ

អ្នកកាន់កាប់ ត្រូវបានសន្មតថា មានសិទ្ធិដែលជាមូលហេតុស្របច្បាប់នៃការកាន់កាប់ចំពោះវត្ថុកាន់កាប់ (មាត្រា188)។ ឧទាហរណ៍ បុគ្គលដែលអះអាងថាខ្លួនជាកម្មសិទ្ធិករ នឹងត្រូវសន្មតថាជាកម្មសិទ្ធិករ ដោយគ្រាន់តែបញ្ជាក់អំពីអង្គហេតុនៃការកាន់កាប់ប៉ុណ្ណោះ ហេតុនេះ បុគ្គលដែលមានវិវាទអំពីចំណុចនេះ ត្រូវតែបញ្ជាក់ថាអ្នកកាន់កាប់នោះគ្មានកម្មសិទ្ធិទេ។ ប៉ុន្តែ ចំពោះអចលនវត្ថុវិញ យើងបានសិក្សារួចហើយថា អានុភាពសន្មតនៃការចុះបញ្ជីគឺមានអាទិភាពជាង ហេតុនេះហើយ អានុភាពសន្មតនៃការកាន់កាប់នេះអាចអនុវត្តបានចំពោះតែអចលនវត្ថុដែលមិនទាន់ចុះបញ្ជីប៉ុណ្ណោះ។

③ សិទ្ធិទទួលផលរបស់អ្នកកាន់កាប់សុចរិត

ឧទាហរណ៍ បុគ្គលដែលបានកាន់កាប់ដីដោយភាន់ច្រឡំថាខ្លួនមានកម្មសិទ្ធិ ទាំងដែលខ្លួនគ្មានកម្មសិទ្ធិ អាចប្រមូលផលផ្លែប៉ោមដែលដាំនៅលើដីនោះបាន។ នេះហៅថា សិទ្ធិទទួលផលរបស់អ្នកកាន់កាប់សុចរិត (មាត្រា189 កថាខណ្ឌទី1)។ ដោយសារតែ ការអនុញ្ញាតឱ្យម្ចាស់សិទ្ធិពិតប្រាកដទាមទារឱ្យអ្នកកាន់កាប់សុចរិតសងផលនៅពេលក្រោយនេះ វាហួសហេតុពេក។ ផលស៊ីវិលដែលជាថ្លៃឈ្នួល ត្រូវអនុវត្តដូចគ្នាផងដែរ។

# ជំពូកទី៤

## នីតិសិទ្ធិលើបំណុល (1) — នីតិកិច្ចសន្យា

I. **ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិលើបំណុល**

1. សិទ្ធិលើបំណុលដែលជាសិទ្ធិមានចំពោះបុគ្គល

2. សិទ្ធិលើបំណុលក្នុងនាមទ្រព្យធនសកម្ម

3. រចនាសម្ព័ន្ធនៃនីតិសិទ្ធិលើបំណុល និង លំដាប់សិក្សា

II. **ការសិក្សាចំណុចសំខាន់ៗនៃកិច្ចសន្យាទូទៅ**

1. ការបង្កើតកិច្ចសន្យា

2. ប្រភេទនៃកិច្ចសន្យា

3. អានុភាពនៃកិច្ចសន្យា

4. ការមិនអនុវត្តកាតព្វកិច្ច និង ការរំលាយកិច្ចសន្យា

5. ឧសន្យាតាមទម្រង់ជាក់លាក់

III. **ការសិក្សាចំណុចសំខាន់ៗនៃកិច្ចសន្យាពិសេស**

1. កិច្ចសន្យាលក់ទិញ

2. កិច្ចសន្យាប្រទានកម្ម

3. កិច្ចសន្យាជួល

4. កិច្ចសន្យាខ្ចីប្រើ

5. កិច្ចសន្យាខ្ចីបរិភោគ

6. កិច្ចសន្យាម៉ៅការ

7. កិច្ចសន្យាអាណត្តិ

8. កិច្ចសន្យាបញ្ញើ

9. កិច្ចសន្យាក្រុមហ៊ុន

10. កិច្ចសន្យាដែលមានច្បាប់កំណត់ផ្សេងទៀត

11. កិច្ចការពារអ្នកប្រើប្រាស់ និង Cooling-Off

## I. **និន្នាការទូទៅនៃនីតិសិទ្ធិលើបំណុល**

### 1. **សិទ្ធិលើបំណុលដែលជាសិទ្ធិមានចំពោះបុគ្គល**

ដូចបានរៀបរាប់ខាងលើនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីសិទ្ធិដែលយើងមានជា 2 គឺ សិទ្ធិមានចំពោះវត្ថុ និង សិទ្ធិមានចំពោះបុគ្គល។ សិទ្ធិមានចំពោះបុគ្គលស្ថិតនៅក្នុងគន្ថីទី3 នៃក្រមរដ្ឋប្បវេណី ហើយគេហៅថា នីតិសិទ្ធិលើបំណុល។

សិទ្ធិលើបំណុលត្រូវបាននាំចូលពីអ៊ឺរ៉ុប (ដំបូងបំផុត គឺប្រទេសបារាំង) ចូលទៅក្នុងក្រមរដ្ឋប្បវេណីទំនើបរបស់ជប៉ុនក្នុងសម័យម៉ីជិ គេបានហៅថា «សិទ្ធិមានចំពោះបុគ្គល» ហើយវាគឺជាសិទ្ធិដែលបុគ្គលជាក់លាក់អាចទាមទារឱ្យបុគ្គលជាក់លាក់ផ្សេងទៀតធ្វើសកម្មភាពណាមួយជាដើម។ ពាក្យថា «សកម្មភាពណាមួយជាដើម» នេះជាទូទៅ សំដៅទៅលើសកម្មភាពដូចជា បង់ប្រាក់ ឬ ប្រគល់ទំនិញជាអាទិ៍ ប៉ុន្តែ ក្នុងករណីមួយចំនួន វាសំដៅទៅលើការមិនធ្វើសកម្មភាពណាមួយដូចជា «មិនបើកហាងលក់ដូចគ្នា» ឬ «មិនបញ្ចេញសម្លេងរំខាននៅពេលយប់» ជាដើម។ មានករណីខ្លះ យើងអាចប្រើពាក្យថា «តាវកាលិក» ដើម្បីសរុបន័យរួមរបស់ការធ្វើសកម្មភាព ឬ មិនធ្វើសកម្មភាពទាំងនេះ។ តាវកាលិកដែលក្លាយជាកម្មវត្ថុនៃសិទ្ធិលើបំណុល តែងតែជារបស់ដែលមានតម្លៃសេដ្ឋកិច្ច ប៉ុន្តែ ក្រមរដ្ឋប្បវេណីបានកំណត់ថា របស់ដែលមិនអាចប៉ាន់ស្មានតម្លៃជាប្រាក់កាសក៏ដោយ ក៏អាចក្លាយជាកម្មវត្ថុនៃសិទ្ធិលើបំណុលផងដែរ (មាត្រា399។ ប៉ុន្តែ តាវកាលិកដែលមានខ្លឹមសារជាសីលធម៌ផ្លូវចិត្តសុទ្ធសាធ មិនអាចក្លាយជាសិទ្ធិលើបំណុលនោះទេ។ ឧទាហរណ៍ សកម្មភាពដែលមានខ្លឹមសារឱ្យ «រៀបចំសែនព្រេនជូនដូនតាជារៀងរាល់ឆ្នាំ» អាចក្លាយជាសិទ្ធិលើបំណុលបាន ប៉ុន្តែ ខ្លឹមសារដែលឱ្យ «បួងសួងក្នុងចិត្តជារៀងរាល់ព្រឹក» មិនអាចវាយតម្លៃថាជា សិទ្ធិលើបំណុលនោះទេ)។ យើងនឹងសិក្សាអំពីលក្ខណៈ និង ប្រភពនៃសិទ្ធិលើបំណុលបែបនេះ នៅក្នុងនីតិសិទ្ធិលើបំណុលនេះ។

### 2. **សិទ្ធិលើបំណុលក្នុងនាមទ្រព្យធនសកម្ម**

ខ្ញុំយល់ថាអ្នកសិក្សាអំពីសេដ្ឋកិច្ច និង គណនេយ្យនឹងអាចយល់អំពីខ្លឹមសារទាំងអស់នេះបានច្រើនថា នៅក្នុងចំណោមទ្រព្យធនសកម្ម (ទ្រព្យសម្បត្តិ) របស់រូបវន្តបុគ្គលក៏ដោយ ក្រុមហ៊ុនក៏ដោយ គឺមានវត្ថុ ពោលគឺ អចលនវត្ថុ ឬ ចលនវត្ថុ ហើយក្រៅពីនេះទៀត គឺមានសិទ្ធិលើបំណុលដែលមានទម្រង់ជាប្រាក់ឱ្យគេខ្ចី ឬ ប្រាក់សន្សំក្នុងគណនី។ ឧទាហរណ៍ នៅក្នុងក្រុមហ៊ុនផ្តល់សេវាជួល និង ក្រុមហ៊ុនផ្តល់ប្រាក់ឥណទានដែលជាក្រុមហ៊ុនថ្មីក្នុងប្រវត្តិសាស្ត្រ ប្រហែលជាមានកម្មសិទ្ធិតិចតួចលើអចលនវត្ថុជាដើម បើប្រៀបធៀបនឹងសិទ្ធិលើបំណុលនៃកម្រៃសេវាជួលជាច្រើន និង សិទ្ធិលើបំណុលជាប្រាក់ឥណទានទូទាត់ជាមុន ដែលក្រុមហ៊ុនទាំងនេះកំពុងមានក្នុងនាមជាទ្រព្យធនសកម្ម តាមប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

នៅក្នុងវង្វង់ក្រមរដ្ឋប្បវេណីក៏ដោយ ដើមឡើយគេផ្ដោតសំខាន់លើការកាន់កាប់វត្ថុ ពោលគឺការមានសិទ្ធិប្រត្យក្សដូចជា កម្មសិទ្ធិលើវត្ថុជាដើម ប៉ុន្តែ នាពេលថ្មីៗ និងនៅក្នុងពេលបច្ចុប្បន្ននេះ ការផ្ដោតសំខាន់នេះត្រូវធ្លាក់ចុះ ហើយសិទ្ធិលើបំណុលបានទទួលឋានៈដែលមានអាទិភាពខ្ពស់ជាង។ វាមានទំនាក់ទំនងនឹងប្រវត្តិសាស្ត្រនៃការទទួលស្គាល់តម្លៃទ្រព្យសម្បត្តិនៃសិទ្ធិលើបំណុល។ នៅដើមសម័យកាលនៃច្បាប់រ៉ូម៉ាំងបានចាត់ទុក សិទ្ធិលើបំណុលនេះគឺជា «ចំណងច្បាប់» ដែលភ្ជាប់បុគ្គលជាក់លាក់មួយទៅនឹងបុគ្គលជាក់លាក់មួយទៀត ហើយមិនអាចធ្វើអនុប្បទានតាមចិត្តឯងទៅឱ្យតតិយជននោះទេ។ ចាប់ពីពាក់កណ្ដាលសម័យកាលនៃច្បាប់រ៉ូម៉ាំងមក គេបានចាប់ផ្ដើមទទួលស្គាល់ភាពដែលអាចធ្វើអនុប្បទានបាននៃសិទ្ធិលើបំណុលនេះ ហើយនៅក្នុងក្រមរដ្ឋប្បវេណីទំនើបនៅក្នុងប្រទេសណាក៏ដោយ គឺបានទទួលស្គាល់សេរីភាពនៃអនុប្បទានសិទ្ធិលើបំណុល។ ជាលទ្ធផល សិទ្ធិលើបំណុលបានក្លាយជាទ្រព្យសម្បត្តិមួយដែលមានតម្លៃ និងសព្វថ្ងៃនេះវាជាទ្រព្យសម្បត្តិមួយដែលងាយស្រួលក្នុងការដោះដូរជាងអចលនវត្ថុជាអាទិ៍ ហើយសិទ្ធិលើបំណុលនេះកាន់តែមានសារៈសំខាន់នៅក្នុងសង្គមជំនួញ។ បើយើងនិយាយពីជ្រុងម្ខាងទៀត នៅសម័យសក្តិភូមិ ទំនាក់ទំនងរវាងអ្នកគ្រប់គ្រង និង អ្នកត្រូវបានគេគ្រប់គ្រង គឺអាស្រ័យទៅលើការមានកម្មសិទ្ធិនៅលើដី ប៉ុន្តែ នៅសម័យបច្ចុប្បន្ននេះ (វាមិនមែនជា ស្ថានភាពពិតដែលយើងចង់ឃើញនោះទេ) វាបានផ្លាស់ប្ដូរមកជាទំនាក់ទំនងរវាងអ្នកគ្រប់គ្រង និង អ្នកត្រូវបានគេគ្រប់គ្រងបែបសេដ្ឋកិច្ច ដែលអាស្រ័យទៅលើទំនាក់ទំនងសិទ្ធិលើបំណុល។

ទោះជាយ៉ាងណាក៏ដោយ យើងអាចនិយាយថា នីតិសិទ្ធិលើបំណុលនេះគឺជាផ្នែកមួយដែលមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការសិក្សាក្រមរដ្ឋប្បវេណី។

### 3. **រចនាសម្ព័ន្ធនៃនីតិសិទ្ធិលើបំណុល និង លំដាប់សិក្សា**

ដូចបានរៀបរាប់ដោយសង្ខេបនៅក្នុងជំពូកទី1 រួចហើយថា ជំពូកទី1 បទប្បញ្ញត្តិទូទៅ គន្ថីទី3 សិទ្ធិលើបំណុលនៃក្រមរដ្ឋប្បវេណី បញ្ញត្តអំពី សារជាតុនៃសិទ្ធិលើបំណុល និង ដំណើរការចាប់ពីការកកើតរហូតដល់រលត់ ហើយនៅក្នុងការសិក្សាច្បាប់ គេហៅផ្នែកនេះថា «សិទ្ធិលើបំណុលទូទៅ»។ ចាប់ពីជំពូកទី2 ដល់ជំពូកទី5 បញ្ញត្តអំពីមូលហេតុនៃការកកើតសិទ្ធិលើបំណុលទាំង 4 គឺ កិច្ចសន្យា ការគ្រប់គ្រងដោយឈ្នាល សេចក្ដីចម្រើនឥតហេតុ និងអំពើអនីត្យានុកូល ហើយនៅក្នុងការសិក្សាច្បាប់ គេហៅផ្នែកនេះថា «សិទ្ធិលើបំណុលពិសេស»។ បើប្រៀបធៀបអំពីសិទ្ធិលើបំណុលទូទៅ និង ពិសេស យើងអាចមើលឃើញថា សិទ្ធិលើបំណុលពិសេសមានចំណុចងាយស្រួលយល់ជាច្រើន ដែលនិយាយជាក់ស្ដែងអំពីបញ្ហានៃការកកើតសិទ្ធិលើបំណុលចាប់ពីកិច្ចសន្យារហូតមក។ ហេតុនេះ នៅទីនេះ ខ្ញុំនឹងពន្យល់បញ្ច្រាសជាមួយក្រមរដ្ឋប្បវេណី ដោយចាប់ផ្ដើមពីខ្លឹមសារនៃសិទ្ធិលើបំណុលពិសេសជាមុន ហើយបន្តចូលទៅសិទ្ធិលើបំណុលទូទៅជាក្រោយ។ ដូចនេះ យើងនឹងចាប់ផ្ដើមពីផ្នែកនៃនីតិកិច្ចសន្យាមុន ប៉ុន្តែ យើងក៏បញ្ចូលចំណុចស្ដីពីសំណងការខូចខាត ជាអាទិ៍ ដែលស្ថិតក្នុងវិសាលភាពនៃសិទ្ធិលើបំណុលទូទៅ ចូលទៅក្នុងនីតិកិច្ចសន្យាផងដែរ។

## II. **ការសិក្សាចំណុចសំខាន់ៗនៃកិច្ចសន្យាទូទៅ**

### 1. **ការបង្កើតកិច្ចសន្យា**

#### (1) **និយមន័យនៃកិច្ចសន្យា**

ដូចបានរៀបរាប់នៅមុននេះបន្តិច ក្រមរដ្ឋប្បវេណីទំនើបបានទទួលស្គាល់ «គោលការណ៍សេរីភាពនៃកិច្ចសន្យា» ហើយដរាបណាវាមិនផ្ទុយនឹងទំនៀមទម្លាប់ល្អ និង សណ្តាប់ធ្នាប់សាធារណៈរបស់យើងគ្រប់គ្នាទេ កិច្ចសន្យាអាចបង្កើតនូវសិទ្ធិលើបំណុលរាប់ពាន់ម៉ឺនទម្រង់បាន។ យើងក៏បានសិក្សារួចហើយថា ដោយសារតែសិទ្ធិលើបំណុលមានអានុភាពមិនដាច់ខាតទៅលើតែភាគីប៉ុណ្ណោះ ហេតុនេះ បុគ្គលគ្រប់រូបអាចបង្កើតដោយសេរី។

ដូចនេះ យើងនឹងសិក្សាលម្អិតបន្តិចចាប់ពីការបង្កើតកិច្ចសន្យា។ បើសិនជាយើងប្រើប្រាស់ពាក្យពេចន៍ដែលមានក្នុងជំពូកទី2 បញ្ញត្តិទូទៅ នៃក្រមរដ្ឋប្បវេណីមកផ្តល់និយមន័យ យើងអាចនិយាយបានថា កិច្ចសន្យាសំដៅទៅលើ «សកម្មភាពរបស់បុគ្គល 2នាក់ ឬ ច្រើននាក់មានបង្ហាញឆន្ទៈនៃសំណើ និង ការបង្ហាញឆន្ទៈនៃស្ទីការត្រូវគ្នា ហើយបង្កើតនូវទំនាក់ទំនងសិទ្ធិករណីយកិច្ចតាមច្បាប់ជាក់លាក់មួយ»។ ឧទាហរណ៍នៃកិច្ចសន្យាលក់ទិញ នៅពេលដែល A បាននិយាយទៅកាន់ B ចង់លក់ទំនិញនេះក្នុងតម្លៃ 2 លានរៀល ហើយ B បាននិយាយថាទិញក្នុងតម្លៃ 2 លានរៀលនេះ ទៅកាន់ A គឺកិច្ចសន្យាកើតមានឡើង។ ពាក្យថា បុគ្គល 2នាក់ ឬ ច្រើននាក់ សំដៅទៅលើជាទូទៅគឺមានបុគ្គលតែ 2 នាក់ប៉ុណ្ណោះ ប៉ុន្តែ ម្ចាស់បំណុលច្រើននាក់ ឬ កូនបំណុលច្រើននាក់អាចចូលរួមក្នុងកិច្ចសន្យាតែមួយបាន។

#### (2) **កិច្ចសន្យាអំពីសិទ្ធិលើបំណុល**

យើងគ្រប់គ្នាតែងគិតថា «កិច្ចសន្យា» គឺជាកិច្ចសន្យាអំពីសិទ្ធិលើបំណុលដែលបង្កើតឱ្យមានទំនាក់ទំនងសិទ្ធិលើបំណុល និង កាតព្វកិច្ចណាមួយ។ ឧទាហរណ៍ ជាទូទៅបំផុតគឺកិច្ចសន្យាលក់ទិញ។ នៅក្នុងការលក់ទិញ សិទ្ធិលើបំណុលនៃថ្លៃលក់ទិញ និង សិទ្ធិលើបំណុលនៃការប្រគល់វត្ថុកើតមានឡើង (លើសពីនេះទៀត នៅក្នុងការលក់ទិញ ការផ្ទេរកម្មសិទ្ធិលើវត្ថុក៏ត្រូវភ្ជាប់មកជាមួយដែរ។ វាមានន័យថា ធាតុផ្សំដែលជាការផ្ទេរសិទ្ធិប្រត្យក្សក៏មានផងដែរ ហើយសូមយើងគិតថា នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិលើបំណុល និង កាតព្វកិច្ច ក៏មានរួមជាមួយនូវធាតុផ្សំនៃការផ្ទេរសិទ្ធិប្រត្យក្សផងដែរ)។ ដូច្នេះ បើសិនជាយើងពិចារណាថា តើមានកិច្ចសន្យាអំពីសិទ្ធិប្រត្យក្សដែរឬទេ? យើងអាចមើលឃើញដូចក្នុងករណីកិច្ចសន្យាបង្កើតសិទ្ធិលើដីដែលយើងបានសិក្សាកន្លងមក ហើយកិច្ចសន្យាដែលមានខ្លឹមសារបង្កើតតែសិទ្ធិប្រត្យក្សមួយមុខបែបនេះ ហៅថា **កិច្ចសន្យាអំពីសិទ្ធិប្រត្យក្ស**។ ការព្រមព្រៀងដែលបង្កើតនូវទំនាក់ទំនងគតិយុត្តតាមច្បាប់គ្រួសារដូចជា អាពាហ៍ពិពាហ៍ ហៅថា **កិច្ចសន្យាអំពីឋានៈ** (តទៅនេះ ពាក្យថា «កិច្ចសន្យា» ក្នុងអត្ថបទនេះ សំដៅទៅលើ កិច្ចសន្យាអំពីសិទ្ធិលើបំណុល)។

### (3) អត្ថន័យនៃបញ្ញត្តិអំពីកិច្ចសន្យា

ដោយឡែក យោងតាមគោលការណ៍សេរីភាពនៃកិច្ចសន្យា កិច្ចសន្យាអាចមានខ្លឹមសារជាច្រើនខុសៗគ្នា ប៉ុន្តែ នៅក្នុងចំណោមនោះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវប្រភេទនៃកិច្ចសន្យាចំនួន 13ប្រភេទ។ ទោះជាបែបនេះក៏ដោយ ខ្ញុំសូមនិយាយម្តងទៀតថា នៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ក៏នីតិសិទ្ធិលើបំណុលនេះបញ្ញត្តឡើងដោយយក «គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន» និង «គោលការណ៍ស្វ័យភាពខាងឆន្ទៈ» ធ្វើជាមូលដ្ឋាន ដែលមានន័យថា យើងគ្រប់គ្នាអាចបង្កើតដោយសេរីនូវវិធានសម្រាប់ទំនាក់ទំនងរវាងខ្លួនឯង តាមរយៈការសន្យាដោយផ្អែកលើឆន្ទៈដោយសេរីរបស់បុគ្គលម្នាក់ និង បុគ្គលម្នាក់ផ្សេងទៀត។ ហេតុនេះ បញ្ញត្តិទាំងអស់នេះក៏ដោយ ក៏គេប្រើប្រាស់ជាការបំពេញបន្ថែម ក្នុងករណីដែលភាគីមិនបានកំណត់វិធានល្អិតល្អន់ជាមុនប៉ុណ្ណោះ ហើយវាគឺជា បញ្ញត្តិស្ម័គ្រចិត្ត។

## 2. ប្រភេទនៃកិច្ចសន្យា

### (1) កិច្ចសន្យាដែលមានច្បាប់កំណត់ និង កិច្ចសន្យាដែលគ្មានច្បាប់កំណត់

ក្រមរដ្ឋប្បវេណី បានជ្រើសរើសយកកិច្ចសន្យាចំនួន 13ប្រភេទ ដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់នៅក្នុងសង្គម ហេតុនេះ គេហៅថា កិច្ចសន្យាដែលមានច្បាប់កំណត់។ ហើយក្រៅពីកិច្ចសន្យាទាំងនេះ គឺជាកិច្ចសន្យាដែលគ្មានច្បាប់កំណត់។ ម្យ៉ាងទៀតកិច្ចសន្យាទាំង 13ប្រភេទនេះ ត្រូវបានដាក់ឈ្មោះតាមច្បាប់ ហើយក្នុងអត្ថន័យនេះ គេអាចហៅថា កិច្ចសន្យាមានឈ្មោះ (មិនមែនក្នុងន័យល្បីឈ្មោះឡើយ) ហើយកិច្ចសន្យាដែលគ្មានច្បាប់កំណត់ក្រៅពីនេះហៅថា កិច្ចសន្យាគ្មានឈ្មោះ ប៉ុន្តែ គ្មានឈ្មោះមិនមានន័យថាមិនមានសារៈសំខាន់នោះទេ។ នៅក្នុងពិភពលោកនេះ កិច្ចសន្យា Lease និង កិច្ចសន្យា Credit ជាដើម គឺមានសារៈសំខាន់ខ្លាំងណាស់ទោះបីជាមិនស្ថិតនៅក្នុងចំណោមប្រភេទទាំង 13 នៃកិច្ចសន្យាក៏ដោយ។ ក្នុងចំណោមកិច្ចសន្យាទាំង 13 ប្រភេទនេះ មានកិច្ចសន្យាមួយចំនួនមិនសូវបានយកមកប្រើប្រាស់នោះទេក្នុងពេលបច្ចុប្បន្ននេះ។

នៅក្នុងករណីដែលការបង្ហាញឆន្ទៈរបស់ភាគីមានភាពមិនច្បាស់លាស់នោះទេ បញ្ហានឹងកើតមានឡើងថា វាជាកិច្ចសន្យាអ្វី (ការបកស្រាយកិច្ចសន្យា)។ នៅក្នុងម៉ោងសិក្សាក្រមរដ្ឋប្បវេណី មានការបង្រៀនអំពីកិច្ចសន្យាលក់ទិញ ឬ កិច្ចសន្យាជួលជាដើម ប៉ុន្តែ នៅក្នុងសង្គមជាក់ស្តែង មានរឿងក្តីជាច្រើនដែលមានបញ្ហាអំពីការបកស្រាយកិច្ចសន្យានោះផ្ទាល់ ឬ បកស្រាយឆន្ទៈរបស់ភាគី។ យើងត្រូវយល់ដឹងអំពីបញ្ហានេះ ហើយវិភាគលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ ដោយផ្តោតសំខាន់លើកិច្ចសន្យាដែលមានច្បាប់កំណត់។

### (2) កិច្ចសន្យាកើតឡើងតាមការព្រមព្រៀង កិច្ចសន្យាកើតឡើងតាមការប្រគល់វត្ថុ និង កិច្ចសន្យាកើតឡើងតាមទម្រង់

ដំបូង យើងអាចបែងចែកជាប្រភេទកិច្ចសន្យាកើតឡើងតាមការព្រមព្រៀង និង កិច្ចសន្យាកើតឡើងតាមការប្រគល់វត្ថុ។ កិច្ចសន្យាជាច្រើនក្នុងពេលបច្ចុប្បន្ន គឺជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀង។ តាមការព្រមព្រៀង

នេះសំដៅទៅលើ ការកើតឡើងនូវអានុភាពបង្កើតដោយមានការបង្ហាញឆន្ទៈត្រូវគ្នាប៉ុណ្ណោះ។ ឧទាហរណ៍ កិច្ចសន្យាលក់ទិញ គឺជាប្រភេទនៃកិច្ចសន្យានេះហើយ (ដោយឡែក នៅតាមប្រទេសមួយចំនួនមានការកំណត់ថា កិច្ចសន្យាលក់ទិញរបស់ដែលមានតម្លៃថ្លៃត្រូវបង្កើតដោយមានលិខិតកិច្ចសន្យាជាចាំបាច់ដែលជាលក្ខខណ្ឌទម្រង់ ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន មិនតម្រូវឱ្យធ្វើលិខិតកិច្ចសន្យានោះទេ។ ដូចនេះ ទោះបីជាកិច្ចសន្យាលក់ទិញអចលនវត្ថុដែលមានតម្លៃខ្លាំងក៏ដោយ ក៏ត្រូវបង្កើតឡើងដោយការត្រូវគ្នានៃការបង្ហាញឆន្ទៈប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ ភាគីតែងធ្វើជាលិខិតកិច្ចសន្យា ដើម្បីបន្សល់ទុកនូវភស្តុតាងសម្រាប់ខ្លួនឯង។ ហើយក៏មានករណីដែលការទិញអចលនវត្ថុដែលមានការចូលរួមពីភ្នាក់ងារ ជាដើម គឺត្រូវអនុវត្តដោយយោងតាមច្បាប់ស្តីពីភ្នាក់ងារអចលនវត្ថុ ហើយផ្អែកតាមច្បាប់ពិសេសនីមួយៗនេះ ភ្នាក់ងារអចលនវត្ថុមានករណីយកិច្ចត្រូវធ្វើលិខិតកិច្ចសន្យា)។

ជាករណីលើកលែងប្រភេទនៃកិច្ចសន្យាផ្សេងទៀត គឺកិច្ចសន្យាដែលកើតឡើងតាមការប្រគល់វត្ថុ ដែលមិនមែនជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀងនោះទេ។ នេះមានន័យថា បើគ្រាន់តែការបង្ហាញឆន្ទៈត្រូវគ្នានៅមិនទាន់គ្រប់គ្រាន់នោះទេ ហើយអានុភាពនៃការបង្កើតនឹងមានចាប់ពីពេលដែលវត្ថុជាកម្មវត្ថុត្រូវបានប្រគល់។ ប៉ុន្តែ នៅក្នុងវិសោធនកម្មច្បាប់ឆ្នាំ2017 នេះ មានកិច្ចសន្យាកើតឡើងតាមការប្រគល់វត្ថុមួយចំនួនបានប្តូរមកជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀងវិញ។ ឧទាហរណ៍ នៅក្នុងករណីកិច្ចសន្យាឱ្យខ្ចី និង ឱ្យប្រើប្រាស់វត្ថុធម្មតា ដែលជាកិច្ចសន្យាខ្ចីប្រើ (មាត្រា593) ការព្រមព្រៀងខ្ចី និង ឱ្យខ្ចីមិននាំឱ្យបង្កើតកិច្ចសន្យានោះទេ ហើយចាប់ពីពេលដែលវត្ថុជាកម្មវត្ថុបានប្រគល់ជាក់ស្តែង ទើបកិច្ចសន្យាត្រូវបានបង្កើតឡើង។ ប៉ុន្តែ គេបានប្តូរមកជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀងវិញ ដោយប្រកាន់ជំហរចម្បងលើការបានព្រមព្រៀងគ្នា។

លើសពីនេះ ដូចបានរៀបរាប់ខាងលើនេះ នៅក្នុងករណីដែលច្បាប់បានកំណត់ឱ្យកិច្ចសន្យាកើតឡើង ដោយត្រូវមានទម្រង់ជាក់លាក់ណាមួយ (ឧទាហរណ៍ ការធ្វើជាលាយលក្ខណ៍អក្សរ) ហៅថាកិច្ចសន្យាកើតឡើងតាមទម្រង់ (នៅក្នុងក្រមរដ្ឋប្បវេណី មានកិច្ចសន្យាធានា។ មាត្រា446 កថាខណ្ឌទី2)។

### (3) កិច្ចសន្យាអញ្ញមញ្ញ និង កិច្ចសន្យាឯកតោភាគី

បន្ទាប់មក យើងអាចបែងចែកជាប្រភេទកិច្ចសន្យាអញ្ញមញ្ញ និង កិច្ចសន្យាឯកតោភាគី។ ដូចជាកិច្ចសន្យាលក់ទិញជាដើម ជាកិច្ចសន្យាដែលបង្កើតសិទ្ធិនិងកាតព្វកិច្ចដល់ភាគីទាំងសងខាង (មានន័យថា អ្នកលក់មានកាតព្វកិច្ចប្រគល់វត្ថុជាកម្មវត្ថុ ហើយអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃលក់ទិញ)។ ក្នុងន័យនេះ យើងហៅថាកិច្ចសន្យាអញ្ញមញ្ញ។ នៅក្នុងកិច្ចសន្យាជួលផ្ទះក៏ដោយ (សូមមើលនៅខាងក្រោម) ក៏ជាកិច្ចសន្យាអញ្ញមញ្ញផងដែរ ដោយអ្នកជួលមានកាតព្វកិច្ចបង់ថ្លៃឈ្នួល និង ប្រគល់ផ្ទះវិញនៅពេលបញ្ចប់កិច្ចសន្យា ហើយអ្នកឱ្យជួលមានកាតព្វកិច្ចបន្តជួលនូវវត្ថុដែលជាកម្មវត្ថុ ក្នុងស្ថានភាពអាចប្រើប្រាស់បាន។

ផ្ទុយមកវិញ កិច្ចសន្យាប្រទានកម្ម (សូមមើលនៅខាងក្រោម) កើតឡើងតាមការព្រមព្រៀងគ្នាថា «ព្រមឱ្យ–ព្រមទទួល» ប៉ុន្តែ ភាគីដែលព្រមទទួលមិនមានកាតព្វកិច្ចអ្វីនោះទេ ហើយភាគីទាយកតែម្ខាងប៉ុណ្ណោះដែលមានកាតព្វកិច្ចប្រគល់។ កិច្ចសន្យាខ្ចីប្រើដែលបានលើកឡើងមុននេះក៏ដូចគ្នាផងដែរថា ក្រោយពេលកិច្ចសន្យាបានបង្កើតឡើងតាមការប្រគល់វត្ថុរួចហើយ ភាគីអ្នកខ្ចីតែម្ខាងប៉ុណ្ណោះដែលមានកាតព្វកិច្ចសងវិញ។ ក្នុងន័យដែលកាតព្វកិច្ចមានទៅលើភាគីតែម្ខាងនេះហើយ ទើបគេហៅថា កិច្ចសន្យាឯកតោភាគី។ ការបែងចែកប្រភេទបែបនេះមានសារៈសំខាន់ណាស់ ដោយសារបញ្ញត្តិមួយចំនួនស្តីពីអានុភាពនៃកិច្ចសន្យា និង ការរំលាយ ត្រូវយកមកប្រើប្រាស់ចំពោះតែកិច្ចសន្យាអញ្ញមញ្ញប៉ុណ្ណោះ។

### (4) កិច្ចសន្យាដែលយកតម្លៃថ្នូរ (មូលា) និង កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ (មុជា)

ការបែងចែកប្រភេទមួយទៀតគឺ កិច្ចសន្យាដែលយកតម្លៃថ្នូរ និង កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។ វាគឺជាការបែងចែកថា តើកិច្ចសន្យានេះមានការផ្តល់តម្លៃតបទៅវិញទៅមកដូចជាការប្រគល់ទំនិញ និង ថ្លៃលក់ទិញនៅក្នុងកិច្ចសន្យាលក់ទិញដែរឬទេ (ការផ្តល់តម្លៃតបនេះមិនចាំបាច់រហូតទាល់តែសមស្របតាមតម្លៃសេដ្ឋកិច្ចជាសច្ចានុម័តនោះទេ ហើយឱ្យតែភាគីទាំងសងខាងយល់ថាជាតម្លៃសមស្របគឺគ្រប់គ្រាន់ហើយ)? ឬក៏ជាកិច្ចសន្យាដែលភាគីតែម្ខាងផ្តល់ទ្រព្យសម្បត្តិដោយគ្មានការផ្តល់តម្លៃតបវិញដូចក្នុងកិច្ចសន្យាប្រទានកម្ម។

ការបែងចែកនេះ ក៏មានសារៈសំខាន់ផងដែរ។ នេះមានន័យថា កម្រិតនៃការទទួលខុសត្រូវក្នុងការធានាដែលនឹងលើកយកមករៀបរាប់នៅពេលក្រោយ ប្រែប្រួលអាស្រ័យទៅលើថា តើជាកិច្ចសន្យាដែលយកតម្លៃថ្នូរ ឬ កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ (នៅក្នុងកិច្ចសន្យាយកតម្លៃថ្នូរ ដូចជាកិច្ចសន្យាលក់ទិញ គឺមានការទទួលខុសត្រូវក្នុងការធានាខ្លាំង ហើយអ្នកលក់ត្រូវមានទំនួលខុសត្រូវ ក្នុងករណីដែលវត្ថុដែលបានប្រគល់ពីការលក់ទិញមិនស្របនឹងតម្លៃនៃថ្លៃលក់ទិញ។ ផ្ទុយមកវិញ កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ដូចជាកិច្ចសន្យាប្រទានកម្ម ត្រូវបានបញ្ញត្តឡើងដោយកំណត់ឱ្យមានការទទួលខុសត្រូវស្រាល ក្នុងន័យថា វត្ថុដែលទទួលបានមកដោយទទេ បើទោះបីជាមានស្នាមបន្តិចបន្តួចក៏ដោយ ក៏ទ្រាំទទួលយកទៅ)។

## 3. អានុភាពនៃកិច្ចសន្យា

### (1) សុពលភាពនៃកិច្ចសន្យា

តាមពិតទៅ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនមិនមានបញ្ញត្តិមូលដ្ឋានស្តីពីអានុភាព ឬ សុពលភាពនៃកិច្ចសន្យានោះទេ។ ដើម្បីឱ្យកិច្ចសន្យាមានអានុភាព កិច្ចសន្យាត្រូវមានខ្លឹមសារដែលស្របច្បាប់ (ភាពស្របច្បាប់), អាចអនុវត្តបាន (ភាពអាចអនុវត្តបាន) និង ជាក់លាក់ (ភាពជាក់លាក់)។ ដូចជាកិច្ចសន្យាលក់ទិញអគារដែលបានឆេះបាត់ទៅហើយនៅពេលចុះកិច្ចសន្យាជាដើម។ ក្នុងករណីនេះ កម្មវត្ថុមិនមានអត្ថិភាពនោះទេ ហើយការអនុវត្តគឺគ្មានលទ្ធភាពតាំងពីដើម ហេតុនេះ កិច្ចសន្យានេះក្លាយជាមោឃភាពដោយសារអលទ្ធភាពតាំងពីដំបូង ហើយសិទ្ធិលើ

បំណុល និង កាតព្វកិច្ចមិនកើតមានឡើងនោះទេ។ ប៉ុន្តែ បើសិនជា អ្នកទិញបានជឿជាក់ថាខ្លួនអាចទទួលបាន អគារនោះ ហើយបានទិញគ្រឿងសម្ភារៈសម្រាប់អគារនោះដែលធ្វើឱ្យការខូចខាតកើតមានឡើង ក្នុងករណីនេះ ការទទួលខុសត្រូវនៃសំណងការខូចខាតដោយសារការជឿជាក់ ក្នុងនាមជា «**កំហុសនៃការចុះកិច្ចសន្យា**» នឹងកើតមានឡើង។ ដោយឡែក ចំពោះកិច្ចសន្យាអនុប្បទានសិទ្ធិលើបំណុលលើថ្លៃលក់ទិញដែលកើតចេញពីការលក់ទំនិញជាដើម មិនមែនអលទ្ធភាពពីដំបូងនោះទេ ហើយអាចបង្កើតបានដោយមានអានុភាព ប្រសិនបើយើងអាចទទួលស្គាល់ភាពជាក់លាក់នៃអំឡុងពេលកំណត់នៃការចាប់ផ្ដើម និង ការបញ្ចប់បាន។

### (2) **អានុភាពចង និង អានុភាពមិនដាច់ខាត**

អានុភាពជាមូលដ្ឋាននៃកិច្ចសន្យាគឺ បង្កើតអានុភាពចងរវាងភាគី ដោយផ្អែកលើការព្រមព្រៀងរបស់ភាគី (កិច្ចសន្យាគឺត្រូវតែគោរពជាដាច់ខាត ហើយនៅក្នុងកិច្ចពិភាក្សាអំពីការធ្វើវិសោធនកម្មនីតិសិទ្ធិលើបំណុលថ្មីៗនេះមានគំនិតជាច្រើនបានទទួលស្គាល់កាន់តែខ្លាំងអំពីអានុភាពចងទៅវិញទៅមក តាមរយៈការចុះកិច្ចសន្យានេះ។ វាគឺជាទំនោររបស់អន្តរជាតិផងដែរ)។ ដូចនេះ ប្រសិនបើភាគីម្ខាងទៀតមិនគោរពទេ គេអាចប្ដឹងទៅតុលាការដើម្បីបង្គាប់ឱ្យអនុវត្តដោយបង្ខំ ឬ បង្គាប់ឱ្យសងសំណងការខូចខាតជំនួសឱ្យការធ្វើសកម្មភាពដែលបានចងតាំងពីដើមនោះ (ពិតប្រាកដហើយថា យើងនឹងពិចារណាផ្សេងពីនេះ ប្រសិនបើភាគីបានព្រមព្រៀងគ្នាអំពីការសន្យាពិសេសដែលមិនឱ្យអនុវត្តដោយបង្ខំនៅក្នុងកិច្ចសន្យាជាដើម)។ លើសពីនេះ កិច្ចសន្យាមិនមានអានុភាពដាច់ខាតទេ ហើយជាគោលការណ៍ អានុភាពចងនេះកើតមានចំពោះតែភាគីនៃកិច្ចសន្យាប៉ុណ្ណោះ។ ប៉ុន្តែ បើសិនជានៅក្នុងកិច្ចសន្យាលក់ទិញរវាង A និង B បានបន្ថែមនូវការសន្យាពិសេសដែលត្រូវបង់ប្រាក់ថ្លៃលក់ទិញដោយផ្ទាល់ទៅ C។ ក្នុងស្ថានភាពបែបនេះ កិច្ចសន្យាដែលផ្ដល់ប្រយោជន៍ដល់តតិយជនក្រៅពីភាគីអាចធ្វើទៅបាន (នៅពេលក្រោយនឹងមានពន្យល់អំពីកិច្ចសន្យាដែលធ្វើសម្រាប់តតិយជន។ ចាប់ពីមាត្រា537) ប៉ុន្តែ ការព្រមព្រៀងដោយឱ្យតតិយជនមានករណីយកិច្ចជាដើម គឺមិនអាចធ្វើទៅបាននោះទេ។

### (3) **ការតវ៉ាឱ្យអនុវត្តព្រមគ្នា**

លើសពីនេះ នៅក្នុងករណីនៃកិច្ចសន្យាអញ្ញមញ្ញ ត្រូវបានគេកំណត់អំពីការតវ៉ាឱ្យអនុវត្តព្រមគ្នា ក្នុងនាមជាអានុភាពនៃអត្ថិភាពរបស់កិច្ចសន្យា។ នេះមានន័យថា បើក្នុងការលក់ទិញវិញ អ្នកទិញអាចតវ៉ា (ការអះអាង និងតតាំងចំពោះការទាមទាររបស់ភាគីម្ខាងទៀត) មិនព្រមបង់ប្រាក់ថ្លៃលក់ទិញរហូតដល់ពេលអ្នកលក់ប្រគល់ទំនិញបាន។ ផ្ទុយមកវិញ អ្នកលក់ក៏អាចតវ៉ាមិនព្រមប្រគល់ទំនិញរហូតដល់ពេលអ្នកទិញបង់ថ្លៃលក់ទិញដែរ (មាត្រា533។ អាចអនុវត្តបានរហូតដល់ពេលដែលភាគីម្ខាងទៀតបានស្នើអនុវត្ត ពោលគឺ រហូតដល់ពេលដែលកាន់ប្រាក់ថ្លៃលក់ទិញមកជាមួយបាន)។ ដូចនេះ ការតវ៉ាឱ្យអនុវត្តព្រមគ្នាទៅវិញទៅមក នឹងក្លាយទៅជាការជម្រុញឱ្យអនុវត្តទៅវិញទៅមក ហើយជាលទ្ធផល វានឹងក្លាយជាការផ្ដល់តាវកាលិកតប។ ពិតប្រាកដហើយ បើសិនជាភាគីបានសម្រេចជាមុនថាត្រូវបង់ប្រាក់ថ្លៃលក់ទិញជាមុនដោយហេតុផលណាមួយនោះ ក្នុងករណីនេះ ភាគីត្រូវគោរពតាម

ការកំណត់នោះ ហេតុនេះ ការតវ៉ាឱ្យអនុវត្តព្រមគ្នាមិនអាចប្រើប្រាស់បាននោះទេ ក្នុងស្ថានភាពបែបនេះ។ ដោយឡែក ភាគីដែលអះអាងអំពីការតវ៉ាឱ្យអនុវត្តព្រមគ្នាមិនមានទំនួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ ទោះបីជាខកខានក្នុងការអនុវត្តនៅពេលនោះក៏ដោយ (សូមមើលចំណុចទី 4 ក្នុងជំពូកនេះ ចំពោះការរំលាយកិច្ចសន្យា និង ការទាមទារសំណងការខូចខាតដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច)។

### (4) ការទទួលបន្ទុកហានិភ័យ

នៅក្នុងប្រព័ន្ធដែលកំណត់អំពីទំនាក់ទំនងកាតព្វកិច្ចទាំងសងខាងនៃកិច្ចសន្យាអញ្ញមញ្ញ នៅមានចំណុចមួយទៀត ដែលហៅថា ការទទួលបន្ទុកហានិភ័យ។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាទិញលក់ផ្ទះលំហែមួយ ដែលផ្ទះលំហែនោះត្រូវបានឆេះអស់ដោយសារតែបន្ទុះភ្នំភ្លើង នៅក្នុងចន្លោះពេលនៃការចុះកិច្ចសន្យា និងមុនពេលកាលបរិច្ឆេទនៃការប្រគល់ ហើយកម្មវត្ថុនៃកិច្ចសន្យាបានបាត់បង់ដោយគ្មានហេតុនៃការទទួលខុសត្រូវរបស់កូនបំណុលនោះទេ តាំងពីពេលចុះកិច្ចសន្យារហូតដល់ពេលប្រគល់ (វាមិនមានហេតុនៃការទទួលខុសត្រូវ ហេតុនេះហើយ វាមិនមែនជាការមិនអនុវត្តកាតព្វកិច្ចដូចរៀបរាប់ខាងក្រោមនោះទេ) ក្នុងករណីនេះ ចំណុចបញ្ហាគឺ តើកូនបំណុលដែលជាអ្នកលក់ និង ម្ចាស់បំណុលដែលជាអ្នកទិញ អ្នកណាត្រូវទទួលបន្ទុកនូវការខូចខាតនោះ? នេះមានន័យថា កាតព្វកិច្ចរបស់កូនបំណុលដែលជាអ្នកលក់ត្រូវក្លាយជាអលទ្ធភាពក្នុងការអនុវត្ត ហើយរលត់ ដោយសារតែគ្មានវត្ថុសម្រាប់ជំនួសបាន ហើយកូនបំណុលគ្មានហេតុនៃការទទួលខុសត្រូវទេ ហេតុនេះហើយ មិនចាំបាច់សងសំណងការខូចខាតនោះទេ (ផ្ទុយមកវិញ ប្រសិនបើកូនបំណុលមានហេតុនៃការទទួលខុសត្រូវ វានឹងក្លាយជាការមិនអនុវត្តកាតព្វកិច្ច។ ហេតុនេះកាតព្វកិច្ចរបស់កូនបំណុលនឹងត្រូវបន្តអត្ថិភាព ដោយប្តូរជាកាតព្វកិច្ចសងសំណងការខូចខាតវិញ សូមមើល 4(1)(2))។ ប៉ុន្តែ បញ្ហាគឺ តើអ្នកទិញដែលជាភាគីម្ខាងទៀតត្រូវបង់ប្រាក់ថ្លៃលក់ទិញតាមការកំណត់ក្នុងកិច្ចសន្យាដែរឬទេ?



ដើមឡើយ ភាគីត្រូវកំណត់អំពីចំណុចនេះក្នុងកិច្ចសន្យា ប៉ុន្តែ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីការទទួលបន្ទុកហានិភ័យ ដើម្បីការពារករណីភាគីមិនបានកំណត់ទុកជាមុន។ នៅក្នុងការធ្វើវិសោធនកម្មឆ្នាំ2017 បញ្ញត្តិជាច្រើនបានកែប្រែ ហើយកូនបំណុលត្រូវទទួលបន្ទុកហានិភ័យចំពោះកិច្ចសន្យាទាំងអស់ (របបកូនបំណុល)។ ប៉ុន្តែ បញ្ញត្តិចាស់ដែលកំណត់ថា «កាតព្វកិច្ចតបត្រូវរលត់» នៅក្នុងការទទួលបន្ទុកហានិភ័យនេះ ត្រូវប្តូរមក «ម្ចាស់បំណុលមានសិទ្ធិបដិសេធក្នុងការអនុវត្តតាវកាលិកតប» វិញ (តាមរចនាសម្ព័ន្ធនៃសិទ្ធិបដិសេធក្នុងការអនុវត្ត។ មាត្រា536 កថាខណ្ឌទី1។ បញ្ញត្តិនៃរបបម្ចាស់បំណុល ចំពោះកិច្ចសន្យាស្តីពីការផ្ទេរកម្មសិទ្ធិលើវត្ថុជាក់លាក់នៅក្នុងកិច្ចសន្យាលក់ទិញជាដើម ត្រូវបានលុបចោល)។ ដូចនេះ បើសិននិយាយអំពីការលក់ទិញគឺ ហានិភ័យនៃការបាត់បង់វត្ថុជាកម្មវត្ថុ ត្រូវក្លាយជាបន្ទុករបស់អ្នកលក់ (កូនបំណុលនៃការប្រគល់)។ របបម្ចាស់បំណុលនេះ (កម្មវត្ថុមិនបានមកលើដៃរបស់ខ្លួនផង តែត្រូវបង់ប្រាក់ថ្លៃលក់ទិញ) រងការរិះគន់យ៉ាងខ្លាំង ហេតុនេះ ខ្ញុំយល់ថាការលុបចោលចំណុចនេះ គឺត្រឹមត្រូវ។ មូលហេតុដែលនាំឱ្យបញ្ញត្តិនេះត្រូវប្តូរមកប្រើប្រាស់រចនាសម្ព័ន្ធសិទ្ធិបដិសេធក្នុងការអនុវត្តវិញ ដោយសារតែចំណុចនេះមានលក្ខណៈជាន់គ្នានឹងបញ្ញត្តិ និង លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា (កាលពីមុន ការរំលាយគឺតម្រូវឱ្យមានហេតុនៃការទទួលខុសត្រូវ ប៉ុន្តែ នៅក្នុងការធ្វើវិសោធនកម្មលើកនេះ ហេតុនៃការទទួលខុសត្រូវមិនមែនជាបញ្ហានៅក្នុងការរំលាយទៀតនោះទេ), ហើយរឿងក្តីនៃការទទួលបន្ទុកហានិភ័យដែលគ្មានហេតុនៃការទទួលខុសត្រូវរបស់ភាគីទាំងសងខាងនេះ ក៏អាចចាត់ចែងតាមការរំលាយកិច្ចសន្យាផងដែរ (នៅក្នុងចំណុចនេះ គឺជាទ្រឹស្តីសិក្សាខ្លាំង ហើយមិនមានជាការធ្វើវិសោធនកម្មដែលងាយស្រួលយល់សម្រាប់ប្រជាពលរដ្ឋនោះទេ)។ ដូចនេះ ម្ចាស់បំណុលអាចរំលាយកិច្ចសន្យាក៏បាន ឬបដិសេធក្នុងការអនុវត្តនៅក្នុងបន្ទុកហានិភ័យក៏បាន។ ដោយឡែក បើសិនជាកិច្ចសន្យាអញ្ញមញ្ញដែលមិនបង្កើត ឬ ផ្ទេរកម្មសិទ្ធិ ដូចជាកតិសន្យាជាដើមវិញ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា536 នៅមុនពេលវិសោធនកម្មនៅរក្សាដដែល ហើយរបបកូនបំណុលមិនបានផ្លាស់ប្តូរនោះទេ។

សូមបញ្ជាក់ថា ការទទួលបន្ទុកហានិភ័យ គឺជាបញ្ហាដែលបានកើតមានឡើងក្នុងចន្លោះពេលនៃការចុះកិច្ចសន្យារហូតដល់ពេលប្រគល់។ បើសិនជាបានប្រគល់ចប់សព្វគ្រប់ហើយ ហានិភ័យត្រូវផ្ទេរទៅអ្នកទិញវិញ បើសិនជាយើងនិយាយអំពីការលក់ទិញ (ក្រោយពេលប្រគល់ បើទោះបីជាកម្មវត្ថុត្រូវឆេះបាត់បង់ក៏ដោយ ក៏អ្នកទិញត្រូវទទួលបន្ទុក ហើយមិនអាចរួចផុតពីករណីយកិច្ចបង់ប្រាក់ថ្លៃលក់ទិញនោះទេ។ មាត្រា567)។

ពាក្យគន្លឹះ: **ការទទួលបន្ទុកហានិភ័យ៖ របបម្ចាស់បំណុល និង របបកូនបំណុល**

បញ្ហានៃការទទួលបន្ទុកហានិភ័យកើតមាននៅក្នុងកិច្ចសន្យាអញ្ញមញ្ញ។ នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ទាំងសិទ្ធិលើបំណុល ទាំងកាតព្វកិច្ចកើតឡើងចំពោះភាគីទាំងសងខាង។ ហេតុនេះ នៅពេលនិយាយអំពី ការទទួលបន្ទុកហានិភ័យដោយរបបម្ចាស់បំណុល (ម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ) ឬ របបកូនបំណុល (កូនបំណុលត្រូវទទួលបន្ទុកហានិភ័យ) សូមកុំច្រឡំអំពីម្ចាស់បំណុល និង កូនបំណុល។ គេអាចដឹងអំពីម្ចាស់បំណុល ឬ កូន

បំណុលអាស្រ័យទៅលើតម្លៃទ្រព្យសម្បត្តិដែលបានបាត់បង់។ បើនិយាយអំពីឧទាហរណ៍នៃផ្ទះលំហែវិញ វាមានន័យថា អ្នកទិញដែលមានសិទ្ធិលើបំណុលទាមទារឱ្យប្រគល់ផ្ទះលំហែ គឺជាម្ចាស់បំណុល ហើយអ្នកលក់ដែលមានករណីយកិច្ចប្រគល់ផ្ទះលំហែរនោះ គឺជាកូនបំណុល។ ដូចនេះ របបម្ចាស់បំណុល សំដៅទៅលើស្ថានភាពដែលម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ មានន័យថា អ្នកទិញដែលជាម្ចាស់បំណុលមិនអាចទទួលបានការប្រគល់ផ្ទះលំហែនោះទេ (ករណីយកិច្ចអនុវត្តរបស់អ្នកលក់ដែលជាកូនបំណុលត្រូវរលត់) ប៉ុន្តែ កាតព្វកិច្ចបង់ប្រាក់ថ្លៃលក់ទិញមិនរលត់នោះទេ ហើយត្រូវបន្តអត្ថិភាព។ បើសិនជារបបកូនបំណុលវិញ កូនបំណុលត្រូវទទួលបន្ទុកហានិភ័យ ហើយមិនអាចទទួលបានតាវកាលិកតបនោះទេ។ ការវិសោធនកម្មច្បាប់បានប្រកាន់យកគោលជំហរនេះ ហើយបានបញ្ញត្តថា «ម្ចាស់បំណុលអាចបដិសេធក្នុងការអនុវត្តការផ្តល់តាវកាលិកតបបាន»។

### (5) **កិច្ចសន្យាធ្វើឡើងដើម្បីតតិយជន**

ឧទាហរណ៍ថា នៅក្នុងកិច្ចសន្យាលក់ទិញរវាង A និង B បានបន្ថែមការសន្យានៃការបង់ប្រាក់ថ្លៃលក់ទិញដោយផ្ទាល់ទៅឱ្យ C ហើយវាជាកិច្ចសន្យាដែលផ្តល់ប្រយោជន៍ដល់តតិយជនក្រៅពីភាគីបែបនេះ ហៅថាកិច្ចសន្យាធ្វើឡើងដើម្បីតតិយជន (ចាប់ពីមាត្រា537)។




នេះជាប្រភេទមួយនៃកិច្ចសន្យាផងដែរ ប៉ុន្តែ ខ្លឹមសារប៉ុណ្ណឹងមិនអាចយកធ្វើជាកិច្ចសន្យាឯករាជ្យបានទេ ហើយវាត្រូវភ្ជាប់ជាមួយកិច្ចសន្យាផ្សេងទៀត ក្នុងនាមជា**ការសន្យាពិសេស** ឬ ជា**ការសន្យាបន្ថែម**។ វាត្រូវបានបញ្ញត្តឡើងក្នុងនាមជាករណីអញ្ញត្តិកម្មនៃគោលគំនិតទូទៅរបស់អានុភាពនៃកិច្ចសន្យា (គ្មានអានុភាពទៅលើបុគ្គលក្រៅពីភាគីនោះទេ) ដោយសារតែអានុភាពនៃកិច្ចសន្យាមានទៅដល់តតិយជន។ ប៉ុន្តែ កិច្ចសន្យាប្រភេទនេះមានការកម្រិតដូចតទៅ ៖ ① ភាគីអាចធ្វើកិច្ចសន្យាដែលផ្តល់ផលប្រយោជន៍ដល់តតិយជន C បាន ប៉ុន្តែ មិនអាចព្រមព្រៀងគ្នាផ្តល់កាតព្វកិច្ចជាអវិជ្ជមានដល់ C នោះទេ។ ② តតិយជន C ដែលជាអ្នកទទួលផលប្រយោជន៍ មិនអាចទទួលផល

ប្រយោជន៍ពីការព្រមព្រៀងរវាង A និង B ដោយឯកឯងនោះទេ ពោលគឺ តតិយជន C ត្រូវបង្ហាញឆន្ទៈទទួលក្នុងការទទួលផលប្រយោជន៍នោះ (**ការបង្ហាញឆន្ទៈទទួលផលប្រយោជន៍**)។ ③ នៅពេលមានការបង្ហាញឆន្ទៈទទួលផលប្រយោជន៍ A និង B មិនអាចដកការព្រមព្រៀងវិញទេ ប៉ុន្តែ ការដកការសន្យាវិញអាចធ្វើបានរហូតដល់ពេលមានការបង្ហាញឆន្ទៈទទួលផលប្រយោជន៍។ ដោយឡែក ក្រោយពេលបង្ហាញឆន្ទៈទទួលផលប្រយោជន៍ អ្នកទទួលផលប្រយោជន៍អាចទាមទារឱ្យផ្តល់តាវកាលិកដោយផ្ទាល់ទៅកាន់កូនបំណុលបាន ប៉ុន្តែ កូនបំណុលក៏អាចអះអាងអំពីការតវ៉ាទាំងអស់ដែលមានចំពោះម្ចាស់បំណុលទៅកាន់អ្នកទទួលផលប្រយោជន៍បាន (ឧទាហរណ៍ អ្នកលក់ A និងអ្នកទិញ B បានចុះកិច្ចសន្យាលក់ទិញជាមួយគ្នា ហើយបានធ្វើកិច្ចសន្យាដើម្បីតតិយជនដែលមានខ្លឹមសារថា «ថ្លៃលក់ទិញត្រូវបង់ដោយផ្ទាល់ទៅ C»។ ហើយ C បានទាមទារឱ្យ B បង់ប្រាក់ក្រោយពេលដែលខ្លួនបានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ ប៉ុន្តែ B មិនទាន់បានទទួលការប្រគល់ទំនិញពី A នោះទេ។ ប្រសិនបើ B អាចអះអាងអំពីការតវ៉ាឱ្យអនុវត្តព្រមគ្នាចំពោះ A , ក្នុងករណីនេះ B ក៏អាចអះអាងអំពីការតវ៉ាឱ្យអនុវត្តព្រមគ្នានេះចំពោះ C ផងដែរ។

## 4. ការមិនអនុវត្តកាតព្វកិច្ច និង ការរំលាយកិច្ចសន្យា

ប្រសិនបើភាគីម្ខាងទៀតមិនគោរពកិច្ចសន្យា ហើយមិនបានអនុវត្តកាតព្វកិច្ច តើយើងគួរធ្វើយ៉ាងណា? ប្រាកដហើយថា យើងអាចពឹងពាក់តុលាការ ហើយអនុវត្តដោយបង្ខំបាន (ហៅថា ការអនុវត្តដោយបង្ខំ) ប៉ុន្តែ បើសិនជាមិនអាចធ្វើទាន់ពេល ឬ ភាគីម្ខាងទៀតបានធ្វើឱ្យបាត់បង់កម្មវត្ថុទៅហើយ ហើយការអនុវត្តក្លាយទៅជាអលទ្ធភាព ក្នុងករណីនេះ តើយើងគួរធ្វើយ៉ាងណាដែរ? ក្នុងករណីនេះ តាមក្រមរដ្ឋប្បវេណី យើងមាន 2 វិធី។ វិធីទីមួយគឺ ការទាមទារសំណងការខូចខាតដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ហើយវិធីមួយទៀតគឺ ការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច។ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនបានអនុញ្ញាតឱ្យរើសយកការរំលាយ ឬ ការទាមទារសំណងការខូចខាតក៏បាន ឬ រើសយកទាំងពីរវិធី ក៏បានដែរ (មាត្រា545 កថាខណ្ឌទី4)។ ប៉ុន្តែ បញ្ញត្តិស្តីពីសំណងការខូចខាតស្ថិតនៅក្នុងវិសាលភាពនៃនីតិសិទ្ធិលើបំណុលទូទៅ ហើយបញ្ញត្តិស្តីពីការរំលាយស្ថិតនៅក្នុងវិសាលភាពនៃនីតិសិទ្ធិលើបំណុលពិសេស ហេតុនេះ នៅទីនេះ ខ្ញុំនឹងពន្យល់ចំណុចទាំងនេះរួមគ្នាតែម្តង។

### (1) ប្រភេទនៃការមិនអនុវត្តកាតព្វកិច្ច

កន្លងមកនេះ គេបានពន្យល់ថា ដើម្បីឱ្យកូនបំណុលទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចតាមក្រមរដ្ឋប្បវេណី លុះត្រាតែ កូនបំណុលត្រូវតែមានហេតុនៃការទទួលខុសត្រូវ (ហេតុនៃការទទួលខុសត្រូវ) ប៉ុន្តែ វិសោធនកម្មឆ្នាំ2017 បានកែប្រែចំណុចនេះ ហើយផ្តោតសំខាន់ទៅលើអានុភាពចងនៃកិច្ចសន្យា។ នេះមានន័យថា បើសិនជាមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាទេ វានឹងក្លាយជាការមិនអនុវត្តកាតព្វកិច្ច ប៉ុន្តែ បើសិនជាអាចទទួលស្គាល់បានថា ផ្អែកតាមខ្លឹមសារនៃកិច្ចសន្យា និង ទស្សនសង្គមទូទៅ កូនបំណុលគ្មានហេតុនៃការទទួលខុសត្រូវនោះទេ ក្នុងករណីនេះ កូនបំណុលអាចរួចផុតពីការទទួលខុសត្រូវបាន (ហេតុនៃការទទួលខុសត្រូវ មិនមែនជាលក្ខខណ្ឌនៃការមិនអនុវត្តកាតព្វកិច្ចនោះទេ ប៉ុន្តែ វាគឺជាលក្ខខណ្ឌដើម្បីរួចផុតពីការទទួលខុសត្រូវ)។ ដូចនេះ ការ

ខកខានមិនបានអនុវត្តដោយសារតែគ្រោះថ្នាក់ធម្មជាតិដូចជា រញ្ជួយដី ឬ បន្ទុះភ្នំភ្លើង ជាអាទិ៍ មិនអាចក្លាយជាការមិនអនុវត្តកាតព្វកិច្ចក្នុងន័យខាងលើនោះទេ។ ចំពោះសកម្មភាពរបស់អ្នកជំនួយក្នុងការអនុវត្តកិច្ចសន្យាដែលមិនមែនជាសាមីភាគីនៃកិច្ចសន្យាក៏ដោយ ក៏ការកំណត់ថាជាការមិនអនុវត្តកាតព្វកិច្ច និង ការកំណត់ថាមានហេតុនៃការទទួលខុសត្រូវ គឺត្រូវអនុវត្តដូចខាងលើនេះ។

ការមិនអនុវត្តកាតព្វកិច្ចអាចបែងចែកជា 3ប្រភេទគឺ ① ការអនុវត្តយឺតយ៉ាវ គឺជាការអនុវត្តហួសពេលកំណត់ដែលបានសន្យា, ② អលទ្ធភាពក្នុងការអនុវត្ត គឺជាការអនុវត្តក្លាយទៅជាមិនអាចធ្វើទៅបាន, ហើយ ③ ការអនុវត្តមិនពេញលេញ គឺជាការអនុវត្តណាមួយក្នុងពេលកំណត់ដែរ ប៉ុន្តែ អនុវត្តមិនដូចទៅនឹងខ្លឹមសារនៃកិច្ចសន្យា ឬ មិនបានពេញលេញ។

### (2) សំណងការខូចខាត

ចំពោះការអនុវត្តយឺតយ៉ាវ បើសិនជាយឺតយ៉ាវក៏ដោយ តែក្រោយមកបានអនុវត្តចប់សព្វគ្រប់ ក្នុងករណីនេះភាគីត្រូវសងសំណងការខូចខាតដែលបានកើតឡើងក្នុងអំឡុងពេលយឺតយ៉ាវនោះ (នេះហៅថា **សំណងចំពោះការយឺតយ៉ាវ**)។ ចំពោះអលទ្ធភាពនៃការអនុវត្ត ភាគីត្រូវសងសំណងជាប្រាក់ជំនួសឱ្យតាវកាលិកដែលត្រូវប្រគល់ (នេះហៅថា **សំណងការខូចខាតជំនួស**)។ ក្រមរដ្ឋប្បវេណីជប៉ុនបានបញ្ញត្តអំពីទំហំនៃសំណងការខូចខាត ក្នុងមាត្រា416 ដោយបែងចែកជា **ការខូចខាតធម្មតា** និង **ការខូចខាតពិសេស**។ ការខូចខាតដែលកើតឡើងជាធម្មតា គឺស្ថិតនៅក្នុងទំហំនៃសំណងការខូចខាតទាំងមូល ចំណែកឯការខូចខាតដែលកើតឡើងក្នុងកាលៈទេសៈពិសេសវិញ ត្រូវបែងចែកជា ករណីដែលភាគីអាចព្យាករណ៍បាន ឬ ករណីដែលភាគីមិនអាចព្យាករបាន (អាស្រ័យលើលទ្ធភាពនៃការប៉ាន់ស្មានជាមុន) ហើយផ្នែកនៃការខូចខាតដែលអាចព្យាករណ៍បាន គឺស្ថិតនៅក្នុងទំហំនៃសំណងការខូចខាត។ ការកំណត់ថាជា ការខូចខាតធម្មតា ឬ ការខូចខាតពិសេស គឺអាស្រ័យទៅលើរឿងក្តីនីមួយៗ។ បើសិនជាយើងលើកឧទាហរណ៍អំពីការទិញផ្ទះ ហើយការប្រគល់ផ្ទះនោះយឺតយ៉ាវ 1ខែ ហេតុនេះ អ្នកទិញត្រូវជួលផ្ទះស្នាក់នៅក្នុងអំឡុងពេល 1ខែនោះ។ ក្នុងករណីនេះ ជាទូទៅគេនឹងទទួលស្គាល់ថា ថ្លៃឈ្នួលផ្ទះគឺជាការខូចខាតធម្មតា។ ប៉ុន្តែ បើសិនជាការទិញផ្ទះនោះធ្វើឡើងដោយបានសន្យាថានឹងលក់បន្តទៅឱ្យបុគ្គលផ្សេងក្នុងតម្លៃខ្ពស់ ប៉ុន្តែ ការលក់បន្តមិនអាចធ្វើទៅបានដោយសារតែការប្រគល់យឺតយ៉ាវ។ ហេតុនេះ បើសិនជាអ្នកទិញទាមទារសំណងដែលជាផលប្រយោជន៍ពីការលក់បន្តនោះ វាគឺជាការខូចខាតពិសេស (បើសិនជាអ្នកទិញ គឺជាបុគ្គលទូទៅ)។ ក្នុងករណីនេះ ការខូចខាតនេះនឹងត្រូវបញ្ចូលក្នុងទំហំនៃសំណង ប្រសិនបើអ្នកលក់អាចព្យាករជាមុនបានថា អ្នកទិញនឹងលក់បន្តនេះ។

**ទំហំនៃសំណងការខូចខាត**




### (3) ការរំលាយកិច្ចសន្យា

វិធីដោះស្រាយមួយទៀត គឺការរំលាយកិច្ចសន្យា។ ការរំលាយកិច្ចសន្យានេះ សំដៅទៅលើការធ្វើឱ្យកិច្ចសន្យាមិនមានតាំងពីដំបូង ដោយម្ចាស់បំណុលដែលជាភាគីរងការមិនអនុវត្តកាតព្វកិច្ច បង្ហាញឆន្ទៈតែម្ខាងទៅកាន់កូនបំណុល (មានន័យថា ការរំលាយកិច្ចសន្យាក្នុងន័យសកម្មភាពគតិយុត្តិ វាជាប្រភេទនៃសកម្មភាពឯកតោភាគីរបស់បុគ្គលតែម្នាក់)។ នៅពេលដែលបង្ហាញឆន្ទៈនេះ អានុភាពនៃការធ្វើ**បដិទាន**កើតឡើងចំពោះភាគី (បដិទានមានន័យថា ស្ថានភាពតាំងពីដំបូង)។ ដូចនេះ ករណីយកិច្ចធ្វើឱ្យត្រឡប់ទៅស្ថានភាពមុនពេលចុះកិច្ចសន្យា គឺកើតមានឡើង (មាត្រា545 កថាខណ្ឌទី1 វាក្យខណ្ឌទី1)។ ប៉ុន្តែ អានុភាពនៃបដិទានមិនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់តតិយជនបានឡើយ។ មានន័យថា បើសិនជាតតិយជនបានទិញទំនិញនោះបន្តពីអ្នកទិញ ហើយបានបំពេញលក្ខខណ្ឌតតាំងរួចរាល់នៅមុនពេលរំលាយកិច្ចសន្យា ក្នុងករណីនេះ ការបដិទានមិនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដែលបុគ្គលនោះទទួលបានឡើយ (មាត្រា545 កថាខណ្ឌទី1 វាក្យខណ្ឌទី2)។

ដោយឡែក អានុភាពប្រតិសកម្ម ពោលគឺអានុភាពដែលធ្វើឱ្យត្រឡប់ទៅស្ថានភាពដើមដែលគ្មានកិច្ចសន្យា នឹងកើតមានឡើងចំពោះកិច្ចសន្យាណាដែលអនុវត្តតែម្តងចប់ប៉ុណ្ណោះ ដូចជា កិច្ចសន្យាលក់ទិញ ជាដើម។ ប៉ុន្តែ ចំពោះការរំលាយកិច្ចសន្យាដែលអនុវត្តជាបន្តបន្ទាប់ ដូចជាកិច្ចសន្យាជួល ជាដើមវិញ, វាមិនមានអានុភាពប្រតិសកម្មទេ ហើយអានុភាពនៃការរំលាយនឹងកើតមានឡើងនៅចំណុចពេលរំលាយឆ្ពោះទៅអនាគតប៉ុណ្ណោះ (ដោយសារតែ ការសងវិញនូវថ្លៃឈ្នួលដែលបានទទួលពីមុន និង ការសងវិញនូវផលប្រយោជន៍នៃការប្រើប្រាស់ពីមុន គឺពុំមានន័យនោះទេ)។

ជាគោលការណ៍ វិធីនៃការរំលាយកិច្ចសន្យាចំពោះករណីអនុវត្តយឺតយ៉ាវ ជំរុញឱ្យភាគីអនុវត្តម្តងទៀត ដោយកំណត់ពេលជាក់លាក់ជាមុនសិន (ហៅថា **ការដាស់តឿន**) ប៉ុន្តែ បើសិនជាធ្វើបែបនឹងហើយ នៅតែមិនព្រមអនុវត្តទៀត ទើបយើងអាចរំលាយកិច្ចសន្យាបាន (មាត្រា541)។ ប៉ុន្តែ នៅក្នុងកិច្ចសន្យាអាចមានចំណុចមួយដែលគេហៅថា **សកម្មភាពដែលកំណត់ពេលជាក់លាក់** ដែលមានខ្លឹមសារថា បើមិនធ្វើសកម្មភាពនោះក្នុងចំណុចពេលនេះទេ វានឹងគ្មានន័យនោះទេ (ឧទាហរណ៍ ការកម៉្មង់ម្ហូបការសម្រាប់ពិធីរៀបអាពាហ៍ពិពាហ៍)។ នៅក្នុងករណីបែបនេះ ការរំលាយកិច្ចសន្យាអាចធ្វើបានភ្លាមៗដោយមិនបាច់ដាស់តឿននោះទេ (មាត្រា542 កថាខណ្ឌទី1 ចំណុច4)។ ហើយករណីអលទ្ធភាពនៃការអនុវត្ត ក៏អាចរំលាយបានភ្លាមៗផងដែរ ដោយសារតែការដាស់តឿនឱ្យអនុវត្តចំពោះរបស់ដែលអលទ្ធភាពទៅហើយ គឺគ្មានន័យនោះទេ (មាត្រា542 កថាខណ្ឌទី1 ចំណុចទី1, ចំណុចទី3, មាត្រា542 កថាខណ្ឌទី2)។ ក្នុងករណីនេះ ទោះបីជានៅមុនពេលកាលបរិច្ឆេទនៃការអនុវត្តដែលបានសន្យាក៏ដោយ ក៏ការរំលាយអាចធ្វើបានដែរ បើសិនជាអាចកំណត់ជាក់លាក់ថាអលទ្ធភាពក្នុងការអនុវត្ត។ ចំណែកឯ ការអនុវត្តមិនពេញលេញវិញ បើសិនជា វាជារបស់ដែលអាចបំពេញនៅពេលក្រោយបាន ក្នុងករណីនេះ យើងអាចដាស់តឿនឱ្យអនុវត្តដូចការអនុវត្តយឺតយ៉ាវ ហើយបើសិនជារបស់ដែលមិនអាចបំពេញនៅពេលក្រោយទេ យើងអាចរំលាយភ្លាមៗដោយមិនចាំបាច់ដាស់តឿន។

### 5. ខសន្យាតាមទម្រង់ជាក់លាក់

ពីមុនមក ក្រមរដ្ឋប្បវេណីមិនបានកំណត់បញ្ញត្តិស្តីពី ខសន្យានោះទេ (ជាខសន្យាពិសេសដែលភាគីតែម្ខាងនៃកិច្ចសន្យាបានត្រៀមជាមុន នៅក្នុងកិច្ចសន្យាដែលភាគច្រើនមានខ្លឹមសារវែង និង ទម្រង់តែមួយ)។ ប៉ុន្តែ នៅក្នុងការធ្វើវិសោធនកម្មច្បាប់បានបញ្ចូលចំណុចស្តីពីខសន្យាតាមទម្រង់ជាក់លាក់នេះ ដោយឈរលើទ្រឹស្តីដែលហៅថា «ខសន្យាសម្រាប់ជំនួញតាមទម្រង់ជាក់លាក់» (គោលការណ៍សមរម្យដែលមានខ្លឹមសារទាំងស្រុង ឬ មួយផ្នែកដែលមានទម្រង់តែមួយសម្រាប់ភាគីទាំងសងខាង នៅក្នុងកិច្ចការជំនួញនៃភាគីជាក់លាក់ ជាមួយនឹងភាគីមិនជាក់លាក់ជាច្រើនផ្សេងទៀត) (ចាប់ពីមាត្រា548.2)។ គេបានបញ្ញត្តអំពីរបៀបនៃការបញ្ចូលខសន្យាតាមទម្រង់ជាក់លាក់ក្នុងកិច្ចសន្យា និង ការអនុញ្ញាតឱ្យភាគីដែលតាក់តែងខសន្យាជាក់លាក់អាចកែប្រែខ្លឹមសារតិចតួចក្នុងខសន្យាតាមទម្រង់ជាក់លាក់ដោយមិនត្រូវការយល់ព្រមពីភាគីម្ខាងទៀត (អ្នកប្រើប្រាស់)។ ប៉ុន្តែ ការតាក់តែងចំណុចនេះរងការរិះគន់ជាច្រើន ហេតុនេះ ខ្ញុំយល់ថាត្រូវការចំណាយពេលវេលាបន្ថែមដើម្បីវាយតម្លៃលើបញ្ញត្តិទាំងនេះ។

## III. ការសិក្សាចំណុចសំខាន់ៗនៃកិច្ចសន្យាពិសេស

### 1. កិច្ចសន្យាលក់ទិញ

#### (1) សញ្ញាណទូទៅ

បន្តទៅនេះ យើងនឹងពិនិត្យមើលអំពីចំណុចសំខាន់ៗនៅក្នុងចំណោមកិច្ចសន្យាដែលមានច្បាប់កំណត់នៅក្នុងក្រមរដ្ឋប្បវេណី។ សូមលើកឡើងម្តងទៀតថា ការលក់ទិញគឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ, កិច្ចសន្យាអញ្ញមញ្ញ និង កិច្ចសន្យាកើតឡើងតាមការព្រមព្រៀង។ ក្រមរដ្ឋប្បវេណី មាត្រា559 បញ្ញត្តថា ជាគោលការណ៍បទប្បញ្ញត្តិស្តីពីការលក់ទិញត្រូវយកមកអនុវត្តដូចគ្នាចំពោះកិច្ចសន្យាដែលយកតម្លៃថ្នូរផ្សេងទៀត។ ដោយឡែក ក្រមរដ្ឋប្បវេណីមិនតម្រូវឱ្យធ្វើជាលិខិតកិច្ចសន្យា ដើម្បីបង្កើតកិច្ចសន្យាលក់ទិញ ឬ កិច្ចសន្យាផ្សេងទៀតនោះទេ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់ការបង្កើតកិច្ចសន្យាតាមការព្រមព្រៀង ដោយគ្មានលិខិតកិច្ចសន្យា បើទោះបីជាការលក់ទិញដែលមានតម្លៃថ្លៃប៉ុណ្ណាក៏ដោយ។ ប៉ុន្តែ បើសិនជាអ្នកទិញគឺជាអ្នកប្រើប្រាស់ ហើយតម្លៃនៃកិច្ចសន្យាមានទំហំធំធេងខ្លាំងជាដើមវិញ ក្នុងករណីនេះ ច្បាប់ពិសេសបានកំណត់ករណីយកិច្ចឱ្យធ្វើជាលិខិតកិច្ចសន្យា (ដូចជា ច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្មដាក់លាក់ ឬ ច្បាប់ស្តីពីការជួញដូរអគារលំនៅឋាន ជាដើម។ សូមមើលចំណុច11ខាងក្រោម)។

#### (2) ការសន្យាលក់ទិញជាមុនដោយឯកតោភាគី

យើងអាចសន្យាជាមុនអំពីការបង្កើតកិច្ចសន្យាលក់ទិញដោយគ្រាន់តែបង្ហាញឆន្ទៈថា «នឹងទិញវត្ថុនេះ» និង «ព្រមលក់»។ ការសន្យាជាមុន ក៏ជាកិច្ចសន្យាផងដែរ ហេតុនេះ វាមានអានុភាពចង ហើយភាគីម្ខាងទៀតដែលបានទទួលសំណើអំពីកិច្ចសន្យាដើម ត្រូវតែផ្តល់ស្វ៊ីការចំពោះសំណើនេះ។ ប្រសិនបើភាគីម្ខាងទៀតបានបដិសេធក្នុងការផ្តល់ស្វ៊ីការតាមតែចិត្តឯង យើងដាក់បណ្តឹងទាមទារសាលក្រមជំនួសឱ្យការបង្ហាញឆន្ទៈផ្តល់ស្វ៊ីការបាន។ ប៉ុន្តែ បើសិនជាភាគីម្ខាងទៀតមិនព្រមសហការ ហើយបើសិនជាអាចទទួលសេចក្តីសម្រេចឈ្នះក្តីក៏ដោយ ក៏បុគ្គលភាគច្រើនមិនប្រើប្រាស់ការសន្យាជាមុនដែលស្មុគស្មាញនេះដែរ។ ហេតុនេះ ចំពោះកិច្ចសន្យាលក់ទិញដែលត្រូវបានយកមកប្រើប្រាស់ជាញឹកញាប់ ក្រមរដ្ឋប្បវេណីបានកំណត់ថា បើមានការសន្យាជាមុន កិច្ចសន្យានឹងបង្កើតអានុភាពនៅពេលដែលភាគីម្ខាងបានបង្ហាញឆន្ទៈបំពេញការទិញ ដោយមិនតម្រូវឱ្យមានការផ្តល់ស្វ៊ីការរបស់ភាគីម្ខាងទៀតនោះទេ (មាត្រា556 កថាខណ្ឌទី1)។ នៅក្នុងពាក្យបច្ចេកទេស គេហៅថា «ការបំពេញការសន្យា» ចំពោះខ្លឹមសារថា « សូមចុះកិច្ចសន្យាតាមខ្លឹមសារនៃការសន្យាជាមុន» ហើយភាគីម្ខាងដែលអាចបំពេញការសន្យានេះ (សិទ្ធិធ្វើឱ្យការសន្យាក្លាយជាកិច្ចសន្យា) ហៅថា «អ្នកមានសិទ្ធិបំពេញការសន្យាជាមុន»។

(3) **ប្រាក់កក់**

ប្រាក់កក់ សំដៅទៅលើប្រាក់ដែលត្រូវបានប្រគល់នៅពេលបង្កើតកិច្ចសន្យា ដូចជា នៅក្នុងកិច្ចសន្យាលក់ទិញ ជាដើម។ ឧទាហរណ៍ ករណីដែលប្រគល់ប្រាក់ជាមុនចំនួន 4លានរៀល (ឬហៅថា ប្រាក់ទ្រនាប់ដៃ) សម្រាប់ការទិញទំនិញដែលមានតម្លៃ 40លានរៀល។ ប៉ុន្តែ បញ្ហាចោទគឺ មុខងាររបស់ប្រាក់កក់នោះ។ ចំពោះមុខងាររបស់ប្រាក់កក់នេះ នីតិករបានតាក់តែងឡើងដោយពិចារណាជាមួយទំនៀមទម្លាប់របស់ប្រទេសជប៉ុនតាំងពីបុរាណមក ហើយបានកំណត់ថា វាមានមុខងាជា «**ប្រាក់កក់សម្រាប់រំលាយកិច្ចសន្យា**»។ នៅពេលដែលអ្នកទិញបានប្រគល់ប្រាក់កក់ទៅឱ្យអ្នកលក់ អ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញដោយបោះបង់ចោលប្រាក់កក់នោះបាន រីឯអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយសងប្រាក់ស្មើនឹង 2ដង នៃប្រាក់កក់នោះមកវិញបានដែរ នៅមុនពេលដែលភាគីម្ខាងទៀតបានចាប់ផ្តើមអនុវត្តកិច្ចសន្យា (មាត្រា557 កថាខណ្ឌទី1។ ក្នុងករណីនេះ យើងចាត់ទុកថា ការចាត់ចែងចំនួននៃប្រាក់កក់គឺជានីតិវិធីមួយសម្រាប់លុបបំបាត់ទំនាក់ទំនងកិច្ចសន្យា ហេតុនេះ ការទាមទារសំណងការខូចខាតក្រៅពីនេះមិនអាចប្រព្រឹត្តទៅបាននោះទេ)។ នេះមានន័យថា ប្រាក់កក់សម្រាប់រំលាយកិច្ចសន្យា មានមុខងារជាការរក្សាទុកសិទ្ធិរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា ដែលភាគីអាចរំលាយកិច្ចសន្យាបានដោយលះបង់ប្រាក់កក់ ឬ សងប្រាក់កក់ 2ដង បើទោះបីជាគ្មានហេតុផលណាមួយតាមតែអំពើចិត្តក៏ដោយ (ភាគីនៃកិច្ចសន្យាអាចព្រមព្រៀងគ្នាដោយកំណត់អំពី ការកកើតសិទ្ធិរំលាយកិច្ចសន្យាបាន។ មាត្រា540 កថាខណ្ឌទី1)។ ប៉ុន្តែមាត្រានេះជាបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្តនោះទេ ហេតុនេះហើយ ភាគីអាចកំណត់ប្រាក់កក់ក្នុងមុខងារផ្សេងបាន (បើសិនជាភាគីម្ខាងមិនអនុវត្តកាតព្វកិច្ចទេ ភាគីម្ខាងទៀតអាចយកប្រាក់កក់ដាច់បាន ពោលគឺ ប្រាក់កក់ជានាសំណងក្នុងករណីបំពានកិច្ចសន្យា ជាអាទិ៍)។ ដោយឡែក យុត្តិសាស្ត្រតុលាការបានកំណត់ថា ត្រូវសន្មតថាជាប្រាក់កក់សម្រាប់រំលាយកិច្ចសន្យា ក្នុងករណីដែលមិនបានកំណត់ច្បាស់លាស់អំពីមុខងាររបស់ប្រាក់កក់នោះ (យ៉ាងណាមិញ ទោះបីជាប្រាក់កក់បែបណាក៏ដោយ ក៏វាមានមុខងារជាប្រាក់កក់បញ្ជាក់កិច្ចសន្យា ហើយវានឹងក្លាយជាភស្តុតាងនៃការបង្កើតកិច្ចសន្យា)។

(4) **ការទទួលខុសត្រូវក្នុងការធានា**

<u>① សញ្ញាណទូទៅ</u>

ការលក់ទិញគឺជាកិច្ចសន្យាមួយដែលដោះដូរគ្នានូវទំនិញ និង ទឹកប្រាក់ដែលមានតម្លៃស្មើគ្នា ហេតុនេះ កន្លងមក ក្រមរដ្ឋប្បវេណីបានកំណត់អំពីបញ្ញត្តិស្តីពីការការទទួលខុសត្រូវរបស់អ្នកលក់ដោយពិនិត្យមើលពីគ្រប់ជ្រុងទាំងអស់ ដើម្បីធានានូវភាពស្មើគ្នានៃតម្លៃ ឬ ភាពស្មើគ្នារបស់ភាគី។ នេះមានន័យថា បើសិនជាកម្មវត្ថុនៃការលក់ទិញមានវិការៈ (ស្លាកស្នាម), មានចំនួនមិនគ្រប់គ្រាន់, មិនបានភ្ជាប់មកជាមួយនូវសិទ្ធិដែលត្រូវតែមាន, ឬក៏ កម្មវត្ថុនោះមានសិទ្ធិរបស់អ្នកដទៃរួមជាមួយ ជាអាទិ៍ ក្នុងករណីនេះ អ្នកលក់ត្រូវមានការទទួលខុសត្រូវក្នុងការធានាដោយត្រូវទទួលរងពិន័យដូចជា ការរំលាយកិច្ចសន្យា និង ការទាមទារសំណងការខូចខាតពីភាគីម្ខាងទៀត។ ប៉ុន្តែ

នៅក្នុងការធ្វើវិសោធនកម្មច្បាប់ឆ្នាំ2017 បានលុបចោលនូវបញ្ញត្តិស្តីពីការទទួលខុសត្រូវក្នុងការធានាដែលមានកំណត់ក្នុងច្បាប់នេះ ហើយបានអនុម័តយកនូវការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា ដោយសារអ្នកលក់មានករណីយកិច្ចផ្ទេរសិទ្ធិ និង ប្រគល់ឱ្យស្របតាមខ្លឹមសារនៃកិច្ចសន្យា ។

គោលការណ៍ជារួមគឺ ការធ្វើវិសោធនកម្មនេះបានបោះបង់ចោលទ្រឹស្តី «វិការៈ» ហើយការទទួលខុសត្រូវក្នុងការធានាលើវិការៈនៃវត្ថុ និង ការទទួលខុសត្រូវក្នុងការធានាលើវិការៈនៃសិទ្ធិដែលមានកន្លងមក ត្រូវរួមបញ្ចូលគ្នាតែមួយជា ការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា។ នេះមានន័យថា បើសិនជាមានករណីដែលមិនស្របតាមខ្លឹមសារនៃកិច្ចសន្យាទេ អ្នកទិញមាន ①សិទ្ធិទាមទារឱ្យអនុវត្តពេញលេញ ②សិទ្ធិទាមទារឱ្យបន្ថយតម្លៃលក់ទិញ ③សិទ្ធិទាមទារសំណងការខូចខាត និង ④សិទ្ធិរំលាយកិច្ចសន្យា។ វិការៈអំពីសិទ្ធិលើកម្មវត្ថុក៏ត្រូវអនុវត្តដូចគ្នា មានន័យថា បើសិនជាកម្មវត្ថុនោះមានសិទ្ធិមួយផ្នែកជារបស់អ្នកដទៃ ក្នុងករណីនេះ វានឹងក្លាយជាកម្មវត្ថុនៃការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា។ ប៉ុន្តែ បើសិនជាសិទ្ធិទាំងអស់គឺជារបស់អ្នកដទៃ (វត្ថុទាំងស្រុងជារបស់អ្នកដទៃ) ហើយអ្នកលក់មិនអាចផ្ទេរសិទ្ធិបានទាល់តែសោះ ក្នុងករណីនេះ វាមិនមានជាបញ្ហានៃការមិនអនុវត្តស្របតាមខ្លឹមសារនៃកិច្ចសន្យាទៀតទេ ហើយវានឹងក្លាយជាបញ្ហានៃបញ្ញត្តិទូទៅស្តីពីការមិនអនុវត្តកាតព្វកិច្ច។

លើសពីនេះ ការធ្វើវិសោធនកម្មច្បាប់នេះលុបបំបាត់នូវទ្រឹស្តីអំពីវិការៈ ដែលជាការ «លាក់បាំង» (បើគ្រាន់តែមើលមួយភ្លែតគឺមិនអាចចាប់អារម្មណ៍ទេ) នៅក្នុងទ្រឹស្តីនៃការទទួលខុសត្រូវក្នុងការធានា។ បញ្ញត្តិស្តីពីលក្ខខណ្ឌអត្តនោម័តដែលជាភាពសុចរិត ឬ ទុច្ចរិតរបស់អ្នកទិញចំពោះវិការៈ ក៏ត្រូវបានលុបបំបាត់ផងដែរ។

<u>② ការទិញលក់វត្ថុអ្នកដទៃ</u>

ដូចមានលើកជាឧទាហរណ៍នៅខាងលើនេះ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនបានទទួលស្គាល់ការធ្វើកិច្ចសន្យាទិញលក់ដោយយកវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃសុទ្ធសាធមកធ្វើជាកម្មវត្ថុ។ នេះមានន័យថា ការដែល B យកវត្ថុរបស់ A ទៅលក់ឱ្យ C គឺជាកិច្ចសន្យាដែលមានអានុភាព (ហៅថា ការលក់ទិញវត្ថុអ្នកដទៃ)។ ក្នុងករណីនេះ B ប្រាកដជាមានករណីយកិច្ចទទួលយកកម្មសិទ្ធិពី A ដើម្បីផ្ទេរកម្មសិទ្ធិនោះទៅឱ្យ C (មាត្រា561)។ បើសិនជាមិនអាចធ្វើទៅបាននោះទេ B ត្រូវទទួលរងការរំលាយកិច្ចសន្យាដោយសារការមិនអនុវត្តកាតព្វកិច្ច និង ការទទួលខុសត្រូវក្នុងការសងសំណងការខូចខាត។

<u>③ សិទ្ធិទាមទារឱ្យអនុវត្តពេញលេញដោយយកមូលហេតុនៃការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា</u>

ក្នុងនាមជាមធ្យោបាយសង្គ្រោះរួមគ្នាជាទូទៅចំពោះ ការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា គេបានបញ្ចូលបញ្ញត្តិថ្មីស្តីពីសិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ (មាត្រា562)។ គេបានបញ្ញត្តច្បាស់លាស់ថា

ប្រសិនបើកម្មវត្ថុដែលត្រូវបានប្រគល់នោះមិនមានប្រភេទ គុណភាព ឬ ចំនួនស្របតាមខ្លឹមសារនៃកិច្ចសន្យាទេ អ្នកទិញមានសិទ្ធិទាមទារឱ្យអនុវត្តពេញលេញបាន តាមរយៈការជួសជុលកម្មវត្ថុ, ការប្រគល់វត្ថុជំនួស ឬ ការប្រគល់ផ្នែកដែលខ្វះ (ការធ្វើឱ្យពេញលេញនៅពេលក្រោយ)។

ដោយឡែក បើសិនជាការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យានោះ កើតឡើងពីហេតុដែលជាការទទួលខុសត្រូវរបស់អ្នកទិញ ក្នុងករណីនេះ ការទាមទារឱ្យអនុវត្តពេញលេញមិនអាចប្រព្រឹត្តទៅបានឡើយ។

④ សិទ្ធិទាមទារឱ្យបន្ថយតម្លៃលក់ទិញដោយយកមូលហេតុនៃការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា

អ្នកទិញដែលមានសិទ្ធិទាមទារឱ្យបន្ថយតម្លៃលក់ទិញ ត្រូវដាស់តឿនភាគីម្ខាងទៀតឱ្យអនុវត្តពេញលេញដោយកំណត់អំឡុងពេលសមរម្យ។ ក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តឱ្យបានពេញលេញក្នុងអំឡុងពេលនោះទេ អ្នកទិញអាចទាមទារឱ្យបន្ថយថ្លៃលក់ទិញ ទៅតាមកម្រិតនៃការអនុវត្តមិនស្របតាមកិច្ចសន្យាបាន (មាត្រា563 កថាខណ្ឌទី1)។ ម្យ៉ាងទៀត ប្រសិនបើការអនុវត្តពេញលេញនោះគឺអលទ្ធភាព ឬ អ្នកលក់បានបដិសេធយ៉ាងច្បាស់អំពីការមិនអនុវត្តពេញលេញ ឬ តាមរយៈសារជាតុនៃកិច្ចសន្យា ឬ ការបង្ហាញឆន្ទៈរបស់ភាគីគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចបានទាល់តែសោះ (ដូចមានពន្យល់នៅក្នុងចំណុចស្តីពីការរំលាយកិច្ចសន្យាដូចជា ការកម្មង់ម្ហូបសម្រាប់រៀបអាពាហ៍ពិពាហ៍ជាដើម ពោលគឺ សកម្មភាពដែលមានកំណត់ពេលជាក់លាក់) បើសិនជាមិនអនុវត្តនៅថ្ងៃជាក់លាក់ ឬ អំឡុងពេលជាក់លាក់នោះទេ ក្នុងករណីទាំងនេះ អ្នកទិញអាចទាមទារឱ្យបន្ថយថ្លៃលក់ទិញភ្លាមៗបាន ដោយមិនចាំបាច់ដាស់តឿន (មាត្រាដដែល កថាខណ្ឌទី2)។

⑤ សិទ្ធិទាមទារឱ្យសងសំណងការខូចខាត និង សិទ្ធិរំលាយរបស់អ្នកទិញ

អ្នកទិញដែលមានសិទ្ធិទាមទារឱ្យអនុវត្តពេញលេញ និង សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់ទិញ អាចអនុវត្តសិទ្ធិទាមទារឱ្យសងសំណងការខូចខាតដោយផ្អែកលើបញ្ញត្តិទូទៅស្តីពីការមិនអនុវត្តកាតព្វកិច្ច (មាត្រា415) ផង និងអាចអនុវត្តសិទ្ធិរំលាយកិច្ចសន្យា (មាត្រា541 , មាត្រា542) ផង (មាត្រា564)។

⑥ ការកម្រិតអំឡុងពេលនៃការទាមទារឱ្យទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា

អ្នកទិញត្រូវជូនដំណឹងអំពី ការទាមទារឱ្យទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យាទៅអ្នកលក់ក្នុងអំឡុងពេល 1ឆ្នាំ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យានោះ, បើមិនបានជូនដំណឹងក្នុងអំឡុងពេលខាងលើនេះទេ អ្នកទិញនឹងបាត់បង់សិទ្ធិទាមទារឱ្យអនុវត្តពេញលេញ សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់ទិញ សិទ្ធិទាមទារសំណងការខូចខាត និង សិទ្ធិរំលាយកិច្ចសន្យា។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើអ្នកលក់បានដឹងអំពីការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា ឬ មាន

កំហុសធ្ងន់ធ្ងរក្នុងការមិនបានដឹងនៅពេលដែលប្រគល់ (មានន័យថា ឆ្នាំកន្លងផុតហើយក៏ដោយ ក៏នៅតែអាចទាមទារបាន)។

2. **កិច្ចសន្យាប្រទានកម្ម**

(1) សញ្ញាណទូទៅ

កិច្ចសន្យាប្រទានកម្ម គឺជាកិច្ចសន្យាតំណាងឱ្យកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ និងជាកិច្ចសន្យាឯកតោភាគី។ ក្រមរដ្ឋប្បវេណីបានកំណត់កិច្ចសន្យាប្រទានកម្ម ជាកិច្ចសន្យាដែលកើតឡើងតាមការព្រមព្រៀង ប៉ុន្តែមានប្រទេសជាច្រើនបានកំណត់កិច្ចសន្យានេះ ជាប្រភេទកិច្ចសន្យាកើតឡើងតាមរយៈការប្រគល់វត្ថុ និង ជាកិច្ចសន្យាកើតឡើងតាមទម្រង់ ក្នុងគោលបំណងជៀសវាងការធ្វើកិច្ចសន្យាដោយបោកប្រាស់ ដោយសារតែកិច្ចសន្យាប្រទានកម្មនេះ មានភាគីទាយកតែម្ខាងប៉ុណ្ណោះដែលរងការខូចខាត។ ដូចនេះ ក្រមរដ្ឋប្បវេណីជប៉ុនបានកំណត់ថាជាកិច្ចសន្យាកើតឡើងតាមព្រមព្រៀង ប៉ុន្តែ ចំពោះប្រទានកម្មដោយសន្យាផ្ទាល់មាត់ ហើយមិនធ្វើជាលាយលក្ខណ៍អក្សរ គឺកើតមានឡើង តែភាគីអាចរំលាយកិច្ចសន្យាបាននៅមុនពេលអនុវត្ត (មាត្រា550) (នៅមុនពេលវិសោធនកម្មក្រមរដ្ឋប្បវេណីឆ្នាំ2017 ចំណុចនេះគឺប្រើពាក្យថា «ការដកសំណើរ»)។ ដោយឡែក ចំពោះកិច្ចសន្យាប្រទានកម្មជាគោលការណ៍ ទាយកមិនមានការទទួលខុសត្រូវក្នុងការធានាចំពោះករណីវត្ថុមានវិការៈនោះទេ ប៉ុន្តែ បើសិនជាទាយកបានដឹងអំពីវិការៈនៃវត្ថុ ហើយបានធ្វើប្រទានកម្មដោយលាក់បាំងវិការៈនេះ ក្នុងករណីនេះ ទាយកត្រូវទទួលខុសត្រូវក្នុងការធានាលើការបំពានទំនុកចិត្ត។ ដូចបានរៀបរាប់រួចហើយថា នៅក្នុងច្បាប់វិសោធនកម្ម បានលុបបំបាត់ការទទួលខុសត្រូវក្នុងការធានានៅក្នុងការលក់ទិញ ហើយនៅក្នុងករណីយកិច្ចរបស់ទាយកក៏បានបញ្ញត្តថា «ត្រូវសន្មតថា ទាយកបានសន្យាប្រគល់ ឬ ផ្ទេរ វត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃប្រទានកម្ម នៅក្នុងស្ថានភាពនៃពេលដែលកំណត់កម្មវត្ថុនៃប្រទានកម្មបាន» (ច្បាប់វិសោធនកម្ម មាត្រា551 កថាខណ្ឌទី1)។

(2) **ប្រទានកម្មពិសេស**

① <u>ប្រទានកម្មដែលមានភ្ជាប់បន្ទុក</u>

យើងនៅតែអាចហៅថាជា ប្រភេទនៃកិច្ចសន្យាប្រទានកម្មដែលមិនយកតម្លៃថ្នូរ ប៉ុន្តែ វាគឺជាកិច្ចសន្យាប្រទានកម្មដែលមានភ្ជាប់បន្ទុកដល់បដិគ្គាហកមានបន្ទុកត្រូវអនុវត្តការផ្តល់តាវកាលិកណាមួយ។ ឧទាហរណ៍ករណីដូចជា «ការប្រទានកម្មដីដែលមានតម្លៃប្រហែល 4000លានរៀល ដោយតម្រូវឱ្យទៅសម្អាតផ្នូរជូនតា និងធ្វើបុណ្យជារៀងរាល់ឆ្នាំចាប់ពីពេលនេះទៅ» ជាអាទិ៍។ នៅក្នុងករណីនេះ ច្បាប់ចាត់ទុកថា ប្រទានកម្មនេះជាកិច្ចសន្យាអញ្ញមញ្ញ(យកតម្លៃថ្នូរ)ក្នុងទំហំនៃតម្លៃតបរបស់បន្ទុកនោះ។ ទាយកមានការទទួលខុសត្រូវនៃការធានាក្នុងកម្រិតនៃបន្ទុក ដូចគ្នានឹងអ្នកលក់ក្នុងកិច្ចសន្យាលក់ទិញ (មាត្រា551 កថាខណ្ឌទី2) ហើយបញ្ញត្តិស្តីពីកិច្ចសន្យាអញ្ញមញ្ញត្រូវយកមកអនុវត្ត (មាត្រា553)។

② ប្រទានកម្មដោយមូលហេតុមរណភាព

ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយកហៅថា ប្រទានកម្មដោយមូលហេតុមរណភាព។ ឧបមាថា នៅពេលមានជីវិត ទាយកបានធ្វើកិច្ចសន្យាថា «បើខ្ញុំស្លាប់ ខ្ញុំនឹងប្រគល់ដីនេះទៅឱ្យអ្នក» ហើយបដិគ្គាហកបានឆ្លើយថា «ខ្ញុំព្រមទទួលយក»។ គេមានវិធីមួយទៀតដែលស្រដៀងគ្នានឹងការប្រទានកម្មនេះផងដែរ។ វិធីនេះគឺជាអច្ច័យទាន ដែលទាយកបានសរសេរក្នុងមតកសាសន៍របស់ខ្លួនថា «ដីនេះនឹងប្រគល់ឱ្យអ្នកណាម្នាក់» (⇒សូមមើល ជំពូកទី១ II.4(2))។ វិធីនេះគឺជាសកម្មភាពឯកតោភាគីដែលបង្កើតឱ្យមានអានុភាពប្រទានកម្មដោយការបង្ហាញឆន្ទៈតែម្ខាង ហើយភាគីម្ខាងទៀតមិនបានដឹង។ ប្រទានកម្មដោយមូលហេតុមរណភាព និង អច្ច័យទានមានលក្ខណៈគតិយុត្តខុសគ្នាដូចបានរៀបរាប់ខាងលើនេះ ប៉ុន្តែ វាមានមុខងារស្រដៀងគ្នាខ្លាំងមែនទែន ហេតុនេះ ក្រមរដ្ឋប្បវេណីបានកំណត់អំពីការយកបញ្ញត្តិស្តីពីអច្ច័យទាន មកអនុវត្តដូចគ្នាចំពោះករណីប្រទានកម្មដោយមូលហេតុមរណភាព លើកលែងតែចំណុចដែលមានលក្ខណៈផ្ទុយគ្នា (មាត្រា554)។ ប៉ុន្តែ អច្ច័យទានត្រូវធ្វើឡើងតាមលិខិតមតកសាសន៍ ហេតុនេះ យោងតាមបញ្ញត្តិស្តីពីមតកសាសន៍ (ដើម្បីឆ្លើយតបនឹងឆន្ទៈចុងក្រោយបំផុតរបស់អ្នកស្លាប់) ទាយកអាចសរសេរសារជាថ្មីប៉ុន្មានដងក៏បានដែរ (មាត្រា1022)។ ប្រទានកម្មដោយមូលហេតុមរណៈភាពគឺជាកិច្ចសន្យាដែលមានភាគីម្ខាងទៀត ហេតុនេះ ភាគីម្ខាងទៀតបានជឿជាក់លើការទទួលប្រទានកម្មរួចហើយ ប៉ុន្តែ យុត្តិសាស្ត្រ និង ទស្សនៈទូទៅបានបកស្រាយថា ទាយកអាចដកការបង្ហាញឆន្ទៈលើកិច្ចសន្យាប្រទានកម្មដោយមូលហេតុមរណភាព ដោយសេរីបាន។ ប៉ុន្តែ មានយុត្តិសាស្ត្រមួយចំនួនបានបកស្រាយថា ក្នុងករណីប្រទានកម្មដោយមូលហេតុមរណភាពដែលមានភ្ជាប់បន្ទុក (**កិច្ចសន្យាប្រទានកម្មដោយមូលហេតុមរណភាពដែលមានភ្ជាប់បន្ទុក**) ហើយបើសិនជាបន្ទុកនោះត្រូវបានអនុវត្តជាមុនរួចហើយ ជាគោលការណ៍ ការដកការបង្ហាញឆន្ទៈមិនអាចធ្វើបានឡើយ (នៅក្នុងកិច្ចសន្យាមួយដែលមានខ្លឹមសារថា «បើសិនជាឯងឧបត្ថម្ភប្រាក់ទ្រទ្រង់ជីវភាពជារៀងរាល់ឆ្នាំមកឱ្យខ្ញុំរហូតដល់ពេលឯងចូលនិវត្តនោះ ខ្ញុំនឹងប្រគល់ដីលើភ្នំនេះឱ្យទៅឯងនៅពេលខ្ញុំស្លាប់» ក្នុងករណីនេះ បើសិនជាបដិគ្គាហកបានអនុវត្តការផ្តល់ប្រាក់ថ្លៃជីវភាពរហូតដល់ពេលខ្លួនចូលនិវត្តមែន ទាយកមិនអាចដកការបង្ហាញឆន្ទៈប្រទានកម្មដោយមូលហេតុមរណភាពបានឡើយ)។

### 3. **កិច្ចសន្យាជួល**

#### (1) **សញ្ញាណទូទៅ**

កិច្ចសន្យាដែលខ្ចីវត្ថុរបស់គេដោយបង់ថ្លៃតប ហៅថា កិច្ចសន្យាជួល។ កិច្ចសន្យាជួលក៏ជាកិច្ចសន្យាដែលយកតម្លៃថ្នូរ កិច្ចសន្យាអញ្ញមញ្ញ និង កិច្ចសន្យាកើតឡើងតាមការព្រមព្រៀងផងដែរ (មាត្រា601) ប៉ុន្តែ ខុសពីកិច្ចសន្យាលក់ទិញត្រង់មិនមែនអនុវត្តតែមួយលើកចប់។ កិច្ចសន្យាជួលគឺជាកិច្ចសន្យាដែលត្រូវបន្តក្នុងអំឡុងពេលជាក់លាក់មួយ ហើយក្រៅពីសិទ្ធិទាមទារតាវកាលិក នៅក្នុងសិទ្ធិជួលនេះមានបញ្ចូលនូវលក្ខណៈពិសេសនៃសារជាតុសិទ្ធិប្រត្យក្សទោះបីជាវាជាសិទ្ធិលើបំណុលក៏ដោយ ដោយសារវាមានរួមផ្សំសារជាតុនៃសិទ្ធិប្រើប្រាស់វត្ថុ។ នៅក្នុង

ន័យនេះ បញ្ញត្តិការពារត្រូវបានបង្កើតឡើង ដោយអនុញ្ញាតឱ្យសិទ្ធិជួលអចលនវត្ថុអាចចុះបញ្ជីបាន ហើយការចុះបញ្ជីនេះធ្វើឱ្យអ្នកជួលអាចតតាំងអំពីសិទ្ធិជួលបាន បើទោះបីជាមានការផ្លាស់ប្តូរកម្មសិទ្ធិករក៏ដោយ (មាត្រា605)។ ជាក់ស្តែងបញ្ញត្តិនេះមិនសូវមានប្រសិទ្ធិភាពនោះទេ ដោយសារតែអ្នកឱ្យជួលមិនព្រមសហការចុះបញ្ជី (ប៉ុន្តែ ការការពារត្រូវបានធ្វើឡើងតាមបញ្ញត្តិនៃច្បាប់ពិសេសវិញ)។ សិទ្ធិជួលនេះខុសគ្នាពីសិទ្ធិលើដី (ជំពូកទី3 I 3(3)) ដែលជាសិទ្ធិប្រត្យក្ស ពោលគឺ អ្នកជួលមិនអាចធ្វើអនុប្បទាន ឬ ជួលបន្តដោយសេរីនោះទេ ហើយការធ្វើអនុប្បទាន ឬ ជួលបន្តត្រូវមានការយល់ព្រមពីអ្នកឱ្យជួល (មាត្រា612 កថាខណ្ឌទី1)។ បើសិនជាធ្វើអនុប្បទាន ឬ ជួលបន្តដោយគ្មានការយល់ព្រមទេ អ្នកឱ្យជួលអាចរំលាយកិច្ចសន្យាបាន (មាត្រាដដែល កថាខណ្ឌទី2)។ ប៉ុន្តែ ដើម្បីជៀសវាងនូវការប្រើប្រាស់បញ្ញត្តិនេះដោយបំពានពីសំណាក់អ្នកឱ្យជួល យុត្តិសាស្ត្របានកម្រិតការរំលាយកិច្ចសន្យាជួលនេះ តែក្នុងករណីដែលការធ្វើអនុប្បទាន ឬ ការជួលបន្តនោះធ្វើឱ្យបាត់បង់ទំនុកចិត្តរវាងអ្នកឱ្យជួល និង អ្នកជួលប៉ុណ្ណោះ (**គោលការណ៍បំពានជំនឿទុកចិត្ត** ឬ **គោលការណ៍រំលោភទំនុកចិត្ត**)។ ដោយឡែក ការរំលាយកិច្ចសន្យាដែលអនុវត្តជាបន្តបន្ទាប់ដូចកិច្ចសន្យាជួលនេះ នឹងធ្វើឱ្យបាត់បង់អានុភាពនៃកិច្ចសន្យានៅចំណុចពេលនេះឆ្ពោះទៅអនាគតប៉ុណ្ណោះ ហើយវាមិនមានអានុភាពប្រតិសកម្មនោះទេ។

### (2) **ករណីយកិច្ចរបស់អ្នកជួល និង អ្នកឱ្យជួល**

អ្នកជួលមានករណីយកិច្ចបង់ថ្លៃឈ្នួលក្នុងនាមជាតម្លៃតបនៃការប្រើប្រាស់ និងប្រើប្រាស់វត្ថុជួលដោយគោរពតាមវិធីប្រើប្រាស់ទូទៅ ហើយនិងមានករណីយកិច្ចសងវត្ថុជួលវិញនៅពេលបញ្ចប់កិច្ចសន្យា។ អ្នកឱ្យជួលមានករណីយកិច្ចបន្តជួលកម្មវត្ថុនៅក្នុងស្ថានភាពដែលអាចប្រើប្រាស់ និង អាស្រ័យផលតាមគោលបំណងនៃកិច្ចសន្យា ហេតុនេះ បើសិនជា ដំបូលផ្ទះជួលលិចទឹកជាដើម អ្នកឱ្យជួលមានករណីយកិច្ចជួសជុលដំបូលនោះ (មាត្រា606)។ ប្រសិនបើអ្នកជួលបានជួសជុលដោយចំណាយសោហ៊ុយរបស់ខ្លួន អ្នកជួលអាចទាមទារឱ្យសងវិញក្នុងនាមជាការចំណាយជាចាំបាច់ដែលទទួលបន្ទុកដោយអ្នកឱ្យជួលបាន (មាត្រា608 កថាខណ្ឌទី1។ បើសិនជាសោហ៊ុយនោះលើសពីការចំណាយជាចាំបាច់ ឧបមាថា បានកែលំអផ្ទះជួលនោះជាថ្មីដែលជាការចំណាយបង្កើនតម្លៃវិញ អ្នកជួលអាចទាមទារឱ្យសងវិញបាននៅពេលបញ្ចប់កិច្ចសន្យា ក្នុងករណីដែលកម្រិតនៃកំណើនតម្លៃនោះនៅតែមាន នាពេលបញ្ចប់កិច្ចសន្យាជួល។ មាត្រាដដែល កថាខណ្ឌទី2)។

### (3) **កិច្ចការពារអ្នកជួលដី និង អ្នកជួលផ្ទះ**

ការជួលផ្ទះ ឬ ការជួលដីដើម្បីអាស្រ័យនៅជាដើម សុទ្ធតែជាការជួលទាំងអស់ ប៉ុន្តែ នៅក្នុងបញ្ញត្តិស្តីពីការជួលនៅក្នុងក្រមរដ្ឋប្បវេណី អនុវត្តទៅលើរាល់កិច្ចសន្យាដែលខ្ចីវត្ថុដោយបង់ថ្លៃឈ្នួលទាំងអស់ ហើយនៅក្នុងនោះមានចំណុចជាច្រើនដែលធ្វើបាត់បង់ផលប្រយោជន៍ដល់អ្នកជួលផ្ទះ ឬ ដីសម្រាប់រស់នៅ ដូចជា ចំណុចអំពីអំឡុងពេលជាអាទិ៍។ ហេតុនេះ នៅឆ្នាំ1921 ច្បាប់ស្តីពីការជួលផ្ទះ និង ច្បាប់ស្តីពីការជួលដី ដែលជាច្បាប់ពិសេសត្រូវបានបង្កើតឡើង ហើយសិទ្ធិលើដី និង សិទ្ធិជួលដែលមានគោលបំណងយកកម្មសិទ្ធិលើអគារ ត្រូវយកច្បាប់ស្តីពីការជួល

ដីមកអនុវត្ត ហើយការជួលអគារជាដើម ត្រូវយកច្បាប់ស្តីពីការជួលផ្ទះមកអនុវត្ត។ ច្បាប់ពិសេសទាំងនេះត្រូវបានធ្វើវិសោធនកម្មក្រោយមកទៀត ដើម្បីផ្តល់ការការពារកាន់តែខ្លាំងដល់អ្នកជួលដី និង អ្នកជួលផ្ទះ ហើយនៅក្នុងយុត្តិសាស្ត្រតុលាការក៏មានទំនោរក្នុងការបកស្រាយ ឱ្យភាគីអ្នកឱ្យជួលពិបាករំលាយកិច្ចសន្យា ដើម្បីឆ្លើយតបទៅនឹងស្ថានភាពសង្គមក្នុងពេលមានវិបត្តិខ្វះលំនៅឋានក្រោយសង្គ្រាមលោកលើកទី2។

ប៉ុន្តែ តាមរយៈសកម្មភាពនេះហើយ ធ្វើឱ្យភាគីអ្នកឱ្យជួលមានការលំបាកយ៉ាងខ្លាំងដើម្បីបញ្ចប់កិច្ចសន្យា បើសិនជាខ្លួនមិនមានមូលហេតុត្រឹមត្រូវខ្លាំង ដូចជា ភាពចាំបាច់ដើម្បីប្រើប្រាស់ខ្លួនឯងជាដើមនោះទេ ហើយក្នុងពេលបច្ចុប្បន្ននេះ មានមតិកាន់តែច្រើនបានលើកឡើងអំពីការធ្វើឱ្យបាត់បង់ផលប្រយោជន៍ហួសហេតុដល់ភាគីអ្នកឱ្យជួល។ ដូចនេះ ច្បាប់ស្តីពីការជួលដី និង ជួលផ្ទះថ្មីដែលបានតាក់តែងឡើងនៅឆ្នាំ1991 បានពិចារណាអំពីបញ្ហានេះ និងបានតាក់តែងឡើងនូវប្រព័ន្ធថ្មីដែលផ្តល់ផលប្រយោជន៍ខ្លះដល់ភាគីអ្នកឱ្យជួលដូចជាចំណុចអំពី **សិទ្ធិជួលដីដែលមានកំណត់ពេលជាក់លាក់** (ច្បាប់ស្តីពីការជួលដី និង ជួលផ្ទះ មាត្រា22) ពោលគឺ ភាគីអាចបង្កើតកិច្ចសន្យាដែលមានអំឡុងពេលលើសពី 50ឆ្នាំ ហើយនៅពេលដែលអំឡុងពេលនេះបានបញ្ចប់ សិទ្ធិរបស់ភាគីនៃអ្នកជួលនឹងបាត់បង់ទាំងស្រុង ហើយមិនអាចបន្តសារជាថ្មីនោះទេ។ ប៉ុន្តែ ច្បាប់ថ្មីនេះអនុវត្តទៅលើកិច្ចសន្យាជួលផ្ទះ និង ជួលដីដែលកើតឡើងក្រោយការបង្កើតច្បាប់នេះប៉ុណ្ណោះ ហេតុនេះហើយ កិច្ចសន្យាដែលកើតឡើងមុនច្បាប់នេះ ត្រូវយកច្បាប់ស្តីពីការជួលដី និង ច្បាប់ស្តីពីការជួលផ្ទះចាស់មកអនុវត្តដដែល។

បើសិនជាប្រៀបធៀបជាក់ស្តែងរវាងបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី និង បញ្ញត្តិនៅក្នុងច្បាប់ស្តីពីការជួលដី និង ជួលផ្ទះថ្មីនេះ យើងអាចមើលឃើញដូចតទៅ៖ (1) ចំពោះអំឡុងពេលនៃកិច្ចសន្យា នៅក្នុងក្រមរដ្ឋប្បវេណីបានកម្រិតអំឡុងពេលវែងបំផុតគឺ 20ឆ្នាំ (ការកំណត់នេះធ្វើឡើងដោយពិចារណារួមគ្នាជាមួយនឹងការជួលឡានធំ និង វត្ថុផ្សេងទៀតជាច្រើន) ហើយកិច្ចសន្យាដែលមានរយៈពេលវែងជាងនេះត្រូវបន្ថយមកត្រឹមរយៈពេល 20ឆ្នាំ ប៉ុន្តែ នៅក្នុងការធ្វើវិសោធនកម្មឆ្នាំ2017 បានពន្យាពេលពី 20ឆ្នាំ ទៅដល់រយៈពេល 50ឆ្នាំវិញ (មាត្រា604 កថាខណ្ឌទី1)។ ផ្ទុយមកវិញ នៅក្នុងច្បាប់ស្តីពីការជួលដី និង ជួលផ្ទះបានកំណត់ អំឡុងពេលបន្តអត្ថិភាព 30ឆ្នាំ ចំពោះសិទ្ធិជួលដី ហើយត្រូវយកអំឡុងពេលតាមការកំណត់ក្នុងកិច្ចសន្យា ប្រសិនបើអំឡុងពេលដែលភាគីកំណត់ក្នុងកិច្ចសន្យាវែងជាងអំឡុងពេលដែលកំណត់ក្នុងច្បាប់ (ច្បាប់ស្តីពីការជួលដី និង ជួលផ្ទះ មាត្រា3)។ ចំពោះការជួលផ្ទះវិញ គឺមិនមានកម្រិតអំពីអំឡុងពេលវែងបំផុតនោះទេ ហេតុនេះភាគីអាចកំណត់កិច្ចសន្យាដែលមានអំឡុងពេលវែងបាន ហើយបើសិនជាបានកំណត់អំឡុងពេលខ្លីដែលតិចជាង 1ឆ្នាំ ចំពោះអគារវិញ ត្រូវចាត់ទុកថាមិនបានកំណត់អំឡុងពេល (ច្បាប់ស្តីពីការជួលដី និង ជួលផ្ទះ មាត្រា29 កថាខណ្ឌទី1)។ ច្បាប់ស្តីពីការជួលដី និង ជួលផ្ទះក៏បានកំណត់អំពីបញ្ញត្តិផ្សេងៗដែលមានផលប្រយោជន៍ដល់អ្នកជួលចំពោះការបន្តសារជាថ្មីផងដែរ។ (2) ប្រសិនបើភាគីមិនបានកំណត់អំឡុងពេលនៃកិច្ចសន្យានោះទេ នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់ថា ភាគីអាចស្នើសុំរំលាយកិច្ចសន្យានៅពេលណាក៏បាន ហើយការជួលដីនឹងបញ្ចប់កិច្ចសន្យាក្រោយការស្នើសុំរំលាយរយៈពេល 1ឆ្នាំ ហើយការជួលអគារនឹងបញ្ចប់កិច្ចសន្យាក្រោយការស្នើសុំរំលាយរយៈពេល 3ខែ (មាត្រា617 កថាខណ្ឌទី1)។

ចំណែកឯ នៅក្នុងច្បាប់ស្តីពីការជួលដី និង ជួលផ្ទះបានកំណត់ថា ការជួលដីត្រូវសន្មតថាមានអំឡុងពេល 30ឆ្នាំ បើទោះបីជាភាគីមិនបានកំណត់អំឡុងពេលក៏ដោយ ហើយការជួលផ្ទះវិញ អ្នកឱ្យជួលអាចស្នើសុំរំលាយកិច្ចសន្យាបាន ប៉ុន្តែ ត្រូវបញ្ជាក់អំពីមូលហេតុត្រឹមត្រូវនៃភាពចាំបាច់ដើម្បីប្រើប្រាស់សម្រាប់ខ្លួនឯង (ច្បាប់ស្តីពីការជួលដី និង ជួលផ្ទះ មាត្រា28) ហើយកិច្ចសន្យានឹងបញ្ចប់ក្រោយការស្នើសុំរំលាយរយៈពេល 6ខែ កន្លងផុត។

### 4. **កិច្ចសន្យាខ្ចីប្រើ**

នេះគឺជាកិច្ចសន្យាឱ្យខ្ចីធម្មតាមួយ ដែលមិនយកថ្លៃឈ្នួលក្នុងនាមជាតាវកាលិកតប ដូចករណីកិច្ចសន្យាជួលនោះទេ។ នេះមានន័យថា អ្នកខ្ចីដែលអាចប្រើប្រាស់កម្មវត្ថុដោយមិនបង់ថ្លៃឈ្នួល ទទួលបានផលប្រយោជន៍តែម្ខាងប៉ុណ្ណោះ។ ចំពោះកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ និង ជាកិច្ចសន្យាឯកតោភាគីនេះ មិនអាចកើតឡើងដោយគ្រាន់តែសន្យាផ្ទាល់មាត់នោះទេ ប៉ុន្តែត្រូវមានការប្រគល់កម្មវត្ថុជាក់ស្តែង ពោលគឺ កិច្ចសន្យានេះកើតឡើងតាមការប្រគល់វត្ថុ។ ប៉ុន្តែ នៅក្នុងសង្គមបច្ចុប្បន្ន កិច្ចសន្យានេះមិនមែនកើតឡើងចំពោះតែក្នុងរង្វង់គ្រួសារនោះទេ សូម្បីតែនៅក្នុងការធ្វើពាណិជ្ជកម្មដែលមានតម្លៃសេដ្ឋកិច្ចក៏កើតមានឡើងច្រើនផងដែរ ហេតុនេះហើយ កិច្ចសន្យានេះត្រូវបានផ្លាស់ប្តូរទៅជាប្រភេទនៃកិច្ចសន្យាដែលកើតឡើងតាមការព្រមព្រៀងវិញ (មាត្រា593)។ នៅក្នុងកិច្ចសន្យាខ្ចីប្រើត្រូវយកបញ្ញត្តិស្តីពីប្រទានកម្មមកអនុវត្តដូចគ្នា ចំពោះការទទួលខុសត្រូវក្នុងការធានា (មាត្រា596)។ ក្រៅពីនេះ ក្រមរដ្ឋប្បវេណីក៏បានកំណត់អំពី បញ្ញត្តិនានាដែលការពារដល់ភាគីអ្នកឱ្យខ្ចីដែលបាត់បង់ផលប្រយោជន៍តែម្ខាង ដូចជា អ្នកខ្ចីមានករណីយកិច្ចប្រគល់វិញនូវវត្ថុខ្ចីនៅពេលដែលគោលបំណងនៃការខ្ចីប្រើបានសម្រេច ប្រសិនបើមិនបានកំណត់អំពីអំឡុងពេលនៅក្នុងកិច្ចសន្យា ជាអាទិ៍។

### 5. **កិច្ចសន្យាខ្ចីបរិភោគ**

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាដែលវត្ថុខ្ចីបានប្រើប្រាស់អស់ ហើយអ្នកខ្ចីបរិភោគត្រូវសងវិញនូវវត្ថុដែលមានប្រភេទ គុណភាព និង បរិមាណដូចគ្នា។ ពោលគឺ ករណីដែលខ្ចីអង្ករពីអ្នកជិតខាងមក ហើយបរិភោគក្រោយមកយកអង្ករផ្សេងទៅសងវិញ ឬ ករណីខ្ចីប្រាក់ពីគេហើយក្រោយមកយកប្រាក់ទៅសងគេវិញ ជាអាទិ៍។ កម្ចីឥណទានពីធនាគារ ជាដើម គឺជាកិច្ចសន្យាខ្ចីបរិភោគប្រាក់នេះហើយ។ ដើមឡើយ ក្រមរដ្ឋប្បវេណីបានកំណត់កិច្ចសន្យាខ្ចីបរិភោគនេះ ជាកិច្ចសន្យាដែលកើតឡើងតាមការប្រគល់វត្ថុ ពោលគឺ ការខ្ចីបរិភោគដែលត្រូវប្រគល់នូវវត្ថុដែលមានប្រភេទ គុណភាព និងបរិមាណដូចគ្នាដោយគ្មានការប្រាក់ (កិច្ចសន្យាមិនយកតម្លៃថ្នូរ) ប៉ុណ្ណោះ (មាត្រា587) ប៉ុន្តែ ខ្ញុំយល់ថា ការបកស្រាយថាជាប្រភេទកិច្ចសន្យាដែលកើតឡើងតាមការព្រមព្រៀងក៏អាចទៅរួចផងដែរ ចំពោះកិច្ចសន្យាដែលមានភ្ជាប់ការប្រាក់ (កិច្ចសន្យាដែលមានតម្លៃថ្នូរ) ដូចជា កម្ចីឥណទានជាដើម។

ដោយឡែក ចំពោះអាត្រាការប្រាក់នៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវកម្រិតអាត្រាអតិបរិមាតាមការកំណត់របស់ច្បាប់ស្តីពីការកម្រិតអាត្រាការប្រាក់ ហើយការព្រមព្រៀងអំពីការប្រាក់ដែលលើសពីការកំណត់

របស់ច្បាប់នេះ គឺមោឃភាព (ផ្នែកនៃការប្រាក់ដែលស្ថិតនៅក្នុងការកម្រិត គឺមានអានុភាព)។ យ៉ាងណាមិញ ការខ្ចីបរិភោគប្រាក់ដែលធ្វើឡើងដោយស្ថាប័នដែលចុះបញ្ជីអាជីវកម្មផ្តល់ប្រាក់កម្ចីជាក់ស្តែង អាចកំណត់អំពីអាត្រាការប្រាក់ខ្ពស់ជាងច្បាប់ស្តីពីការកម្រិតអាត្រាការប្រាក់ ដោយផ្អែកលើច្បាប់ស្តីពីអាជីវកម្មផ្តល់ប្រាក់កម្ចី ប៉ុន្តែ ការអនុវត្តបែបនេះត្រូវបានលុបបំបាត់ក្រោយការធ្វើវិសោធនកម្មឆ្នាំ2010។

## 6. កិច្ចសន្យាម៉ៅការ

### (1) សញ្ញាណទូទៅ

កិច្ចសន្យាដែលឱ្យជាងសំណង់សង់ផ្ទះឱ្យ ជាអាទិ៍ គឺជាកិច្ចសន្យាម៉ៅការ។ ការម៉ៅការនេះមានលក្ខណៈពិសេសត្រង់ថា អ្នកម៉ៅការមិនត្រឹមតែផ្តល់កម្លាំងពលកម្មនោះទេ ថែមទាំងត្រូវសម្រេចការងារជាក់លាក់ណាមួយដែលជាគោលបំណងនៃកិច្ចសន្យា។ នេះជាប្រភេទនៃកិច្ចសន្យាអញ្ញមញ្ញដែលទទួលបានកម្រៃពីការសម្រេចការងារជាក់លាក់មួយ, ជាកិច្ចសន្យាយកតម្លៃថ្នូរ និង ជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀង។ ការបង់កម្រៃ និង ការប្រគល់កម្មវត្ថុនៃការងារមានទំនាក់ទំនងនៃការអនុវត្តព្រមគ្នា (មាត្រា633)។ ការជួលតន្ត្រីករឱ្យសម្តែងក៏ជាប្រភេទមួយនៃការងារម៉ៅការផងដែរ ប៉ុន្តែ ការងារដែលគ្មានការប្រគល់បែបនេះ ត្រូវផ្តល់កម្រៃនៅក្រោយពេលដែលការងារបានបញ្ចប់ (មាត្រា633 វាក្យខណ្ឌទី2)។ ប៉ុន្តែ នៅក្នុងការធ្វើវិសោធនកម្មច្បាប់ឆ្នាំ2017 បានកំណត់ថា ប្រសិនបើមិនអាចបន្តការងារបានទៀតនៅក្នុងដំណាក់នៃការអនុវត្តការងារ ដោយគ្មានមូលហេតុនៃការទទួលខុសត្រូវរបស់ម្ចាស់ការទេ ហើយបើសិនជាអ្នកម៉ៅការអាចផ្តល់តាវកាលិកដោយផ្នែកបាន ក្នុងករណីនេះ អ្នកម៉ៅការអាចទាមទារកម្រៃចំពោះផ្នែកដែលបានអនុវត្តការងារ ប្រសិនបើម្ចាស់ការអាចទទួលបានផលប្រយោជន៍ណាមួយពីតាវកាលិកនោះ ដោយចាត់ទុកថាតាវកាលិកមួយផ្នែកនោះបានសម្រេចស្ថាពរ (មាត្រា634)។ ម្យ៉ាងទៀត ដោយពិចារណាពីការម៉ៅការទាក់ទងនឹងការសាងសង់ជាដើម មានបញ្ញត្តិពិសេសមួយផ្នែកស្តីពីវិធីរំលាយ និងការទទួលខុសត្រូវក្នុងការធានានៅក្នុងការម៉ៅការ (កិច្ចសន្យាស្តង់ដារដែលត្រូវបង្កើតឡើងនៅក្នុងវិស័យសាងសង់ ដែលកំពុងប្រើប្រាស់គឺយោងតាមវិធាននេះ)។

### (2) ការទទួលខុសត្រូវក្នុងការធានា

អ្នកម៉ៅការមានការទទួលខុសត្រូវក្នុងការធានា ប្រសិនបើកម្មវត្ថុនៃការងារដែលបានសម្រេច និងប្រគល់មកនោះមានវិការៈ (ឧទាហរណ៍ ផ្ទះដែលបានសាងសង់ហើយនោះ មានជ្រាបទឹក)។ ដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណីពីមុនមានកំណត់បញ្ញត្តិពិសេសជាច្រើនអំពីការទទួលខុសត្រូវក្នុងការធានានៅក្នុងការម៉ៅការ ប៉ុន្តែនៅក្នុងការធ្វើវិសោធនកម្មច្បាប់ឆ្នាំ2017 នេះ គេបានកំណត់បញ្ញត្តិពិសេសតិចតួចប៉ុណ្ណោះអំពីការម៉ៅការ ដោយត្រូវយកបញ្ញត្តិស្តីពីការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យានៃការលក់ទិញ មកអនុវត្តដូចគ្នាចំពោះករណីម៉ៅការផងដែរ។ នេះមានន័យថា ទោះបីជាកម្មវត្ថុដែលបានប្រគល់ទៅឱ្យម្ចាស់ការមិនស្របតាមខ្លឹម

សារនៃកិច្ចសន្យាក៏ដោយ ក៏ម្ចាស់ការមិនអាចទាមទារឱ្យអនុវត្តពេញលេញ (ជួសជុល) បន្ថយតម្លៃ ឬ សំណងការខូចខាតនោះទេ បើសិនជាវិការៈនោះកើតឡើងពីការផ្តល់វត្ថុធាតុដើមរបស់ម្ចាស់ការ ឬ កើតឡើងពីការបញ្ជារបស់ម្ចាស់ការ (ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលអ្នកម៉ៅការបានដឹងអំពីភាពមិនត្រឹមត្រូវនៃវត្ថុធាតុដើម ឬ ការបញ្ជានោះ ហើយមិនបានជូនដំណឹងដល់ម្ចាស់ការ។ មាត្រា636)។ ដោយឡែក បញ្ញត្តិខាងលើនេះគឺជាវិធានដែលមាននៅមុនពេលវិសោធនកម្ម ហើយបញ្ញត្តិពិសេសជាច្រើនផ្សេងទៀតនៃការម៉ៅការត្រូវបានលុបចោលតាមរយៈវិសោធនកម្ម ហើយបញ្ញត្តិភាគច្រើនកាន់តែមានទំនោរទៅរកការលក់ទិញ។

### (3) ការរំលាយ

ចំណុចពិសេសនៃសិទ្ធិរំលាយសម្រាប់កិច្ចសន្យាម៉ៅការ គឺនៅមុនពេលការងារបញ្ចប់ជាស្ថាពរ ម្ចាស់ការអាចរំលាយកិច្ចសន្យានៅពេលណាក៏បាន ដោយបង់សំណងការខូចខាតឱ្យអ្នកម៉ៅការ (មាត្រា641)។ នេះគឺជាការពិចារណាដល់ករណីដែលម្ចាស់ការបានពឹងពាក់ការងារណាមួយ ដែលក្រោយមកយល់ឃើញថាមិនចាំបាច់ទៅវិញ ហេតុនេះ ម្ចាស់ការគ្រាន់តែបង់សំណងការខូចខាតដល់អ្នកម៉ៅការវិញ គឺគ្រប់គ្រាន់ហើយ។

## 7. កិច្ចសន្យាអាណត្តិ

### (1) សញ្ញាណទូទៅ

កិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាដែលពឹងពាក់ឱ្យបុគ្គលណាម្នាក់ធ្វើសកម្មភាពណាមួយមកឱ្យខ្លួន ហើយខ្លឹមសារនៃសកម្មភាពនោះអាចជាសកម្មភាពគតិយុត្ត ដូចជាការចុះកិច្ចសន្យាជំនួសខ្លួនក៏បាន ឬ សកម្មភាពជាក់ស្តែង ដូចជា ការធ្វើជាអ្នកមើលថែកូនជំនួសខ្លួនក៏បានដែរ។ វាជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀង ហើយអាចជាកិច្ចសន្យាដែលយកតម្លៃថ្នូរ ឬ មិនយកតម្លៃថ្នូរតាមការព្រមព្រៀងរបស់ភាគី (ដោយសារ វាជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀង ហេតុនេះ ការធ្វើលិខិតប្រគល់អាណត្តិមិនមានជាលក្ខខណ្ឌបង្កើតកិច្ចសន្យានោះទេ)។ ជាគោលការណ៍ អាណត្តិសំដៅទៅលើ ករណីដែលអាណត្តិគាហកខ្លួនឯង មានករណីយកិច្ចចាត់ចែងកិច្ចការដែលខ្លួនបានទទួលពីអាណត្តិទាយក ហេតុនេះ អាណត្តិគាហកត្រូវសម្រេចកិច្ចការនោះ (មាត្រា644) ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត (ករណីយកិច្ចគ្រប់គ្រងដោយសុចរិត)។

យើងអាចពិចារណាបានថា កិច្ចសន្យាអាណត្តិយកទំនាក់ទំនងនៃការជឿជាក់របស់ភាគីជាមូលដ្ឋាន ហើយជាគោលការណ៍ អាណត្តិទាយកអាចរំលាយកិច្ចសន្យាពាក់កណ្តាលទីបាន ប៉ុន្តែ អាណត្តិគាហកអាចទាមទារសោហ៊ុយ និងកម្រៃដែលបានធ្វើកន្លងមកបាន (មាត្រា648 កថាខណ្ឌទី3)។

ដោយឡែក ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានកំណត់អំពីអាណត្តិ និង ការតំណាងផ្សេងពីគ្នា (ជំពូកទី2 III.4) ហើយក៏អាចមានករណីខ្លះ អាណត្តិគាហក និង អ្នកតំណាងគឺជាបុគ្គលតែមួយផងដែរ។

យ៉ាងណាមិញ យើងបានពិនិត្យមើលរួចហើយអំពីកិច្ចសន្យាអាណាព្យាបាលតាមការស្ម័គ្រចិត្តដោយផ្អែកលើច្បាប់ស្តីពីប្រព័ន្ធអាណាព្យាបាលតាមការស្ម័គ្រចិត្ត (ជំពូកទី2 III.2(3)③)។ ហើយកិច្ចសន្យាអាណាព្យាបាលតាមការស្ម័គ្រចិត្តនេះ គឺជាកិច្ចសន្យាអាណត្តិដែលសាមីខ្លួនបានផ្តល់សិទ្ធិតំណាង ឱ្យទៅអ្នកអាណាព្យាបាលតាមការស្ម័គ្រចិត្ត លើការគ្រប់គ្រងទ្រព្យសម្បត្តិ និង ជីវភាពរបស់ខ្លួននៅក្នុងស្ថានភាពដែលសាមីខ្លួនអលទ្ធភាពក្នុងការវិនិច្ឆ័យដោយសារតែវិបត្តិបញ្ញាស្មារតី។ ដូចនេះ ចំណុចដែលមិនមានបញ្ញត្តនៅក្នុងច្បាប់ស្តីពីប្រព័ន្ធអាណាព្យាបាលតាមការស្ម័គ្រចិត្ត ត្រូវយកបញ្ញត្តិស្តីពីកិច្ចសន្យាអាណត្តិក្នុងក្រមរដ្ឋប្បវេណីមកអនុវត្ត។

### (2) **ករណីយកិច្ចរបស់អាណត្តិទាយក (សិទ្ធិរបស់អាណត្តិគាហក)**

នៅពេលដែលអាណត្តិគាហកបានចេញចំណាយដែលចាំបាច់សម្រាប់ចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចទាមទារការចំណាយនោះពីអាណត្តិទាយកបាន (មាត្រា650 កថាខណ្ឌទី1។ ការទាមទារឱ្យបង់ជាមុនក៏បានដែរ។ មាត្រា649)។ ហើយបើសិនជាអាណត្តិគាហកបានទទួលកាតព្វកិច្ចជំនួសឱ្យអាណត្តិទាយកដើម្បីចាត់ចែងកិច្ចការអាណត្តិ ក្នុងករណីនេះ អាណត្តិគាហកអាចឱ្យអាណត្តិទាយកសងកាតព្វកិច្ចនោះជំនួសខ្លួនបាន (មាត្រាដដែល កថាខណ្ឌទី2)។ មួយវិញទៀត នៅពេលដែលអាណត្តិគាហកបានទទួលរងការខូតខាតដោយសារចាត់ចែងកិច្ចការអាណត្តិដោយគ្មានកំហុសរបស់ខ្លួនទេ អាណត្តិគាហកអាចទាមទារសំណងការខូចខាតនោះពីអាណត្តិទាយកបាន (មាត្រាដដែល កថាខណ្ឌទី3)។ ករណីយកិច្ចសងសំណងរបស់អាណត្តិទាយក គឺជាការទទួលខុសត្រូវដោយគ្មានកំហុស។ ការខូចខាតដែលកើតឡើងដោយសារការចាត់ចែងកិច្ចការអាណត្តិមានដូចជា ការឆ្លងជំងឺដែលបណ្តាលមកពីការទទួលអាណត្តិការងារមើលថែរក្សាអ្នកជំងឺដែលមានជំងឺឆ្លងជាដើម ពោលគឺ កិច្ចការអាណត្តិដែលងាយបង្កគ្រោះថ្នាក់។ ប៉ុន្តែ ការជួបគ្រោះថ្នាក់ចរាចរណ៍នៅពេលធ្វើដំណើរទៅចុះកិច្ចសន្យាដែលអាណត្តិទាយកពឹងពាក់ឱ្យធ្វើជាដើមនោះ មិនត្រូវរាប់បញ្ចូលឡើយ។

## 8. **កិច្ចសន្យាបញ្ញើ**

កិច្ចសន្យាដែលឱ្យគេថែរក្សាវត្ថុសម្រាប់ខ្លួនឯង ហៅថាកិច្ចសន្យាបញ្ញើ។ ដើមឡើយកិច្ចសន្យានេះ គឺជាកិច្ចសន្យាដែលកើតឡើងតាមការប្រគល់វត្ថុ តាមរយៈការសន្យារបស់ភាគីម្ខាងថានឹងថែរក្សាវត្ថុណាមួយសម្រាប់ភាគីម្ខាងទៀត ហើយបានទទួលវត្ថុនោះមកក្នុងដៃ ប៉ុន្តែ វិសោធនកម្មច្បាប់ឆ្នាំ2017 បានផ្លាស់ប្តូរទៅជាប្រភេទនៃកិច្ចសន្យាដែលកើតឡើងតាមការព្រមព្រៀងវិញ (មានអានុភាពតាមការព្រមព្រៀង) (មាត្រា657)។ អ្នកឱ្យគេរក្សាទុកវត្ថុហៅថា អ្នកផ្ញើ ហើយអ្នកដែលទទួលរក្សាទុកវត្ថុ ហៅថា អ្នកទទួលបញ្ញើ។ បញ្ញើបែងចែកជា បញ្ញើដែលបង់កម្រៃ និង បញ្ញើដែលមិនបង់កម្រៃ។ ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកទទួលបញ្ញើដែលមិនបង់កម្រៃ គឺ «ប្រុងប្រយ័ត្នចំពោះវត្ថុនោះឱ្យដូចជាទ្រព្យសម្បត្តិរបស់ខ្លួន» ចំពោះវត្ថុបញ្ញើ (មាត្រា659)។ ករណីយកិច្ចនេះ គឺជាការប្រុងប្រយ័ត្នដែលមានកម្រិតទាបជាងករណីយកិច្ចគ្រប់គ្រងដោយសុចរិតក្នុងកិច្ចសន្យាអាណត្តិជាអាទិ៍ (ប៉ុន្តែ អ្នកទទួលបញ្ញើដែលបង់កម្រៃត្រូវមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត)។

## 9. កិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុន គឺជាកិច្ចសន្យាមួយប្រភេទដែលបង្កើតជាក្រុម ហើយកើតមានអានុភាពនៅពេលដែលភាគីនីមួយៗបានសន្យាថាវិនិយោគទ្រព្យធនរបស់ខ្លួន ដើម្បីប្រកបកិច្ចការណាមួយរួមគ្នា (មាត្រា667 កថាខណ្ឌទី1)។ ទ្រព្យធនដែលប្រើនៅកន្លែងនេះ សំដៅទៅលើទាំងការផ្តល់ទ្រព្យសម្បត្តិ និង ការផ្តល់ពលកម្ម (មាត្រាដដែល កថាខណ្ឌទី2)។ ប៉ុន្តែ តម្រូវឱ្យមានការប្រកបកិច្ចការណាមួយរួមគ្នា។

លក្ខណៈពិសេសមួយនៃក្រុមហ៊ុន គឺការវិនិយោគ និង ការធ្វើលទ្ធកម្មទ្រព្យសម្បត្តិក្រុមហ៊ុនជាដើម នឹងក្លាយជាកម្មសិទ្ធិរួមទាំងអស់។ មាត្រាច្បាប់សរសេរថា ការវិនិយោគរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ និង ទ្រព្យសម្បត្តិផ្សេងទៀតរបស់ក្រុមហ៊ុន «ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុន» (មាត្រា 668) ប៉ុន្តែ ទស្សនល្បីៗបានហៅទម្រង់កម្មសិទ្ធិអវិភាគនៃក្រុមហ៊ុនថា «កម្មសិទ្ធិរួម»។ នេះគ្រាន់តែជា កម្មសិទ្ធិអវិភាគក្នុងន័យចង្អៀត ហើយវាមានន័យថា កម្មសិទ្ធិករអវិភាគម្នាក់ៗមានចំណែកអវិភាគរៀងៗខ្លួន ហើយអាចទាមទារឱ្យបែងចែកចំណែកអវិភាគរបស់ខ្លួនបាន ប៉ុន្តែ លក្ខណៈពិសេសនៅក្នុងករណីក្រុមហ៊ុនវិញ គឺសមាជិកក្រុមហ៊ុននីមួយៗគ្រាន់តែមានចំណែកអវិភាគតាមតួលេខរៀងខ្លួន ប៉ុន្តែមិនអាចទាមទារឱ្យបែងចែកបាននោះទេ ហើយទ្រព្យសម្បត្តិទាំងអស់គឺជាវត្ថុរួមរបស់ក្រុមហ៊ុន។ ហើយសិទ្ធិលើបំណុលដែលកើតចេញពីការធ្វើជំនួញរវាងក្រុមហ៊ុនជាមួយអ្នកណាមួយ ក៏អនុវត្តដូចគ្នាផងដែរ គឺទម្រង់នៃការទាមទារធ្វើឡើងក្នុងនាមសមាជិកក្រុមហ៊ុនទាំងអស់ (សមាជិកក្រុមហ៊ុនតែម្នាក់មិនអាចទាមទារតែចំណែករបស់ខ្លួននោះទេ)។

## 10. កិច្ចសន្យាដែលមានច្បាប់កំណត់ផ្សេងទៀត

កិច្ចសន្យាផ្សេងទៀតដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី រួមមាន កិច្ចសន្យាដូរ ដែលជាការប្តូរកម្មសិទ្ធិនៃវត្ថុមួយជាមួយនឹងកម្មសិទ្ធិនៃវត្ថុមួយផ្សេងទៀតក្រៅពីប្រាក់ (មាត្រា586។ យើងអាចគិតស្រដៀងនឹងការលក់ទិញដែលប្តូរវត្ថុជាមួយប្រាក់), កិច្ចសន្យាការងារ ដែលជាការជួលបុគ្គលណាមួយឱ្យផ្តល់ពលកម្ម (មាត្រា623។ ក្នុងពេលបច្ចុប្បន្ននេះ កិច្ចសន្យាការងារក្នុងសង្គមទូទៅ ត្រូវយកច្បាប់ពិសេសដូចជា ច្បាប់ស្តីពីស្តង់ដារការងារជាដើមមកអនុវត្ត ហេតុនេះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណី អនុវត្តទៅលើតែកិច្ចសន្យានៃអ្នកបម្រើការងារតាមផ្ទះប៉ុណ្ណោះ ហើយបញ្ញត្តិទាំងនេះពុំសូវមានសារៈសំខាន់នោះទេ), កិច្ចសន្យាធនលាភសាមញ្ញិកមួយជីវិត ដែលភាគីម្ខាងត្រូវផ្តល់ប្រាក់ ឬ តាវកាលិកផ្សេងទៀតជាទៀងទាត់ដល់ភាគីម្ខាងទៀត ឬ តតិយជន រហូតដល់ពេលដែលភាគីណាម្ខាងទទួលមរណភាព (មាត្រា689។ ឧទាហរណ៍ កូនបំណុលនៃធនលាភទទួលយកប្រាក់ ឬ ភាគហ៊ុនដែលជាទ្រព្យធនដើម ហើយផ្តល់ការប្រាក់ ឬ ធនលាភនៃទ្រព្យធននោះជាទៀងទាត់ទៅឱ្យម្ចាស់បំណុលនៃធនលាភជាដើម។ កិច្ចសន្យានេះពុំសូវមានការអនុវត្តនៅប្រទេសជប៉ុននោះទេ), កិច្ចសន្យាសះជា ដែលជាកិច្ចសន្យាបញ្ចប់វិវាទ ដោយភាគីធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក (មាត្រា695)។ ការសះជានេះកើតឡើងតាមការចុះកិច្ចសន្យាដោយស្ម័គ្រចិត្តរបស់ភាគីទាំងសងខាង ឬ តាមការជួយសម្របសម្រួលពីចៅក្រម (ដោយឡែក ពាក្យពេជន៍សាមញ្ញដែលស្រដៀងគ្នានឹង

ការសះជា គឺការដោះស្រាយវិវាទដោយពិភាក្សាគ្នា។ ពាក្យនេះអាចមានន័យដូចនឹងកិច្ចសន្យាសះជា ប៉ុន្តែ ការសះជាសំដៅទៅលើការធ្វើសម្បទានទៅវិញទៅមក ដោយឡែក ការដោះស្រាយវិវាទតាមការពិភាក្សាអាចមានករណីខ្លះភាគីតែម្ខាងបោះបង់ចោលការអះអាងរបស់ខ្លួន(ក្រៅផ្លូវតុលាការ) ហើយបញ្ចប់វិវាទ)។

11. **កិច្ចការពារអ្នកប្រើប្រាស់ និង** Cooling-Off

(1) **ប្រព័ន្ធ Cooling-Off**

នៅពេលដែលភាគីបានចុះកិច្ចសន្យាជាមួយគ្នា ភាគីនីមួយៗត្រូវអនុវត្តកាតព្វកិច្ចដោយគោរពគោលការណ៍សុចរិត និងស្មោះត្រង់ ហើយមិនអាចបញ្ចប់កិច្ចសន្យាដោយចិត្តឯងនោះទេ លើកលែងតែករណីមានប្រាក់កក់ដើម្បីរំលាយកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយ មានករណីខ្លះដែលអ្នកប្រើប្រាស់ទូទៅ បានចុះកិច្ចសន្យាដោយលង់ជឿជាក់លើឈ្មួញទុច្ចរិត ឬ សំដីផ្អែមរបស់អ្នកលក់។ ពិតហើយថា ករណីបែបនេះ យើងអាចលុបចោលការបង្ហាញឆន្ទៈ ហើយធ្វើឱ្យកិច្ចសន្យានោះក្លាយជាមោឃភាព បើសិនជាមានការឆបោក ឬ ការភាន់ច្រឡំ ហើយបើសិនជាមានការមិនអនុវត្តកាតព្វកិច្ចវិញ យើងអាចរំលាយកិច្ចសន្យាបាន ប៉ុន្តែ មានករណីជាច្រើនដោយសារការប្រើប្រាស់ពាក្យពេចន៍របស់អ្នកលក់ ឬ ការលង់តាមការអូសទាញតាមបរិយាកាសជុំវិញជាដើម (ដោយសារតែចុះកិច្ចសន្យាតាមការសម្រេចចិត្តដោយឆន្ទៈរបស់ខ្លួន) គឺពិបាកឱ្យយើងអាចអះអាងអំពីការឆបោក ឬ ការភាន់ច្រឡំណាស់ ហើយក៏មិនអាចរំលាយកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចនោះទេ ដោយសារតែភាគីម្ខាងទៀតបានរៀបចំទំនិញទុកជាមុន និង ប្រគល់តាមការព្រមព្រៀងរួចរាល់។ នៅក្នុងករណីបែបនេះ អ្នកប្រើប្រាស់ដែលមិនអាចទទួលបានការការពារដោយផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី អាចទទួលបានការការពារជាពិសេសតាមប្រព័ន្ធ Cooling-Off ដែលមានកំណត់នៅក្នុងច្បាប់ពិសេសមួយចំនួន ដែលប្រព័ន្ធនេះផ្តល់ឱកាសដល់អ្នកប្រើប្រាស់អាចដោះខ្លួនពីកិច្ចសន្យាណាមួយ ក្រោយពេលដែលបានពិចារណាជាក់លាក់ក្នុងអំឡុងពេលកំណត់មួយ។

ប្រព័ន្ធនេះមានកំណត់នៅក្នុង**ច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មជាក់លាក់** (ច្បាប់ចាស់ស្តីពីការលក់ចល័ត) **ច្បាប់ស្តីពីការលក់ដោយបង់រំលស់ និង ច្បាប់ស្តីពីការធ្វើអាជីវកម្មដីលំនៅឋាន** ជាអាទិ៍។ នៅក្នុងច្បាប់នេះបានចងកាតព្វកិច្ចឱ្យអាជីវករប្រគល់នូវលិខិតកិច្ចសន្យាជាអាទិ៍ទៅឱ្យអ្នកទិញនៅពេលចុះកិច្ចសន្យា ហើយអ្នកទិញអាចអនុវត្តសិទ្ធិ Cooling-Off ដែលមានចែងក្នុងកិច្ចសន្យានោះ (តាមន័យគតិយុត្តគឺសំដៅលើការដកសំណើ ឬ ការរំលាយកិច្ចសន្យា) (ប៉ុន្តែ ការអនុវត្តសិទ្ធិ Cooling-Off នេះ អាចធ្វើបានចំពោះតែប្រភេទនៃកិច្ចសន្យាដែលមានកំណត់ក្នុងច្បាប់ពិសេសប៉ុណ្ណោះ) ក្នុងអំឡុងពេលកំណត់មួយគិតចាប់ពីពេលបានទទួលកិច្ចសន្យា (ការទិញទំនិញពីការធ្វើពាណិជ្ជកម្មជាក់លាក់ គឺមានរយៈពេល 8ថ្ងៃ)។

### (2) ការបង្កើតច្បាប់ស្តីពីកិច្ចសន្យាអ្នកប្រើប្រាស់

នៅក្នុងច្បាប់ពិសេសដែលបានរៀបរាប់ខាងលើនេះ ដែលមានកម្មវត្ថុកំណត់ពីប្រភេទអាជីវកម្មនីមួយៗ មិនអាចការពារដល់អ្នកប្រើប្រាស់បានពេញលេញនោះទេ។ ដូចនេះ **ច្បាប់ស្តីពីកិច្ចសន្យាអ្នកប្រើប្រាស់** បានតាក់តែងឡើងនៅក្នុងខែមេសា ឆ្នាំ 2000 ហើយដាក់ឱ្យប្រើប្រាស់នៅខែមេសា ឆ្នាំ2001 (ត្រូវយកមកអនុវត្តលើកិច្ចសន្យាដែលកើតមានក្រោយច្បាប់នេះដាក់ឱ្យប្រើប្រាស់)។ ច្បាប់នេះមានគោលបំណងចងក្រងនូវបទបញ្ញត្តិទូទៅមួយដើម្បីការពារដល់អ្នកប្រើប្រាស់ពីការលក់ទិញទំនិញ ឬ សេវា ឬ ការចុះកិច្ចសន្យាផ្គត់ផ្គង់ដែលមិនត្រឹមត្រូវ និង វិធីសាស្ត្រលក់ដែលទុច្ចរិត។ តាមរយៈច្បាប់នេះ អ្នកប្រើប្រាស់អាចលុបចោលកិច្ចសន្យាដែលបានធ្វើឡើងក្នុងស្ថានភាពដូចជា អ្នកប្រើប្រាស់បានទទួលការពន្យល់បោកប្រាស់អំពីចំណុចសំខាន់ណាមួយ ឬ ការពន្យល់អំពីហេតុដែលមិនពិតទាល់តែសោះដូចជា ការឡើងថ្លៃទំនិញ ឬ អ្នកលក់អង្គុយរង់ចាំនៅផ្ទះរហូតមិនព្រមចាកចេញ (មិនព្រមត្រឡប់ទៅវិញ) ឬ អ្នកលក់មិនព្រមឱ្យចាកចេញពីទីតាំងលក់ (ការឃាត់ឃាំង) ជាអាទិ៍ (នេះគឺជាការទទួលស្គាល់អំពី សិទ្ធិលុបចោលកិច្ចសន្យា បើទោះបីជាលក្ខខណ្ឌនៃការឆបោក ឬ ការគម្រាមកំហែងដែលកំណត់ក្នុងក្រមរដ្ឋប្បវេណីមិនទាន់បំពេញក៏ដោយ)។ ហើយកិច្ចសន្យាដែលមានលក្ខខណ្ឌឱ្យភាគីអ្នកប្រើប្រាស់តែម្ខាងទទួលរងការបាត់បង់ផលប្រយោជន៍ ត្រូវមោឃភាព (ដូចជា អ្នកលក់ «មិនទទួលខុសត្រូវទាំងស្រុងចំពោះករណីបែបណាក៏ដោយ» ជាអាទិ៍)។

# ជំពូកទី៥

## នីតិសិទ្ធិលើចំណុល (2) — នីតិអំពើអនីត្យានុកូល

I. **មូលហេតុនៃការកកើតសិទ្ធិលើចំណុលក្រៅពីកិច្ចសន្យា**

II. **ការសិក្សាអំពីចំណុចសំខាន់នៃអំពើអនីត្យានុកូល**

1. អំពើអនីត្យានុកូលគឺជា
2. គំនិតដើមស្តីពីសំណងការខូចខាតនៃអំពើអនីត្យានុកូល
3. លក្ខខណ្ឌបង្កើតអំពើអនីត្យានុកូល
4. អានុភាពនៃអំពើអនីត្យានុកូល
5. អំពើអនីត្យានុកូលពិសេស

III. **ការសិក្សាអំពីចំណុចសំខាន់នៃការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនឥតហេតុ**

1. ការគ្រប់គ្រងដោយឈឺឆ្អាល
2. សេចក្តីចម្រើនឥតហេតុ

## I. មូលហេតុនៃការកកើតសិទ្ធិលើបំណុលក្រៅពីកិច្ចសន្យា

ដូចបានរៀបរាប់នៅក្នុងជំពូកទី4 នៅក្នុងផ្នែកស្តីពីសិទ្ធិលើបំណុលពិសេសៗ បានកំណត់អំពីមូលហេតុនៃការកកើតសិទ្ធិលើបំណុលជា 4ប្រភេទ។ នៅក្នុងនោះមូលហេតុដែលសំខាន់ជាងគេបំផុត គឺកិច្ចសន្យា ហើយបន្ទាប់មកទៀតមាន ការគ្រប់គ្រងដោយឈឺឆ្អាល សេចក្តីចម្រើនឥតហេតុ និង អំពើអនីត្យានុកូល។ នៅក្នុងចំណោមមូលហេតុនៃការកកើតសិទ្ធិលើបំណុលទាំងនោះ យើងអាចនិយាយថា ការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនឥតហេតុ គឺជាករណីពិសេស ប៉ុន្តែ អំពើអនីត្យានុកូលមានសារៈសំខាន់បន្ទាប់ពីកិច្ចសន្យា។ ខ្ញុំនឹងពន្យល់ចាប់ពីចំណុចស្តីពីអំពើអនីត្យានុកូលមុនដែលមានសារៈខាន់ខ្លាំង ប៉ុន្តែខុសពីលំដាប់លំដោយនៃមាត្រាច្បាប់ ។

## II. ការសិក្សាអំពីចំណុចសំខាន់នៃអំពើអនីត្យានុកូល

### 1. អំពើអនីត្យានុកូលគឺជា

អំពើអនីត្យានុកូល សំដៅទៅលើការកកើតសិទ្ធិទាមទារឱ្យសងសំណងការខូចខាតដែលជនរងគ្រោះមានទៅលើចារី នៅក្នុងប្រព័ន្ធផ្តល់សំណងការខូចខាត ក្នុងករណីដែលបុគ្គលណាម្នាក់បានបង្ករជាការខូចខាតដោយខុសច្បាប់ទៅលើបុគ្គលផ្សេង ដោយចេតនា ឬ កំហុស។ ក្រមរដ្ឋប្បវេណីមាត្រា709 កំណត់ថា «បុគ្គលដែលបានបំពានដល់សិទ្ធិ និង ផលប្រយោជន៍តាមផ្លូវច្បាប់របស់បុគ្គលដទៃ ដោយចេតនា ឬ កំហុស ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ»។ ពាក្យពេចន៍ដែលប្រើប្រាស់នៅមុនពេលវិសោធនកម្មច្បាប់ឆ្នាំ2004 គឺ «បានបំពានដល់សិទ្ធិរបស់បុគ្គលដទៃ» ហេតុនេះហើយទើបពីមុនធ្លាប់មានបញ្ហាត្រង់ថា បើសិនជាការបំពាននោះមិនបានធ្វើទៅលើសិទ្ធិទេ តើវាអាចក្លាយជាអំពើអនីត្យានុកូលដែរឬទេ? បច្ចុប្បន្ននេះ ចំណុចនេះត្រូវបានបកស្រាយថា «ការបំពានខុសច្បាប់ដល់បុគ្គលដទៃ» ហើយគេបានវិសោធនកម្មដោយប្រើប្រាស់ពាក្យដែលមានន័យច្បាស់លាស់។

ដូចនេះ ឧទាហរណ៍ជាក់ស្តែងអំពីអំពើអនីត្យានុកូលគ្របដណ្តប់លើករណីជាច្រើនដូចជា គ្រោះថ្នាក់ចរាចរណ៍ ការបំពុលបរិស្ថាន កំហុសនៃការព្យាបាល ដែលគេហៅថាអំពើអនីត្យានុកូលនៃអង្គហេតុ និង ការបំពានផលប្រយោជន៍អាជីវកម្ម (**ដណ្តើមអតិថិជន**) និង ការដណ្តើមយកកិច្ចសន្យា (**ការបំពានសិទ្ធិលើបំណុលយ៉ាងធ្ងន់ធ្ងរ**) ដែលគេហៅថា **អំពើអនីត្យានុកូលនៃជំនួញ**។ កម្មវត្ថុនៃសំណងរួមមានការខូចខាតជាទ្រព្យសម្បត្តិ និង ការខូចខាតផ្លូវចិត្ត (ពោលគឺ **សំណងជំងឺចិត្ត**)។

## 2. គំនិតដើមស្តីពីសំណងការខូចខាតនៃអំពើអនីត្យានុកូល

ខ្ញុំសូមពន្យល់អំពីគោលគំនិតនៃអំពើអនីត្យានុកូល ដោយប្រៀបធៀបជាមួយនឹងទោសព្រហ្មទណ្ឌដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។ សំណងការខូចខាតក្នុងក្រមរដ្ឋប្បវេណី និង ទោសព្រហ្មទណ្ឌ (រួមទាំងទោសពិន័យជាប្រាក់) នៅក្នុងក្រមព្រហ្មទណ្ឌ គឺជារបស់ 2 ដែលខុសពីគ្នាដាច់ស្រឡះ។ អំពើអនីត្យានុកូលមិនមែនជាការបង្គាប់ឱ្យសងសំណងការខូចខាត ក្នុងនាមជាទោសទណ្ឌចំពោះចារីនោះទេ។ វាគ្រាន់តែជាការពិចារណាអំពីសមភាពនៃការទទួលខុសត្រូវនូវការខូចខាត ដែលចារីត្រូវប៉ះប៉ូវផ្នែកសេដ្ឋកិច្ច ឬ ផ្នែកស្មារតីដល់ជនរងគ្រោះ ពោលគឺ ការឱ្យបំពេញចន្លោះឡើងវិញ។ ហើយអំពើខ្លះត្រូវក្លាយជាបទល្មើសតាមក្រមព្រហ្មទណ្ឌ រួមជាមួយអំពើអនីត្យានុកូលតាមក្រមរដ្ឋប្បវេណី ប៉ុន្តែ អំពើខ្លះអាចបង្កើតជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែ មិនអាចក្លាយជាអំពើអនីត្យានុកូលក៏មាន ហើយក៏អាចផ្ទុយពីនេះ គឺអំពើខ្លះក្លាយជាអំពើអនីត្យានុកូល ប៉ុន្តែមិនបង្កើតជាបទល្មើសព្រហ្មទណ្ឌនោះទេ។ ពីព្រោះលក្ខខណ្ឌដើម្បីបង្កើតអំពើអនីត្យាកូល និង លក្ខខណ្ឌដែលនាំឱ្យកើតមានបទល្មើសនីមួយៗ គឺខុសគ្នាហើយដូចបានរៀបរាប់ខាងលើ អំពីភាពខុសគ្នានៃគោលគំនិតរបស់ប្រព័ន្ធទាំង2 នេះ។ ឧទាហរណ៍ ការបើកបរឡានក្នុងគោលបំណងបុកបុគ្គលណាមួយ ហើយបង្ករជារបួសស្នាម ក្នុងករណីនេះ អំពើអនីត្យានុកូលនឹងកើតមានឡើង ហើយចារីនឹងត្រូវទាមទារឱ្យបង់សំណងការខូចខាតជាថ្លៃព្យាបាលរបួស និង ផលប្រយោជន៍ដែលបាត់បង់ក្នុងអំឡុងពេលដែលមិនអាចធ្វើការបាន ហើយទន្ទឹមនឹងនេះ ចារីនឹងត្រូវទទួលទោសបង្ករបួសស្នាមតាមក្រមព្រហ្មទណ្ឌ។ ប៉ុន្តែ បើសិនជាការបើកឡានប៉ះទង្គិចដល់ភាគីម្ខាងទៀតកើតឡើងដោយសារកំហុសវិញ បទល្មើសព្រហ្មទណ្ឌនឹងមិនចោទជាបញ្ហាទេ តែសំណងការខូចខាតតាមអំពើអនីត្យានុកូលនឹងកើតមានឡើង។ ផ្ទុយមកវិញ បើទោះបីជាបទល្មើសព្រហ្មទណ្ឌកើតមានក៏ដោយ ប៉ុន្តែ បើមិនមានកើតឡើងនូវការខូចខាតជាទ្រព្យសម្បត្តិ ឬ ស្មារតីដល់បុគ្គលដទៃនោះទេ អំពើអនីត្យានុកូលក៏ពុំមានកើតមានឡើងដែរ។

## 3. លក្ខខណ្ឌបង្កើតអំពើអនីត្យានុកូល

មាត្រា709 បានកំណត់អំពីលក្ខខណ្ឌទូទៅនៃការបង្កើតនូវអំពើអនីត្យានុកូលទូទៅជា 4 គឺ (1) ចេតនា ឬ កំហុសរបស់ចារី (2) ភាពខុសច្បាប់នៃអំពើបំពាន (3) ការកើតឡើងការខូចខាត និង (4) ទំនាក់ទំនងហេតុនិងផលរវាងអំពើបំពាននិងការខូចខាត។

### (1) ចេតនា និង កំហុស

ចំណុចនេះយើងអាចហៅបានថាជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ធំទាំង3 នៃក្រមរដ្ឋប្បវេណី គឺ «**គោលការណ៍ទទួលខុសត្រូវដោយមានកំហុស**»។ ពោលគឺ បើសិនជាទង្វើគ្រប់យ៉ាងទាំងអស់របស់យើងត្រូវតែមានការទទួលខុសត្រូវ ដោយមិនពិចារណាអំពីភាពមាន ឬ គ្មានកំហុសទាល់តែសោះនោះ ការអភិវឌ្ឍន៍សកម្មភាពរបស់បុគ្គលនីមួយៗនឹងត្រូវបានរារាំង ហេតុនេះហើយ ទើបគេបង្កើតឱ្យមាននូវគោលគំនិតស្តីពីការទទួលខុសត្រូវតែ

ក្នុងករណីមានចេតនា ឬ កំហុសប៉ុណ្ណោះ ដើម្បីរក្សាការពារនូវសេរីភាពនៃការធ្វើសកម្មភាពរបស់បុគ្គលនីមួយៗ។ គោលគំនិតនេះនៅតែបន្តអនុវត្តហូតមកដល់ពេលបច្ចុប្បន្ន ប៉ុន្តែ ការរីកចម្រើននៃសង្គមពាណិជ្ជកម្មបានធ្វើឱ្យគេបន្ថែមនូវគោលគំនិតបន្ថែមទៀត គឺ ការទទួលខុសត្រូវដោយគ្មានកំហុស សម្រាប់អនុវត្តទៅលើការខូចខាតមួយចំនួននៅក្នុងបរិបទផ្សេងៗនៃសង្គមបច្ចុប្បន្ន។ ដោយឡែក ទ្រឹស្តីនៃកំហុស គឺពិចារណាអំពីការមិនប្រុងប្រយ័ត្ននៅក្នុងចិត្តរបស់ចារីម្នាក់ៗតាមលក្ខណៈអត្តនោម័ត ប៉ុន្តែ នៅពេលបច្ចុប្បន្ននេះ គេប្តូរមកពិចារណាទៅលើការល្មើសទៅនឹងករណីយកិច្ចជៀសវាងនូវលទ្ធផលដែលអាចសម្រេចបានដោយសត្យានុម័ត ដែលជាការខកខានអនុវត្តករណីយកិច្ចត្រូវជៀសវាងនូវលទ្ធផលដែលអាចការពារបាន បើសិនជាចារីបានព្យាករ និង ប្រុងប្រយ័ត្នជាមុន។

យ៉ាងណាមិញ នៅក្នុងករណីអំពើអនីត្យានុកូល ជនរងគ្រោះដែលទាមទារសំណង ត្រូវបញ្ជាក់អំពីចេតនា ឬ កំហុសរបស់ចារី (ចំណុចនេះ បញ្ច្រាសគ្នាជាមួយនឹងករណីភាគីនៃកិច្ចសន្យា។ ដើមឡើយ ភាគីនៃកិច្ចសន្យាត្រូវឈរលើករណីយកិច្ចនៃការអនុវត្តដោយផ្អែកតាមគោលការណ៍សុចរិតនិងស្មោះត្រង់ ហេតុនេះ បើសិនជាមានការមិនអនុវត្តកាតព្វកិច្ចនៅក្នុងកិច្ចសន្យា ម្ចាស់បំណុលដែលទាមទារសំណងការខូចខាត មិនចាំបាច់បញ្ជាក់អំពីហេតុនៃការទទួលខុសត្រូវដូចជា ចេតនា ឬ កំហុសរបស់កូនបំណុលដែលមិនអនុវត្តនោះទេ ហើយកូនបំណុលត្រូវបញ្ជាក់ថាខ្លួនគ្មានហេតុនៃការទទួលខុសត្រូវ ទើបអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងការខូចខាត។

### (2) **ភាពខុសច្បាប់**

លក្ខខណ្ឌទី2 គឺជាភាពខុសច្បាប់នៃការបំពានសិទ្ធិ និង ផលប្រយោជន៍ (មានអំពើបំពានខុសច្បាប់) ដូចពាក្យពេចន៍ដែលប្រើប្រាស់ក្នុងមាត្រាច្បាប់ខាងលើនេះ។ ឧទាហរណ៍ ភាគីម្ខាងបានអនុវត្តតាមវិធានកំណត់នៅក្នុងការប្រកួតយូដូ ហើយបានបង្ករបួសស្នាមដល់ភាគីម្ខាងទៀត នៅក្នុងករណីនេះ ជាទូទៅអំពើនេះខ្វះភាពខុសច្បាប់ ហេតុនេះហើយ វាមិនអាចក្លាយជាអំពើអនីត្យានុកូលនោះទេ។ ការបង្ករបួសស្នាមដល់ភាគីម្ខាងទៀត ដោយសារតែគ្មានមធ្យោបាយផ្សេងពីនេះ ដើម្បីគេចខ្លួនពីការវាយប្រហារពីភាគីម្ខាងទៀតនោះ ក៏អាចរួចផុតពីភាពខុសច្បាប់ដែរ។ ករណីនេះហៅថា **ការការពារជាធម្មានុរូប** (មាត្រា720)។

បើសិនជាពិបាកក្នុងការសម្រេចអំពីភាពមាន ឬ គ្មានភាពខុសច្បាប់នេះ ក្នុងករណីនេះ ទ្រឹស្តីជាច្រើននៅពេលបច្ចុប្បន្ននេះបានបកស្រាយថា ត្រូវសម្រេចដោយវិនិច្ឆ័យទៅលើលក្ខណៈ និង ប្រភេទនៃផលប្រយោជន៍ដែលរងការបំពាន រួមជាមួយនឹងបែបយ៉ាងនៃអំពើបំពាន (មានន័យថា បើសិនជាការបំពានផលប្រយោជន៍មានតិចតួចក៏ដោយ ប៉ុន្តែ បើវិធីនៃការបំពានមានលក្ខណៈអាក្រក់ខ្លាំង គេអាចសម្រេចថា មានភាពខុសច្បាប់ធ្ងន់ធ្ងរ)។ ប៉ុន្តែ ចំពោះលក្ខខណ្ឌនៃភាពខុសច្បាប់នេះ មានទ្រឹស្តី2 ដែលបកស្រាយផ្ទុយគ្នា។ ទ្រឹស្តីមួយបកស្រាយថាភាពខុសច្បាប់នេះ ត្រូវពិចារណាដាច់ដោយឡែកពីលក្ខខណ្ឌចេតនា និង កំហុស រីឯទ្រឹស្តីមួយទៀតបកស្រាយថា ពិចារណាដោយបញ្ចូលលក្ខខណ្ឌទាំងនេះរួមគ្នា (ឧទាហរណ៍ នៅក្នុងករណីអំពើអនីត្យានុកូលនៃជំនួញ ដែល X បានចុះកិច្ចសន្យាជាមួយ A រួចហើយ ប៉ុន្តែ Y បានដណ្តើមយក ហើយបង្ខំឱ្យ A ចុះកិច្ចសន្យាជាមួយខ្លួន។ រឿងនេះពេលខ្លះ

អាចស្ថិតនៅក្នុងទំហំនៃការប្រកួតប្រជែងដោយសេរី ហេតុនេះហើយ ការសម្រេចអំពីអត្ថិភាពនៃភាពខុសច្បាប់ គឺមានការលំបាកខ្លាំង។ ប៉ុន្តែ ទ្រឹស្តីមួយចំនួនបកស្រាយថា រឿងនេះអាចក្លាយជាករណីអំពើអនីត្យានុកូល ប្រសិនបើ Y មានឆន្ទៈ (ឆន្ទៈបំពាន) ដណ្តើមកិច្ចសន្យា ដោយបង្កការខូចខាត (ខ្លាំងជាងចេតនា) ដល់ X។

### (3) ការកើតឡើងការខូចខាត

លក្ខខណ្ឌទី3 គឺការកើតឡើងការខូចខាត។ បើទោះបីជាអំពើនោះខុសច្បាប់ខ្លាំងយ៉ាងណាក៏ដោយ តែបើគ្មានការខូចខាតកើតឡើងចំពោះភាគីម្ខាងទៀតទេ ក៏វាមិនអាចក្លាយជាអំពើអនីត្យានុកូលដែរ។ ការខូចខាតនេះបែកចែកជា ការខូចខាតទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ (សំណងជំងឺចិត្ត) ដូចបានរៀបរាប់ខាងលើនេះ។ នៅក្នុងការខូចខាតទ្រព្យសម្បត្តិត្រូវបែងចែកជា ការខូចខាតសកម្ម ដូចជា ថ្លៃព្យាបាលរបួស និង ការខូចខាតអកម្ម ដូចជា ការបាត់បង់ផលប្រយោជន៍ដោយការមិនទទួលបានចំណូល ក្នុងអំឡុងពេលសម្រាកព្យាបាលរបួស។ លើសពីនេះ នៅក្នុងផលប្រយោជន៍ដែលទទួលរងការបំពាន រួមបញ្ចូលទាំងការប៉ះពាល់ដល់ផលប្រយោជន៍នៃបុគ្គលភាព ដូចជា កេរ្តិ៍ឈ្មោះ និង ឯកជនភាព ជាអាទិ៍ (មាត្រា710)។ ការបំពានដល់អាយុជីវិត ពោលគឺ ឪពុកម្តាយ សហព័ទ្ធ និង កូនរបស់ជនរងគ្រោះដែលបានបាត់បង់ជីវិតដោយសាររងអំពើអនីត្យានុកូល មានសិទ្ធិទាមទារសំណងការខូចខាតផ្លូវចិត្តបាន (មាត្រា711) ប៉ុន្តែ បុគ្គលក្រៅពីនេះក៏អាចមានសិទ្ធិទាមទារសំណងការខូចខាតផ្លូវចិត្តផងដែរ បើសិនជាអាចបញ្ជាក់អំពីការទទួលរងនូវការខូចខាតផ្លូវចិត្តបាន។

### (4) ទំនាក់ទំនងហេតុនិងផល

លក្ខខណ្ឌទី4 គឺទំនាក់ទំនងហេតុនិងផល ពោលគឺ ការខូចខាតដែលកើតឡើងដោយសារតែអំពើអនីត្យានុកូលនោះ ត្រូវតែមានទំនាក់ទំនងដើមហេតុ និង លទ្ធផល។ ប៉ុន្តែ នៅក្នុងការបំពុលបរិស្ថានជាអាទិ៍ ជនរងគ្រោះមានការលំបាកយ៉ាងខ្លាំងក្នុងការបញ្ជាក់អំពីចំណុចនេះ ដូចជា សារធាតុពុលបានចូលទៅក្នុងខ្លួនជនរងគ្រោះដោយរបៀបណា ហើយបង្កជាជំងឺដោយរបៀបណាជាដើម។ ដូចនេះ យុត្តិសាស្ត្រតុលាការបានបកស្រាយអនុគ្រោះត្រង់ចំណុចនេះថា ជនរងគ្រោះមិនតម្រូវឱ្យបញ្ជាក់អំពីមូលហេតុវិទ្យាសាស្ត្រលម្អិតនោះទេ ហើយគ្រាន់តែមានការបញ្ជាក់ត្រឹមតែអាចជឿជាក់បានថា ប្រហែលជាមានគឺគ្រប់គ្រាន់ហើយ។

### (5) សមត្ថភាពក្នុងការទទួលខុសត្រូវ

ចំណុចនេះមានលក្ខណៈខុសគ្នាបន្តិចទៅនឹងលក្ខខណ្ឌនៃការបង្កើតខាងលើនេះ ប៉ុន្តែ ដើម្បីទម្លាក់នូវការទទួលខុសត្រូវសំណងការខូចខាតនៃអំពើអនីត្យានុកូលដល់ចារីបាន លុះត្រាតែ ចារីនោះមានសមត្ថភាពក្នុងការទទួលខុសត្រូវ (សមត្ថភាពដែលអាចទទួលខុសត្រូវនូវអំពើអនីត្យានុកូល)។ នេះមានន័យថា បុគ្គលនោះត្រូវតែមានបញ្ញា និង សមត្ថភាពក្នុងការវិនិច្ឆ័យគ្រប់គ្រាន់ ដែលអាចមើលឃើញអំពីលទ្ធផលដែលអាចកើតឡើងចេញពី

អំពើរបស់ខ្លួន ហេតុនេះ បុគ្គលដែលគ្មានសមត្ថភាពបែបនេះនឹងត្រូវរួចផុតពីការទទួលខុសត្រូវនូវអំពើអនីត្យានុកូល ក្នុងនាមជាបុគ្គលដែលគ្មានសមត្ថភាពទទួលខុសត្រូវ។

ជនដែលគ្មានសមត្ថភាពទទួលខុសត្រូវដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី គឺជា (1) ជននៅក្នុងចំណោមអនីតិជនដែលគ្មានសមត្ថភាពបញ្ញាគ្រប់គ្រាន់ដើម្បីពិចារណាលើការទទួលខុសត្រូវនូវអំពើរបស់ខ្លួន (មាត្រា712) និង (2) ជនដែលស្ថិតក្នុងស្ថានភាពដែលខ្វះសមត្ថភាពពិចារណាលើការទទួលខុសត្រូវនូវអំពើរបស់ខ្លួន ដោយសារតែវិបត្តិផ្នែកស្មារតី (មាត្រា713)។ ចំពោះជនទី (1) យើងត្រូវវិនិច្ឆ័យតាមលក្ខណៈរបស់បុគ្គលម្នាក់ៗ ប៉ុន្តែ ភាគច្រើនគេបានកម្រិតមូលដ្ឋាននេះត្រឹមអាយុតិច ឬ ច្រើនជាង 12ឆ្នាំ។ ឧទាហរណ៍ថា ក្មេងថ្នាក់មតេយ្យបានយកដុំថ្មទៅដាក់នៅលើផ្លូវរថភ្លើង ហើយបណ្តាលឱ្យមានគ្រោះថ្នាក់រថភ្លើងរត់ធ្លាក់គន្លងផ្លូវ ក្នុងករណីនេះ ក្មេងនោះមិនមានទំនួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះទេ។ ប៉ុន្តែ បើសិនជាក្មេងថ្នាក់វិទ្យាល័យបានធ្វើនូវអំពើដូចគ្នានេះ ក្មេងនោះត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល (ក្នុងនាមជាជនដែលមានសមត្ថភាពពិចារណាលើការទទួលខុសត្រូវ)។

ចំពោះជនទី (2) ដែលជាជនស្ថិតក្នុងស្ថានភាពដែលខ្វះសមត្ថភាពពិចារណាលើការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដោយសារតែវិបត្តិផ្នែកស្មារតីវិញ មាត្រា713 វាក្យខណ្ឌទី2 បានកំណត់ថា ជននោះមិនអាចរួចផុតពីការទទួលខុសត្រូវនូវសំណងការខូចខាតបានឡើយ បើសិនជាស្ថានភាពដែលខ្វះសមត្ថភាពពិចារណានោះកើតឡើងដោយចេតនា ឬ កំហុសរបស់សាមីខ្លួនដែលមានលក្ខណៈបណ្តោះអាសន្ន ដូចជា ការធ្វើជាផឹកស្រាឱ្យស្រវឹងខ្លាំងដើម្បីវាយតប់បុគ្គលណាមួយ ជាអាទិ៍។

ទោះបីជាចារីអាចរួចផុតពីការទទួលខុសត្រូវនូវអំពើអនីត្យានុកូលដោយផ្អែកលើមាត្រា712 និង មាត្រា713 ក៏ដោយ ក៏មិនមែនមានន័យថា គ្មានអ្នកដែលត្រូវទទួលខុសត្រូវនោះទេ។ តាមរយៈមាត្រា714 ដូចរៀបរាប់ខាងក្រោម បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យ នឹងទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលជំនួសឱ្យបុគ្គលខាងលើនេះ ក្នុងនាមជាការបំពានករណីយកិច្ចត្រួតពិនិត្យ។

## 4. **អានុភាពនៃអំពើអនីត្យានុកូល**

### (1) គោលការណ៍នៃសំណងជាប្រាក់

ជាគោលការណ៍ សំណងនៃអំពើអនីត្យានុកូលគឺសំណងជាប្រាក់ (មាត្រា722 កថាខណ្ឌទី1)។ ចំពោះករណីបរិហារកេរ្តិ៍ តុលាការអាចចេញសាលក្រមបង្គាប់ឱ្យធ្វើការចាត់ចែងសមរម្យណាមួយដើម្បីស្តារកេរ្តិ៍ឈ្មោះឡើងវិញ ដូចជា ការសុំទោសជាសាធារណៈនៅលើទំព័រកាសែតជាដើម ជំនួសឱ្យការសងសំណង ឬ បន្ថែមលើការសងសំណង (មាត្រា723)។

(2) **ទំហំនៃសំណងការខូចខាត**

មាត្រាច្បាប់មិនមានបញ្ញត្តិពីកម្រិតណាមួយចំពោះចំណុចនេះទេ ហេតុនេះ ជាគោលការណ៍ ការខូចខាតទាំងអស់ដែលកើតឡើងដោយអំពើអនីត្យានុកូលនោះ ត្រូវក្លាយជាកម្មវត្ថុនៃការសងសំណងទាំងអស់។ ប៉ុន្តែ យើងក៏មានភាពចាំបាច់ក្នុងការដកចេញនូវការទាមទារណាក្រៅពីច្បាប់ផងដែរ (ឧទាហរណ៍ នាវាមួយបានលិចបាត់ដោយសារតែបានប៉ះទង្គិចគ្នា ហើយក្នុងរយៈប៉ុន្មានថ្ងៃក្រោយគ្រោះថ្នាក់ តំបន់នោះបានផ្ទុះសង្គ្រាមឡើង ហេតុនេះហើយ តម្លៃសម្រាប់ចំណាយលើការស្រង់នាវាជាអាទិ៍ កើនឡើងខ្ពស់ខ្លាំង។ នៅក្នុងរឿងក្តីនេះ ជនរងគ្រោះដែលជាម្ចាស់នាវាបានទាមទារសំណងការខូចខាត ដែលបានគណនាដោយយកតម្លៃដែលកើនឡើងខ្ពស់នោះ)។ ហេតុនេះហើយ គោលគំនិតនៅក្នុងយុត្តិសាស្ត្របានបកស្រាយថា អំពើ និង ការកើតឡើងនូវការខូចខាតត្រូវតែមាន**ទំនាក់ទំនងហេតុផលសមស្រប** ហើយខ្លឹមសារនេះមានលេចឡើងនៅក្នុងមាត្រា416 នៃក្រមរដ្ឋប្បវេណី(បានរៀបរាប់រួចហើយ ក្នុងជំពូកទី៤ ការមិនអនុវត្តកាតព្វកិច្ច) ហេតុនេះ យើងអាចយកចំណុចនេះមកអនុវត្តប្រដូចបាន។ ពិតមែនហើយថា គោលគំនិតដែលលើកឡើងថា សំណងការខូចខាតត្រូវធ្វើក្នុងទំហំដែលអាចទទួលស្គាល់ថាសមស្របដោយពិចារណាជាទូទៅ គឺសមហេតុផល ប៉ុន្តែ គោលគំនិតនេះមានប្រភពនៅក្នុងច្បាប់អាឡឺម៉ង់ដែលប្រកាន់យករបបផ្តល់សំណងគ្មានកម្រិត ហើយរបៀបនៃការតាក់តែងបញ្ញត្តិស្តីពីសំណងការខូចខាតនេះខុសពីប្រទេសជប៉ុនទៀត ហេតុនេះ ខ្ញុំយល់ថារបៀបនៃការពន្យល់នេះនៅមានមន្ទិលជាច្រើន(នៅប្រទេសជប៉ុន មាត្រា416 បានបែងចែកជាការខូចខាតធម្មតា និង ការខូចខាតពិសេសចំពោះការមិនអនុវត្តកាតព្វកិច្ច ហើយបានប្រើប្រាស់របបផ្តល់សំណងមានកម្រិត។ ដូចនេះ មានការរិះគន់ថា ការនាំយកនូវពាក្យបច្ចេកទេសស្តីពីទំនាក់ទំនងហេតុនិងផលដែលកើតមានក្នុងស្ថានភាពនៃប្រទេសអាឡឺម៉ង់ គឺមិនចាំបាច់នោះទេ)។

(3) **ការទូទាត់កំហុស**

នៅក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ជាដើម បើសិនជាភាគីជនរងគ្រោះក៏មានកំហុសផងដែរនោះ តុលាការអាចពិចារណាអំពីការទូទាត់កំហុស ហើយសម្រេចអំពីចំនួននៃសំណងបាន (មាត្រា722 កថាខណ្ឌទី2)។ ឧបមាថា ការខូចខាតដែលកើតមានឡើងមានចំនួន 40លានរៀល ហើយតុលាការបានទទួលស្គាល់ថា ភាគីជនរងគ្រោះមានកំហុស 30% (ឧទាហរណ៍ថា នៅក្នុងគ្រោះថ្នាក់ចរាចរណ៍នេះ មានមូលហេតុចម្បងបណ្តាលមកពីអ្នកបើកបរមិនមើលទៅខាងមុខដោយប្រុងប្រយ័ត្ន ប៉ុន្តែ ជនរងគ្រោះក៏មានកំហុសក្នុងការចេញមកផ្លូវឡានដោយប្រញាប់ប្រញាល់ដែរ) ក្នុងករណីនេះ ការខូចខាតសរុបរួមមានចារី 70% និងជនរងគ្រោះ 30% ហើយតុលាការត្រូវចេញសាលក្រមកំណត់អំពីសំណងចំនួន 28លានរៀល។

## 5. អំពើអនីត្យានុកូលពិសេស

### (1) សញ្ញាណទូទៅ

ក្រមរដ្ឋប្បវេណីបានកំណត់អំពីអំពើអនីត្យានុកូលពិសេសមួយចំនួន បន្ថែមពីលើអំពើអនីត្យានុកូលទូទៅនៃមាត្រា709។ អំពើអនីត្យានុកូលពិសេសទាំងនេះ សុទ្ធតែមានលក្ខណៈពិសេសត្រង់ថា នៅក្នុងលក្ខខណ្ឌនៃការបង្កើតមានជាតុផ្សំនៃការទទួលខុសត្រូវដោយគ្មានកំហុសតិច ឬ ច្រើន។ មានន័យថា វាមិនមែនជាទង្វើរបស់សាមីខ្លួននោះទេ ប៉ុន្តែ ជននោះត្រូវទទួលខុសត្រូវនៃអំពើអនីត្យានុកូលនោះក្នុងទំហំជាក់លាក់មួយ ដោយប្រៀបបាននឹងអំពើនោះសាមីខ្លួនបានប្រព្រឹត្ត ដោយសារតែសាមីខ្លួនមានទំនាក់ទំនងជាក់លាក់ជាមួយបុគ្គលដែលបានប្រព្រឹត្ត (ប៉ុន្តែ ឧបមាថាជននោះមានការប្រុងប្រយ័ត្នគ្រប់គ្រាន់ក្នុងការជ្រើសរើស ឬ ត្រួតពិនិត្យអ្នកប្រព្រឹត្ត ក្នុងករណីនេះជននោះអាចរួចផុតពីការទទួលខុសត្រូវ ពោលគឺមានហេតុមួយចំនួនដែលអាចរួចផុតពីការទទួលខុសត្រូវបាន ប៉ុន្តែមិនមែនមានន័យថា គ្មានការទទួលខុសត្រូវទាល់តែសោះនោះទេ។ ចំណុចនេះនឹងរៀបរាប់បន្ថែមខាងក្រោម)។

### (2) ការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យជនដែលគ្មានសមត្ថភាពទទួលខុសត្រូវ

បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យជនដែលគ្មានសមត្ថភាពទទួលខុសត្រូវ (ឧទាហរណ៍ថា សិស្សថ្នាក់បឋម គឺសំដៅទៅលើឪពុកម្តាយក្មេងនោះជាអាទិ៍ ហើយបើសិនជាអ្នកបាត់បង់ការចង់ចាំ គឺសំដៅទៅលើអ្នកអាណាព្យាបាល ឬ ប្រធានមន្ទីរពេទ្យផ្នែកវិបត្តិផ្លូវចិត្តជាអាទិ៍) ឬ អ្នកតំណាងនៃអ្នកត្រួតពិនិត្យ (សិស្សសាលាបឋម គឺសំដៅទៅលើនាយកសាលាបឋមនោះ) មានការទទួលខុសត្រូវក្នុងការសងសំណង ចំពោះអំពើអនីត្យានុកូលដែលបានធ្វើឡើងដោយជនដែលគ្មានសមត្ថភាពទទួលខុសត្រូវ (មាត្រា714 កថាខណ្ឌទី1 និងទី2)។ ក្នុងបញ្ញត្តិនេះក៏មានកំណត់ផងដែរថា អ្នកមានករណីយកិច្ចត្រួតពិនិត្យអាចរួចផុតពីការទទួលខុសត្រូវបើសិនជាគ្មានការធ្វេសប្រហែសចំពោះករណីយកិច្ចត្រួតពិនិត្យ ប៉ុន្តែ ការអះអាងអំពីភាពគ្មានការធ្វេសប្រហែសចំពោះករណីយកិច្ចត្រួតពិនិត្យនេះ មិនងាយនឹងបានជោគជ័យនោះទេ។

### (3) ការទទួលខុសត្រូវរបស់និយោជក

មាត្រា715 ស្តីពីការទទួលខុសត្រូវរបស់និយោជក បានកំណត់ថា និយោជិតខ្លួនឯងត្រូវមានការទទួលខុសត្រូវផង ហើយនិយោជកដែលប្រើនិយោជិតនោះ ឬ អ្នកត្រួតពិនិត្យជំនួសនិយោជកនោះ ត្រូវមានការទទួលខុសត្រូវរួមគ្នា ចំពោះអំពើអនីត្យានុកូលដែលបានប្រព្រឹត្តឡើងដោយនិយោជិត ពោលគឺបុគ្គលដែលខ្លួនបានប្រើឱ្យធ្វើសកម្មភាពការងារ។ ប៉ុន្តែ និយោជកអាចរួចផុតពីការទទួលខុសត្រូវបាន ប្រសិនបើខ្លួនអាចបញ្ជាក់អំពីការប្រុងប្រយ័ត្នសមស្របក្នុងការជ្រើសរើស និង ត្រួតពិនិត្យនិយោជិត។ និយោជក និង អ្នកត្រួតពិនិត្យដែលបានបង់សំណងដល់ជនរងគ្រោះ អាចទាមទារសំណងនោះវិញបាន ពីនិយោជិតដែលបានប្រព្រឹត្តអំពើអនីត្យានុកូល (មាត្រា715 កថាខណ្ឌទី3)។ ប៉ុន្តែ បញ្ញត្តិស្តីពីការទាមទារសំណងវិញនេះ មានរឿងក្តីខ្លះ ជាចុងក្រោយនិយោជិតត្រូវបង់សំណងទាំងអស់

ទៅវិញដែលមិនយុត្តិធម៌ ហេតុនេះ យុត្តិសាស្ត្រ និង ទ្រឹស្តីខ្លះបានបកស្រាយថា ការទាមទារឱ្យសងវិញនេះមិនអាចធ្វើចំពោះទំហំសំណងទាំងអស់បានទេ ដោយសារពិចារណាលើគោលការណ៍សុចរិតភាព។

(4) **អំពើអនីត្យានុកូលរួម**

មាត្រា719 កំណត់អំពីអំពើអនីត្យានុកូលរួម។ ឧបមាថា ជនម្នាក់ត្រូវជនមួយក្រុមវាយតប់ ហើយបានរងរបួស ហើយក្រោយមកទៀត ជនរងគ្រោះបានសន្លប់បាត់ស្មារតីដោយមិនដឹងថាត្រូវនឹងកណ្តាប់ដៃរបស់បុគ្គលណានោះទេ ហេតុនេះ បើសិនជាយើងកំណត់ថា ក្នុងករណីដែលគេមិនអាចកំណត់អត្តសញ្ញាណចារីបាន គឺមិនអាចទាមទារសំណងបាន នោះជនរងគ្រោះនឹងខ្វះនូវការការពារ។ នៅក្នុងករណីបែបនេះហើយ ទើបមាត្រានេះបញ្ញត្តថា បុគ្គលទាំងអស់នោះត្រូវមានការទទួលខុសត្រូវដោយសាមគ្គីភាព (បើសិនជា A B និង C បានវាយតប់ D ឱ្យរងរបួស ក្នុងករណីនេះ D អាចទាមទារសំណងទាំងអស់ចំពោះនរណាម្នាក់ក្នុងចំណោម A B និង C ក៏បាន)។ ហើយគោលគំនិតនេះក៏អាចយកមកអនុវត្តចំពោះករណីដែលគ្រោះថ្នាក់ចរាចរណ៍ដែលបង្កឡើងដោយរថយន្ត X និង រថយន្ត Y ហើយបណ្តាលឱ្យអ្នកថ្មើរជើង Z រងគ្រោះជាអាទិ៍ (វាក្លាយជាអំពើអនីត្យានុកូលរួមរបស់ X និង Y)។ លើសពីនេះ អ្នកផ្តើមគំនិត និង អ្នកសមគំនិត ពោលគឺអ្នកបញ្ជាឱ្យធ្វើ និង អ្នកបានជួយទំនុកបម្រុង ត្រូវចាត់ទុកថាជាចារីរួម (មាត្រាដដែល កថាខណ្ឌទី2)។

(5) **ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ**

អ្នកកាន់កាប់សត្វ ឬ អ្នកគ្រប់គ្រងសត្វជំនួសឱ្យអ្នកកាន់កាប់ ត្រូវទទួលខុសត្រូវចំពោះសំណងការខូចខាតដែលសត្វនោះបានធ្វើទៅលើអ្នកដទៃ (មាត្រា718 កថាខណ្ឌទី1 និង ទី2)។ ឧទាហរណ៍ សត្វចិញ្ចឹមបានរត់ចេញពីផ្ទះ ហើយខាំអ្នកដទៃឱ្យមានរបួស ក្នុងករណីនេះ អ្នកកាន់កាប់សត្វនោះត្រូវសងសំណងការខូចខាត (នៅទីនេះ គេប្រើពាក្យថា អ្នកកាន់កាប់ ហេតុនេះហើយទោះបីជាកម្មសិទ្ធិករ ឬ មិនមែនកម្មសិទ្ធិករក៏ដោយ ឱ្យតែបុគ្គលនោះជាអ្នកចិញ្ចឹមសត្វជាក់ស្តែង) ហើយបើសិនជាសត្វចិញ្ចឹមបានរត់ចេញពីពេទ្យសត្វ ហើយខាំអ្នកដទៃឱ្យមានរបួសវិញ ប្រធានមន្ទីរពេទ្យក្នុងនាមជាអ្នកគ្រប់គ្រងជំនួសត្រូវទទួលខុសត្រូវចំពោះការខូចខាត។ ប៉ុន្តែ មាត្រា718 ប្រើប្រាស់ក្នុងករណីដែលសត្វនោះរត់ចេញក្រៅហើយខាំអ្នកដទៃ ប៉ុន្តែ បើសិនជាម្ចាស់សត្វជាអ្នកឱ្យសត្វចិញ្ចឹមខ្លួនខាំអ្នកដទៃវិញ ក្នុងករណីនេះ វាក្លាយជាអំពើអនីត្យានុកូលរបស់ម្ចាស់សត្វខ្លួនឯង ផ្អែកតាមមាត្រា709។

(6) **ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី**

មាត្រា717 កំណត់អំពីការទទួលខុសត្រូវនៃអំពើអនីត្យានុកូល 3ដំណាក់កាល ចំពោះវិការៈនៃការថែរក្សា ឬ តម្លើងនូវឧបករណ៍សាងសង់សំណង់ដូចជាអគារ និង របងជាដើម (ឧទាហរណ៍ របងបេតុងបានដួលរលំទៅលើអ្នកថ្មើរជើងហើយបង្កជារបួស)។ នេះមានន័យថា ចំពោះអំពើអនីត្យានុកូលនៃសំណង់បែបនេះ អ្នកមានទំនួលខុសត្រូវសងសំណងដំបូងបំផុត គឺអ្នកកាន់កាប់ដោយផ្ទាល់ទីមួយ (បើផ្ទះដួល គឺសំដៅលើ អ្នកដួល)។ ប៉ុន្តែ កម្ម

សិទ្ធិករនៃសំណង់ត្រូវទទួលខុសត្រូវចំពោះការខូចខាតនោះ (បើផ្ទះដួល គឺសំដៅលើ ម្ចាស់ផ្ទះដែលដួលផ្ទះឱ្យគេ) ប្រសិនបើអ្នកកាន់កាប់នោះបានប្រុងប្រយ័ត្នគ្រប់គ្រាន់សម្រាប់ការពារមិនឱ្យកើតឡើងការខូចខាត (មាត្រា717 កថាខណ្ឌទី1)។ លើសពីនេះ ប្រសិនបើមានបុគ្គលដែលត្រូវទទួលខុសត្រូវអំពីដើមហេតុនៃការខូចខាតផ្សេងទៀត (ឧបមាថា ការដួលរលំរបស់បេតុងនោះបង្កឡើងពីការធ្វេសប្រហែសរបស់ជាងសាងសង់ដែលបានទទួលម៉ៅការ ជាអាទិ៍) អ្នកកាន់កាប់ ឬ កម្មសិទ្ធិករដែលបានផ្តល់សំណងឱ្យជនរងគ្រោះ អាចអនុវត្តសិទ្ធិទាមទារសំណងចំពោះបុគ្គលនោះបាន (តាមឧទាហរណ៍ខាងលើនេះ គឺសំដៅទៅលើ អ្នកម៉ៅការ) (មាត្រាដដែល កថាខណ្ឌទី3)។

## 6. បញ្ញត្តិផ្សេងទៀតស្តីពីអំពើអនីត្យានុកូល

ក្រមរដ្ឋប្បវេណីមានមាត្រាដែលកំណត់ថា ត្រូវចាត់ទុកថាទារកនៅក្នុងផ្ទៃបានចាប់កំណើត ចំពោះសិទ្ធិទាមទារសំណងការខូចខាត (មាត្រា721)។ ឧទាហរណ៍ថា ប្តីបានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ហើយបានបន្សល់ទុកនូវប្រពន្ធដែលកំពុងមានផ្ទៃពោះ ក្នុងករណីនេះ គេអាចទាមទារសំណងការខូចខាតចំពោះចំណែករបស់បុគ្គល 2នាក់ ដែលជាប្រពន្ធ និង ទារកក្នុងផ្ទៃបាន។ វាគឺជាបញ្ញត្តិដែលពិចារណាអំពីការជួយសង្គ្រោះដល់ជនរងគ្រោះ។

ដោយឡែក សិទ្ធិទាមទារសំណងការខូចខាតចំពោះអំពើអនីត្យានុកូលនេះត្រូវបានបែងចែកជា 2 ហើយទីមួយគឺរយៈពេល 20ឆ្នាំ គិតចាប់ពីពេលដែលអំពើនោះកើតឡើង និងទីពីរ គឺរយៈពេល 3ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការខូចខាត និង ចារី (មាត្រា724)។

## 7. ច្បាប់ស្តីពីការធានាសំណងការខូចខាតដោយរថយន្ត

ចំពោះករណីគ្រោះថ្នាក់ចរាចរណ៍ដែលបង្កឡើងដោយរថយន្ត ត្រូវយកច្បាប់ស្តីពីការធានាសំណងការខូចខាតដោយរថយន្ត(តទៅហៅកាត់ថា ច្បាប់សំណងការខូចខាតរថយន្ត) ដែលជាច្បាប់ពិសេសនៃក្រមរដ្ឋប្បវេណីមកអនុវត្ត។ នៅក្នុងច្បាប់នេះមានគោលគំនិតស្តីពី «បុគ្គលចូលរួមការបើកបរ» ហើយបុគ្គលដែលគ្រប់គ្រងរថយន្តជាដើម (តែក្នុងករណីជាច្រើនបុគ្គលនោះ គឺជាអ្នកបើកបរ) ទោះបីជាមិនមែនជាអ្នកបើកបរដោយផ្ទាល់ក៏ដោយ ក៏ត្រូវមានទំនួលខុសត្រូវចំពោះសំណងការខូចខាតផងដែរ (អ្នកបើកបរជាក់ស្តែងក៏មានការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនៃមាត្រា709 ផងដែរ)។ នៅក្នុងច្បាប់នេះបានចែងអំពីប្រព័ន្ធធានារ៉ាប់រងសំណងការខូចខាតដោយបង្ខំ (តទៅហៅកាត់ថា ការធានារ៉ាប់រងសំណង) ហើយបង្ខំឱ្យបុគ្គលដែលគ្រប់គ្រងរថយន្តទាំងអស់ត្រូវតែមានធានារ៉ាប់រងនេះ ហេតុនេះ សំណងការខូចខាតនឹងត្រូវចំណាយដោយការធានារ៉ាប់រងនោះ។ ដូចនេះ ជនរងគ្រោះដោយគ្រោះថ្នាក់រថយន្តនឹងទទួលការធានាក្នុងការផ្តល់សំណងពីធានារ៉ាប់រងនោះ ហើយបើសិនជាមិនទាន់គ្រប់គ្រាន់ ជនរងគ្រោះអាចទាមទារបន្ថែមដោយផ្អែកលើអំពើអនីត្យានុកូលនៃក្រមរដ្ឋប្បវេណីបាន (យ៉ាងណាមិញនៅក្នុងច្បាប់នេះមានគោលបំណងសងសំណងចំពោះការខូចខាតដល់រូបរាងកាយ ដូចជាថ្លៃព្យាបាលជាដើម

ហើយមិនគ្របដណ្តប់លើការខូចខាតជាវត្ថុនោះទេ ហេតុនេះហើយ ការខូចខាតលើសំលៀកបំពាក់ ឬ សំភារៈផ្សេង ជាដើម ត្រូវទាមទារដោយផ្អែកលើមាត្រា709 នៃក្រមរដ្ឋប្បវេណី)។

### 8. ច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល

ចំពោះការខូចខាតដែលបណ្តាលមកពីវិការៈនៃទំនិញ គេត្រូវយកច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផលដែលបានចូលជាធរមាននៅខែ7 ឆ្នាំ1995 មកអនុវត្ត (ច្បាប់នេះភាគច្រើនគេហៅកាត់ថា ច្បាប់PL ដោយយកតាមពាក្យភាសាអង់គ្លេសគឺ Product Liability (ការទទួលខុសត្រូវចំពោះផលិតផល))។ បើនិយាយឱ្យខ្លីទៅ ច្បាប់នេះបានជំនួសលក្ខខណ្ឌ «កំហុស» នៃអំពើអនីត្យានុកូល ដោយលក្ខខណ្ឌ «វិការៈ» នៃផលិតផល។ បើសិនជាវិការៈនៃផលិតផលដែលបានប្រគល់នោះ ធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត រូបរាងកាយ និង ទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងករណីនេះ អ្នកផលិតជាដើមត្រូវមានទំនួលខុសត្រូវចំពោះសំណងការខូចខាតដែលបានកើតឡើងដោយសារវិការៈនោះ (ច្បាប់PL មាត្រា3)។ ប៉ុន្តែ អ្នកផលិតមិនទទួលខុសត្រូវនោះទេតាមរយៈច្បាប់នេះ បើសិនជាការខូចខាតនោះកើតមានចំពោះតែវត្ថុនោះផ្ទាល់ (ច្បាប់PL មាត្រា3)។ ដោយសារតែច្បាប់នេះត្រូវមានសង្គតភាពជាមួយក្រមរដ្ឋប្បវេណីក្នុងនាមជាច្បាប់ពិសេស (ជាដំបូងត្រូវយកច្បាប់ពិសេសមកប្រើ ហើយបើសិនជាគ្មានបញ្ញត្តិនោះទេ ក្រមរដ្ឋប្បវេណីដែលជាច្បាប់ទូទៅត្រូវយកមកអនុវត្តនៅពេលក្រោយ) ហេតុនេះ ចំពោះការខូចខាតកើតមានលើវត្ថុនោះផ្ទាល់ជនរងគ្រោះអាចទាមទារឱ្យមានការទទួលខុសត្រូវក្នុងករណីមិនអនុវត្តកាតព្វកិច្ច ឬ ការទទួលខុសត្រូវចំពោះការអនុវត្តមិនស្របតាមខ្លឹមសារនៃកិច្ចសន្យា ឬ ការទទួលខុសត្រូវអំពើអនីត្យានុកូលធម្មតាតាមក្រមរដ្ឋប្បវេណីដែលបានពន្យល់កន្លងមកបាន (ច្បាប់PL មាត្រា6)។

យើងមានភាពចាំបាច់ត្រូវយល់ឱ្យច្បាស់អំពីមូលហេតុដែលត្រូវបង្កើតច្បាប់ពិសេសបែបនេះ។ ឧទាហរណ៍ថា បុគ្គលណាម្នាក់បានទិញផលិតផលអគ្គិសនីមួយគ្រឿង ហើយផលិតផលនោះបានឆាបឆេះឡើង ហើយបង្កឱ្យឆេះក្នុងបន្ទប់។ កន្លែងដែលអាចទាមទារសំណងបាន គឺកន្លែងលក់ និង កន្លែងផលិត។ ប៉ុន្តែ វាមានលទ្ធភាពខ្ពស់ណាស់ដែលកន្លែងលក់មិនបានដឹងអំពីវិការៈនៃផលិតផលនោះ ហេតុនេះ កន្លែងលក់គ្មានហេតុដែលត្រូវទទួលខុសត្រូវដោយសារការមិនអនុវត្តកាតព្វកិច្ចនៅក្នុងកិច្ចសន្យាលក់ទិញ ហើយក៏គ្មានកំហុសនៃអំពើអនីត្យានុកូលផងដែរ។ ហេតុនេះ ជនរងគ្រោះបានត្រឹមតែទាមទារឱ្យកន្លែងលក់ទទួលខុសត្រូវក្នុងការធានាវិការៈ ដែលត្រូវបានទទួលស្គាល់មុនការធ្វើវិសោធនកម្មច្បាប់ឆ្នាំ2017ប៉ុណ្ណោះ (គ្មានកំហុស ក៏ទទួលខុសត្រូវដែរ)។ ប៉ុន្តែ ទស្សនៈទូទៅបកស្រាយថា សំណងការខូចខាតនៅក្នុងករណីនៃការទទួលខុសត្រូវក្នុងការធានាវិការៈ ត្រូវកម្រិតត្រឹមតម្លៃនៃផលិតផលអគ្គិសនីនោះប៉ុណ្ណោះ (ដោយសារតែ នេះជាការទទួលខុសត្រូវដែលបានទទួលស្គាល់ដើម្បីធានានូវការផ្តល់សំណងស្មើនឹងតម្លៃនៃកិច្ចសន្យាលក់ទិញ បើទោះបីជាគ្មានកំហុសក៏ដោយ)។ ឥឡូវពិចារណាអំពីការទទួលខុសត្រូវរបស់កន្លែងផលិតម្តង។ កន្លែងផលិតមិនមែនជាភាគីនៃកិច្ចសន្យាលក់ទិញជាមួយជនរងគ្រោះនោះទេ ហេតុនេះ ការទាមទារឱ្យទទួលខុសត្រូវដោយសារការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា គឺមានការលំបាកខ្លាំង។ បើទាមទារ

តាមអំពើអនីត្យានុកូលវិញ គឺអាចធ្វើបានបើទោះបីជាមិនមែនភាគីផ្ទាល់នៃកិច្ចសន្យាក៏ដោយ ប៉ុន្តែ ជនរងគ្រោះមានករណីយកិច្ចក្នុងការបញ្ជាក់អំពីចេតនា ឬ កំហុសរបស់ចារីនៅក្នុងអំពើអនីត្យានុកូល។ អ្នកប្រើប្រាស់ដែលគ្មានជំនាញ មានការលំបាកយ៉ាងខ្លាំងក្នុងការបញ្ជាក់ថា តើអ្នកផលិតបានប្រព្រឹត្តកំហុសបែបណាក្នុងដំណើរការផលិត។ ហេតុនេះហើយ ច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផលនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដាក់ការទទួលខុសត្រូវឱ្យអ្នកផលិត ក្នុងករណីដែលជនរងគ្រោះអាចបញ្ជាក់អំពី «វិការៈ» នៃផលិតផល ជំនួសឱ្យ «កំហុស»។ «វិការៈ» សំដៅទៅលើ «ការខ្វះខាតលក្ខណៈសុវត្ថិភាពនៃផលិតផលធម្មតាដែលត្រូវតែមាន» (ច្បាប់PL មាត្រា2 កថាខណ្ឌទី2)។ ហេតុនេះ បើយើងគិតអំពីករណីទូរទស្សន៍ជាអាទិ៍ ដែលបានឆាបឆេះឡើង នៅពេលកំពុងប្រើប្រាស់ជាធម្មតា ក្នុងករណីនេះ ជនរងគ្រោះមានភាពងាយស្រួលខ្លាំងណាស់ក្នុងការបញ្ជាក់អំពីវិការៈ ជាងការបញ្ជាក់អំពីកំហុស។

ដោយឡែក បុគ្គលដែលត្រូវបានចាត់ទុកថាជា «អ្នកផលិតជាដើម»នៅក្នុងច្បាប់នេះ សំដៅទៅលើបុគ្គលដែលបានផលិត កែច្នៃ ឬ នាំចូលនូវផលិតផលនោះ (ទោះបីជាមិនបានផលិតដោយខ្លួនឯងក៏ដោយ) និង បុគ្គលដែលបានដាក់នាមករណ៍ សញ្ញាពាណិជ្ជកម្ម ស្លាកពាណិជ្ជកម្ម និង សញ្ញាផ្សេងទៀតនៅលើទំនិញនោះក្នុងនាមជាអ្នកផលិត (ច្បាប់PL មាត្រា2 កថាខណ្ឌទី3)។

ប៉ុន្តែ បើកម្មវត្ថុនៃការទទួលខុសត្រូវមានរហូតដល់ការខូចខាតកើតឡើងពីវិការៈដែលសូម្បីតែបច្ចេកវិទ្យាទំនើបក៏មិនអាចរកឃើញនោះ គឺវាជ្រុលហួសហេតុចំពោះភាគីអ្នកផលិត។ ហេតុនេះហើយ នៅក្នុងច្បាប់នេះបានកំណត់អំពី «ការតវ៉ាអំពីហានិភ័យនៃការអភិវឌ្ឍន៍»។ ដូចនេះ បើសិនជាអ្នកផលិតជាដើមអាចបញ្ជាក់ថា វិការៈនេះមិនអាចរកឃើញឡើយ តាមរយៈបច្ចេកវិទ្យានៅចំណុចពេលដែលបានប្រគល់ផលិតផលនោះ ក្នុងករណីនេះ អ្នកផលិតអាចរួចផុតពីការទទួលខុសត្រូវបាន (ច្បាប់PL មាត្រា4 ចំណុច1)។

## III. ការសិក្សាអំពីចំណុចសំខាន់នៃការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនឥតហេតុ

### 1. ការគ្រប់គ្រងដោយឈឺឆ្អាល

#### (1) និយមន័យ

មូលហេតុនៃការកកើតសិទ្ធិលើបំណុលទី3 គឺការគ្រប់គ្រងដោយឈឺឆ្អាល។ បើគ្រាន់តែស្តាប់លឺពាក្យពេចន៍បែបនេះ វាពិបាកនឹងមើលឃើញអំពីឧទាហរណ៍ណាស់។ ប៉ុន្តែ សូមពិចារណាទាំងអស់គ្នាលើករណីដែលមានបុគ្គលម្នាក់បានធ្វើសកម្មភាពណាមួយសម្រាប់ប្រយោជន៍របស់អ្នកដទៃ ទាំងអ្នកដទៃនោះមិនបានពឹងពាក់ឱ្យធ្វើនោះទេ។ នៅក្នុងជំពូកទី4 ខ្ញុំបានរៀបរាប់រួចហើយអំពីកិច្ចសន្យាដែលកើតឡើងតាមការព្រមព្រៀងឱ្យបុគ្គលណាម្នាក់ធ្វើសកម្មភាពណាមួយសម្រាប់ខ្លួន ហើយវាជាកិច្ចសន្យាអាណត្តិ។ ក្នុងករណីនេះ វាជាកិច្ចសន្យា ហេតុនេះសោ

ហ៊ុយដែលបានចំណាយគឺអាចទាមទារបាន ហើយសិទ្ធិទាមទារកម្រៃក៏កើតមានដែរ បើសិនជាភាគីបានការព្រមព្រៀងអំពីកម្រៃនោះ។ ប៉ុន្តែឧបមាថា អំឡុងពេលដែលអ្នកជិតខាងរបស់អ្នកមួយគ្រួសារកំពុងតែធ្វើដំណើរកំសាន្ត ហើយមានខ្យល់ព្យុះបានបក់មកបណ្តាលឱ្យខូចដំបូលផ្ទះរបស់អ្នកជិតខាងនោះ។ បើទុកបែបនេះ សំភារៈក្នុងផ្ទះនឹងកាន់តែខូចខាតធ្ងន់ធ្ងរ ហេតុនេះ អ្នកបានជួសជុលដំបូលនោះដោយទឹកចិត្តរបស់ខ្លួនឯង ទាំងអ្នកជិតខាងនោះមិនបានផ្តាំផ្ញើឱ្យជួយចាំផ្ទះនោះទេ។ បើសិនជាគេមិនបានពឹងពាក់នោះទេ វាមិនអាចកើតមានជាកិច្ចសន្យាអាណត្តិជាអាទិ៍ឡើយ។ បើសិនជាច្បាប់មិនបានពិចារណាទាល់តែសោះចំពោះករណីបែបនេះទេ អំពើរបស់អ្នកដែលជួយជួសជុលនោះ អាចក្លាយជាការប្រព្រឹត្តអំពើអនីត្យានុកូលដោយជ្រៀតជ្រែកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយចិត្តឯង ហើយការជួយយកអាសារគ្នានៅក្នុងសង្គមនឹងលែងកើតមានទៀតហើយ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានកំណត់ថា នៅក្នុងករណីបែបនេះ ការទាមទារកម្រៃតបស្នងមិនអាចធ្វើបានទេ ប៉ុន្តែ ការទាមទារឱ្យសងសោហ៊ុយដែលបានចំណាយនោះ (សោហ៊ុយដែលជាប្រយោជន៍សម្រាប់សាមីខ្លួន) អាចធ្វើទៅបាន។ នេះហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល (ចាប់ពីមាត្រា697)។

**(2) លក្ខខណ្ឌបង្កើត និង អានុភាព**

ដើម្បីបង្កើតជាការគ្រប់គ្រងដោយឈឺឆ្អាលបាន យ៉ាងហោចណាស់នៅពេលដែលធ្វើសកម្មភាព គឺចាំបាច់ត្រូវមានស្ថានភាពមិនអាចដឹងច្បាស់ថា វាផ្ទុយនឹងឆន្ទៈ និងផលប្រយោជន៍របស់សាមីខ្លួន (ភាគីដែលគេធ្វើការងារឱ្យ)។ នៅពេលដែលការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបានទទួលស្គាល់ ភាពខុសច្បាប់នៃអំពើនោះត្រូវបានបដិសេធចោល ហើយក្លាយជាអំពើស្របច្បាប់ ហើយអ្នកគ្រប់គ្រងដោយឈឺឆ្អាលមានសិទ្ធិទាមទារឱ្យសងសោហ៊ុយដែលជាផលប្រយោជន៍ចំពោះសាមីខ្លួនបាន (មាត្រា702 កថាខណ្ឌទី1)។ ក្នុងករណីនេះ អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារពីសាមីខ្លួនបាន បើសិនជាបានចំណាយសោហ៊ុយរួចហើយ ប៉ុន្តែ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាលគ្រាន់តែមានកាតព្វកិច្ចវិញ (ឧទាហរណ៍ អ្នកគ្រប់គ្រងដោយឈឺឆ្អាលនោះបានហៅជាងដំបូលមកជួសជុល ប៉ុន្តែមិនទាន់បានបង់សោហ៊ុយនៅឡើយទេ) អ្នកគ្រប់គ្រងដោយឈឺឆ្អាលនោះអាចទាមទារឱ្យសាមីខ្លួនបង់សោហ៊ុយជំនួស ដូចគ្នានឹងករណីកិច្ចសន្យាអាណត្តិ (ការអនុវត្តដូចគ្នានៃមាត្រា650 កថាខណ្ឌទី2 ស្របតាមមាត្រា702 កថាខណ្ឌទី2)។

យ៉ាងណាមិញ នៅពេលដែលចាប់ផ្តើមគ្រប់គ្រងហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាលមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដូចគ្នានឹងអាណត្តិគ្គាហកនៃកិច្ចសន្យាអាណត្តិ ហើយត្រូវគ្រប់គ្រងដោយវិធីណាដែលមានប្រយោជន៍បំផុតសម្រាប់សាមីខ្លួន (មាត្រា697 កថាខណ្ឌទី1)។ ដោយឡែក បើសិនជាអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានគ្រប់គ្រងកិច្ចការ ដើម្បីជួយសង្គ្រោះដល់សាមីខ្លួនពីគ្រោះថ្នាក់បន្ទាន់ផ្សេងៗ ក្នុងករណីនេះ អ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនមានទំនួលខុសត្រូវចំពោះសំណងនៃការខូចខាតដែលកើតចេញពីការគ្រប់គ្រងនោះទេ លើកលែងតែករណីមានចេតនា ឬ កំហុសធ្ងន់ធ្ងរ (មានន័យថា បើសិនជាបុគ្គលម្នាក់បានជួយអ្នកកំពុង

លង់ទឹក ហើយប្រសិនបើពេលជួយនោះធ្វើឱ្យរហែកអាវរបស់អ្នកលង់ទឹកនោះក៏ដោយ ក៏បុគ្គលនោះមិនមានការទទួលខុសត្រូវចំពោះសំណងទេ លើកលែងតែ បុគ្គលនោះមានបំណងធ្វើឱ្យរហែកទាំងមិនសមហេតុផល)។ នេះហៅថា **ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់** (មាត្រា698)។

### 2. សេចក្ដីចម្រើនឥតហេតុ

#### (1) និយមន័យ

មូលហេតុនៃការកកើតសិទ្ធិលើបំណុលទី4 គឺសេចក្ដីចម្រើនឥតហេតុ។ នេះជាករណីដែលបានទទួលផលប្រយោជន៍ទាំងគ្មានមូលហេតុតាមផ្លូវច្បាប់។ ឧទាហរណ៍ ករណីប្រាក់ដែលត្រូវបង់ទៅឱ្យអ្នកដទៃ បែរជាច្រឡំផ្ទេរមកលេខគណនីធនាគាររបស់យើង ជាអាទិ៍។ ក្នុងករណីនេះ យើងនឹងទទួលរងការទាមទារឱ្យសងវិញពីម្ចាស់សិទ្ធិពិតប្រាកដ ក្នុងនាមជាសេចក្ដីចម្រើនឥតហេតុ។

ប៉ុន្តែ វិសាលភាពនៃសិទ្ធិទាមទារ នៅក្នុងករណីសេចក្ដីចម្រើនឥតហេតុនេះ ខុសគ្នាអាស្រ័យទៅលើភាពសុចរិត ឬ ទុច្ចរិតរបស់បុគ្គលដែលបានទទួលផលប្រយោជន៍។ បុគ្គលសុចរិត ពោលគឺបុគ្គលដែលបានទទួលផលប្រយោជន៍ដោយមិនបានដឹងថាខ្លួនគ្មានមូលហេតុក្នុងការទទួល ត្រូវសងវិញនូវផលប្រយោជន៍ដែលនៅតែមានប៉ុណ្ណោះ (មាត្រា703)។ ប៉ុន្តែ បុគ្គលដែលបានទទួលផលប្រយោជន៍ទុច្ចរិតដែលបានដឹងថាខ្លួនគ្មានមូលហេតុក្នុងការទទួល ត្រូវសងវិញនូវផលប្រយោជន៍ដែលបានទទួលទាំងអស់រួមជាមួយការប្រាក់ និងត្រូវសងការខូចខាតដែលកើតមានឡើងចំពោះម្ចាស់សិទ្ធិពិតប្រាកដ (មាត្រា704)។

#### (2) លក្ខខណ្ឌបង្កើត

លក្ខខណ្ឌបង្កើតសេចក្ដីចម្រើនឥតហេតុរួមមាន ①ការទទួលផលប្រយោជន៍ ②ការបាត់បង់ផលប្រយោជន៍ ③ទំនាក់នៃការទទួលផលប្រយោជន៍ និង ការបាត់បង់ផលប្រយោជន៍ (ការកើតឡើងនូវការខូចខាតដោយសារអង្គហេតុដែលធ្វើឱ្យកើតឡើងនូវការទទួលផលប្រយោជន៍) និង ④នត្ថិភាពនៃមូលហេតុតាមផ្លូវច្បាប់នៃការទទួលបានផលប្រយោជន៍។ ដូចនេះ ការបានទទួលផលប្រយោជន៍ ដោយគ្មានអ្នកបាត់បង់ផលប្រយោជន៍ មិនអាចក្លាយជាសេចក្ដីចម្រើនឥតហេតុនោះទេ (ការបាត់បង់ផលប្រយោជន៍ក្នុងករណីនេះសំដៅទៅលើ ការធ្លាក់ចុះនូវទ្រព្យសម្បត្តិជាក់ស្ដែង និង ការមិនកើនឡើងនូវទ្រព្យសម្បត្តិដែលគួរតែកើនឡើង បើសិនជាគ្មានហេតុនៃសេចក្ដីចម្រើនឥតហេតុនោះ)។ សេចក្ដីចម្រើនឥតហេតុត្រូវកម្រិតត្រឹមការទទួលបានផលប្រយោជន៍ ឬ ការបាត់បង់ផលប្រយោជន៍ដែលមានទំហំតូចជាង ដូចនេះ បើការបាត់បង់ផលប្រយោជន៍របស់បុគ្គលម្នាក់មានចំនួន 20លានរៀល ហើយការទទួលបានផលប្រយោជន៍របស់បុគ្គលម្នាក់ទៀតមានចំនួន 40លានរៀល (ដោយមានទេពកោសល្យរបស់អ្នកទទួលបានផលប្រយោជន៍) ក្នុងករណីនេះ បញ្ហានៃសេចក្ដីចម្រើនឥតហេតុមានចំនួន 20លានរៀល។

(3) **អានុភាព**

ទំហំនៃសិទ្ធិទាមទារឱ្យសងវិញ ខុសគ្នាអាស្រ័យទៅលើភាពសុចរិត ឬ ទុច្ចរិតរបស់បុគ្គលដែលបានទទួលផលប្រយោជន៍ ដូចបានរៀបរាប់ខាងលើនេះ។ បុគ្គលសុចរិត ពោលគឺបុគ្គលដែលបានទទួលផលប្រយោជន៍ដោយមិនបានដឹងថាខ្លួនគ្មានមូលហេតុក្នុងការទទួល ត្រូវសងវិញនូវ **ផលប្រយោជន៍ដែលនៅតែមាន** ប៉ុណ្ណោះ (មាត្រា 703)។ ប៉ុន្តែ បុគ្គលដែលបានទទួលផលប្រយោជន៍ទុច្ចរិតដែលបានដឹងថាខ្លួនគ្មានមូលហេតុក្នុងការទទួល ត្រូវសងវិញនូវផលប្រយោជន៍ដែលបានទទួលទាំងអស់រួមជាមួយការប្រាក់ និងត្រូវសងការខូចខាតដែលកើតមានឡើងចំពោះម្ចាស់សិទ្ធិពិតប្រាកដ (មាត្រា704)។ នេះមានន័យថា បើសិនជាវត្ថុដែលបានទទួលនោះជាទំនិញ ហើយបុគ្គលដែលទទួលផលប្រយោជន៍សុចរិតបានយកទៅប្រើទាំងមិនបានដឹង ហើយបានធ្វើឱ្យបែកបាក់ជាដើម ក្នុងករណីនេះ បុគ្គលដែលទទួលផលប្រយោជន៍សុចរិតនោះគ្រាន់តែប្រគល់នូវទំនិញទាំងបែកបាក់នោះ គឺគ្រប់គ្រាន់។ បើសិនជាប្រាក់វិញ ក៏ត្រូវសងប្រាក់ដែលនៅសល់ក្នុងដៃប៉ុណ្ណោះ ប៉ុន្តែ ការយកប្រាក់នោះទៅចំណាយសម្រាប់ជីវភាព ក៏ជាផ្នែកនៃផលប្រយោជន៍ដែលនៅតែមានដែរ។

(4) **ករណីលើកលែងនៃសេចក្តីចម្រើនឥតហេតុ**

យ៉ាងណាមិញ មានករណីលើកលែងមួយចំនួនដែលការទាមទារឱ្យសងសេចក្តីចម្រើនឥតហេតុវិញ មិនអាចធ្វើទៅបាន បើទោះបីជាការទទួលផលប្រយោជន៍នោះគ្មានមូលហេតុតាមផ្លូវច្បាប់ក៏ដោយ។ ក្នុងនោះមានករណីដែលហៅថា ការសងទាំងដឹងថាគ្មានអត្ថិភាពនៃកាតព្វកិច្ច ពោលគឺ កូនបំណុលបានសងទាំងដឹងថាខ្លួនគ្មានជំពាក់បំណុលអ្វីទាល់តែសោះ (មាត្រា705)។ ក្រៅពីនេះនៅមានប្រព័ន្ធមួយទៀតដែលហៅថា **ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់** (មាត្រា708)។ នេះជាបញ្ញត្តិដែលហាមមិនឱ្យទាមទារឱ្យសងវិញនូវតាវកាលិកដែលខុសច្បាប់ ហើយវាជាបញ្ញត្តិអំពីសកម្មភាពគតិយុត្តដែលផ្ទុយនឹងទំនៀមទម្លាប់ល្អ និងសណ្តាប់ធ្នាប់សាធារណៈនៃមាត្រា90 ដែលបានរៀបរាប់រួចមកហើយ (⇒ជំពូកទី2 III.1(3))។ ឧទាហរណ៍ កិច្ចសន្យាដែលមានខ្លឹមសារថា បើលេងល្បែងចាញ់ត្រូវបង់ប្រាក់ គឺមោឃភាព ដោយផ្ទុយនឹងទំនៀមទម្លាប់ល្អ និងសណ្តាប់ធ្នាប់សាធារណៈ ហេតុនេះ ជាក់ស្តែងគ្មានកាតព្វកិច្ចកើតឡើងនោះទេ បើទោះបីជាលេងល្បែងចាញ់ក៏ដោយ។ ប៉ុន្តែ បើសិនជាលេងចាញ់ ហើយបានឱ្យប្រាក់គេនៅកន្លែងនោះរួចហើយ តែក្រោយមកទាមទារឱ្យគេសងវិញដោយមូលហេតុមោឃភាពជាដើម ក្នុងករណីនេះ បើសិនជាប្តឹងទៅតុលាការទាមទារឱ្យសងវិញក៏ដោយ ក៏តុលាការមិនអាចទទួលស្គាល់នោះទេ។ ច្បាប់មិនផ្តល់ជំនួយដល់បុគ្គលណាដែលទាមទារឱ្យបដិទាននូវផលប្រយោជន៍ដែលបាត់បង់មកវិញ ចំពោះការប្រព្រឹត្តអំពើផ្ទុយនឹងសង្គមរបស់បុគ្គលនោះឡើយ (បើមិនដូច្នោះទេ ច្បាប់នឹងក្លាយទៅជាឧបករណ៍ការពារសកម្មភាពដែលផ្ទុយនឹងសង្គមមិនខាន)។ នេះជាការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់ ហើយនៅប្រទេសអង់គ្លេសសម័យបុរាណបានបញ្ញត្តពី គោលការណ៍ Clean Hands (បុគ្គលត្រូវចូលសវនាការដោយបាតដៃស្អាតស្អំ)។

# ជំពូកទី 6

## នីតិសិទ្ធិលើបំណុល (3) — នីតិសិទ្ធិលើបំណុលទូទៅ

I. **ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិលើបំណុល**

1. ខ្លឹមសារនៃសិទ្ធិលើបំណុលទូទៅ

2. លក្ខណៈជាមូលដ្ឋាននៃសិទ្ធិលើបំណុល

3. អត្ថន័យនៃបញ្ញត្តិស្តីពីសិទ្ធិលើបំណុលទូទៅ—ភាពចាំបាច់នៅក្នុងសកម្មភាពជំនួញជាក់ស្តែង

II. **ការសិក្សាអំពីចំណុចសំខាន់នៃសិទ្ធិលើបំណុលទូទៅ**

1. ប្រភេទនៃសិទ្ធិលើបំណុល

2. ការមិនអនុវត្តកាតព្វកិច្ច

3. សមត្ថភាពរបស់ម្ចាស់បំណុល

4. ទំនាក់ទំនងសិទ្ធិលើបំណុលនៃភាគីច្រើននាក់

5. អនុប្បទានសិទ្ធិលើបំណុល

6. ការរលត់សិទ្ធិលើបំណុល

III. **ក្រមរដ្ឋប្បវេណី និង កិច្ចការច្បាប់នៃសហគ្រាស**

## I. **ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិលើបំណុល**

### 1. **ខ្លឹមសារនៃសិទ្ធិលើបំណុលទូទៅ**

ដូចបានរៀបរាប់នៅក្នុងជំពូកទី4 នៅក្នុងផ្នែកស្តីពីសិទ្ធិលើបំណុលទូទៅគឺកំណត់អំពី លក្ខណៈនៃសិទ្ធិលើបំណុល អានុភាព និង ការផ្ទេរ ព្រមទាំងការរលត់នៃសិទ្ធិលើបំណុលនោះ។ ផ្នែកនេះគឺត្រូវនឹងបទប្បញ្ញត្តិនៃជំពូកទី1 គន្ថីទី3 នៅក្នុងក្រមរដ្ឋប្បវេណី។ នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់អំពី គោលបំណងនៃសិទ្ធិលើបំណុលនៅក្នុងផ្នែកដំបូងនៅក្នុងជំពូកនេះ ប៉ុន្តែ គោលបំណងនៃសិទ្ធិលើបំណុលដែលរៀបរាប់នៅទីនេះ សំដៅទៅ ខ្លឹមសារ និង កម្មវត្ថុនៃសិទ្ធិលើបំណុល។ នៅក្នុងផ្នែកបន្ទាប់ស្តីពីអានុភាពនៃសិទ្ធិលើបំណុល គឺបញ្ញត្តិអំពី ករណីដែលមានការបំពាន ឬ ប្រុងនឹងបំពានអានុភាពចងវាងភាគីនៃកិច្ចសន្យាដែលជាមូលដ្ឋាននៃសិទ្ធិលើបំណុល។ ពោលគឺបញ្ហាដែលទាក់ទងនឹងការអនុវត្តកាតព្វកិច្ចដោយបង្ខំ សំណងការខូចខាតនៃការមិនអនុវត្តកាតព្វកិច្ច និង ការរក្សាការពារទ្រព្យសម្បត្តិទទួលខុសត្រូវ។ ប៉ុន្តែ ចំពោះសំណងនៃការខូចខាតនៃការមិនអនុវត្តកាតព្វកិច្ច ខ្ញុំបានរៀបរាប់ខ្លះមកហើយនៅក្នុងជំពូកទី4។ នៅក្នុងផ្នែកទីបី គឺជាផ្នែកស្តីពីទំនាក់ទំនងសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់ភាគីច្រើននាក់ ហើយបញ្ញត្តិអំពីករណីដែលម្ចាស់បំណុល ឬកូនបំណុលមានច្រើននាក់។ ផ្នែកបន្ទាប់ទៀត ស្តីពីអនុប្បទានសិទ្ធិលើបំណុល ពោលគឺ បញ្ហាទាក់ទងនឹងការផ្ទេរសិទ្ធិលើបំណុលទៅឱ្យបុគ្គលផ្សេងតាមរយៈកិច្ចសន្យា ហើយផ្នែកចុងក្រោយស្តីពីបញ្ហានៃការរំលត់សិទ្ធិលើបំណុល តាមរយៈការសងសិទ្ធិលើបំណុលជាអាទិ៍។

### 2. **លក្ខណៈជាមូលដ្ឋាននៃសិទ្ធិលើបំណុល**

ដូចបានសិក្សាកន្លងមក សិទ្ធិប្រត្យក្សគឺជាសិទ្ធិដែលមានលក្ខណៈផ្តាច់មុខ និង ដាច់ខាតដែលអាចអះអាងចំពោះបុគ្គលគ្រប់រូបក្នុងសកលលោក ហេតុនេះហើយ ច្បាប់ត្រូវកំណត់អំពីប្រភេទនៃសិទ្ធិប្រត្យក្សនេះឱ្យបានច្បាស់លាស់។ ផ្ទុយមកវិញ សិទ្ធិលើបំណុល គឺជាសិទ្ធិដែលបុគ្គលជាក់លាក់ម្នាក់អាចទាមទារចំពោះបុគ្គលជាក់លាក់ម្នាក់ទៀត ហើយជាគោលការណ៍សិទ្ធិនេះមានអានុភាពមិនដាច់ខាត ដែលកើតមានរវាងតែគូរភាគីប៉ុណ្ណោះ (ភាពមិនដាច់ខាតនៃសិទ្ធិលើបំណុល)។ ដោយសារតែបែបនេះហើយ ទើបភាគីអាចបង្កើតដោយសេរីនូវខ្លឹមសារនៃសិទ្ធិលើបំណុលរាប់ពាន់ម៉ឺនប្រភេទ ក្នុងទំហំដែលមិនផ្ទុយនឹងទំនៀមទម្លាប់ល្អ និង សណ្តាប់ធ្នាប់សាធារណៈ។ នេះហៅថាសេរីភាពនៃការបង្កើតសិទ្ធិលើបំណុល។ សិទ្ធិលើបំណុលគ្មានលក្ខណៈផ្តាច់មុខដូចសិទ្ធិប្រត្យក្សនោះទេ ហើយក៏គ្មានកម្រិតនូវគោលការណ៍សិទ្ធិប្រត្យក្សតែមួយលើវត្ថុតែមួយដែរ (នៅលើវត្ថុតែមួយ គេអាចបង្កើតសិទ្ធិប្រត្យក្សតែមួយប៉ុណ្ណោះ)។ ឧបមាថា តារាងចម្រៀង A បានចុះកិច្ចសន្យាទៅសម្តែងនៅមហោស្រព B ហើយក៏បានចុះកិច្ចសន្យាទៅសម្តែងនៅមហោស្រព C នៅថ្ងៃនិងម៉ោងតែមួយ។ ក្នុងករណីនេះ កិច្ចសន្យាទាំងសងខាងសុទ្ធតែមានអានុភាព ហេតុនេះ ទាំងសិទ្ធិលើបំណុលរបស់មហោស្រព B ទាមទារឱ្យទៅសម្តែង ហើយនិងសិទ្ធិលើបំណុលរបស់មហោស្រព Cទាមទារឱ្យទៅសម្តែង ដែលមានចំពោះ A គឺកើតឡើងដូចគ្នាដោយគ្មានបញ្ហាអ្វីឡើយ (ក្នុងករណីនេះ មហោស្រព B និង មហោស្រព C ស្មើភាពគ្នាដោយគ្មានអ្នកណាមានសិទ្ធិអាទិភាពលើអ្នកណានោះទេ។ នេះ

ហៅថា គោលការណ៍សមភាពនៃម្ចាស់បំណុល)។ ប្រាកដហើយថា រាងកាយរបស់ A គឺមានតែមួយ ហើយអាចទៅសម្ដែងនៅកន្លែងតែមួយប៉ុណ្ណោះ។ ប៉ុន្តែ សិទ្ធិលើបំណុលរបស់មហោស្រពដែល A មិនបានទៅសម្ដែង មិនបាត់បង់នោះទេ ហើយសិទ្ធនេះត្រូវផ្លាស់ប្ដូរទៅជាសិទ្ធិទាមទារសំណងការខូចខាត ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចរបស់ A វិញ។

សិទ្ធិលើបំណុលគឺជាសិទ្ធិដែលមិនដាច់ខាត ដូចនេះ ជាគោលការណ៍ សិទ្ធិនេះមានតែអានុភាពទាមទារ និង អានុភាពបណ្ដឹង (អានុភាពសម្រេចសិទ្ធិដោយបណ្ដឹង) ចំពោះភាគីម្ខាងទៀតប៉ុណ្ណោះ។ បើទោះបីជាមានតតិយជនផ្សេងមករំខានក៏ដោយ ក៏ភាគីមិនអាចទាមទារឱ្យតតិយជនបញ្ឈប់ការរារាំងនោះទេ ហើយដូចក្នុងឧទាហរណ៍ខាងលើនេះ សិទ្ធិលើបំណុលនេះ ជាគោលការណ៍ មានអានុភាពត្រឹមតែទាមទារការខូចខាត ក្នុងនាមជាការមិនអនុវត្តកាតព្វកិច្ចប៉ុណ្ណោះ ប្រសិនបើភាគីម្ខាងទៀតមានហេតុនៃការទទួលខុសត្រូវ។ ហើយអញ្ញត្តិកម្មអាចមានករណីដូចជា សិទ្ធិជួលដែលបានចុះបញ្ជី ជាអាទិ៍ (ជាទូទៅ សិទ្ធិលើបំណុលមិនមានប្រព័ន្ធបង្ហាញជាសាធារណៈអំពីអត្ថិភាពរបស់វាទេ (ចំពោះការផ្ទេរគឺអនុវត្តផ្សេង) ប៉ុន្តែមានប្រព័ន្ធចុះបញ្ជីសម្រាប់សិទ្ធិជួល។ មើលជំពូកទី4 III (1)) ហើយយុត្តិសាស្ត្រ និង ទ្រឹស្ដីមួយចំនួនបានទទួលស្គាល់សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង ចំពោះការបំពានពីតតិយជនដែលគ្មានសិទ្ធិ ដោយផ្អែកលើសិទ្ធិជួលដែលបានចុះបញ្ជីបាន។ ពិតហើយថា សិទ្ធិលើបំណុលផ្សេងទៀតដូចជាចំណុចស្ដីពីអំពើអនីត្យានុកូលនៃជំនួញដែលបានរៀបរាប់ពីមុន ដែលជាការដណ្ដើមកិច្ចសន្យាដោយទុច្ចរិតខ្លាំង ហើយបំពានសិទ្ធិលើបំណុល ក្នុងករណីនេះ ភាគីអាចទាមទារសំណងការខូចខាតបាន បើសិនជាលក្ខខណ្ឌនៃអំពើអនីត្យានុកូលបានបំពេញ។ ប៉ុន្តែ នេះជាការទាមទារដោយផ្អែកលើអំពើអនីត្យានុកូលនោះទេ ហើយសិទ្ធិលើបំណុលផ្ទាល់នេះ គ្មានអានុភាពទាមទារចំពោះតតិយជននោះទេ។

### 3. **អត្ថន័យនៃបញ្ញត្តិស្ដីពីសិទ្ធិលើបំណុលទូទៅ —ភាពចាំបាច់នៅក្នុងសកម្មភាពជំនួញជាក់ស្ដែង**

សិទ្ធិលើបំណុលទូទៅនេះជាផ្នែកមួយដែលឆ្លុះបញ្ចាំងអំពីទំនាក់ទំនងផលប្រយោជន៍ដ៏ស្មុគស្មាញជាងគេនៅក្នុងសង្គមជំនួញ បន្ទាប់ពីនីតិប្រាតិភោគដែលនឹងសិក្សាក្នុងជំពូកបន្ទាប់។ នេះមានន័យថា បើសិនជាយើងយល់អំពីការអនុវត្តជំនួញជាក់ស្ដែង យើងនឹងយល់កាន់តែច្បាស់អំពីខ្លឹមសារនេះ។ សូមចាប់អារម្មណ៍ថា ចំណុចដែលស្ដីពីការដាក់ប្រាតិភោគ ការគ្រប់គ្រង និង ការប្រមូលសិទ្ធិលើបំណុលដែលជាចំណុចសំខាន់នៅក្នុងកិច្ចការរបស់សហគ្រាសពាណិជ្ជកម្មនេះហើយ វាពាក់ព័ន្ធខ្លាំងជាមួយនឹងសិទ្ធិលើបំណុលនេះ និង នីតិប្រាតិភោគ។

បញ្ហាជាក់ស្ដែងនៃការដាក់ប្រាតិភោគរួមមាន **ការធានាដោយវត្ថុ** ដែលជាការធានាដោយទទួលយកវត្ថុ ពោលគឺចលនវត្ថុ ឬ អចលនវត្ថុធ្វើជាថ្នូរ និង **ការធានាដោយបុគ្គល** ដែលជាការធានាដោយទ្រព្យសម្បត្តិទាំងអស់របស់បុគ្គលណាម្នាក់ក្រៅពីកូនបំណុល ក្នុងករណីដែលកូនបំណុលពុំមានចលនវត្ថុ និង អចលនវត្ថុដែលសមស្របសម្រាប់ដាក់ធានា។ រូបភាពនៃការធានាដោយបុគ្គលនេះ គឺការធានាដែលនឹងរៀបរាប់ខាងមុខ។ ការធានាដោយ

បុគ្គលនេះមិនសូវមានស្ថេរភាពដូចការជានាដោយវត្ថុនោះទេ ដោយសារតែទ្រព្យសម្បត្តិរបស់បុគ្គលដែលយកមកជានានោះអាចមានការឡើងចុះ។ ប៉ុន្តែ ការជានាដោយវត្ថុនេះត្រូវឆ្លងកាត់នីតិវិធីស្មុគស្មាញដូចជាការចុះបញ្ជី ឬ ការប្រគល់វត្ថុជាអាទិ៍ ផ្ទុយមកវិញ ការជានាដោយបុគ្គលវិញមានលក្ខណៈងាយស្រួល ដោយសារតែតម្រូវឱ្យមានលិខិតកិច្ចសន្យាតែមួយប៉ុណ្ណោះ ពោលគឺការព្រមព្រៀងរបស់ភាគី។

លើសពីនេះ ក្នុងពេលបច្ចុប្បនេះ យើងអាចសង្កេតឃើញថា អ្នកជំនួញភាគច្រើនបាននិយមប្រើប្រាស់សិទ្ធិលើបំណុលទៅដាក់ជានាដើម្បីទទួលយកដើមទុន ឬ លក់សិទ្ធិលើបំណុលដើម្បីបំពេញទុនក្នុងសហគ្រាស។ ដើមឡើយ សិទ្ធិលើបំណុលតាមក្រមរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ឱ្យធ្វើអនុប្បទានបាន ប៉ុន្តែ តាមខ្លឹមសារនៃមាត្រាមិនបានប៉ាន់ស្មានដល់ការផ្ទេរយ៉ាងសកម្មបែបនេះ ដើម្បីប្រមូលទុននោះទេ។ នេះហៅថាលំហូរនីយកម្មនៃសិទ្ធិលើបំណុល។ បញ្ហាទាំងអស់នេះ សុទ្ធតែមានពាក់ព័ន្ធជាមួយសិទ្ធិលើបំណុលទូទៅនេះ។

## II. ការសិក្សាអំពីចំណុចសំខាន់នៃសិទ្ធិលើបំណុលទូទៅ

### 1. ប្រភេទនៃសិទ្ធិលើបំណុល

ភាគីអាចបង្កើតដោយសេរីនូវខ្លឹមសារនៃសិទ្ធិលើបំណុលរាប់ពាន់ម៉ឺនប្រភេទ ប៉ុន្តែ យើងអាចបែងចែកជាប្រភេទមួយចំនួនបាន។ ឧទាហរណ៍ ការបែងចែកជាប្រភេទ សិទ្ធិលើបំណុលដែលបានកំណត់វត្ថុជាក់លាក់ និង សិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុ គឺមានសារៈសំខាន់ណាស់។

#### (1) សិទ្ធិលើបំណុលដែលបានកំណត់វត្ថុជាក់លាក់

បើសិនជាយើងពិចារណាអំពីការទិញលក់ផ្ទាំងគំនូរ និង ដី គឺគ្មានរបស់ណាផ្សេងទៀតដែលដូចគ្នានោះទេ ហេតុនេះ សិទ្ធិលើបំណុលគឺជាសិទ្ធិទាមទារទៅលើតាវកាលិកនៃវត្ថុដែលបានកំណត់ជាក់លាក់នោះ។ នេះហៅថា សិទ្ធិលើបំណុលដែលបានកំណត់វត្ថុជាក់លាក់។ ចំពោះសិទ្ធិលើបំណុលដែលបានកំណត់វត្ថុជាក់លាក់នេះ កូនបំណុលមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតលើវត្ថុដែលជាកម្មវត្ថុ (**ករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន**) (ចំណុចនេះបានកំណត់ដោយពិចារណាអំពីដើមហេតុនៃការកកើតកិច្ចសន្យា និង សិទ្ធិលើបំណុលផ្សេងទៀត ព្រមទាំងគោលគំនិតទូទៅនៃសង្គមជំនួញ) រហូតដល់ពេលអនុវត្ត (មាត្រា400។ មានន័យថា បើសិនជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញគឺជាវត្ថុដែលបានកំណត់ជាក់លាក់ ក្នុងករណីនេះ បើសិនជានៅក្រោយពេលចុះកិច្ចសន្យានិងរហូតដល់ពេលប្រគល់ កូនបំណុលបានទុកវត្ថុនោះចោលហាលភ្លៀង ហើយបណ្តាលឱ្យខូចខាតវត្ថុនោះ វានឹងក្លាយជាការមិនបានអនុវត្តកាតព្វកិច្ចរបស់កូនបំណុលខ្លួនឯង ហើយត្រូវមានករណីយកិច្ចសងការខូចខាតនោះ)។ បើសិនជាវត្ថុដែលជាកម្មវត្ថុបានបាត់បង់នៅមុនពេលប្រគល់ (ដោយសារតែគ្មានវត្ថុ

ណាយកមកជំនួសបាន) ក្នុងករណីនេះ វានឹងក្លាយជាអលទ្ធភាពក្នុងការអនុវត្ត ហើយសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនឹងប្តូរទៅជាសិទ្ធិទាមទារសំណងការខូចខាត។

### (2) **សិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុ**

#### ① សញ្ញាណទូទៅ

ផ្ទុយមកវិញ បើសិនជាទិញលក់ស្រាបៀម៉ាកណាមួយចំនួនប៉ុន្មានយួរជាដើម វាគឺជាវត្ថុដែលបានកំណត់តាមប្រភេទដែលអាចជំនួសបាន ក្នុងករណីនេះ គេហៅថា សិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុ។ ចំពោះសិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុនេះ (ដោយសារតែមានវត្ថុជំនួស) ករណីយកិច្ចគ្រប់គ្រងរបស់កូនបំណុលមិនត្រូវបានកំណត់នោះទេ ប៉ុន្តែ កូនបំណុលមានករណីយកិច្ចរកវត្ថុផ្សេងដែលមានប្រភេទដូចគ្នាពីទីផ្សារមកជំនួស ក្នុងករណីដែលកម្មវត្ថុបានបាត់បង់នៅមុនពេលប្រគល់ (ពោលគឺ បើសិនជាហាងលក់ស្រាបៀបានធ្វើឱ្យបែកដបស្រាបៀដែលគេបានកម្មង់នៅក្នុងហាងរបស់ខ្លួន ក្នុងករណីនេះ ហាងលក់ស្រាបៀរនោះមានករណីយកិច្ចរៀបចំនូវដបស្រាបៀផ្សេងដែលមានប្រភេទដូចគ្នាមកជំនួស)។ ឧបមាថា ភាគីគ្រាន់តែកម្ម៉ង់ថាយក «ឥដ្ឋការ៉ូដែលជាគ្រឿងសំណង់» ដោយមិនបានកំណត់អំពីគុណភាពនៃកម្មវត្ថុនោះទេ (ហើយបើសិនជាមិនបានកំណត់អំពីសាជាតុនៃកិច្ចសន្យាផងដែរនោះ) ក្នុងករណីនេះ កូនបំណុលត្រូវតែផ្តល់នូវវត្ថុដែលមានគុណភាពធម្មតាពីក្នុងចំណោមវត្ថុដែលមានប្រភេទដូចគ្នា (មាត្រា401 កថាខណ្ឌទី1)។

#### ② ការកំណត់ជាក់លាក់នូវសិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុ

ទោះបីជាឧទាហរណ៍អំពីស្រាបៀនៅខាងលើក៏ដោយ យើងអាចមើលឃើញថានៅក្នុងដំណាក់កាលណាមួយរហូតដល់ពេលអនុវត្តកិច្ចសន្យា ម្ចាស់បំណុលនឹងសម្រេចថា «យកយួរមួយនេះ» ពីក្នុងចំណោមប្រភេទនៃស្រាបៀជាច្រើននោះ។ ចំពោះការដឹកជញ្ជូនស្រាបៀ ជាធម្មតាវាមិនបានកំណត់ទេរហូតដល់ដំណាក់កាលដែលហាងលក់ស្រាបៀដឹកដល់ផ្ទះអ្នកទិញ ហើយអ្នកទិញចង្អុលថា «យកមួយនេះ» ប៉ុន្តែក្នុងករណីដែលអ្នកទិញបានទៅទិញស្រាវីស្គីនៅហាងផ្ទាល់សម្រាប់ជាអំណោយ ហើយបានចង្អុលម៉ាកស្រាវីស្គីណាមួយពីធ្នើរក្នុងហាងថា «យកមួយនោះ» ដើម្បីឱ្យហាងវេចខ្ចប់ឱ្យ ស្រាវីស្គីមួយដបដែលត្រូវបានវេចខ្ចប់នោះគឺត្រូវបានកំណត់។ នេះហៅថា «ការកំណត់ជាក់លាក់» នូវសិទ្ធិលើបំណុលតាមប្រភេទ។ ក្រមរដ្ឋប្បវេណីបានកំណត់ថា បើសិនជាកូនបំណុលបានបញ្ចប់សកម្មភាពនានាដើម្បីប្រគល់ ឬ បានកំណត់វត្ថុដែលត្រូវប្រគល់ដោយមានការឯកភាពពីម្ចាស់បំណុល បន្ទាប់ពីនេះវត្ថុនោះនឹងក្លាយជាកម្មវត្ថុនៃសិទ្ធិលើបំណុល (មាត្រា401 កថាខណ្ឌទី2)។ ចាប់ពីពេលដែលបានកំណត់ជាក់លាក់ជាលទ្ធផល សិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុនឹងត្រូវអនុវត្តដូចគ្នានឹងសិទ្ធិលើបំណុលដែលបានកំណត់វត្ថុជាក់លាក់ ហើយកូនបំណុលមានករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន ចំពោះវត្ថុដែលបានកំណត់ជាក់លាក់នោះ (បើទោះបីជាមានករណីយកិច្ចគ្រប់គ្រងកើតឡើងក៏ដោយ ប៉ុន្តែក្នុងករណីដែលវត្ថុនោះបានបាត់បង់

វាគ្រាន់តែក្លាយទៅជាករណីយកិច្ចសងសំណងការខូចខាត ហើយកូនបំណុលលែងមានករណីយកិច្ចក្នុងការស្វែងរកវត្ថុដែលមានប្រភេទដូចគ្នាពីទីផ្សារមកជំនួសកម្មវត្ថុទៀតហើយ)។

③ សិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុដែលត្រូវបានកម្រិត

សិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុដែលត្រូវបានកម្រិត (មានកំណត់) គឺជាការកម្រិតនូវប្រភេទតាមវិសាលភាពពិសេស (អត្ថិភាពនៅទីតាំង) ដែលជាទម្រង់មួយនៃសិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុ។ ឧទាហរណ៍ ក្នុងករណីសិទ្ធិទាមទារឱ្យប្រគល់អង្ករ Koshihikari ចំនួន៣០០គីឡូក្រាម ដែលមាននៅក្នុងឃ្លាំងរបស់ក្រុមហ៊ុន ក ទោះបីជានៅមុនពេលកំណត់ជាក់លាក់ក៏ដោយ ប្រសិនបើអង្ករនៅក្នុងឃ្លាំងនោះអស់ វានឹងក្លាយជាអលទ្ធភាពក្នុងការអនុវត្ត ហើយកូនបំណុលមិនមានករណីយកិច្ចស្វែងរកវត្ថុនោះពីទីផ្សារឡើយ (ប្រសិនបើអង្ករ Koshihikari នៅក្នុងឃ្លាំងត្រូវបានឆេះអស់នោះ មានតែកាតព្វកិច្ចសងសំណងការខូចខាតប៉ុណ្ណោះដែលកើតឡើង)។

### (3) សិទ្ធិលើបំណុលជាប្រាក់ និង អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

សិទ្ធិលើបំណុលដែលត្រូវបង់ជាប្រាក់ (សិទ្ធិលើបំណុលជាប្រាក់) គឺជាសិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុដែលច្បាស់លាស់បំផុត (ប្រាក់មិនអាចបាត់បង់ពីលើពិភពលោកនេះទេ ហេតុនេះ អលទ្ធភាពក្នុងការអនុវត្តមិនអាចកើតមានឡើយ។ មាត្រា419 កថាខណ្ឌទី3) ប៉ុន្តែ ក្រមរដ្ឋប្បវេណីមានកំណត់អំពីបញ្ញត្តិពិសេសមួយចំនួនស្តីពីសិទ្ធិលើបំណុលជាប្រាក់។ ដោយឡែក អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ក្នុងក្រមរដ្ឋប្បវេណី គឺ 3 ភាគរយក្នុង១ឆ្នាំ (មាត្រា404)។ ដើមឡើយ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ (អនុវត្តនៅក្នុងករណីដែលភាគីមិនបានសម្រេចនៅក្នុងកិច្ចសន្យា និង ករណីការប្រាក់យឺតយ៉ាវនៃការមិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូលជាអាទិ៍) គឺត្រូវបានកំណត់ «5ភាគរយក្នុង១ឆ្នាំ» ប៉ុន្តែ នៅក្នុងវិសោធនកម្មច្បាប់ឆ្នាំ2017 គេបានទម្លាក់មក «3ភាគរយ»(មាត្រា404កថាខណ្ឌទី២) ដោយពិចារណាអំពីស្ថានភាពនៃទីផ្សារអត្រាការប្រាក់ក្នុងរយៈពេលខ្លីក្នុងរយៈពេល៣ឆ្នាំ (មាត្រាដដែល ចាប់ពីកថាខណ្ឌទី3)។ នេះជាវិសោធនកម្មមួយដែលមានការឯកភាពគ្នា (មានប្រទេសជាច្រើននៅប៉ែកអឺរ៉ុបបានកែប្រែអត្រាការប្រាក់នេះ)។ ទន្ទឹមនឹងនេះ បទបញ្ញត្តិដោយឡែកស្តីពីអត្រាការប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម (ច្បាប់ពាណិជ្ជកម្ម មាត្រា514 កំណត់អត្រា 6ភាគរយក្នុងមួយឆ្នាំ) ក៏ត្រូវបានលុបចោលដែរ។

ពាក្យគន្លឹះ: **ការកាត់បន្ថយការប្រាក់ពាក់កណ្តាលកាល**

ត្រង់នេះគឺមានបញ្ហាមួយ អំពីការកាត់បន្ថយការប្រាក់ពាក់កណ្តាលកាល ដែលយកមកប្រើប្រាស់សម្រាប់គណនា «ផលប្រយោជន៍ដែលបាត់បង់» នៅក្នុងសំណងជានារ៉ាប់រងជាអាទិ៍។ នៅប្រទេសជប៉ុន ប្រាក់ជានារ៉ាប់រងមិនបង់ជាដំណាក់កាលនោះទេ ហើយត្រូវបង់ផ្តាច់តែម្តង។ ឧបមាថា ផលប្រយោជន៍ដែលបាត់បង់មានអំឡុងពេល

10ឆ្នាំ ក្នុងករណីនេះ ចំនួនទឹកប្រាក់ដែលត្រូវបានទទួលរៀងរាល់ឆ្នាំជាបន្តបន្ទាប់ ត្រូវយកមកបង់តែមួយលើក។ ហេតុនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងបង់ដោយយកចំនួនទឹកប្រាក់សរុបទាំងអស់ ដកជាមួយនឹងអត្រាការប្រាក់ប្រចាំឆ្នាំ។ ដូចនេះ បើអត្រាការប្រាក់កំណត់ដោយច្បាប់ធ្លាក់ចុះ ការកាត់បន្ថយការប្រាក់ពាក់កណ្ដាលកាលក៏ថយចុះដែរ ហេតុនេះហើយ ភាគីទទួលផលនឹងទទួលបានប្រាក់ធានារ៉ាប់រងខ្ពស់ជាងចំនួនទឹកប្រាក់ពីមុននៅក្នុងគ្រោះថ្នាក់ដូចគ្នា (ចំណុចនេះ យើងអាចនិយាយថា វិសោធនកម្មនេះផ្ដល់ប្រយោជន៍ដល់ភាគីទទួលផល ប៉ុន្តែ ភាគីក្រុមហ៊ុនធានារ៉ាប់រងអាចនឹងបង្កើនតម្លៃធានារ៉ាប់រងដើម្បីបង្គ្រប់)។

### (4) **សិទ្ធិលើបំណុលជាប្រាក់ដើម និង សិទ្ធិលើបំណុលជាការប្រាក់**

នៅក្នុងការខ្ចីប្រាក់អាចបង្កើតឱ្យមាន សិទ្ធិលើបំណុលជាប្រាក់ដើម និង សិទ្ធិលើបំណុលជាការប្រាក់ ប៉ុន្តែ សិទ្ធិលើបំណុលជាការប្រាក់ដែលបានកើតឡើងរួចហើយ អាចកាត់ផ្ដាច់ចេញតែចំណែកនោះ ហើយចាត់ចែងបាន។ បើសិនជាមានសិទ្ធិលើបំណុលក្នុងកម្ចីប្រាក់ចំនួន 200លានរៀល ហើយបង្កើតការប្រាក់ 10លានរៀលក្នុងមួយឆ្នាំ ក្នុងករណីនេះ សិទ្ធិលើបំណុលជាប្រាក់ដើមនោះ (ភ្ជាប់កិច្ចសន្យាការប្រាក់) ប្រាកដជាអាចធ្វើអនុប្បទានបាន ប៉ុន្តែ ឧបមាថា មានការប្រាក់នៅក្នុងឆ្នាំដំបូងដែលបានកើតឡើង ហើយម្ចាស់បំណុលមិនទាន់បានទទួលការសងនៅឡើយ នោះម្ចាស់បំណុលអាចធ្វើអនុប្បទាននូវសិទ្ធិលើបំណុលជាការប្រាក់ចំពោះតែចំណែកដែលបានកើតឡើងហើយ ពីការប្រាក់ចំនួន 10លានរៀលនោះ ទៅឱ្យតតិយជនបាន។

### (5) **សិទ្ធិលើបំណុលអនិយ័ត**

នៅក្នុងការព្រមព្រៀងរបស់ភាគី ដែលអនុញ្ញាតឱ្យមានសិទ្ធិលើបំណុលដែលអាចជ្រើសរើសយក «រថយន្តមួយគ្រឿង ឬ ប្រាក់ 40លានរៀល» ជាអាទិ៍ ធ្វើជាគោលបំណងនៃតាវកាលិក សិទ្ធិលើបំណុលនេះហៅថា សិទ្ធិលើបំណុលអនិយ័ត (មាត្រា406)។ នេះជាការជ្រើសរើសរបស់ដែលមានលក្ខណៈខុសៗគ្នានៃការជ្រើសរើសនីមួយៗ ហើយវាមិនដូចគ្នាទាល់តែសោះទៅនឹង សិទ្ធិលើបំណុលដែលបានកំណត់តាមប្រភេទវត្ថុ ដូចជា «យកស្រាបៀមួយយួរនេះជំនួសឱ្យស្រាបៀមួយយួរផ្សេងទៀត (ពីក្នុងប្រភេទនៃស្រាបៀដូចគ្នា)»។

## 2. **ការមិនអនុវត្តកាតព្វកិច្ច**

### (1) **ការអនុវត្តកាតព្វកិច្ចដោយបង្ខំ**

ការអនុវត្តដោយបង្ខំ គឺជាការទទួលយកជំនួយពីស្ថាប័នរដ្ឋ ដើម្បីសម្រេចការអនុវត្តដោយបង្ខំ ក្នុងករណីដែលភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ចតាមការសន្យា (ការដែលម្ចាស់បំណុលប្រើកម្លាំងខ្លួនឯងបង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច (**ការសង្គ្រោះដោយកម្លាំងខ្លួនឯង**) ជាគោលការណ៍ គឺមិនត្រូវបានអនុញ្ញាតឡើយ)។ ក្រមរដ្ឋប្បវេណី (មាត្រា414) និង ច្បាប់ស្តីពីការអនុវត្ត បានកំណត់អំពីវិធីអនុវត្តដោយបង្ខំជា 3ប្រភេទ ដូចខាងក្រោមនេះ។

① ការបង្ខំដោយផ្ទាល់

វិធីដែលស្ថាប័នរដ្ឋសម្រេចដោយបង្ខំនូវការបង់ប្រាក់ ឬ ប្រគល់វត្ថុ ដោយមិនពិចារណាអំពីឆន្ទៈរបស់កូនបំណុល។ អាជ្ញាសាលាទៅដល់ទីតាំងរបស់កូនបំណុល ហើយអនុវត្ត។

② ការអនុវត្តជំនួស

វិធីដែលឱ្យតតិយជនសម្រេចខ្លឹមសារនៃសិទ្ធិលើបំណុល ហើយស្ថាប័នរដ្ឋប្រមូលសោហ៊ុយសម្រាប់ចំណាយពីកូនបំណុល។ ឧទាហរណ៍ថា ក្រុមហ៊ុនសំណង់បញ្ឈប់ការសាងសង់ពាក់កណ្តាលទី ក្នុងករណីនេះ គេអាចឱ្យក្រុមហ៊ុនសំណង់ផ្សេងបន្តសាងសង់ ហើយប្រមូលសោហ៊ុយដែលបានចំណាយលើការសាងសង់ពីក្រុមហ៊ុនសំណង់ដើម។

③ ការបង្ខំដោយប្រយោល

វិធីដែលដាក់សម្ពាធផ្លូវចិត្តដល់កូនបំណុលឱ្យអនុវត្តកាតព្វកិច្ច ដោយតុលាការបង្គាប់ឱ្យកូនបំណុលមានករណីយកិច្ចត្រូវបង់ប្រាក់ចំនួនជាក់លាក់មួយ រហូតដល់ពេលអនុវត្តកាតព្វកិច្ច។ ឧទាហរណ៍ វិធីអនុវត្តនេះ ប្រើប្រាស់ក្នុងករណីដែលការបំពានកាតព្វកិច្ចមិនឱ្យបញ្ចេញសម្លេងរំខាននៅតែមានជាបន្តបន្ទាប់ (តុលាការចេញសាលក្រម «បង្គាប់ឱ្យបង់ប្រាក់ 4លានរៀលក្នុងមួយថ្ងៃរហូតដល់ពេលបញ្ឈប់សម្លេងរំខាន»)។ ដើមឡើយប្រទេសជប៉ុនមិនអនុញ្ញាតការអនុវត្តជំនួស②ទេ ក្នុងករណីដែល ការបង្ខំដោយផ្ទាល់①អាចធ្វើបាន ហើយទទួលស្គាល់ការអនុវត្តដោយប្រយោល③ តែក្នុងករណីដែលការអនុវត្តវិធីទី① និងទី② មិនអាចធ្វើទៅបានប៉ុណ្ណោះ។ ប៉ុន្តែ នៅក្នុងវិសោធនកម្មច្បាប់អនុវត្តរដ្ឋប្បវេណីឆ្នាំ2003 បានពង្រីកវិសាលភាពនៃការអនុវត្តដោយប្រយោល។

### (2) សំណងការខូចខាតនៃការមិនអនុវត្តកាតព្វកិច្ច

① សញ្ញាណទូទៅ

ចំណុចនេះ ខ្ញុំបានពន្យល់គ្រួសៗរួចហើយនៅក្នុងជំពូកទី4។ ការមិនអនុវត្តកាតព្វកិច្ច (ការមិនបានអនុវត្តតាមគោលបំណងនៃកាតព្វកិច្ច) បែងចែកជា 3ប្រភេទ គឺ ការអនុវត្តយឺតយ៉ាវ អលទ្ធភាពក្នុងការអនុវត្ត និង ការអនុវត្តមិនពេញលេញ។ ទោះជាយ៉ាងណាក៏ដោយ បើសិនជាមិនបានអនុវត្តកាតព្វកិច្ចតាមការសន្យាទេ ម្ចាស់បំណុលអាចទាមទារសំណងការខូចខាតបាន។ ប៉ុន្តែ កូនបំណុលអាចរួចផុតពីការទទួលខុសត្រូវ ប្រសិនបើកូនបំណុលគ្មានហេតុនៃការទទួលខុសត្រូវ ដោយពិចារណាលើខ្លឹមសារនៃកិច្ចសន្យា និង ទស្សនៈទូទៅក្នុងសង្គម (មាត្រា415)។ នៅមុនវិសោធនកម្មច្បាប់ឆ្នាំ2017 ក្រមរដ្ឋប្បវេណីកំណត់ថា កូនបំណុលពុំមានការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ចឡើយ ប្រសិនបើកូនបំណុលគ្មានហេតុដែលត្រូវទទួលខុសត្រូវ (ហេតុដែលអាចដាក់ឱ្យទទួលខុសត្រូវ)។ ពោលគឺ ហេតុនៃការទទួលខុសត្រូវមិនមែនជាលក្ខខណ្ឌបង្កើតការមិនអនុវត្តកាតព្វកិច្ចនោះទេ ប៉ុន្តែ វាជាលក្ខខណ្ឌដែលអាចរួចផុតពីការទទួលខុសត្រូវទៅវិញ (មានន័យថា ករណីប្រធានសក្តិដូចជា ការកាត់ផ្តាច់ផ្លូវដោយសារ

ញ្ញួយដី ជាអាទិ៍ កូនបំណុលពុំមានការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ បើទោះបីជាអនុវត្តយឺតយ៉ាវក៏ដោយ ពីព្រោះគ្មានហេតុនៃការទទួលខុសត្រូវ)។

② ទំហំនៃសំណងការខូចខាត

ក្រមរដ្ឋប្បវេណីជប៉ុនបានកំណត់ថា ការខូចខាតដែលកើតឡើងជាទូទៅដោយសារការមិនអនុវត្តកាតព្វកិច្ច (ការខូចខាតធម្មតា) ត្រូវបញ្ចូលទៅក្នុងទំហំនៃសំណង ចំណែកឯការខូចខាតដែលកើតឡើងដោយកាលៈទេសៈពិសេសវិញ (ការខូចខាតពិសេស) អាចបញ្ចូលក្នុងទំហំនៃសំណងបាន លុះត្រាតែកូនបំណុលអាចព្យាករណ៍អំពីការខូចខាតនោះជាមុនប៉ុណ្ណោះ (ដែលអាចព្យាករជាមុន) (មាត្រា416។ នេះហៅថា គោលការណ៍កម្រិតសំណង)។ តើអ្វីជាការខូចខាតធម្មតា ហើយអ្វីជាការខូចខាតពិសេសនោះ គឺអាស្រ័យទៅលើរឿងក្ដីនីមួយៗ។ ឧបមាថា អ្នកលក់បានប្រគល់ផ្ទះយឺតយ៉ាវរយៈពេល 1ខែ នៅក្នុងកិច្ចសន្យាទិញផ្ទះសម្រាប់ស្នាក់នៅ ហើយអ្នកទិញត្រូវទៅជួលបន្ទប់ស្នាក់នៅសិន ក្នុងករណីនេះ ថ្លៃឈ្នួលបន្ទប់នេះគឺជាការខូចខាតទូទៅ។ បើសិនជាអ្នកទិញនោះបានសន្យាលក់បន្តទៅឱ្យអ្នកផ្សេង តែត្រូវបញ្ឈប់វិញដោយសារតែការយឺតយ៉ាវក្នុងការប្រគល់នេះ ហើយអ្នកលក់បានខូចខាតនូវផលប្រយោជន៍ពីការលក់បន្តនោះ ក្នុងករណីនេះ យើងអាចនិយាយថា វាជាការខូចខាតពិសេស។ ការខូចខាតនេះអាចបញ្ចូលក្នុងទំហំនៃសំណងបាន លុះត្រាតែកូនបំណុលបានដឹង ឬ អាចព្យាករអំពីការលក់បន្តនេះប៉ុណ្ណោះ។

③ ការទូទាត់កំហុស

សំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬការកើតឡើងនូវការខូចខាត ឬការរីករាលដាលការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច អាចត្រូវបានកាត់បន្ថយចំនួនទឹកប្រាក់នៃសំណងបាន ដោយពិចារណាអំពីទំហំនៃកំហុសរបស់ភាគីម្ចាស់បំណុល (មាត្រា418។ ចំណុចនេះស្ទើរតែដូចគ្នានឹងការទូទាត់កំហុសនៃអំពើអនីត្យានុកូល (មាត្រា722) ដែលបានសិក្សារួចហើយ ជំពូកទី5 II 4 (3))។

④ ការកំណត់ជាមុននូវចំនួនសំណង

ភាគីអាចព្រមព្រៀងជាមុនអំពីចំនួននៃសំណងការខូចខាតបាន (ប៉ុន្តែ ការកំណត់ដែលផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ អាចត្រូវបានមោឃភាព។ មាត្រា420 កថាខណ្ឌទី1)។ តាមការអនុវត្តជាក់ស្ដែង ការកំណត់ជាមុននូវចំនួននៃសំណងនេះធ្វើឡើងដោយមូលហេតុថា ការគណនាអំពីសំណងនៅពេលក្រោយគឺលំបាក ហើយមួយទៀត គឺការកំណត់ចំនួនទឹកប្រាក់ឱ្យខ្ពស់ ដើម្បីបង្ការមិនឱ្យភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ច។

⑤ ឧបាទេសកម្មនៃអ្នកសង

នៅពេលដែលម្ចាស់បំណុលបានទទួលសំណងគ្រប់ចំនួននៃវត្ថុ ឬ សិទ្ធិដែលជាគោលបំណងនៃសិទ្ធិលើបំណុលរួចហើយ កូនបំណុលនឹងទទួលបានឋានៈជំនួសឱ្យម្ចាស់បំណុលទៅលើវត្ថុ និង សិទ្ធិលើបំណុលនោះ។ នេះហៅថា ឧបាទេសកម្មនៃអ្នកសង (មាត្រា422⇒ សូមយោងចំណុច 3(1) នៅខាងក្រោយ)។ ឧទាហរណ៍ បុគ្គលម្នាក់បានសងការខូចខាតទាំងស្រុងដល់ម្ចាស់បំណុល ដោយសារតែបានធ្វើឱ្យបាត់វត្ថុដែលខ្លួនយកមករក្សាទុកក្នុងកិច្ចសន្យាបញ្ញើ។ ក្រោយមក បើសិនជាវត្ថុនោះបានរកឃើញមកវិញ បុគ្គលនោះនឹងទទួលបានកម្មសិទ្ធិនៅលើវត្ថុនោះ (ជំនួសឱ្យកម្មសិទ្ធិករដើម)។

### (3) ការយឺតយ៉ាវក្នុងការទទួលរបស់ម្ចាស់បំណុល

ផ្ទុយមកវិញ កូនបំណុលបានព្យាយាមអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យាហើយ ប៉ុន្តែ ម្ចាស់បំណុលមិនព្រមទទួល។ ករណីនេះ គេហៅថា ការយឺតយ៉ាវក្នុងការទទួល។ ក្រមរដ្ឋប្បវេណី មាត្រា413 កំណត់ថា បើសិនជាម្ចាស់បំណុលបានប្រកែក ឬ មិនទទួលការសងដែលកូនបំណុលបានស្នើផ្ដល់ការសង (មានន័យថា កូនបំណុលបានយកកម្មវត្ថុទៅដល់ផ្ទះរបស់ម្ចាស់បំណុល បើសិនជាកាតព្វកិច្ចដែលកូនបំណុលសន្យាថាយកទៅឱ្យ ឬ កូនបំណុលបានរៀបចំរួចរាល់ក្នុងការប្រគល់ ហើយបានជូនដំណឹងទៅម្ចាស់បំណុល បើសិនជាកាតព្វកិច្ចដែលម្ចាស់បំណុលសន្យាថាទៅយក) ក្នុងករណីនេះ កូនបំណុលនឹងរួចផុតពីការទទួលខុសត្រូវចំពោះសំណងនៃការមិនអនុវត្តកាតព្វកិច្ច ហើយករណីយកិច្ចប្រុងប្រយ័ត្ននៃការគ្រប់គ្រងវត្ថុត្រូវប្ដូរពីការគ្រប់គ្រងក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត (ករណីយកិច្ចប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិត) មកត្រឹមការគ្រប់គ្រងក្នុងនាមជារបស់ខ្លួនឯងពោលគឺកម្រិតនៃករណីយកិច្ចគ្រប់គ្រងទាបជាងមុន (មាត្រា413 កថាខណ្ឌទី1 ⇒ចំពោះ«ការប្រុងប្រយ័ត្នដូចនឹងការគ្រប់គ្រងក្នុងនាមជារបស់ខ្លួនឯង» សូមយោងកិច្ចសន្យាបញ្ញើមិនយកតម្លៃថ្នូរនៅក្នុងជំពូកទី4)។ ហើយនៅពេលដែលសោហ៊ុយនៃការអនុវត្តកើនឡើង ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវចំនួននៃការកើនឡើងនោះ (មាត្រាដដែល កថាខណ្ឌទី2)។ ទោះបីជាមានការព្រមព្រៀងជាមុនយ៉ាងណាក៏ដោយ ក៏បន្ទុកហានិភ័យក្នុងករណីដែលកម្មវត្ថុបានបាត់បង់នៅមុនពេលប្រគល់ ត្រូវផ្ទេរទៅឱ្យម្ចាស់បំណុលបន្ទាប់ពីបានស្នើអនុវត្តហើយ (មាត្រា567 កថាខណ្ឌទី2)។ ប៉ុន្តែ គេកំពុងតែពិភាក្សាគ្នាថា អានុភាពទាំងនេះ គឺជាអានុភាពនៃការយឺតយ៉ាវក្នុងការទទួល ឬ អានុភាពនៃការស្នើផ្ដល់ការសង។

ដោយឡែក ទ្រឹស្ដីជាច្រើនបានលើកឡើងថា ការយឺតយ៉ាវក្នុងការទទួល អាចបង្កើតឱ្យមានអានុភាពត្រឹមកម្រិតដូចខាងលើប៉ុណ្ណោះ ហើយមិនទទួលស្គាល់ដល់ថ្នាក់ជា «ការមិនអនុវត្តកាតព្វកិច្ច» របស់ម្ចាស់បំណុលនោះទេ (ដោយពិចារណាថា កាតព្វកិច្ចទទួលគឺជាកាតព្វកិច្ច ហើយពិចារណាថា មិនបានអនុវត្តកាតព្វកិច្ចទទួលនោះ។ មានទ្រឹស្ដីខ្លះបកស្រាយបែបនេះ)។ ផ្ទុយមកវិញ ភាគីកូនបំណុលមិនអាចទាមទារលុបចោល ឬសំណងការខូចខាតចំពោះម្ចាស់បំណុលបានឡើយ។ ប៉ុន្តែ ទ្រឹស្ដីមានឥទ្ធិពលក្នុងពេលបច្ចុប្បន្ននេះមានគំនិតផ្ទុយពីនេះ មានន័យថា

ចំពោះកិច្ចសន្យាដែលម្ចាស់បំណុលមានករណីយកិច្ចទទួលយកដូចជាកិច្ចសន្យាលក់ទិញជាអាទិ៍ គេអាចទទួលស្គាល់ការមិនអនុវត្តកាតព្វកិច្ចចំពោះករណីយកិច្ចនោះបាន (នៅក្រោយពេលធ្វើវិសោធនកម្ម កិច្ចសន្យាដែលមានទទួលស្គាល់អំពីកាតព្វកិច្ចទទួល នឹងអាចវាយតម្លៃថាមានការមិនអនុវត្តកាតព្វកិច្ចនោះ នៅក្នុងការសម្រេចនីមួយៗ)។

3. **សមត្ថភាពរបស់ម្ចាស់បំណុល** (ការរក្សាការពារទ្រព្យសម្បត្តិទទួលខុសត្រូវ)

(1) **ការរក្សាការពារទ្រព្យសម្បត្តិទទួលខុសត្រូវគឺជា**

ជាទូទៅ ករណីខ្ចីដើមទុនពីធនាគារជាដើម អ្នកឱ្យខ្ចីតែងយកអ្វីមកដើម្បីធានា។ ប៉ុន្តែ នៅក្នុងទំនាក់ទំនងជាមួយភាគីដែលជួញដូរទំនិញជាមួយគ្នាជាបន្តបន្ទាប់ ភាគច្រើនម្ចាស់បំណុលមិនទាមទារឱ្យមានការធានាចំពោះសិទ្ធិលើបំណុលនៃថ្លៃលក់ដែលមិនទាន់បានបង់គ្រប់ពេលទាំងអស់ទេ ទោះបីជាថ្លៃលក់នោះមិនទាន់ទូទាត់ហើយសិទ្ធិលើបំណុលនោះកើនឡើងច្រើនក៏ដោយ ហើយនៅតែបន្តការជួញដូរជាមួយគ្នាជាបន្តបន្ទាប់ដោយសារតែទុកចិត្តគ្នាទៅវិញទៅមក។ ម្ចាស់បំណុលបែបនេះ ហៅថាម្ចាស់បំណុលទូទៅ បើសិនជាប្រៀបធៀបជាមួយម្ចាស់បំណុលដែលទទួលបានការសងដោយអាទិភាពពីប្រាតិភោគ។ ដូច្នេះ ការទាមទារសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលទូទៅអាចសម្រេចបាន លុះត្រាតែកូនបំណុលមានទ្រព្យសម្បត្តិស្មើនឹងសិទ្ធិលើបំណុលនោះប៉ុណ្ណោះ។ ទ្រព្យសម្បត្តិទាំងអស់ដែលកូនបំណុលអាចចាត់ចែងបាន សម្រាប់ធានាការសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលទូទៅបែបនេះ ហៅថា ទ្រព្យសម្បត្តិទទួលខុសត្រូវ។ ប៉ុន្តែ ទ្រព្យសម្បត្តិនេះប្រែប្រួលទៅតាមស្ថានភាពរបស់កូនបំណុល ពេលគឺ ពេលខ្លះប៉ោង ហើយពេលខ្លះធូរ ដូចជាប៉េតប៉ោងអញ្ចឹង។ ដូចនេះ បើសិនជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលមានលើសពី 40លានរៀល ចំពោះសិទ្ធិលើបំណុល 40លានរៀល គឺ ការទាមទារសិទ្ធិលើបំណុលនោះអាចសម្រេចបានទាំងស្រុង ប៉ុន្តែ បើទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលមានតែ 32លានរៀល ឬ 24លានរៀលវិញ នោះសិទ្ធិលើបំណុលមិនអាចប្រមូលបានទាំងស្រុងនោះទេ។ ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានបង្កើតនូវប្រព័ន្ធដែលអនុញ្ញាតឱ្យម្ចាស់បំណុលដែលស្ថិតនៅក្នុងគោលជំហរអស្ថិរភាពបែបនេះ អាចអនុវត្តសិទ្ធិលើបំណុលជំនួសឱ្យកូនបំណុលក្នុងករណីកំណត់មួយ ហើយការជ្រៀតជ្រែកក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលនេះ ធ្វើឡើងក្នុងគោលបំណងរក្សាទំហំនៃទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុល។ ប្រព័ន្ធនេះគឺជាសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល និង សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍។ ដើមឡើយកូនបំណុលអាចចាត់ចែងទ្រព្យសម្បត្តិខ្លួនដោយសេរី ហេតុនេះ ការជ្រៀតជ្រែករបស់ម្ចាស់បំណុល ត្រូវកម្រិតក្នុងទំហំនៃកម្រិតអប្បបរមានៃការរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ (យ៉ាងណាមិញ ពាក្យថាឧបាទេសកម្មគឺសំដៅទៅលើការទទួលយកឋានៈជំនួស ហេតុនេះ វាមានខ្លឹមសារខុសគ្នានឹងការតំណាង។ សូមយោង «ឧបាទេសកម្មដោយការសង» នៅក្នុងជំពូកនេះ II 6(2)④ )។

## (2) សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល

### ① សញ្ញាណទូទៅ

ម្ចាស់បំណុល A មានសិទ្ធិលើបំណុលនៃថ្លៃលក់ចំនួន 40លានរៀល ចំពោះកូនបំណុល B។ ដោយឡែក B បែរជាមានសិទ្ធិលើបំណុលដែលមិនទាន់ប្រមូលចំនួន 60លានរៀល ចំពោះកូនបំណុល C (បើមើលពី A វិញ C គឺជាកូនបំណុលទី3) ហើយគ្មានទ្រព្យសម្បត្តិអ្វីផ្សេងពីនេះទេ។ ហើយ B មិនអើពើក្នុងការទាមទារសិទ្ធិលើបំណុលដែលមានចំនួន 60លានរៀលនេះ ពី C នោះទេ ហេតុនេះ បើនៅតែទុកចោលបែបនេះ សិទ្ធិលើបំណុលនេះអាចនឹងត្រូវរលត់ដោយអាជ្ញាយុកាល។ នៅក្នុងករណីបែបនេះ សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល គឺជាសិទ្ធិដែលអនុញ្ញាតឱ្យ A ទទួលយកឋានៈជំនួសឱ្យ B ហើយទាមទារសិទ្ធិលើបំណុលចំពោះ C (មាត្រា423)។ មានន័យថា សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល គឺម្ចាស់បំណុលអាចអនុវត្តសិទ្ធិចំពោះកូនបំណុលទី3 ជំនួសឱ្យកូនបំណុលបាន (សិទ្ធិដែលត្រូវបានធ្វើឧបាទេសកម្ម) ក្នុងករណីដែលចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន (នេះជាការអនុវត្តសិទ្ធិដោយផ្ទាល់របស់ម្ចាស់បំណុល ហើយមិនមែនជាការអនុវត្តក្នុងនាមអ្នកតំណាងនោះទេ)។




### ② អានុភាព

ក្នុងករណីនេះ A អាចប្រមូលក្នុងទំហំនៃសិទ្ធិលើបំណុលរបស់ខ្លួន ពោលគឺត្រឹមកម្រិត 40លានរៀល (មាត្រា423.2)។ ដើមឡើយ ការប្រមូលសិទ្ធិលើបំណុលជំនួស គឺត្រូវតែយកទៅប្រគល់ឱ្យ B ជាមុនសិន ប៉ុន្តែករណីរបស់ដែលប្រមូលបាននោះគឺជាប្រាក់វិញ A អាចទទួលយកការសងដោយអាទិភាពជាក់ស្តែងបាន តាមរយៈការទូទាត់ (ជំពូកនេះ II.6(5)) ប្រាក់នោះជាមួយនឹងសិទ្ធិលើបំណុលរបស់ខ្លួន (មាត្រា423.3)។

### ③ ទំហំនៃការអនុវត្ត និង លក្ខខណ្ឌនៃការអនុវត្ត

សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល ក៏អាចអនុវត្តចំពោះសិទ្ធិជាក់លាក់ក្រៅពីសិទ្ធិលើបំណុលជាប្រាក់ផងដែរ (សិទ្ធិលើបំណុលដែលទាមទារឱ្យផ្តល់តាវកាលិកជាក់លាក់ក្រៅពីការបង់ជាប្រាក់។ ឧទាហរណ៍ សិទ្ធិជួល ឬ

សិទ្ធិទាមទារឱ្យចុះបញ្ជីផ្ទេរ ជាអាទិ៍)។ ឧទាហរណ៍ A បានជួលដីពី B ហើយជនដែលគ្មានសិទ្ធិ C បានចាប់ផ្តើមប្រើប្រាស់ដីនោះដោយចិត្តឯង ហើយបានបំពានដល់សិទ្ធិជួលរបស់ A ក្នុងករណីនេះ សិទ្ធិជួលរបស់ A គឺជាសិទ្ធិលើបំណុល ហេតុនេះ A មិនអាចតតាំងចំពោះតតិយជនឡើយ (ពោលគឺ C) ដរាបណាមិនទាន់បានចុះបញ្ជី (មាត្រា605) ឬ បំពេញអានុភាពតតាំងផ្សេងទៀត។ ដូចនេះ A អាចអនុវត្តសិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងរបស់ B (ដោយសារតែ B ជាកម្មសិទ្ធិករនៅលើដី ហេតុនេះ គាត់មានសិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងដោយផ្អែកលើកម្មសិទ្ធិបាន) ចំពោះ C ដោយឧបាទេសកម្ម ដើម្បីរក្សាការពារសិទ្ធិជួលរបស់ខ្លួនដែលមានចំពោះ B បាន។ ប៉ុន្តែ ម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិឧបាទេសកម្មចំពោះ សិទ្ធិដែលមានតែកូនបំណុលផ្ទាល់ទើបអាចអនុវត្តបាន ដូចជាសិទ្ធិទាមទារឱ្យលែងលះរបស់កូនបំណុលជាដើម (សិទ្ធិផ្តាច់មុខផ្ទាល់ក្នុងការអនុវត្ត) និង សិទ្ធិដែលហាមមិនឱ្យរឹបអូសនោះទេ (វាក្យខណ្ឌទី2 កថាខណ្ឌ1 នៃមាត្រា423)។

យ៉ាងណាមិញ សិទ្ធិឧបាទេសកម្មអាចអនុវត្តបានតែក្នុងករណីដែលមានភាពចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់អ្នកអនុវត្តសិទ្ធិឧបាទេសកម្មប៉ុណ្ណោះ ដោយសារតែ នេះជាការជ្រៀតជ្រែកដល់ការចាត់ចែងសិទ្ធិរបស់អ្នកដទៃ។ ដូច្នេះ បើសិទ្ធិជាសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិលើបំណុលជាប្រាក់ ក្នុងករណីនេះ លក្ខខណ្ឌជាមូលដ្ឋាននៃការអនុវត្តសិទ្ធិឧបាទេសកម្ម គឺកូនបំណុលអសាធនភាព។ ប៉ុន្តែ បើសិនជាសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិលើបំណុលជាក់លាក់ ដូចជាសិទ្ធិទាមទារឱ្យចុះបញ្ជីផ្ទេរជាដើម ក្នុងករណីនេះ សិទ្ធិឧបាទេសកម្មអាចអនុវត្តទៅបាន បើសិនជាគ្មានវិធីផ្សេងដើម្បីរក្សាការពារសិទ្ធិ ហើយអសាធនភាពនៃកូនបំណុលមិនមែនជាបញ្ហាទៀតនោះទេ (មាត្រា423.7)។

### (3) **សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍**

#### ① សញ្ញាណទូទៅ

សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ឬ អាចហៅម្យ៉ាងទៀតថា សិទ្ធិលុបចោលរបស់ម្ចាស់បំណុល។ ឧទាហរណ៍ដូចខាងលើនេះ B មានទ្រព្យសម្បត្តិដែលជាដីតែមួយគត់ដែលមានតម្លៃប្រហែល 200 លានរៀល ហើយ B បានប្រទានកម្មដីនោះទៅឱ្យ D ដែលជាសាច់ញាតិរបស់ខ្លួន ដើម្បីគេចពីការទាមទាររបស់ម្ចាស់បំណុល ហើយ B បានក្លាយជាអសាធនភាព។ ក្នុងករណីនេះ ដើម្បីរក្សាការពារនូវសិទ្ធិលើបំណុលចំនួន 40 លានរៀល របស់ខ្លួន A អាចលុបចោលកិច្ចសន្យាប្រទានកម្មរវាង B និង D បាន ក្នុងនាមជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ (មាត្រា424)។ តាមរយៈនេះ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺជាប្រព័ន្ធដែលមានគោលបំណងលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ហើយបង្វែរទ្រព្យសម្បត្តិដែលបានចាកចេញពីទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលចូលមកក្នុងនោះវិញ (ឧទាហរណ៍ ការបង្វែរទំហំនៃទ្រព្យសម្បត្តិទទួលខុសត្រូវឱ្យដូចដើមវិញ ករណីដែលកូនបំណុលបានបន្ថយទំហំទ្រព្យនោះដោយចេតនា)។

② <u>អានុភាព</u>

ជាគោលការណ៍ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ អាចអនុវត្តបានក្នុងទំហំដែលប៉ះពាល់ដល់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលខ្លួនឯងប៉ុណ្ណោះ។ ដូចនេះ សិទ្ធិលើបំណុលចំនួន 40លានរៀល របស់ម្ចាស់បំណុល A អាចលុបចោលត្រឹមកម្រិតនៃទឹកប្រាក់ 40លានរៀលនេះ ប៉ុណ្ណោះ ចំពោះប្រទានកម្មនូវទំហំទឹកប្រាក់ 200លានរៀល ដែល B បានផ្ទេរទៅឱ្យ D (មាត្រា424.8)។ ប៉ុន្តែ ដីគឺមិនអាចបែងចែកទេ ពោលគឺត្រូវលុបចោលនូវប្រទានកម្មទាំងស្រុង ហើយលក់ដោយបង្ខំនូវដីដែលត្រឡប់មកជារបស់Bវិញ ហើយ A ប្រមូលបំណុលចំនួន 40លានរៀល ពីថ្លៃលក់ដោយបង្ខំនោះ។ ក្នុងករណីនេះ ម្ចាស់បំណុលទូទៅផ្សេងទៀតក្រៅពី A ក៏អាចចូលរួមប្រមូលបំណុលបានដែរ ពោលគឺ ការចូលរួមចែកចំណែក។




សាលក្រមស្ថាពរនៃសិទ្ធិលុបចោល នឹងមានអានុភាពចំពោះកូនបំណុល និង ម្ចាស់បំណុលទាំងអស់ (មាត្រា425) ប៉ុន្តែ ករណីសិទ្ធិលើបំណុលជាប្រាក់វិញ នឹងមានលទ្ធផលដូចគ្នានឹងករណីសិទ្ធិឧបាទេសកម្មដែរ ដែលជាក់ស្តែងម្ចាស់បំណុលដែលបានអនុវត្តសិទ្ធិលុបចោល អាចទទួលបានការប្រមូលបំណុលដោយអាទិភាព។ ឧបមាថា ម្ចាស់បំណុល A បានលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ដោយការផ្តល់តាវកាលិកជាប្រាក់ជាដើម ក្នុងករណីនេះ ម្ចាស់បំណុល A អាចទាមទារឱ្យប្រគល់តាវកាលិកនោះមកខ្លួនផ្ទាល់ជាមុនសិនបាន ដោយមូលហេតុថា កូនបំណុល B អាចនឹងប្រកែកមិនព្រមទទួលយកនូវប្រាក់ដែលបដិទានមកវិញជាអាទិ៍ (មាត្រា424.9)។ ហើយម្ចាស់បំណុល A អាចទូទាត់នូវប្រាក់ដែលបានទទួលមកនោះ ជាមួយនឹងសិទ្ធិលើបំណុលដែលខ្លួនអាចទាមទារចំពោះ B បាន (ជំពូកនេះ II.6(5)) ហើយតាមរយៈនេះ ម្ចាស់បំណុលបានទទួលការសងដោយអាទិភាព។

③ <u>លក្ខខណ្ឌ</u>

សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺខុសពីសិទ្ធិឧបាទេសកម្ម ត្រង់ថា សិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារគឺចាំបាច់ត្រូវជាសិទ្ធិលើបំណុលជាប្រាក់។ លក្ខខណ្ឌនៃអំពើដែលនាំឱ្យខូចខាតនូវ

ផលប្រយោជន៍នេះ ត្រូវមានលក្ខខណ្ឌសត្យានុម័តដែលជាស្ថានភាពនៃអំពើនោះត្រូវមានភាពបំពានផលប្រយោជន៍ (សូមយោងមាត្រា424.2 និងមាត្រា424.3 ជាអាទិ៍) និង ត្រូវមានលក្ខខណ្ឌអត្តនោម័តដែលជាឆន្ទៈបំពានប្រយោជន៍ចំពោះម្ចាស់បំណុលរបស់អ្នកធ្វើអំពើ និង ភាពទុច្ចរិតរបស់អ្នកដែលបានទទួលផលប្រយោជន៍។ យ៉ាងណាមិញ សិទ្ធិឧបាទេសកម្មអាចធ្វើឡើងក្រៅផ្លូវតុលាការបាន ប៉ុន្តែ សិទ្ធិលុបចោលនេះ (អានុភាពមានអំណាចខ្លាំងជាង) ត្រូវតែធ្វើឡើងតាមផ្លូវតុលាការ។

<u>④ អំឡុងពេលដាក់ពាក្យបណ្តឹង</u>

ការធ្វើបណ្តឹងនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍មិនអាចធ្វើទៅបានឡើយ បើសិនជាអំឡុងពេល 2ឆ្នាំបានកន្លងផុតគិតចាប់ពីពេលដែលម្ចាស់បំណុលបានដឹងអំពីមូលហេតុនៃការលុបចោល ឬ 10 ឆ្នាំគិតចាប់ពីពេលដែលបានប្រព្រឹត្តអំពើ (មាត្រា426)។




## 4. ទំនាក់ទំនងសិទ្ធិលើបំណុលនៃភាគីច្រើននាក់

### (1) ចំណុចដែលត្រូវសិក្សាអំពីទំនាក់ទំនងនៃភាគីច្រើននាក់

នៅទីនេះ យើងមិនផ្តោតទៅលើករណីម្ចាស់បំណុលម្នាក់ជាមួយកូនបំណុលម្នាក់នោះទេ តែជាករណីដែលនៅក្នុងកិច្ចសន្យាមួយដែលមានម្ចាស់បំណុល ឬ កូនបំណុលច្រើននាក់ ហេតុនេះ បញ្ហាដែលបង្កពីភាគីច្រើននាក់នឹងកើតមានឡើង។ ចំណុចនេះមានប្រភេទជាច្រើនដូចជា កាតព្វកិច្ចវិភាគីយ៍ និង សិទ្ធិលើបំណុលអវិភាគីយ៍ ជាអាទិ៍។ ប៉ុន្តែ ឧបមាថា ភាគីកូនបំណុលមានច្រើននាក់ ហើយខ្លឹមសារនៃសិទ្ធិលើបំណុលគឺជាប្រាក់ ក្នុងករណីនេះ ចំណុចបញ្ហាអាចមាន 3 ដូចតទៅនេះ។ (1) តើម្ចាស់បំណុលអាចទាមទារចំពោះកូនបំណុលច្រើននាក់ដោយរបៀបណា ហើយទាមទារចំនួនប៉ុន្មាន? នេះហៅថាទំនាក់ទំនងខាងក្រៅ។ (2) ហេតុដែលកើតមានឡើងរវាង

ម្ចាស់បំណុលនិងកូនបំណុលម្នាក់ក្នុងចំណោមកូនបំណុលជាច្រើន ឧបមាថា ម្ចាស់បំណុលបានលើកលែងបំណុលចំពោះកូនបំណុលម្នាក់ តើវាមានឥទ្ធិពលបែបណាដល់កូនបំណុលផ្សេងទៀត? នេះហៅថា ទំនាក់ទំនងឥទ្ធិពល។ (3) បើកូនបំណុលម្នាក់បានសងបំណុលរួចហើយ តើកូនបំណុលម្នាក់នោះទាមទារពីកូនបំណុលផ្សេងវិញរបៀបណា? នេះហៅថា ទំនាក់ទំនងទាមទារឱ្យសងនៅផ្ទៃក្នុងរបស់កូនបំណុល។ ចំណុចដំបូង យើងនឹងចាប់ផ្តើមវែកញែកទៅតាមប្រភេទនីមួយៗនៃទំនាក់ទំនងភាគីច្រើនចំពោះចំណុចទាំង 3នេះ។ ចំណុចបន្ទាប់គឺ យើងនឹងមើលអំពីមុខងារនៃការធានាសិទ្ធិលើបំណុលត្រូវបានបំពេញនៅក្នុងទំនាក់ទំនងដែលភាគីមានច្រើននាក់។ ទោះបីជាបែបនេះក៏ដោយ គ្រប់ប្រភេទកាតព្វកិច្ចទាំងអស់ មិនសុទ្ធតែមានមុខងារនេះទេ ។ មុខងារនៃការធានាមានសារៈសំខាន់ខ្លាំងចំពោះកាតព្វកិច្ចដោយសាមគ្គីភាពដែលលេចឡើងនៅចុងបញ្ចប់នៃមាត្រារហូតដល់ចំណុចទី២ ហើយចំពោះកាតព្វកិច្ចនៃការធានា គឺអាចនិយាយបានថា ការបង្កើតឱ្យមានភាគីច្រើនរូបគឺដើម្បីបម្រើមុខងារនៃការធានានេះឯង។

### (2) សិទ្ធិលើបំណុលវិភាគីយ៍ និង កាតព្វកិច្ចវិភាគីយ៍

ក្រមរដ្ឋប្បវេណីកំណត់ថា ក្នុងករណីដែលមានកូនបំណុល និង ម្ចាស់បំណុលច្រើននាក់ ចំពោះសិទ្ធិលើបំណុលតែមួយ ប្រសិនបើភាគីមិនមានការព្រមព្រៀងពិសេសទេ ជាគោលការណ៍ កូនបំណុល និង ម្ចាស់បំណុលនីមួយៗអាចទាមទារឱ្យបែងចែកបាន (មាត្រា427)។ ហើយការបែងចែកនេះត្រូវសន្មតថាស្មើៗគ្នា បើសិនជាភាគីមិនបានកំណត់ពិសេស។ ឧទាហរណ៍ បើសិនជាកូនបំណុល 3នាក់បានខ្ចីប្រាក់ពីធនាគារចំនួន 120លានរៀល ក្នុងករណីនេះ កូនបំណុលនីមួយៗត្រូវមានកាតព្វកិច្ច 40លានរៀលម្នាក់ (កាតព្វកិច្ចវិភាគីយ៍) ហើយបើសិនជាបុគ្គល 2នាក់បានលក់វត្ថុអវិភាគរបស់ខ្លួនទៅឱ្យកូនបំណុលតែម្នាក់ ក្នុងតម្លៃ 120លានរៀល ក្នុងករណីនេះ បុគ្គលម្នាក់ៗមានសិទ្ធិលើបំណុលជាទឹកប្រាក់ថ្លៃលក់ទិញ ម្នាក់60លានរៀល (សិទ្ធិលើបំណុលវិភាគីយ៍)។ ប៉ុន្តែ បើសិនជាទទួលស្គាល់គោលការណ៍នេះជ្រុលពេក ជាពិសេសករណីកាតព្វកិច្ចវិភាគីយ៍ ភាគច្រើនវានឹងអាចមានលទ្ធផលមិនល្អចំពោះម្ចាស់បំណុល (សូមយោង (4) កាតព្វកិច្ចសាមគ្គីភាព ខាងក្រោយនេះ)។

### (3) សិទ្ធិលើបំណុលអវិភាគីយ៍ និង កាតព្វកិច្ចអវិភាគីយ៍

បើសិនជាមិនអាចបែងចែកតាវកាលិកបានដោយសារតែលក្ខណៈនៃកម្មវត្ថុ ក្នុងករណីនេះ ការអនុវត្តត្រូវធ្វើទាំងមូលតែម្តង ដោយមិនអាចបែងចែកជាសិទ្ធិលើបំណុលវិភាគីយ៍ និង កាតព្វកិច្ចវិភាគីយ៍នោះទេ (សូមយោងមាត្រា428 និងមាត្រា430)។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញរថយន្តមួយគ្រឿង ដែលមានអ្នកទិញ 2នាក់ ក្នុងករណីនេះ រថយន្តមិនអាចបែងចែកជាពាក់កណ្តាលនោះទេ ហេតុនេះ បើសិនជាបុគ្គលណាមួយបានទទួលការប្រគល់រួចហើយ តាមរយៈនេះ បុគ្គលម្នាក់ទៀតនឹងសន្មតថាបានទទួលការប្រគល់ដូចគ្នា (សិទ្ធិលើបំណុលអវិភាគីយ៍។ ចំពោះថ្លៃឈ្នួលដែលបានជួលឱ្យ C នូវបន្ទប់ដែលជាកម្មសិទ្ធិអវិភាគរបស់ A និង B ក៏ជា សិទ្ធិលើបំណុលអវិភាគីយ៍ផងដែរ ហេតុនេះ មិនអាចបង់ត្រឹមពាក់កណ្តាលនោះទេ)។ អ្នកលក់ 2នាក់ មានកម្មសិទ្ធិអវិភាគលើរថយន្ត

មួយគ្រឿង ហើយអ្នកទិញមានតែម្នាក់ ក្នុងករណីនេះ ប្រសិនបើអ្នកលក់ណាម្នាក់បានប្រគល់រថយន្តទៅឱ្យអ្នកទិញ ហើយតាមរយៈនេះ អ្នកលក់ម្នាក់ផ្សេងទៀតក៏ត្រូវសន្មតថា បានអនុវត្តកាតព្វកិច្ចផងដែរ (កាតព្វកិច្ចអវិភាគិយ៍)។

### (4) កាតព្វកិច្ចដោយសាមគ្គីភាព

#### ① អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

ខ្ញុំយល់ថា កាតព្វកិច្ចជានាជារឿងដែលសំខាន់បំផុតនៅក្នុងជីវភាពពិតរបស់បុគ្គលម្នាក់ៗ ប៉ុន្តែ យើងចាំបាច់ត្រូវដឹងអំពី កាតព្វកិច្ចដោយសាមគ្គីភាពជាមុនសិន។ ឧបមាថា B C និង D បានខ្ចីប្រាក់ពីធនាគារ A ចំនួន 360 លានរៀល ក្នុងគោលបំណងបើកហាងរួមគ្នា។ ដូចបានរៀបរាប់ពីមុន ក្រមរដ្ឋប្បវេណីបានកំណត់ថា បើសិនជាម្ចាស់បំណុលដែលជាធនាគារ A និង កូនបំណុល 3នាក់ទៀត មិនបានសម្រេចជាមុននោះទេ បំណុលនេះនឹងក្លាយជាកាតព្វកិច្ចវិភាគីយ៍។ ការបែងចែកនេះគឺជាគោលការណ៍ (មាត្រា427)។ បើសិនជាកាតព្វកិច្ចនេះជាកាតព្វកិច្ចវិភាគីយ៍ នៅពេលកំណត់ពេលបានមកដល់ A អាចទាមទារឱ្យ B C និង D សងចំនួន 120លានរៀលម្នាក់បាន។ ដូចនេះ ឧបមាថា នៅពេលកំណត់សងនេះ B បានបាត់ខ្លួន ឬ ក្លាយជាអសាធនភាពជាដើម ក្នុងករណីនេះ ម្ចាស់បំណុលអាចទាមទារ 120លានរៀលម្នាក់ ពីកូនបំណុល 2នាក់ប៉ុណ្ណោះ ប៉ុន្តែ មិនអាចប្រមូលបំណុល 120លានរៀលទៀត ពី B នោះទេ។ ដូច្នេះហើយ ម្ចាស់បំណុលនឹងជួបការលំបាក ហេតុនេះ A អាចឱ្យ B C និង D ខ្ចីប្រាក់ 360លានរៀល ដោយធ្វើកិច្ចសន្យាជាកាតព្វកិច្ចដោយសាមគ្គីភាពបាន។ បើធ្វើបែបនេះ នៅពេលដែលកំណត់ពេលសងមកដល់ A អាចទាមទារ B ក៏បាន C ក៏បាន ឬ D ក៏បាន ឱ្យសងប្រាក់ចំនួន 360លានរៀល ទាំងអស់បាន។ ប្រាកដហើយថា ម្ចាស់បំណុលមិនអាចទាមទារឱ្យសងសរុបរហូតដល់ទៅ 1080លានរៀលនោះទេ។ កាតព្វកិច្ចដោយសាមគ្គីភាព សំដៅទៅលើករណីដែលកូនបំណុលនីមួយៗមានករណីយកិច្ចត្រូវសងនូវប្រាក់ទាំងអស់ ហេតុនេះ A អាចជ្រើសរើសឱ្យ B C ឬ D សងប្រាក់ទាំងអស់ក៏បាន ឬ ទាមទារឱ្យសងដោយបែងចែកចំនួនយ៉ាងម៉េចក៏បានដែរ (មាត្រា436 គឺមានន័យបែបនេះ)។

នេះគឺជា ករណីដែលក្រមរដ្ឋប្បវេណីបានកំណត់អំពី ស្ថានភាពដែលកូនបំណុលដោយសាមគ្គីភាពមានឆន្ទៈសាមគ្គីភាពជាអត្តនោម័ត (នៅក្នុងឧទាហរណ៍ខាងលើនេះ កូនបំណុលដោយសាមគ្គីភាពបានបង្ហាញឆន្ទៈខ្ចីប្រាក់ដោយមានបំណងបើកហាងរួមគ្នា។ នេះហៅថា ភាគីមាន «ទំនាក់ទំនងរួមជាអត្តនោម័ត»)។ ពិតប្រាកដហើយ ការទទួលយកជាកាតព្វកិច្ចដោយសាមគ្គីភាព ឬ យ៉ាងណានោះ គឺជាសេរីភាពរបស់ភាគី ហើយភាគីអាចព្រមព្រៀងពិសេសផ្សេងទៀតដោយស្ម័គ្រចិត្ត ប៉ុន្តែប្រសិនបើចុះកិច្ចសន្យាដោយយកកាតព្វកិច្ចដោយសាមគ្គីភាព គឺនឹងក្លាយទៅជាបែបនេះ។ ក្នុងករណីនេះ នៅក្នុងទំនាក់ទំនងផ្ទៃក្នុងរវាងកូនបំណុលខ្លួនឯង កូនបំណុលអាចសម្រេចអំពីភាគនៃបន្ទុកចុងក្រោយបាន(⇒ពាក្យគន្លឹះ៖ចំណែកនៃបន្ទុក) ឧបមាថា 120លានរៀលក្នុងម្នាក់ជាអាទិ៍ ប៉ុន្តែ ម្ចាស់បំណុលនៅតែអាចទាមទារចំពោះកូនបំណុលណាក៏បាន នូវចំនួនទឹកប្រាក់ទាំងអស់នោះ។ ចំពោះម្ចាស់បំណុល បើទោះបីជាមានកូនបំណុលណាម្នាក់បាត់ខ្លួនក៏ដោយ ក៏ខ្លួននៅតែអាចប្រមូលបំណុលពីកូនបំណុលផ្សេងទៀតបាន

ហេតុនេះ អានុភាពនៃសិទ្ធិលើបំណុលត្រូវបានពង្រឹងជាងមុន ឬនិយាយម្យ៉ាងទៀតថា កូនបំណុលត្រូវជានាកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។

ពាក្យគន្លឹះ៖ **ចំណែកនៃបន្ទុក**

ចំណែកនៃបន្ទុកគឺជាភាគរយនៃបន្ទុក។ ដូចនេះ ករណីដែលមានកូនបំណុលសាមគ្គីភាព 3នាក់ដែលជា B C និង D ចំពោះកាតព្វកិច្ច 360លានរៀល នោះចំណែកនៃបន្ទុកម្នាក់ៗ ក្នុងករណីគ្មានការកំណត់ពិសេសគឺ 120លានរៀល ស្មើៗគ្នា។ ក្នុងស្ថានភាពនេះ បើសិនជា B បានបង់ប្រាក់ 72លានរៀល ឱ្យទៅម្ចាស់បំណុល ក្នុងករណីនេះ B អាចទាមទារ C និង D សងប្រាក់ក្នុងម្នាក់ចំនួន 24លានរៀល មកឱ្យខ្លួនបាន។ ប៉ុន្តែ សូមនិយាយដដែលៗ ដើម្បីកុំឱ្យច្រឡំត្រង់ចំណុចថា កូនបំណុលនីមួយៗនៃកាតព្វកិច្ចដោយសាមគ្គីភាពមានករណីយកិច្ចសងប្រាក់ទាំងអស់ (360លានរៀល) ឱ្យទៅម្ចាស់បំណុល ហើយបើសិនជាកូនបំណុលណាមួយ បានសងលើសរហូតដល់ចំណែកកូនបំណុលផ្សេងដទៃ កូនបំណុលនោះអាចទាមទារឱ្យសងវិញចំពោះកូនបំណុលដូចគ្នាបាន ប៉ុន្តែ នៅក្នុងទំនាក់ទំនងជាមួយម្ចាស់បំណុល កូនបំណុលនីមួយៗមិនអាចអះអាងថាខ្លួនសងប្រាក់ត្រឹមចំណែកនៃបន្ទុករបស់ខ្លួននោះទេ។

② ហេតុនៃអានុភាពដាច់ខាតនៃកាតព្វកិច្ចដោយសាមគ្គីភាព

នៅក្នុងកាតព្វកិច្ចដោយសាមគ្គីភាព បានយកទំនាក់ទំនងជាអត្តនោម័តនៃកូនបំណុលដូចគ្នាធ្វើជាបុរេលក្ខខណ្ឌ។ ហេតុនេះហើយ ហេតុដែលបានកើតឡើងរវាងម្ចាស់បំណុល និង កូនបំណុលម្នាក់ ដែលធ្វើឱ្យមានឥទ្ធិពលណាមួយដល់កូនបំណុលផ្សេងទៀត គឺមានលក្ខណៈសមហេតុផល។ ឧទាហរណ៍ ហេតុទាំងនេះរួមមាន ការសង (បើសិនជាកូនបំណុលណាម្នាក់បានសងមួយផ្នែក នោះចំនួនទឹកប្រាក់ដែលកូនបំណុលដោយសាមគ្គីភាពផ្សេងទៀតត្រូវសង គឺជាចំនួនដែលនៅសល់) នវកម្ម (មាត្រា513) និង ការទូទាត់ (ចាប់ពីមាត្រា505) ជាអាទិ៍។ ប៉ុន្តែ នៅក្នុងវិសោធនកម្មច្បាប់ឆ្នាំ2017 មានកែប្រែហេតុមួយចំនួនដែលធ្លាប់មានឥទ្ធិពលចំពោះកូនបំណុលដោយសាមគ្គីភាពផ្សេងទៀត (ហៅថា ហេតុនៃអានុភាពដាច់ខាត) ទៅជាគ្មានឥទ្ធិពលចំពោះកូនបំណុលដោយសាមគ្គីភាពផ្សេងទៀត (ហៅថា ហេតុនៃអានុភាពមិនដាច់ខាត) ទៅវិញ (ប្រសិនបើគ្មានបញ្ញត្តិថាជាអានុភាពដាច់ខាតទេ ជាគោលការណ៍គឺជាអានុភាពមិនដាច់ខាត)។ ①ដំបូង គឺការទាមទារឱ្យអនុវត្ត (មាត្រា434 អំពីហេតុនៃអានុភាពដាច់ខាតមុនវិសោធនកម្មច្បាប់ ត្រូវបានលុបចោល)។ មូលហេតុគឺ កាតព្វកិច្ចដោយសាមគ្គីភាពមានប្រភេទជាច្រើនខុសៗគ្នា ហេតុនេះ បើសិនជាទទួលស្គាល់អំពីអានុភាពដាច់ខាតជាទូទៅចំពោះកាតព្វកិច្ចដោយសាមគ្គីភាព ក្នុងករណីនេះ កូនបំណុលដោយសាមគ្គីភាពដែលមិនបានទទួលការទាមទារឱ្យអនុវត្ត អាចក្លាយជាការអនុវត្តយឺតយ៉ាវ ឬ អំឡុងពេលរលត់ដោយអាជ្ញាយុកាលត្រូវបានបន្តសារជាថ្មីទាំងកូនបំណុលនោះមិនបានដឹង។ ②បន្ទាប់មកគឺ ការលើកលែងក៏ដូចគ្នាដែរ (មាត្រា437 អំពីហេតុនៃអានុភាពដាច់ខាតមុនវិសោធនកម្មច្បាប់ ត្រូវបានលុបចោល)។ ពីព្រោះ យើងយល់ឃើញថា ឆន្ទៈជាទូទៅរបស់ម្ចាស់បំណុលដែលលើកលែងបំណុលឱ្យកូនបំណុលដោយសាមគ្គីភាពណាម្នាក់ គ្មានបំណងចង់ឱ្យមានឥទ្ធិពលដល់កូនបំណុលដោយសាមគ្គីភាពផ្សេងទៀតនោះទេ។

③ចំណុចចុងក្រោយមួយទៀតគឺ ការសម្រេចអាជ្ញាយុកាលចំពោះកូនបំណុលដោយសាមគ្គីភាពណាម្នាក់ (មាត្រា439 អំពីហេតុនៃអានុភាពដាច់ខាតមុនវិសោធនកម្មច្បាប់ ត្រូវបានលុបចោល)។ តាមរយៈនេះ មុខងារជានានៃកាតព្វកិច្ចដោយសាមគ្គីភាពត្រូវបានពង្រឹង។ ចំណុចផ្សេងទៀត ដូចជា ហេតុនៃការរាប់អាជ្ញាយុកាលសារជាថ្មី ហេតុនៃការបង្អង់អាជ្ញាយុកាល កំហុសរបស់កូនបំណុលសាមគ្គីភាពណាម្នាក់ ការអនុវត្តឃឹតយ៉ាវ អានុភាពនៃសាលក្រមដែលបានចេញចំពោះកូនបំណុលណាម្នាក់ និងអានុភាពនៃការជូនដំណឹងទៅកាន់កូនបំណុលណាម្នាក់ ជាអាទិ៍ ត្រូវមានអានុភាពមិនដាច់ខាតទាំងអស់។

### (5) កាតព្វកិច្ចធានា

#### ① សញ្ញាណទូទៅ

បន្ទាប់ពីយល់អំពីខ្លឹមសារខាងលើរួចហើយ ខ្ញុំនឹងរៀបរាប់បន្តអំពីកាតព្វកិច្ចធានា។ នេះជាចំណុចដែលតំណាងឱ្យការធានាដោយបុគ្គលដូចបានលើកឡើងពីខាងដើម ប៉ុន្តែនៅពេលក្លាយខ្លួនជាអ្នកធានា ត្រូវតែប្រុងប្រយ័ត្នហើយប្រយ័ត្នទៀត។ នៅក្នុងការធានា មានការធានាធម្មតា និង ការធានាដោយសាមគ្គីភាព ហើយជាពិសេស ការធានាដោយសាមគ្គីភាពនេះត្រូវប្រុងប្រយ័ត្នជាងគេ។ ពាក្យថា ការធានានេះ យើងបានឮជាញឹកញាប់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ហើយប្រហែលជាអាចយល់ខ្លឹមសារមួយកម្រិតដែរ ប៉ុន្តែ បញ្ហាត្រង់ថា តើការយល់នោះត្រឹមត្រូវដែរឬទេ? ខ្ញុំនឹងពន្យល់បណ្តើរ និង សាកល្បងការយល់ដឹងនេះបណ្តើរ។

យ៉ាងណាមិញ កាតព្វកិច្ចធានា គឺភ្ជាប់ជាមួយនឹងកាតព្វកិច្ចចម្បង ហើយមានវាសនារួមគ្នា។ នេះមានន័យថា បើសិនជាកាតព្វកិច្ចចម្បងបានរលត់ដោយសារការសង នោះកាតព្វកិច្ចធានាក៏រលត់ដែរ ហើយបើសិនជាកាតព្វកិច្ចចម្បងត្រូវបានលុបចោល នោះកាតព្វកិច្ចធានាក៏ត្រូវបាត់បង់ដែរ (នេះហៅថា ភាពបន្ទាប់បន្សំនៃកាតព្វកិច្ចធានា)។

#### ② កិច្ចសន្យាធានា និង កាតព្វកិច្ចធានា

ឧបមាថា A គឺជាម្ចាស់បំណុល និង B គឺជាកូនបំណុល ហើយ B ពឹងពាក់ឱ្យ C ជួយធ្វើជាអ្នកធានា ក្នុងករណីនេះ តើ C ត្រូវចុះកិច្ចសន្យាជាមួយអ្នកណា? ចម្លើយគឺ មិនមានចុះជាមួយ B ទេ។ កិច្ចសន្យាធានានេះគឺ ត្រូវចុះជាមួយ A ដែលជាម្ចាស់បំណុល។ លើសពីនេះ បើសិនជា B បាននិយាយថា «ខ្លួនមានអ្នកធានាផ្សេងទៀតដែរ ហេតុនេះ ខ្ញុំមិននាំការលំបាកដល់អ្នកនោះទេ» ហើយករណីដែល Cក្លាយខ្លួនជាអ្នកធានា ប៉ុន្តែ ជាតុពិតគឺគ្មានអ្នកធានាផ្សេងទៀតនោះទេ ក្នុងករណីនេះក៏ដោយ ក៏អ្នកធានាមិនអាចបញ្ឈប់កិច្ចសន្យាជាមួយ A ដែលគ្មានទំនាក់ទំនងអ្វីទាល់តែសោះជាមួយស្ថានភាពនោះទេ។ យ៉ាងណាមិញ កន្លងមកក្រមរដ្ឋប្បវេណីបានទទួលស្គាល់ការបង្កើតកិច្ចសន្យាធានាទោះបីជាគ្មានលិខិតកិច្ចសន្យាក៏ដោយ ប៉ុន្តែ វិសោធនកម្មឆ្នាំ2004 បានកែប្រែបញ្ញត្តិនេះទៅជា កិច្ចសន្យាធានានឹងមិនកើតមានអានុភាពឡើយ បើសិនជាមិនបានធ្វើជាលាយលក្ខ័អក្សរទៅវិញ ដោយសារបានពិចារណាអំពីការការពារដល់អ្នកធានាដែលត្រូវទទួលបន្ទុកតែម្ខាងតាមរយៈកិច្ចសន្យាធានា (មាត្រា446 កថាខណ្ឌ

ទី2។ ដោយឡែក លិខិតជាលាយលក្ខណ៍អក្សរនេះអាចធ្វើជាទម្រង់អេឡិចត្រូនិចក៏បានដែរ។ មាត្រាដដែល កថាខណ្ឌទី3)។ បន្ទាប់មក នៅពេលការកំណត់ពេលសងបានមកដល់ A បានទាមទារឱ្យ C សង។ នៅក្នុងករណីនេះ តើ C អាចនិយាយថា សូមទៅទាមទារពី B ជាមុនសិនទៅបានដែរឬទេ? ចម្លើយគឺ អ្នកធានាធម្មតាអាចនិយាយបែបនេះបាន ប៉ុន្តែ អ្នកធានាដោយសាមគ្គីភាពមិនអាចនិយាយបែបនេះនោះទេ។




③ អ្នកធានាធម្មតា និង អ្នកធានាដោយសាមគ្គីភាព

នៅក្នុងមាត្រា446 កំណត់ថា អ្នកធានាសំដៅទៅលើបុគ្គលដែលទទួលបន្ទុកអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ក្នុងករណីដែលកូនបំណុលចម្បងមិនអនុវត្តកាតព្វកិច្ច (នេះហៅថា **ភាពបំពេញបន្ថែម**នៃកាតព្វកិច្ចធានា)។ ប៉ុន្តែ នេះជាករណីនៃការធានាធម្មតា មានន័យថា អ្នកធានាមានសិទ្ធិតវ៉ាចំនួន 2។ ទីមួយគឺ **ការតវ៉ាឱ្យដាស់តឿន** ដែលជាការតវ៉ាឱ្យម្ចាស់បំណុលទាមទារពីកូនបំណុលចម្បងជាមុន និង ទីពីរគឺ **ការតវ៉ាឱ្យស្រាវជ្រាវ** ដែលជាការតវ៉ាឱ្យម្ចាស់បំណុលអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិដែលកូនបំណុលចម្បងមានជាមុន។ មានន័យថា អ្នកធានាស្ថិតនៅពីក្រោយខ្នងរបស់កូនបំណុលចម្បង ប៉ុន្តែ ប្រសិនបើវាជាទំនាក់ទំនងនៃកូនបំណុលចម្បងជាមួយនឹងអ្នកធានាដោយសាមគ្គីភាពវិញ ក្នុងករណីនេះ សិទ្ធិតវ៉ាទាំងពីរខាងលើនេះនឹងត្រូវបាត់បង់ ហើយទំនាក់ទំនងរបស់អ្នកធានាដោយសាមគ្គីភាពជាមួយម្ចាស់បំណុល គឺដូចគ្នានឹងទំនាក់ទំនងកូនបំណុលដោយសាមគ្គីភាពដែលបានរៀបរាប់ខាងលើនេះ (មាត្រា454, មាត្រា458)។ ពោលគឺ អ្នកធានាដោយសាមគ្គីភាពឈរទន្ទឹមគ្នាជាមួយកូនបំណុលចម្បង ហើយនៅពេលដែលកំណត់ពេលសងមកដល់ ម្ចាស់បំណុលអាចទាមទារប្រាក់ទាំងអស់ពីអ្នកធានាដោយសាមគ្គីភាពតែម្តង ដោយមិនចាំបាច់យកកូនបំណុលចម្បងធ្វើជាភាគីម្ខាងទៀតតាំងពីដំបូងនោះទេ។

សូមប្រុងប្រយ័ត្នត្រង់ចំណុចនេះថា មានអ្នកខ្លះយល់ច្រឡំថាអ្នកធានាដោយសាមគ្គីភាព មានភាពងាយស្រួលជាងអ្នកធានាធម្មតា ដោយសារតែបន្ទុកនៃការធានាត្រូវបែងចែកជាមួយអ្នកផ្សេងច្រើននាក់។ ប៉ុន្តែ វាផ្ទុយស្រឡះពីការពិត។

④ ការធានារួម

យ៉ាងណាមិញ ករណីមានអ្នកធានាច្រើននាក់ ហៅថា ការធានារួម។ ការធានារួមនៅក្នុងការធានាធម្មតា គឺ **មានផលប្រយោជន៍នៃការបែងចែកនូវបន្ទុក** ហើយផលប្រយោជន៍នេះ សំដៅទៅលើការបែងចែកបន្ទុករវាងអ្នកធានាច្រើននាក់ (មាត្រា456។ ពោលគឺ បើមានអ្នកធានា 2រូប ចំពោះកាតព្វកិច្ចចំនួន 760លានរៀល ក្នុងករណីនេះ បន្ទុកម្នាក់ៗគឺ 80លានរៀល)។ ប៉ុន្តែ ករណីធានាដោយសាមគ្គីភាពវិញ បើទោះបីជាមានអ្នកធានាផ្សេងទៀតប៉ុន្មាននាក់ក៏ដោយ ក៏ម្ចាស់បំណុលអាចទាមទារពីអ្នកធានាណាតែម្នាក់ ឱ្យសងប្រាក់មុនគេនូវចំនួនទឹកប្រាក់ទាំងអស់បានដែរ ហើយដូចគ្នានឹងករណីកាតព្វកិច្ចដោយសាមគ្គីភាពដែលបានរៀបរាប់ពីមុន (ទោះបីជាមានអ្នកធានាដោយសាមគ្គីភាព 2នាក់ ចំពោះកាតព្វកិច្ចចំនួន 160លានរៀលក៏ដោយ ក៏អ្នកធានាដោយសាមគ្គីភាពនីមួយៗមានករណីយកិច្ចសងប្រាក់ទាំងអស់ចំនួន 160លានរៀល ដែរ បើសិនជាទទួលបានការទាមទារពីម្ចាស់បំណុល។ សូមចងចាំថា ការធានាដោយសាមគ្គីភាពមិនមែនសំដៅលើការសោមគ្គីរួមគ្នាជាមួយអ្នកធានាដូចគ្នានោះទេ ប៉ុន្តែ វាជាការសាមគ្គីភាពជាមួយនឹងកូនបំណុលចម្បង)។

⑤ ការធានាបំណុលអណ្តែត(ការធានាជាបន្តបន្ទាប់)

ដើមឡើយ ការធានា គឺជាប្រព័ន្ធដែលមានគោលបំណងធានានូវការសងកាតព្វកិច្ចចម្បងជាក់លាក់មួយ។ ប៉ុន្តែ ឧទាហរណ៍ថា ម្ចាស់បំណុល និង កូនបំណុលប្រកបកិច្ចការជំនួញជាមួយគ្នាជាបន្តបន្ទាប់ (សូមគិតថា ជាទំនាក់ទំនងមួយដែលទិញទំនិញជាប្រចាំ ហើយសងប្រាក់នៅរៀងរាល់ចុងខែនីមួយៗ) ហើយចំនួនកាតព្វកិច្ចមានឡើងមានចុះទៅតាមខែនីមួយៗ។ នៅក្នុងករណីបែបនេះ ប្រសិនបើយើងចុះកិច្ចសន្យាធានាកាតព្វកិច្ចគ្រប់ពេលនីមួយៗ គឺ វាគួរឱ្យធុញណាស់។ ដូចនេះ យើងអាចបង្កើតកិច្ចសន្យាធានាក្នុងទំហំមួយដែលកំណត់អំពីកម្រិតនៃចំនួនទឹកប្រាក់ជាក់លាក់ និង អំឡុងពេល (ឧទាហរណ៍ថា រយៈពេល 3ឆ្នាំ ត្រឹមទឹកប្រាក់ខ្ពស់បំផុតចំនួន 1200លានរៀល ជាអាទិ៍) ដើម្បីធានាកាតព្វកិច្ចរបស់កូនបំណុលនោះបាន។ នេះហៅថា ការធានាបំណុលអណ្តែត។ លើសពីនេះ នៅក្នុងន័យទូលាយ គេបានពិចារណាអំពីគោលគំនិតនៃការធានាជាបន្តបន្ទាប់ ដែលជាទម្រង់មួយសម្រាប់ធានានូវកាតព្វកិច្ចបង់ថ្លៃឈ្នួលនៃកិច្ចសន្យាជួលក្នុងអំឡុងពេលជាក់លាក់ បន្ថែមពីការធានាបំណុលអណ្តែតខាងលើនេះ។

ការធានាបំណុលអណ្តែតនេះ ជាការធានាដែលមានប្រសិទ្ធភាពខ្ពស់ និង ងាយស្រួលជាងការធានាដាច់ដោយឡែក ហេតុនេះ នៅក្នុងការអនុវត្តជាក់ស្តែងគេនិយមប្រើប្រាស់ការធានាបែបនេះ។ ប៉ុន្តែ បើយើងមើលពីជ្រុងម្ខាងទៀតវិញ អ្នកធានាបំណុលអណ្តែតនឹងមានបន្ទុកកាន់តែធំតែម្ខាងក្នុងរយៈពេលមួយដ៏វែង។ ដូចនេះ នៅក្នុងវិសោធនកម្មឆ្នាំ2004 គេបានរៀបចំនូវបញ្ញត្តិថ្មីដែលកម្រិតនូវអានុភាពនៃកិច្ចសន្យាធានាបំណុលអណ្តែតចំពោះកម្ចីប្រាក់ជាបុគ្គលឯកជនជាអាទិ៍ ដើម្បីការពារដល់អ្នកធានាបំណុលអណ្តែតឯកជន (មាត្រា465.2 ដល់មាត្រា465.5)។ ហេតុនេះហើយ កិច្ចសន្យាដែលគ្មានកំណត់អំពីកម្រិតអតិបរិមាត្រូវចាត់ទុកថាមោឃភាព ហើយការទទួលខុស

ត្រូវរបស់អ្នកធានាបំណុលអណ្តែត គឺកម្រិតត្រឹមកាលបរិច្ឆេទស្ថាពរនៃប្រាក់ដើម ហើយអំឡុងពេលការធានាខ្ពស់បំផុត គឺ 5ឆ្នាំ បើមានកំណត់ក្នុងកិច្ចសន្យា និងចាត់ទុកថាអំឡុងពេល 3ឆ្នាំ បើគ្មានកំណត់ក្នុងកិច្ចសន្យា។ លើសពីនេះ នៅក្នុងវិសោធនកម្មឆ្នាំ2017 បានពង្រីកទៅដល់គ្រប់ប្រភេទកិច្ចសន្យាធានាបំណុលអណ្តែតទាំងអស់ ដើម្បីការពារដល់អ្នកធានាជាឯកជន ហើយកិច្ចសន្យាធានាជាបុគ្គលឯកជនដែលមិនបានកំណត់កម្រិតអតិបរិមាត្រូវចាត់ទុកថា មោឃភាពទាំងអស់ (វិសោធនកម្ម មាត្រា465.2)។

⑥ ការធានាដោយស្ថាប័ន

ថ្មីៗនេះ មានស្ថាប័នធ្វើអាជីវកម្មធានាដែលត្រូវបានបង្កើតឡើងដោយច្បាប់ពិសេស។ ឧទាហរណ៍ សមាគមផ្តល់ការធានាឥណទាន មាននៅទូទាំងប្រទេស បានទទួលកម្រៃសេវាធានាពីសហគ្រាសធុនតូច និង ធុនមធ្យម ហើយសមាគមនោះនឹងក្លាយជាអ្នកធានា ដើម្បីផ្តល់ជំនួយដល់សហគ្រាសធុនតូច និង ធុនមធ្យម ក្នុងការខ្ចីដើមទុនពីស្ថាប័នហិរញ្ញវត្ថុ។ ប៉ុន្តែ ដើម្បីធានានិរន្តរភាពនៃស្ថាប័នរបស់ខ្លួន សមាគមផ្តល់ការធានាឥណទានតែងតម្រូវឱ្យកូនបំណុលចាត់តាំងអ្នកធានាដោយសាមគ្គីភាពផ្សេងទៀត ឬ ចុះកិច្ចសន្យាដែលផ្តល់ផលប្រយោជន៍ដល់សមាគមក្នុងការទាមទារឱ្យសងវិញនៅដំណាក់កាលចុងក្រោយក្នុងកិច្ចសន្យាផ្តល់ការធានានេះ។

⑦ ការធានារូបវន្តបុគ្គល

កិច្ចសន្យាធានារូបវន្តបុគ្គល ដែលឪពុកម្តាយធានាឱ្យកូនរបស់ខ្លួននៅពេលចូលបម្រើការងារនៅក្នុងក្រុមហ៊ុន ជាអាទិ៍ គឺមានលក្ខណៈខុសគ្នាបន្តិចបន្តួចនឹងការធានានៅទីនេះ។ ការធានានៅទីនេះ សំដៅទៅលើការធានាដោយយកចំនួនកាតព្វកិច្ចរបស់កូនបំណុលចម្បងធ្វើជាកម្មវត្ថុ។ ប៉ុន្តែ កិច្ចសន្យាធានារូបវន្តបុគ្គល សំដៅទៅលើ**កិច្ចសន្យាធានាការខូចខាត**មួយប្រភេទ ដែលធានាដល់ការសងសំណងក្នុងករណីដែលសាមីខ្លួនដែលបានបម្រើការងារនោះបានធ្វើឱ្យខូចខាតដល់ក្រុមហ៊ុន ហើយអ្នកធានាមិនអាចបានដឹងជាមុនអំពីចំនួនសំណងនោះទេ។ ក្នុងករណីបែបនេះហើយ ទើបច្បាប់ពិសេសស្តីពីការធានារូបវន្តបុគ្គល (ឆ្នាំ1933) បានតាក់តែងឡើង ដោយសារព្រួយបារម្ភថាបន្ទុករបស់អ្នកធានានឹងធ្ងន់ហួសហេតុ។ ច្បាប់នេះបានការពារមិនឱ្យអ្នកធានាទទួលបន្ទុកធ្ងន់ហួសហេតុពេកដោយកម្រិតអំពីអំឡុងពេលមានអានុភាពរបស់កិច្ចសន្យា និង ភ្ជាប់ករណីយកិច្ចឱ្យនិយោជកត្រូវជូនដំណឹងទៅអ្នកធានានៅពេលដែលសាមីខ្លួនផ្លាស់ប្តូរប្រភេទនៃការងារ ជាអាទិ៍។

⑧ ការការពារអ្នកធានាដោយបុគ្គលចំពោះកាតព្វកិច្ចអាជីវកម្ម

វិសោធនកម្មច្បាប់ឆ្នាំ2017 បានតាក់តែងថ្មីនូវបញ្ញត្តិដែលការពារដល់អ្នកធានា ចំពោះកិច្ចសន្យាធានាដោយបុគ្គលឯកជនចំពោះកាតព្វកិច្ចទាក់ទងនឹងអាជីវកម្ម ដោយបន្ថឹងនូវលក្ខខណ្ឌទម្រង់ និង ករណីយកិច្ចរបស់កូនបំណុលចម្បង។

ដំបូង វិសោធនកម្មច្បាប់បានកំណត់ថា បើសិនជាបុគ្គលឯកជនធានាអំពីកាតព្វកិច្ចទាក់ទងនឹងអាជីវកម្ម ក្នុងករណីនេះ ការបញ្ជាក់អំពីឆន្ទៈនៃការធានានេះត្រូវធ្វើយ៉ាងតឹងរ៉ឹង ហើយការបង្ហាញឆន្ទៈធានាដែលមិនបានធ្វើដោយលិខិតយថាភូត ត្រូវចាត់ទុកថាមោឃភាព (ច្បាប់វិសោធនកម្ម មាត្រា465.6)។ នេះមានន័យថា ចំពោះកាតព្វកិច្ចអាជីវកម្មដែលមានចំនួនទឹកប្រាក់ច្រើន និង ហានិភ័យខ្ពស់ គឺត្រូវបញ្ជាក់ឆន្ទៈនៅចំពោះមុខរបស់មន្ត្រីសារការី។

ប៉ុន្តែ វាមានករណីលើកលែង។ គេហៅថា ការធានាដោយអ្នកគ្រប់គ្រងពាណិជ្ជកម្ម។ ពោលគឺ ប្រសិនបើកូនបំណុលចំបងគឺជានីតិបុគ្គល ហើយអ្នកធានាគឺជាបុគ្គលឯកជនដែលជា អភិបាល ប្រធាន ឬ នាយកប្រតិបត្តិនៃនីតិបុគ្គលនេះ ជាអាទិ៍ ក្នុងករណីនេះ គេមិនចាំបាច់បញ្ជាក់ឆន្ទៈដោយលិខិតយថាភូតនោះទេ (ច្បាប់វិសោធនកម្ម មាត្រា465.9 ចំណុច1)។ ចំពោះករណីលើកលែងមួយទៀតគឺ អ្នកធានាជាអ្នកសហការអាជីវកម្មជាមួយនឹងកូនបំណុលចម្បងដែលមិនមានជានីតិបុគ្គល ឬ ជា «សហព័ទ្ធរបស់កូនបំណុលចម្បងដែលកំពុងបម្រើការងារ» នៅក្នុងអាជីវកម្មរបស់កូនបំណុលចម្បងនោះ (ច្បាប់វិសោធនកម្ម មាត្រា465.9 ចំណុច3)។ នៅក្នុងចំណោមករណីទាំងពីរខាងលើនេះ ចំពោះការធានាដែលជាសហព័ទ្ធរបស់កូនបំណុល គឺនៅមានបញ្ហាមួយចំនួន។ ចំពោះលក្ខខណ្ឌថា «កំពុងបម្រើការងារ» នេះ ចុះបើសហព័ទ្ធនោះគ្រាន់តែមានឈ្មោះជាបុគ្គលិកប៉ុណ្ណោះ តើករណីបែបនេះត្រូវសម្រេចដូចម្តេច? ជាទូទៅ សហព័ទ្ធមានការលំបាកក្នុងការបដិសេធមិនព្រមក្លាយជាអ្នកធានា ហើយវាអាចមានហានិភ័យដល់ការបែកបាក់គ្រួសារទៀត ហេតុនេះហើយ ខ្ញុំយល់ថា ទោះបីជាដាក់ឱ្យអនុវត្តហើយក៏ដោយ ក៏នៅមានចំណុចដែលត្រូវពិភាក្សាដែរ។

មួយវិញទៀត ច្បាប់វិសោធនកម្មបានកំណត់អំពីករណីយកិច្ចថ្មីដែលកូនបំណុលចម្បង ត្រូវមានករណីយកិច្ចផ្តល់នូវព័ត៌មានអំពីទ្រព្យសម្បត្តិ និង ស្ថានភាពចំណូលចំណាយរបស់ខ្លួនទៅឱ្យអ្នកធានាដែលជាបុគ្គលឯកជន នៅពេលចុះកិច្ចសន្យា ចំពោះការធានាកាតព្វកិច្ចទាក់ទងនឹងអាជីវកម្ម (ច្បាប់វិសោធនកម្ម មាត្រា465.10)។ អ្នកធានាអាចលុបចោលកិច្ចសន្យាធានាបាន បើសិនជាកូនបំណុលមិនបានផ្តល់ព័ត៌មានខាងលើនេះ ឬ បានផ្តល់ព័តមានដែលមិនត្រឹមត្រូវ ដើម្បីឱ្យអ្នកធានាផ្តល់ការយល់ព្រមដោយជឿជាក់ខុស ហើយម្ចាស់បំណុលបានដឹង ឬ អាចដឹងអំពីស្ថានភាពទាំងនេះ (មាត្រាដដែល កថាខណ្ឌទី2)។

<u>⑨ ការធានាដោយវត្ថុ</u>

ដោយឡែក នៅទីនេះខ្ញុំនឹងពន្យល់ជាមុនអំពី **អ្នកធានាដោយវត្ថុ**។ ទោះបីជាគេហៅថា ការធានាក៏ដោយ ក៏វាមានលក្ខណៈខុសគ្នាទាំងស្រុងទៅនឹងការធានាតាមនីតិសិទ្ធិលើបំណុលដែរ។ អ្នកធានាដោយវត្ថុ សំដៅទៅលើ « អ្នកដែលបានផ្តល់វត្ថុធានាសម្រាប់បុគ្គលដទៃ» នៅក្នុងករណីតតិយជនក្រៅពីកូនបំណុលបានដាក់វត្ថុធានាដែលជាកម្មសិទ្ធិរបស់ខ្លួនដើម្បីកូនបំណុល។ ឧបមាថា A ជាម្ចាស់បំណុល និង B ជាកូនបំណុល ហើយ C បានបង្កើតហ៊ីប៉ូតែកលើដីរបស់ខ្លួនឱ្យ A ដើម្បីធានាឱ្យ B ជាអាទិ៍ (ជំពូកទី7 II (1))។ ពោលគឺ អ្នកធានាមានកាតព្វកិច្ចធានានូវ

កាតព្វកិច្ចរបស់កូនបំណុលចម្បង ប៉ុន្តែ អ្នកធានាដោយវត្ថុគ្រាន់តែទទួលខុសត្រូវត្រឹមកម្រិតនៃវត្ថុធានាដែលបានផ្តល់ ហើយមិនមានកាតព្វកិច្ចសងចំពោះម្ចាស់បំណុលទេ (មានន័យថា បើសិនជា B មិនអាចសងបានទេ C គ្រាន់តែបាត់បង់ដី ដោយសារ A អនុវត្តហ៊ីប៉ូតែក ប៉ុន្តែ C មិនមានករណីយកិច្ចសងដោយផ្ទាល់ជាអាទិ៍នោះទេ)។

## 5. **អនុប្បទានសិទ្ធិលើបំណុល**

### (1) **សញ្ញាណទូទៅ**

នៅទីនេះ យើងនឹងលើកអំពីបញ្ហានៃការផ្ទេរសិទ្ធិលើបំណុល។ សិទ្ធិលើបំណុលដែលជាបញ្ហានៅទីនេះ គឺជាសិទ្ធិលើបំណុលធម្មតា ដែលជាសិទ្ធិលើបំណុលនៃប្រាក់កម្ចីចំនួន 40លានរៀល ដែល A មានលើ B (រហូតដល់មានពេលវិសោធនកម្មឆ្នាំ2017 គេបានហៅថា «សិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ»)។ សូមប្រយ័ត្នថា វាខុសគ្នាពី**ឧបករណ៍ដែលអាចជួញដូរបាន** ដែលជាកម្មវត្ថុនៅក្នុងវិស័យច្បាប់ពាណិជ្ជកម្ម (នៅក្នុងវិសោធនកម្មច្បាប់ឆ្នាំ2017 បានរៀបចំនូវបញ្ញត្តិទូទៅស្តីពីឧបករណ៍ដែលអាចជួញដូរបាន នៅចាប់ពីមាត្រា520.2)។ ឧបករណ៍ដែលអាចជួញដូរបាន ដូចជា **រូបិយាណត្តិ ឬ មូលប្បទានប័ត្រ** ជាដើម បានយក សិទ្ធិលើបំណុលដែលជាសិទ្ធិរបស់មនុស្សចំពោះមនុស្សមកសរសេរលើសន្លឹកមូលបត្រ ហើយសិទ្ធិលើបំណុលនោះត្រូវបានផ្ទេរ តាមរយៈការចារនៅខ្នងនៃសន្លឹកប័ណ្ណ និង ការផ្ទេរសន្លឹកប័ណ្ណនេះ។ នេះជាវិធីមួយដែលអាចធ្វើឱ្យសិទ្ធិលើបំណុលមានលំហូរយ៉ាងសកម្ម។ ប៉ុន្តែ សិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនអាចក្លាយជាឧបករណ៍ដែលអាចជួញដូរបានបែបនេះទេ។ ទោះបីជាមានលិខិតបញ្ជាក់សិទ្ធិលើបំណុលក៏ដោយ ក៏លិខិតនេះគ្រាន់តែជាឯកសារបញ្ជាក់អំពីសិទ្ធិលើបំណុល ហើយការផ្ទេរសិទ្ធិត្រូវធ្វើឡើងតាមរយៈការព្រមព្រៀងរបស់ភាគី (អនុប្បទានគឺមានអានុភាព បើទោះបីជាគ្មានការធ្វើលិខិតកិច្ចសន្យាអនុប្បទាន និង ការប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុលក៏ដោយ)។

នៅដើមសម័យកាលនៃច្បាប់រ៉ូម៉ាំង មិនបានទទួលស្គាល់ការធ្វើអនុប្បទានដោយសេរីនោះទេ ដោយសារគិតថា សិទ្ធិលើបំណុលគឺជាច្រវ៉ាក់ច្បាប់ដែលភ្ជាប់បុគ្គលនិងបុគ្គល ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ទោះបីជាប្រទេសណាក៏ដោយ ក៏ទទួលស្គាល់ការធ្វើអនុប្បទានដោយសេរីនៃសិទ្ធិលើបំណុលផងដែរ (មាត្រា466 កថាខណ្ឌទី1)។ ពាក្យថា អាចអនុប្បទានបានដោយសេរី សំដៅទៅលើ ការផ្ទេរដែលម្ចាស់បំណុលអាចព្រមព្រៀងជាមួយបុគ្គលណាផ្សេង ហើយផ្ទេរសិទ្ធិលើបំណុលទៅឱ្យបុគ្គលផ្សេងនោះ ដោយមិនពិចារណាអំពីឆន្ទៈរបស់កូនបំណុលនោះទេ។ ក្នុងករណីនេះ អ្នកធ្វើអនុប្បទានហៅថា អនុប្បាទាយី ហើយអ្នកទទួលអនុប្បទានហៅថា អនុប្បទានិក។ ដូច្នេះ អនុប្បទានសិទ្ធិលើបំណុល សំដៅទៅលើកិច្ចសន្យារវាងអនុប្បទាយី និង អនុប្បទានិកដែលបានផ្ទេរសិទ្ធិលើបំណុលដោយមិនផ្លាស់ប្តូរលក្ខណៈដើម តាមរយៈការលក់ ឬ ប្រទានកម្មសិទ្ធិលើបំណុល។ ដោយឡែក ភាគីអាចព្រមព្រៀងអំពីខសន្យាពិសេសដែលហាមឃាត់មិនឱ្យធ្វើអនុប្បទាន ឬ កម្រិតការធ្វើអនុប្បទានបាន (មាត្រា466 កថាខណ្ឌទី2)។




### (2) អានុភាពនៃការសន្យាពិសេសកម្រិតការធ្វើអនុប្បទាន និង សុពលភាពនៃអនុប្បទានសិទ្ធិលើបំណុល

កន្លងមកនេះ នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់ថា អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានហាមឃាត់មិនឱ្យធ្វើអនុប្បទាន ត្រូវចាត់ទុកថាមោឃភាព ប៉ុន្តែ វិសោធនកម្មច្បាប់ឆ្នាំ2017 បានកែតម្រូវចំណុចនេះយ៉ាងច្រើន។ ក្នុងការអនុវត្តជាក់ស្តែង អនុប្បទានសិទ្ធិលើបំណុល (ឬ ក្នុងនាមជាប្រាតិភោគដោយអនុប្បទាន) ដើម្បីប្រមូលដើមទុន គឺមានច្រើនខ្លាំងណាស់ ហេតុនេះ ដើម្បីកុំឱ្យរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មនេះ ជាគោលការណ៍អនុប្បទានសិទ្ធិលើបំណុលត្រូវកំណត់ថាមានសុពលភាព បើទោះបីជាមានការសន្យាពិសេសកម្រិតការធ្វើអនុប្បទានក៏ដោយ (មាត្រា466 កថាខណ្ឌទី2)។ ប៉ុន្តែ ផ្ទុយមកវិញ ការសន្យាពិសេសអំពីការកម្រិតការធ្វើអនុប្បទានក៏មានសុពលភាពផងដែរ ដើម្បីការពារនូវផលប្រយោជន៍នៃការបង់ប្រាក់ចំពោះភាគីជាក់លាក់របស់កូនបំណុល (កូនបំណុលអាចបដិសេធការអនុវត្តកាតព្វកិច្ច ចំពោះអនុប្បទានិកដែលបានដឹងអំពីអត្ថិភាពនៃការសន្យាពិសេសកម្រិតការធ្វើអនុប្បទាន ឬមិនបានដឹងដោយមានកំហុសធ្ងន់ធ្ងរ ហើយកូនបំណុលនោះនឹងរួចផុតពីការទទួលខុសត្រូវ បើសិនជាបានសងទៅកាន់អនុប្បទាយីដើម។ មាត្រា466 កថាខណ្ឌទី3) ហេតុនេះហើយ បញ្ញត្តិនេះ មានភាពស្មុគស្មាញខ្លាំង។ យើងត្រូវរង់ចាំការវាយតម្លៃពីការអនុវត្តជាក់ស្តែង ដើម្បីអាចដឹងថា នេះជា វិសោធនកម្មដែលល្អ ឬ យ៉ាងណា (ក៏មានមតិលើកឡើងថា ការទទួលអនុប្បទាននូវការសន្យាហាមឃាត់ដែលមានសុពលភាព គឺផ្ទុយនឹងគោលការណ៍ អនុលោមភាពរបស់សហគ្រាស)។ យ៉ាងណាមិញ កូនបំណុលដែលត្រូវបានអនុប្បទានសិទ្ធិលើបំណុលដែលភ្ជាប់ការសន្យាពិសេសអំពីការកម្រិតការធ្វើអនុប្បទាន អាចរួចផុតពីកាតព្វកិច្ច ដោយតម្កល់សិទ្ធិនោះនៅមន្ទីរកិច្ចការច្បាប់ (មាត្រា466.2)។ ហើយសិទ្ធិលើបំណុលដែលបានភ្ជាប់ការសន្យាពិសេសអំពីការកម្រិតការធ្វើអនុប្បទាន ក៏អាចរឹបអូសបានដែរ (មាត្រា466.4។ នេះជាគោលគំនិតដែលមានតាំងពីពេលតាក់តែងក្រមរដ្ឋប្បវេណីសម័យម៉ីជិ)។

### (3) សុពលភាពនៃការអនុប្បទានសិទ្ធិលើបំណុលពេលអនាគត

សូមប្រុងប្រយ័ត្នថា ការធ្វើអនុប្បទានសិទ្ធិលើបំណុលដែលគ្រោងនឹងកើតឡើងពេលអនាគត ក៏មានសុពលភាពដែរ (សិទ្ធិលើបំណុលជាថ្លៃឈ្នួលសម្រាប់ឆ្នាំក្រោយនៃសាខាហាងជួល ឬ សិទ្ធិលើបំណុលនៃថ្លៃលក់ទំនិញដែលអ្នកទិញបច្ចុប្បន្ន នឹងទិញក្នុងពេល3ឆ្នាំក្រោយ ជាអាទិ៍)។ នេះជាចំណុចដែលយុត្តិសាស្ត្របានទទួលស្គាល់រួចហើយ (ការធ្វើអនុប្បទានសិទ្ធិលើបំណុលនាពេលប៉ុន្មានឆ្នាំក្រោយក៏មានសុពលភាព ហើយលទ្ធភាពដែលអាចកើតមានឡើងតិចក៏ដោយ ឬ ច្រើនក៏ដោយ គឺមិនប៉ះពាល់ដល់សុពលភាពនោះទេ។ ក្នុងករណីដែលមិនកើតមានឡើងទេ ភាគីត្រូវដោះស្រាយរវាងគ្នាតាមរយៈការមិនអនុវត្តកាតព្វកិច្ចជាអាទិ៍) ហើយនៅក្នុងវិសោធនកម្មច្បាប់ឆ្នាំ2017 គេបានកំណត់ជាបញ្ញត្តិច្បាស់លាស់ (មាត្រា466.6)។

### (4) លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុល

ក្រមរដ្ឋប្បវេណីប្រទេសជប៉ុនបានប្រើប្រាស់គោលការណ៍នៃលក្ខខណ្ឌតតាំង ចំពោះការធ្វើអនុប្បទានសិទ្ធិលើបំណុលនេះ ដូចគ្នានឹងការផ្ទេរសិទ្ធិប្រត្យក្សដែរ (⇒ជំពូកទី3 II.2(2))។ នេះក៏ជាបញ្ញត្តិនៃប្រព័ន្ធក្រមរដ្ឋប្បវេណីរបស់បារាំងដែរ។ នេះមានន័យថា សិទ្ធិលើបំណុលត្រូវបានផ្ទេរ ដោយគ្រាន់តែមានការព្រមព្រៀងរវាងអនុប្បទានិក និង អនុប្បទាយីប៉ុណ្ណោះ ប៉ុន្តែ អនុប្បទានិក និង អនុប្បទាយីត្រូវធ្វើនីតិវិធីបំពេញលក្ខខណ្ឌតតាំង ដើម្បីអាចអះអាងអំពីការអនុប្បទាននោះ ចំពោះកូនបំណុល និងតតិយជនបាន។ លក្ខខណ្ឌតតាំងនៃករណីអចលនវត្ថុ គឺការចុះបញ្ជី ប៉ុន្តែ លក្ខខណ្ឌតតាំងនៃករណីសិទ្ធិលើបំណុល គឺការជូនដំណឹងទៅកូនបំណុលដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាពរ ឬ ការយល់ព្រមរបស់កូនបំណុលដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាពរ (មាត្រា467 កថាខណ្ឌទី2)។ ប៉ុន្តែ នៅក្នុងទំនាក់ទំនងចំពោះកូនបំណុលវិញ គឺមានភាពងាយស្រួលជាង ត្រង់ថាការជូនដំណឹង ឬ ការយល់ព្រម អាចធ្វើតាមវិធីធម្មតា ដោយមិនចាំបាច់ប្រើប្រាស់លិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាពរនោះទេ (មាត្រា467 កថាខណ្ឌទី1)។ មូលហេតុដែលគេដាក់លក្ខខណ្ឌតតាំងដោយផ្តោតសំខាន់លើកូនបំណុលដែលជាការជូនដំណឹងទៅកូនបំណុល ឬ ការយល់ព្រមពីកូនបំណុលនេះ គឺដោយសារតែ សិទ្ធិលើបំណុលខុសពីសិទ្ធិប្រត្យក្ស ហើយសិទ្ធិនេះត្រូវសម្រេចដោយការអនុវត្តរបស់កូនបំណុល ហេតុនេះហើយ កូនបំណុលចាំបាច់ត្រូវតែដឹងថាខ្លួនត្រូវសងទៅកាន់អ្នកណា។ អ្នកតាក់តែងច្បាប់យល់ឃើញថា បើសិនជាកូនបំណុលបានដឹងជាមុន ក្នុងករណីនេះ តតិយជនដែលចង់បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុលអាចសួរអំពីស្ថានភាពពីកូនបំណុលបាន ពោលគឺ មុខងារបង្ហាញជាសាធារណៈត្រូវបានប្រើប្រាស់ ទោះបីជាមិនបានពេញលេញក៏ដោយ តាមរយៈកូនបំណុលដើរតួនាទីជាមជ្ឈមណ្ឌលព័ត៌មានកណ្តាល។ លិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាពរ សំដៅទៅលើលិខិតដែលអាចបញ្ជាក់បានថា ត្រូវបានធ្វើឡើងនៅពេលណា ដែលជាលិខិតយថាភូតដែលធ្វើឡើងដោយសារការី ឬ លិខិតបញ្ជាក់ដែលបានបោះត្រាកាលបរិច្ឆេទដោយមន្ត្រី ឬ ស្ថាប័នរដ្ឋ ជាអាទិ៍ (ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា5)។

### (5) កាលបរិច្ឆេទស្តាពរ និង អនុប្បទានជាន់គ្នា

មូលហេតុដែលចាំបាច់ឱ្យមានកាលបរិច្ឆេទស្តាពរ គឺដោយសារតែការជូនដំណឹង ឬ ការយល់ព្រមដែលជាលក្ខខណ្ឌតតាំងនេះ អាចមានអត្ថិភាពច្រើន ហើយខុសពីការចុះបញ្ជីនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សដែលមានតែមួយ។ ហេតុនេះ យើងត្រូវការទម្រង់លិខិតដែលអាចជាភស្តុតាងច្បាស់លាស់ ថាបានចេញមុន ឬ ក្រោយ ដើម្បីសម្រេចថាអ្នកណាបានបំពេញលក្ខខណ្ឌតតាំងបានលឿនជាងគេបំផុត។ លើសពីនេះ បើសិនជាសិទ្ធិលើបំណុលត្រូវបានធ្វើអនុប្បទានជាន់គ្នា ក្នុងករណីនេះ អនុប្បទានិកដែលបានបំពេញលក្ខខណ្ឌតតាំងមុនគេ នឹងក្លាយជាម្ចាស់សិទ្ធិ ប៉ុន្តែមិនមែនអនុប្បទានិកដែលបានធ្វើកិច្ចសន្យាអនុប្បទានមុនគេនោះទេ (សូមកុំច្រឡំ ហើយចងចាំចំណុចនេះទុក)។ នៅប្រទេសជប៉ុន វិធីទទួលកាលបរិច្ឆេទស្តាពរដែលស្រួលធ្វើជាងគេ គឺការផ្ញើសំបុត្រប្រៃសណីយ៍ដែលមានបញ្ជាក់ខ្លឹមសារនៅតាមការិយាល័យប្រៃសណីយ៍ (⇒ពាក្យគន្លឹះ: កាលបរិច្ឆេទស្តាពរ និង សំបុត្រប្រៃសណីយ៍ដែលបញ្ជាក់ខ្លឹមសារ)។

> ពាក្យគន្លឹះ: **កាលបរិច្ឆេទស្តាពរ និង សំបុត្រប្រៃសណីយ៍ដែលបញ្ជាក់ខ្លឹមសារ**
>
> នៅពេលផ្ញើសំបុត្រប្រៃសណីយ៍ដែលបញ្ជាក់ខ្លឹមសារ អ្នកផ្ញើត្រូវរៀបចំសំបុត្រជា 3ច្បាប់ (ច្បាប់ដើម 1 និង ច្បាប់ចម្លង 2) និង កាន់ស្រោមសំបុត្រទៅកាន់កន្លែងទទួលនៅតាមការិយាល័យប្រៃសណីយ៍។ មន្ត្រីទទួលពាក្យនឹងបោះត្រាបញ្ជាក់កាលបរិច្ឆេទទទួលសំបុត្រផ្ញើ ហើយផ្ញើចេញមួយច្បាប់ ហើយរក្សាទុកមួយច្បាប់នៅក្នុងការិយាល័យ និង ប្រគល់ជូនអ្នកផ្ញើមួយច្បាប់វិញ។

វិធីនេះគឺងាយស្រួល ប៉ុន្តែ វាមានបញ្ហាធំមួយ។ ការបញ្ជាក់កាលបរិច្ឆេទទទួលសំបុត្រផ្ញើ គឺជាកាលបរិច្ឆេទនៃចំណុចពេលដែលការិយាល័យនឹងផ្ញើចេញ ហើយចំណុចពេលនោះនឹងក្លាយជាចំណុចសំខាន់នៃលក្ខខណ្ឌតតាំង ប៉ុន្តែ កូនបំណុលមិនទាន់បានដឹងនៅឡើយទេ។ ហេតុនេះហើយ នៅប្រទេសជប៉ុនគឺមានទ្រឹស្តីនៃពេលទៅដល់ដែលលើកឡើងថា មូលដ្ឋានដែលយកមកកំណត់អំពីអាទិភាពនៃលក្ខខណ្ឌតតាំងក្នុងករណីអនុប្បទានជាន់គ្នា គួរតែសម្រេចតាមការជូនដំណឹងដែលបានទៅដល់កូនបំណុលមុនវិញ ចំពោះករណីជូនដំណឹងដែលមានកាលបរិច្ឆេទស្តាពរ។ សូមអ្នកទាំងអស់គ្នាសិក្សាឱ្យបានលម្អិតអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុលនេះ ដោយសារតែយុត្តិសាស្ត្រ និង ទ្រឹស្តីជាច្រើនបានបកស្រាយលើបញ្ហានេះ ក្នុងពេលថ្មីៗនេះ។ ការអនុវត្តជាក់ស្តែងក៏ចាប់ផ្តើមមានការលក់ ឬ ដាក់ប្រាតិភោគសិទ្ធិលើបំណុលដើម្បីជាវិធីប្រមូលទុនកាន់តែច្រើនផងដែរ។

### (6) ការចុះបញ្ជីអនុប្បទានសិទ្ធិលើបំណុល

ដូចបានរៀបរាប់ខាងលើនេះ នៅពេលដែលម្ចាស់បំណុលយកសិទ្ធិលើបំណុលទៅលក់ដើម្បីប្រមូលទុន (**ចរន្តកម្មសិទ្ធិលើបំណុល**) ឬ ដាក់ប្រាតិភោគដោយអនុប្បទានដើម្បីយកកម្ចី (ប្រាតិភោគដោយអនុប្បទានសិទ្ធិលើបំណុល) ជាអាទិ៍ នោះការជូនដំណឹងទៅកូនបំណុលម្នាក់ៗទាំងអស់គ្រប់ពេល គឺស្មុគស្មាញខ្លាំង ហើយ

ចំណាយសោហ៊ុយច្រើន។ ដូចនេះ ច្បាប់ពិសេសស្តីពី អនុប្បទានសិទ្ធិលើបំណុល បានអនុម័តឡើងនៅឆ្នាំ1998។ ច្បាប់នេះ បានបង្កើតអំពីប្រព័ន្ធដែលចុះបញ្ជីអេឡិចត្រូនិចអំពីព័ត៌មាននៃអនុប្បទានជាច្រើន ដែលធ្លាប់បានកត់ត្រាជាឯកសារ ហើយចាត់ទុកថា ជាការជូនដំណឹងដោយផ្អែកលើលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាកនៅក្នុងកថាខណ្ឌទី2 មាត្រា467 នៃក្រមរដ្ឋប្បវេណី (ប៉ុន្តែ នេះជាការចុះបញ្ជីដែលកូនបំណុលមិនបានដឹង ហេតុនេះ អនុប្បទានិកអាចប្រើប្រាស់ការចុះបញ្ជី ដើម្បីបំពេញលក្ខខណ្ឌតតាំងចំពោះតតិយជនបាន។ យ៉ាងណាមិញ អនុប្បទានិកត្រូវជូនដំណឹងដោយភ្ជាប់នូវលិខិតបញ្ជាក់អំពីចំណុចចុះបញ្ជីដោយឡែកទៅកូនបំណុល ដើម្បីអនុវត្តសិទ្ធិចំពោះកូនបំណុល)។ វាជាការចុះបញ្ជីអេឡិចត្រូនិចដំបូងបង្អស់នៅប្រទេសជប៉ុន ហើយបច្ចុប្បន្ននេះ មានការអនុវត្តជាក់ស្តែងច្រើនខ្លាំងណាស់ (ដោយឡែកច្បាប់នេះត្រូវបានវិសោធនកម្មបន្ថែមនៅឆ្នាំ2004 ហើយប្តូរទៅជាច្បាប់ពិសេសស្តីពីការអនុប្បទានសិទ្ធិលើបំណុលចលនវត្ថុ។ ⇒ជំពូកទី7 II.3(2))។

### (7) **អនុប្បទានសិទ្ធិលើបំណុល និង ការតវ៉ារបស់កូនបំណុល**

កូនបំណុលដែលត្រូវបានធ្វើអនុប្បទានសិទ្ធិលើបំណុល អាចអះអាងចំពោះម្ចាស់បំណុលថ្មី នូវការតវ៉ា (ការដែលបានសងមួយផ្នែក ឬ ការទូទាត់នៃសិទ្ធិលើបំណុលផ្ទុយ (⇒ជំពូកនេះ 6(5)) ដែលខ្លួនមានទាំងអស់លើម្ចាស់បំណុលចាស់ (អនុប្បទាយី) រហូតដល់ពេលលក្ខខណ្ឌតតាំងនៃអនុប្បទានត្រូវបានបំពេញ (មាត្រា468 កថាខណ្ឌទី1។ «លក្ខខណ្ឌតតាំង» នៅទីនេះ សំដៅលើ ការជូនដំណឹង ឬ យល់ព្រមដែលកំណត់ក្នុងមាត្រា467 កថាខណ្ឌទី1 (លក្ខខណ្ឌអនុវត្តសិទ្ធិចំពោះកូនបំណុល))។ បញ្ញត្តិនេះគឺត្រូវតែមាន ដោយសារតែកូនបំណុលត្រូវបានគេធ្វើកិច្ចសន្យាអនុប្បទានទាំងខ្លួនមិនបានចូលរួម ហេតុនេះ ការដាក់ឱ្យកូនបំណុលស្ថិតនៅក្នុងស្ថានភាពដែលបាត់បង់ផលប្រយោជន៍ជាងមុនពេលអនុប្បទាន គឺមិនសមហេតុផលទេ។

ដោយឡែក នៅមុនពេលវិសោធនកម្មច្បាប់ឆ្នាំ2017 នៅចំណុចនេះ មានបញ្ញត្តិមួយដែលកំណត់ថា កូនបំណុលមិនអាចអះអាងចំពោះអនុប្បទានិក នូវការតវ៉ាដែលបានអះអាងចំពោះអនុប្បទាយីកន្លងមកនោះទេ ប្រសិនបើខ្លួនបានផ្តល់ការយល់ព្រមដោយគ្មានការតវ៉ា។ ប៉ុន្តែ បញ្ញត្តិនេះត្រូវបានលុបចោលហើយ (ចាប់ពីក្រោយពេលវិសោធនកម្មទៅ អានុភាពដូចខាងលើនេះ អាចកើតមានបាន លុះត្រាតែកូនបំណុលបានបង្ហាញឆន្ទៈបោះបង់ចោលនូវការតវ៉ាទាំងអស់ប៉ុណ្ណោះ)។

### (8) **សិទ្ធិលើបំណុលដែលចុះបញ្ជីអេឡិចត្រូនិច**

តាំងពីដើមមក សិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះតាមក្រមរដ្ឋប្បវេណីនេះអាចធ្វើអនុប្បទានបាន ប៉ុន្តែយើងមិនដែលនឹកស្មានថា វាត្រូវបានធ្វើចរន្តកម្មយ៉ាងសកម្មបែបនេះនោះទេ។ ដើមឡើយ គេប្រើប្រាស់នូវ រូបិយាណត្តិ ដើម្បីឱ្យការផ្ទេរពីបុគ្គលមួយទៅបុគ្គលមួយមានភាពងាយស្រួល និង រលូន។ វាជាសិទ្ធិលើបំណុលដែលមានសរសេរនៅលើក្រដាស (មានរូបរាង្គ) ហើយសិទ្ធិលើបំណុលត្រូវធ្វើអនុប្បទាន (គេហៅថាខ្នងលិខិត ហើយ

ការផ្ទេរអាចធ្វើបានតាមរយៈការចុះហត្ថលេខាលើខ្នងលិខិតនោះ) តាមរយៈការផ្ទេរក្រដាសនោះ (សូមពិនិត្យមើលលំអិតនៅក្នុងច្បាប់ស្តីពី រូបិយាណត្តិ)។ នៅប្រទេសជប៉ុន គេនិយមប្រើប្រាស់ប្រព័ន្ធរូបិយាណត្តិនេះខ្លាំងណាស់ ប៉ុន្តែ នៅពេលសម័យកុំព្យូទ័រចូលមកដល់ គេបានយល់ឃើញថា ការចេញ ការថែរក្សា និង ការដោះដូររូបិយាណត្តិនេះ ក្លាយទៅជាបន្ទុកទៅវិញ (លើសពីនេះ រូបិយាណត្តិនេះត្រូវបង់ពន្ធតែមប្រិយ៍)។ ការប្រើប្រាស់រូបិយាណត្តិធ្លាក់មកត្រឹម 10% នៅក្នុងអំឡុងពេល 20ឆ្នាំនេះ ដោយគិតចាប់ពីឆ្នាំ1990។ ដោយឡែក សិទ្ធិលើបំណុលធម្មតាវិញ មិនចាំបាច់ប្រគល់ក្រដាសទេ ហើយក៏មិនត្រូវបង់ពន្ធនោះទេ ប៉ុន្តែវាមានហានិភ័យអនុប្បទានជាន់គ្នា និងមានផលវិបាកត្រង់ថា អត្ថិភាពនៃសិទ្ធិលើបំណុលនេះមិនច្បាស់លាស់ ហើយមិនមានការធានាថាកូនបំណុលនឹងសងនោះទេ។ ដោយសារមានស្ថានភាពបែបនេះហើយ នៅក្នុងឆ្នាំ2007 គេបានបង្កើតនូវសិទ្ធិលើបំណុលដែលចុះបញ្ជីអេឡិចត្រូនិច ដែលបង្កើត និង ផ្ទេរតាមរយៈការចុះបញ្ជីនៅក្នុងកុំព្យូទ័រ ដើម្បីលុបបំបាត់នូវចំណុចខ្វះខាតនានារបស់សិទ្ធិលើបំណុល និង រូបិយាណត្តិ (**ច្បាប់ស្តីពីសិទ្ធិលើបំណុលដែលចុះបញ្ជីអេឡិចត្រូនិច**)។ នៅចុងឆ្នាំ2009 ស្ថាប័នចុះបញ្ជីសិទ្ធិលើបំណុលអេឡិចត្រូនិចដែលជាសហគ្រាសរបស់ឯកជន បានចាប់ផ្តើមដំណើរការ ហើយប្រតិបត្តិការជាក់ស្តែងបានចាប់បង្កើតឡើង។ នៅពេលអនាគត យើងសង្ឃឹមថានឹងអាចរកវិធីសាស្ត្រដែលអាចប្រើប្រាស់ជំនួសឱ្យរូបិយាណត្តិ និង វិធីសាស្ត្រដាក់ប្រាតិភោគជំនួសឱ្យសិទ្ធិលើបំណុលបាន។

### (9) ការទទួលកាតព្វកិច្ច និង អនុប្បទានកិច្ចសន្យា (ផ្ទេរឋានៈក្នុងកិច្ចសន្យា)

ការផ្ទេរកាតព្វកិច្ច (ការទទួលកាតព្វកិច្ច) ក៏ត្រូវបានយុត្តិសាស្ត្រ និង ទ្រឹស្តីនានាទទួលស្គាល់ ហើយនៅក្នុងវិសោធនកម្មឆ្នាំ2007 បានយកខ្លឹមសារទាំងនោះធ្វើជាបញ្ញត្តិច្បាប់តែម្តង។ ការទទួលកាតព្វកិច្ចនេះរួមមាន ការទទួលកាតព្វកិច្ចដែលធ្វើឱ្យកូនបំណុលដើមរួចខ្លួន (ពោលគឺ កូនបំណុលមុនរួចខ្លួន ហើយជំនួសដោយកូនបំណុលថ្មី។ មាត្រា472 ដល់ មាត្រា472.4) និង ការទទួលកាតព្វកិច្ចដំណាលគ្នា (ពោលគឺ កូនបំណុលមុននៅដដែលហើយបន្ថែមកូនបំណុលថ្មី។ មាត្រា470 និង មាត្រា471)។ ប៉ុន្តែ កិច្ចសន្យានេះមិនអាចបង្កើតឡើងតាមទំនើងចិត្តរបស់កូនបំណុល និង អ្នកទទួលនោះទេ។ សិទ្ធិលើបំណុលមិនអាចសម្រេចបាននោះទេ បើសិនជាកូនបំណុលគ្មានសមត្ថភាពសង ហេតុនេះ ការផ្លាស់ប្តូរកូនបំណុល គឺជាបញ្ហាសំខាន់ខ្លាំងណាស់ដែលអាចផ្លាស់ប្តូរលទ្ធភាពនៃការសម្រេចសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល។ ដូចនេះ កិច្ចសន្យាទទួលកាតព្វកិច្ច ត្រូវធ្វើឡើងដោយបុគ្គលបីនាក់ដែលជា កូនបំណុល ម្ចាស់បំណុល និង អ្នកទទួល ឬ ធ្វើឡើងដោយកូនបំណុល និង អ្នកទទួល ហើយត្រូវមានការឯកភាពពីម្ចាស់បំណុល (យល់ព្រម)។

ម្យ៉ាងទៀត ក្រៅពីការផ្ទេរតែសិទ្ធិលើបំណុល ឬ ផ្ទេរតែកាតព្វកិច្ច ការផ្ទេរសិទ្ធិលើបំណុល និង កាតព្វកិច្ចជាសកលដែលកើតចេញពីកិច្ចសន្យា ទៅឱ្យតតិយជនក៏បានដែរពោលគឺ ឋានៈក្នុងកិច្ចសន្យា (នៅក្នុងច្បាប់វិសោធនកម្មឆ្នាំ2017 បានបង្កើតថ្មីនូវ មាត្រា539.2)។ នេះហៅថា អនុប្បទានកិច្ចសន្យា ឬ ការផ្ទេរឋានៈក្នុងកិច្ចសន្យា។ អនុប្បទាននៃកិច្ចសន្យានេះ រួមមានទាំងការទទួលកាតព្វកិច្ចផងដែរ ហេតុនេះហើយ បើសិនជាកិច្ចសន្យានោះធ្វើ

ឡើងដោយអនុប្បទានិក និង អនុប្បទាយី ក្នុងករណីនេះ ត្រូវមានការឯកភាពពីភាគីម្ខាងទៀត (យល់ព្រម) ផងដែរ។ សូមចងចាំថា អនុប្បទាននៃកិច្ចសន្យា ត្រូវក្តោបទាំងអនុប្បទានសិទ្ធិលើបំណុល និង ការទទួលកាតព្វកិច្ច ព្រមទាំងការផ្ទេរនូវសិទ្ធិលុបចោល និង សិទ្ធិរំលាយដែលភាគីនៃកិច្ចសន្យាមានផងដែរ។

## 6. ការរលត់សិទ្ធិលើបំណុល

### (1) សញ្ញាណទូទៅ

ចំណុចចុងក្រោយនៃនីតិសិទ្ធិលើបំណុលទូទៅ គឺបញ្ញត្តិអំពីមូលហេតុនៃការរំលត់សិទ្ធិលើបំណុល ដូចជា ការសង ជាអាទិ៍។ សិទ្ធិលើបំណុលត្រូវរលត់ដោយសារគោលបំណងនៃសិទ្ធិលើបំណុលនោះបានសម្រេច តាមរយៈការទទួលការសងតាមខ្លឹមសារនៃកិច្ចសន្យាពីកូនបំណុល។ ហើយមូលហេតុផ្សេងទៀតនៃការរលត់សិទ្ធិលើបំណុល រួមមាន ការសងដោយវត្ថុជំនួសដែលភាគីបានចុះកិច្ចសន្យារំលត់សិទ្ធិលើបំណុលដោយការយកវត្ថុមកជំនួស ឬ ការតម្កល់ឱ្យរំលត់សិទ្ធិលើបំណុល តាមវិធីស្នើសុំឱ្យកន្លែងតម្កល់នៃមន្ទីរកិច្ចការច្បាប់រក្សាទុក នៅពេលដែលម្ចាស់បំណុលមិនព្រមទទួល ឬ នៅពេលដែលមិនដឹងថា អ្នកណាជាម្ចាស់បំណុល, ឬ ការទូទាត់ដែលរំលត់នូវសិទ្ធិលើបំណុលក្នុងចំនួនស្មើគ្នារវាងសិទ្ធិលើបំណុលរបស់ខ្លួន និង សិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតដែលមានចំពោះខ្លួន, ឬ តាមវិធីផ្សេងទៀត។ នៅក្នុងចំណោមវិធីរំលត់ទាំងនេះ សូមចងចាំថា ការទូទាត់មានមុខងារជានាកាតព្វកិច្ច (មានន័យថា នៅពេលដែលភាគីម្ខាងទៀតមិនព្រមសងទេ យើងអាចប្រមូលបំណុលដោយទូទាត់ជាមួយសិទ្ធិលើបំណុលរបស់យើង) និង ការទូទាត់នេះជាមធ្យោបាយប្រមូលបំណុលងាយស្រួលជាងគេបំផុត នៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម។

### (2) ការសង

#### ① សំណើផ្តល់ការសង

បើសិនជាបានសងជាក់ស្តែងដោយគោរពតាមគោលបំណងដើមនៃកាតព្វកិច្ច នោះកាតព្វកិច្ចនឹងរលត់។ ប៉ុន្តែ ឧបមាថា ភាគីម្ខាងទៀតមិនព្រមទទួលដោយគ្មានហេតុផល ឬ មិនអាចសងបានដោយសារភាគីម្ខាងទៀតមិននៅផ្ទះ ក្នុងករណីនេះ កូនបំណុលអាចរួចផុតពីការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ច ដោយធ្វើសំណើផ្តល់ការសងបាន។ សំណើរផ្តល់ការសងរួមមាន «**ការស្នើជាក់ស្តែង**» ពោលគឺ កូនបំណុលយកវត្ថុទៅដល់កន្លែងត្រូវអនុវត្ត (មាត្រា493 វាក្យខណ្ឌទី1) និង «**ការស្នើផ្ទាល់មាត់**» ពោលគឺ ក្នុងករណីដែលម្ចាស់បំណុលបានបដិសេធក្នុងការទទួលជាមុន ជាអាទិ៍ កូនបំណុលត្រូវបញ្ចប់ការរៀបចំសង ហើយដាស់តឿនឱ្យម្ចាស់បំណុលមកទទួលការសង (មាត្រា493 វាក្យខណ្ឌទី2)។ ចំពោះការអនុវត្តដែលម្ចាស់បំណុលត្រូវធ្វើសកម្មភាពណាមួយសម្រាប់ការអនុវត្ត (ករណីដែលម្ចាស់បំណុលបានសន្យាថានឹងមកយកដោយផ្ទាល់ ឬ ម្ចាស់បំណុលបានសន្យាថានឹងប្រាប់អំពីទីតាំងដើម្បីអនុវត្ត ជាអាទិ៍) ក៏អាចស្នើផ្ទាល់មាត់បានដែរ (មាត្រាដដែល វាក្យខណ្ឌទី3)។

### ② ការសងដោយតតិយជន

ការសងអាចធ្វើតាមរយៈតតិយជនក្រៅពីកូនបំណុលក៏បានដែរ (មាត្រា474)។ ការសងដោយតតិយជននេះ អាចជាការសងជំនួសដោយចេញពីទឹកចិត្តសប្បុរសក៏មាន ឬ ការសងជំនួសដើម្បីមិនឱ្យខាតបង់ប្រយោជន៍របស់ខ្លួនឯងក៏មាន (ឧបមាថា កូនបំណុល B មិនអាចសងបំណុលចំពោះម្ចាស់បំណុល A ហើយធ្វើឱ្យ អ្នកធានាដោយវត្ថុ C ព្រួយបារម្ភអំពីការដាក់លក់ដោយបង្ខំនូវវត្ថុហ៊ីប៉ូតែកដែលខ្លួនបានដាក់សម្រាប់ធានាបំណុល។ ហេតុនេះ C បានសងទៅ A ជំនួសឱ្យ B ដោយសារតែខ្លួនមិនចង់របូតវត្ថុដែលដាក់ហ៊ីប៉ូតែកនោះពីក្នុងដៃ)។ ប៉ុន្តែ កាតព្វកិច្ចមួយចំនួនមិនអនុញ្ញាតឱ្យសងដោយអ្នកដទៃនោះទេ ដោយសារតែសារជាតុនៃកាតព្វកិច្ចនោះ ដូចជា កាតព្វកិច្ចប្រគុំភ្លេងរបស់តន្ត្រីករ ជាអាទិ៍ (មាត្រាដដែល កថាខណ្ឌទី4)។ ហើយការសងដោយទឹកចិត្តសប្បុរសរបស់តតិយជនដែលគ្មានទំនាក់ទំនងផលប្រយោជន៍ មិនអាចធ្វើឡើងដោយផ្ទុយនឹងឆន្ទៈរបស់កូនបំណុលឡើយ (លើកលែងតែករណីម្ចាស់បំណុលមិនបានដឹងអំពីភាពផ្ទុយនឹងឆន្ទៈរបស់កូនបំណុល។ មាត្រា474 កថាខណ្ឌទី2)។

### ③ ការកាត់បំណុលដោយការសង

ក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចច្រើនដែលមានប្រភេទដូចគ្នា (ឧទាហរណ៍ថា មានកាតព្វកិច្ចជាប្រាក់មួយចំនួន 200លានរៀល និងកាតព្វកិច្ចជាប្រាក់មួយទៀតចំនួន 240លានរៀល) ចំពោះម្ចាស់បំណុលតែម្នាក់ ហើយបើសិនជាការសងមិនទាន់គ្រប់គ្រាន់សម្រាប់រំលត់កាតព្វកិច្ចទាំងអស់នៅឡើយទេ (ឧទាហរណ៍ថា សងបានតែចំនួន 160លានរៀល) អ្នកសងអាចសម្រេចយកកាតព្វកិច្ចណាដែលត្រូវយកមកកាត់មុនបាន (មាត្រា488 កថាខណ្ឌទី1)។ ប្រសិនបើអ្នកសងមិនបានសម្រេចយកកាតព្វកិច្ចណាទេ អ្នកដែលទទួលការសងអាចសម្រេចបាន (មាត្រាដដែល កថាខណ្ឌទី2) ប៉ុន្តែ បើសិនជាអ្នកទាំងពីរខាងលើនេះមិនបានសម្រេចទេ ការកាត់កាតព្វកិច្ចត្រូវធ្វើឡើងតាមលំដាប់ដែលមានកំណត់នៅក្នុងមាត្រា488 កថាខណ្ឌទី4 (ហៅថា **ការកាត់កាតព្វកិច្ចតាមច្បាប់កំណត់**)។

### ④ ឧបាទេសកម្មដោយការសង

បើសិនជាតតិយជនបានសងជំនួសកូនបំណុល តតិយជននោះអាចទាមទារសំណងចំពោះកូនបំណុលបាន លើកលែងតែករណីដែលមានឆន្ទៈប្រទានកម្ម។ ប៉ុន្តែ ខ្ញុំយល់ថាអំណាចបង្ខំឱ្យសងជាក់ស្តែងនឹងទន់ខ្សោយណាស់ បើសិនជាតតិយជននោះអាចអនុវត្តសិទ្ធិទាមទារសំណង ដោយគ្រាន់តែនិយាយថា «សងខ្ញុំមក»។ ហេតុនេះហើយ ប្រព័ន្ធដែលមានមុខងារធានានូវការសម្រេចសិទ្ធិទាមទារសំណងនៅក្នុងរឿងក្តីបែបនេះ គឺជា ឧបាទេសកម្មដោយការសង (ចាប់ពីមាត្រា499)។ ឧបាទេសកម្មមានន័យថាជំនួសឋានៈ ហើយវាខុសពីការតំណាង។ កន្លែងនេះមានន័យថា តតិយជនដែលបានសងទទួលឋានៈពីម្ចាស់បំណុល ហើយអាចអនុវត្តនូវសិទ្ធិរបស់ម្ចាស់បំណុលដែលបានរលត់នៅក្នុងទំនាក់ទំនងជាមួយកូនបំណុលបាន។ ហេតុដូច្នេះហើយ ឧបមាថា កូនបំណុល B បានបង្កើតហ៊ីប៉ូតែក ឬ មានអ្នកធានាចំពោះម្ចាស់បំណុល A ក្នុងករណីនេះ តតិយជន C ដែលបានសងដោយជំនួស អាចធ្វើឧបាទេស

កម្មជំនួស A ក្នុងទំហំនៃសិទ្ធិទាមទារសំណង ហើយអាចអនុវត្តហ៊ីប៉ូតែក ឬ ទាមទារឱ្យអ្នកធានាសង ដើម្បីសម្រេចការទាមទារសំណងបាន។ ឧបាទេសកម្មដោយការសងរួមមាន **ឧបាទេសកម្មដោយស្ម័គ្រចិត្ត** និង **ឧបាទេសកម្មដោយច្បាប់កំណត់**។ ដូចនៅក្នុងឧទាហរណ៍អំពីអ្នកធានាដោយវត្ថុដែលបានលើកឡើងខាងលើនេះ ប្រសិនបើអ្នកដែលមានទំនាក់ទំនងផលប្រយោជន៍បានសង (បើមិនសងនោះទេ ខ្លួននឹងអាចបាត់បង់ផលប្រយោជន៍) ក្នុងករណីនេះ អ្នកធានាដោយវត្ថុនោះអាចធ្វើឧបាទេសកម្មដោយការសងដោយស្វ័យប្រវត្តិបាន (មានន័យថា គ្មាននីតិវិធីណាមួយដែលត្រូវបំពេញទេ) ក្នុងនាមជាឧបាទេសកម្មដោយច្បាប់កំណត់។ ប៉ុន្តែ ក្នុងករណីតតិយជនដែលគ្មានទំនាក់ទំនងផលប្រយោជន៍បានសងវិញ វានឹងក្លាយជាឧបាទេសកម្មដោយស្ម័គ្រចិត្ត ហើយឧបាទេសកម្មដោយស្ម័គ្រចិត្តនេះអាចតតាំងចំពោះកូនបំណុល និង អ្នកដទៃបាន លុះត្រាតែតតិយជននោះបានបំពេញលក្ខខណ្ឌតតាំងដូចគ្នានឹងលក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលផងដែរ (មាត្រា500)។

<u>⑤ ការសងទៅជនដែលគ្មានសិទ្ធិ</u>

ជាទូទៅ បើសិនជាការសងមិនបានធ្វើចំពោះម្ចាស់បំណុលពិតប្រាកដ ឬ បុគ្គលដែលទទួលបានសិទ្ធិអំណាចក្នុងការទទួលការសងពីម្ចាស់បំណុល (អ្នកតំណាង ជាអាទិ៍) ទេ អានុភាពមិនកើតមានឡើងឡើយ។ ប៉ុន្តែ វាមានករណីលើកលែងចំពោះបញ្ញត្តិស្តីពី **ការសងទៅជនដែលមានរូបខាងក្រៅដូចជាបុគ្គលដែលមានសិទ្ធិទទួល** (មាត្រា478)។ នៅមុនវិសោធនកម្មឆ្នាំ2017 គេបានហៅថា ការសងចំពោះឧបអ្នកកាន់កាប់សិទ្ធិលើបំណុល។ មានន័យថា បុគ្គលនោះមិនមែនជាម្ចាស់បំណុលទេ ប៉ុន្តែមើលទៅហាក់បីដូចជាម្ចាស់បំណុល។ បើសិនជាកូនបំណុលបានសងទៅបុគ្គលនោះដោយសុចរិត និង គ្មានកំហុស (លក្ខខណ្ឌគ្មានកំហុសនេះ ត្រូវបានបន្ថែមនៅក្នុងវិសោធនកម្មច្បាប់ឆ្នាំ2004 ដោយយកតាមយុត្តិសាស្ត្រ និងទ្រឹស្តីទូទៅ) ពោលគឺ បានសងដោយជឿជាក់លើរូបភាពខាងក្រៅថា បុគ្គលនោះ គឺជាម្ចាស់បំណុល ក្នុងករណីនេះ ការសងនោះនឹងមានសុពលភាព។ ដើមឡើយ យើងគិតថា បញ្ញត្តិនេះជាករណីលើកលែងក្នុងករណីដែលអ្នកណាក៏ងាយច្រឡំ ប៉ុន្តែ នៅប្រទេសជប៉ុនត្រូវបានធនាគារប្រើប្រាស់យ៉ាងច្រើនចំពោះការទាមទារឱ្យសងវិញ ចំពោះបុគ្គលដែលមិនមែនជាម្ចាស់គណនីពិតប្រាកដ (បញ្ញត្តិនេះបានទទួលបន្តពីក្រមរដ្ឋប្បវេណីបារាំង ប៉ុន្តែ នៅប្រទេសបារាំងប្រើប្រាស់តែក្នុងករណីដែលមានការសងដោយភាន់ច្រឡំដោយសារតែមិនអាចជៀសបាន។ ហើយការប្រើប្រាស់យ៉ាងច្រើននេះ គឺជាលក្ខណៈពិសេសដែលមានតែនៅប្រទេសជប៉ុននោះទេ)។

### (3) **ការសងដោយវត្ថុជំនួស**

ឧបមាថា A បានឱ្យប្រាក់ B ខ្ចីចំនួន 400លានរៀល ហើយជំនួសឱ្យការសងប្រាក់កម្ចីនេះ B ទទួលការឯកភាពពី A ហើយបានផ្ទេរផ្ទះដែលជាកម្មសិទ្ធិរបស់ខ្លួនឱ្យទៅ A។ នៅក្នុងករណីដូចខាងលើនេះ ការដែលកូនបំណុលបានព្រមព្រៀងជាមួយម្ចាស់បំណុល ដើម្បីរំលត់សិទ្ធិលើបំណុលដើម តាមរយៈការអនុវត្តនូវការផ្តល់តាវកាលិកខុសពីខ្លឹមសារនៃតាវកាលិកដើម ហៅថា ការសងដោយវត្ថុជំនួស (មាត្រា482។ ឱ្យតែភាគីបានព្រមព្រៀងគ្នា ការសង

ដោយវត្ថុជំនួសដែលផ្តល់តាវកាលិកនូវត្បូងដែលមានតម្លៃ 320លានរៀល ជំនួសឱ្យដីដែលមានតម្លៃ 400លានរៀល ក៏មានសុពលភាពដែរ)។ ការសងដោយវត្ថុជំនួស គឺជាកិច្ចសន្យាដែលចាំបាច់ត្រូវមានការព្រមព្រៀងរបស់ម្ចាស់បំណុល និង អ្នកសង ហើយនៅក្នុងវិសោធនកម្មច្បាប់បានកំណត់កិច្ចសន្យានេះ ជាកិច្ចសន្យាកើតឡើងតាមការព្រមព្រៀង ប៉ុន្តែ សិទ្ធិលើបំណុលនឹងរលត់នៅពេលដែលបានផ្តល់តាវកាលិកជាក់ស្តែង។ ការសងដោយវត្ថុជំនួសក៏អាចធ្វើឡើងក្នុងគោលបំណងធានាដែរ ក្នុងនាមជា **ការសន្យាជាមុននៅកិច្ចសន្យាសងជំនួស** (ឬ កិច្ចសន្យាសងដោយវត្ថុជំនួសដោយភ្ជាប់លក្ខខណ្ឌ) ដែលមានខ្លឹមសារថា «ខ្ញុំនឹងព្រមប្រគល់ផ្ទះនេះ បើសិនជាមិនអាចសងប្រាក់កម្ចីបាន» ជាដើម។

### (4) **ការតម្កល់**

បើសិនជាកូនបំណុលបានព្យាយាមសង ប៉ុន្តែ ម្ចាស់បំណុលមិនព្រមទទួលដោយសារ មិនសុខចិត្តនឹងចំនួនទឹកប្រាក់ ឬ ម្ចាស់បំណុលបានបាត់ខ្លួនជាអាទិ៍ ក្នុងករណីនេះ កូនបំណុលអាចរួចផុតពីការទទួលខុសត្រូវនៃការមិនអនុវត្តកាតព្វកិច្ច ដោយការស្នើផ្តល់ការសងដែលបានរៀបខាងលើនេះ។ ប៉ុន្តែ បើគ្រាន់តែស្នើផ្តល់ការសងទេ កាតព្វកិច្ចនៅតែមានដដែល។ ហើយវិធីធ្វើឱ្យកាតព្វកិច្ចនោះរលត់ គឺការតម្កល់។ ជាក់ស្តែង កូនបំណុលអាចធ្វើឱ្យសិទ្ធិលើបំណុលរលត់ ដោយការដាក់តម្កល់កម្មវត្ថុដែលត្រូវសង នៅការិយាល័យតម្កល់នៃមន្ទីរកិច្ចការច្បាប់ទូទាំងប្រទេសបាន។ ប៉ុន្តែ ការតម្កល់នេះមិនអនុញ្ញាតឱ្យធ្វើនោះទេ បើសិនជាដើមឡើយអាចសងបាន ពោលគឺ បើគ្មាន**មូលហេតុនៃការតម្កល់**ទេ គឺមិនអាចធ្វើបានទេ។ មូលហេតុនៃការតម្កល់អាចជា ករណីដែលម្ចាស់បំណុលបដិសេធមិនទទួល ឬ មិនអាចទទួលបាន, ឬករណីដែលមិនអាចស្គាល់ម្ចាស់បំណុលដោយគ្មានកំហុស ពោលគឺករណីដែលនៅក្រោយពេលម្ចាស់បំណុលបានស្លាប់ កូនបំណុលមិនអាចដឹងថាបុគ្គលណាគឺជាសន្តតិជន, ឬករណីដែលសិទ្ធិលើបំណុលតែមួយត្រូវបានធ្វើអនុប្បទានជាច្រើនដងពេក ហើយមិនអាចដឹងថាអ្នកណាជាម្ចាស់បំណុលពិតប្រាកដជាដើម (មាត្រា494)។

### (5) **ការទូទាត់**

ឧបមាថា A មានសិទ្ធិលើបំណុលនៃប្រាក់កម្ចីចំនួន 160លានរៀល ចំពោះ B ហើយ B បានលក់ទំនិញឱ្យ A ហើយមានសិទ្ធិលើបំណុលជាថ្លៃលក់ចំនួន 80លានរៀល។ ក្នុងករណីនេះ B អាចបង្ហាញឆន្ទៈរំលត់សិទ្ធិលើបំណុល និង កាតព្វកិច្ចទៅវិញទៅមកចំពោះទឹកប្រាក់ចំនួន 80លានរៀល ហើយបដិសេធចំពោះការបង់ប្រាក់ចំនួន 80លានរៀលនេះ ចំពោះការទាមទារឱ្យសងប្រាក់ចំនួន 160លានរៀល ពី A បាន។ នេះហៅថា ការទូទាត់។ ការទូទាត់ គឺជាការរំលត់សិទ្ធិលើបំណុល**ក្នុងចំនួនទឹកប្រាក់ស្មើគ្នា** តាមរយៈការបង្ហាញឆន្ទៈតែម្ខាង ក្នុងករណីដែលម្ចាស់បំណុល និង កូនបំណុលមានសិទ្ធិលើបំណុលប្រភេទដូចគ្នា (ឧទាហរណ៍ សិទ្ធិលើបំណុលជាប្រាក់ និងសិទ្ធិលើបំណុលជាប្រាក់) ទៅវិញទៅមក (មាត្រា505)។ ក្នុងករណីនេះ សិទ្ធិលើបំណុលដែលផ្តើមធ្វើការទូទាត់ ហៅថា **សិទ្ធិលើបំណុលដែលផ្តើមការទូទាត់** ហើយសិទ្ធិលើបំណុលដែលទទួលរងការទូទាត់ ហៅថា **សិទ្ធិលើបំណុលដែលទទួល**

**ការទូទាត់**។ ការទូទាត់ដែលក្រមរដ្ឋប្បវេណីបានកំណត់ គឺជាសកម្មភាពឯកតោភាគីតាមរយៈការបង្ហាញឆន្ទៈតែម្ខាង ប៉ុន្តែ ភាគីទាំងសងខាងអាចព្រមព្រៀងគ្នាទាំងសងខាង ហើយបង្កើតកិច្ចសន្យាទូទាត់ដោយសេរីបាន។ នៅក្នុងករណីនៃការទូទាត់ក្នុងនាមជាសកម្មភាពឯកតោភាគី សិទ្ធិលើបំណុលទាំងសងខាងត្រូវតែមានប្រភេទដូចគ្នា ហើយសិទ្ធិលើបំណុលទាំងសងខាងនោះត្រូវតែដល់កំណត់ពេលសងដូចគ្នា (ថ្ងៃកំណត់ដែលត្រូវសង) (មាត្រា505 កថាខណ្ឌទី1 វាក្យខណ្ឌទី1)។ ស្ថានភាពដែលសិទ្ធិលើបំណុលទាំងសងខាងអាចទូទាត់បានបែបនេះ ហៅថា **ស្ថានភាពសមស្របនឹងការទូទាត់**។ ប៉ុន្តែ ឧបមាថា សិទ្ធិលើបំណុលរបស់ A បានដល់កំណត់សង (ថ្ងៃកំណត់ដែល B ត្រូវសងបានមកដល់) ប៉ុន្តែ សិទ្ធិលើបំណុល B មិនទាន់ដល់កំណត់សងនោះទេ (A មិនទាន់ត្រូវសងនោះទេ ដោយសារតែកំណត់ពេលសងដែលបានសន្យាមិនទាន់មកដល់) ក្នុងករណីនេះ ភាគី A អាចបោះបង់ផលប្រយោជន៍នៃកំណត់ពេល (មាត្រា136 កថាខណ្ឌទី2) ហើយទូទាត់បាន។ ហើយអានុភាពនៃការទូទាត់ ត្រូវកើតឡើងត្រឡប់ទៅថ្ងៃដែលជាស្ថានភាពសមស្របនឹងការទូទាត់ (មាត្រា506 កថាខណ្ឌទី2)។

យ៉ាងណាមិញ ភាគីអាចកំណត់ការសន្យាពិសេសហាមឃាត់មិនឱ្យទូទាត់ជាមុនបាន (មាត្រា505 កថាខណ្ឌទី2) ប៉ុន្តែ ការសន្យាពិសេសដែលហាមឃាត់នេះ អាចតតាំងចំពោះតែតតិយជនដែលបានដឹង ឬ មិនបានដឹងដោយមានកំហុសធ្ងន់ធ្ងរ (ពោលគឺ ទុច្ចរិតមានកំហុសធ្ងន់ធ្ងរ) ប៉ុណ្ណោះ (មាត្រាដដែល កថាខណ្ឌទី2 វាក្យខណ្ឌទី2)។ កូនបំណុលនៃសិទ្ធិទាមទារសំណងការខូចខាតដោយអំពើអនីត្យានុកូលទុច្ចរិត និង ម្ចាស់បំណុលនៃសិទ្ធិលើបំណុលទាមទារសំណងការខូចខាតទាក់ទងនឹងអាយុជីវិត និង រូបរាងកាយរបស់បុគ្គល មិនអាចតតាំងអំពីការទូទាត់នោះទេ បើទោះបីជាមានសិទ្ធិលើបំណុលជាប្រាក់ចំពោះម្ចាស់បំណុល (ជនរងគ្រោះ) ក៏ដោយ (មាត្រា509។ ការកំណត់នេះ ធ្វើឡើងដើម្បីធានាឱ្យជនរងគ្រោះទទួលបានការសំណងជាប្រាក់ជាក់ស្តែង)។

## III. ក្រមរដ្ឋប្បវេណី និងកិច្ចការច្បាប់នៃសហគ្រាស

បញ្ហាដែលស្មុគស្មាញជាងគេនៅក្នុងការអនុវត្តជាក់ស្តែង គឺបញ្ហានៃការប្រមូលសិទ្ធិលើបំណុល និង ការអនុវត្តប្រាតិភោគដែលពាក់ព័ន្ធជាចម្បងនៅក្នុងនីតិសិទ្ធិលើបំណុលទូទៅ និង នីតិប្រាតិភោគប្រត្យក្ស។ នៅក្នុងស្ថានភាពនេះហើយដែលក្រមរដ្ឋប្បវេណីបានបង្ហាញអំពី ការតទល់គ្នានៃផលប្រយោជន៍របស់ភាគី។ ទោះបីជាអ្នកទាំងអស់គ្នាមិនប្រឡងយកវិជ្ជាជីវៈ ដើម្បីក្លាយជាអ្នកច្បាប់ ហើយបម្រើការងារនៅតាមធនាគារ ក្រុមហ៊ុនពាណិជ្ជកម្ម និង រោងចក្រនានាក៏ដោយ ក៏ចំណេះដឹងដែលបានរៀបរាប់ខាងលើនេះ មានសារៈសំខាន់ដែរ។ ខ្ញុំសូមលើកអំពីឧទាហរណ៍ជាក់ស្តែងជូន។ ឧបមាថា ក្រុមហ៊ុនពាណិជ្ជកម្មដៃគូដែលអ្នកបានឱ្យកម្ចីទុន ឬ មានសិទ្ធិលើបំណុលនៃថ្លៃលក់ទំនិញជាអាទិ៍ បានធ្លាក់ក្នុងសភាពលំបាក។ បុគ្គលគ្រប់គ្នាដែលកាន់កិច្ចការច្បាប់របស់សហគ្រាសត្រូវតែប្រើប្រាស់ចំណេះដឹងនៃនីតិសិទ្ធិលើបំណុលទូទៅ និង នីតិប្រាតិភោគប្រាត្យក្ស ដើម្បីរក្សាការពារ និង ប្រមូលសិទ្ធិលើបំណុលរបស់ខ្លួន។ ដំបូង បើសិនជាមានភ្ជាប់ហ៊ីប៉ូតែកជាដើម (⇒ជំពូកទី7 II.1(1)) ទៅលើសិទ្ធិលើបំណុល

ចំពោះក្រុមហ៊ុនដែលជិតរលំនោះ ក្នុងករណីនេះ ត្រូវអនុវត្តសិទ្ធិហ៊ីប៉ូតែកនោះ ដើម្បីប្រមូលបំណុលមុន។ បើសិនជាមានអ្នកជានាដោយបុគ្គល មានករណីខ្លះអ្នកជានានោះក៏អាចដួលរលំជាមួយក្រុមហ៊ុននៃកូនបំណុលផងដែរ ហេតុនេះ យើងត្រូវចាត់ចែងការងារនេះជាបន្ទាន់មុនពេលស្ថានភាពទ្រព្យធនកាន់តែយ៉ាប់យ៉ឺន។ ចំពោះសិទ្ធិលើបំណុលដែលគ្មានប្រាតិភោគវិញ យើងត្រូវគិតថា តើក្រុមហ៊ុនខាងយើងមានជាប់កាតព្វកិច្ចអ្វីចំពោះក្រុមហ៊ុននោះដែរទេ ពោលគឺ ស្វែងរកសិទ្ធិលើបំណុលផ្ទុយ បើសិនជាមាន យើងត្រូវបង្ហាញឆន្ទៈទូទាត់ចំពោះកាតព្វកិច្ចនោះជាមុនសិន។ បន្ទាប់មក បើសិនជាក្រុមហ៊ុនជិតរលត់នោះមានសិទ្ធិលើបំណុលចំពោះតតិយជន យើងអាចទាមទារសិទ្ធិលើបំណុលនោះជំនួសឱ្យប្រាក់ថ្លៃលក់ទំនិញ ពោលគឺ មធ្យាបាយដែលទាមទារឱ្យផ្ទេរអនុប្បទានសិទ្ធិលើបំណុល ក្នុងនាមជាការសងដោយវត្ថុជំនួស ប៉ុន្តែ មានករណីខ្លះ ការផ្ទេរបែបនេះត្រូវបានលុបចោល ដោយម្ចាស់បំណុលផ្សេងទៀតដែលបានអនុវត្តសិទ្ធិទាមទារឱ្យលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍។ ម្ចាស់បំណុលដែលបានអនុវត្តសិទ្ធិលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ តែងទទួលបាននូវផលប្រយោជន៍សម្រាប់ខ្លួន ហេតុនេះ យើងត្រូវពិនិត្យមើលសកម្មភាពរបស់ម្ចាស់បំណុលផ្សេងផងដែរ ហើយមិនត្រូវឱ្យកន្លងផុតឱកាសប្រើប្រាស់សិទ្ធិលុបចោលទេ។ បើពិនិត្យមើលទៅ វាហាក់បីដូចជាវិធាននៅក្នុងសៀវភៅធម្មតា ប៉ុន្តែ ពេលខ្លះ វាអាចជាអាវុធដែលប្រើប្រាស់ក្នុងសង្គ្រាមវិវាទពាណិជ្ជកម្ម (⇒ពាក្យគន្លឹះ: កិច្ចការច្បាប់នៃសហគ្រាស)។

ពាក្យគន្លឹះ: **កិច្ចការច្បាប់សហគ្រាស**

កិច្ចការច្បាប់សហគ្រាសមានដំណើរវិវត្តន៍ពី កិច្ចការច្បាប់ដោះស្រាយវិវាទ ទៅជាកិច្ចការច្បាប់បង្ការវិវាទ និង កិច្ចការច្បាប់ជាយុទ្ធសាស្ត្រ។ កិច្ចការច្បាប់ជាយុទ្ធសាស្ត្រ សំដៅទៅលើការរៀបចំរចនាសម្ព័ន្ធចាត់ចែងផ្លូវច្បាប់ដោយមានទិសដៅលើកកំពស់ប្រសិទ្ធិភាពកិច្ចការពាណិជ្ជកម្ម និងពិចារណាអំពីហានិភ័យ និង ផលចំណេញនៃសហគ្រាស។ ហើយនៅក្នុងសហគ្រាសទំនើបនពេលបច្ចុប្បន្ន ផ្នែកកិច្ចការច្បាប់កាន់តែមានសារៈសំខាន់ខ្លាំងឡើង។

យ៉ាងណាមិញ ខ្ញុំសូមផ្តាំផ្ញើដល់អ្នកដែលចង់ចាប់ជំនាញកិច្ចការសហគ្រាស។ សូមសិក្សាទាំងក្រមរដ្ឋប្បវេណី ច្បាប់ក្រុមហ៊ុន និង ច្បាប់ក្ស័យធនផងដែរ។ ហើយសហគ្រាសដែលមានទំហំធំ តែងមានទំនាក់ទំនងពាណិជ្ជកម្មច្រើនឆ្លងប្រទេស ហេតុនេះ សូមសិក្សាភាសាអង់គ្លេសក្នុងកម្រិតដែលអាចអានលិខិតកិច្ចសន្យាជាភាសាអង់គ្លេសបាន។ លើសពីនេះ អ្នកត្រូវយល់ដល់អំពីមូលដ្ឋានគ្រឹះនៃគណនេយ្យផងដែរ (តើគួរតែរកដើមទុនដែលចូលនៅក្នុងផ្នែកណានៃតារាងតុល្យការជាដើម) ចំពោះកិច្ចការច្បាប់នៅក្នុងសហគ្រាសហិរញ្ញវត្ថុ។ ដោយឡែក «**ច្បាប់គ្រឹះស្ថានហិរញ្ញវត្ថុ**» មិនមែនជាវិស័យច្បាប់ដែលឯករាជ្យនោះទេ ប៉ុន្តែ វាគឺជាពិភពច្បាប់ដ៏ធំដែលយកក្រមរដ្ឋប្បវេណីជាមូលដ្ឋាន ហើយមានបូករួមនូវបញ្ញត្តិច្បាប់ជាច្រើនដូចជា ច្បាប់ក្រុមហ៊ុន ច្បាប់ក្ស័យធន (ច្បាប់ក្ស័យធន ឬច្បាប់សម្បទារដ្ឋប្បវេណី) ច្បាប់អនុវត្តរដ្ឋប្បវេណី ច្បាប់រក្សាការពាររដ្ឋប្បវេណី ច្បាប់ប្រតិបត្តិការឧបករណ៍ហិរញ្ញវត្ថុ និង ច្បាប់ពន្ធ ជាអាទិ៍។

# **ជំពូកទី** 7

## **នីតិសិទ្ធិប្រត្យក្ស** (2) — **នីតិសិទ្ធិប្រាតិភោគប្រត្យក្ស**

I. **ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស**

1. អត្ថន័យ និង លក្ខណៈនៃសិទ្ធិប្រាតិភោគប្រត្យក្ស

2. មុខងាររបស់សិទ្ធិប្រាតិភោគប្រត្យក្ស និង ឋានៈនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស

II. **ចំណុចសំខាន់ៗនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស**

1. សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យា

2. សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់

3. ប្រាតិភោគដែលគ្មានច្បាប់កំណត់

## I. **ទិដ្ឋភាពទូទៅនៃនីតិសិទ្ធិប្រាតិភោគប្រាត្យក្ស**

### 1. **អត្ថន័យ និង លក្ខណៈនៃសិទ្ធិប្រាតិភោគប្រត្យក្ស**

#### (1) **អត្ថន័យ**

សូមសាកល្បងគិតថា នៅពេលឱ្យទុនទៅអ្នកដទៃ (ឱ្យគេខ្ចីប្រាក់) តើយើងគួរធ្វើយ៉ាងម៉េច? បើសិនជានៅក្នុងរង្វង់ឪពុកម្ដាយ និង បងប្អូន ភាគច្រើនយើងជឿជាក់លើភាគីម្ខាងទៀត ហេតុនេះ យើងគ្រាន់តែកំណត់ថ្ងៃត្រូវសង និង ចំនួនការប្រាក់ប៉ុណ្ណោះ ប៉ុន្តែ នៅក្នុងកិច្ចការជំនួញទូទៅ វាមិនងាយស្រួលបែបនេះទេ។ ស្ទើរតែគ្រប់ករណីភាគីអ្នកឱ្យខ្ចីនឹងទាមទារឱ្យមានប្រាតិភោគ ដើម្បីការពារពេលភាគីអ្នកខ្ចីមិនព្រមសងវិញ។ វិធីសាស្ត្រមួយក្នុងចំណោមនោះគឺ ដាក់ប្រាតិភោគលើវត្ថុដែលជារបស់អ្នកខ្ចី ហើយបើមិនអាចសងបានទេ អ្នកឱ្យខ្ចីនឹងយកវត្ថុនោះទៅប្ដូរជាប្រាក់ (លក់ដោយបង្ខំ) ហើយប្រមូលបំណុលវិញ។ នេះហៅថា ការធានាដោយវត្ថុ (ផ្ទុយមកវិញ ការចាត់តាំងអ្នកធានា ដែលបានរៀបរាប់នៅក្នុងជំពូកមុន ហៅថា អ្នកធានាដោយបុគ្គល)។ ក្នុងករណីនេះ ម្ចាស់បំណុលដែលជាភាគីឱ្យទុន បានគ្រប់គ្រងលើតម្លៃដោះដូរ (បើប្តូរជាលុយ តើត្រូវបានប៉ុន្មាន) លើវត្ថុដែលបានដាក់ប្រាតិភោគនោះ ហើយមិនមានគ្រប់គ្រងលើតម្លៃប្រើប្រាស់ទេ។ នៅក្នុងចំណោមសិទ្ធិប្រត្យក្សដែលជាសិទ្ធិគ្រប់គ្រងដោយផ្ទាល់ចំពោះវត្ថុ សិទ្ធិប្រាតិភោគប្រត្យក្សគឺជាសិទ្ធិដែលគ្រប់គ្រងតាមទម្រង់បែបនេះ។

#### (2) **លក្ខណៈគតិយុត្ត**

ដូចនេះ នៅក្នុងសិទ្ធិប្រាតិភោគប្រត្យក្សមាន **លក្ខណៈបន្ទាប់បន្សំ** (បើសិទ្ធិលើបំណុលរលត់ នោះសិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវរលត់ដែរ) (និង **លក្ខណៈទៅជាមួយគ្នា** ពោលគឺ បើសិទ្ធិលើបំណុលត្រូវបានធ្វើអនុប្បទាន នោះសិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវភ្ជាប់ទៅជាមួយដែរ) ដែលមានវាសនារួមជាមួយនឹងសិទ្ធិលើបំណុលដែលជាប្រភពដើម។ ហើយដើម្បីឱ្យអានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សកាន់តែខ្លាំង ក្រមរដ្ឋប្បវេណីបានកំណត់ថា សិទ្ធិប្រាតិភោគប្រត្យក្សអាចអនុវត្តចំពោះកម្មវត្ថុទាំងមូល រហូតដល់ពេលម្ចាស់បំណុលទទួលបានការសងគ្រប់ចំនួន ពោលគឺ **លក្ខណៈអវិភាគភាព** (មាត្រា296 និងមាត្រាផ្សេងទៀត)។ លើសពីនេះ បើសិនជាកម្មវត្ថុនៃប្រាតិភោគត្រូវបានយកទៅលក់ ឬ ដាក់ជួល ហើយបង្កើតជាថ្លៃលក់ និង ថ្លៃឈ្នួល ឬ កម្មវត្ថុនៃប្រាតិភោគនោះត្រូវបានបាត់បង់ ឬ ខូចខាត ហើយបង្កើតជាប្រាក់សំណងការខូចខាតជាអាទិ៍ ក្នុងករណីនេះ សិទ្ធិប្រាតិភោគប្រត្យក្សក៏មានអានុភាពទៅលើរបស់ទាំងអស់ខាងលើផងដែរ។ នេះហៅថា **លក្ខណៈឧបាទេសកម្មលើវត្ថុ**។ ហើយលក្ខណៈនេះត្រូវបានទទួលស្គាល់ចំពោះសិទ្ធិប្រាតិភោគប្រត្យក្ស 3 ប្រភេទ នៅក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្សទាំង 4ប្រភេទ (មាត្រា304 និងមាត្រាផ្សេងទៀត។ សិទ្ធិឃាត់ទុកដែលនឹងលើកមកបង្ហាញនៅពេលក្រោយនេះ មិនត្រូវបានទទួលស្គាល់លក្ខណៈឧបាទេសកម្មលើវត្ថុទេ ដោយសារតែ សិទ្ធិនេះគ្មានអានុភាពទទួលបានការសងដោយអាទិភាពពីតម្លៃនៃកម្មវត្ថុទេ)។

(3) **ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស**

ដូចបានបង្ហាញនៅក្នុងជំពូកទី3 រួចហើយថា នៅក្នុងសិទ្ធិប្រាតិភោគប្រត្យក្សរួមមាន សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យា ដែលកើតឡើងតាមរយៈកិច្ចសន្យារបស់ភាគី និង សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់ ដែលច្បាប់បានផ្តល់ឱ្យនៅពេលដែលបានបំពេញស្ថានភាពជាក់លាក់មួយ។ ក្រមរដ្ឋប្បវេណីបានកំណត់ថា ហ៊ីប៉ូតែក និង សិទ្ធិលើការបញ្ចាំ គឺជាសិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យា ហើយ សិទ្ធិឃាត់ទុក និង ឯកសិទ្ធិ គឺជាសិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់។ នៅក្នុងសង្គមជំនួញបច្ចុប្បន្ននេះបានផ្តោតសំខាន់លើសិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យាខ្លាំងជាង។ ជាពិសេសគឺ ហ៊ីប៉ូតែក។ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់សិទ្ធិប្រាតិភោគប្រត្យក្សតែ 4ប្រភេទប៉ុណ្ណោះ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងបានគិតចេញនូវការប្រើប្រាស់វត្ថុ ដើម្បីបម្រើឱ្យមុខងារប្រាតិភោគក្រៅពីការកំណត់ក្នុងក្រមរដ្ឋប្បវេណីផងដែរ ហើយប្រាតិភោគនេះ ត្រូវបានទទួលស្គាល់ដោយច្បាប់យុត្តិសាស្ត្រ ឬ ច្បាប់ទំនៀមទម្លាប់។ សិទ្ធិប្រាតិភោគទាំងនេះ ហៅថាសិទ្ធិប្រាតិភោគដែលគ្មានច្បាប់កំណត់ (ខ្ញុំនឹងពន្យល់ត្រួសៗនៅក្នុងផ្នែកចុងក្រោយនៃជំពូកនេះ)។

## 2. **មុខងាររបស់សិទ្ធិប្រាតិភោគប្រត្យក្ស និង ឋានៈនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស**

សិទ្ធិប្រាតិភោគប្រត្យក្ស គឺជាសិទ្ធិប្រត្យក្សដែលគ្រប់គ្រងតម្លៃដោះដូរនៃវត្ថុ ដូចបានពន្យល់នៅក្នុងលក្ខណៈគតិយុត្តនៃសិទ្ធិប្រាតិភោគប្រត្យក្សខាងលើរួចហើយថា សិទ្ធិប្រាតិភោគប្រត្យក្ស សំដៅទៅលើ សិទ្ធិដែលត្រូវបានបង្កើតឡើងដើម្បីធានាដល់អត្ថិភាពនៃសិទ្ធិលើបំណុល ដោយយកតម្លៃនៃវត្ថុដែលកំពុងក្តោបក្តាប់ជាថ្នូរ។ នេះជាមូលហេតុដ៏ត្រឹមត្រូវ ដែលយើងគួរតែសិក្សាសិទ្ធិប្រាតិភោគប្រត្យក្ស រួមជាចង្កោមជាមួយនឹងសិទ្ធិលើបំណុល។

ឧបមាថា ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុល X ក្នុងពេលបច្ចុប្បន្នមានចំនួន 400លានរៀល (ទ្រព្យសម្បត្តិទទួលខុសត្រូវដែលអាចយកទៅសងបំណុលបានជាដើម) ហើយក្នុងនោះមានដី «ក» ដែលមានតម្លៃ 200លានរៀល។ កូនបំណុលនោះមានម្ចាស់បំណុលចំនួន 5នាក់ គឺ A B C D និង E ហើយម្ចាស់បំណុលម្នាក់ៗ មានសិទ្ធិលើបំណុលចំនួន 200លានរៀល។ បើសិនជាគ្មានម្ចាស់បំណុល A B C D និង E ណាមួយ បានយកប្រាតិភោគមកធានាសិទ្ធិលើបំណុលទេ ក្នុងករណីម្ចាស់បំណុល A B C D និង E អនុវត្តដោយបង្ខំដោយសារកូនបំណុលមិនសងបំណុលនេះ ម្ចាស់បំណុលទាំង 5នាក់ ត្រូវប្រមូលបានស្មើៗគ្នានូវចំនួន 80លានរៀលក្នុងម្នាក់ ពីទ្រព្យសម្បត្តិចំនួន 400លានរៀល របស់ X ដោយអនុលោមតាមគោលការណ៍សមភាពរវាងម្ចាស់បំណុល (សូមសិក្សាលំអិតនៅក្នុងច្បាប់អនុវត្តរដ្ឋប្បវេណី)។ សូមប្តូរមកករណីដែលមានតែ A ម្នាក់ បានបង្កើតហ៊ីប៉ូតែកដែលជាសិទ្ធិប្រាតិភោគប្រត្យក្សនៅលើដី «ក» វិញម្តង។ បើសិនជាកំណត់ពេលសងបានមកដល់ ហើយកូនបំណុលនៅតែមិនទាន់សងនៅឡើយ ក្នុងករណីនេះ A អាចអនុវត្តហ៊ីប៉ូតែកលើដី «ក» នោះ។ ហើយបើដី «ក» លក់បានតម្លៃ 200លានរៀល A អាចប្រមូលសិទ្ធិលើបំណុលពីថ្លៃលក់ដីនោះចំនួន 200លានរៀល ដោយអាទិភាពជាងម្ចាស់បំណុលដទៃបាន។ មានន័យថា ម្ចាស់បំណុល 4នាក់ផ្សេងទៀត ត្រូវប្រមូលបំណុលស្មើគ្នាពីទ្រព្យសម្បត្តិដែលនៅសល់ចំនួន 200

លានរៀល ពោលគឺ ក្នុងម្នាក់ត្រូវទទួលបាន 50លានរៀលប៉ុណ្ណោះ។ នេះហៅថា អានុភាពនៃការសងដោយអាទិភាព ដែលមានក្នុងសិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ហ៊ីប៉ូតែក ជាអាទិ៍។

ពិតហើយថា វិធីសាស្ត្រធានាសិទ្ធិលើបំណុល ក៏មានការធានាដោយបុគ្គលដែលបានសិក្សារួចហើយ នៅក្នុងជំពូកមុន។ នៅក្នុងរឿងក្តីខាងលើនេះ បើសិនជា B បានឱ្យ X ចាត់តាំងអ្នកធានា Y ក្នុងករណីនេះ B នឹងអាចទទួលបានការសងគ្រប់ចំនួននៃទឹកប្រាក់ 200លានរៀល ពី Y (ឬបូករួមពីទ្រព្យសម្បត្តិរបស់ X និង Y តែម្តង) ដរាបណា Y មានទ្រព្យធនគ្រប់គ្រាន់។ ប៉ុន្តែ ការធានាដោយបុគ្គលនេះ ពោលគឺទ្រព្យសម្បត្តិរបស់អ្នកធានាជាអាទិ៍ងាយនឹងប្រែប្រួលណាស់ ហើយគ្មានស្ថិរភាពនោះទេ។ ផ្ទុយមកវិញ ការធានាដោយវត្ថុដែលជាហ៊ីប៉ូតែកជាអាទិ៍មានភាពពិតប្រាកដជាង។ ទោះជាយ៉ាងណាក៏ដោយ ក៏សិទ្ធិប្រត្យក្សដែលមានអានុភាពនៃការសងដោយអាទិភាពត្រូវការចុះបញ្ជី និងគោរពនីតិវិធីបង្កើតស្មុគស្មាញជាងការធានាដោយបុគ្គល ដែលត្រូវការតែកិច្ចសន្យាប៉ុណ្ណោះ។ មួយវិញទៀត អចលនវត្ថុមួយចំនួនអាចធ្លាក់ថ្លៃយ៉ាងគំហុក ហើយបង្កើតជាហានិភ័យដែលធ្វើឱ្យម្ចាស់បំណុលមិនអាចប្រមូលបំណុលគ្រប់ចំនួន ដូចគ្នានឹងការធានាដោយបុគ្គលដែរ។ ហេតុនេះហើយ សូមអ្នកទាំងអស់គ្នាពិចារណាអំពីមធ្យោបាយនានាទៅតាមប្រភេទដែលបានបញ្ញត្តនៅក្នុងនីតិសិទ្ធិប្រាតិភោគប្រត្យក្ស និង នីតិសិទ្ធិលើបំណុលទូទៅ ដើម្បីប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពក្នុងការប្រមូលសិទ្ធិលើបំណុលវិញ។

## II. ចំណុចសំខាន់ៗនៃនីតិសិទ្ធិប្រាតិភោគប្រត្យក្ស

### 1. សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យា

#### (1) ហ៊ីប៉ូតែក

① <u>សញ្ញាណទូទៅ</u>

សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់ក្នុងកិច្ចសន្យារួមមាន ហ៊ីប៉ូតែក និង សិទ្ធិលើការបញ្ចាំ។ សិទ្ធិប្រាតិភោគប្រត្យក្ស គ្រាន់តែក្តោបក្តាប់តម្លៃសេដ្ឋកិច្ចនៃវត្ថុនោះ ហេតុនេះ បើសិនជាហ៊ីប៉ូតែក យើងគ្រាន់តែចុះបញ្ជីអំពីហេតុនៃការបង្កើតហ៊ីប៉ូតែកលើដី និង អគារប៉ុណ្ណោះ ហើយដី និង អគារដែលបានចុះបញ្ជីបង្កើតហ៊ីប៉ូតែកនោះ មិនចាំបាច់ផ្ទេរការកាន់កាប់មកម្ចាស់បំណុលទេ ហើយកូនបំណុល ពោលគឺអ្នកខ្ចីប្រាក់ នៅតែអាចបន្តប្រើប្រាស់ដូចធម្មតាបាន (សូមយោងមាត្រា369)។ ក្រោយមក បើសិនជាកូនបំណុលមិនអាចសងប្រាក់បានទេ ម្ចាស់បំណុលអាចអនុវត្តហ៊ីប៉ូតែកដែលបានចុះបញ្ជីនោះ (មានន័យថា ស្នើឱ្យតុលាការលក់ដោយបង្ខំចំពោះដី និងអគារ) ហើយទទួលយកការសងដោយអាទិភាពជាងម្ចាស់បំណុលដទៃពីប្រាក់ថ្លៃលក់នោះ។ សិទ្ធិប្រាតិភោគប្រត្យក្សដែលមានសារៈសំខាន់ខ្លាំងបំផុតនៅក្នុងសង្គមជំនួញ គឺហ៊ីប៉ូតែកនេះ។

② មុខងារនៃហ៊ីប៉ូតែក និងការចុះបញ្ជី

ដូចបានរៀបរាប់ខាងលើនេះ ហ៊ីប៉ូតែកគឺជាសិទ្ធិប្រត្យក្សក្នុងទស្សនអរូបិយ (មិនអាចវិនិច្ឆ័យដោយមើលពីខាងក្រៅបាន) ដែលក្តោបក្តាប់តែតម្លៃនៃកម្មវត្ថុ ហេតុនេះ សិទ្ធិនេះមានភាពចាំបាច់ក្នុងការចុះបញ្ជីដើម្បីបង្ហាញជាសាធារណៈ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានកំណត់យកតែអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដែលមានមធ្យោបាយបង្ហាញជាសាធារណៈនៅក្នុងសៀវភៅប៉ុណ្ណោះ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក (មាត្រា369។ ក្រៅពីនេះមានកំណត់នៅក្នុងច្បាប់ពិសេស ដូចជា សំណង់ការដ្ឋាន នាវា និង ក្រុមហ៊ុនជាអាទិ៍ ដែលមានប្រើប្រាស់ប្រព័ន្ធចុះបញ្ជី និង កំណត់ត្រា ក៏ក្លាយជាកម្មវត្ថុនៃហ៊ីប៉ូតែកផងដែរ)។

ដើមឡើយ ហ៊ីប៉ូតែកគឺជាប្រព័ន្ធដើម្បីធានាដល់សិទ្ធិលើបំណុលនីមួយៗ។ ក្រមរដ្ឋប្បវេណីប្រទេសជប៉ុនដែលបានយកលំនាំពីក្រមរដ្ឋប្បវេណីបារាំង មាននិន្នាការធានាសិទ្ធិលើបំណុលនីមួយៗនេះខ្លាំងណាស់ (ប៉ុន្តែ ប្រទេសនានាដូចជា អាឡឺម៉ង់ជាដើម មិនគិតហ៊ីប៉ូតែកត្រឹមតែជាប្រពន្ធ័ធានាសិទ្ធិលើបំណុលនោះទេ ថែមទាំងបង្កើតច្បាប់ដោយយកជាកម្មវត្ថុនៃការវិនិយោគផងដែរ។ នេះមានន័យថា គេព្យាយាមធ្វើឱ្យហ៊ីប៉ូតែកមានលំហូរនៃការលក់បាន)។ ដូចនេះ គោលគំនិតនៃការកំណត់លំដាប់ហ៊ីប៉ូតែកក៏ត្រូវបានបង្កើតឡើងផងដែរ ដោយសារតែហ៊ីប៉ូតែកក្តោបក្តាប់តែតម្លៃនៃកម្មវត្ថុហ៊ីប៉ូតែកដើម្បីធានាត្រឹមតម្លៃនៃសិទ្ធិលើបំណុលប៉ុណ្ណោះ។ នេះមានន័យថា កូនបំណុលអាចបង្កើតហ៊ីប៉ូតែកច្រើន និង អាចចុះបញ្ជីបានលើសិទ្ធិប្រាតិភោគប្រត្យក្សតែមួយ។ ឧទាហរណ៍ថា ដំបូង កូនបំណុល A បានបង្កើត និងចុះបញ្ជីហ៊ីប៉ូតែកលើដី «ក» របស់ខ្លួនដែលសន្មតថាអាចលក់ក្នុងតម្លៃ 4000លានរៀល នៅពេលខ្ចីប្រាក់ 2000លានរៀលពី B (នេះហៅថា ហ៊ីប៉ូតែកលំដាប់ទីមួយ)។ បន្ទាប់មក A បានខ្ចីប្រាក់ចំនួន 1600លានរៀល ពី C ហើយបានបង្កើត និង ចុះបញ្ជីហ៊ីប៉ូតែកលើដី «ក» ដដែលនោះ (ហ៊ីប៉ូតែកលំដាប់ទីពីរ)។ ហើយក្រោយមកទៀត A បានខ្ចីប្រាក់ចំនួន 800លានរៀល ពី D ហើយបានបង្កើត និង ចុះបញ្ជីហ៊ីប៉ូតែកលើដី «ក» ដដែលដើម្បីធានា (ហ៊ីប៉ូតែកលំដាប់ទីបី)។ ហើយឧបមាថា A មិនអាចសងប្រាក់ទៅ B C និង D ទេ ហើយកំណត់ពេលសម្រាប់សងសុទ្ធតែហួសពេលកំណត់ទាំងអស់ (ជាក់ស្តែង វានៅមានបញ្ហានៃការប្រាក់ទៀត ប៉ុន្តែ ខ្ញុំសូមរំលងចំណុចនេះ។ សូមយោងមាត្រា374 កថាខណ្ឌទី1 វាក្យខណ្ឌទី1)។ ហើយដី «ក» លក់ជាក់ស្តែងបានចំនួន 4000លានរៀល។ B មានអាទិភាពលំដាប់ទីមួយ ហេតុនេះអាចប្រមូលបំណុលទាំងអស់ចំនួន 2000លានរៀល ពីក្នុង 4000លានរៀល។ បន្ទាប់មក C អាចប្រមូលសិទ្ធិលើបំណុលចំនួន 1600លានរៀល ពីក្នុងទឹកប្រាក់នៅសល់ 2000លានរៀល។ ប៉ុន្តែ D ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទីបីចុងក្រោយបំផុត បានឱ្យខ្ចីចំនួន 800លានរៀល ប៉ុន្តែ ប្រាក់ថ្លៃលក់ដី «ក» នៅសល់តែ 400លានរៀលប៉ុណ្ណោះ ក្រោយពីម្ចាស់បំណុលពីរនាក់បានដករួច ហេតុនេះបានទទួលត្រឹមប្រាក់ 400លានរៀល (ប្រាក់ដែលនៅសល់ 400លានរៀលទៀត នឹងគ្មានប្រាតិភោគធានា ហើយអាចបន្តទាមទារឱ្យកូនបំណុលសងបាន)។ ប៉ុន្តែ បើសិនជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់លើ (ឧបមាថា ហ៊ីប៉ូតែកលំដាប់ទីពីរ C) បានទទួលការសងតាមកិច្ចសន្យា ក្នុងករណីនេះ ការចុះបញ្ជីហ៊ីប៉ូតែករបស់បុគ្គលនោះនឹងត្រូវលុបចោល ហើយ ម្ចាស់ហ៊ីប៉ូតែកលំដាប់ទីបី D នឹងបានឡើងលំដាប់ (តាមឧទាហរណ៍ខាងលើនេះ គឺឡើងពី

លំដាប់ទីបី ទៅលំដាប់ទីពីរ ហើយនៅក្នុងការអនុវត្តហ៊ីប៉ូតែក D នឹងទទួលបានការសងគ្រប់ចំនួននៃទឹកប្រាក់ 800លានរៀល បន្ទាប់ពី B)។ ប៉ុន្តែ ឧបមាថា តម្លៃទីផ្សារនៃដីបានធ្លាក់ចុះ ហើយដី «ក» លក់បានតែតម្លៃ 2000លានរៀល ក្នុងករណីនេះ ហ៊ីប៉ូតែកលំដាប់ទីមួយ B នឹងប្រមូលបំណុលចំនួន 2000លានរៀលនោះ ហើយចាប់ពីអ្នកលំដាប់ទីពីរទៅ សូម្បីតែ 100រៀលក៏ប្រមូលមិនបានដែរ។




### ③ ទំនាក់ទំនងនៃហ៊ីប៉ូតែក និង សិទ្ធិប្រើប្រាស់

ហ៊ីប៉ូតែកក្តោបក្តាប់តែតម្លៃនៃកម្មវត្ថុ ហើយសិទ្ធិប្រើប្រាស់ស្ថិតនៅនឹងកម្មសិទ្ធិករដដែល។ ហេតុនេះ ក្រោយបង្កើតហ៊ីប៉ូតែកក៏ដោយ ក៏កម្មសិទ្ធិករអាចបង្កើតសិទ្ធិជួល និង ទទួលយកផលប្រយោជន៍ពីដីនោះបានដែរ។ ដើម្បីការពារដល់អ្នកជួល គេបានរៀបចំនូវបញ្ញត្តិដែលអនុញ្ញាតឱ្យអ្នកជួលរយៈពេលខ្លី (សិទ្ធិជួលដែលមានអំឡុងពេលមិនលើសពីការកំណត់ក្នុងមាត្រា602។ 5ឆ្នាំចំពោះដី និង 3ឆ្នាំចំពោះអគារ) អាចតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក បើទោះបីជាបានចុះបញ្ជីក្រោយការបង្កើតហ៊ីប៉ូតែកក៏ដោយ (មាត្រា395 ចាស់)។ ប៉ុន្តែ ក្នុងពេលបច្ចុប្បន្ននេះ សិទ្ធិជួលរយៈពេលខ្លីនេះ ភាគច្រើនត្រូវបានបង្កើតឡើងក្នុងគោលបំណងរារាំងដល់ការអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែក ហេតុនេះហើយ វិសោធនកម្មច្បាប់ឆ្នាំ2003 បានលុបចោលបញ្ញត្តិនេះ ហើយបានបង្កើតនៅរយៈពេលបង្អង់ចំនួន 6ខែ (មាត្រា395 ថ្មី) ចំពោះអ្នកជួលដែលត្រូវបានទាមទារឱ្យប្រគល់តាមការអនុវត្តហ៊ីប៉ូតែក (លក់ដោយបង្ខំ)។

④ ហ៊ីប៉ូតែក និង សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស

ដោយសារតែហ៊ីប៉ូតែកគឺជាសិទ្ធិប្រត្យក្ស ហេតុនេះ ម្ចាស់សិទ្ធិហ៊ីប៉ូតែកក៏មានសិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងចំពោះការបំពានដែរ។ ប៉ុន្តែ ហ៊ីប៉ូតែកជាសិទ្ធិគ្រប់គ្រងតម្លៃប៉ុណ្ណោះ ដូចនេះ យើងនៅមានមន្ទិលថា តើអ្វីទៅជាការបំពាន ហើយពេលណាទើបអាចទាមទារឱ្យបញ្ឈប់បាន។ ទស្សនៈភាគច្រើនលើកឡើងថា បើសិនជាតម្លៃនៃកម្មវត្ថុបានធ្លាក់ចុះក្នុងកម្រិតដែលមិនអាចធានាដល់ហ៊ីប៉ូតែកបាន ដោយសារតែការកាប់ដើមឈើដោយមិនត្រឹមត្រូវ ឬបំផ្លាញផ្ទះនៅលើដីដែលជាប់ហ៊ីប៉ូតែក ក្នុងករណីនេះ ម្ចាស់សិទ្ធិហ៊ីប៉ូតែកអាចទាមទារឱ្យបញ្ឈប់ការរារាំងបាន (ការទាមទារឱ្យបញ្ឈប់ការយកចេញ ឬ ទាមទារឱ្យធ្វើបដិទាន ជាអាទិ៍)។

⑤ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ក៏ត្រូវបានទទួលស្គាល់ផងដែរ។ បើសិនជាហ៊ីប៉ូតែកធម្មតា គេបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលជាក់លាក់ (សិទ្ធិលើបំណុលចំនួន 2000លានរៀល របស់ AចំពោះB) ប៉ុន្តែ បើសិនជា A និង B ជួញដូរជាមួយគ្នាជារឿយៗ ក្នុងករណីនេះ វានឹងគួរឱ្យធុញទ្រាន់ណាស់ ដែលត្រូវបង្កើត និង លុបហ៊ីប៉ូតែកម្តងមួយៗ ពីសិទ្ធិលើបំណុលជាក់លាក់នីមួយៗនោះ។ ហេតុនេះ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានបង្កើតឡើង ដើម្បីអាចធានាកាតព្វកិច្ចជាសកលមិនជាក់លាក់ (ដោយកំណត់ជាមុនអំពីកម្រិតនៃចំនួនអតិបរមា ពោលគឺ ចំនួនខ្ពស់បំផុតនៃជំនួញដែលធានា)។ ចំណុចនេះបានធ្វើឱ្យលេចឡើងនូវបញ្ហាជាច្រើន ហេតុនេះក្រមរដ្ឋប្បវេណីបានបន្ថែមបញ្ញត្តិពិស្តារជាច្រើន ដើម្បីសម្រួលដល់បញ្ហាទាំងនេះ (មាត្រា398.2〜មាត្រា398.22)។

⑥ វិសាលភាពនៃហ៊ីប៉ូតែកទៅលើកម្មវត្ថុ

ហ៊ីប៉ូតែកមានវិសាលភាពទៅលើ វត្ថុដែលបានក្លាយទៅជាវត្ថុតែមួយ (វត្ថុភ្ជាប់) នៃអចលនវត្ថុដែលជាប់ហ៊ីប៉ូតែក (មាត្រា370 វាក្យខណ្ឌទី1)។ ខ្ញុំយល់ស្របចំពោះ វិសាលភាពនៃហ៊ីប៉ូតែកទៅលើវត្ថុភ្ជាប់ (មាត្រា242។ ឧទាហរណ៍ របងថ្ម ថ្មចិញ្ចើមផ្លូវ ដើមឈើ និង កូនរុក្ខជាតិដែលជាប់នឹងដីជាអាទិ៍) នៃគោលគំនិតនៃវត្ថុភ្ជាប់នេះ ប៉ុន្តែ ខ្ញុំនៅមានមន្ទិលចំពោះការពន្លាតអានុភាពទៅលើវត្ថុចំណុះ (មាត្រា87។ ថ្មដែលបានទុកនៅលើដី ឬ ថ្មទុកក្នុងសួនច្បារដែលអាចលើកចេញបាន ឬ កម្រាលដែលក្រាលនៅលើអគារ និងគ្រឿងសង្ហារឹមជាអាទិ៍។ ⇒ពាក្យគន្លឹះ: វត្ថុចម្បង និង វត្ថុចំណុះ, វត្ថុដើម និង ផល)។ ផ្ទុយមកវិញ ចំពោះផលធម្មជាតិ និង ផលស៊ីវិល គឺជាវត្ថុដែលភ្ជាប់នឹងអចលនវត្ថុតែមួយ ប៉ុន្តែ ហ៊ីប៉ូតែកគឺជាសិទ្ធិដែលរក្សាទុកសិទ្ធិកាន់កាប់ និង អាស្រ័យផលលើកម្មវត្ថុឱ្យទៅអ្នកបង្កើត ហេតុនេះ ជាគោលការណ៍ អានុភាពនៃហ៊ីប៉ូតែកមិនមានទៅលើផលដែលបានប្រមូល ឬ ទទួលនៅមុនពេលអនុវត្តហ៊ីប៉ូតែកនោះទេ (ប៉ុន្តែ មានអានុភាពទៅលើផលដែលកំពុងតែមាននៅពេលអនុវត្ត។ មាត្រា371)។

លើសពីនេះ ហ៊ីប៉ូតែកក៏មានអានុភាពទៅលើសិទ្ធិដែលចំណុះឱ្យកម្មវត្ថុនៃហ៊ីប៉ូតែកដែរ (សិទ្ធិដែលភ្ជាប់នឹងអចលនវត្ថុដែលត្រូវបានបង្កើតហ៊ីប៉ូតែក)។ ឧទាហរណ៍ កូនបំណុលបានបង្កើតហ៊ីប៉ូតែកទៅលើអគាររបស់ខ្លួននៅ

លើដីដែលកំពុងជួល ក្នុងករណីនេះ ហ៊ីប៉ូតែកក៏មានទៅលើសិទ្ធិជួលដីផងដែរ ហើយអ្នកទិញដោយបង្ខំនូវអគារនោះ (អ្នកដែលបានទិញក្នុងការលក់ដោយបង្ខំ) នឹងធ្វើលទ្ធកម្មអគារដែលមានភ្ជាប់ជាមួយសិទ្ធិជួល (ប៉ុន្តែ វាមានបញ្ហាពាក់ព័ន្ធនឹងសិទ្ធិជួលនៅក្នុងក្រមរដ្ឋប្បវេណី និង នៅក្នុងច្បាប់ស្តីពីការជួលដីជួលផ្ទះ។ ⇒ : ជំពូកទី4 III.3)។

⑦ ឧបាទេសកម្មលើវត្ថុ

ឧទាហរណ៍ថា B បានយកផ្ទះ «ក» ទៅបង្កើតហ៊ីប៉ូតែក ដើម្បីខ្ចីទុនពី A (ម្ចាស់បំណុល A ហៅថា ម្ចាស់សិទ្ធិហ៊ីប៉ូតែក ហើយ កូនបំណុល B ហៅថា អ្នកបង្កើតហ៊ីប៉ូតែក)។ បើសិនជាផ្ទះ «ក» នោះត្រូវភ្លើងឆេះ ហើយបាត់បង់ទៅ ក្នុងករណីនេះ A នឹងបាត់បង់ប្រាតិភោគផងដែរ។ ប៉ុន្តែ បើសិនជា B បានទិញធានារ៉ាប់រងអគ្គិភ័យលើផ្ទះ «ក» ហើយនាំឱ្យ B អាចទាមទារថ្លៃធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងបាន ក្នុងករណីនេះ អានុភាពនៃហ៊ីប៉ូតែកក៏មានទៅលើសិទ្ធិទាមទារប្រាក់ធានារ៉ាប់រងអគ្គិភ័យនេះផងដែរ (A អាចប្រមូលប្រាក់ទុន ពីប្រាក់ធានារ៉ាប់រងអគ្គិភ័យនោះបាន)។ ក្នុងករណីដូចខាងលើនេះដែលកម្មវត្ថុនៃប្រាតិភោគបានបាត់បង់ ឬ ខូចខាត(ឬករណីដែលមានការលក់ទិញ ឬការជួល) ហើយអានុភាពនៃសិទ្ធិប្រាតិភោគមានទៅដល់ «ប្រាក់ ឬ វត្ថុផ្សេងទៀត» ដែលអ្នកបង្កើត (នៅក្នុងឧទាហរណ៍ខាងលើនេះ គឺ B) ត្រូវទទួលបាន ហៅថា «ឧបាទេសកម្មលើវត្ថុ»។ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនបានទទួលស្គាល់អានុភាពនេះ ចំពោះហ៊ីប៉ូតែក (មាត្រា372 និង មាត្រា304) សិទ្ធិលើការបញ្ចាំ និង ឯកសិទ្ធិដែលនឹងត្រូវរៀបរាប់នៅបន្ទាប់នេះ។ យុត្តិសាស្ត្របានទទួលស្គាល់ឧបាទេសកម្មលើវត្ថុនៃសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ហេតុនេះ ម្ចាស់សិទ្ធិហ៊ីប៉ូតែកចំពោះអគារដែលមានអ្នកជួល អាចអនុវត្តហ៊ីប៉ូតែកដោយប្រមូលបំណុល ពីការលក់ដោយបង្ខំលើអគារនោះក៏បាន ឬ ពីការធ្វើឧបាទេសកម្មលើវត្ថុដែលជាសិទ្ធិលើបំណុលថ្លៃឈ្នួលដោយមិនលក់ដោយបង្ខំក៏បាន។

⑧ សិទ្ធិលើដីតាមច្បាប់កំណត់

ឧទាហរណ៍ថា B មានកម្មសិទ្ធិលើដី និង អគារដែលនៅលើដីនោះ ហើយ B បង្កើតហ៊ីប៉ូតែកនៅលើតែអាគារប៉ុណ្ណោះ នៅពេល B ខ្ចីប្រាក់ទុនពី A (ដូចបានរៀបរាប់រួចហើយថា នៅប្រទេសជប៉ុនបានចាត់ទុកថា ដី និង អគារគឺជាអចលនវត្ថុដាច់ដោយឡែកពីគ្នា។ ⇒ ជំពូកទី3 I.1)។ ហើយឧបមាថា B មិនអាចសងបំណុលបាន ហើយ A បានអនុវត្តហ៊ីប៉ូតែក ហើយក្រោយពីលក់ដោយបង្ខំ C បានទិញយកអគារនោះ (A ប្រមូលប្រាក់កម្ចីពីថ្លៃលក់អគារ)។ តាមរយៈនេះ C នឹងស្ថិតក្នុងស្ថានភាពដែលទទួលបានកម្មសិទ្ធិលើអគារ ប៉ុន្តែ គ្មានសិទ្ធិប្រើប្រាស់ដី។ ដូចនេះ នៅពេលដែលបង្កើតហ៊ីប៉ូតែក បើសិនជានៅលើដីនោះមានអគារ ហើយដី និង អគារនោះគឺជារបស់កម្មសិទ្ធិករតែម្នាក់ (នៅក្នុងឧទាហរណ៍ខាងលើនេះ គឺ B) ហើយបើសិនជាដី ឬ អគារណាមួយនោះត្រូវបានយកទៅបង្កើតហ៊ីប៉ូតែក ហើយក្រោយមកទៀត កម្មសិទ្ធិករលើដី និង កម្មសិទ្ធិករលើអគារ អាចក្លាយទៅជាបុគ្គលផ្សេងគ្នា តាមរយៈការលក់ដោយបង្ខំ (នៅក្នុងឧទាហរណ៍ខាងលើនេះ គឺ C បានក្លាយជាកម្មសិទ្ធិករលើអគារ) ក្នុងករណីនេះ ក្រមរដ្ឋប្បវេណីបានចាត់ទុកថា អ្នកបង្កើតហ៊ីប៉ូតែកដែលជាកម្មសិទ្ធិករលើដី (B) បានបង្កើតសិទ្ធិលើដី ដើម្បីកម្មសិទ្ធិករថ្មី

លើអគារ (C) នៅពេលលក់ដោយបង្ខំ។ យើងបានសិក្សារួចមកហើយអំពីសិទ្ធិលើដី (⇒ជំពូកទី3) ប៉ុន្តែ សិទ្ធិលើដីដែលដើមឡើយត្រូវកើតឡើងដោយតាមរយៈកិច្ចសន្យាបង្កើតរបស់ភាគី បែរជាត្រូវកើតឡើងតាមកំណត់របស់ច្បាប់ នៅពេលលក្ខខណ្ឌដាក់លាក់បានបំពេញបែបនេះ ហៅថា សិទ្ធិលើដីតាមច្បាប់កំណត់ (មាត្រា388)។

### (2) សិទ្ធិលើការបញ្ចាំ

សិទ្ធិលើការបញ្ចាំ គឺជាសិទ្ធិដែលក្តោបក្តាប់តែតម្លៃសេដ្ឋកិច្ចប៉ុណ្ណោះ ប៉ុន្តែ សិទ្ធិនេះខុសពីហ៊ីប៉ូតែកត្រង់ថា វត្ថុនោះត្រូវផ្ទេរទៅឱ្យម្ចាស់បំណុល (ម្ចាស់បំណុលត្រូវកាន់កាប់)។ មិនមែនផ្ទេរកម្មសិទ្ធិនោះទេ ប៉ុន្តែ ម្ចាស់បំណុលត្រូវគ្រប់គ្រងវត្ថុរបស់កូនបំណុល។ បើសិនជាកូនបំណុលមិនអាចសងប្រាក់បានទេ ម្ចាស់បំណុលអាចប្រមូលសិទ្ធិលើបំណុលដោយអាទិភាព តាមរយៈការលក់ដោយបង្ខំវត្ថុនោះ (សូមយោង មាត្រា342)។ សិទ្ធិលើការបញ្ចាំ អាចបង្កើតលើចលនវត្ថុ អចលនវត្ថុ និង សិទ្ធិលើទ្រព្យសម្បត្តិដូចជាសិទ្ធិលើបំណុលផ្សេងទៀតបានទាំងអស់ ប៉ុន្តែ សិទ្ធិលើការបញ្ចាំនេះអាចសមស្របនឹងករណីចលនវត្ថុ (ដោយសារតែម្ចាស់បំណុលនឹងបាត់បង់ផលប្រយោជន៍ នៅពេលដែលទុកវត្ថុនៅនឹងកូនបំណុល ហើយកូនបំណុលលក់ និង ប្រគល់ទៅឱ្យតតិយជនតាមទំនើងចិត្តនោះ) ប៉ុន្តែ ចំពោះអចលនវត្ថុវិញ គេនិយមប្រើប្រាស់ហ៊ីប៉ូតែកដោយសារកូនបំណុលនៅមានសិទ្ធិប្រើប្រាស់វត្ថុ (យ៉ាងណាមិញ ចំពោះចលនវត្ថុក៏ដោយ ក្នុងពេលថ្មីៗនេះ គេតែងប្រើប្រាស់ប្រាតិភោគដោយអនុប្បទានដែលនឹងលើកមករៀបរាប់នៅខាងក្រោយ)។

## 2. សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់

### (1) សិទ្ធិឃាត់ទុក

ឧបមាថា អតិថិជន A បានយកនាឡិកាដៃមកជួសជុលនៅក្នុងហាងនាឡិកា B ហើយថ្លៃជួសជុលអស់ចំនួន 40ម៉ឺនរៀល។ នៅពេលដែលជួសជុលរួចហើយ បើហាងនាឡិកា B ប្រគល់នាឡិកាដៃវិញទាំង A មិនទាន់បង់ប្រាក់ ក្នុងករណីនេះ ខ្លួននឹងបាត់បង់ការធានាដែលអាចទាមទារថ្លៃជួសជុលបាន (មធ្យោបាយដែលបង្ខំដោយប្រយោល)។ ហេតុដូច្នេះហើយ ក្រមរដ្ឋប្បវេណីបានកំណត់វិធានដែល B មិនចាំបាច់ប្រគល់វិញរហូតដល់ពេលទទួលបានការបង់ថ្លៃជួសជុល (មិនពាក់ព័ន្ធនឹងឆន្ទៈរបស់ភាគី)។ នេះគឺជា សិទ្ធិឃាត់ទុក នៅក្នុងប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់។ បើនិយាយជាភាសាច្បាប់គឺ «សិទ្ធិដែលអាចឃាត់ទុកវត្ថុនោះ ប្រសិនបើអ្នកកាន់កាប់ (ហាងនាឡិកា B) វត្ថុរបស់អ្នកដទៃ (នាឡិកាដៃ) មានសិទ្ធិលើបំណុលដែលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ (សិទ្ធិលើបំណុលលើថ្លៃជួសជុលចំនួន 40ម៉ឺនរៀល) រហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលនោះបាន» (ប៉ុន្តែ នៅក្នុងសិទ្ធិឃាត់ទុកនេះ មិនមានអានុភាពនៃការប្រមូលសិទ្ធិលើបំណុលដោយអាទិភាពពីថ្លៃលក់នៃកម្មវត្ថុដែលបានឃាត់ទុក នៅពេលប្តូរវត្ថុនោះជាប្រាក់នោះទេ (អានុភាពសងដោយអាទិ

ភាព)។ ដោយឡែក សូមប្រៀបធៀប សិទ្ធិឃាត់ទុកនេះ ទៅនឹងការតវ៉ាឱ្យអនុវត្តព្រមគ្នាដែលបានរៀបរាប់នៅក្នុងជំពូកទី4។ ⇒ជំពូកទី4 II.3(3))។

(2) **ឯកសិទ្ធិ**

ឧបមាថា ហាងលក់ទំនិញ Y កំពុងជួបវិបត្តិក្នុងការបង្វិលដើមទុន ហើយ Y មិនព្រមបង់ប្រាក់ខែចំនួន 8លានរៀល ទៅឱ្យ X ដែលបម្រើការងារនៅក្នុងហាងនោះ។ មួយវិញទៀត Y កំពុងជំពាក់ប្រាក់កម្ចីពីដៃគូជំនួញ Z ចំនួន 72លានរៀល ហើយ Z មានបំណងអនុវត្តដោយបង្ខំ (លក់ដោយបង្ខំនូវទ្រព្យសម្បត្តិ ហើយប្រមូលសិទ្ធិលើបំណុលពីប្រាក់ថ្លៃលក់នោះ) ទៅលើទ្រព្យសម្បត្តិរបស់ Y (មានត្រឹមតែចំនួន 40លានរៀលប៉ុណ្ណោះ) ដោយសារតែ Y មិនបានបង់ប្រាក់ បើទោះបីជាពេលកំណត់សងបានកន្លងផុតក៏ដោយ។ បើសិនជា X ចូលរួមចែកចំណែកដូចនេះ Z និង X ត្រូវបែងចែកនូវទ្រព្យសម្បត្តិរបស់ Y ។ ហើយបើយោងតាមគោលការណ៍សមភាពនៃម្ចាស់បំណុលនៅក្នុងច្បាប់អនុវត្តរដ្ឋប្បវេណីជប៉ុន ក្នុងករណីនេះ Z ត្រូវបានចំនួន 36លានរៀល ហើយ X ត្រូវបានចំនួន 4លានរៀល ពីទ្រព្យសម្បត្តិ 40លានរៀល របស់ Y ដោយសារតែ សមមាត្រនៃសិទ្ធិលើបំណុលរបស់ X និង Y គឺ 1 ភាគ 9។ ប៉ុន្តែ សិទ្ធិលើបំណុលនៃប្រាក់ខែ គឺជាសិទ្ធិលើបំណុលដែលពាក់ព័ន្ធនឹងជីវភាពរបស់ X ហេតុនេះ បើមើលពីទស្សនៈគោលនយោបាយសង្គម សិទ្ធិលើបំណុលនេះគួរតែរក្សាទុកឱ្យបានគ្រប់ចំនួនដល់ X។ ដូចនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពី «សិទ្ធិប្រាតិភោគប្រត្យក្សតាមការកំណត់របស់ច្បាប់ដែលបុគ្គលមានសិទ្ធិលើបំណុលជាក់លាក់ (នៅក្នុងឧទាហរណ៍ខាងលើនេះគឺ X) អាចទទួលបាននូវការសងសិទ្ធិលើបំណុលនោះ (នៅក្នុងឧទាហរណ៍ខាងលើនេះ គឺ 8លានរៀល ត្រូវទទួលបានការសងគ្រប់ចំនួនដោយអាទិភាព) ដោយអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត (Z) ពីទ្រព្យសម្បត្តិរបស់កូនបំណុល (Y)។ នេះហៅថា ឯកសិទ្ធិ។ ឯកសិទ្ធិនៅក្នុងក្រមរដ្ឋប្បវេណីមានកំណត់ចាប់ពីមាត្រា306 ប៉ុន្តែឯកសិទ្ធិនេះបែងចែកជា ឯកសិទ្ធិទូទៅដែលមានលើទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុល និងឯកសិទ្ធិលើចលនវត្ថុដែលមានអានុភាពទៅលើចលនវត្ថុជាក់លាក់របស់កូនបំណុល ព្រមទាំង ឯកសិទ្ធិលើអចលនវត្ថុដែលមានអានុភាពទៅលើអចលនវត្ថុជាក់លាក់របស់កូនបំណុល។ ទោះបីជាឯកសិទ្ធិទូទៅ ឬឯកសិទ្ធិលើចលនវត្ថុក៏ដោយ ក៏ម្ចាស់ឯកសិទ្ធិមិនអាចអនុវត្តបានទៀតទេ នៅក្រោយពេលកូនបំណុលបានប្រគល់កម្មវត្ថុទៅឱ្យតតិយជន (ពុំមាន «**អានុភាពទៅជាមួយ**» នោះទេ។ មាត្រា333)។

### 3. **ប្រាតិភោគដែលគ្មានច្បាប់កំណត់**

សិទ្ធិប្រាតិភោគប្រត្យក្សទាំង 4ប្រភេទដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីខាងលើនេះ គឺជាសិទ្ធិប្រាតិភោគដែលមានច្បាប់កំណត់ ហើយសិទ្ធិប្រាតិភោគក្រៅពីនេះពុំមានកំណត់ក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងបានបង្កើតនូវទម្រង់នៃប្រាតិភោគ ដែលម្ចាស់បំណុលអាចទទួលបានកម្មវត្ថុនៃប្រាតិភោគផ្ទាល់ ដើម្បីសងទៅលើសិទ្ធិលើបំណុលរបស់ខ្លួន (ឧទាហរណ៍ថា កូនបំណុលបានអនុប្បទានកម្មវត្ថុធានាឱ្យទៅម្ចាស់បំណុល ក្នុងគោលបំណងដាក់ធានាប៉ុណ្ណោះ ប៉ុន្តែ បើសិនជាកូនបំណុលមិនអាចសងបំណុលទេ ម្ចាស់បំណុលនឹងធ្វើលទ្ធកម្ម

សិទ្ធិនោះតែម្តង) នៅពេលដែលកូនបំណុលមិនអាចសងបំណុលបាន ហើយដែលត្រូវបានទទួលស្គាល់ដោយច្បាប់ទំនៀមទម្លាប់ និងយុត្តិសាស្ត្រ។ នេះហៅថា ប្រាតិភោគដែលគ្មានច្បាប់កំណត់។ ប្រាតិភោគទាំងនោះរួមមាន **ប្រាតិភោគដោយការចុះបញ្ជីបណ្តោះអាសន្ន ប្រាតិភោគដោយអនុប្បទាន** និង **ប្រាតិភោគដោយឃាត់កម្មសិទ្ធិ** (ប្រាតិភោគទាំងនេះ មិនមែនជាប្រភេទនៃសិទ្ធិប្រត្យក្សដែលទើបបង្កើតថ្មីនោះទេ ហេតុនេះ វាមិនផ្ទុយនឹងគោលការណ៍សិទ្ធិប្រត្យក្សដែលកំណត់ក្នុងច្បាប់នោះទេ។ ប្រាតិភោគដោយការចុះបញ្ជីបណ្តោះអាសន្ននៅក្នុងចំណោមនោះ ត្រូវបានបញ្ញត្តដោយច្បាប់ពិសេសហើយ)។ ជាពិសេស ប្រាតិភោគដោយអនុប្បទាន កាន់តែមានសារៈសំខាន់ខ្លាំងនៅក្នុងសង្គមពាណិជ្ជកម្មបច្ចុប្បន្ន។

### (1) ប្រាតិភោគដោយការចុះបញ្ជីបណ្តោះអាសន្ន

ឧបមាថា A បានចុះកិច្ចសន្យាឱ្យ B ខ្ចីប្រាក់ ហើយបើសិនជាដល់ពេលកំណត់ B មិនអាចសងបានទេ A នឹងទទួលបានកម្មសិទ្ធិលើវត្ថុដែលជារបស់ B ឬ របស់តតិយជន (អ្នកធានាដោយវត្ថុ) ជំនួសឱ្យការអនុវត្តដោយបង្ខំ។ ហើយត្រូវចុះបញ្ជីបណ្តោះអាសន្នជាមុនអំពី សិទ្ធិដែលរំពឹងទុកថានឹងទទួលបានការផ្ទេរកម្មសិទ្ធិលើវត្ថុនោះ។ នេះគឺជាទម្រង់នៃការធានាក្នុងពាណិជ្ជកម្មដែល គេហៅថា «ប្រាតិភោគដោយការចុះបញ្ជីបណ្តោះអាសន្ន»។ ជាក់ស្តែងភាគីអាចបង្កើតនូវកិច្ចសន្យាដូចជា «ការសន្យាជាមុននៃការសងដោយវត្ថុជំនួស» ឬ «កិច្ចសន្យាសងដោយវត្ថុជំនួសដែលមានភ្ជាប់លក្ខខណ្ឌបង្អង់» ដែលមានខ្លឹមសារថា «កូនបំណុលនឹងយកវត្ថុនេះមកសង បើសិនជាមិនអាចសងបំណុលបាន» ហើយលើសពីនេះអាចជា «ការសន្យាជាមុននូវការទិញលក់» ដែលមានខ្លឹមសារថា «កូនបំណុលនឹងលក់វត្ថុនេះឱ្យ បើសិនជាមិនអាចសងបំណុលបាន» ជាដើម (បើជាក់ស្តែងមិនបានចុះបញ្ជីបណ្តោះអាសន្នក៏ដោយ ក៏កិច្ចសន្យាមានសុពលភាពដែរ)។ ហើយភាគីនឹងជ្រើសរើសយកវិធីចុះបញ្ជីបណ្តោះអាសន្ន អំពីការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលជាលទ្ធផលនៃការចុះកិច្ចសន្យាខាងលើនេះ (ការចុះបញ្ជីបណ្តោះអាសន្នអាចបន្តទៅចុះបញ្ជីចម្បងនៅពេលដែលកូនបំណុលមិនអាចសងបាន ហើយការចុះបញ្ជីបណ្តោះអាសន្ននេះមានអានុភាពធានានូវលំដាប់អាទិភាពនៃការចុះបញ្ជី បើទោះបីជាកូនបំណុលបានចុះបញ្ជីផ្ទេរទៅឱ្យតតិយជនក្នុងអំឡុងពេលនោះក៏ដោយ)។ ការអនុវត្តវិធីបែបនេះ ត្រូវបានគេយកមកប្រើប្រាស់យ៉ាងទូលំទូលាយមួយរយៈពេលផងដែរ ដោយសារតែម្ចាស់បំណុលអាចធ្វើលទ្ធកម្មប្រាក់ បានច្រើនជាងប្រាក់ដែលបានឱ្យកូនបំណុលខ្ចី (ឧបមាថា ឱ្យខ្ចីទុនចំនួន 40 លានរៀល ហើយសន្យាទទួលយកការសងដោយវត្ថុជំនួសដែលមានតម្លៃ 80លានរៀល)។ ដូចនេះ ដើម្បីមិនឱ្យម្ចាស់បំណុលទទួលបានផលប្រយោជន៍ច្រើនហួសហេតុ ច្បាប់ស្តីពីប្រាតិភោគដោយការចុះបញ្ជីបណ្តោះអាសន្ន ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ1978 ហើយច្បាប់នេះបានដាក់ករណីយកិច្ចឱ្យម្ចាស់បំណុលត្រូវបង់ប្រាក់ដែលនៅសល់ពីតម្លៃនៃកម្មវត្ថុ និង តម្លៃនៃសិទ្ធិលើបំណុលដែលត្រូវបានធានា (ប្រាក់ជម្រះ)។

(2) **ប្រាតិភោគដោយអនុប្បទាន**

នៅពេលដែល A ឱ្យ B ខ្ចីប្រាក់ B ត្រូវធ្វើក្នុងទម្រង់ដែលអនុប្បទានកម្មសិទ្ធិលើវត្ថុឱ្យទៅ A ហើយពេលដែលកំណត់ពេលសងមកដល់ បើសិនជា B អាចសងបំណុលបាន A ត្រូវសងវត្ថុនោះមកវិញ ប៉ុន្តែ បើសិនជា B មិនអាចសងបំណុលបានទេ A ធ្វើលទ្ធកម្មលើវត្ថុនោះតែម្តង។ នេះជាប្រាតិភោគក្នុងទម្រង់ពាណិជ្ជកម្ម ដែលគេហៅថា « ប្រាតិភោគដោយអនុប្បទាន»។ ការអនុវត្តបែបនេះ ដើមឡើយគឺមានបញ្ហានៃភាពស្របច្បាប់ ដោយសារតែ វាជាទម្រង់ (ទិញលក់) គឺខុសខ្លាំងពីស្ថានភាពជាក់ស្តែង (ខ្ចីប្រាក់) ប៉ុន្តែ យុត្តិសាស្ត្រតុលាការ បានទទួលស្គាល់ថាមិនមែនជាសកម្មភាពដែលខុសនឹងគន្លងច្បាប់នោះទេ។ ប៉ុន្តែ ការអនុវត្តជាក់ស្តែងត្រូវបានធ្វើឡើងច្រើនពេក ហើយករណីភាគច្រើនបំផុត គឺម្ចាស់បំណុលទទួលបានផលប្រយោជន៍ច្រើនហួសហេតុ ដូចនេះ យុត្តិសាស្ត្រតុលាការបានដាក់ឱ្យ អ្នកទិញ (ម្ចាស់បំណុល) មានករណីយកិច្ចសងប្រាក់ជម្រះដូចករណីប្រាតិភោគដោយការចុះបញ្ជីបណ្តោះអាសន្នដែរ។ យ៉ាងណាមិញ នៅក្នុងពេលបច្ចុប្បន្ននេះក៏ដោយ ក៏អ្នកសិក្សាច្បាប់ជាច្រើនកំពុងតែខ្វែងគំនិតគ្នាត្រង់ចំណុចថា ប្រាតិភោគដោយអនុប្បទាននេះ ត្រូវមានទម្រង់ផ្លូវច្បាប់ជាការផ្ទេរកម្មសិទ្ធិ (ចាត់ទុកម្ចាស់បំណុល ថាជាកម្មសិទ្ធិករ។ ទម្រង់ផ្ទេរកម្មសិទ្ធិ) ឬ ត្រូវមានទម្រង់ផ្លូវច្បាប់ជាការបង្កើតសិទ្ធិប្រាតិភោគ (ចាត់ទុកថាម្ចាស់បំណុលទទួលបានតែសិទ្ធិប្រាតិភោគប៉ុណ្ណោះ។ ទម្រង់សិទ្ធិប្រាតិភោគ)។ គេយល់ថា យុត្តិសាស្ត្រតុលាការបានគាំទ្រនូវទម្រង់ផ្ទេរកម្មសិទ្ធិ ប៉ុន្តែ បន្ថែមការកែតម្រូវក្នុងនាមជាប្រាតិភោគទៅតាមភាពចាំបាច់។ ដោយឡែក ប្រាតិភោគដោយអនុប្បទាននេះ ត្រូវបានគេយកមកអនុវត្តទូលំទូលាយលើអចលនវត្ថុ និង ចលនវត្ថុ ព្រមទាំងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដូចជាសិទ្ធិលើបំណុលជាដើម ក្នុងនាមជាមធ្យោបាយផ្លូវច្បាប់ក្នុងការប្រមូលប្រាក់ទុន (បើសិនជាចលនវត្ថុ និង សិទ្ធិលើបំណុលវិញ គេតែងនិយមធ្វើក្នុងទម្រង់ប្រាតិភោគដោយអនុប្បទានលើចលនវត្ថុលក្ខណៈប្រមូលផ្តុំ ដែលដាក់ប្រាតិភោគនូវវត្ថុជាច្រើនរួមគ្នា ឬ ប្រាតិភោគដោយអនុប្បទាននូវសិទ្ធិលើបំណុលនាពេលអនាគត។ ក្នុងករណីនេះ គេបានជ្រើសរើសយកវិធីប្តូរលក្ខណៈនៃការកាន់កាប់ (⇒ជំពូកទី3 II.2(5)③) ធ្វើជាលក្ខខណ្ឌតតាំងចំពោះករណីចលនវត្ថុ ដែលវិធីនេះមិនអាចមើលឃើញការផ្លាស់ប្តូរពីខាងក្រៅទាល់តែសោះ ប៉ុន្តែ ប្រព័ន្ធនៃការចុះបញ្ជី អំពីការធ្វើអនុប្បទានចលនវត្ថុថ្មី ត្រូវបានបង្កើតឡើង ដោយអនុវត្តដូចគ្នាទៅនឹងប្រព័ន្ធនៃការចុះបញ្ជី អំពីការធ្វើអនុប្បទានសិទ្ធិលើបំណុល ដែលបានរៀបចំឡើងដោយការធ្វើវិសោធនកម្មច្បាប់ពិសេសស្តីពីការធ្វើអនុប្បទានសិទ្ធិលើបំណុលឆ្នាំ2004 (⇒ជំពូកទី6 5(4))។ តាមរយៈនេះ ចលនវត្ថុក៏ត្រូវបានធ្វើតាមវិធីបង្ហាញជាសាធារណៈយ៉ាងច្បាស់លាស់ដែរ។ ប៉ុន្តែ ការចុះបញ្ជីនេះ មានលក្ខខណ្ឌតតាំងស្របគ្នាទៅនឹងការប្រគល់ និង ការប្តូរលក្ខណៈនៃការកាន់កាប់ដែរ ហេតុនេះហើយ ឧបមាថា បើមានបុគ្គលណាដែលទទួលបានការប្តូរលក្ខណៈនៃការកាន់កាប់មុន នឹងទទួលបានអាទិភាពមុន។ យ៉ាងណាមិញ នៅក្នុងការវិសោធនកម្មនេះ បានផ្លាស់ប្តូរឈ្មោះច្បាប់នេះ ទៅជាច្បាប់ថ្មីស្តីពីការធ្វើអនុប្បទានចលនវត្ថុ និង សិទ្ធិលើបំណុល)។

### (3) ប្រាតិភោគដោយឃាត់កម្មសិទ្ធិ

ឧបមាថា **អ្នកលក់បង់រំលស់** A (ការលក់ដោយវិធីបង់រំលស់ជាដំណាក់កាលទៅតាមខែ ឬ ឆ្នាំ ជាដើម) បានចុះកិច្ចសន្យាលក់ទំនិញឱ្យទៅ B។ ក្នុងករណីនេះ ទំនិញបានប្រគល់ទៅឱ្យ B ភ្លាមៗ ប៉ុន្តែ កម្មសិទ្ធិនៃទំនិញនោះត្រូវឃាត់ទុកនៅ A រហូតដល់ពេលដែលបង់ប្រាក់បានគ្រប់ចំនួននាពេល 1ឆ្នាំក្រោយ (ក្នុងអំឡុងពេល 1ឆ្នាំនេះ ទោះបី Bប្រើប្រាស់វត្ថុនោះក៏ដោយ តែមិនមែនជាកម្មសិទ្ធិករនោះទេ)។ នេះគឺជាវិធីជានាដែលតម្រូវឱ្យ B បង់ប្រាក់ដែលនៅសល់ តាមរយៈការឃាត់ទុកកម្មសិទ្ធិ។ កិច្ចសន្យាបែបនេះ គឺមានសុពលភាព ហើយត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ។ ដើមឡើយ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពី ឯកសិទ្ធិនៃចលនវត្ថុ ដែលជាមធ្យោបាយដើម្បីធានានូវសិទ្ធិលើបំណុលថ្លៃលក់របស់អ្នកលក់នៃចលនវត្ថុដែលបានប្រគល់នោះ (មាត្រា311) ប៉ុន្តែ ភាគីតែងនិយមជ្រើសរើសយកមធ្យោបាយនៃការធ្វើការសន្យាពិសេស អំពីការមិនផ្ទេរកម្មសិទ្ធិរហូតដល់ពេលបង់ថ្លៃលក់គ្រប់ចំនួនដូចខាងលើនេះ ហើយនៅពេលដែលអ្នកទិញមិនបានបង់ថ្លៃគ្រប់ចំនួន អ្នកលក់នឹងរំលាយកិច្ចសន្យាលក់ទិញ ហើយទាមទារឱ្យប្រគល់កម្មវត្ថុវិញ ដោយផ្អែកលើកម្មសិទ្ធិ។ នេះហៅថា «ការឃាត់កម្មសិទ្ធិ»។ វាស្រដៀងគ្នានឹងប្រាតិភោគដោយអនុប្បទានដែរ ប៉ុន្តែ ខុសគ្នាត្រង់ថា អ្នកទិញមានឆន្ទៈធ្វើលទ្ធកម្មលើកម្មវត្ថុ មិនមែនជាការកម្ចីទុននោះទេ។ ទ្រឹស្តីជាច្រើនបានបកស្រាយខុសគ្នា ប៉ុន្តែ យុត្តិសាស្ត្រតុលាការបានបកស្រាយថា វិធីនេះមានទម្រង់ជាការផ្ទេរកម្មសិទ្ធិ (ពោលគឺ ចាត់ទុកថា អ្នកលក់នៅមានឋានៈជាកម្មសិទ្ធិករដដែល) ក្នុងនាមទំនាក់ទំនងគតិយុត្តខាងក្រៅ (ករណីដែលមានវិវាទជាមួយតតិយជនដែលបានទិញបន្តពីអ្នកទិញ)។

# ជំពូកទី 8 : នីតិញាតិ

I. **អត្ថន័យ និង ឋានៈនៃនីតិគ្រួសារ**

II. **ទិដ្ឋភាពទូទៅនៃនីតិញាតិ**

1. ខ្លឹមសារនៃនីតិញាតិ
2. ទស្សនៈស្តីពីញាតិ

III. **ចំណុចសំខាន់ៗនៃនីតិញាតិ**

1. អាពាហ៍ពិពាហ៍
2. ការលែងលះ
3. ឪពុកម្តាយនិងកូនបង្កើត · កូនចិញ្ចឹម
4. អំណាចមេបា អាណាព្យាបាល ហិតូបត្ថម្ភ និង ការទំនុកបម្រុង

## I. អត្ថន័យ និង ឋានៈនៃនីតិគ្រួសារ

បទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី នីតិសិទ្ធិប្រត្យក្ស និង នីតិសិទ្ធិលើបំណុល ដែលបានសិក្សានៅក្នុងជំពូកមុន គេហៅថា ផ្នែកស្តីពីនីតិទ្រព្យសម្បត្តិនៃក្រមរដ្ឋប្បវេណី។ ផ្ទុយមកវិញ ផ្នែកស្តីពីនីតិញាតិ (គន្ថីទី4 ញាតិ នៃក្រមរដ្ឋប្បវេណី) និង ផ្នែកស្តីពីនីតិសន្តតិកម្ម (គន្ថីទី5 សន្តតិកម្ម) ត្រូវបានគេហៅថា វិស័យនីតិគ្រួសារ (ពីមុនគេហៅថា នីតិឋានៈបុគ្គល)។ វិស័យនៃនីតិគ្រួសារនេះ ពិតជាមានសារៈសំខាន់ណាស់នៅក្នុងជីវភាពរស់នៅរបស់ប្រជាជន ប៉ុន្តែ វិស័យនេះមិនសូវបានដាក់បញ្ចូលទៅក្នុងវិញ្ញាសាប្រឡងវិជ្ជាជីវៈនានានោះទេ បើប្រៀបធៀបជាមួយវិស័យនីតិទ្រព្យសម្បត្តិ។ ប៉ុន្តែ ផ្នែកស្តីពីនីតិសន្តតិកម្ម មានខ្លឹមសារជាច្រើនដែលទាក់ទងជាមួយវិស័យនីតិទ្រព្យសម្បត្តិ ហើយផ្នែកមួយចំនួននៃនីតិញាតិក៏មានទំនាក់ទំនងជាមួយនឹងបញ្ហានៃនីតិទ្រព្យសម្បត្តិផងដែរ។ យើងគួរតែមានចំណេះដឹងអំពីវិស័យនេះជាមុនផងដែរ មុនពេលសិក្សាអំពីច្បាប់ស្តីពីពន្ធសន្តតិកម្ម ជាអាទិ៍។ នៅខាងក្រោមនេះ ខ្ញុំសាកល្បងរៀបរាប់ឱ្យងាយយល់អំពីផ្នែកស្តីពីនីតិគ្រួសារ ដោយផ្តោតសំខាន់លើចំណុចដែលទាក់ទងនឹងនីតិទ្រព្យសម្បត្តិ និង ចំណុចដែលបានរៀបរាប់ខាងលើនេះ។

## II. ទិដ្ឋភាពទូទៅនៃនីតិញាតិ

### 1. ខ្លឹមសារនៃនីតិញាតិ

នៅក្នុងគន្ថីស្តីពីញាតិនៃក្រមរដ្ឋប្បវេណីមានកំណត់អំពី ទស្សនៈស្តីពីញាតិ ក្នុងនាមជាបទប្បញ្ញត្តិទូទៅ, បន្ទាប់មកនៅក្នុងជំពូកទី2 ស្តីពីអាពាហ៍ពិពាហ៍ មានកំណត់អំពី ការបង្កើត មោឃភាពនិងការលុបចោល ព្រមទាំងអានុភាពនៃអាពាហ៍ពិពាហ៍ ហើយបន្ទាប់មកទៀតមានកំណត់អំពី ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ និង ការលែងលះ។ នៅក្នុងជំពូកទី3 ស្តីពីឪពុកម្តាយនិងកូន មានកំណត់អំពី កូនបង្កើតនិងកូនសុំ ហើយនៅក្នុងជំពូកទី4 ស្តីពីអំណាចមេបា, ជំពូកទី5 ស្តីពីអាណាព្យាបាល និង ជំពូកទី6 ស្តីពីហិតូបត្ថម្ភ និង ការទំនុកបម្រុង, ជំពូកទី7 ស្តីពីអាហារកាតព្វកិច្ច។ នៅក្នុងពេលថ្មីៗនេះ ជំពូកទី2: អាយុគ្រប់រៀបអាពាហ៍ពិពាហ៍ និង ជំពូកទី3: ការសុំកូនពិសេស មានការធ្វើវិសោធនកម្មយ៉ាងសំខាន់។

### 2. ទស្សនៈស្តីពីញាតិ

#### (1) ញាតិ និង ថ្នាក់ញាតិ

«ញាតិ» ដែលបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីរួមមាន ①ញាតិលោហិតក្នុង 6ថ្នាក់ ②សហព័ទ្ធ និង ③ញាតិពន្ធក្នុង 3ថ្នាក់ (មាត្រា725)។ ការកំណត់អំពីទំហំនៃញាតិនេះ មិនសូវជាមានតម្លៃនោះទេក្នុងពេលបច្ចុប្បន្ននេះ ប៉ុន្តែសូមយល់ទាំងអស់គ្នាអំពីវិធីរាប់ថ្នាក់ញាតិ ក្នុងនាមជាចំណេះដឹងទូទៅ។ ថ្នាក់ញាតិត្រូវកំណត់ដោយគណនាចំនួន

នៃតំណពូជរវាងញាតិ (មាត្រា726 កថាខណ្ឌទី1)។ ដូចនេះ អ្នក និង ឪពុក គឺជាញាតិថ្នាក់ទី1 ហើយអ្នក និង ជីតារបស់អ្នក គឺជាញាតិថ្នាក់ទី2។ ករណីខ្សែផ្ទាល់រវាងឪពុកនិងកូន ឬ ជីតានិងចៅ (បើក្នុងរូបទំនាក់ទំនងគ្រួសារ គឺជាខ្សែបញ្ឈរ) គឺងាយស្រួលរាប់នោះទេ។ ប៉ុន្តែ ករណីសាខាញាតិដូចជាបងប្អូនបង្កើត ឬ បងប្អូនជីដូនមួយវិញ (បើក្នុងរូបទំនាក់ទំនងគ្រួសារ គឺជាខ្សែផ្ដេក) ត្រូវរាប់លំដាប់តំណពូជឡើងទៅបុព្វញាតិរួម ហើយរាប់ចុះមកដល់បុគ្គលនោះ (មាត្រា726 កថាខណ្ឌទី2)។ ដូចនេះ ករណីរបស់បងប្អូនបង្កើត (បង—ឪពុកម្ដាយ—ប្អូន) គឺជាញាតិថ្នាក់ទី2 ហើយករណីរបស់បងប្អូនជីដូនមួយ (ឧបមាថា កូនរបស់ប្អូនរបស់ឪពុក) គឺ សាមីខ្លួន—ឪពុក—ជីដូនជីតា—ប្អូនរបស់ឪពុក—កូនរបស់ឪពុក) គឺជាញាតិថ្នាក់ទី4។

#### (2) **ញាតិលោហិត និង ញាតិពន្ធ**

ញាតិលោហិត សំដៅទៅលើក្រុមនៃបុគ្គលដែលមានបុព្វជនរួមគ្នា ពោលគឺមានចំណងលោហិតជាមួយគ្នាដូចជា ឪពុកនិងកូន ឬ បងនិងប្អូន ជាដើម។ ហើយទំនាក់ទំនងរវាងកូនចិញ្ចឹម (⇒ជំពូកនេះ III.3) និង ឪពុកម្ដាយចិញ្ចឹម ជាមួយនឹងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាព ដូចគ្នានឹងញាតិលោហិតគិតចាប់ពីថ្ងៃដែលបានសុំកូនកើតឡើង (មាត្រា727)។ ប៉ុន្តែ ទំនាក់ទំនងញាតិនេះនឹង ត្រូវបញ្ចប់ដោយការកាត់កាល់ (ការរំលាយកូនសុំ, មាត្រា729)។ ញាតិពន្ធ សំដៅទៅលើក្រុមនៃបុគ្គលដែលបានបង្កើតទំនាក់ទំនងតាមរយៈអាពាហ៍ពិពាហ៍ (⇒ជំពូកនេះ III.1) ដូចជា ប្អូនរបស់ប្រពន្ធ ឬ ម្ដាយរបស់ប្ដី ជាអាទិ៍។ ដូចនេះ ទំនាក់ទំនងញាតិពន្ធនេះ នឹងត្រូវបញ្ចប់ដោយការលែងលះ (មាត្រា728 កថាខណ្ឌទី1។ ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាងបានទទួលមរណភាព ហើយបុគ្គលដែលនៅរស់បានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ។ មាត្រាដដែល កថាខណ្ឌទី2)។ យ៉ាងណាមិញ ប្ដីប្រពន្ធត្រូវគិតជាឯកតារួមគ្នា នៅពេលរាប់ថ្នាក់ញាតិពន្ធ។

## III. **ចំណុចសំខាន់ៗនៃនីតិញាតិ**

### 1. **អាពាហ៍ពិពាហ៍**

#### (1) **ការបង្កើតអាពាហ៍ពិពាហ៍**

ចំពោះអាពាហ៍ពិពាហ៍ (ការរៀបការ) ត្រូវគោរពគោលការណ៍អាពាហ៍ពិពាហ៍តាមច្បាប់ មានន័យថា ប្ដីប្រពន្ធត្រូវបានគេចាប់ផ្ដើមទទួលស្គាល់ នៅពេលដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅសាលាក្រុង (មាត្រា739)។ ដូចនេះ ការបង្កើតអាពាហ៍ពិពាហ៍ គឺតម្រូវឱ្យបំពេញលក្ខខណ្ឌសារជាតុ ពោលគឺ ភាគីមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា (អាពាហ៍ពិពាហ៍ក៏ជាប្រភេទមួយនៃកិច្ចសន្យាផងដែរ) និង លក្ខខណ្ឌទម្រង់ ពោលគឺ ការដាក់ពាក្យ និងទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍។ បើសិនជាមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទេ ទោះបីជាពួកគេបាន

រៀបចំពិធីយ៉ាងអធិកអធមនៅក្នុងព្រះវិហារ ឬ វត្តអារ៉ាមតាមប្រពៃណីយ៉ាងណាក៏ដោយ ក៏ពួកគេអាចមានទំនាក់ទំនងត្រឹមអនីតិសង្វាសប៉ុណ្ណោះ តែមិនអាចក្លាយជាប្ដីប្រពន្ធស្របច្បាប់នោះទេ។ នៅប្រទេសជប៉ុន **អាយុគ្រប់រៀបអាពាហ៍ពិពាហ៍** ត្រូវបានកំណត់ថា ចំពោះបុរសគឺ 18ឆ្នាំ ហើយចំពោះនារីគឺ 16ឆ្នាំ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន (មាត្រា731) ប៉ុន្តែ អាយុគ្រប់រៀបអាពាហ៍ពិពាហ៍របស់នារី ត្រូវបានតំឡើងមក 18ឆ្នាំវិញ ចាប់ពីការដាក់ឱ្យអនុវត្តខ្លឹមសារវិសោធនកម្មក្រមរដ្ឋប្បវេណី នៅថ្ងៃទី1 ខែមេសា ឆ្នាំ2022 (ទន្ទឹមនឹងនេះ អាយុដល់នីតិភាពនៃបុរសនារី ក៏ត្រូវបានធ្វើវិសោធនកម្មប្ដូរមក 18ឆ្នាំ ផងដែរ)។ មានន័យថា នៅក្រោយពេលការអនុវត្តក្រមរដ្ឋប្បវេណីវិសោធនកម្ម ករណីដែលអនីតិជនរៀបអាពាហ៍ពិពាហ៍នៅប្រទេសជប៉ុននឹងលែងកើតមានបន្តទៅទៀត។ ជាមួយគ្នានេះផងដែរ បញ្ញត្តិដែលស្ដីពីការចាំបាច់ទទួលការយល់ព្រមពីឪពុកម្ដាយ នៅពេលអនីតិជនរៀបអាពាហ៍ពិពាហ៍ ក៏ត្រូវបាននិរាករណ៍ផងដែរ (កថាខណ្ឌទី1 មាត្រា737))។ ហើយទ្វេពន្ធភាពត្រូវបានហាមឃាត់ (មាត្រា732)។ ក្រៅពីនេះ កាលពីមុន គេបានកំណត់អំពីអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍សារជាថ្មីចំពោះនារី ក្នុងអំឡុងពេល 6ខែ គិតចាប់ពីថ្ងៃអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល (មាត្រា733 កថាខណ្ឌទី1 ចាស់, បញ្ញត្តិនេះធ្វើឡើង ដើម្បីជៀសវាងនូវបញ្ហានៃការកំណត់អំពីបិតុភាពចំពោះកូនដែលបានកើតមក)។ ប៉ុន្តែ សាលដីកាតុលាការកំពូលខែធ្នូ ឆ្នាំ2015 បានសម្រេចថា ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍សារជាថ្មីដែលលើសពី 100ថ្ងៃ គឺផ្ទុយនឹងរដ្ឋធម្មនុញ្ញ ហេតុនេះ នៅឆ្នាំ2016 អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍នេះត្រូវបានធ្វើវិសោធនកម្មមកត្រឹម 100ថ្ងៃវិញ (លើសពីនេះ មាត្រា733 កថាខណ្ឌទី2 ដែលកំណត់អំពី ករណីដែលអាចរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍សារជាថ្មី ត្រូវបានបង្កើតថ្មី)។ ហើយការរៀបអាពាហ៍ពិពាហ៍រវាងបុរសនារី ដែលមានទំនាក់ទំនងញាតិជិតគ្នាក្នុងទំហំជាក់លាក់មួយត្រូវបានហាមឃាត់ (មាត្រា734 កថាខណ្ឌទី1 ជាអាទិ៍)។ យ៉ាងណាមិញ ចំពោះការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិជិតគ្នានេះ គឺសំដៅទៅលើអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ (ឪពុក និង កូន ជាអាទិ៍) ឬ សាខាញាតិលោហិតក្នុង 3ថ្នាក់ (ឧទាហរណ៍ កូនរបស់បង និង ប្អូន ជាអាទិ៍) ត្រូវបានហាមឃាត់ (មាត្រា734 កថាខណ្ឌទី1។ ដូចនេះ ការរៀបអាពាហ៍ពិពាហ៍រវាងបងប្អូនជីដូនមួយដែលជាញាតិថ្នាក់ទី4 អាចធ្វើទៅបាន)។ កូនចិញ្ចឹម និង ឪពុកម្ដាយចិញ្ចឹម ក៏មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍រវាងគ្នាបានដែរ ដោយសារតែពួកគេកើតមានទំនាក់ទំនងញាតិលោហិតផ្ទាល់ចាប់ពីថ្ងៃសុំកូន។ ប៉ុន្តែ កូនចិញ្ចឹម និង កូនបង្កើតអាចរៀបអាពាហ៍ពិពាហ៍រវាងគ្នាបាន (មាត្រា734 កថាខណ្ឌទី1 វាក្យខណ្ឌទី1)។ លើសពីនេះ ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ (ឧទាហរណ៍ ឪពុកក្មេក និង កូនប្រសាស្រី) ក៏ត្រូវបានហាមឃាត់ដែរ ហើយត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាងបានទទួលមរណភាព ហើយបុគ្គលដែលនៅរស់បានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍ (មាត្រា735)។

### (2) នាមត្រកូលរបស់ប្ដីប្រពន្ធ

ក្រមរដ្ឋប្បវេណីបច្ចុប្បន្ននេះ បានកំណត់ឱ្យប្ដីប្រពន្ធជ្រើសរើសយកនាមត្រកូលរួម (ត្រកូល) នៅពេលរៀបអាពាហ៍ពិពាហ៍។ នេះគឺជា គោលការណ៍នាមត្រកូលរួមរបស់ប្ដីប្រពន្ធ (មាត្រា750)។ ចំណុចនេះមិនអាចនិយាយ

ជាផ្លូវការថា ផ្ទុយនឹងសមភាពនៃប្តីប្រពន្ធនោះទេ ប៉ុន្តែ បច្ចុប្បន្ននេះ ប្តីប្រពន្ធសឹងតែ 98% បានជ្រើសរើសយកនាមត្រកូលរបស់ប្តី។ នាពេលបច្ចុប្បន្ននេះ ការធ្វើវិសោធនកម្មច្បាប់ ដែលផ្តល់សិទ្ធិជ្រើសរើសនាមត្រកូលប្តីប្រពន្ធផ្សេងគ្នាក្រោយពេលរៀបការ ក្នុងករណីដែលប្តីប្រពន្ធនីមួយៗចង់រក្សានាមត្រកូលរៀងៗខ្លួន ត្រូវបានលើកយកមកពិភាក្សាដែរ ប៉ុន្តែ មិនអាចសម្រេចជាលទ្ធផលបាន ហើយសាលដីកាតុលាការកំពូលចុះខែធ្នូ ឆ្នាំ2015 បានបកស្រាយថា មាត្រា750 មានធម្មនុញ្ញភាព (ការសម្រេចដែលបន្សល់នៅមន្ទិលជាច្រើន)។

### (3) ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្តីប្រពន្ធអាចសម្រេចដោយសេរីនៅក្នុងកិច្ចសន្យា អំពីការចាត់ចែងទំនាក់ទំនងទ្រព្យសម្បត្តិនៅក្នុងអាពាហ៍ពិពាហ៍ (កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ប៉ុន្តែ ក្រមរដ្ឋប្បវេណីជប៉ុនបានកម្រិតនូវចំណុចមួយចំនួន ដូចជា កិច្ចសន្យាដែលមិនបានចុះបញ្ជីមុនពេលដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មិនអាចតតាំងនឹងប្រតិសិទ្ធិនៃប្តីប្រពន្ធ ឬតតិយជន (មាត្រា756) ហើយកិច្ចសន្យានេះមិនអាចផ្លាស់ប្តូរនោះទេ នៅក្រោយពេលដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ (មាត្រា758 កថាខណ្ឌទី1)។ ម្យ៉ាងទៀត ប្រសិនបើមិនបានបង្កើតកិច្ចសន្យាដោយឡែកមុនពេលដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទេ គេត្រូវអនុវត្តតាមបញ្ញត្តិនៃប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់នៅក្នុងក្រមរដ្ឋប្បវេណី ហើយករណីភាគច្រើននៅក្នុងប្រទេសជប៉ុន គឺអនុវត្តតាមប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់។

ករណីអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ គឺទ្រព្យសម្បត្តិដែលមានតាំងពីមុនអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដែលដាក់ឈ្មោះរបស់ខ្លួនឯង ត្រូវក្លាយជាទ្រព្យសម្បត្តិដោយឡែករបស់បុគ្គលដែលដាក់ឈ្មោះនោះ (បើដាក់ឈ្មោះប្តី គឺជារបស់ប្តី, បើដាក់ឈ្មោះប្រពន្ធ គឺជារបស់ប្រពន្ធ) ហើយទ្រព្យសម្បត្តិដែលមិនដឹងច្បាស់ថាជារបស់អ្នកណា ត្រូវសន្មតថា ជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ (មាត្រា762។ ពាក្យថា សន្មត គឺជាករណីដែលច្បាប់គិតថាមានន័យបែបនឹងជាមុនសិន ហើយភាគីអាចផ្លាស់ប្តូរការគិតបែបនេះ ដោយការបញ្ជាក់ផ្ទុយពីនេះ)។ នេះហៅថា ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក។

សោហ៊ុយអាពាហ៍ពិពាហ៍ ពោលគឺ សោហ៊ុយជីវភាពរបស់ប្តីប្រពន្ធ និង សោហ៊ុយចិញ្ចឹមកូនដែលមិនទាន់ពេញវ័យជាដើម ត្រូវទទួលបន្ទុកតាមចំណែកដោយប្តីប្រពន្ធ ដោយពិចារណាទៅលើទ្រព្យធន ចំណូល និង ចំណុចផ្សេងទៀតទាំងអស់ (ករណីយកិច្ចទទួលចំណែកបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍។ មាត្រា760។ ពាក្យថា សោហ៊ុយអាពាហ៍ពិពាហ៍ មិនមែនសំដៅលើសោហ៊ុយចំណាយលើពិធីអាពាហ៍ពិពាហ៍នោះទេ)។

### (4) ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចនៃកិច្ចការគ្រួសារប្រចាំថ្ងៃ

ក្រមរដ្ឋប្បវេណីបានកំណត់អំពី ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចនៃកិច្ចការគ្រួសារប្រចាំថ្ងៃ ក្នុងនាមជាការពន្លាតនូវប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ ទៅលើទំនាក់ទំនងខាងក្រៅរបស់ប្តីប្រពន្ធ។ ក្រមរដ្ឋប្បវេណី មាត្រា761 កំណត់ថា ប្រសិនបើប្តី ឬ ប្រពន្ធណាម្ខាង បានធ្វើសកម្មភាពគតិយុត្តដែលពាក់ព័ន្ធនឹងកិច្ច

ការគ្រួសារប្រចាំថ្ងៃជាមួយតតិយជន ប្ដី ឬ ប្រពន្ធម្ខាងទៀត ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច ដែលបានកើតឡើង តាមរយៈសកម្មភាពនោះ (ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែល ប្ដី ឬ ប្រពន្ធម្ខាងទៀតនោះ បានជូនដំណឹងជាមុនទៅកាន់តតិយជន អំពីការមិនទទួលខុសត្រូវ)។ បើសិនជាប្ដី ឬ ប្រពន្ធណាម្ខាងបានចំណាយ ឬ ខ្ចីប្រាក់ពីគេជាដើម សម្រាប់បំពេញតម្រូវការចំណីអាហារ សំលៀកបំពាក់ ឬ ការស្នាក់នៅ ដើម្បីទ្រទ្រង់ជីវភាពរួមរបស់ប្ដីប្រពន្ធ ហើយតាមរយៈនេះបានធ្វើឱ្យប្ដី ឬ ប្រពន្ធម្ខាងនោះមានកាតព្វកិច្ចចំពោះអ្នកដទៃ (កាតព្វកិច្ចដែលមានលក្ខណៈប្រចាំថ្ងៃ និង លក្ខណៈកិច្ចការគ្រួសារ) ក្នុងករណីនេះ ប្ដីប្រពន្ធទាំងសងខាងមានការទទួលខុសត្រូវដោយសាមគ្គីភាព នៅក្នុងការអនុវត្តកាតព្វកិច្ច។ ឧទាហរណ៍ ប្ដីក៏មានទំនួលខុសត្រូវផងដែរ ចំពោះការអនុវត្តកាតព្វកិច្ចដែលបង្កើតឡើងដោយប្រពន្ធ។ កាតព្វកិច្ចទាំងនោះមានដូចជា កាតព្វកិច្ចបង់ថ្លៃអគ្គិសនី កាតព្វកិច្ចបង់ថ្លៃឈ្នួល (ឈ្នួលផ្ទះ) និង កាតព្វកិច្ចបង់ថ្លៃទិញគ្រឿងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ជាដើម។ ពោលគឺ នេះគឺជាបញ្ញត្តិដែលផ្ដល់ការទទួលខុសត្រូវដោយសាមគ្គីភាពទៅលើសហព័ទ្ធម្ខាងទៀត ដើម្បីការពារដល់ភាគីម្ខាងទៀតនៃកិច្ចការជំនួញ ចំពោះកាតព្វកិច្ចដែលកើតចេញពីជីវភាពរួមរបស់ប្ដីប្រពន្ធ (ដោយសារតែលក្ខណៈជីវភាពរួម មិនអាចទទួលខុសត្រូវចំពោះកាតព្វកិច្ចបាន) ជៀសជាងកាតព្វកិច្ចរបស់ប្ដី ឬ ប្រពន្ធណាតែម្ខាង។ ដូចនេះ កាតព្វកិច្ចដែលសមស្របនឹងកាតព្វកិច្ចនៃកិច្ចការប្រចាំថ្ងៃ ត្រូវតែមានព្រំដែនច្បាស់លាស់ ហើយឧបមាថា សកម្មភាពចាត់ចែងអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់ប្ដី ឬ ប្រពន្ធណាម្ខាង មិនអាចក្លាយជាកិច្ចការគ្រួសារប្រចាំថ្ងៃឡើយ។

### (5) កិច្ចសន្យារវាងប្ដីប្រពន្ធ

បើសិនជាប្ដីប្រពន្ធបានចុះកិច្ចសន្យារវាងគ្នា ឧបមាថា កិច្ចសន្យាប្រទានកម្ម ក្នុងករណីនេះ ប្ដី ឬ ប្រពន្ធណាម្ខាង អាចលុបចោលកិច្ចសន្យាប្រទានកម្មនោះពេលណាក៏បានដែរ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (មាត្រា754)។ ហើយការអនុវត្តកិច្ចសន្យារវាងប្ដីប្រពន្ធ ត្រូវធ្វើឡើងតាមរយៈសេចក្ដីស្រលាញ់ និង សីលធម៌ មិនមែនការអនុវត្តដោយបង្ខំតាមផ្លូវច្បាប់នោះទេ ប៉ុន្តែ បញ្ញត្តិនេះរងការរិះគន់ជាច្រើនពីអ្នកច្បាប់។

### (6) កំជាប់ពាក្យ និង អនីតិសង្វាស

នៅក្នុងសង្គមទូទៅបានហៅ ការសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ (រៀបការ) ថា កំជាប់ពាក្យ ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីពុំមានបញ្ញត្តអំពី កំជាប់ពាក្យនោះទេ។ ដូចនេះ ការវាយតម្លៃនៃកំជាប់ពាក្យ គឺអាស្រ័យទៅលើយុត្តិសាស្ត្រ និង ទ្រឹស្ដី។ បើសិនជាបកស្រាយថា កំជាប់ពាក្យនេះគឺជា កិច្ចសន្យាដែលសន្យាជាមុនអំពីការរៀបអាពាហ៍ពិពាហ៍នាពេលអនាគត ក្នុងករណីនេះ ការបដិសេធតាមទំនើងចិត្តរបស់ភាគីម្ខាង គឺជាការមិនអនុវត្តកាតព្វកិច្ច (⇒ ជំពូកទី6)។ ហើយបើសិនជាបកស្រាយថា ការបដិសេធដោយចេតនា ឬ កំហុសនេះ បានបង្កការខូចខាតដោយមិនត្រឹមត្រូវចំពោះបុគ្គលផ្សេង (ជាទ្រព្យសម្បត្តិ ឬ ជាសតិអារម្មណ៍) ក្នុងករណីនេះ វានឹងក្លាយជាអំពើអនីត្យានុកូល (

⇒ជំពូកទី5)។ ទោះបីជាជ្រើសរើសយកការបកស្រាយណាមួយក៏ដោយ ក៏ការបដិសេធតាមទំនើងចិត្តរបស់ភាគីម្ខាង នឹងក្លាយជាកម្មវត្ថុនៃការផ្តល់សំណងការខូចខាត។

ការបង្កើតកំជាប់ពាក្យ មិនតម្រូវឱ្យគោរពតាមលក្ខខណ្ឌទម្រង់ណាមួយនោះទេ។ យ៉ាងណាមិញ នៅក្នុងសង្គមទូទៅ តែងនិយមប្រគល់ជំនូនផងដែរ។ ប៉ុន្តែ នេះគឺជាទំនៀមទម្លាប់ក្នុងសង្គមទូទៅប៉ុណ្ណោះ ហើយការបង្កើតកំជាប់ពាក្យនេះ មិនអាស្រ័យទៅលើការប្រគល់ជំនូន ឬ ការមិនប្រគល់ជំនូននោះទេ។ លក្ខណៈគតិយុត្តនៃជំនូន គឺជាប្រភេទមួយនៃប្រទានកម្ម ដើម្បីជាភស្តុតាងបញ្ជាក់អំពីការបង្កើតកំជាប់ពាក្យប៉ុណ្ណោះ។ ជាទូទៅ ជំនូននេះត្រូវបានប្រគល់ដើម្បីបញ្ជាក់អំពីការកំជាប់ពាក្យ រួមជាមួយនឹងគោលបំណងនៃការរៀបអាពាហ៍ពិពាហ៍នាពេលអនាគត ហេតុនេះហើយ ជំនូនត្រូវសងមកវិញ ប្រសិនបើកំជាប់ពាក្យបានរលាយ។ ជាគោលការណ៍ ការទាមទារឱ្យសងវិញនេះ ត្រូវធ្វើឡើងដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ (⇒ជំពូកទី5) ប៉ុន្តែ យុត្តិសាស្ត្របានបកស្រាយថា ការទាមទារឱ្យសងវិញនេះមិនអាចធ្វើបានឡើយ ប្រសិនបើការរលាយនៃកំជាប់ពាក្យនោះ កើតឡើងដោយសារទំនួលខុសត្រូវរបស់ភាគីដែលបានលើកជំនូន។ សូមពិចារណាថា វាគឺជាប្រភេទមួយនៃការដាក់ពិន័យ ហើយផលប្រយោជន៍ជាទ្រព្យសម្បត្តិដែលទទួលបានពីជំនូន ត្រូវចាត់ទុកថាជា សំណងនៃការខូចខាតនៃអំពើអនីត្យានុកូល ហើយភាគីម្ខាងទៀតអាចរក្សាទុកនូវជំនូននោះបាន (បើសិនជាការខូចខាតដែលកើតឡើងនោះ មានទំហំធំធេងជាងតម្លៃជាទ្រព្យសម្បត្តិនៃជំនូនដែលបានទទួល ភាគីម្ខាងទៀតនោះអាចទាមទារសំណងការខូចខាតបន្ថែមបាន)។

ពាក្យថា «អនីតិសង្វាស» ក៏មិនមែនជាពាក្យពេចន៍ដែលបញ្ញត្តក្នុងច្បាប់ផងដែរ។ នៅក្នុងចំណោមបុរសនារីដែលបានរស់នៅជីវភាពរួមគ្នាដោយមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ (ករណីដូចជា រស់នៅជាមួយគ្នាហើយរួមគ្នាទ្រទ្រង់ការចំណាយនានាក្នុងផ្ទះ) ចំពោះបុរសនារីដែលមានឆន្ទៈរៀបអាពាហ៍ ទោះបីជាមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏ត្រូវបានគេហៅថាជា អនីតិសង្វាស ផងដែរ(បើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍នោះទេ វាគ្រាន់តែជាការស្នាក់នៅរួមគ្នាធម្មតាប៉ុណ្ណោះ)។ បើសិនជាជ្រើសរើសយកគោលការណ៍អាពាហ៍ពាហ៍តាមច្បាប់ ក្នុងករណីនេះ បើទោះបីជាបុរសនារីនោះមានជីវភាពរួមគ្នាដូចជាប្តីប្រពន្ធយ៉ាងណាក៏ដោយ ក៏ពួកគេគ្រាន់តែមានទំនាក់ទំនងអនីតិសង្វាស បើមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ហើយពួកគេមិនអាចទទួលបានការការពារតាមផ្លូវច្បាប់នោះទេ។ ប៉ុន្តែ ការជ្រើសរើសយកគោលការណ៍នេះបានបង្កឱ្យមានបញ្ហា។ ហេតុនេះហើយ យុត្តិសាស្ត្រ និង ទ្រឹស្តីបានប្រឹងប្រែងរកវិធីផ្តល់ការការពារផ្លូវច្បាប់ដល់ភាគីអនីតិសង្វាស។ ទ្រឹស្តីបច្ចុប្បន្ននេះ បានចាត់ទុក អនីតិសង្វាសជាទំនាក់ទំនងឧបអាពាហ៍ពិពាហ៍ ហើយអះអាងថា ការបដិសេធទំនាក់ទំនងនេះត្រូវពិចារណាតាមបែបបទនៃអំពើអនីត្យានុកូល (គោលការណ៍ឧបអាពាហ៍ពិពាហ៍)។ បើនិយាយឱ្យច្បាស់ទៅ នេះមានន័យថា អនីតិសង្វាសដែលមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មិនអាចទទួលស្គាល់តាមអានុភាពនៃអាពាហ៍ពិពាហ៍ដែលអាចចុះជាសមាជិកក្នុងប័ណ្ណគ្រួសារឡើយ ប៉ុន្តែ តាមរយៈអានុភាពនៃការទទួលស្គាល់ជីវភាពរួមគ្នានេះ គេអាចអនុវត្តប្រដូចចំពោះចំណុចដូចជា ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក

ករណីយកិច្ចទទួលបន្ទុកចំណែកនៃសោហ៊ុយអាពាហ៍ពិពាហ៍ ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចនៃកិច្ចការផ្ទះប្រចាំថ្ងៃ និង ការបែងចែកទ្រព្យសម្បត្តិ ជាដើម។

## 2. **ការលែងលះ**

### (1) **នីតិវិធីនៃការលែងលះ**

បើសិនជាទំនាក់ទំនងអាពាហ៍ពិពាហ៍មិនចុះសម្រុងនឹងគ្នាទេ បញ្ហានៃការលែងលះនឹងកើតឡើង ហើយក្រមរដ្ឋប្បវេណីជប៉ុនមានបញ្ញត្តអំពី ការលែងលះតាមការព្រមព្រៀង ដែលអាចលែងលះដោយគ្រាន់តែមានការព្រមព្រៀងរបស់ភាគី (មាត្រា763) និង ការលែងលះតាមតុលាការ ដែលត្រូវមានការទទួលស្គាល់នៅក្នុងតុលាការ។ ចំពោះការលែងលះតាមតុលាការ ចាំបាច់ត្រូវមានមូលហេតុនៃការលែងលះដូចជា ការផិតក្បត់ ឬ ការបោះបង់ចោលសហព័ទ្ធដោយទុច្ចរិត ជាអាទិ៍ ហើយមូលហេតុធ្ងន់ធ្ងរផ្សេងទៀតដែលពិបាកនឹងបន្តអាពាហ៍ពិពាហ៍ ក៏ជាមូលហេតុនៃការលែងលះផងដែរ (មាត្រា770)។ នៅក្នុងចំណុចនេះ សាលដីកាពេញអង្គរបស់តុលាការកំពូលឆ្នាំ1987 បានសម្រេចថា ការទាមទារលែងលះពីបុគ្គលដែលមានទំនួលខុសត្រូវ ពោលគឺភាគីដែលមានការទទួលខុសត្រូវក្នុងការបង្កើតវិវាទលែងលះ ក៏អាចត្រូវបានទទួលស្គាល់ដែរ។ យ៉ាងណាមិញ ក្រៅពីនីតិវិធីទាំង 2ខាងលើនេះ ច្បាប់មានកំណត់អំពីនីតិវិធីនៃការលែងលះដោយសន្ទានកម្មនៅក្នុងតុលាការគ្រួសារ និង ការលែងលះដោយដីកាសម្រេចផងដែរ។

### (2) **ការបែងចែកទ្រព្យសម្បត្តិ**

ភាគីម្ខាងដែលបានលែងលះ អាចទាមទារឱ្យភាគីម្ខាងទៀតបែងចែកទ្រព្យសម្បត្តិបាន ហើយបើសិនជាភាគីមិនអាចពិភាក្សារវាងគ្នាបានទេ តុលាការគ្រួសារអាចកំណត់អំពីលទ្ធភាពនៃការបែងចែក និង ចំនួនដែលត្រូវបែងចែកបាន (មាត្រា768)។ នៅពេលបែងចែកទ្រព្យសម្បត្តិ តុលាការត្រូវពិចារណាទៅលើចំនួននៃទ្រព្យសម្បត្តិដែលប្តីប្រពន្ធបានធ្វើលទ្ធកម្មដោយសហការគ្នា និង ស្ថានភាពផ្សេងៗទៀត។

យ៉ាងណាមិញ ទំនាក់ទំនងនៃការបែងចែកទ្រព្យសម្បត្តិនេះ និង សំណងជម្ងឺចិត្ត អាចក្លាយជាបញ្ហា។ យើងអាចគិតថា មានករណីខ្លះនៃសំណងជម្ងឺចិត្តនៃការលែងលះអាចបញ្ចូលទៅក្នុងការបែងចែកទ្រព្យសម្បត្តិ ប៉ុន្តែ យុត្តិសាស្ត្រតុលាការបានសម្រេចថា ទោះបីជាការបែងចែកទ្រព្យសម្បត្តិបានធ្វើឡើងរួចហើយក៏ដោយ ក៏ការបែងចែកនេះមិនបានបញ្ចូលនូវសារជាតុនៃសំណងការខូចខាតនោះទេ ហេតុនេះ ភាគីរងគ្រោះនៅតែអាចទាមទារសំណងជំងឺចិត្តបន្ថែម ប្រសិនបើចំនួននៃទ្រព្យសម្បត្តិ ឬ វិធីបែងចែកមិនគ្រប់គ្រាន់ សម្រាប់ការខូចខាតផ្នែកស្មារតីរបស់ភាគីរងគ្រោះ។

លើសពីនេះ នៅក្នុងករណីមួយចំនួននៃការបែងចែកទ្រព្យសម្បត្តិតាមការពិភាក្សា គឺធ្វើឡើងដើម្បីលាក់ទ្រព្យសម្បត្តិប៉ុណ្ណោះ ឧបមាថា ប្តីបានលែងលះជាមួយប្រពន្ធ ហើយបែងចែកទ្រព្យសម្បត្តិទៅឱ្យប្រពន្ធ ដើម្បីបញ្ចៀសពី

ការទាមទាររបស់ម្ចាស់បំណុល ជាអាទិ៍។ ដូចនេះ បើសិនជាចំនួនទ្រព្យសម្បត្តិដែលបានបែងចែកនោះ មានទំហំលើសហួសហេតុពេកពីគោលបំណងក្នុងមាត្រា768 នៃក្រមរដ្ឋប្បវេណី និងមានហេតុពិសេសអំពីការចាត់ចែងទ្រព្យសម្បត្តិដោយបន្លំក្នុងរូបភាពបែងចែកទ្រព្យសម្បត្តិ ក្នុងករណីនេះ ទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកនោះនឹងក្លាយជាកម្មវត្ថុនៃការអនុវត្តសិទ្ធិលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ (មាត្រា424)។

### 3. ឪពុកម្តាយនិងកូនបង្កើត · កូនចិញ្ចឹម

#### (1) ឪពុកម្តាយ និង កូនបង្កើត

នៅក្នុងទំនាក់ទំនងឪពុកម្តាយនិងកូន រួមមាន កូនដែលចាប់កំណើតពីប្តីប្រពន្ធដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ គេហៅថា កូនមានខាន់ស្លា (មាត្រា772ដូចរៀបរាប់ខាងក្រោយនេះ បញ្ញត្តពីការសន្មតបិតុភាព និងការសន្មតភាពមានខាន់ស្លា) និង កូនដែលចាប់កំណើតពីបុរសនារីដែលមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ គេហៅថា កូនឥតខាន់ស្លា។ ដើមឡើយ កូនទាំង 2នេះ ត្រូវទទួលបានចំណែកសន្តតិកម្មខុសគ្នា (ចំពោះចំណែកសន្តតិកម្ម សូមយោងចំណុច III.2) ប៉ុន្តែ វិសោធនកម្មច្បាប់ឆ្នាំ2013 បានកែតម្រូវឱ្យទទួលបានចំណែកសន្តតិកម្មស្មើគ្នាវិញ។

ចំពោះទំនាក់ទំនងឪពុកម្តាយ និង កូនបង្កើត ពោលគឺ ទំនាក់ទំនងសាច់ឈាមនៃកូនដែលបានកើតចេញពីឪពុកម្តាយ អាចបែងចែកជា 2ករណី។ ករណីទី1 គឺជាទំនាក់ទំនងម្តាយ និង កូន ដែលករណីភាគច្រើនបំផុតយើងអាចបញ្ជាក់តាមរយៈអង្គហេតុនៃការសម្រាលកូននោះបាន ប៉ុន្តែ ករណីទី2 គឺជាទំនាក់ទំនងឪពុក និង កូន ដែលយើងអាចមានការលំពាក់ក្នុងការបញ្ជាក់ក្នុងករណីខ្លះ។ មាត្រា772 កថាខណ្ឌទី1 កំណត់ថា ទារកដែលនៅក្នុងផ្ទៃរបស់ប្រពន្ធដែលកំពុងមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី។ ការសន្មតនេះអាចផ្លាស់ប្តូរបានចំពោះតែការតវ៉ាដែលបានធ្វើឡើងក្នុងនីតិវិធីពិសេសដែលបានកំណត់ក្នុងច្បាប់ប៉ុណ្ណោះ (ការបដិសេធបិតុភាពដោយឪពុក។ មាត្រា774)។ ហើយផ្ទុយមកវិញ ប្រព័ន្ធស្តីពីការទទួលស្គាល់បានរៀបចំឡើង សម្រាប់ករណីកូនដែលចាប់កំណើតនៅពេលដែលម្តាយមិនបានរៀបអាពាហ៍ពិពាហ៍។ បុគ្គលដែលជាឪពុកអាចទទួលស្គាល់ទំនាក់ទំនងឪពុកកូនតាមការស្ម័គ្ររបស់ខ្លួនបាន ហើយនេះហៅថាការទទួលស្គាល់ដោយស្ម័គ្រចិត្ត ក្នុងករណីនេះ បុគ្គលដែលបានទទួលស្គាល់នោះ នឹងត្រូវបានសន្មតថាជា ឪពុក (មាត្រា779។ មាត្រាច្បាប់ ក៏មានកំណត់អំពីការទទួលស្គាល់ដោយម្តាយផងដែរ។ ប៉ុន្តែ នេះជាបញ្ញត្តិសម្រាប់ករណីពិសេសដែលម្តាយមិនអាចបញ្ជាក់អំពីអង្គហេតុពពោះ និង សម្រាលបាន ដូចជាករណីកូនវង្វេង ឬ កូនដែលត្រូវគេបោះបង់ចោល)។ ហើយកូន បច្ឆាញាតិរបស់កូននោះ ឬ អ្នកតំណាងដែលច្បាប់កំណត់របស់បុគ្គលទាំងនោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ ដើម្បីបញ្ជាក់អំពីទំនាក់ទំនងឪពុកនិងកូន តាមផ្លូវតុលាការបាន (មាត្រា787។ ការទទួលស្គាល់ដោយបង្ខំ)។

កូនដែលឥតខាន់ស្លាអាចទទួលបានឋានៈជាកូនមានខាន់ស្លាចំពោះ 2ករណី ដូចតទៅនេះ។ ករណីទីមួយគឺ កូនដែលឪពុកបានទទួលស្គាល់ ទទួលបានឋានៈជាកូនមានខាន់ស្លា តាមរយៈអាពាហ៍ពិពាហ៍របស់ឪពុកម្ដាយរបស់កូននោះ (មាត្រា789 កថាខណ្ឌទី1)។ ករណីទីពីរគឺ កូនដែលឪពុកម្ដាយបានទទួលស្គាល់ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ បានទទួលឋានៈជាកូនមានខាន់ស្លាចាប់ពីពេលដែលបានទទួលស្គាល់ (មាត្រា789 កថាខណ្ឌទី2)។

### (2) កូនចិញ្ចឹម

ប្រព័ន្ធដែលបង្កើតទំនាក់ទំនងកូនរបស់អ្នកដទៃដែលគ្មានជាប់សាច់ឈាម ឱ្យក្លាយជាកូនតាមផ្លូវច្បាប់របស់អ្នកតាមការព្រមព្រៀងរបស់ភាគី ហៅថា កូនចិញ្ចឹម (មាត្រា792)។ កូនចិញ្ចឹមទទួលឋានៈជាកូនមានខាន់ស្លា ប៉ុន្តែកូនចិញ្ចឹមនឹងមានឪពុកម្ដាយ 4នាក់ ដោយសារតែ កូនចិញ្ចឹមមិនកាត់ផ្ដាច់ទំនាក់ទំនងទាំងស្រុងជាមួយឪពុកម្ដាយបង្កើត និង ញាតិរបស់ខ្លួននោះទេ (កូនចិញ្ចឹមនោះនៅតែមានសិទ្ធិទទួលសន្តតិកម្ម នូវទ្រព្យសម្បត្តិពីឪពុកម្ដាយបង្កើតរបស់ខ្លួន។ ⇒ជំពូកទី9 II.1(1))។ ប៉ុន្តែ មានបុគ្គលខ្លះចង់ចិញ្ចឹមបីបាច់កូនដែលទើបតែកើតរបស់អ្នកដទៃក្នុងនាមជាកូនរបស់ខ្លួនឯង ហើយចង់រំលត់ទំនាក់ទំនងកូននោះជាមួយនឹងឪពុកម្ដាយ និង ញាតិរបស់កូននោះតែម្ដង ហេតុនេះហើយ នៅឆ្នាំ1987 ប្រទេសជប៉ុនបានបង្កើតនូវប្រព័ន្ធសុំកូនពិសេស ដើម្បីបំពេញតម្រូវការនេះ (ក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា817.2)។ ហើយជាគោលការណ៍ កូននោះត្រូវមានអាយុតិចជាង 15ឆ្នាំ ហើយត្រូវបង្កើតទំនាក់ទំនងកូនសុំនេះ ដោយដីកាសម្រេចរបស់តុលាការគ្រួសារ (វាក្យខណ្ឌទី1 កថាខណ្ឌទី1 នៃមាត្រា817.5 នៃច្បាប់វិសោធនកម្មក្រមរដ្ឋប្បវេណីដែលអនុវត្តនៅថ្ងៃទី1 ខែមេសា ឆ្នាំ2020។ ហើយបទបញ្ញត្តិដែលកំណត់ឱ្យកូនសុំត្រូវមានអាយុក្រោម 6ឆ្នាំ ត្រូវបានដំឡើងយ៉ាងច្រើនមកអាយុក្រោម 15ឆ្នាំវិញ។ លើសពីនេះទៅទៀត បើសិនជាអាចបំពេញលក្ខខណ្ឌពិសេសផ្សេងទៀត ការសុំកូនអាចទទួលស្គាល់រហូតដល់អាយុក្រោម 18ឆ្នាំ។ (វាក្យខណ្ឌទី2 កថាខណ្ឌទី1 នៃមាត្រា817.5)។ចំពោះករណីសុំកូនពិសេសនេះ ទំនាក់ទំនងរបស់កូននោះជាមួយនឹងឪពុកម្ដាយបង្កើតត្រូវបាត់បង់ (សិទ្ធិសន្តតិកម្មក៏បាត់បង់ដែរ) ហើយការកត់ត្រាជាសមាជិកក្នុងប័ណ្ណគ្រួសារ ក៏ត្រូវបានប្រើប្រាស់វិធីខុសពីកូនចិញ្ចឹមទូទៅ ដើម្បីធ្វើយ៉ាងណាមិនឱ្យដឹងយ៉ាងងាយស្រួលថាកូននោះជាកូនចិញ្ចឹមឡើយ (យ៉ាងណាមិញ ការស្នើសុំចុះសំបុត្រកំណើតចំពោះកូនរបស់អ្នកដទៃដែលទើបតែកើតភ្លាមៗ ក្នុងនាមជាកូនបង្កើតរបស់ខ្លួន ពោលគឺ «ការបន្លំជាកូនបង្កើត» គឺមិនអាចបង្កើតទំនាក់ទំនងឪពុកម្ដាយនិងកូនបង្កើតនោះទេ ដោយសារតែការស្នើសុំចុះសំបុត្រកំណើតត្រូវមោឃភាព។ ប៉ុន្តែ ទ្រឹស្ដីច្បាប់ និង សាលក្រមរបស់តុលាការជាន់ទាបបានសម្រេចទទួលស្គាល់អានុភាពនៃការស្នើសុំនោះ ក្នុងនាមជាការស្នើសុំបង្កើតទំនាក់ទំនងកូនសុំ។ ដោយឡែក តុលាការកំពូលបានបដិសេធការបកស្រាយបែបនេះ)។

ទំនាក់ទំនងឪពុកម្ដាយ និងកូនចិញ្ចឹមតាមរយៈការសុំកូនធម្មតា អាចបញ្ចប់ដោយការកាត់កាល់បាន (ផ្ទុយមកវិញ ទំនាក់ទំនងឪពុកម្ដាយ និងកូនចិញ្ចឹមតាមរយៈការបង្កើតសុំកូនពិសេស ជាគោលការណ៍មិនអាចរំលត់ដោយការកាត់កាល់នោះទេ។ មាត្រា817.10 កថាខណ្ឌទី2។ ដោយសារតែ សុំកូនពិសេសមានបំណងបង្កើតទំនាក់

ទំនងឱ្យដូចជាឪពុកម្ដាយនិងកូនបង្កើតរវាងភាគី)។ គោលគំនិតនៃការកាត់កាល់ ដូចគ្នានឹងការលែងលះផងដែរ ដោយសារការកាត់កាល់នេះ រួមមានការកាត់កាល់តាមការព្រមព្រៀង និង ការកាត់កាល់តាមតុលាការ។ ក្រោយពេលដែលភាគីនៃការសុំកូនណាម្ខាងបានទទួលមរណភាព ហើយភាគីម្ខាងទៀតដែលនៅរស់ អាចស្នើសុំការអនុញ្ញាតពីតុលាការគ្រួសារ ដើម្បីកាត់កាល់បាន (មាត្រា811 កថាខណ្ឌទី6។ គេហៅថា ការកាត់កាល់ក្រោយមរណភាព)។

## 4. **អំណាចមេបា អាណាព្យាបាល ហិតូបត្ថម្ភ និង ការទំនុកបំរុង**

### (1) **សញ្ញាណទូទៅ**

ទិសដៅនៃនីតិគ្រួសារសម័យទំនើប គឺ ការពារកូន ការពារសហព័ទ្ធ និង ការពារចាស់ជរានៅក្នុងគ្រួសារ។ ប្រទេសជប៉ុនបានវិវត្តន៍ទៅរកសង្គមដែលសម្បូរចាស់ជរា ហេតុនេះ បញ្ហាស្ដីពីអាណាព្យាបាល និង ការទំនុកបំរុងត្រូវពិចារណាឡើងវិញពីជ្រុងមួយផ្សេង (នេះគឺជាបញ្ហាពាក់ព័ន្ធនឹងអាណាព្យាបាលលើនីតិជន ហើយចំណុចនេះត្រូវបានធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីនៅខែធ្នូ ឆ្នាំ1999 ហើយដាក់ឱ្យអនុវត្តនៅខែមេសា ឆ្នាំ2000។ ដូចនេះ គេបានពិចារណាពីគោលគំនិតនៃជីវភាពធម្មតា ដែលជាគោលគំនិតក្នុងការបង្កើតសង្គមមួយដែលគោរពឆន្ទៈរបស់សាមីខ្លួន និង សិទ្ធិសម្រេចដោយខ្លួនឯង ព្រមទាំងអាចឱ្យបុគ្គលដែលមានពិការភាព ក៏អាចរស់នៅជីវភាពធម្មតានៅក្នុងផ្ទះ និង ក្នុងតំបន់ជាមួយមនុស្សទូទៅ)។

### (2) **អំណាចមេបា**

<u>① អំណាចមេបា និង អ្នកមានអំណាចមេបា</u>

កូនដែលមិនទាន់ដល់នីតិភាព ត្រូវស្ថិតនៅក្រោមអំណាចមេបា (មាត្រា818)។ មានន័យថា ស្ថិតនៅក្រោមការថែរក្សា ការអប់រំ និង ការគ្រប់គ្រងទ្រព្យសម្បត្តិពីឪពុកម្ដាយ។ យ៉ាងណាមិញ កន្លងមកយើងមានប្រព័ន្ធមួយដែលកូនជាអនីតិជនត្រូវចាត់ទុកថាដល់នីតិភាពដោយការរៀបអាពាហ៍ពិពាហ៍ (មាត្រា753) ហើយនៅក្នុងករណីនេះ កូននោះនឹងរួចផុតពីអំណាចមេបា (ការចាត់ទុកជានីតិជន)។ ដូចបានរៀបរាប់ខាងលើនេះ អាយុដល់នីតិភាពទាំងបុរសទាំងនារីត្រូវបានធ្វើវិសោធនកម្មដោយប្ដូរមកអាយុ18ឆ្នាំ ហើយអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍របស់នារី ក៏ត្រូវដំឡើងមក 18ឆ្នាំផងដែរ នៅក្នុងការអនុវត្តវិសោធនកម្មក្រមរដ្ឋប្បវេណីថ្ងៃទី1 ខែមេសា ឆ្នាំ2022។ ហេតុនេះ ស្ថានភាពដែលអនីតិជនរៀបអាពាហ៍ពិពាហ៍នឹងលែងកើតមាន ហើយបញ្ញត្តិនេះក៏ត្រូវបាននិរាករណ៍។

បុគ្គលដែលមានអំណាចមេបា គឺជាឪពុកម្ដាយរបស់អនីតិជននោះ (មាត្រា818 កថាខណ្ឌទី1)។ មិនត្រឹមតែឪពុកម្ដាយបង្កើតនោះទេ ឪពុកម្ដាយចិញ្ចឹមក៏មានសិទ្ធិអំណាចមេបាផងដែរ (មាត្រា818 កថាខណ្ឌទី2)។ ទ្រឹស្ដីបានយល់ឃើញខុសគ្នាត្រង់ចំណុចថា បើសិនជាឪពុកម្ដាយចិញ្ចឹមមានអំណាចមេបា តើឪពុកម្ដាយបង្កើតបាត់បង់អំណាចមេបាដែរឬទេ? ឬក៏ គ្រាន់តែឪពុកម្ដាយចិញ្ចឹមមានអាទិភាពជាងប៉ុណ្ណោះ។ ប៉ុន្តែ មិនមែនឪពុកម្ដាយគ្រប់

របស់ខ្លួនតែអាចក្លាយជាអ្នកមានអំណាចមេបានោះទេ។ នៅពេលដែលឪពុក ឬ ម្តាយខ្លួនឯងគឺជាអនីតិជន អ្នកមានអំណាចមេបារបស់ឪពុក ឬ ម្តាយ (ឬ អ្នកអាណាព្យាបាល) ត្រូវអនុវត្តសិទ្ធិអំណាចមេបាជំនួស (មាត្រា833 និង មាត្រា867 កថាខណ្ឌទី1)។ បើសិនជាឪពុក ឬ ម្តាយដែលត្រូវបានចាត់ទុកថាជា ជនដែលហាមមិនឱ្យចាត់ចែងទ្រព្យសម្បត្តិបានដោយផ្អែកលើក្រមរដ្ឋប្បវេណីចាស់ ទ្រឹស្តីភាគច្រើនបកស្រាយថា បុគ្គលទាំងនោះក៏មិនអាចអនុវត្តសិទ្ធិអំណាចមេបាបានដែរ ប៉ុន្តែ ចំណុចទាំងនេះពុំបានបញ្ញត្តក្នុងច្បាប់នោះទេ (យុត្តិសាស្ត្រតុលាការបានបកស្រាយបន្ថែមថា ឧបជនដែលហាមមិនឱ្យចាត់ចែងទ្រព្យសម្បត្តិបាន ក៏មិនអាចអនុវត្តអំណាចមេបាបានឡើយ)។

② ខ្លឹមសារនៃសិទ្ធិអំណាចមេបា

ខ្លឹមសារនៃសិទ្ធិអំណាចមេបារួមមាន ទីមួយគឺ **បីបាច់ថែរក្សារូបកាយ** ពោលគឺ ការគ្រប់គ្រង ថែរក្សា និង អប់រំ ហើយអំណាចនេះគឺជាសិទ្ធិផង និង ករណីយកិច្ចផងរបស់ឪពុកម្តាយ (មាត្រា820)។ ទីពីរគឺ **គ្រប់គ្រងទ្រព្យសម្បត្តិ** ពោលគឺ គ្រប់គ្រងទ្រព្យរបស់កូន ហើយតំណាងឱ្យកូននោះ ចំពោះសកម្មភាពគិតយុត្តពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនោះ (សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ។ មាត្រា824)។ ប៉ុន្តែ បើសិនជាសកម្មភាពណាដែលបង្កើតឱ្យមានកាតព្វកិច្ចដែលកូនត្រូវអនុវត្ត អ្នកមានអំណាចមេបាត្រូវទទួលការយល់ព្រមពីកូនដែលជាសាមីខ្លួន (មាត្រាដដែល។ ឧទាហរណ៍ ការចុះកិច្ចសន្យាដែលតម្រូវឱ្យកូនទៅសំដែងក្នុងភាពយន្តជាដើម ឪពុកម្តាយមិនអាចចុះកិច្ចសន្យាដោយគ្មានការយល់ព្រមពីកូននោះទេ)។ ពាក្យថា «តំណាង» នៅក្នុងមាត្រា842 មានអត្ថន័យដូចគ្នានឹងការតំណាងទូទៅ។ មានន័យថា អ្នកដែលមានអំណាចមេបា (មិនមែនជាអ្នកតំណាងតាមរយៈកិច្ចសន្យាប្រគល់សិទ្ធិតំណាងនោះទេ ប៉ុន្តែ ច្បាប់បានប្រគល់ឋានៈក្នុងនាមជាអ្នកតំណាង) គឺជាអ្នកតំណាងដែលច្បាប់បានកំណត់របស់កូន។ ជាគោលការណ៍ អ្នកមានអំណាចមេបាអាចគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់កូន ប៉ុន្តែ មិនមានអំណាចទៅលើទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបាបានអនុញ្ញាតឱ្យចាត់ចែងដោយកំណត់គោលបំណង (មាត្រា5) និង ទ្រព្យសម្បត្តិអាជីវកម្មដែលកំពុងគ្រប់គ្រងដោយកូនដែលបានទទួលការអនុញ្ញាតឱ្យធ្វើអាជីវកម្ម (មាត្រា6)។

③ សកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា

ឧទាហរណ៍ ចំពោះសកម្មភាពដែលយកទ្រព្យសម្បត្តិរបស់កូនទៅប្រទានកម្មឱ្យអ្នកមានអំណាចមេបា វានឹងផ្តល់ប្រយោជន៍ដល់អ្នកមានអំណាចមេបា ប៉ុន្តែ វានាំឱ្យបាត់បង់ផលប្រយោជន៍ដល់កូន។ សកម្មភាពដែលមានផលប្រយោជន៍ផ្ទុយគ្នារវាងឪពុក ឬ ម្តាយដែលមានអំណាចមេបា ជាមួយនឹងកូនបែបនេះ ហៅថា សកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា។ ចំពោះសកម្មភាពដែលមានផលប្រយោជន៍ផ្ទុយគ្នានេះ បុគ្គលដែលមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការគ្រួសារ ជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូន (មាត្រា826 កថាខណ្ឌទី1)។ ចំណុចនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនមានច្រើននាក់ ហើយផលប្រយោជន៍របស់កូនណាម្នាក់ផ្ទុយគ្នានឹងផលប្រយោជន៍របស់កូនផ្សេងទៀត (មាត្រា826 កថាខណ្ឌទី2)។

④ ការដកហូត និង ការព្យួរអំណាចមេបា

នៅក្នុងឆ្នាំ2011 គេបានបង្កើតនូវយន្តការ 2 ដើម្បីការពារដល់ការរំលោភកបំពានលើកុមារ។ ទីមួយគឺ យន្តការនៃការសម្រេចដកហូតអំណាចមេបា ក្នុងករណីដែលមានការអនុវត្តអំណាចមេបាដោយប៉ះពាល់យ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់កូន ដូចជា ឪពុកម្តាយបានបោះបង់កូនចោលដោយបំពាន ឬ ដោយទុច្ចរិតជាអាទិ៍ (មាត្រា834)។ ទីពីរគឺ យន្តការនៃការសម្រេចព្យួរអំណាចមេបា ដែលអាចកម្រិតអំណាចមេបាក្នុងរយៈពេលតិចជាង 2ឆ្នាំ ក្នុងករណីដែលការអនុវត្តអំណាចមេបាជួបការលំបាក ឬ មិនត្រឹមត្រូវ ហើយប៉ះពាល់ដល់ផលប្រយោជន៍របស់កូន (មាត្រា834.2)។

### (3) ប្រព័ន្ធអាណាព្យាបាល ហិតូបត្ថម្ភ និង ទំនុកបម្រុង

① និយមន័យ

ប្រព័ន្ធអាណាព្យាបាល គឺជាប្រព័ន្ធដែលបង្កើតឡើងដើម្បីការពារដល់អនីតិជនដែលមិនអាចទទួលបានការការពារដោយអំណាចមេបា និង នីតិជននៅក្រោមអាណាព្យាបាល (ជនដែលហាមមិនឱ្យចាត់ចែងទ្រព្យសម្បត្តិនៅក្នុងច្បាប់ចាស់)។ បុគ្គលដែលអនុវត្តមុខងារអាណាព្យាបាល ហៅថា អ្នកអាណាព្យាបាល។ ដូចនេះ អនីតិជនត្រូវអមដោយអ្នកមានអំណាចមេបាក្នុងនាមជាអ្នកតំណាងតាមច្បាប់កំណត់ និងត្រូវអមដោយអ្នកអាណាព្យាបាលរបស់អនីតិជន ក្នុងករណីដែលគ្មានអ្នកមានអំណាចមេបា ឬ អ្នកអំណាចមេបាគ្មានសិទ្ធិគ្រប់គ្រង។ អ្នកអាណាព្យាបាល ក៏ជាអ្នកតំណាងដែលច្បាប់កំណត់ដែរ។ នីតិជននៅក្រោមអាណាព្យាបាលត្រូវតែអមដោយអ្នកអាណាព្យាបាលជានិច្ច។ ហើយគេអាចបន្ថែម អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ដើម្បីពិនិត្យលើអ្នកអាណាព្យាបាលបាន (ចាប់ពីមាត្រា848)។ ផ្ទុយមកវិញ ប្រព័ន្ធហិតូបត្ថម្ភ គឺជាប្រព័ន្ធដែលបង្កើតឡើងសម្រាប់ការពារដល់ជននៅក្រោមហិតូបត្ថម្ភ (ឧបជនដែលហាមមិនឱ្យចាត់ចែងទ្រព្យសម្បត្តិនៅក្នុងច្បាប់ចាស់) ហើយបុគ្គលដែលអនុវត្តមុខងារហិតូបត្ថម្ភ ហៅថា ហិតូបត្ថម្ភកៈ។ សូមបញ្ជាក់ថា នៅក្នុងច្បាប់ចាស់ ហិតូបត្ថម្ភកៈមានសិទ្ធិអំណាចត្រឹមតែផ្តល់ការយល់ព្រម នៅពេលដែលឧបជនដែលហាមមិនឱ្យចាត់ចែងទ្រព្យសម្បត្តិធ្វើសកម្មភាពជាក់លាក់ណាមួយប៉ុណ្ណោះ ប៉ុន្តែ នៅក្នុងច្បាប់ថ្មី ហិតូបត្ថម្ភកៈមានទាំងសិទ្ធិលុបចោលសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើដោយគ្មានការយល់ព្រម និងសិទ្ធិតំណាងចំពោះសកម្មភាពជាក់លាក់ណាដែលភាគីបានជ្រើសរើស។ យ៉ាងណាមិញ នៅក្នុងច្បាប់ថ្មីក៏បានបញ្ចូលនូវប្រព័ន្ធថ្មីដែលជាប្រព័ន្ធទំនុកបម្រុង។ ហើយប្រព័ន្ធនេះ មានគោលបំណងការពារដល់បុគ្គលដែលមានសម្ថភាពក្នុងការវិនិច្ឆ័យមិនពេញលេញ ដោយសារតែវិបត្តិផ្នែកស្មារតីកម្រិតទាប ហើយមិនទទួលបានការការពារពីច្បាប់ចាស់ (ចំពោះចំណុចខាងលើនេះ សូមយោងខ្លឹមសារនៅក្នុងជំពូកស្តីពី បទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ⇒ជំពូកទី2 II.2(3))។

② ការចាប់ផ្ដើមអាណាព្យាបាល

អាណាព្យាបាលនឹងចាប់ផ្ដើម នៅពេលដែលពុំមានបុគ្គលដែលអនុវត្តអំណាចមេបាចំពោះអនីតិជន ឬ បុគ្គលដែលអនុវត្តអំណាចមេបាគ្មានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ ឬ នៅពេលដែលមានដីកាសម្រេចចាប់ផ្ដើមអាណាព្យាបាល ចំពោះនីតិជននៅក្រោមអាណាព្យាបាល (មាត្រា838)។

③ ការជ្រើសរើសអ្នកអាណាព្យាបាល និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល

បុគ្គលដែលមានអំណាចមេបាចុងក្រោយ អាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន នៅក្នុងមតកសាសន៍បាន។ ឪពុក ឬ ម្ដាយណាម្ខាងដែលមានអំណាចមេបា ប៉ុន្តែគ្មានសិទ្ធិគ្រប់គ្រង អាចកំណត់ឪពុក ឬ ម្ដាយម្ខាងទៀតធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបាន (មាត្រា839)។ ប្រសិនបើគ្មានការកំណត់ដូចខាងលើនេះទេ តុលាការគ្រួសារអាចជ្រើសរើសអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អនីតិជននៅក្រោមអាណាព្យាបាល ឬ ញាតិ និង អ្នកមានទំនាក់ទំនងផលប្រយោជន៍ផ្សេងទៀតរបស់អនីតិជននោះ (មាត្រា840)។ ចំពោះអ្នកអាណាព្យាបាលសម្រាប់នីតិជនវិញ តុលាការគ្រួសារត្រូវជ្រើសរើសដោយឆន្ទានុសិទ្ធិ នៅពេលដែលសម្រេចសេចក្ដីអំពីការចាប់ផ្ដើមអាណាព្យាបាល។ ទោះបីជាអ្នកអាណាព្យាបាលសម្រាប់នីតិជនត្រូវបានជ្រើសតាំងក៏ដោយ ក៏នៅពេលដែលចាំបាច់ តុលាការគ្រួសារអាចជ្រើសរើសអ្នកអាណាព្យាបាលសម្រាប់នីតិជនបន្ថែមដោយឆន្ទានុសិទ្ធិ ឬ តាមការទាមទាររបស់នីតិជននៅក្រោមអាណាព្យាបាល ឬ ញាតិ និង អ្នកមានទំនាក់ទំនងផលប្រយោជន៍ផ្សេងទៀតរបស់នីតិជននោះ ឬ អ្នកអាណាព្យាបាលសម្រាប់នីតិជនខ្លួនឯង (មាត្រា843)។ ហើយវិធីជ្រើសរើសអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវកំណត់ដោយបុគ្គលដែលអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ តាមការជ្រើសតាំងរបស់តុលាការគ្រួសារ។ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់នីតិជន ត្រូវជ្រើសតាំងដោយតុលាការគ្រួសារ (ចាប់ពីមាត្រា848)។

④ មុខងាររបស់អ្នកអាណាព្យាបាល និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល

អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានមុខងារស្ទើរតែដូចគ្នាទាំងស្រុងនឹងអ្នកមានអំណាចមេបា ប៉ុន្តែមានការកម្រិតតិចតួច (មាត្រា857)។ អ្នកអាណាព្យាបាលសម្រាប់នីតិជនមានមុខងារចាត់ចែងកិច្ចការជីវភាព និងថែទាំសុខភាពដល់នីតិជននៅក្រោមអាណាព្យាបាល និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់នីតិជននៅក្រោមអាណាព្យាបាលក្នុងនាមជាអ្នកតំណាងដែលច្បាប់កំណត់ (មាត្រា858 និងមាត្រា859)។ នៅក្នុងច្បាប់ថ្មីបានបន្ថែមចំណុចអំពីរាល់សកម្មភាពទាំងអស់ត្រូវគោរពឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅ (មាត្រា858)។ ក្នុងពេលថ្មីៗនេះគេបានបង្កើតនូវបញ្ញត្តិដែលអនុវត្តឱ្យ នីតិជននៅក្រោមអាណាព្យាបាលអាចគ្រប់គ្រងវត្ថុប្រៃសណីយ៍ (មាត្រា860.2)។ មុខងាររបស់អ្នកត្រួតពិនិត្យអាណាព្យាបាល គឺត្រួតពិនិត្យកិច្ចការរបស់អ្នកអាណាព្យាបាល ហើយអ្នក

ត្រួតពិនិត្យនោះ ត្រូវទាមទារឱ្យតុលាការត្រួសារជ្រើសរើសអ្នកអាណាព្យាបាល ដោយគ្មានការយឺតយ៉ាវ ក្នុងករណីដែលគ្មានអ្នកអាណាព្យាបាល ជាអាទិ៍ (មាត្រា851)។

⑤ មុខងាររបស់ហិតូបត្ថម្ភកៈ និង អ្នកទំនុកបម្រុង

ហិតូបត្ថម្ភកៈមានសិទ្ធិផ្តល់ការយល់ព្រម (មាត្រា13) នៅពេលដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើសកម្មភាពជាកំណត់ណាមួយ (ការទិញលក់អចលនវត្ថុ ការធានា ការប្រទានកម្ម ឬ ការសាងសង់ និង កែលម្អផ្ទះជាអាទិ៍)។ លើសពីនេះ ហិតូបត្ថម្ភកៈក៏មានសិទ្ធិលុបចោល និង សិទ្ធិតំណាងលើសកម្មភាពជាក់លាក់ណាមួយផងដែរ (⇒សូមយោង ជំពូកទី2 III.2(3))។ ចំពោះករណីប្រព័ន្ធនៃការទំនុកបម្រុងដែលទើបនឹងបង្កើតថ្មីក៏ដូចគ្នាផងដែរ អ្នកទំនុកបម្រុងអាចត្រូវបានប្រគល់នូវសិទ្ធិផ្តល់ការយល់ព្រម សិទ្ធិលុបចោល ឬ សិទ្ធិតំណាង ចំពោះសកម្មភាពគតិយុត្តជាក់លាក់ដែលភាគីបានជ្រើសរើសបាន (⇒សូមយោង ជំពូកទី2 III.2(3))។

## **ជំពូកទី 9 : នីតិសន្តតិកម្ម**

I. **ទិដ្ឋភាពទូទៅនៃនីតិសន្តតិកម្ម**

1. រចនាសម្ព័ន្ធនៃសន្តតិកម្ម

II. **ចំណុចសំខាន់ៗនៃនីតិសន្តតិកម្ម**

1. សន្តតិកម្មតាមច្បាប់

2. ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

3. ការបែងចែកមត៌ក

4. សន្តតិកម្មដោយមតកសាសន៍

5. ការបំបែកទ្រព្យសម្បត្តិ

6. នត្ថិភាពនៃសន្តតិជន

## I. ទិដ្ឋភាពទូទៅនៃនីតិសន្តតិកម្ម

### 1. រចនាសម្ព័ន្ធនៃសន្តតិកម្ម

#### (1) ការទទួលសិទ្ធិ និងករណីយកិច្ចដោយសន្តតិកម្ម

បុគ្គលនឹងបាត់បង់សមត្ថភាពទទួលសិទ្ធិនៅពេលដែលទទួលមរណភាព។ មានន័យថា បុគ្គលនោះពុំមែនជាកម្មសិទ្ធិករ ហើយក៏ពុំមែនជាម្ចាស់បំណុលទៀតដែរ។ ដូចនេះ យើងត្រូវតែពិចារណាអំពី បុគ្គលណាដែលត្រូវក្លាយជាម្ចាស់សិទ្ធិថ្មីដោយទទួលបន្តនូវទ្រព្យធនរបស់បុគ្គលនោះ។ ចំពោះកាតព្វកិច្ចក៏ដោយ បើសិនជាគ្មានអ្នកណាដែលត្រូវទទួលបន្តនោះទេ ម្ចាស់បំណុលនឹងគ្មានស្ថិរភាពឡើយ។ វិធានដែលកំណត់អំពីការទទួលបន្តទាំងអស់ខាងលើនេះ គឺជា នីតិសន្តតិកម្ម។ បុគ្គលដែលទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចពីអ្នកស្លាប់ ហៅថា សន្តតិជន ហើយបុគ្គលដែលត្រូវគេទទួលបន្ត (អ្នកស្លាប់) ហៅថា មតកជន។

#### (2) សន្តតិកម្មតាមមតកសាសន៍ និង សន្តតិកម្មតាមច្បាប់

វិធានជាមូលដ្ឋាននៃសន្តតិកម្មមាន 2ប្រភេទ។ វិធានទីមួយគឺជា សន្តតិកម្មតាមមតកសាសន៍។ ដោយគោរពតាមគោលការណ៍ស្វ័យភាពនៃឆន្ទៈ និង ស្វ័យភាពនៃបុគ្គលឯកជន ជាគោលការណ៍ បុគ្គលអាចសម្រេចបានដោយសេរី ចំពោះវិធីបែងចែកទ្រព្យសម្បត្តិរបស់ខ្លួនក្រោយពេលស្លាប់។ វិធីនេះគឺជា មតកសាសន៍ដែលជាសកម្មភាពឯកតោភាគី។ ដូចនេះ មតកជនអាចធ្វើមតកសាសន៍ដែលមានខ្លឹមសារថា ប្រទានកម្មទ្រព្យសម្បត្តិទាំងអស់ឱ្យទៅនរណាម្នាក់ដែលមិនជាប់សាច់ឈាមទាល់តែសោះក៏បាន ឬ បរិច្ចាគទៅកន្លែងណាក៏បានដែរ។ ប៉ុន្តែ នៅប្រទេសជប៉ុនមានបញ្ញត្តិស្តីពី ភាគបម្រុង (នឹងពន្យល់នៅផ្នែកខាងក្រោយ) ហើយបានកម្រិតជាក់លាក់នូវការធ្វើមតកសាសន៍ (ឪពុកម្តាយ សហព័ទ្ធ និង កូនរបស់មតកជនជាអាទិ៍ ត្រូវបានការពារសិទ្ធិ ចំពោះចំណែកជាក់លាក់មួយនៃមត៌ក)។ ប៉ុន្តែ មតកសាសន៍នឹងមានអានុភាពទាំងស្រុង ប្រសិនបើគ្មានការទាមទារអំពីភាគបម្រុងនេះ។

វិធានទីពីរ គឺជាសន្តតិកម្មតាមច្បាប់ ហើយដែលច្បាប់បានកំណត់នូវ ការបែងចែកនូវទ្រព្យសម្បត្តិរបស់អ្នកស្លាប់ទៅញាតិជាក់លាក់ នូវភាគរយជាក់លាក់មួយ។ ក្រមរដ្ឋប្បវេណីជប៉ុនទទួលស្គាល់នូវសន្តតិកម្មតាមមតកសាសន៍ និង សន្តតិកម្មតាមច្បាប់ទាំងពីរនេះ។ ទ្រឹស្តីច្បាប់នៅមានវិវាទនៅឡើយ ចំពោះការកំណត់យកនូវវិធីសន្តតិកម្មណាមួយធ្វើជាគោលការណ៍ ប៉ុន្តែ ទស្សនៈភាគច្រើនបានកំណត់យកសន្តតិកម្មតាមមតកសាសន៍ជាគោលការណ៍ ដោយសារតែគោរពតាមស្វ័យភាពនៃឆន្ទៈ ហើយករណីដែលគ្មានការកំណត់ដោយមតកសាសន៍ទេ សន្តតិកម្មតាមច្បាប់ត្រូវយកមកបំពេញបន្ថែម។ ប៉ុន្តែ នៅប្រទេសជប៉ុនជាក់ស្តែង គេមិនសូវនិយមធ្វើជាមតកសាសន៍នៅឡើយទេ ហេតុនេះ យើងហាក់ដូចជាមើលឃើញថា សន្តតិកម្មតាមច្បាប់គឺជាគោលការណ៍ ហើយមតកសាសន៍ធ្វើឡើងតែក្នុងករណីដែលមិនចង់បែងចែកដោយសន្តតិកម្មតាមច្បាប់ប៉ុណ្ណោះ។

(3) **អានុភាពនៃសន្តតិកម្ម**

សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងស្រុងដែលជាទ្រព្យសម្បត្តិរបស់មតកជន នៅពេលដែលសន្តតិកម្មចាប់ផ្តើម (មាត្រា896)។ លើកលែងតែសិទ្ធិ និង ករណីយកិច្ចផ្តាច់មុខរបស់មតកជន (សិទ្ធិ និងករណីយកិច្ចផ្តាច់មុខរបស់មតកជនប៉ុណ្ណោះ)។ សិទ្ធិផ្តាច់មុខរបស់បុគ្គលសំដៅទៅលើ សិទ្ធិទាមទារអាហារកាតព្វកិច្ច និង សិទ្ធិទាមទារប្រាក់ឧបត្ថម្ភជីវភាពជាអាទិ៍ ហើយករណីយកិច្ចផ្តាច់មុខរបស់បុគ្គលសំដៅទៅលើកាតព្វកិច្ចធានានៅក្នុងកិច្ចសន្យាធានាផ្ទាល់ខ្លួនជាអាទិ៍។ ប្រសិនបើសន្តតិជនមានច្រើននាក់ មត៌កនឹងក្លាយជាកម្មសិទ្ធិអវិភាគរបស់សន្តតិជននីមួយៗ (មាត្រា898) ហើយសហសន្តតិជននីមួយៗត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជន តាមសមាមាត្រនៃចំណែកសន្តតិកម្មរបស់ខ្លួន (មាត្រា899)។

(4) **វិសោធនកម្មច្បាប់សន្តតិកម្មឆ្នាំ**2018

គន្ថីទី5 ស្តីពី សន្តតិកម្ម នៃក្រមរដ្ឋប្បវេណីជប៉ុន ត្រូវបានធ្វើវិសោធនកម្មនៅខែ កក្កដា ឆ្នាំ2018 ដោយផ្តោតទៅលើផ្នែកស្តីពី មតកសាសន៍ សន្តតិកម្មតាមច្បាប់ ការបែងចែកមត៌ក កិច្ចគាំពារសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធជាអាទិ៍។ វិសោធនកម្មទាំងនេះ គឺជាគោលនយោបាយដោះស្រាយបញ្ហាសង្គមដែលមានអត្រាកំណើតទាប និង អត្រាជរាខ្ពស់។ នៅពេលសិក្សាអំពីផ្នែកស្តីពីសន្តតិកម្មនេះ សូមអ្នកទាំងអស់គ្នាយកចិត្តទុកដាក់ទៅលើទំនោររបស់សង្គមផងដែរ។

## II. ចំណុចសំខាន់ៗនៃនីតិសន្តតិកម្ម

### 1. សន្តតិកម្មតាមច្បាប់

(1) **សន្តតិជនតាមច្បាប់**

សន្តតិកម្មតាមច្បាប់បានកំណត់អំពី បុគ្គលដែលនឹងក្លាយទៅជាអ្នកទទួលបន្ត តាមរយៈការកើតឡើងនូវអង្គហេតុស្តីពីមរណភាពរបស់មតកជន (ពេលចាប់ផ្តើមសន្តតិកម្មគឺជាពេលស្លាប់របស់មតកជន។ មាត្រា882)។ តើអ្នកណាខ្លះដែលច្បាប់បានកំណត់ថាជាអ្នកទទួលបន្ត ឬ សន្តតិជន (សន្តតិជនតាមច្បាប់)។ ដំបូង ប្រសិនបើមតកជនមាន**សហព័ទ្ធ** (ពោលគឺ ប្រពន្ធ ប្រសិនបើមតកជនគឺជាប្តី) បុគ្គលនោះនឹងក្លាយជាសន្តតិជនជានិច្ច (មាត្រា890) ហើយត្រូវទទួលសន្តតិកម្មនូវលំដាប់ដូចគ្នាទៅនឹងញាតិលោហិតរបស់មតកជនខាងក្រោមនេះ (ប៉ុន្តែសហព័ទ្ធអនីតិសង្វាសដែលមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំត្រូវបានទទួលស្គាល់សិទ្ធិសន្តតិកម្មនោះទេ)។ ហើយញាតិលោហិតរបស់មតកជនត្រូវបានកំណត់លំដាប់ ក្នុងនោះ លំដាប់ទីមួយ គឺជាកូនរបស់មតកជន (មាត្រា887 កថាខណ្ឌទី1)។ ប្រសិនបើកូនរបស់មតកជនបានស្លាប់នៅមុនពេលចាប់ផ្តើមសន្តតិកម្ម (កូននោះ

បានស្លាប់នៅមុនពេលមតកជនស្លាប់) ជាអាទិ៍ **បច្ឆាញាតិ**ដែលជាកូនរបស់បុគ្គលនោះ (ពោលគឺ ចៅរបស់មតកជន) ត្រូវក្លាយជាសន្តតិជនដោយជំនួស (ហៅថា **សន្តតិជនជំនួស**។ មាត្រា887 កថាខណ្ឌទី2)។ យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីបានកំណត់អំពី ការចាត់ទុកថាទារកនៅក្នុងគភ៌បានចាប់កំណើតចំពោះសន្តតិកម្ម ហើយនេះជាការទទួលស្គាល់សិទ្ធិសន្តតិកម្មរបស់ទារកក្នុងគភ៌ (មាត្រា886 កថាខណ្ឌទី1។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយនៅពេលដែលទារកបានស្លាប់នៅពេលកើត។ មាត្រាដដែល កថាខណ្ឌទី2)។ បើសិនជាមតកជនពុំមានកូន និងចៅទេ សន្តតិជននឹងត្រូវកំណត់ទៅតាមលំដាប់ដូចខាងក្រោមនេះ។ លំដាប់ទីពីរ គឺ**បុព្វញាតិខ្សែផ្ទាល់** (ញាតិលោហិតនៃជំនាន់មុនដែលមានទំនាក់ខ្សែផ្ទាល់ជាមួយមតកជន ដូចជា ឪពុកម្តាយ និង យាយតា។ ប៉ុន្តែ ឪពុកម្តាយមានអាទិភាពជាងយាយតា), បន្ទាប់មកលំដាប់ទីបី គឺបងប្អូនប្រុសស្រីរបស់មតកជន។ ដូចនេះ សូមកត់សម្គាល់ថា ចំពោះសន្តតិជននៃញាតិលោហិត បើសិនជាមានកូន (ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ) បុព្វញាតិខ្សែផ្ទាល់ដូចជា ឪពុកម្តាយជាដើម មិនអាចក្លាយជាសន្តតិជនទេ ហើយលុះតែគ្មានបច្ឆាញាតិខ្សែផ្ទាល់ និង បុព្វញាតិខ្សែផ្ទាល់ ទើបបងប្អូនប្រុសស្រី (ឬបច្ឆាញាតិរបស់ពួកគេ) ទើបអាចក្លាយជាសន្តតិជន (មាត្រា889)។

យ៉ាងណាមិញ បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាតលើមតកជន ឬ បានបង្ខំ ឬ ឆបោកឱ្យមតកជនធ្វើមតកសាសន៍ មិនអាចក្លាយជាសន្តតិជនបានឡើយ (**មូលហេតុនៃអភ័ព្វរបស់សន្តតិជន**។ មាត្រា891)។ ហើយប្រសិនបើបុគ្គលដែលត្រូវសន្មតជាសន្តតិជនដែលមានសិទ្ធិទាមទារភាគបម្រុង បានធ្វើបាប ឬ ធ្វើអំពើមិនត្រឹមត្រូវលើមតកជន ក្នុងករណីនេះ មតកជនអាចទាមទារឱ្យតុលាការគ្រួសារ ដកសន្តតិជននោះចេញពីសន្តតិជនដែលត្រូវសន្មតបាន (ការផ្តាច់មត៌កពីសន្តតិជន។ មាត្រា892)។

### (2) **ចំណែកសន្តតិកម្មតាមច្បាប់**

ក្រមរដ្ឋប្បវេណី មាត្រា900 កំណត់អំពីចំណែកនៃសន្តតិកម្មក្នុងករណីសន្តតិជនដែលត្រូវបានច្បាប់សន្មតនៃលំដាប់ដូចគ្នាមានច្រើននាក់ ដូចខាងក្រោមនេះ។ (1) ករណីសហព័ទ្ធ និង កូន គឺ ម្នាក់ៗត្រូវបានចំណែក 1 ភាគ 2។ ប្រសិនបើកូនមានចំនួន 2នាក់ ដូចនេះ ចំណែក 1 ភាគ 2 របស់កូនត្រូវយកទៅចែកស្មើគ្នាទៀត (បែងចែកពាក់កណ្តាលម្នាក់ទៀត) ហេតុនេះ កូនម្នាក់ៗត្រូវបានចំណែក 1 ភាគ 4 ។ (2) ករណីសហព័ទ្ធ និង បុព្វញាតិខ្សែផ្ទាល់ គឺ សហព័ទ្ធទទួលបាន 2 ភាគ 3 ហើយ បុព្វញាតិខ្សែផ្ទាល់ទទួលបាន 1 ភាគ 3 ។ ប្រសិនបើបុព្វញាតិខ្សែផ្ទាល់មានច្រើននាក់ ចំណែកសន្តតិកម្មរបស់បុព្វញាតិខ្សែផ្ទាល់ត្រូវយកទៅបែកចែកស្មើៗគ្នា។ (3) ករណីសហព័ទ្ធ និង បងប្អូនប្រុសស្រី គឺ សហព័ទ្ធទទួលបានចំណែក 3 ភាគ 4 ហើយបងប្អូនប្រុសស្រីទទួលបានចំណែក 1 ភាគ 4 ។ ប្រសិនបើបងប្អូនប្រុសស្រីនោះមានច្រើននាក់ ចំណែកសន្តតិកម្មរបស់បងប្អូនប្រុសស្រីត្រូវយកទៅបែងចែកស្មើៗគ្នា។ (4) ចំណែកសន្តតិកម្មរបស់បងប្អូនប្រុសស្រីដែលមានឪពុកម្តាយរួមគ្នាតែម្ខាង គឺទទួលបានចំណែក 1 ភាគ 2 នៃចំណែករបស់បងប្អូនប្រុសស្រីដែលមានឪពុកម្តាយទាំងសងខាងរួមគ្នាប៉ុណ្ណោះ (បញ្ញត្តិស្តីពីចំណែកសន្តតិកម្ម

របស់កូនគ្មានខាន់ស្លា ត្រូវស្មើនឹង 1 ភាគ 2 នៃកូនមានខាន់ស្លា ធ្លាប់មានពីមុនមក ប៉ុន្តែ ត្រូវបាននិរាករណ៍នៅក្នុងឆ្នាំ2013)។

ពាក្យគន្លឹះ : **ចំណែកសន្តតិកម្មរបស់សហព័ទ្ធ**

ចំណែកសន្តតិកម្មរបស់សហព័ទ្ធ នៅក្នុងបញ្ញត្តិច្បាប់បច្ចុប្បន្នដែលបានធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីឆ្នាំ1980 បានកើនឡើងច្រើនជាងមុន បើប្រៀបធៀបនឹងបញ្ញត្តិច្បាប់កន្លងមក (ឆ្នាំ1947)។ តារាងខាងក្រោមនេះគឺបង្ហាញអំពីចំណែកសន្តតិកម្មដែលបានរៀបរាប់ខាងលើនេះ។

| | | |
|---|---|---|
| សន្តតិកម្មរួមជាមួយនឹងសន្តតិជនលំដាប់ទី 1 | សហព័ទ្ធ | 1/2 |
| | កូន | 1/2 |
| សន្តតិកម្មរួមជាមួយនឹងសន្តតិជនលំដាប់ទី 2 | សហព័ទ្ធ | 2/3 |
| | បុព្វញាតិខ្សែផ្ទាល់ | 1/3 |
| សន្តតិកម្មរួមជាមួយនឹងសន្តតិជនលំដាប់ទី 3 | សហព័ទ្ធ | 3/4 |
| | បងប្អូនប្រុសស្រី | 1/4 |

ក្រមរដ្ឋប្បវេណី មាត្រា901 បានកំណត់ថា ករណីដែលបច្ឆាញាតិផ្ទាល់ក្លាយជាសន្តតិជនជំនួស ផ្អែកតាមមាត្រា887 កថាខណ្ឌទី2 និង ទី3 (មានន័យថា ចៅជាអាទិ៍ ក្នុងករណីដែលកូនដែលជាសន្តតិជនបានស្លាប់) ត្រូវទទួលបានចំណែកសន្តតិកម្មដូចគ្នានឹងចំណែករបស់បុព្វញាតិផ្ទាល់នៃសន្តតិជនជំនួសនោះ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានច្រើននាក់ ចំណែកដែលបច្ឆាញាតិផ្ទាល់នីមួយៗនោះត្រូវទទួលបាន គឺត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា900 ស្តីពីចំណែកសន្តតិកម្ម (មាត្រា901 កថាខណ្ឌទី1។ មានន័យថា ប្រសិនបើចៅមានច្រើននាក់ ចំណែកសន្តតិកម្មរបស់កូនដែលបានស្លាប់នោះ ត្រូវយកមកបែងចែកស្មើៗគ្នារវាងចៅៗ)។ ហើយត្រូវអនុវត្តដូចគ្នាផងដែរ (មាត្រា901 កថាខណ្ឌទី2) ចំពោះករណីកូនរបស់បងប្អូនប្រុសស្រីក្លាយជាសន្តតិជនជំនួស ដោយផ្អែកលើបញ្ញត្តិនៃមាត្រា889 កថាខណ្ឌទី2 (មានន័យថា កូនរបស់បងប្អូនប្រុសស្រីដែលបានក្លាយជាសន្តតិជន ហើយបុគ្គលទាំងនោះបានស្លាប់)។

(3) **ចំណែកសន្តតិកម្មតាមការកំណត់**

ក្រមរដ្ឋប្បវេណី មាត្រា902 បានកំណត់ថា ទោះបីជាមានបញ្ញត្តិទាំងពីរខាងលើនេះក៏ដោយ ក៏មតកជនអាចកំណត់អំពីចំណែកសន្តតិកម្មរបស់សហសន្តតិជន ឬ ប្រគល់អាណត្តិឱ្យតតិយជនដើម្បីកំណត់អំពីចំណែកសន្តតិកម្មនេះ នៅក្នុងមតកសាសន៍បាន (មាត្រា902 កថាខណ្ឌទី1។ ប៉ុន្តែ ចំពោះភាគបម្រុង សូមយោងចំណុច 4.(សន្តតិកម្មតាមមតកសាសន៍) 5)។ ប្រសិនបើមតកជន បានកំណត់អំពីចំណែកសន្តតិកម្មរបស់សន្តតិជនម្នាក់ ឬច្រើននាក់នៅក្នុងចំណោមសហសន្តតិជនច្រើននាក់ ឬ បើសិនជាមតកជនបានកំណត់ឱ្យតតិយជនផ្សេងជាអ្នក

កំណត់ខ្លឹមសារខាងលើនេះ ក្នុងករណីនេះ ចំណែកសន្តតិកម្មរបស់សហសន្តតិជនផ្សេងទៀត (សន្តតិជនដែលមិនទទួលបានការកំណត់អំពីចំណែកសន្តតិកម្ម) ត្រូវអនុលោមតាមបញ្ញត្តិទាំងពីរមាត្រាខាងលើនេះ (មាត្រា902 កថាខណ្ឌទី2)។

(4) **សមភាពរវាងសន្តតិជន**

① ចំណែកសន្តតិកម្មរបស់បុគ្គលដែលទទួលបានផលប្រយោជន៍ពិសេស

ប្រសិនបើសន្តតិជនដែលត្រូវបានសន្មតមានច្រើននាក់ ហើយនៅក្នុងចំណោមសន្តតិជនទាំងអស់នោះ បើសិនជាមានបុគ្គលណាដែលបានទទួលប្រទានកម្មជាពិសេសនៅពេលមតកជននៅរស់ ឬ ទទួលបានដោយអច្ច័យទានជាដើម ក្នុងករណីនេះ ទ្រព្យសម្បត្តិដែលបានទទួលទាំងអស់ខាងលើនេះ ត្រូវសន្មតថាជាចំណែកសន្តតិកម្មដែលបានប្រគល់ឱ្យមុន ហើយត្រូវគណនាចំណែកសន្តតិកម្ម ដោយរាប់បញ្ចូលទ្រព្យសម្បត្តិទាំងអស់នោះត្រឡប់មកវិញ (ផ្នែកដែលបានទទួលផលរួចហើយ ត្រូវដកចេញពីចំណែកសន្តតិកម្មរបស់បុគ្គលនោះ)។ នេះគឺជា ប្រព័ន្ធយកត្រឡប់មកវិញនូវផលប្រយោជន៍ពិសេស (មាត្រា903)។ ផលប្រយោជន៍ពិសេសដែលអាចយកមកពិចារណាបាន មានដូចជា ការទទួលបាននូវការឧបត្ថម្ភថ្លៃសិក្សាដែលមានចំនួនច្រើនខ្លាំងបើប្រៀបធៀបជាមួយសន្តតិជនផ្សេងទៀត និង ប្រទានកម្មអចលនវត្ថុនៅពេលរៀបអាពាហ៍ពិពាហ៍ជាអាទិ៍។ ប៉ុន្តែ ច្បាប់វិសោធនកម្មឆ្នាំ2018 បានបង្កើតនូវបញ្ញត្តិថ្មីដែលកំណត់ថា ត្រូវសន្មតថាការបង្ហាញឆន្ទៈប្រទានកម្ម ឬ អច្ច័យទានរបស់មតកជនត្រូវបានដកមកវិញ ប្រសិនបើមតកជនបានធ្វើប្រទានកម្ម ឬ អច្ច័យទាននូវអចលនវត្ថុ (អគារ ឬ ដីនៃអគារនោះ) ដែលសហព័ទ្ធម្ខាងដែលមានចំណងអាពាហ៍ពិពាហ៍លើសពី 20ឆ្នាំ កំពុងរស់នៅ (កថាខណ្ឌទី4 មាត្រា904 នៃច្បាប់វិសោធនកម្ម)។ នេះគឺជាបញ្ញត្តិដែលបង្កើតឡើងដើម្បីធានានូវជីវភាពរបស់ភាគីម្ខាងទៀតនៅពេលជរា (ដាក់ឱ្យអនុវត្ត នៅថ្ងៃទី1 ខែ សីហា ឆ្នាំ2019)។

② ភាគនៃវិភាគទាន

នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើសិនជាមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់ពលកម្មដល់ការងាររបស់មតកជន ឬ ដោយការថែទាំមតកជនជាអាទិ៍ ក្នុងករណីនេះ ការធ្វើវិភាគទានទាំងនោះត្រូវតែយកមកគណនានៅក្នុងចំណែកនៃសន្តតិកម្ម ទើបអាចឆ្លុះបញ្ចាំងអំពីសមភាពបាន។ ដោយផ្អែកតាមទស្សនៈនេះ ទើបនៅឆ្នាំ1980 បញ្ញត្តិស្តីពីភាគនៃវិភាគទានត្រូវបានបន្ថែម (មាត្រា904.2)។ វិភាគទានបែបនេះ ត្រូវវាយតម្លៃជាចំនួនទឹកប្រាក់ ហើយទទួលស្គាល់ជាចំនួនកើនតម្លៃនៃចំណែកសន្តតិកម្មសម្រាប់តែចំនួនវិភាគទាននោះ តាមការពិភាក្សារបស់សហសន្តតិជន ឬ សេចក្តីសម្រេចរបស់តុលាការគ្រួសារ។

③ ការបង្កើតប្រព័ន្ធជនដែលផ្ដល់វិភាគទានពិសេស

ផ្ទុយមកវិញ នៅក្នុងក្រមរដ្ឋប្បវេណីពុំមានកំណត់អំពីប្រព័ន្ធដែលលើកទឹកចិត្តដូចប្រព័ន្ធភាគនៃវិភាគទានខាងលើនោះទេ បើទោះជាបុគ្គលដែលក្រៅពីសហសន្តិជន បានផ្ដល់នូវការបរិច្ចាគពិសេសដល់មតកជនយ៉ាងណាក៏ដោយ (ឧទាហរណ៍ថា សហព័ទ្ធរបស់សន្តតិជន ជាដើម)។ ឧទាហរណ៍ថា A និង B មានកូនពីរនាក់គឺ C និង D ហើយក្រោយមក B បានស្លាប់ ហើយ D ក៏បានបំបែកលំនៅ។ អ្នកដែលមើលថែរក្សា A ដែលជាចាស់ជរានោះ គឺជា E ដែលជាប្រពន្ធរបស់ C។ បើទោះបីជា C បានស្លាប់ទៅហើយ ក៏ E នៅតែបន្តមើលថែរក្សា A ដដែល។ ក្នុងករណីនេះ បើសិនជាក្រោយមក A បានស្លាប់, D នឹងក្លាយទៅជាសន្តតិជនតែម្នាក់គត់ ហើយ E មិនទទួលបាននូវមត៌កណាមួយទាល់តែសោះពី A។ ចំណែកឯ ប្រព័ន្ធជនមាននិស្ស័យពិសេសវិញ (នឹងរៀបរាប់លម្អិតនៅផ្នែកខាងក្រោយ) គឺមិនអាចយកមកប្រើប្រាស់បាននោះទេ បើទោះបីជាមានសន្តតិជនតែម្នាក់ក៏ដោយ។ ហេតុនេះ នៅក្នុងច្បាប់វិសោធនកម្មឆ្នាំ2018 គេបានបង្កើតនូវមាត្រា1050 នៅក្នុងជំពូកទី10 ថ្មី «ការផ្ដល់វិភាគទានពិសេស» ចូលទៅផ្នែកចុងក្រោយនៃគន្ថីស្ដីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។ ក្នុងជំពូកនេះបានបង្កើតនូវប្រព័ន្ធថ្មីដែលអនុញ្ញាតឱ្យ «ញាតិរបស់មតកជនដែលបានផ្ដល់នូវវិភាគទានពិសេសក្នុងការទ្រទ្រង់ ឬ បង្កើនមត៌ករបស់មតកជន តាមរយៈការមើលថែទាំ ព្យាបាល ឬ ការផ្ដល់កម្លាំងពលកម្មផ្សេងទៀតដល់មតកជនដោយមិនយកកម្រៃ» អាចទាមទារឱ្យបង់ថ្លៃវិភាគទានពិសេស ដែលជាការលើកទឹកចិត្តផ្លូវច្បាប់ដល់ការបរិច្ចាគរបស់ជនដែលបានផ្ដល់វិភាគទានពិសេស បើទោះបីជាក្នុងករណីដែលមានសន្តតិជនផ្សេងក៏ដោយ។ តាមរយៈនេះ E ដែលនៅក្នុងឧទាហរណ៍ខាងលើនេះ អាចទាមទារឱ្យបង់ប្រាក់ស្មើនឹងកម្រិតនៃការបរិច្ចាគ (ថ្លៃវិភាគទានពិសេស) ចំពោះសន្តតិជន D នៅក្រោយពេលសន្តតិកម្មចាប់ផ្ដើមបាន។

## 2. **ការយល់ព្រម និង ការបោះបង់សន្តតិកម្ម**

សន្តតិកម្មគឺជាការទទួលបន្តទំនាក់ទំនងទ្រព្យសម្បត្តិទាំងស្រុងរបស់អ្នកស្លាប់ (ហៅថា ការទទួលបន្តជាសកល)។ នេះមានន័យថា នៅក្នុងករណីអ្នកស្លាប់មានបំណុលកាលនៅរស់ បំណុលនោះក៏ត្រូវដាក់បញ្ចូលក្នុងមត៌កផងដែរ។ តាមរយៈនេះហើយ ទើបមានករណីខ្លះបំណុលមានច្រើនជាងទ្រព្យសម្បត្តិសកម្ម។ នៅក្នុងករណីបែបនេះក៏ដោយ តើបុគ្គលដែលក្លាយជាសន្តតិជនត្រូវតែទទួលសន្តតិកម្មដែរឬទេ? បើសិនជាពិចារណាពីទស្សនៈអំពីស្វ័យភាពនៃឆន្ទៈរបស់បុគ្គល យើងត្រូវតែផ្ដល់ឱកាសឱ្យសន្តតិជនអាចសម្រេចចិត្តដោយខ្លួនឯង។ ដូចនេះ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់នូវសិទ្ធិរបស់សន្តតិជនក្នុងការជ្រើសរើសយក ①ការបដិសេធទាំងស្រុងចំពោះការទទួលទ្រព្យសម្បត្តិបន្ត (**ការបោះបង់សន្តតិកម្ម**) ឬ ②ការទទួលយកទ្រព្យសម្បត្តិទាំងស្រុង (**ការយល់ព្រមទាំងស្រុង**) ឬ ③ទទួលខុសត្រូវក្នុងការសងកាតព្វកិច្ចជាដើម ក្នុងកម្រិតនៃទ្រព្យសម្បត្តិសកម្មដែលបានធ្វើសន្តតិកម្ម (**ការយល់ព្រមដោយកម្រិត**) (សូមកត់សម្គាល់ថា សន្តតិជនពុំមានជម្រើសក្នុងការទទួលសន្តតិកម្មតែទ្រព្យសម្បត្តិសកម្ម ហើយមិនទទួលកាតព្វកិច្ចនោះទេ)។ សន្តតិជនត្រូវតែជ្រើសរើសតាមជម្រើសខាងលើនេះ ក្នុងអំឡុងពេល

3ខែ (គេហៅថា អំឡុងពេលសម្រាប់ពិចារណា) ចាប់ពីពេលដែលបានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្ដើម (មាត្រា915 កថាខណ្ឌទី1)។

① **ការបោះបង់សន្តតិកម្ម** : ការបោះបង់សន្តតិកម្មត្រូវដាក់ពាក្យសុំទៅតុលាការគ្រួសារ (មាត្រា938) ប៉ុន្តែបុគ្គលដែលបានបោះបង់ ត្រូវចាត់ទុកថា មិនមែនជាសន្តតិជនតាំងពីដំបូង (មាត្រា939)។

② **ការយល់ព្រមទាំងស្រុង** : នៅក្នុងករណីយល់ព្រមទាំងស្រុង សន្តតិជនត្រូវទទួលបន្តសិទ្ធិ និងករណីយកិច្ចរបស់មតកជនដោយគ្មានកម្រិត (មាត្រា920)។ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងផងដែរ នៅក្នុងករណីដែលសន្តតិជននោះបានចាត់ចែងមត៌កទាំងស្រុង ឬ មួយផ្នែក ឬ ក្នុងករណីដែលសន្តតិជនមិនបានធ្វើការបោះបង់ ឬ យល់ព្រមដោយកម្រិត ក្នុងអំឡុងពេល 3ខែ គិតចាប់ពីពេលដែលបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្មជាអាទិ៍ (មាត្រា921)។

③ **ការយល់ព្រមដោយកម្រិត** : សន្តតិជនដែលយល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីទ្រព្យសម្បត្តិ ហើយដាក់ទៅតុលាការគ្រួសារ និងថ្លែងការណ៍អំពីការយល់ព្រមដោយកម្រិត ក្នុងអំឡុងពេល 3ខែ គិតចាប់ពីពេលដែលបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្មជាអាទិ៍ (មាត្រា924)។ ដោយឡែក ប្រសិនបើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបានតែក្នុងករណីដែលមានការយល់ព្រមពីសន្តតិជនទាំងអស់ប៉ុណ្ណោះ (មាត្រា923)។ បើមិនធ្វើបែបនេះទេ ទំនាក់ទំនងគតិយុត្តនឹងស្មុគស្មាញខ្លាំង។ ហេតុនេះ នៅក្នុងចំណោមសន្តតិជនជាច្រើន បើមានសន្តតិជនតែម្នាក់បានអះអាងអំពីបោះបង់ ឬ យល់ព្រមទាំងស្រុង សន្តតិជនផ្សេងទៀតមិនអាចទទួលយល់ព្រមដោយកម្រិតឡើយ (យ៉ាងណាមិញ ប្រសិនបើសហសន្តតិជនផ្សេងទៀតបានបោះបង់សន្តតិកម្មទាំងអស់គ្នា ក្នុងករណីនេះ បុគ្គលដែលនៅសល់តែម្នាក់ឯងអាចយល់ព្រមដោយកម្រិតបាន)។

### 3. ការបែងចែកមត៌ក

ករណីដែលសន្តតិជនមានច្រើននាក់ ទ្រព្យសម្បត្តិសន្តតិកម្មត្រូវក្លាយជាទ្រព្យអវិភាគរបស់សហសន្តតិជនទាំងអស់នោះសិន។ ហើយនីតិវិធីផ្ទេរចុងក្រោយបំផុតនៃទ្រព្យសម្បត្តិសន្តតិកម្មទាំងអស់នោះ គឺជា ការបែងចែកមត៌ក។ ការបែងចែកមត៌កមាន 2ប្រភេទ គឺ ការបែងចែកតាមការពិភាក្សា និង ការបែងចែកតាមតុលាការ (មាត្រា907)។ រឿងក្ដីវិវាទភាគច្រើននៃសន្តតិកម្ម កើតឡើងនៅក្នុងដំណាក់កាលបែងចែកមត៌កនេះ។ បើសិនជាសន្តតិជនអាចពិភាក្សាវាងគ្នាបាន ឧបមាថា ដីមួយឡូត៍ដែលបានធ្វើសន្តតិកម្មរួម អាចធ្វើជាកម្មសិទ្ធិអវិភាគទៅតាមភាគយនៃចំណែកសន្តតិកម្មដដែល ដោយមិនបែងចែកក៏បានដែរ។ មតកជនក៏អាចកំណត់អំពីវិធីបែងចែកមត៌កនៅក្នុងមតកសាសន៍បានដែរ (មាត្រា908)។ ការបែងចែកដោយតុលាការ ត្រូវធ្វើឡើងតាមរយៈនីតិវិធីសម្រេចសេចក្ដីនៃតុលាការគ្រួសារ។

## 4. **សន្តតិកម្មដោយមតកសាសន៍**

### (1) **ទម្រង់នៃមតកសាសន៍**

មតកសាសន៍កើតមានអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំស្លាប់ (មាត្រា985) ហេតុនេះ ក្រមរដ្ឋប្បវេណីបានតម្រូវឱ្យមតកសាសន៍គោរពនូវទម្រង់យ៉ាងតឹងរឹង ក្នុងគោលបំណងក្តាប់ឱ្យបានច្បាស់លាស់អំពីឆន្ទៈចុងក្រោយរបស់អ្នកស្លាប់ និង ជៀសវាងមិនឱ្យបុគ្គលផ្សេងអាចបន្លំបាន (មតកសាសន៍ពុំអាចធ្វើខុសពីទម្រង់ដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនោះទេ។ មាត្រា960)។ ទម្រង់ធម្មតាដែលត្រូវ បានកំណត់(មាត្រា967) មាន 3 ប្រភេទគឺ មតកសាសន៍ដោយលិខិតឯកជន មតកសាសន៍ដោយលិខិតយថាភូត និង មតកសាសន៍ដោយលិខិតសម្ងាត់ ហើយទម្រង់ពិសេស (មាត្រា967 វាក្យខណ្ឌទី2) ដែលត្រូវបានកំណត់រួមមាន មតកសាសន៍ក្នុងពេលគ្រោះថ្នាក់បន្ទាន់ និង មតកសាសន៍នៅទីដាច់ពីគេ (មតកសាសន៍ដោយជនដែលមានគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតនៅក្នុងចំណោមមតកសាសន៍ខាងលើនេះ គឺជាវិធីធ្វើមតកសាសន៍ដែលជនកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិតដោយសារជំងឺ ឬ ហេតុផ្សេងទៀត ត្រូវមានការចូលរួមដោយសាក្សីយ៉ាងតិច 3នាក់ ហើយប្រកាសអំពីខ្លឹមសារនៃមតកសាសន៍ដោយផ្ទាល់មាត់ចំពោះសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងអស់នោះ ហើយសាក្សីម្នាក់នោះត្រូវសរសេរខ្លឹមសារជាលាយលក្ខណ៍អក្សរ។ មតកសាសន៍ប្រភេទនេះ អាចហៅម៉្យាងទៀតថា មតកសាសន៍នៅដង្ហើមចុងក្រោយ។ មាត្រា976)។ ប្រសិនបើពុំមានមតកសាសន៍ ឬ មានមតកសាសន៍ដែរ តែគ្មានអានុភាព ក្នុងករណីនេះ សន្តតិកម្មតាមច្បាប់ត្រូវយកមកអនុវត្ត។

① **មតកសាសន៍ដោយលិខិតឯកជន** : មតកសាសន៍ដោយលិខិតឯកជននេះ គឺជាទម្រង់ដែលងាយស្រួលធ្វើជាងគេ ដោយម្ចាស់បណ្តាំមិនចាំបាច់ខ្ចីដៃពីអ្នកណាឡើយ ប៉ុន្តែ ម្ចាស់បណ្តាំត្រូវសរសេរខ្លឹមសារទាំងអស់ ចុះថ្ងៃខែឆ្នាំ និង សរសេរឈ្មោះដោយខ្លួនឯង និង ត្រូវបោះត្រា។ យ៉ាងណាមិញ បញ្ជីទ្រព្យសម្បត្តិដែលជាឯកសារភ្ជាប់មិនចាំបាច់សរសេរដោយដៃខ្លួនឯងនោះទេ។ ការបន្ថែម ការលុប និង ការកែប្រែពុំមានអានុភាពឡើយ ប្រសិនបើម្ចាស់បណ្តាំមិនបានបង្ហាញអំពីកន្លែងនោះ ហើយសរសេរបន្ថែមនូវខ្លឹមសារកែតម្រូវ ហើយចុះឈ្មោះ និង បោះត្រានៅនឹងកន្លែងនោះទេ (មាត្រា968)។

② **មតកសាសន៍ដោយលិខិតយថាភូត** : មតកសាសន៍ដោយលិខិតយថាភូតនេះ ត្រូវធ្វើឡើងដោយមន្ត្រីសារការី ហើយ 1)មានការចូលរួមពីសាក្សីយ៉ាងតិច 2នាក់។ 2)ម្ចាស់បណ្តាំត្រូវប្រកាស (ប្រាប់ផ្ទាល់មាត់) អំពីខ្លឹមសារនៃមតកសាសន៍ចំពោះមន្ត្រីសារការី។ 3)មន្ត្រីសារការីត្រូវសរសេរជាលាយលក្ខណ៍អក្សរនូវសេចក្តីថ្លែងរបស់ម្ចាស់បណ្តាំ ហើយអានឱ្យម្ចាស់បណ្តាំ និង សាក្សីស្តាប់ ក្រោយមកដាក់ឱ្យម្ចាស់បណ្តាំ និង សាក្សីពិនិត្យមើល (ការដាក់ឱ្យពិនិត្យមើលនេះ ត្រូវបានបន្ថែមនៅក្នុងវិសោធនកម្មច្បាប់ខែមេសា ឆ្នាំ2000)។ 4)ម្ចាស់បណ្តាំ និង សាក្សីត្រូវសរសេរឈ្មោះ និង បោះត្រា ក្រោយពីទទួលស្គាល់នូវភាពត្រឹមត្រូវនៃសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ។ 5)មន្ត្រីសារការីត្រូវសរសេរឈ្មោះ និង បោះត្រា ហើយលេខាចារឹកនូវខ្លឹមសារថា មតកសាសន៍នេះបានធ្វើឡើង

ដោយគោរពតាមលក្ខខណ្ឌខាងលើនេះ (មាត្រា969)។ ទម្រង់នេះអាចស្មុគស្មាញបន្តិច ប៉ុន្តែ មានភាពច្បាស់លាស់ខ្លាំង។ យ៉ាងណាមិញ នៅក្នុងករណីដែលបុគ្គលដែលមិនអាចនិយាយបានមានបំណងធ្វើមតកសាសន៍ដោយលិខិតយថាភូត ម្ចាស់បណ្ដាំត្រូវឱ្យអ្នកបកប្រែភាសាកាយវិការជាអ្នកធ្វើសេចក្ដីថ្លែង ឬ សរសេរដោយខ្លួនឯងនូវខ្លឹមសារមតកសាសន៍ ជំនួសឱ្យការប្រកាសដោយម្ចាស់បណ្ដាំក្នុងចំណុច 2)បាន។ ត្រូវអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលម្ចាស់បណ្ដាំ ឬ សាក្សីគឺជាបុគ្គលដែលមិនអាចស្ដាប់បាន ដោយមន្ត្រីសារការីត្រូវឱ្យអ្នកបកប្រែកាយវិការបង្ហាញអំពីខ្លឹមសារនៃមតកសាសន៍ ជំនួសឱ្យការអានឱ្យស្ដាប់នៃចំណុចទី 3)បាន (ខ្លឹមសារនេះកំណត់ក្នុងមាត្រា969.2 ដែលត្រូវបានបន្ថែមនៅក្នុងវិសោធនកម្មច្បាប់ខែមេសា ឆ្នាំ2000)។

③ **មតកសាសន៍ដោយលិខិតសម្ងាត់** : មតកសាសន៍ដោយលិខិតសម្ងាត់នេះ គឺជាមតកសាសន៍ដែលម្ចាស់បំណ្ដាំត្រូវសរសេរដោយខ្លួនឯង ឬ ឱ្យអ្នកដទៃសរសេរ ដោយសរសេរឈ្មោះ និង បោះត្រារបស់ខ្លួនឯង ហើយដាក់ចូលក្នុងស្រោមសំបុត្របិទជិត និង បោះត្រាពីលើមាត់ស្រោមសំបុត្រនោះ។ បន្ទាប់មកម្ចាស់បំណ្ដាំ ត្រូវដាក់សំបុត្របិទជិតនោះ នៅចំពោះមុខមន្ត្រីសារការីម្នាក់ និង សាក្សី 2នាក់ ហើយថ្លែងការណ៍ថា ក្នុងសំបុត្រនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយសរសេរដោយខ្លួនឯងផ្ទាល់ ឬ ដោយបុគ្គលណាផ្សេងជាអាទិ៍ និងក្រោយមកមន្ត្រីសារការីត្រូវចុះថ្ងៃខែឆ្នាំដែលម្ចាស់បំណ្ដាំបានដាក់ចូល និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំនៅលើសំបុត្របិទជិតនោះ ហើយត្រូវចុះហត្ថលេខាដោយខ្លួនមន្ត្រីសារការីផ្ទាល់ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បំណ្ដាំ (មាត្រា970)។ យ៉ាងណាមិញ នៅក្នុងករណីដែលបុគ្គលដែលមិនអាចនិយាយបាន ហើយមានបំណងធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ បុគ្គលនោះត្រូវធ្វើសេចក្ដីថ្លែងការណ៍ដូចខាងលើនេះ ដោយការបកប្រែរបស់អ្នកបកប្រែ ឬ ដោយលិខិតបិទជិតនោះដោយខ្លួនឯង (មាត្រា972 នៃវិសោធនកម្មច្បាប់ខែមេសា ឆ្នាំ2000)។

### (2) អច្ច័យទាន

ជាគោលការណ៍ ខ្លឹមសារនៃមតកសាសន៍គឺធ្វើបានដោយសេរី។ ម្ចាស់បណ្ដាំ អាចកំណត់អំពីការផ្លាស់ប្ដូរចំណែកនៃសន្តតិកម្មចំពោះសន្តតិជនដែលត្រូវបានសន្មតជាអាទិ៍នៅក្នុងមតកសាសន៍បាន ហើយក្នុងមតកសាសន៍នេះ ក៏អាចកំណត់អំពីការប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅអ្នកណាក៏បានដែរ (ទោះបីជាបុគ្គលក្រៅពីសន្តតិជនដែលបានសន្មតក៏បានដែរ)។ នេះហៅថា អច្ច័យទាន។ អាចធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិទាំងអស់ឱ្យទៅអ្នកណាម្នាក់ (**អច្ច័យទានសកល**) ឬ ធ្វើអច្ច័យទានតែទ្រព្យសម្បត្តិជាក់លាក់ណាមួយឱ្យទៅអ្នកណាម្នាក់ (**អច្ច័យទានមានកំណត់**) ក៏បានដែរ (មាត្រា964)។

អ្នកដែលទទួលអច្ច័យទានហៅថា អច្ច័យលាភី។ បើសិនជាមិនចង់ទទួលអច្ច័យទានទេ អច្ច័យលាភីអាចបោះបង់អច្ច័យទានពេលណាក៏បាន នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព (មាត្រា986 កថាខណ្ឌទី1)។ ដោយសារតែ សន្តតិជនតាមផ្លូវច្បាប់អាចបោះបង់សន្តតិកម្មបាន ហេតុនេះ អច្ច័យលាភីក៏ដូចគ្នាដែរ។ យ៉ាងណាមិញ អច្ច័យលាភីសកលត្រូវមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងសន្តតិជនផងដែរ (មាត្រា990)។

សូមពិនិត្យមើលអំពី ប្រទានកម្មដោយមូលហេតុមរណភាពវិញម្តង។ ដូចបានរៀបរាប់នៅក្នុងជំពូកទី4 រួចហើយថា ប្រទានកម្មដោយមូលហេតុមរណភាព គឺជាប្រទានកម្មដែលមានភ្ជាប់លក្ខខណ្ឌបង្អង់ស្តីពីមរណភាពរបស់ទាយក (អានុភាពកើតឡើងដោយសារមរណភាព) ហើយវាជាកិច្ចសន្យាដែលមតកជនបានធ្វើពេលនៅរស់ ខុសពីអច្ច័យទានដែលជាសកម្មភាពឯកតោភាគី។ ដោយឡែក ប្រទានកម្មនេះមានមុខងារស្រដៀងគ្នានឹងអច្ច័យទាន ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានកំណត់ថា បញ្ញត្តិស្តីពីអច្ច័យទានត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីប្រទានកម្មដោយមូលហេតុមរណភាព (មាត្រា554)។ នៅក្នុងច្បាប់ស្តីពីពន្ធលើសន្តតិកម្មក៏បានបញ្ចូលប្រទានកម្មដោយមូលហេតុមរណភាពជាអច្ច័យទានផងដែរ (ច្បាប់ដដែល មាត្រា1.3 កថាខណ្ឌទី1 ចំណុចទី1)។

### (3) ការដកមតកសាសន៍

គោលការណ៍សេរីភាពនៃមតកសាសន៍ រួមបញ្ចូលទាំងសេរីភាពនៃខ្លឹមសារ និង សេរីភាពនៃការដកវិញ។ ម្ចាស់បណ្តាំ អាចដកមតកសាសន៍មួយផ្នែក ឬ ទាំងមូលនៅពេលណាក៏បាន ដោយគោរពតាមទម្រង់នៃមតកសាសន៍ (មាត្រា1022)។ មានន័យថា គេគោរពនូវឆន្ទៈនាពេលចុងក្រោយបំផុតនៅមុនពេលទទួលមរណភាព ហេតុនេះ មតកសាសន៍អាចសរសេរឡើងវិញចំនួនប៉ុន្មានដងក៏បានដែរ។ ហើយប្រសិនបើខ្លឹមសារនៃមតកសាសន៍មុន និង មតកសាសន៍ក្រោយផ្ទុយគ្នា ត្រូវចាត់ទុកថា មតកសាសន៍ក្រោយបានដកនូវមតកសាសន៍មុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ (មាត្រា1023 កថាខណ្ឌទី1)។

## 5. សិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ

### (1) គោលបំណងនៃការបង្កើត

តាមរយៈវិសោធនកម្មច្បាប់សន្តតិកម្មឆ្នាំ2018 បញ្ញត្តិស្តីពី សិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ និង សិទ្ធិអាស្រ័យនៅរយៈពេលខ្លីរបស់សហព័ទ្ធត្រូវបានបង្កើតថ្មី ហើយត្រូវដាក់ឱ្យអនុវត្តនៅថ្ងៃទី1 ខែមេសា ឆ្នាំ2020។ គោលបំណងនៃការបង្កើតបញ្ញត្តិនេះ គឺដើម្បីគាំពារសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធដែលនៅរស់ ក្នុងសង្គមដែលសម្បូរដោយចាស់ជរាក្នុងពេលបច្ចុប្បន្ន។ បើនិយាយឱ្យងាយយល់ទៅ នេះគឺជាវិធានដែលបានបង្កើតថ្មី ដើម្បីឱ្យប្រពន្ធដែលរស់នៅក្នុងផ្ទះដែលមានឈ្មោះរបស់ប្តី អាចបន្តរស់នៅក្នុងផ្ទះនោះទៀត ក្នុងករណីដែលប្រពន្ធ និង កូនបានបែងចែកទ្រព្យសម្បត្តិនៅពេលដែលប្តីស្លាប់។

### (2) សិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ

សិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ (មាត្រា1028 ថ្មី) គឺជាសិទ្ធិតាមច្បាប់ដែលទទួលស្គាល់ឱ្យសហព័ទ្ធអាចប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុដែលជាកម្មសិទ្ធិរបស់មតកជនដោយមិនគិតកម្រៃអស់មួយជីវិត ឬ ក្នុងអំឡុងពេលជាក់លាក់ណាមួយ ក្នុងករណីដែលសហព័ទ្ធកំពុងស្នាក់នៅអចលនវត្ថុនោះនៅពេលចាប់ផ្តើមសន្តតិកម្ម។ ①

សហព័ទ្ធអាចធ្វើលទ្ធកម្មសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ ក្នុងនាមជាជម្រើសមួយនៅពេលបែងចែកមត៌កក៏បាន ឬ ②សហព័ទ្ធអាចធ្វើលទ្ធកម្មសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ តាមរយៈអច្ច័យទានរបស់មតកជនក៏បាន។

ឧបមាថា មត៌កសរុបមានចំនួន 50ម៉ឺនដុល្លារ (ផ្ទះតម្លៃ 30ម៉ឺនដុល្លារ ហើយប្រាក់ក្នុងគណនីចំនួន 20ម៉ឺនដុល្លារ) ហើយសន្តតិជនរួមមាន ប្រពន្ធ និង កូន 2នាក់។ ករណីនេះពុំមានមតកសាសន៍ទេ ហេតុនេះ សន្តតិកម្មត្រូវបែងចែកជា 1ភាគ2 តាមការកំណត់របស់ច្បាប់។ នៅមុនពេលវិសោធនកម្ម ប្រពន្ធត្រូវទទួលបានសន្តតិកម្មក្នុងចំនួន 25ម៉ឺនដុល្លារប៉ុណ្ណោះ ហេតុនេះ គាត់មិនអាចធ្វើសន្តតិកម្មទាំងស្រុងនូវកម្មសិទ្ធិនៃផ្ទះបានទេ។ ដូចនេះ ផ្ទះនោះត្រូវលក់ ហើយប្តូរជាប្រាក់ ដើម្បីបែងចែកទៅសន្តតិជន។ ហើយក្រោយមក សហព័ទ្ធនឹងបាត់បង់ផ្ទះដើម្បីស្នាក់នៅបន្តទៀត។ ដូចនេះ បន្ទាប់ពីការធ្វើវិសោធនកម្ម កម្មសិទ្ធិនៃផ្ទះដែលជាកម្មសិទ្ធិដែលមានភ្ជាប់បន្ទុក (កាតព្វកិច្ចដែលត្រូវឱ្យសហព័ទ្ធរស់នៅក្នុងអំឡុងពេលជាក់លាក់មួយ គឺជា «បន្ទុក») និង សិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ ត្រូវយកមកបែងចែកគ្នា ហើយប្រពន្ធត្រូវទទួលសន្តតិកម្មនូវសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធ ដើម្បីអាចបន្តរស់នៅផ្ទះរបស់ខ្លួន ចំណែកឯ កូនត្រូវទទួលសន្តតិកម្មនូវកម្មសិទ្ធិដែលភ្ជាប់បន្ទុក។ ឧបមាថា តម្លៃនៃសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធមានចំនួន 15ម៉ឺនដុល្លារ ក្នុងករណីនេះ ប្រពន្ធអាចធ្វើសន្តតិកម្មនូវសិទ្ធិអាស្រ័យនៅ និង ប្រាក់ក្នុងគណនីចំនួន 10ម៉ឺនដុល្លារទៀត (កូនធ្វើសន្តតិកម្មនូវកម្មសិទ្ធិដែលមានភ្ជាប់បន្ទុកចំនួន 15ម៉ឺនដុល្លារ និង ប្រាក់ក្នុងគណនីចំនួន 10ម៉ឺនដុល្លារ)។ តាមរយៈនេះ ប្រពន្ធអាចរក្សាបានទាំងកន្លែងស្នាក់នៅ និង ប្រាក់ថ្លៃជីវភាពបាន។

អំឡុងពេលអត្ថិភាពនៃសិទ្ធិអាស្រ័យនៅរបស់សហព័ទ្ធនេះ គឺពេញមួយជីវិតរបស់សហព័ទ្ធ (វាក្យខណ្ឌទី1 មាត្រា1030 ថ្មី។ ប៉ុន្តែ គេអាចកំណត់ផ្សេងបាន តាមរយៈការពិភាក្សាបែងចែកទ្រព្យសម្បត្តិ, មតកសាសន៍ ឬ ដីកាសម្រេចរបស់តុលាការគ្រួសារ។ វាក្យខណ្ឌទី2 មាត្រាដដែល)។ មានន័យថា នៅពេលដែលសហព័ន្ធបានស្លាប់ កូនដែលទទួលកម្មសិទ្ធិដែលមានភ្ជាប់បន្ទុក នឹងទទួលបានកម្មសិទ្ធិយ៉ាងពេញលេញ នៅចំណុចពេលដែល «បន្ទុក» បានបាត់បង់នោះ។

### (3) សិទ្ធិអាស្រ័យនៅរយៈពេលខ្លីរបស់សហព័ទ្ធ

សិទ្ធិអាស្រ័យនៅរយៈពេលខ្លីរបស់សហព័ទ្ធ សំដៅទៅលើសិទ្ធិដែលសហព័ទ្ធអាចបន្តប្រើប្រាស់ដោយមិនគិតកម្រៃពីអគារជាកម្មសិទ្ធិរបស់មតកជន ក្នុងអំឡុងពេលរហូតដល់មានការសម្រេចស្ថាពរចំពោះអគារនោះតាមរយៈការពិភាក្សាបែងចែកទ្រព្យសម្បត្តិ ឬ ក្នុងអំឡុងពេល 6ខែ គិតចាប់ពីពេលដែលសន្តតិកម្មបានចាប់ផ្តើម ក្នុងករណីដែលសហព័ទ្ធនោះកំពុងស្នាក់នៅដោយមិនគិតកម្រៃលើអគារនោះនៅពេលចាប់ផ្តើមសន្តតិកម្ម នៅក្នុងរឿងក្តីដែលត្រូវបែងចែកមត៌ករវាងសហសន្តតិជន (មាត្រា1037 ថ្មី)។ នៅក្នុងយុត្តិសាស្ត្រច្បាប់មុនពេលវិសោធនកម្ម គេបានសន្មតថា ជាគោលការណ៍ មតកជន និង សន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ បានបង្កើតនូវកិច្ចសន្យាជួលរវាងគ្នា ប្រសិនបើសន្តតិជននោះកំពុងតែរស់នៅផ្ទះរបស់មតកជន នៅពេលចាប់ផ្តើមសន្តតិកម្ម។ ប៉ុន្តែ នៅក្នុងយុត្តិសាស្ត្រច្បាប់នេះមានចំណុចបញ្ហាមួយ។ ប្រសិនបើផ្ទះស្នាក់នោះបានធ្វើអច្ច័យទានទៅឱ្យតតិយ

ជន ឬ មតកជនបានបង្ហាញឆន្ទៈបដិសេធ ក្នុងករណីនេះ សិទ្ធិជួលមិនត្រូវបានសន្មតថាកើតឡើងនោះទេ។ ដូចនេះ តាមរយៈបញ្ញត្តិនៃសិទ្ធិអាស្រ័យនៅរយៈពេលខ្លីរបស់សហព័ទ្ធនេះ សហព័ទ្ធអាចបន្តអាស្រ័យនៅយ៉ាងហោចណាស់រយៈពេល 6ខែ បើទោះបីជាមតកជនជាអាទិ៍មានឆន្ទៈយ៉ាងណាក៏ដោយ។

### 6. **ភាគបម្រុង**

ក្រមរដ្ឋប្បវេណីមានកំណត់អំពីប្រព័ន្ធភាគបម្រុង ហើយវាជាការកម្រិតជាក់លាក់មួយចំពោះសេរីភាពនៃមតកសាសន៍។ បើផ្អែកតាមការគោរពឆន្ទៈរបស់បុគ្គលឯកជន គេគួរតែទទួលស្គាល់នូវសេរីភាពនៃការចាត់ចែងទាំងពេលនៅរស់ និងការចាត់ចែងក្រោយពេលស្លាប់ ប៉ុន្តែ ក្រុមគ្រួសារដែលទទួលបានអាហារកាតព្វកិច្ចពីអ្នកស្លាប់ជាអាទិ៍ និង ការរំពឹងទុកនៃការទទួលបន្តទ្រព្យសម្បត្តិរបស់សន្តតិជនដែលត្រូវសន្មត ក៏គួរតែត្រូវបានការពារផងដែរ។ ដូចនេះ មត៌កមួយផ្នែកត្រូវចាត់ទុកជាភាគបម្រុង ហើយទុកសម្រាប់ធានាដល់សន្តតិជន។ ប៉ុន្តែ ទោះបីជាមានការធានាភាគបម្រុងនេះក៏ដោយ ក៏ការធ្វើអច្ច័យទាន ឬ ប្រទានកម្មមុនពេលស្លាប់ នូវទ្រព្យសម្បត្តិទាំងអស់មិនត្រូវបានមោឃភាពនោះទេ។ តាមរយៈការអនុវត្តការទាមទារចំនួនដែលបំពានភាគបម្រុង អ្នកមានសិទ្ធិលើភាគបម្រុងដែលរងការបំពានភាគបម្រុង អាចទាមទារជាទឹកប្រាក់ស្មើនឹងកម្រិតនៃការបំពានដល់ភាគបម្រុងបាន (មាត្រា1046 ថ្មី។ មុនវិសោធនកម្មឆ្នាំ2018 គេបានបញ្ញត្តថា អ្នកមានសិទ្ធិលើភាគបម្រុងអាចបដិសេធអច្ច័យទាន និង ប្រទានកម្មពេលនៅរស់ នូវផ្នែកដែលបានបំពានភាគបម្រុងបាន។ ប៉ុន្តែ តាមរយៈវិសោធនកម្មនេះ គេបានប្តូរពីការបដិសេធនោះមកជាអាចទាមទារជាប្រាក់នូវផ្នែកដែលបំពាននោះបាន។ ហេតុនេះ ពាក្យ «ការទាមទារដើម្បីបង្រ្គប់ភាគបម្រុង» នៅក្នុងមាត្រា1031 ដែលប្រើមុនពេលវិសោធនកម្ម ត្រូវប្តូរមក «ការទាមទារចំនួនដែលបំពានភាគបម្រុង» វិញ)។

អ្នកដែលមានសិទ្ធិលើភាគបម្រុងដែលត្រូវបានទទួលស្គាល់ភាគបម្រុង គឺជាបុគ្គលដែលជាសន្តតិជនត្រូវបានសន្មតទាំងអស់ ក្រៅពីបងប្អូនប្រុសស្រី។ សមាមាត្រនៃភាគបម្រុងមានដូចតទៅនេះ : 1 ភាគ 3 នៃទ្រព្យសម្បត្តិសន្តតិកម្ម ក្នុងករណីដែលមានតែបុព្វញាតិខ្សែផ្ទាល់ក្លាយជាសន្តតិជន ហើយ 1 ភាគ 2 នៃទ្រព្យសម្បត្តិ (មាត្រា1042) ក្នុងករណីក្រៅពីនេះ (ករណីដែលមានសហព័ទ្ធ និង បច្ឆាញាតិខ្សែផ្ទាល់ជាអាទិ៍)។ ភាគបម្រុងនីមួយៗរបស់អ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រូវយកមកគណនាតាមសមាមាត្រនៃចំណែកសន្តតិកម្មតាមច្បាប់របស់បុគ្គលនីមួយៗ។ ឧទាហរណ៍ថា សន្តតិជនរួមមាន សហព័ទ្ធ និង កូន 2នាក់។ ដំបូង ភាគបម្រុងសរុប គឺចំនួន 1 ភាគ 2 នៃទ្រព្យសម្បត្តិសន្តតិកម្ម។ បន្ទាប់មកទៀត ចំណែក 1 ភាគ 2 នៃភាគបម្រុងសរុបនោះ ត្រូវចែកទៅឱ្យសហព័ទ្ធ ហើយ ចំណែក 1 ភាគ 2 នៃភាគបម្រុងសរុបដែលនៅសល់ ត្រូវចែកទៅឱ្យកូន 2នាក់។ ហើយកូនទាំង 2 នាក់ ត្រូវយកទៅចែកបន្ត ជា 2 ចំណែកស្មើៗគ្នា។

សូមកត់សម្គាល់ថា ទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ត្រូវរាប់បញ្ចូលទាំងទ្រព្យសម្បត្តិដែលបានបាត់បង់ តាមរយៈប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល 1ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្មផងដែរ (មាត្រា1044)(ចំពោះប្រទានកម្មដែលបានធ្វើឡើងដោយភាគីទាំងសងខាងដែលបានដឹងថា ប្រទានកម្មនោះនឹងប

ណ្តាលឱ្យប៉ះពាល់ដល់ភាគបម្រុង គឺត្រូវតែរាប់បញ្ចូល បើទោះបីជារយៈពេល 1ឆ្នាំ បានកន្លងផុតក៏ដោយ)។ បើមិនកំណត់បែបនេះទេ ប្រព័ន្ធនៃភាគបម្រុងអាចរងការបំផ្លាញ ដោយប្រទានកម្មមុនពេលមតកជនទទួលមរណភាព។ ដូចនេះ ទ្រព្យសម្បត្តិដែលក្លាយជាមូលដ្ឋាននៃភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិនៅពេលស្លាប់ (ពេលចាប់ផ្តើមសន្តតិកម្ម) បូកជាមួយតម្លៃនៃទ្រព្យសម្បត្តិជាក់លាក់ដែលបានធ្វើប្រទានកម្ម ហើយដកចេញវិញនូវចំនួនកាតព្វកិច្ចពីទ្រព្យសម្បត្តិទាំងអស់នោះ (មាត្រា1043 កថាខណ្ឌទី1)។

យ៉ាងណាមិញ សិទ្ធិទាមទារចំនួនដែលបំពានភាគបម្រុងត្រូវរលត់ដោយអាជ្ញាយុកាល បើមិនបានអនុវត្តក្នុងអំឡុងពេល 1ឆ្នាំបានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និង អត្ថិភាពនៃអច្ច័យទាន ឬ ប្រទានកម្មដែលបានបំពានភាគបម្រុង។ សិទ្ធិទាមទារឱ្យកាត់បន្ថយនេះ ក៏ត្រូវរលត់ផងដែរ បើអំឡុងពេល 10ឆ្នាំបានកន្លងផុត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម (មាត្រា1048)។

### 7. **ការបំបែកទ្រព្យសម្បត្តិ**

ម្ចាស់បំណុលលើទ្រព្យសម្បត្តិសន្តតិកម្ម (បុគ្គលដែលមានសិទ្ធិលើបំណុលចំពោះមតកជន) ឬ អច្ច័យលាភីដែលទទួលទ្រព្យសម្បត្តិពីមតកជនតាមរយៈអច្ច័យទាន (ករណីដែលសន្តតិជនខ្លួនឯងផ្ទាល់កំពុងជាប់បំណុល) អាចទាមទារឱ្យតុលាការគ្រួសារ បំបែកទ្រព្យសម្បត្តិសន្តតិកម្មចេញពីទ្រព្យសម្បត្តិរបស់សន្តតិជន ក្នុងអំឡុងពេល 3 ខែ គិតចាប់ពីពេលសន្តតិកម្មចាប់ផ្តើមបាន ដើម្បីការពារមិនឱ្យទ្រព្យសម្បត្តិសន្តតិកម្ម និងទ្រព្យសម្បត្តិរបស់សន្តតិជនប្រឡូកចូលគ្នា ហើយម្ចាស់បំណុលមិនអាចទាមទារឱ្យផ្តល់តាវកាលិកបាន (នេះហៅថា ការបំបែកទ្រព្យសម្បត្តិប្រភេទទីមួយ។ មាត្រា941 កថាខណ្ឌទី1)។ ហើយបុគ្គលដែលបានទាមទារឱ្យបំបែកទ្រព្យសម្បត្តិ អាចទទួលការសងពីទ្រព្យសម្បត្តិសន្តតិកម្មនោះ មុនម្ចាស់បំណុលនៃសន្តតិជនបាន (មាត្រា942)។ ផ្ទុយមកវិញ ម្ចាស់បំណុលរបស់សន្តតិជន ក៏អាចទាមទារឱ្យបំបែកទ្រព្យសម្បត្តិផងដែរ (ក្នុងករណីដែលសន្តតិជនបានទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិអកម្មជាច្រើន ហើយស្ថានភាពហិរញ្ញវត្ថុក្លាយជាយ៉ាប់យ៉ឺនខ្លាំង) ដើម្បីរក្សាការពារនូវការប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនបាន (នេះហៅថា ការបំបែកទ្រព្យសម្បត្តិប្រភេទទីពីរ។ មាត្រា950)។

### 8. **នត្ថិភាពនៃសន្តតិជន**

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កត្រូវក្លាយជានីតិបុគ្គល (នីតិបុគ្គលមត៌ក។ មាត្រា951)។ នៅក្នុងករណីនេះ តុលាការគ្រួសារត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមការទាមទាររបស់បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ ឬ ព្រះរាជអាជ្ញា (មាត្រា952 កថាខណ្ឌទី1។ បញ្ញត្តិស្តីពីអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលអវត្តមានត្រូវយកមកអនុវត្តដូចគ្នា ចំពោះករណីអ្នកគ្រប់គ្រងមត៌កនេះ។ មាត្រា953)។ ទោះបីជាមិនអាចស្វែងរកឃើញសន្តតិជន នៅពេលដែលតុលាការគ្រួសារ ប្រកាសជាសាធារណៈអំពីការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កក៏ដោយ ក៏អ្នកគ្រប់គ្រងនោះត្រូវប្រកាសជាសាធារណៈ ដើម្បីផ្តល់ឱកាសឱ្យម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាច

ដាក់ពាក្យសុំទាមទារ (មាត្រា957)។ ហើយតុលាការគ្រួសារអាចប្រកាសអំពីការស្រាវជ្រាវរកសន្តតិជន តាមការទាមទាររបស់អ្នកគ្រប់គ្រង ឬ ព្រះរាជអាជ្ញាបាន (មាត្រា958)។ បើសិនជានៅតែមិនអាចរកឃើញសន្តតិជនទៀត តុលាការគ្រួសារ អាចផ្តល់មត៌កទាំងអស់ ឬ មួយផ្នែកដែលនៅសល់ក្រោយពីការជម្រះបញ្ជី ទៅឱ្យជនដែលមានជីវភាពជាមួយនឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនមាននិស្ស័យពិសេសផ្សេងទៀត តាមការទាមទាររបស់ជនទាំងនោះបាន (ការផ្តល់ចំណែកមត៌កទៅឱ្យ**ជនមាននិស្ស័យពិសេស**។ មាត្រា958.3)។ នៅក្នុងករណីដែលពុំមានទាំងជនមាននិស្ស័យពិសេសទៀត មត៌កដែលនៅសល់ទាំងអស់ត្រូវដាក់ទៅក្នុងរតនាគាររបស់រដ្ឋ (មាត្រា959)។

សូមអ្នកទាំងអស់គ្នាកុំយល់ច្រលំអំពី ការផ្តល់ចំណែកមត៌កឱ្យជនមាននិស្ស័យពិសេស និង ជនដែលផ្តល់វិភាគទានពិសេស ដែលត្រូវបានបង្កើតថ្មីនៅក្នុងវិសោធនកម្មឆ្នាំ2018។ ប្រព័ន្ធជនដែលផ្តល់វិភាគទានពិសេសដែលបានរៀបរាប់ខាងលើនេះ (មាត្រា1050 ថ្មី, សូមយោងជំពូកនេះ II.1(4)③) គឺជាប្រព័ន្ធដែលគាំពារដល់សាច់ញាតិដែលបានថែទាំព្យាបាលជាអាទិ៍ដោយមិនយកកម្រៃ ហើយមិនអាចក្លាយជាសន្តតិជន នៅពេលដែលមានសន្តតិជនផ្សេងទៀត។ ចំណែកឯ ការផ្តល់ចំណែកមត៌កឱ្យជនមាននិស្ស័យពិសេស ត្រូវយកមកប្រើប្រាស់តែក្នុងករណីដែលពុំមានសន្តតិជនណាម្នាក់ប៉ុណ្ណោះ។

## ជំពូកទី 10 : ជំបូន្មានក្នុងការសិក្សា

I. **មុនពេលទម្លាក់ទាំងននចុះ**

II. **ជំបូន្មាននៃការសិក្សាក្រមរដ្ឋប្បវេណីសម្រាប់អ្នកអានកម្រិតដំបូង**

1. វិធីសិក្សា

2. យុត្តិសាស្ត្រ និង ទ្រឹស្តីបកស្រាយ

III. **ជំបូន្មាននៃការសិក្សាក្រមរដ្ឋប្បវេណីសម្រាប់អ្នកអានកម្រិតមធ្យម**

1. វិធីសិក្សា

2. ប្រព័ន្ធតុលាការ និង យុត្តិសាស្ត្រ

3. សម្រាប់បុគ្គលដែលចង់ក្លាយជាអ្នកអានកម្រិតខ្ពស់

IV. **សេចក្តីសន្និដ្ឋាន**

## I. មុនពេលទម្លាក់ទាំងនេះចុះ

នៅជំពូកមុននេះ យើងបានបញ្ចប់អំពីទិដ្ឋភាពទូទៅទាំងស្រុងរបស់ក្រមរដ្ឋប្បវេណី។ នៅមុនពេលជម្រាលាពីអ្នកអានទាំងអស់គ្នា ខ្ញុំសូមរៀបរាប់បន្ថែមអំពីវិធីសិក្សាក្រមរដ្ឋប្បវេណីដែលធ្លាប់ឆ្លងកាត់ដោយខ្លួនឯង និង ដំបូន្មានសម្រាប់អ្នកទាំងអស់គ្នាដើម្បីឈានទៅការសិក្សាកម្រិតកាន់តែខ្ពស់ទៅទៀត។ ខ្លឹមសារនេះសម្រាប់អ្នកអានគ្រប់កម្រិត ដែលរួមមានដំបូន្មានសម្រាប់អ្នកអានកម្រិតដំបូង និង សម្រាប់អ្នកអានកម្រិតមធ្យម ប៉ុន្តែ ទោះបីជាខ្លួនអ្នកទាំងអស់គ្នាស្ថិតនៅក្នុងកម្រិតណាមួយក៏ដោយ ក៏សូមអានដំបូន្មានសម្រាប់កម្រិតទាំងពីរនេះតែម្តង។

## II. ដំបូន្មាននៃការសិក្សាក្រមរដ្ឋប្បវេណីសម្រាប់អ្នកអានកម្រិតដំបូង

### 1. វិធីសិក្សា

សូមអ្នកទាំងអស់គ្នាប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការអានមកដល់ត្រឹមនេះ ហើយស្វែងយល់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ នៅទីនេះ ខ្ញុំសូមបង្ហាញអំពីចំណេះដឹងត្រៀមដល់អ្នកទាំងអស់គ្នា។

#### (1) ការសិក្សាច្បាប់គឺជាមុខវិជ្ជាតម្រូវឱ្យយល់

មានបុគ្គលខ្លះ ជាពិសេសបុគ្គលដែលមានបំណងប្រឡងយកវិជ្ជាជីវៈ ប្រហែលជាចាប់ផ្តើមសិក្សាមុខវិជ្ជាច្បាប់ ដោយការទន្ទេញតាំងពីដើមមកហើយមើលទៅ។ ប៉ុន្តែ នេះជាវិធីសិក្សាដែលមិនត្រឹមត្រូវ។ មុខវិជ្ជាច្បាប់មិនមែនជាមុខវិជ្ជាទន្ទេញនោះទេ។ នៅក្នុងដំណាក់កាលដែលយើងសង្ខេបនូវចំណុចសំខាន់ៗ ដើម្បីឆ្លើយសំណួរឱ្យបានរហ័ស ប្រហែលជាចាំបាច់ត្រូវទន្ទេញក៏ថាបាន ប៉ុន្តែ នៅមុនដល់ដំណាក់កាលនេះ យើងត្រូវសិក្សាដោយពិចារណាថា ហេតុអ្វីបានជាប្រព័ន្ធនេះត្រូវបានបង្កើតឡើង ឬ តើមូលដ្ឋាននៃវិធានបែបនេះគឺជាអ្វី ជាអាទិ៍ ហើយឈានទៅស្វែងយល់អំពីបទបញ្ញត្តិនីមួយៗ។ ចំពោះការសិក្សាច្បាប់ពិសេស ឧទាហរណ៍ថា ការរៀនច្បាប់ពន្ធនីមួយៗដើម្បីត្រៀមសម្រាប់ប្រឡងភ្នាក់ងារពន្ធដារជាអាទិ៍ វាប្រហែលជាមានភាពចាំបាច់ក្នុងការចងចាំនូវវិធានពិសេសនានា ប៉ុន្តែ ក្នុងករណីនេះក៏ដោយ ក៏អ្នកទាំងអស់គ្នាត្រូវយល់រចនាសម្ព័ន្ធច្បាប់ទាំងមូលដោយពិចារណាអំពីស្តង់ដារ និង មូលដ្ឋានជាអាទិ៍។ ចំពោះច្បាប់ទូទៅវិញ នៅក្នុងករណីក្រមរដ្ឋប្បវេណីដែលជាច្បាប់មូលដ្ឋាននៃនីតិឯកជននេះ បើទោះបីជាអ្នកទាំងអស់គ្នាចង់ទន្ទេញឱ្យចាំក៏មិនអាចចាំអស់បានឡើយ។ នៅក្នុងស្ថានភាពនីមួយៗ យើងពិចារណាអំពីផលប្រយោជន៍របស់ភាគីដែលកំពុងតែប្រឈមគ្នា ដោយឈរលើការគោរពឆន្ទៈរបស់ភាគី និង សមភាពរបស់ភាគី ហើយឈានទៅសន្និដ្ឋានអំពីគោលគំនិតដែលស្រដៀងគ្នា តាមរយៈការស្វែងយល់ចំណុចនីមួយៗកន្លងមក (នៅក្នុងចំណុចមុន គេមានគោលគំនិតបែបនេះ ហើយគេបានតាក់តែងបញ្ញត្តិបែបនេះ ហេតុនេះនៅក្នុងចំណុចនេះក៏អាចប្រើបែបនេះដូចគ្នា ដូចនេះ វាគួរតែជាបញ្ញត្តិដែលមានខ្លឹមសារយ៉ាងនេះ)។

(2) **បង្កើតគំនូសទំនាក់ទំនង**

វាអាចលម្អិតពេកហើយ ប៉ុន្តែ ខ្ញុំសូមឱ្យយោបល់ខ្លះអំពីវិធីបន្តការអាន នៅពេលដែលអានសៀវភៅដែលពន្យល់អំពីច្បាប់។ មនុស្សភាគច្រើនប្រហែលជាអានដោយយកប៊ិចក្រហមគូសពីក្រោម ឬ យកហ្វឺតពណ៌ផ្សេងៗទៅហាយឡាយពីលើអត្ថបទ។ ការអានដោយវិធីនេះក៏ល្អដែរ។ ប៉ុន្តែ ការស្វែងយល់ដោយគ្មានគោលដៅ និង ដោយពាក្យពេចន៍ គឺពិបាកនឹងចងចាំ។ ដូចនេះ ខ្ញុំលើកទឹកចិត្តឱ្យ អ្នកទាំងអស់គ្នាខំប្រឹងស្វែងយល់ ដោយប្រើប្រាស់ខ្មៅដៃ ហើយគូសគំនូសទំនាក់ទំនងរបស់ភាគីនៅលើកន្លែងណាមួយ ឬលើគែមសៀវភៅក៏បានដែរ។ ឧទាហរណ៍ថា «A បានធ្វើអនុប្បទានដីមួយកន្លែងទៅ B ហើយ B បានធ្វើអនុប្បទានបន្តទៅឱ្យ C។ ប៉ុន្តែ ការចុះបញ្ជីកំពុងស្ថិតនៅក្នុងឈ្មោះរបស់ B នៅឡើយ»។ ដូចនេះ គំនូសទំនាក់ទំនងអាចគូសបានដូចខាងក្រោមនេះ ៖




ប៉ុន្តែ ឧទាហរណ៍ថា « A បានធ្វើអនុប្បទានដីមួយកន្លែងទៅ B ហើយក្រោយមក A បានធ្វើអនុប្បទានដីដូចគ្នានេះទៅ C។ ប៉ុន្តែ ការចុះបញ្ជីស្ថិតនៅឈ្មោះរបស់ A នៅឡើយ។ ដូចនេះ គំនូសទំនាក់ទំនងអាចគូសបានដូចខាងក្រោមនេះ ៖




លើសពីនេះ បើសិនជានេះមិនមែនជាអចលនវត្ថុ ហើយជាការធ្វើអនុប្បទានសិទ្ធិលើបំណុលវិញ ការគូសគំនូសក៏ត្រូវផ្ទេមួយកម្រិតថែមទៀត។ ឧទាហរណ៍ថា «សិទ្ធិលើបំណុលដែល A មានចំពោះ B បានផ្ទេរទៅឱ្យ C» ក្នុងករណីនេះ បើសិនជាយើងគូររូបព្រួញខ្សែរមួយតំណាងឱ្យសិទ្ធិលើបំណុល ហើយ រូបព្រួញខ្សែពីរតំណាងឱ្យការធ្វើអនុប្បទាន វាកាន់តែងាយស្រួលយល់ (សូមយោង ជំពូកទី6 II)។

នៅពេលដែលអ្នកទាំងអស់គ្នាអានសៀវភៅច្បាប់ដ៏ធំក៏ដោយ សូមប្រើប្រាស់វិធីនេះដូចគ្នា។ យើងអាចគូស គំនូសបុគ្គលដែលលេចឡើងនៅក្នុងមាត្រាច្បាប់ដូចជា អក្សរ A តំណាងឱ្យអ្នកលក់ ហើយ B តំណាងឱ្យអ្នកទិញ ហើយ C តំណាងឱ្យតតិយជន បន្ទាប់មកគូសទំនាក់ទំនងរបស់បុគ្គលទាំងនេះ។ ខ្ញុំយល់ឃើញថា អ្នកទាំងអស់គ្នានឹងមានអារម្មណ៍ថា យល់អំពីខ្លឹមសារនៃមាត្រាច្បាប់ជាងការហាយឡាយខ្លឹមសារសំខាន់ទៅទៀត។

## 2. **យុត្តិសាស្ត្រ និង ទ្រឹស្ដីបកស្រាយ**

នៅក្នុងសៀវភៅនេះ ខ្ញុំបានពន្យល់អំពីប្រព័ន្ធ និង បញ្ញត្តិសំខាន់ៗនីមួយៗនៅក្នុងក្រមរដ្ឋប្បវេណី ប៉ុន្តែ ពុំបានបង្ហាញលម្អិតអំពី យុត្តិសាស្ត្រ និង ទ្រឹស្ដីបកស្រាយនោះទេ។ ហេតុនេះ ខ្ញុំសូមពន្យល់អំពី តួនាទីរបស់យុត្តិសាស្ត្រ និង ទ្រឹស្ដីបកស្រាយនៅក្នុងការសិក្សាក្រមរដ្ឋប្បវេណី ព្រមទាំងអត្ថន័យនៃការសិក្សាយុត្តិសាស្ត្រ និង ទ្រឹស្ដីបកស្រាយទាំងនោះ។

### (1) **យុត្តិសាស្ត្រ**

បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវបានតាក់តែងឡើង ដោយព្យាករអំពីវិវាទនានាដែលនឹងអាចកើតមានឡើងជាក់ស្តែង ប៉ុន្តែ វិវាទផ្លូវច្បាប់ជាក់ស្តែងគឺមានយ៉ាងច្រើនសន្ធឹកសន្ធាប់ ហេតុនេះ មាត្រាច្បាប់ដែលបានតាក់តែងឡើងមួយមុខ មិនអាចគ្របដណ្តប់គ្រប់ករណីវិវាទទាំងអស់នោះទេ។ ហើយពេលខ្លះ ការបកស្រាយខ្លឹមសារដែលសរសេរនៅក្នុងមាត្រាច្បាប់ ក៏ក្លាយបញ្ហាដែលត្រូវវិនិច្ឆ័យដោយតុលាការផងដែរ។ នៅក្នុងករណីបែបនេះ យុត្តិសាស្ត្រមានការងារបំពេញចន្លោះនៃមាត្រាច្បាប់ ឬ បញ្ជាក់ឱ្យច្បាស់លាស់នូវចំណុចដែលមានមន្ទិលក្នុងការបកស្រាយជាអាទិ៍។ ករណីដែលយុត្តិសាស្ត្រដំណើរការបែបនេះ ត្រូវបានគេយល់ថា «ច្បាប់យុត្តិសាស្ត្រត្រូវបានបង្កើតឡើង» ឬ «យុត្តិសាស្ត្រគំរូត្រូវបានបង្កើតឡើង»។ សូមចំណាំថា ខ្លឹមសារដែលត្រូវបានវាយតម្លៃថាជា «យុត្តិសាស្ត្រ» ជាទូទៅ គឺជាការបកស្រាយទៅលើចំណុចដែលមានទ្រឹស្ដីនានាបានបកស្រាយច្រើន ដោយសាលដីការបស់តុលាការកំពូល (ឬឧត្តមក្រុមប្រឹក្សាតុលាការកំពូល)។

### (2) **ទ្រឹស្ដីបកស្រាយ**

ផ្ទុយមកវិញ តើទ្រឹស្ដីបកស្រាយមានអត្ថន័យបែបណា។ ចំពោះចំណុចដែលអ្នកច្បាប់មានគំនិតខ្វែងគ្នាលើការបកស្រាយមាត្រាច្បាប់ ឬ ចំពោះដំណោះស្រាយទៅលើវិវាទថ្មីដែលពុំមានមាត្រាច្បាប់កំណត់ជាដើម ទ្រឹស្ដីបកស្រាយជាបឋមនឹងបង្ហាញអំពីចំណុចបញ្ហា ហើយមានពេលខ្លះលើកឡើងពីយុត្តិសាស្ត្រដែលមានពីមុន។ ទោះបីជាមានយុត្តិសាស្ត្រពីមុនដែលបកស្រាយស្ទើរតែជាក់លាក់ក៏ដោយ ក៏ទ្រឹស្ដីបកស្រាយអាចបង្ហាញអំពីភាពមិនត្រឹមត្រូវនៃយុត្តិសាស្ត្រពីមុននោះ ដោយសារតែសង្ខិតភាពនៃការបកស្រាយ ឬ ការវិវត្តន៍នៃសង្គមជាអាទិ៍ ហើយមានករណីខ្លះ ទ្រឹស្ដីបកស្រាយអាចរិះគន់ទៅលើយុត្តិសាស្ត្រ ហើយជំរុញឱ្យមានការកែប្រែយុត្តិសាស្ត្រ។ ដូចនេះ ការសិក្សាទ្រឹស្ដីបកស្រាយកាន់តែមានភាពចាំបាច់ នៅពេលអ្នកទាំងអស់គ្នាសិក្សាដល់កម្រិតខ្ពស់។ ប៉ុន្តែ ចំពោះអ្នកសិក្សា

កម្រិតដំបូង សូមសិក្សាតែទៅលើទ្រឹស្ដីបកស្រាយដែលគេហៅថាទ្រឹស្ដីទូទៅ ឬ ទ្រឹស្ដីមានឥទ្ធិពលទៅបានហើយ (ប៉ុន្តែ ទោះបីជា «ទ្រឹស្ដីទូទៅ» ដែលស្ទើរតែអ្នកសិក្សាច្បាប់ទាំងអស់ឯកភាពក៏ដោយ ក៏មានករណីខ្លះ នៅពេលដែលបន្តស្រាវជ្រាវទៅ ទ្រឹស្ដីភាគតិចដែលរិះគន់បានក្លាយជាមានឥទ្ធិពលជាងក៏មានដែរ)។

(3) **ការចេញដំណើរពីមាត្រា**

ដូចបានរៀបរាប់ខាងលើនេះអំពី មុខងាររបស់យុត្តិសាស្ត្រ និង ទ្រឹស្ដីបកស្រាយរួចហើយ ប៉ុន្តែ ចំណុចដែលសំខាន់បំផុតគឺជាខ្លឹមសារដែលគេបានសរសេរក្នុងមាត្រាច្បាប់។ ការយល់អំពីខ្លឹមសារយ៉ាងត្រឹមត្រូវនៃមាត្រាច្បាប់ហើយក្រោយមកបង្កើនចំណេះដឹងអំពីយុត្តិសាស្ត្រ និង ទ្រឹស្ដីបកស្រាយ គឺជាគោលដៅល្អបំផុត។ នៅពេលដែលអ្នកទាំងអស់គ្នាសិក្សា សូមមានច្បាប់នៅក្នុងដៃ ហើយព្យាយាមចងចាំនូវគោលគំនិតរបស់មាត្រាជាដំបូង។

## III. **ដំបូន្មាននៃការសិក្សាក្រមរដ្ឋប្បវេណីសម្រាប់អ្នកអានកម្រិតមធ្យម**

### 1. **វិធីសិក្សា**

ខាងក្រោមនេះ គឺជាយោបល់របស់ខ្ញុំផ្ទាល់ខ្លួនបន្តិចបន្តួច សម្រាប់បុគ្គលដែលក្លាយជាអ្នកសិក្សាកម្រិតមធ្យមនៃក្រមរដ្ឋប្បវេណី។

(1) **សូមពិចារណារឿងរ៉ាវលើជំហររបស់ភាគីម្ខាងទៀត**

នៅក្នុងក្រមរដ្ឋប្បវេណី ការពិចារណាអំពីតុល្យភាពនៃផលប្រយោជន៍របស់ភាគី គឺមានសារៈសំខាន់យ៉ាងខ្លាំង។ ឧទាហរណ៍ថា នៅក្នុងកិច្ចសន្យារវាង A និង B បើសិនជា A ទទួលបានផលប្រយោជន៍ខ្លាំង នោះមានន័យថា B នឹងបាត់បង់ផលប្រយោជន៍ខ្លាំង។ ហេតុនេះ ក្រមរដ្ឋប្បវេណីមានគោលដៅចម្បងក្នុងការរក្សាសមភាពរបស់ភាគីនៅក្នុងប្រភេទនៃជម្លោះនានាក្នុងសង្គម ហើយធ្វើការកែលំអរផ្សេងៗដើម្បីធានានូវសមភាពនេះ និង ផ្ដល់នូវកម្រិតស្ដង់ដារមួយសម្រាប់វាស់នូវសេចក្ដីសម្រេចជាដើម។ បើសិនជាយើងអាចពិចារណាទៅលើគោលជំហររបស់ភាគីតែម្ខាងនោះទេ យើងពុំអាចសិក្សាក្រមរដ្ឋប្បវេណីបានល្អឡើយ។ វាមានករណីជាច្រើនដែលយើងគិតថា វាជារឿងសាមញ្ញធម្មតា ប៉ុន្តែ វាមិនមានជារឿងសាមញ្ញធម្មតារបស់អ្នកដទៃ បើសិនជាយើងផ្លាស់ប្ដូរនូវជំហររបស់ខ្លួនឯង (រឿងសាមញ្ញរបស់សិស្សអាចជារឿងមិនសាមញ្ញរបស់គ្រូ ឬ រឿងសាមញ្ញរបស់ម្ដាយក្មេកអាចជារឿងមិនសាមញ្ញរបស់កូនប្រសារស្រី ជាអាទិ៍។ ពិតហើយ ករណីបញ្ច្រាសពីនេះក៏មានដែរ)។ នៅក្នុងជីវភាពធម្មតាក៏ដោយ បើសិនជាអ្នកទាំងអស់គ្នាសាកល្បងពិចារណា ពីគោលជំហររបស់អ្នកទៃវិញយ៉ាងម៉េចដែរ។

### (2) គ្មានមូលដ្ឋានវាយតម្លៃដែលអាចកាត់ជាពីរស្មើគ្នា

នៅពេលដែលសិក្សាក្រមរដ្ឋប្បវេណីទៅមុខទៀត អ្នកទាំងអស់គ្នានឹងចាប់ផ្តើមមានសំនួរថា «តើនៅក្នុងក្រមរដ្ឋប្បវេណីមាននូវគោលគំនិត និង មូលដ្ឋាននៃការវិនិច្ឆ័យដែលយើងអាចយកគោលគំនិតនោះ មកដោះស្រាយឱ្យបានជាក់លាក់ និង ត្រឹមត្រូវដែរឬទេ?» ។ បើសិនជានៅក្នុងក្រមព្រហ្មទណ្ឌ ឬ ច្បាប់ស្តីពីមូលប្បទានប័ត្រជាដើម តែងមានកំណត់អំពីគោលជំហរ ឬ របបជាមូលដ្ឋានយ៉ាងច្បាស់លាស់ ហេតុនេះ យើងអាចមើលឃើញរូបភាពទាំងស្រុងនៃច្បាប់ទាំងមូលបានច្បាស់ ប៉ុន្តែ ខ្ញុំយល់ថានៅក្នុងក្រមរដ្ឋប្បវេណីពុំមានគោលជំហរជាមូលដ្ឋានច្បាស់បែបនេះនោះទេ ហើយខ្ញុំគិតថាយើងនឹងគិតខុស បើសិនជាយល់ឃើញថាក្រមរដ្ឋប្បវេណីមានកំណត់អំពីគោលជំហរទាំងនេះ។ ដូចបានឃើញកន្លងមក ខ្លឹមសារដែលកំណត់ក្នុងក្រមរដ្ឋប្បវេណីពិតជាមានច្រើនបែបច្រើនយ៉ាងណាស់ ហើយមានបញ្ញត្តិជាច្រើនពុំសូវមានទម្រង់បច្ចេកទេសនោះទេ ហេតុនេះ ការយកស្តង់ដារនៃការវិនិច្ឆ័យជាក់លាក់តែមួយទៅអនុវត្ត មិនអាចធ្វើមានរបៀបរៀបរយនោះទេ។ នេះមានន័យថា បុគ្គលដែលមានអត្តចរិកចង់ពឹងផ្អែកលើខ្នាតមួយ ឬ មូលដ្ឋានអ្វីមួយច្បាស់លាស់ ដើម្បីស្វែងយល់អំពីខ្លឹមសារក្រមរដ្ឋប្បវេណី ប្រហែលជាមិនអាចសិក្សាក្រមរដ្ឋប្បវេណីបានល្អនោះទេ។ យើងអាចនិយាយជាលក្ខណៈទូទៅថា គោលគំនិតដើមនៃក្រមរដ្ឋប្បវេណីគឺយុត្តិធម៌ សេរីភាព និង សមភាព ហើយគោលបំណងជាមូលដ្ឋានចម្បងរបស់ក្រមរដ្ឋប្បវេណីគឺ ស្វ័យភាពនៃឆន្ទៈ និង ស្វ័យភាពនៃបុគ្គលឯកជន ហើយដើម្បីឱ្យសម្រេចនូវគោលគំនិត និង គោលបំណងខាងលើនេះ យើងត្រូវមានប្រជាពលរដ្ឋដែលអាចបង្កើតនូវវិធានរបស់ខ្លួនដោយខ្លួនឯងបាន។

យ៉ាងណាមិញ នៅក្នុងចំណោមអ្នកសិក្សាច្បាប់ មានបុគ្គលមួយចំនួនបានលើកឡើងថា គោលបំណងចម្បងរបស់ក្រមរដ្ឋប្បវេណី គឺ «សុវត្ថិភាពនៃជំនួញ» ហើយការលើកឡើងនេះមិនត្រឹមត្រូវនោះទេ។ សុវត្ថិភាពនៃជំនួញសំដៅទៅលើឧទាហរណ៍ដូចជា វត្ថុដែលជាកម្មសិទ្ធិរបស់ A បានធ្លាក់ទៅលើដៃរបស់ C ដោយសកម្មភាពរបស់ B និង C ហើយបើសិនជាយើងការពារសិទ្ធិរបស់ C ដែលបានចូលទៅក្នុងសកម្មភាពជំនួញ ពោលគឺការពារសុវត្ថិភាពលំហូរ ក្នុងករណីនេះ អ្នកដែលត្រូវបាត់បង់ប្រយោជន៍គឺជា A ដែលជាម្ចាស់សិទ្ធិពិតប្រាកដទៅវិញ (ពោលគឺ សុវត្ថិភាពលំនឹង)។ ចំពោះការធ្វើលទ្ធកម្មភ្លាមៗ (មាត្រា192) ក៏ជាប្រព័ន្ធដែលបង្កើតឡើងតាមគោលគំនិតដើមខាងលើនេះដែរ ប៉ុន្តែ វាជាប្រព័ន្ធពិសេសដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។ គោលបំណងដែលក្រមរដ្ឋប្បវេណីផ្តោតសំខាន់គឺជាភាពសុខដុមរមនា រវាងសុវត្ថិភាពលំហូរ ឬ សុវត្ថិភាពលំនឹង ហើយមិនមែនត្រូវការពារនូវសុវត្ថិភាពលំហូរគ្រប់ពេលវេលាទាំងអស់នោះទេ (ចំពោះចំណុចនេះ សូមអ្នកទាំងអស់គ្នាចងចាំថា ច្បាប់ពាណិជ្ជកម្មដែលជាច្បាប់ពិសេសរបស់ក្រមរដ្ឋប្បវេណី មានគោលបំណងឱ្យកិច្ចការជំនួញប្រព្រឹត្តទៅដោយមានវឌ្ឍនៈភាព និង ប្រក្រតីភាព ហេតុនេះ ច្បាប់ពាណិជ្ជកម្មនឹងផ្តល់ការការពារដល់ «សុវត្ថិភាពលំហូរ» ជាងក្រមរដ្ឋប្បវេណី)។

(3) **«ការប្រៀបធៀបផលប្រយោជន៍» គឺជាមធ្យោបាយចុងក្រោយ**

នៅពេលសិក្សាក្រមរដ្ឋប្បវេណីទៅមុខទៀត ឧទាហរណ៍ថា ក្រោយពីពិចារណាលើករណីជាច្រើនរួចហើយ ជាលទ្ធផល ទ្រឹស្តីបកស្រាយខ្លះបានយកមធ្យោបាយ «ប្រៀបធៀបផលប្រយោជន៍» នៅក្នុងដំណាក់កាលដែលត្រូវសម្រេចថាគួការពារ X ឬ Y។ យើងត្រូវពិចារណាគ្រប់ស្ថានភាពដូចជា តើមានដើមហេតុអ្វីដែលបណ្តាលឱ្យភាគីធ្វើសកម្មភាពបែបនេះ? ឬក៏ តើភាគីអាចដឹងជាមុនអំពីស្ថានភាពនេះដែរឬទេ? រួចហើយទើបយើងប្រៀបធៀបនូវផលប្រយោជន៍របស់ភាគីដូចត្រូវទទួលការការពារ។ ប៉ុន្តែ ការពិចារណាបែបនេះ ក៏ត្រូវប្រុងប្រយ័ត្នផងដែរ។ មូលដ្ឋានដែលត្រូវសម្រេចនៅក្នុងក្រមរដ្ឋប្បវេណីគឺ ការបកស្រាយមាត្រា និង ការបកស្រាយឆន្ទៈរបស់ភាគី។ ហេតុនេះ ការស្វែងរកដំណោះស្រាយដោយផ្តោតទៅលើការប្រៀបធៀបផលប្រយោជន៍តែមួយមុខ ហើយមិនពិចារណាអំពីមូលដ្ឋានទាំងនេះរបស់ក្រមរដ្ឋប្បវេណី គឺមិនអាចធ្វើបានឡើយ។ មាត្រាច្បាប់ត្រូវបានបង្កើតឡើង ដោយពិចារណាអំពីតុល្យភាពនៃផលប្រយោជន៍របស់ភាគីជាមុនរួចហើយ។ ដូចនេះ យើងត្រូវផ្តើមចេញពីការស្វែងរក «ការរក្សាតុល្យភាពនៃផលប្រយោជន៍ដែលស្ថិតនៅក្នុងខ្លឹមសារនៃមាត្រាច្បាប់» ជាមុន។ ហើយត្រូវស្វែងយល់អំពី ការអនុវត្តប្រដូច (ការអនុវត្តប្រដូច គឺជាការយកមាត្រាដែលបានតាក់តែងឡើងក្នុងគោលបំណងផ្សេង ទៅអនុវត្តឱ្យទូលាយលើករណីផ្សេងទៀត ដោយមូលហេតុថាមានគោលបំណងដូចគ្នាជាដើម) ដែលជាការបន្លាយខ្សែនៃការអនុវត្តឱ្យវែង។ បើសិនជាយើងពិចារណានៃការអនុវត្តដោយផ្ទាល់ និង អនុវត្តប្រដូចរួចហើយ នៅតែមិនអាចមានចម្លើយទៀត ទើបយើងត្រូវពិចារណាមធ្យោបាយចុងក្រោយដែលជាការប្រៀបធៀបផលប្រយោជន៍។ ហើយមានករណីជាច្រើនដែលគេបកស្រាយដោយយោងលើ**បញ្ញត្តិទូទៅ**រួមមាន **ភាពផ្ទុយនឹងគោលការណ៍សុចរិតភាព** (មាត្រា1 កថាខណ្ឌទី2) និង **ការប្រើប្រាស់សិទ្ធិដោយបំពាន** (មាត្រា1 កថាខណ្ឌទី3) ដូចជាលើកឡើងថា «នៅក្នុងស្ថានភាពបែបនេះ យើងមិនអាចទទួលស្គាល់មធ្យោបាយច្បាប់បែបនេះនោះទេ ដោយសារតែផ្ទុយនឹងគោលការណ៍សុចរិតភាព» ឬ «ការអនុវត្តសិទ្ធិ (ទោះបីជាមានសិទ្ធិក៏ដោយ) នៅក្នុងស្ថានភាពបែបនេះ គឺជាការប្រើប្រាស់សិទ្ធិដោយបំពាន» ជាអាទិ៍ (ការដោះស្រាយដោយប្រើប្រាស់បញ្ញត្តិទូទៅ មានន័យថា ជាការប្រើប្រាស់មធ្យោបាយចុងក្រោយ)។

## 2. ប្រព័ន្ធតុលាការ និង យុត្តិសាស្ត្រ

ខ្ញុំសូមបកស្រាយលម្អិតអំពី ដំណើរនៃការបង្កើត និង របៀបដកស្រង់ «យុត្តិសាស្ត្រ» ដែលបានពន្យល់ដោយសង្ខេបចំពោះអ្នកអានកម្រិតដំបូង ចំពោះអ្នកអានកម្រិតមធ្យមនៅទីនេះ។

នៅក្នុងប្រទេសជប៉ុន ចំពោះវិវាទទូទៅអាចទទួលបានការសម្រេចដោយតុលាការយ៉ាងច្រើនបំផុតគឺ 3 ដង ដោយតុលាការតំបន់–តុលាការឧទ្ធរណ៍–តុលាការកំពូល (ចំពោះរឿងក្តីរដ្ឋប្បវេណីដែលមានចំនួនទឹកប្រាក់តិចគឺត្រូវជម្រះដោយ 3ថ្នាក់ដែលជា តុលាការសង្ខេប–តុលាការតំបន់–តុលាការឧទ្ធរណ៍។ ហើយការសម្រេចសេចក្តីរបស់តុលាការគ្រួសារចំពោះរឿងក្តីគ្រួសារ ជាគោលការណ៍គឺ ជំនុំជម្រះលើកទី1 នៅតុលាការគ្រួសារ–ជំនុំជម្រះលើកទី2 នៅតុលាការឧទ្ធរណ៍)។ ការជំនុំជម្រះរបស់តុលាការទាំងអស់លើកលែងតែតុលាការកំពូល គឺជាការជំនុំ

ជម្រះលើអង្គហេតុដែលជាវិវាទទៅតាមករណីអង្គហេតុនីមួយៗ ហើយតុលាការកំពូលជំនុំជម្រះដោយផ្តោតទៅលើអង្គច្បាប់ប៉ុណ្ណោះ (ការបកស្រាយមាត្រា ជាអាទិ៍)។ ហេតុនេះ ទោះបីជាសេចក្តីសម្រេចរបស់តុលាការជាន់ទាបត្រឹមតុលាការឧទ្ធរណ៍ បានសម្រេចនូវខ្លឹមសារដែលមានប្រភេទដូចគ្នាយ៉ាងច្រើនបែបណាក៏ដោយ ក៏វាមិនអាចក្លាយជាការសម្រេចចុងក្រោយរបស់អង្គតុលាការ ដរាបណាតុលាការកំពូលមិនទាន់បានចេញសាលដីកា។ លុះត្រាតែ ភាគីមិនសុខចិត្តនឹងសាលដីកាតុលាការឧទ្ធរណ៍ និងធ្វើបណ្តឹងសារទុក្ខទៅតុលាការកំពូល ហើយក្រោយមកតុលាការកំពូលចេញសេចក្តីសម្រេច ទើបឈានដល់ដំណាក់កាលដែលច្បាប់យុត្តិសាស្ត្រត្រូវបានបង្កើត។ ដូចនេះ ចំពោះសេចក្តីសម្រេចរបស់តុលាការជាន់ទាបត្រឹមតុលាការឧទ្ធរណ៍ គេមិនហៅថា «យុត្តិសាស្ត្រ» ទេ តែហៅថា «សេចក្តីសម្រេចពីមុន»។ នៅពេលដែលតុលាការកំពូលសម្រេចសេចក្តីម្តងហើយម្តងទៀតតាមគោលគំនិតដដែលទៅលើរឿងក្តីប្រភេទដូចគ្នា វានឹងក្លាយទៅជាច្បាប់យុត្តិសាស្ត្រស្ថាពរ។ ដូចនេះ អ្នកទាំងអស់គ្នាត្រូវសិក្សាផងដែរអំពីសាលដីការតុលាការកំពូលដែលបានក្លាយជាយុត្តិសាស្ត្រច្បាប់ ឬ សាលដីការតុលាការកំពូលណាមួយក៏ដោយដែលមានលទ្ធភាពខ្ពស់ក្លាយជាយុត្តិសាស្ត្រថ្មីនៅពេលក្រោយ។ តុលាការតែងជ្រើសរើសសាលដីការតុលាការកំពូលដែលត្រូវបានវាយតម្លៃជាយុត្តិសាស្ត្រថ្មី ហើយចងក្រងនៅក្នុងកម្រងសាលដីកាតុលាការកំពូល (រដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ ប៉ុន្តែ មិនមែនសាលដីកាតុលាការកំពូលទាំងអស់ត្រូវបានចងក្រងជាសាធារណៈនោះទេ)។ ឧទាហរណ៍ បើយើងដកស្រង់ថា «Judgement of the Supreme Court, March 7, 1974 (Minshu 28-2-174)» វាគឺជាសាលដីកាដែលត្រូវបានប្រកាសដោយសាលសវនាការតូចនៃតុលាការកំពូល ចុះថ្ងៃទី7 ខែមីនា ឆ្នាំ1974 ដូចនេះ សាលដីកានេះត្រូវបានចងក្រងនៅក្នុងកម្រងសាលដីការដ្ឋប្បវេណីតុលាការកំពូលជប៉ុន Minshu ភាគទី28 លេខ2 ទំព័រ174។

ដោយឡែក មានក្រុមហ៊ុនទស្សនាវដ្តីយុត្តិសាស្ត្រដែលបោះពុម្ពសាលក្រមរដ្ឋប្បវេណីមួយចំនួន បានចងក្រងទាំងសាលដីកាតុលាការកំពូល តុលាការឧទ្ធរណ៍ និង តុលាការតំបន់ផងដែរ។ ទស្សនាវដ្តីទាំងនោះមានឈ្មោះដូចជា «Hanrei Jiho (Hanji)» «Hanrei Times (Hanta)» និង «Kinyushoji Hanrei (Kinhan)» ជាអាទិ៍។ នៅក្នុងករណីដែលសាលក្រមនោះមានចងក្រងនៅក្នុងកម្រងសាលដីការដ្ឋប្បវេណីតុលាការកំពូលផង និង ទស្សនាវដ្តីយុត្តិរបស់ក្រុមហ៊ុនឯកជនផង ជាទូទៅ យើងត្រូវដកស្រង់ចេញពីកម្រងសាលដីការដ្ឋប្បវេណីតុលាការកំពូលមកអាន ប៉ុន្តែ ដើម្បីសិក្សាបន្ថែម អ្នកទាំងអស់គ្នាក៏គួរតែមើលទាំងទស្សនាវដ្តីយុត្តិសាស្ត្ររបស់ក្រុមហ៊ុនឯកជនផងដែរ។ ដោយសារតែទស្សនាវដ្តីយុត្តិសាស្ត្ររបស់ក្រុមហ៊ុនឯកជនតែងមានភ្ជាប់មកជាមួយនូវការបកស្រាយដែលគេហៅថា «មតិយោបល់» ទៅលើសាលក្រមដែលបានចងក្រង ហើយវាមានប្រយោជន៍សម្រាប់ការសិក្សា។

### 3. សម្រាប់បុគ្គលដែលចង់ក្លាយជាអ្នកអានកម្រិតខ្ពស់

លើសពីនេះ ខ្ញុំសូមផ្តល់ជាដំបូន្មានខ្លះសម្រាប់បុគ្គលដែលចង់ក្លាយជាអ្នកសិក្សាកម្រិតខ្ពស់ទៅលើជំនាញក្រមរដ្ឋប្បវេណី។ កន្លែងនេះ ចំពោះបុគ្គលដែលមិនចាប់អារម្មណ៍នោះទេ អាចអានរំលងចោលបាន។

#### (1) ការស្វែងយល់អំពីគោលបំណងនៃប្រព័ន្ធនានាដោយចាប់ផ្តើមពីការបកស្រាយច្បាប់

ក្រមរដ្ឋប្បវេណីគឺជាច្បាប់មូលដ្ឋាននៃនីតិឯកជន ហើយត្រូវបានបង្កើតឡើងជិត 110ឆ្នាំ មកហើយ ហេតុនេះ អ្នកទាំងអស់គ្នាប្រហែលជាយល់ថា ចំណុចបញ្ហាដែលត្រូវលើកយកមកបកស្រាយប្រហែលជាលែងមាននៅសល់ទៀតហើយ។ ប៉ុន្តែ ជាក់ស្តែង ចំណុចបញ្ហាគឺនៅសល់ច្រើនខ្លាំងណាស់។ ហើយមូលហេតុមួយនៅក្នុងនោះគឺ ការបកស្រាយឱ្យច្បាស់អំពីគោលបំណងនៃប្រព័ន្ធនានា និង អត្ថន័យនៃបញ្ញត្តិក្នុងនាមជាចំណុចចាប់ផ្តើមនៃកិច្ចការបកស្រាយ មានការយឺតយ៉ាវ។ ក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការស្រាវជ្រាវតាមទិសដៅនេះកើតឡើងយ៉ាងគំហុក ប៉ុន្តែ វានៅមានបញ្ហាជាច្រើននៅឡើយ។ ហើយវិសោធនកម្មក្នុងឆ្នាំ2017 នឹងបង្កើតឱ្យមានបញ្ហានៃការបកស្រាយថ្មីៗទៀត។

តើដើមឡើយប្រព័ន្ធផ្សេងៗនៅក្នុងក្រមរដ្ឋប្បវេណី ផ្តោតលើអ្វី ហើយមានគោលបំណងបែបណា? នេះជាការងារដ៏សំខាន់ដើម្បីសម្រេចថា តើមាត្រានីមួយៗត្រូវបកស្រាយយ៉ាងដូចម្តេច។ និយាយបញ្ច្រាសមកវិញគឺ នៅពេលដែលអ្នកទាំងអស់គ្នាមិនដឹងថា តើមូលហេតុអ្វីបានជាគេបកស្រាយបែបនេះ? សូមអ្នកទាំងអស់គ្នាសិក្សាត្រឡប់ក្រោយទៅរកឫសគល់ និង គោលបំណងនៃប្រព័ន្ធនោះ។ ក្នុងករណីនេះ មានសៀវភៅខ្លះគេសរសេររៀបរាប់យ៉ាងលម្អិតអំពីគោលបំណងនៃប្រព័ន្ធនានា និង សៀវភៅខ្លះពុំមានសរសេរលម្អិតនោះទេ ហេតុនេះ សូមអ្នកទាំងអស់គ្នាអានសៀវភៅផ្សេងៗឱ្យបានច្រើន ហើយប្រៀបធៀបគ្នា។

#### (2) ការប្រែប្រួលនៃសង្គម និង ការបកស្រាយក្រមរដ្ឋប្បវេណី

ក្រោយពេលដែលបានសិក្សាយ៉ាងច្បាស់លាស់អំពីគោលបំណងនៃប្រព័ន្ធរួចហើយ បញ្ហាបន្ទាប់គឺជា ការស្វែងរកវិធីបកស្រាយប្រព័ន្ធ និង មាត្រានីមួយៗឱ្យបានត្រឹមត្រូវ។ វាគឺជាចំណុចដែលមានការពាក់ព័ន្ធគ្នាដូចជា តើក្រមរដ្ឋប្បវេណីមានតួនាទីបែបណានៅក្នុងសង្គម? ឬ តើវាមានទំនាក់ទំនងបែបណាទៅនឹងច្បាប់ពិសេស? ជាអាទិ៍ ពោលគឺ វាមានទំនាក់ទំនងជាមួយភាពសមហេតុផលនៃទ្រឹស្តីនៅក្នុងមុខវិជ្ជាសិក្សា ដែលគេហៅថា «ការសិក្សាអំពីការបកស្រាយច្បាប់»។ វាជាបញ្ហាដែលពិបាកបំផុត។

ជាដំបូង គឺបញ្ហានៃការពិនិត្យមើលលក្ខណៈនៃច្បាប់ ពោលគឺ តើយើងគួរតែទទួលស្គាល់ថា (1) ច្បាប់ត្រូវតែរក្សានូវអត្ថន័យ លក្ខណៈ និង មុខងារ ដែលគេផ្តល់ឱ្យនៅពេលតាក់តែងជារៀងរហូត ឬ (2) ច្បាប់ត្រូវផ្លាស់ប្តូរជាបន្តបន្ទាប់ទៅតាមការវិវត្តន៍របស់សម័យកាលនីមួយៗ (គោលគំនិតទី (1) គឺ ទ្រឹស្តីឆន្ទៈរបស់នីតិករ ហើយគោល

គំនិតទី (2) គឺ ទ្រឹស្តីធន្ទៈរបស់ច្បាប់)។ គោលគំនិតទាំងពីរនេះ ប្រហែលជាមានជាក់ស្តែង ប៉ុន្តែការមើលច្បាប់តាមរយៈការប្រកាន់យកនូវគោលគំនិតណាមួយខាងលើនេះ វានឹងចេញនូវលទ្ធផលគោលគំនិតនៃការបកស្រាយខុសគ្នា។ ខ្ញុំគិតថាវិធីដែលត្រឹមត្រូវសម្រាប់ការបកស្រាយច្បាប់គឺ ចាប់ផ្តើមដំបូងដោយស្វែងយល់ឱ្យបានត្រឹមត្រូវអំពីគោលបំណងដើមនៃប្រព័ន្ធទាំងមូល និង ស្រាវជ្រាវស៊ីជម្រៅអំពីអត្ថន័យដើមរបស់មាត្រានោះ ហើយតាមរយៈនេះ យើងអាចកំណត់អំពីចំនួននៃវិធីសាស្ត្របកស្រាយដែលអាចធ្វើទៅបាន។ ប្រសិនបើមានការវិវត្តន៍សង្គមដែលត្រូវបញ្ចូលនូវតម្រូវការណាមួយដែលខុសពីតម្រូវការសង្គមនៅពេលតាក់តែងច្បាប់នោះ (ឧទាហរណ៍ ខ្លឹមសារអំពីការប្រែប្រួលទម្រង់នៃជំនួញ ឬ ខ្លឹមសារដែលជាទស្សនៈមូលដ្ឋាន ជាអាទិ៍) វាអាចបន្ថែមនូវលទ្ធភាពនៃការបកស្រាយផ្សេងៗទៀត។

បន្ទាប់មក តើគោលគំនិតដែលលើកឡើងថា ច្បាប់គួរតែត្រូវបានធ្វើវិសោធនកម្ម ឬ ត្រូវផ្លាស់ប្តូរទន្ទឹមគ្នាជាមួយការផ្លាស់ប្តូររបស់សង្គម យ៉ាងម៉េចដែរ? ហើយចំណុចនេះ វាអាស្រ័យទៅលើចរិកលក្ខណៈរបស់ច្បាប់នោះ។ ឧបមាថា ច្បាប់ពាណិជ្ជកម្មគឺជាច្បាប់មានលក្ខណៈបច្ចេកទេស និង ឯកទេសខ្លាំងជាងក្រមរដ្ឋប្បវេណី។ ដូចនេះ នៅក្នុងវិស័យនេះគឺចាំបាច់ត្រូវឆ្លើយតបឱ្យបានប្រកៀក និង រហ័សជាមួយការផ្លាស់ប្តូររបស់សង្គម ហេតុនេះ ភាពចាំបាច់ និង ភាពត្រឹមត្រូវនៃការធ្វើវិសោធនកម្មគឺមានកម្រិតខ្ពស់។ តាមជាក់ស្តែងក៏ដោយ ច្បាប់ពាណិជ្ជកម្មត្រូវបានធ្វើវិសោធនកម្មញឹកញាប់ខ្លាំង។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីគឺជាច្បាប់មូលដ្ឋាននៃនីតិឯកជន ហើយមានមូលដ្ឋាននៃគោលគំនិតដើមនៃច្បាប់ពិសេសជាច្រើន។ ហើយមានគោលដៅគ្របដណ្តប់លើ ភាគីជាច្រើនប្រភេទ និង ទម្រង់នៃជំនួញជាច្រើនប្រភេទផងដែរ (នៅក្នុងកិច្ចសន្យាលក់ទិញតែមួយក៏ដោយ ទាំងការទិញទំនិញពីហាងលក់ទំនិញ ទាំងការផ្ទេរឱ្យគ្នានូវរបស់ដែលខ្លួនស្រលាញ់ទៅឱ្យមិត្តភក្តិ សុទ្ធតែស្ថិតនៅក្រោមវិសាលភាពរបស់ក្រមរដ្ឋប្បវេណី)។ យើងក៏ត្រូវពិចារណាអំពីស្ថិរភាពគតិយុត្តផងដែរ។ តើគួរធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី ឬ តើគួរបង្កើតច្បាប់ពិសេសថ្មីដើម្បីដោះស្រាយជាដើម គឺជាបញ្ហាដ៏សំខាន់។

### (3) **ក្នុងនាមជាអ្នកប្រើប្រាស់ច្បាប់**

ជាចុងក្រោយនេះ ខ្ញុំសូមបង្ហាញអំពីសំនួរសំខាន់ដែលត្រូវសួរ នៅពេលពិចារណាអំពីច្បាប់នានា មិនត្រឹមតែក្រមរដ្ឋប្បវេណីនោះទេ។ ទាំងនៅក្នុងការបកស្រាយច្បាប់ និងទាំងនៅក្នុងការតាក់តែងច្បាប់ តើយើងត្រូវគិតថា នៅកន្លែងណាមួយដែលអាចមានច្បាប់ដែលជាចំណុចកំពូលនៃគោលគំនិត លើសពីចំណេះដឹងរបស់មនុស្សយើងគ្រប់គ្នា (ច្បាប់ធម្មជាតិ) ឬ យើងត្រូវគិតថា ច្បាប់ដែលយើងមានសព្វថ្ងៃគឺជារបស់ដែលល្អបំផុត ហើយគួរកែតម្រូវម្តងមួយៗទៅតាមកាលៈទេសៈ។ នេះគឺជាចំណុចមន្ទិលដែលធ្លាប់បានពិភាក្សាយូរមកហើយ។ ប្រសិនបើឈរលើគោលជំហរនៃគំនិតវិទ្យាសាស្ត្រចំពោះការសិក្សាច្បាប់ គេប្រាកដជាបដិសេធអំពីអត្ថិភាពនៃច្បាប់ ឬ របស់ដែលលើសពីចំណេះដឹងរបស់មនុស្ស។ ប៉ុន្តែ យើងនៅតែមានមន្ទិលផងដែរ ចំពោះការយកមុខវិជ្ជាច្បាប់ដែលជាមុខវិជ្ជាពឹងផ្អែក

លើការវាយតម្លៃ ទៅប្រៀបធៀបស្មើគ្នានឹងមុខវិជ្ជាវិទ្យាសាស្ត្រ ដូចជាមុខវិជ្ជាជីវៈវិទ្យា។ ទោះជាយ៉ាងម៉េចក៏ដោយ មនុស្សយើងម្នាក់ៗមិនមែនជាភាវៈដែលល្អឥតខ្ចោះនោះទេ ហើយមនុស្សដែលមិនល្អឥតខ្ចោះបើទោះបីជាប្រឹងប្រែងបញ្ចេញនូវគំនិតល្អយ៉ាងណាក៏ដោយ ក៏ច្បាប់ដែលចេញមកពុំអាចល្អឥតខ្ចោះនោះទេ ហើយអ្នកច្បាប់ទាំងអស់មិនអាចខ្វះបាននូវគោលគំនិតដាក់ខ្លួនបែបនេះនោះទេ។

## IV. **សេចក្តីសន្និដ្ឋាន**

សរុបមក ក្រមរដ្ឋប្បវេណីគឺជាច្បាប់ដែលមានភាពពាក់ព័ន្ធយ៉ាងច្រើនចំពោះទំនាក់ទំនងជីវភាពសង្គមនៅក្នុងមួយដំណើរជីវិតរបស់យើងម្នាក់ៗ និងជាច្បាប់មាន «មុខ» យ៉ាងច្រើនតាំងពីកម្រិតដែលពិចារណាអំពីចំណងនៃឆន្ទៈរបស់បុគ្គលនិងបុគ្គល រហូតដល់កម្រិតដែលពាក់ព័ន្ធការគណនានូវការខូចខាតដែលកើតឡើងពីការធ្វើជំនួញទ្រព្យសម្បត្តិដូចជា ការធានាកាតព្វកិច្ច និង ការធានាដោយវត្ថុជាអាទិ៍។ គ្រាន់តែប៉ុននេះ យើងអាចនិយាយថាច្បាប់នេះគឺពិបាកនឹងសិក្សាខ្លាំង ហើយទូលំទូលាយ និង ជ្រៅជ្រះខ្លាំង។ ប៉ុន្តែ លើកលែងតែបុគ្គលដែលយកការស្រាវជ្រាវក្រមរដ្ឋប្បវេណីជាអាយុជីវិត សូមអ្នកទាំងអស់គ្នាសិក្សាក្រមរដ្ឋប្បវេណីទៅតាមកម្រិតចាំបាច់ និង ចំណង់ចំណូលចិត្តម្នាក់ៗបានហើយ។ នៅក្នុងអត្ថន័យនេះ ក្រមរដ្ឋប្បវេណីជាច្បាប់ធំទូលាយនិង ស៊ីជម្រៅ ប៉ុន្តែដាច់ខាតមិនធ្វើឱ្យយើងពិបាកនឹងផ្សាភ្ជាប់ជាមួយនោះទេ ផ្ទុយមកវិញ ដូចខ្ញុំបានលើកឡើងតាំងពីខាងដើមម្ល៉េះថា វាជាច្បាប់នៅជិតស្និទ្ធនឹងយើងខ្លាំងបំផុតប្រសិនបើយើងមិនច្រឡំពីច្រកចូលទេ។ ក្រមរដ្ឋប្បវេណីហាក់បីដូចជា ហ្គាឡាស៊ីពោរពេញទៅដោយសក្តានុពលដែលត្រូវតែស្រាវជ្រាវឱ្យស៊ីជម្រៅ ទោះបីជាប្រជាពលរដ្ឋក៏ដោយ ឬ និស្សិតត្រៀមប្រឡង និង អ្នកស្រាវជ្រាវច្បាប់ក៏ដោយ។

សៀវភៅនេះត្រូវបានសរសេរឡើងដោយផ្តោតសំខាន់ទៅលើ បុគ្គលដែលមិនធ្លាប់បានសិក្សាក្រមរដ្ឋប្បវេណីទាល់តែសោះ ហើយជាពិសេសបុគ្គលដែលកំពុងតែចាប់ជំនាញ សេដ្ឋកិច្ច ពាណិជ្ជកម្ម ឬ ជំនាញផ្សេងៗទៀតដើម្បីធ្វើយ៉ាងណាបង្ហាញអំពីទិដ្ឋភាពទូទៅ និង របៀបសិក្សាក្រមរដ្ឋប្បវេណីឱ្យមានប្រសិទ្ធិភាពបំផុត ហើយសូមឱ្យសៀវភៅនេះអាចក្លាយជាមគ្គុទេសន៍ដល់ «អ្នកដែលចង់សិក្សាក្រមរដ្ឋប្បវេណី»។ ប៉ុន្តែ ខ្ញុំពិតជាសប្បាយចិត្តណាស់ប្រសិនបើសៀវភៅនេះអាចផ្តល់នូវសារប្រយោជន៍ដល់បុគ្គលគ្រប់រូបទាំងអស់ ដែលបានអានសៀវភៅនេះមកដល់ត្រឹមនេះ រួមទាំងបុគ្គលផ្សេងពីបុគ្គលខាងលើនេះផងដែរ។ ខ្ញុំសូមជូនពរឱ្យការសិក្សារបស់អ្នកទាំងអស់គ្នាកាន់តែមានផ្លែផ្កា ហើយសូមបញ្ចប់សៀវភៅត្រឹមនេះ។